# អដ្ឋកថា ព្រះសុត្តន្តបិដក

## ធម្មបទដ្ឋកថា

## បឋមភាគ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៨

# អដ្ឋកថា ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ គាថាធម្មបទ

ឈ្មោះ

# ធម្មបទដ្ឋកថា

## បឋមភាគ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៨

អធិប្បាយ

គាថាធម្មបទ មាន ៣ វគ្គ

យមកវគ្គ អប្បមាទវគ្គ និងចិត្តវគ្គ

# គាថាធម្មបទ

## បឋមភាគ រួមមាន ៣ វគ្គ

### **១-យមកវគ្គ** មាន ១៤ រឿង

១.រឿងព្រះចក្ខុបាលត្ថេរ:
២.រឿងមដ្ឋកុណ្ឌលី
៣.រឿងព្រះតិស្សត្ថេរ:
៤.រឿងនាងកាឡីយក្ខិណី
៥.ភិក្ខុអ្នកក្រុងកោសម្ពី
៦.ចុល្លកាល និងមហាកាល
៧.រឿងព្រះទេវទត្ត
៨.រឿងសញ្ជ័យ
៩.រឿងព្រះនន្ទត្ថេរ:
១០.រឿងនាយចុន្ទសូករិក:
១១.រឿងធម្មិកឧបាសក
១២.រឿងព្រះទេវទត្ត
១៣.រឿងនាងសុមនាទេវី
១៤.រឿងភិក្ខុ ២ រូបសម្លាញ់គ្នា

### **២-អប្បមាទវគ្គ** មាន ៩ រឿង

១.រឿងព្រះនាងសាមាវតី
២.កុម្ភឃោសក:
៣.រឿងព្រះចូឡបន្ថក:
៤.រឿងពាលនក្ខត្តឫក្ស
៥.រឿងព្រះមហាកស្សប:
៦.ភិក្ខុ ២ រូប ជាសឡាញ់នឹងគ្នា
៧.រឿងសក្កទេវរាជ
៨.រឿងភិក្ខុមួយរូប
៩.រឿងព្រះតិស្ស:មានប្រក្រតីនៅក្នុងនិគម

### **៣-ចិត្តវគ្គ** មាន ៩ រឿង

១.រឿងព្រះមេឃយ:
២.រឿងភិក្ខុមួយរូប
៣.រឿងឧក្កណ្ឋិតភិក្ខុ
៤.រឿងព្រះភាគិនេយ្យសង្ឃរក្ខិត:
៥.រឿងព្រះចិត្តហត្ថត្ថេរ:
៦.ភិក្ខុអ្នកប្រារព្វវិបស្សនា
៧.រឿងព្រះបូតិគត្តតិស្ស:
៨.ឆន្នគោបាលក:
៩.រឿងព្រះសោរេយ្យត្ថេរ:

# ស្រៈនិងសៀ៍យ

# *Signes et accents:*



# ស្រះពេញតួ

# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សង្ហ<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូប<br>Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម<br>Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ<br>Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| លង្កា<br>Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា<br>Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| រ៉ូម Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ᨸ | ᨹ | ᨻ | ᨽ | ᨾ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/· |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី

វិកកាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យតាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងមានឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរ ក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមកមាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-

បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹង

ជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

## និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមាន-ព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់ វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះចៅសុសុនាគៈធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណៈគ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងវាងនិកាយពហុលិយៈនោះៗ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

ជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តា អាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញ មកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយ-វាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញ ពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយ បែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទ ក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែក ចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយ នេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយ អាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយនោះ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់ និកាយ ដែលពោលមកហើយនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

(ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតអស់

ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍ កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថាឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថា ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុង

ជម្ពូទ្វីប មានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ព្រោះព្រះថេរៈទាំងឡាយមានព្រះសារីបុត្ត ( ឈ្មោះដូចអគ្គសាវក ) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅ រហូតដល់កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាម ដទៃទៀតថា (សិរិនិវាស) ខ្វះ (សិរិកុដៈ) ខ្វះ (សិរិកូដ្ឋៈ) ខ្វះ ក្នុងពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កាដែលមានព្រះសង្ឃបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរហួតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាច យ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរកោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជា

ព្រះមេត្តេយ្យពោធិសត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោស: និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនាព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ: ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធាន

ហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស
លោកគ្រូធម្មបណ្ឌិត រស់ សុជាត
លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក នាក់ ម៉ៅ |
| ឧបាសក ឌុំ ទួន | ឧបាសក ហុក សីងហួត |
| ឧបាសក ជីម ជំនិត | ឧបាសក កើត និត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ុម វ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត |
| ឧបាសក សោម រតនៈ | ឧបាសក សំ ឆាយ |
| ឧបាសក ម៉ៅ ឆុន | ឧបាសក ជា ស៊ីថាន |
| ឧបាសិកា ថាប់ លឿម | ឧបាសិកា ហាយ សារ៉ាត់ |
| ឧបាសិកា ប៊ុត សុម៉ាលី | ឧបាសិកា យស សម្បត្តិ |
| ឧបាសិកា ពូ ហ៊ាង | ឧបាសិកា ប៊ុត សេដាដួង |
| ឧបាសិកា ប៉ែន រមណី | |

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៊ូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មបញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀតសមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី
បូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ
និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ៖-

ឧទ្ទិសថ្វាយ និងគោរពជូន :

-ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

ពាក្យប្រារព្ធ ១

**យមកវគ្គទី ១**

១-រឿងព្រះចក្ខុបាលត្ថេរៈ ៤
-កុដុម្ពីក៍ធ្វើពិធីសូមបុត្រ ៥
-ព្រះសាស្តាប្រថាប់នៅក្នុងក្រុងសាវត្ថី ២៥ វស្សា ៦
-ធុរៈ២យ៉ាងក្នុងព្រះសាសនា ១៣
-ព្រះមហាបាលសមាទានធេសជ្ជិកធុតង្គ ១៦
-ព្រះមហាបាលប្រឹក្សាជាមួយករជ្ជកាយ ១៩
-ពួកភិក្ខុនៅគាល់ព្រះសាស្តា ២៤
-សាមណេរដល់នូវសីលវិបត្តិព្រោះសំឡេងស្ត្រី ២៩
-អាសនៈព្រះឥន្ទក្តៅ ៣២
-បុព្វកម្មរបស់ព្រះចក្ខុបាល ៣៩
-អធិប្បាយគាថា ៤២

២-រឿងមដ្ឋកុណ្ឌលី ៤៩
-ព្រះសម្ពុទ្ធឃើញឧបនិស្ស័យរបស់មដ្ឋកុណ្ឌលី ៥១
-ព្រាហ្មណ៍ថ្វាយទានដល់ព្រះពុទ្ធ ៦៤
-ចិត្តជាធំក្នុងកម្មគ្រប់យ៉ាង ៦៧
-អធិប្បាយគាថា ៦៩

៣-រឿងព្រះតិស្សត្ថេរៈ ៧៤
-បុព្វកម្មរបស់ព្រះតិស្សត្ថេរៈ ៧៨

-ពៀរមិនរម្ងាប់ដោយពៀរ ៨៦

-អធិប្បាយគាថា ៨៨

៤-រឿងនាងកាឡីយក្ខិនី ៩១

-ព្រាត់គ្នាស្វែងរគ្នាព្រោះពៀរតែមួយជាតិ ៩៥

-ពៀរមិនរម្ងាប់ដោយពៀរ តែរម្ងាប់ដោយការមិនចងពៀរ ៩៨

-អធិប្បាយគាថា ១០០

៥-រឿងភិក្ខុក្រុងកោសម្ពី ១០៦

-ព្រះសាស្តាត្រាស់ទូន្មានឱ្យសាមគ្គី ១០៨

-ដំរីចារិលេយ្យកៈឧបដ្ឋាកព្រះសាស្តា ១១៥

-ភិក្ខុក្រុងកោសម្ពីទូលសូមខមាទោសព្រះសាស្តា ១២៥

-អធិប្បាយគាថា ១២៨

៦-រឿងចុល្លកាល និងមហាកាល ១៣១

-អធិប្បាយគាថា ១៤៤

៧-រឿងព្រះទេវទត្ត ១៥០

-កាលមុនព្រះទេវទត្តជាព្រានដំរី ១៥៤

-អធិប្បាយគាថា ១៥៩

៨-រឿងសញ្ជ័យ ១៦២

-ព្រះសាស្តាទ្រង់បញ្ជូនសាវកទៅប្រកាសព្រះសាសនា ១៧០

-ប្រវត្តិព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន ១៧២

-ព្រះអស្សជិសម្ដែងបេះដូងព្រះសាសនា ១៧៤

-សម្លាញ់ពីរនាក់សម្រេចព្រះសោតា ១៧៩

-ពួកភិក្ខុតិះដៀលព្រះសាស្តា ១៨៦

-បុព្វកម្មរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ១៨៧

-បុព្វកម្មរបស់ជន ៥៥ នាក់មានយសកុលបុត្រជាដើម ១៩១

-បុព្វកម្មរបស់ភទ្ទវគ្គីយ៍ ៣០ នាក់ ១៩២

-បុព្វកម្មរបស់ជដិល ៣ នាក់ បងប្អូន ១៩៣

-បរិភោគអាហារដែលគេឧទ្ទិសចំពោះសង្ឃស្លាប់ទៅ... ១៩៧

-បុព្វកម្មរបស់អគ្គសាវកទាំងពីររូប ២០២

-អធិប្បាយគាថា ២១៩

៩–រឿងព្រះនន្ទត្ថេរ: ២២២

-រាហុលកុមារទូលសូមសម្បត្តិពីព្រះសាស្ដា ២២៥

-ព្រះនន្ទបំណងចង់សឹក ២២៨

-អធិប្បាយគាថា ២៣៦

-បុព្វកម្មរបស់ព្រះនន្ទ ២៣៨

១០–រឿងនាយចុន្ទសូករិក: ២៤៤

-អធិប្បាយគាថា ១៤៩

១១–រឿងធម្មិកឧបាសក ២៥១

-អធិប្បាយគាថា ២៥៨

១២–រឿងព្រះទេវទត្ត ២៥៩

-ព្រះទេវទត្តព្យាយាមសម្លាប់ព្រះពុទ្ធ ២៧០

-បុព្វកម្មព្រះទេវទត្ត ២៧៧

-ព្រះទេវទត្តឱ្យសាវកនាំទៅគាល់ព្រះសាស្ដា ២៨២

-អធិប្បាយគាថា ២៩០

១៣–រឿងនាងសុមនាទេវី ២៩២

-អធិប្បាយគាថា ២៩៧

១៤–រឿងភិក្ខុជាសំឡាញ់ពីររូប ២៩៩

-អធិប្បាយគាថា ៣០៦

## អប្បមាទវគ្គទី ២

១-រឿងព្រះនាងសាមាវតី ៣១០
-ប្រវត្តិព្រះបាទឧទេន ៣១០
-ព្រះបាទឧទេន និងបក្សីហត្ថីលិង្គ ៣១៥
-ប្រវត្តិឃោសកៈសេដ្ឋី ៣២៥
-សុនខទៅកើតជាឃោសកទេវបុត្រ ៣៣២
-ឃោសកទារកត្រូវចោះបង់ចោល ៣៣៥
-ឲ្យឧក្ខដល់គេ ឧក្ខនោះត្រឡប់មករកខ្លួនវិញ ៣៤១
-ឧបាយថ្មីរបស់សេដ្ឋី ៣៤៦
-ព្រះបាទឧទេនប្រទានដំណែងសេដ្ឋីដល់... ៣៥៧
-ប្រវត្តិរបស់ព្រះនាងសាមាវតី ៣៦២
-ប្រវត្តិរបស់ព្រះនាងវាសុលទត្តា ៣៧២
-ប្រវត្តិរបស់ព្រះនាងមាគន្ទិយា ៣៨៧
-សេដ្ឋី ៣ នាក់ និងតាបស ៣៩៥
-ព្រះនាងសាមាវតីត្រូវភ្លើងឆេះ ៤២៦
-បុព្វកម្មព្រះនាងសាមាវតី និងបរិវារ ៤៣២
-បុព្វកម្មរបស់នាងខុជ្ជុត្តរា ៤៣៤
-ព្រះសាស្តាយាងសម្តែងធម៌ត្រង់ធម្មសភា ៤៣៧
-អធិប្បាយគាថា ៤៣៩
២-រឿងកុម្ភឃោសកៈ ៤៤៧
-អធិប្បាយគាថា ៤៦២
៣-រឿងព្រះចូឡបន្ថកៈ ៤៦៤
-បុព្វកម្មរបស់ព្រះចូឡបន្ថកៈ ៤៧១

-អធិប្បាយគាថា ៤៩០

៤-រឿងពាលនក្ខត្តឫក្ស ៤៩២

-អធិប្បាយគាថា ៤៩៤

៥-រឿងព្រះមហាកស្សបត្ថេរ: ៤៩៧

-អធិប្បាយគាថា ៤៩៩

៦-រឿងភិក្ខុជាសទ្ធាញ់ពីររូប ៥០១

-អធិប្បាយគាថា ៥០៤

៧-រឿងសក្កទេវរាជ ៥០៧

-មឃមាណពបំពេញវត្តបទ ៧ ប្រការ ៥២០

-នាងសុជាតាធីតារបស់អាសុរ ៥៣២

-អធិប្បាយគាថា ៥៣៦

៨-រឿងភិក្ខុមួយរូប ៥៣៨

-អធិប្បាយគាថា ៥៣៩

៩-រឿងព្រះតិស្សត្ថេរ:មានប្រក្រតីនៅក្នុងនិគម ៥៤២

-អធិប្បាយគាថា ៥៤៦

## ចិត្តវគ្គទី ៣

១-រឿងព្រះមេឃិយត្ថេរ: ៥៤៨

-អធិប្បាយគាថា ៥៥០

២-រឿងភិក្ខុមួយរូប ៥៥៤

-អធិប្បាយគាថា ៥៦៦

-ភិក្ខុនោះត្រឡប់នៅកាន់មាតិកគ្រាមម្តងទៀត ៥៦៨

៣-រឿងឧក្កណ្ឋិតភិក្ខុ ៥៧២

-អធិប្បាយគាថា ៥៧៧

៤-រឿងព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ ៥៧៩

-អធិប្បាយគាថា ៥៨៥

៥-រឿងព្រះចិត្តហត្ថត្ថេរៈ ៥៨៧

-អធិប្បាយគាថា ៥៩២

៦-រឿងព្រះភិក្ខុច្រាវពួវិបស្សនា ៦០១

-អធិប្បាយគាថា ៦០៧

៧-រឿងព្រះបូតិគត្តតិស្សត្ថេរៈ ៦១១

-អធិប្បាយគាថា ៦១៤

៨-រឿងនន្ទគោបាលកៈ ៦១៩

-អធិប្បាយគាថា ៦២១

៩-រឿងព្រះសោរេយ្យត្ថេរៈ ៦២៤

-បុរសអាចក្លាយជាស្ត្រី ស្ត្រីអាចក្លាយជា... ៦២៦

-អធិប្បាយគាថា ៦៣៦

# ធម្មបទដ្ឋកថា

## បឋមភាគ

## យមកវគ្គទី ១

សូមនមស្ការព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ

ព្រះកុមារកស្សបត្ថេរ[១] អ្នកហ្វឹកហាត់ខ្លួនល្អហើយ ប្រព្រឹត្តរៀបរយដោយប្រក្រតី មានចិត្តតាំងមាំ ប្រាថ្នាការតាំងនៅនៃព្រះសទ្ធម្ម ប្រាថ្នាហើយថា ព្រះសាស្តាទ្រង់ឆ្លាតក្នុងធម៌ និងមិនមែនធម៌ ទ្រង់មានបទ គឺ ព្រះសទ្ធម្មដល់ព្រមហើយ ព្រះអង្គមានហឫទ័យពោរពេញទៅដោយព្រះករុណា ឲ្យឧស្សាហៈដោយល្អហើយ ទ្រង់បានអាស្រ័យហេតុនោះៗ សំដែងធម្មបទណាដ៏ប្រសើរ ដែលជាគ្រឿងចម្រើនបីតិបាមោជ្ជៈ របស់ទេវតា និងមនុស្ស

---

១ ជាឈ្មោះរបស់ព្រះសង្ឃត្ថេរមួយអង្គក្នុងសម័យព្រះពុទ្ធឃោសាចារ្យ មិនមែនជាព្រះកុមារកស្សបៈក្នុងសម័យពុទ្ធកាលទេ។

ទាំងឡាយ ការពណ៌នាអត្ថនៃធម្មបទនោះដែលនាំតៗ គ្នាមក ជាពាក្យដែលល្អិតសុខុម តាំងនៅដោយភាសារបស់អ្នកកោះក្នុងតម្ពបណ្ណិ[១] រមែងមិនឲ្យសម្រេចការដល់ព្រមនៃប្រយោជន៍ដល់សត្វទាំងឡាយដ៏សេសបាន យ៉ាងណា ការពណ៌នាសេចក្តីនៃធម្មបទនោះ នឹងគប្បីឲ្យសម្រេចនូវប្រយោជន៍ដល់មនុស្សលោកទាំងពួងបាន ។

ខ្ញុំដែលព្រះថេរៈនោះ អារាធនាដោយគោរពហើយ ទើបនមស្ការព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រទ្រង់នូវសិរី ទ្រង់ទតឃើញទីបំផុតលោកបាន ទ្រង់មានឫទ្ធិដ៏រុងរឿង កាលមនុស្សលោកត្រូវសេចក្តីងងឹត គឺ មោហៈគ្របសង្កត់ ទ្រង់ញុំាងប្រទីប គឺ ព្រះសទ្ធម្មឲ្យរុងរឿង ខ្ញុំសូមបូជាព្រះសទ្ធម្មនៃព្រះសម្ពុទ្ធអង្គនោះ និងធ្វើអញ្ជលីដល់ព្រះសង្ឃនៃព្រះពុទ្ធអង្គនោះ ហើយទើបវៀរភាសា

១ កោះជាទីនៅរបស់ពួកជនអ្នកមានចាតដៃក្រហម គឺ កោះលង្កា ។

នោះ និងលំដាប់នៃពាក្យពេជន៍ដែលពិស្តារពេក ហើយលើកឡើងកាន់ភាសាបែបផែន (ភាសាបាលី) ដែលជាទីរីករាយនៃចិត្ត ហើយពោលអដ្ឋកថានៃធម្មបទនោះដោយខ្លឹមសារមិនសេសសល់ដោយភាសាដទៃ ធ្វើបទព្យញ្ជនៈនៃគាថាទាំងឡាយក្នុងធម្មបទនោះ ដែលនៅមិនទាន់ជាក់ច្បាស់ឲ្យជាក់ច្បាស់ នាំមកនៅបីតិបាមោជ្ជៈនៃចិត្ត ដែលអាស្រ័យអត្ថ និងធម៌ដល់អ្នកប្រាជ្ញទាំងឡាយ ។

# យមកវគ្គ ទី ១

## ១ រឿងព្រះចក្ខុចាលថេរ

[១១] *មានបុច្ឆាថា ព្រះធម្មទេសនានេះថា ៖*

*មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា*
*មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា*
*តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។*

*ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។*

*ដូច្នេះ ព្រះសាស្តាត្រាស់ហើយ នៅក្នុងកន្លែងណា ។*

*វិសជ្ជនាថា ព្រះអង្គត្រាស់ហើយនៅក្នុងក្រុងសាវត្ថី ។*

មានបុច្ឆា *(ជាលំដាប់) ថា ព្រះអង្គទ្រង់ប្រារព្ធនរណា ។*

## វិសជ្ជនាថា ព្រះអង្គទ្រង់ប្រារព្ធព្រះចក្ខុបាលត្ថេរ ។

### កុដុម្ពិកធ្វើពិធីសូមបុត្រ

ដូចបានស្តាប់មក ក្នុងក្រុងសាវត្ថី មានសេដ្ឋីឈ្មោះមហាសុវណ្ណ ជាកុដុម្ពិកស្តុកស្តម មានទ្រព្យច្រើន មានសម្បត្តិច្រើន (តែ) មិនមានបុត្រ ។ ថ្ងៃមួយចូលទៅកាន់កំពង់ទឹក ងូតស្រេចហើយក៏ត្រឡប់មកវិញ ឃើញដើមឈើធំដែលជាមេឈើមួយដើម មានមែកបរិបូណ៌ក្នុងចន្លោះផ្លូវ គិតថា ដើមឈើនេះនឹងមានទេវតា ដែលមានសក្តិធំស្ថិតនៅ ។ ដូច្នេះហើយ ទើបឲ្យសម្អាតខាងក្រោមដើមឈើនោះឲ្យស្អាត ឲ្យព័ទ្ធរបង រោយខ្សាច់ឲ្យស្មើ លើកទង់ជ័យ និងទង់បដាសំពត់ឡើង តាក់តែងដើមឈើជាមេព្រៃនោះហើយ ធ្វើសេចក្តីប្រាថ្នា (គឺបន់) ថា ខ្ញុំបានបុត្រ ឬធិតាហើយ និងធ្វើសក្ការៈធំចំពោះលោក ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ក្នុងកាលជាលំដាប់មក ភរិយារបស់សេដ្ឋីក៏តាំងគភ៌ ។ លោកក៏ឲ្យពិធីរក្សាគភ៌[1] ដល់នាង ។ លុះកន្លងទៅ ១០ ខែ នាងប្រសូត្របុត្រ

---

១ ជាពិធីមួយក្នុងសាសនាព្រាហ្មណ៍ គេធ្វើ ២ ដង គឺ ធ្វើកាលភរិយាតាំងគភ៌បាន ៥ ខែម្តង ហៅថា បំចាម្រឹតមៈ ធ្វើពេលតាំងគភ៌បាន ៧ ខែម្តង ហៅថា សត្តាម្រឹតមៈ។

មួយរូប លោកសេដ្ឋីដាក់ឈ្មោះបុត្រនោះថា **បាលៈ** ព្រោះហេតុទារកនោះខ្លួនអាស្រ័យដើមឈើធំដែលជាមេព្រៃដែលខ្លួនអភិបាល ទើបបាន ។ ក្នុងកាលតមក លោកសេដ្ឋីក៏បានបុត្រមួយរូបទៀត ដាក់ឈ្មោះបុត្រនោះថា **ចុល្លបាល** ដាក់ឈ្មោះបុត្រជំបូងថា **មហាបាលៈ** កាលកុមារទាំង ២ នោះចម្រើនវ័យឡើង មាតាបិតាក៏គិតចងចំណងដោយគ្រឿងចង គឺ ការគ្រប់គ្រងគេហដ្ឋាន ។ ក្នុងកាលតមក មាតាបិតាបានធ្វើកាលកិរិយាស្លាប់ទៅ ។ វង្សញាតិក៏បើកសម្បត្តិទាំងអស់ប្រគល់ឲ្យដល់បុត្រសេដ្ឋីទាំងពីរ ។

## ព្រះសាស្ដាប្រថាប់នៅក្នុងក្រុងសាវត្ថី ២៥ វស្សា

ក្នុងសម័យនោះ ព្រះសាស្ដាប្រកាសព្រះធម្មចក្កឲ្យប្រព្រឹត្តទៅហើយ ស្ដេចយាងទៅដោយលំដាប់ ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ដែលអនាថបិណ្ឌិកសេដ្ឋីបរិច្ចាគទ្រព្យចំនួន ៥៤ កោដិ សាងថ្វាយ ទ្រង់ទូន្មានមហាជនឲ្យតាំងនៅក្នុងផ្លូវសួគ៌ និងផ្លូវនិព្វាន ។ ពិតហើយ ព្រះសាស្ដាស្ដេចគង់ចាំវស្សាតែម្ដងប៉ុណ្ណោះនៅនិគ្រោធមហាវិហារ ដែលព្រះញាតិ-វង្ស ខាងព្រះជននី ៨ ម៉ឺនត្រកូល ខាងព្រះជនក ៨ ម៉ឺនត្រកូល រួមគ្នាជា

មួយសែនប្រាំមួយម៉ឺនត្រកូល សាងថ្វាយ , ព្រះអង្គស្ដេចគង់ចាំវស្សានៅក្នុងជេតពនមហាវិហារ ដែលអនាថបិណ្ឌិសេដ្ឋីសាងថ្វាយ ១៩ វស្សា , ស្ដេចគង់ចាំវស្សានៅក្នុងបុព្វារាម ដែលនាងវិសាខាមហាឧបាសិកាបរិច្ចាគទ្រព្យចំនួន ២៧ កោដិ សាងថ្វាយ ៦ វស្សា ។ ទ្រង់អាស្រ័យត្រកូលទាំងពីរដែលជាអ្នកធំដោយគុណធម៌ ស្ដេចគង់ចាំវស្សានៅក្នុងក្រុងសាវត្ថី (ជាគោចរគ្រាម) បាន ២៥ វស្សា ដោយប្រការដូច្នេះ ។ ទាំងលោកអនាថបិណ្ឌិកសេដ្ឋី ទាំងនាងវិសាខាមហាឧបាសិកា រមែងចូលទៅកាន់ទីដើម្បីឧបដ្ឋាកព្រះតថាគតក្នុងមួយថ្ងៃ ២ ដង ជាប្រចាំ ។ ម្យ៉ាងទៀត កាលទៅមិនធ្លាប់មានដៃទទេទៅទេ ដោយគិតថា ក្រែងភិក្ខុកំលោះ និងសាមណេរឃើញដៃរបស់យើងដូច្នេះ កាលទៅមុនវេលាឆាន់អាហារ រមែងប្រើឲ្យមនុស្សកាន់របស់ទំពារជាដើមទៅ កាលទៅខាងក្រោយវេលាឆាន់អាហារប្រើឲ្យមនុស្សកាន់បញ្ចភេសជ្ជៈ(១) និងអដ្ឋបាន(២) ទៅ ។ មួយទៀត ក្នុងគេហដ្ឋាននៃលោកទាំងពីរនោះ គេរៀបចំអាសនៈទុកដើម្បីភិក្ខុមួយកន្លែង

---

(១) ភេសជ្ជៈ ៥ គឺ ទឹកដោះថ្លា.១ ទឹកដោះខាប់.២ ប្រេង.៣ ទឹកឃ្មុំ.៤ ទឹកអំពៅ.៥ ។
(២) អដ្ឋបានៈ ៨ គឺ ១.ទឹកស្វាយ ២.ទឹកព្រីង ៣.ទឹកចេកមានគ្រាប់ ៤.ទឹកចេកមិនមានគ្រាប់ ៥.ទឹកស្រគំ ៦.ទឹកចន្ទ ឬទឹកទំពាំងបាយជូរ ៧.ទឹកក្រអៅឈូក ៨. ទឹកម៉ាក់ប្រ៉ាង ។

២ ពាន់អង្គជាប្រចាំ ។ ភិក្ខុអង្គណា ប្រាថ្នាវត្ថុណា នឹងជាបាយ ទឹក ឬ ភេសជ្ជៈ វត្ថុនោះក៏សម្រេចដល់ភិក្ខុអង្គនោះសមតាមប្រាថ្នា ។ លោកទាំងពីរនោះ អនាថបិណ្ឌិកសេដ្ឋី មិនធ្លាប់ទូលសួរបញ្ហាចំពោះព្រះសាស្ដាសូម្បីតែមួយដង ។ បានឮថា លោកគិតថា ព្រះតថាគតជាព្រះពុទ្ធ ទ្រង់ល្អិតល្អន់ ជាក្សត្រិយ៍ល្អិតល្អន់ កាលទ្រង់សំដែងធម៌ដល់យើង ដោយទ្រង់មានព្រះតម្រិះថា គហបតីមានឧបការៈដល់តថាគតច្រើន ដូច្នេះ ទ្រង់នឹងលំបាក ទើបមិនទូលសួរបញ្ហាដោយសេចក្ដីស្រឡាញ់ក្នុងព្រះសាស្ដា ដោយសេចក្ដីស្រឡាញ់ដ៏ក្រៃលែង ។ ឯព្រះសាស្ដា ពេលសេដ្ឋីអង្គុយហើយ ទ្រង់មានព្រះពុទ្ធតម្រិះថា សេដ្ឋីម្នាក់នេះរក្សាតថាគត ក្នុងទីមិនគួររក្សា ហេតុថា តថាគតបានកាត់សីសៈរបស់តថាគត ដែលប្រដាប់ហើយ ខ្វេះគ្រាប់ភ្នែករបស់តថាគតចេញហើយ ចៀរសាច់បេះដូងរបស់តថាគតហើយ លះបង់កូនប្រពន្ធ ដែលជាទីស្រឡាញ់ស្មើដោយជីវិត របស់តថាគតហើយ បំពេញបារមី ៤ អសង្ខេយ្យមួយសែនកប្ប ក៏បំពេញហើយដើម្បីសំដែងធម៌ដល់អ្នកដទៃប៉ុណ្ណោះ សេដ្ឋីនេះរក្សាតថាគតក្នុងទីមិនគួររក្សា (លុះទ្រង់

ព្រះពុទ្ធតម្រិះ) ដូច្នេះហើយ ក៏ត្រាស់ព្រះធម្មទេសនាកណ្ឌទីមួយ ។ គ្រានោះ ក្នុងក្រុងសាវត្ថីមានមនុស្សនៅ ៧ កោដិ[១] (៧០ លាននាក់) ។ ក្នុងមនុស្សទាំងនោះ អ្នកបានស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ បានជាអរិយសាវកប្រមាណ ៥ កោដិ នៅជាបុថុជ្ជនប្រមាណ ២ កោដិ ។ ក្នុងមនុស្សទាំងនោះ កិច្ចរបស់ព្រះអរិយសាវកមានត្រឹមតែ ២ យ៉ាងប៉ុណ្ណោះ គឺ ក្នុងពេលមុនឆាន់អាហារ លោកថ្វាយទាន ខាងក្រោយការឆាន់អាហារហើយ លោកកាន់គ្រឿងសក្ការៈបូជា មានរបស់ក្រអូប និងបាច់ផ្កាជាដើម ប្រើមនុស្សឲ្យកាន់ទេយ្យធម៌ មានសំពត់ ភេសជ្ជៈ និងទឹកបានៈជាដើម ទៅដើម្បីស្តាប់ធម៌ ។

ក្រោយមកថ្ងៃមួយ កុដុម្ពិកមហាបាលៈឃើញពួកអរិយសាវកកាន់គ្រឿងសក្ការៈបូជា មានរបស់ក្រអូប និងបាច់ផ្កាជាដើមទៅកាន់វិហារ ទើបសួរថា មហាជនទាំងនេះនាំគ្នាទៅណា កាលបានឮថា ទៅស្តាប់ធម៌ ក៏គិតថា យើងនឹងទៅដែរ កាលទៅដល់ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយនៅ

---

១.ក្នុងក្រុងសាវត្ថីមិនប្រាជកថា ធំរហូតដាក់មនុស្សបាន ៧០ លាននាក់ ព្រោះដូច្នោះ គួរតែជាអនេកសង្ខ្យា ។

ខាងក្រោយបរិស័ទ ។

ធម្មតាព្រះពុទ្ធទាំងឡាយ កាលទ្រង់សំដែងធម៌ ទ្រង់ទតមើលនូវឧបនិស្ស័យនៃគុណ មានសរណៈ សីល និងបព្វជាជាដើម (ជាមុន) ទើបទ្រង់សំដែងធម៌តាមអធ្យាស្រ័យ ។ ព្រោះដូច្នោះ ថ្ងៃនោះព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់កុដុម្ពិកមហាបាលៈ កាលទ្រង់សំដែងធម៌ បានត្រាស់អនុបុព្វិកថា គឺ ទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោស សេចក្តីអាក្រក់ និងសេចក្តីសៅហ្មងនៃកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ (គឺ ការចេញចាកកាមទាំងឡាយ) ។ កុដុម្ពិកមហាបាលៈ បានស្តាប់ធម៌នោះហើយ គិតថា បុត្រ និងធិតាក្តី ភោគសម្បត្តិក្តី រមែងទៅតាមអ្នកទៅកាន់បរលោកមិនបាន សូម្បីសរីរៈក៏ទៅតាមខ្លួនមិនបាន ប្រយោជន៍អ្វីដែលយើងគ្រប់គ្រងផ្ទះ យើងនឹងបួស ពេលធម្មទេសនាចប់ គេក៏ចូលទៅគាល់ព្រះសាស្តា ទូលសូមបួស ។ ខណៈនោះ ព្រះសាស្តាត្រាស់សួរគេថា ញាតិណាៗ របស់អ្នក ដែលនឹងត្រូវលាមិនមានទេឬ?

គេទូលថា បពិត្រព្រះអង្គ ប្អូនប្រុសរបស់ខ្ញុំព្រះអង្គ មាន ។

ព្រះសាស្ដាត្រាស់ថា បើដូច្នោះ អ្នកចូរទៅលាគេ (ជាមុន) ។ គេទូលទទួលថា ករុណាព្រះអង្គ ហើយថ្វាយបង្គំលាព្រះសាស្ដា ទៅដល់ផ្ទះឲ្យហៅប្អូនប្រុសមក ប្រគល់ទ្រព្យសម្បត្តិឲ្យថា នែប្អូន ទ្រព្យដែលមានវិញ្ញាណក្តី ទ្រព្យដែលមិនមានវិញ្ញាណក្តី ឯណាមួយ ដែលមាននៅក្នុងត្រកូលនេះ ទ្រព្យនោះចូរជាការៈរបស់ឯងទាំងអស់ ឯងចូរថែរក្សាទ្រព្យនោះចុះ ។

ប្អូនប្រុសសួរថា បង ទៅណា?

បងប្រុសឆ្លើយថា បងនឹងបួសក្នុងសំណាក់ព្រះសាស្ដា ។

ប្អូននិយាយថា បងនិយាយអ្វី កាលមាតារបស់យើងស្លាប់ហើយ ប្អូនបានបងដូចជាមាតា កាលបិតាស្លាប់ហើយ បានបងដូចជាបិតា សម្បត្តិដ៏ច្រើនមាននៅក្នុងផ្ទះរបស់យើង យើងនៅគ្រប់គ្រងផ្ទះនោះហើយអាចធ្វើបុណ្យបាន សូមបងកុំធ្វើយ៉ាងនោះឡើយ ។

បងពោលថា បងបានស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ព្រោះ (ហេតុដែល) ព្រះសាស្ដាទ្រង់សំដែងធម៌មានគុណពីរោះ ទាំងក្នុងបទដើម

បទកណ្តាល បទចុង លើកឡើងកាន់ត្រៃលក្ខណៈ[1] ដ៏ល្អិតសុខុម ធម៌នោះ នរណាៗ មិនអាចនឹងបំពេញឲ្យបរិបូណ៌ក្នុងកណ្តាលផ្ទះបាន បងនឹងទៅបួសហើយ ។

ប្អូនអង្វរថា បង តែឥឡូវនេះបងនៅកំលោះ ចាំចាស់សិនសឹមបងទៅបួសចុះ ។

បងពោលទៀតថា ប្អូនអើយ មនុស្សចាស់ សូម្បីដៃ និងជើងរបស់ខ្លួននៅតែមិនស្តាប់ មិនប្រព្រឹត្តទៅក្នុងអំណាច ចាំបាច់ពោលថ្វីដល់ញាតិទាំងឡាយ បងមិនអាចធ្វើតាមពាក្យរបស់ប្អូនឡើយ បងនឹងបំពេញសមណបដិបត្តិឲ្យបរិបូណ៌ ។

ដៃនិងជើងរបស់អ្នកណា ទ្រុឌទ្រោមទៅព្រោះជរា
ថាមិនស្តាប់ អ្នកនោះមានកម្លាំងដែលជរាកម្ចាត់ចេញ
ហើយ និងប្រព្រឹត្តធម៌បានដូចម្តេច?

បងនឹងចេញបួសហើយ ។

---

១.ត្រៃលក្ខណៈ គឺ អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ ។

## ធុរៈ ២ យ៉ាងក្នុងព្រះសាសនា

កាលប្អូនប្រុសកំពុងឃាំមិនឲ្យទៅ គេក៏ទៅកាន់សម្នាក់របស់ព្រះ-សាស្តា ទូលសូមបួស និងបានបព្វជាឧបសម្បទាហើយនៅក្នុងសំណាក់នៃព្រះអាចារ្យ និងឧបជ្ឈាយ៍គ្រប់ ៥ វស្សា[១] ចេញវស្សាបវារណាហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទូលសួរថា បពិត្រព្រះអង្គ ក្នុងព្រះសាសនានេះ មានធុរៈប៉ុន្មានយ៉ាង?

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ធុរៈមាន ២ យ៉ាងប៉ុណ្ណោះ គឺ គន្ថធុរៈ និងវិបស្សនាធុរៈ ។

ព្រះមហាបាលៈទូលសួរថា បពិត្រព្រះអង្គ គន្ថធុរៈដូចម្តេច វិប-ស្សនាធុរៈដូចម្តេច ព្រះអង្គ?

ព្រះ. ម្នាលភិក្ខុ ធុរៈនេះ ការរៀននិកាយមួយក្តី និកាយពីរក្តី ចប់ពុទ្ធវចនៈ គឺ ព្រះត្រៃបិដកក្តី តាមសមគួរដល់បញ្ញារបស់ខ្លួន ហើយទ្រទ្រង់ចាំ ពោលប្រាប់ពុទ្ធវចនៈនោះ ឈ្មោះថា គន្ថធុរៈ ។ ចំណែកការ

---

១. បើស្តាប់តាមនេះ ព្រះមហាបាលៈបព្វជាឧបសម្បទដោយញត្តិចតុត្ថកម្មវាចា មិនមែនជាឯហិភិក្ខុឧបសម្បទាទេ ។

ផ្តើមតាំងការអស់ទៅ និងការសូន្យទៅទុកក្នុងអត្តភាព ញុំាងវិបស្សនាឲ្យចម្រើនដោយអំណាចនៃការធ្វើជាប់តគ្នា ហើយកាន់យកព្រះអរហត្ត របស់ភិក្ខុអ្នកមានការប្រព្រឹត្តស្រាល⁽¹⁾ ត្រេកអរតែក្នុងសេនាសនៈដ៏ស្ងាត់ ឈ្មោះថា វិបស្សនាធុរៈ ។

មហាបាលៈ. បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបួសហើយពេលចាស់ មិនអាចនឹងបំពេញគន្ថធុរៈឲ្យបរិបូណ៌បាន តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូណ៌បាន សូមព្រះអង្គត្រាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំព្រះអង្គផងចុះ ។ លំដាប់នោះ ព្រះសាស្តាបានត្រាស់ប្រាប់កម្មដ្ឋានរហូតដល់ព្រះអរហត្ត ដល់ព្រះមហាបាលៈនោះ ។ លោកថ្វាយបង្គំលាព្រះសាស្តា ស្វែងរកភិក្ខុនឹងទៅជាមួយខ្លួន បានភិក្ខុ ៦០ អង្គ ចេញទៅជាមួយលោក អស់ផ្លូវ ១២០ យោជន៍ ដល់ស្រុកជាយដែន ក្នុងតំបន់មួយ ទើបព្រមទាំងបរិវារចូលទៅបិណ្ឌបាតក្នុងស្រុកនោះ ។

ពួកមនុស្ស ឃើញភិក្ខុទាំងឡាយអ្នកដល់ព្រមដោយវត្ត មានចិត្ត

---

១.ធ្វើខ្លួនឲ្យមានការៈតិច ឬជាអ្នកដែលមានសេចក្តីត្រូវការ ដែលគេបដិបត្តិតាមបានងាយ ឬមានបរិក្ខារត្រឹមតែ៨ ។

ជ្រះថ្លា តាក់តែងអាសនៈ និងនិមន្តឲ្យគង់ អង្គៀសដោយអាហារដ៏ប្រណីត ហើយសួរថា លោកម្ចាស់ លោកម្ចាស់នឹងទៅទីណា? ពួកភិក្ខុក៏ឆ្លើយថា ឧបាសក ឧបាសិកាទាំងឡាយ ពួកអាត្មានឹងទៅកាន់ទីដែលសប្បាយ ដូច្នេះ មនុស្សដែលជាបណ្ឌិតដឹងថា លោកម្ចាស់ដ៏ចម្រើនទាំងឡាយ ស្វែងរក សេនាសនៈទីចាំវស្សា ទើបពោលអារាធនាថា លោកម្ចាស់ដ៏ចម្រើន បើ លោកម្ចាស់ទាំងឡាយនៅក្នុងទីនេះរហូតអស់ត្រៃមាស ខ្ញុំម្ចាស់ទាំងឡាយ នឹងតាំងនៅក្នុងសរណៈ ហើយរក្សាសីល ។ ចំណែកពួកភិក្ខុក៏គិតគ្នាថា យើងអាស្រ័យត្រកូលទាំងនេះ នឹងធ្វើការចេញចាកភពបាន ដូច្នេះ ទើប ទទួលនិមន្ត ។ ពួកមនុស្សទទួលបដិញ្ញារបស់ភិក្ខុហើយ បាននាំគ្នាចាត់ចែង វិហារ ចាត់ចែងទីនៅក្នុងពេលយប់ និងទីនៅក្នុងពេលថ្ងៃ ហើយប្រគេន ។ ក៏ភិក្ខុទាំងនោះ ចូលទៅបិណ្ឌបាតក្នុងតំបន់មួយ នាស្រុកនោះជាប្រចាំ ។ គ្រានោះ ពេទ្យម្នាក់ទៅរកភិក្ខុទាំងនោះ បវារណាថា បពិត្រលោកម្ចាស់ ដ៏ចម្រើន ធម្មតាក្នុងទីនៅរបស់មនុស្សច្រើន រមែងមានសេចក្ដីមិនសប្បាយ ខ្លះ កាលសេចក្ដីមិនសប្បាយនោះកើតឡើងហើយ លោកម្ចាស់ទាំងឡាយ

គប្បីប្រាប់ដល់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងធ្វើភេសជ្ជៈប្រគេន ។

## ព្រះមហាបាលសមាទានេសជ្ជិកធុតង្គ

ក្នុងថ្ងៃចូលវស្សា ព្រះថេរៈហៅភិក្ខុទាំងនោះមក (ព្រមគ្នា) ហើយសួរថា លោកមានអាយុទាំងឡាយ លោកទាំងឡាយនឹងឲ្យត្រៃមាសនេះកន្លងទៅដោយឥរិយាបថប៉ុន្មាន ?

ភិក្ខុទាំងឡាយឆ្លើយថា នឹងឲ្យកន្លងទៅដោយឥរិយាបថគ្រប់ទាំង ៤ លោកម្ចាស់ ។

ម. លោកមានអាយុទាំងឡាយ ក៏ប្រការនោះសមគួរលះឬ យើងទាំងឡាយគប្បីជាអ្នកមិនប្រមាទមិនមែនឬ ព្រោះយើងទាំងឡាយរៀនព្រះកម្មដ្ឋានមកក្នុងសំណាក់ព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅ ។ ក៏ធម្មតាថា ព្រះពុទ្ធទាំងឡាយ ដែលបុគ្គលប្រមាទ មិនអាចនឹងឲ្យទ្រង់រីករាយបាន ព្រោះថាព្រះពុទ្ធទាំងឡាយនោះ ដែលបុគ្គលមានអធ្យាស្រ័យល្អ (ជំពូកខ្លះ) គប្បីឲ្យទ្រង់រីករាយបាន និងឈ្មោះថា អបាយទាំង ៤ ដូចជាផ្ទះរបស់ខ្លួនឯងនៃបុគ្គលប្រមាទហើយ សូមលោកទាំងឡាយចូរជាអ្នកមិនប្រមាទចុះ ។

ភិ. ករុណា លោកម្ចាស់ ។

ម. លោកដ៏មានអាយុទាំងឡាយ ខ្ញុំនឹងឲ្យត្រៃមាសនេះកន្លងទៅដោយឥរិយាបថ ៣ នឹងមិនទម្រេតខ្លួនឡើយ ។

ភិ. សាធុ សូមលោកម្ចាស់ចូរជាអ្នកមិនប្រមាទចុះ ។

កាលព្រះថេរៈមិនចុះកាន់និទ្រា ក្នុងខែខាងដើមកន្លងទៅហើយ រោគក្នុងចក្ខុក៏កើតឡើង ។ ទឹកភ្នែកក៏ហូរចេញពីភ្នែកទាំង ២ ខាង ដូចធ្លាំងដែលធ្លុះ ។ លោកបំពេញសមណធម៌រហូតអស់រាត្រី ក្នុងវេលាអរុណរះឡើង ទើបចូលបន្ទប់អង្គុយ ។ ក្នុងវេលាភិក្ខាចារ ភិក្ខុទាំងឡាយទៅកាន់សំណាក់របស់ព្រះថេរៈពោលថា ដល់វេលាភិក្ខាចារហើយ លោកម្ចាស់ ។ ព្រះថេរៈឆ្លើយថា លោកដ៏មានអាយុទាំងឡាយ បើដូច្នោះ លោកទាំងឡាយកាន់បាត្រ និងចីវរចុះ ហើយឲ្យភិក្ខុទាំងឡាយកាន់បាត្រ និងចីវររបស់ខ្លួនចេញទៅ ។ ភិក្ខុទាំងឡាយ ឃើញភ្នែកទាំងពីររបស់ព្រះថេរៈ មានទឹកភ្នែកហូរចេញ ទើបសួរថា នោះជាអ្វី លោកម្ចាស់ ។

ម. លោកដ៏មានអាយុទាំងឡាយ ខ្យល់ចាក់ភ្នែករបស់ខ្ញុំ ។

ភិ. លោកម្ចាស់ ពេទ្យបវារណាយើងទុកមិនមែនឬ ? យើងគួរប្រាប់ដល់គេ ។

ម. ល្អហើយ លោកដ៏មានអាយុទាំងឡាយ ។

ភិក្ខុទាំងឡាយទើបបានប្រាប់ពេទ្យ ។ ពេទ្យចម្អិនប្រេងបញ្ជូនទៅប្រគេន ។ ព្រះថេរៈកាលបន្តក់ប្រេងនោះក្នុងច្រមុះ អង្គុយបន្តក់ហើយទើបចូលទៅក្នុងស្រុក ។ ពេទ្យឃើញក៏សួរថា លោកម្ចាស់ បានឮថាខ្យល់ចាក់ភ្នែករបស់លោកម្ចាស់ឬ ។

ម. អើ ឧបាសក ។

ពេទ្យ. លោកម្ចាស់ ខ្ញុំស្ងួប្រេងហើយបញ្ជូនទៅប្រគេន លោកម្ចាស់បន្តក់តាមច្រមុះហើយឬ ។

ម. អើ ឧបាសក ។

ពេទ្យ. ឥឡូវនេះយ៉ាងណាដែរ លោកម្ចាស់ ។

ម. នៅឈឺនៅឡើយ ឧបាសក ។

ពេទ្យគិតក្នុងចិត្តថា យើងផ្សំប្រេងដើម្បីញ៉ាំងរោគស្ងប់បានដោយ

ការបន្ទក់ត្រឹមតែមួយដងប៉ុណ្ណោះទៅប្រគេនហើយ ហេតុអ្វី ពេគទើបមិន ជា ទើបសាកសួរថា លោកម្ចាស់ ប្រេងនោះលោកអង្គុយបន្តក់ ឬដេក បន្តក់ ។ ព្រះថេរៈនៅស្ងៀម លោកសូម្បីពេទ្យសាកសួរក៏មិននិយាយ ។ ពេទ្យគិតថា យើងនឹងទៅកាន់វិហារមើលទីនៅដោយខ្លួនឯង ដូច្នេះ ហើយ ក៏ពោលថា បើដូច្នោះ សូមនិមន្តចុះ លោកម្ចាស់ ។ ពេទ្យគេចចេញពី ព្រះថេរៈហើយ ក៏ទៅកាន់វិហារមើលទីនៅរបស់ព្រះថេរៈ ឃើញតែទីចង្រ្កម និងទីអង្គុយប៉ុណ្ណោះ មិនឃើញទីដេក ទើបសាកសួរថា "លោកម្ចាស់ ប្រេងនោះ លោកម្ចាស់អង្គុយបន្តក់ ឬដេកបន្តក់" ។ ព្រះថេរៈនៅស្ងៀម ។ ពេទ្យអង្វរដដែលៗ ថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំធ្វើដូច្នោះ ធម្មតាសមណធម៌ កាលរាងកាយនៅប្រព្រឹត្តទៅ ក៏អាចធ្វើបាន សូមលោក ម្ចាស់ដេកបន្តក់ថ្នាំចុះ" ។

## ព្រះមហាបាលប្រឹក្សាជាមួយការជួកាយ

ព្រះថេរៈឆ្លើយថា "ទៅចុះ អ្នកមានអាយុ ខ្ញុំប្រឹក្សាហើយទើប សម្រេចចិត្ត" ។ ក្នុងទីនោះ មិនមានញាតិសាលោហិតរបស់ព្រះថេរៈឡើយ

លោកគប្បីប្រឹក្សាជាមួយនរណាហ្ន៎ ។ ក៏លោកប្រឹក្សាជាមួយករជ្ជកាយ[១] ថា "នែ៎ បាលិតៈដ៏មានអាយុ លោកចូរពោលមកមើល លោកនឹងឃើញដល់ចក្ខុ ឬនឹងឃើញដល់ព្រះពុទ្ធសាសនា ក៏ក្នុងសង្សារវដ្តដែលមានខាងដើម និងខាងចុង ដែលបុគ្គលដឹងមិនបាន ខ្លួនលោកជាអ្នកខ្វាក់ភ្នែករាប់មិនបានឡើយ តែព្រះពុទ្ធទាំងឡាយក៏បរិនិព្វានទៅហើយច្រើនរយ ច្រើនពាន់ព្រះអង្គ ក្នុងព្រះពុទ្ធទាំងនោះ ព្រះពុទ្ធសូម្បីតែមួយព្រះអង្គ លោកក៏កំណត់មិនបាន[២] ក្រែងលោកតាំងចិត្តទុកខ្លួនឯងថា នឹងមិនដេករហូតអស់ ៣ ខែ ក្នុងវជូវក្សៀងនេះ ព្រោះដូច្នោះ ចក្ខុរបស់លោកត្រូវខូច ឬបែកធ្លាយក៏ដោយ លោកចូរជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនាទុកចុះ កុំឃើញដល់ភ្នែកឡើយ" កាលពោលទូន្មានកូតកាយ បានភាសិតគាថាទាំងនេះថា

ចក្ខុដែលលោកប្រកាន់ថារបស់ខ្លួន ចូរវិនាសទៅចុះ
ត្រចៀកក៏ចូរវិនាសទៅចុះ កាយក៏ដូចគ្នាយ៉ាងនោះចុះ សូម្បី
គ្រប់វត្ថុដែលអាស្រ័យកាយនេះ ក៏ចូរវិនាសទៅចុះ បាលិតៈ

---

១. កាយ ដែលកើតពីធុលីមានក្នុងសរីរៈ ២.មិនធ្លាប់ជួប ។

ហេតុអ្វី លោកទើបប្រមាទ ចក្ខុដែលលោកប្រកាន់ថារបស់

ខ្លួន ចូរទ្រុឌទ្រោមទៅចុះ ត្រចៀកក៏ចូរទ្រុឌទ្រោមទៅចុះ

កាយក៏ដូចគ្នានោះចុះ សូម្បីវត្ថុគ្រប់យ៉ាងដែលអាស្រ័យ

កាយនេះ ក៏ចូរទ្រុឌទ្រោមទៅចុះ បាលិត: ហេតុដូចម្ដេច

លោកទើបប្រមាទ ចក្ខុដែលលោកប្រកាន់ថាជារបស់ខ្លួន

ចូរបែកធ្លាយទៅចុះ ត្រចៀកក៏ចូរបែកធ្លាយទៅចុះ រូបក៏

ដូចគ្នា សូម្បីវត្ថុគ្រប់យ៉ាងដែលអាស្រ័យរូបនេះ ក៏ចូរបែក

ធ្លាយទៅចុះ បាលិត: ហេតុអ្វី លោកទើបប្រមាទ ។

កាលព្រះថេរៈឲ្យឱវាទដល់ខ្លួនឯងដោយ ៣ គាថាយ៉ាងនេះហើយ បានអង្គុយធ្វើនត្ថុកម្ម[១] ទើបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ពេទ្យឃើញហើយសាកសួរថា "លោកម្ចាស់ ធ្វើនត្ថុកម្មហើយឬ" ។

ម. អើ ឧបាសក ។

ពេទ្យ. យ៉ាងណាហើយ លោកម្ចាស់ ។

ម. នៅឈឺ ឧបាសក ។

---

១- ប្រែថា ផ្សុំ ឬបន្តក់ប្រេង ។

ពេទ្យ. លោកម្ចាស់អង្គុយបន្តក់ ឬដេកបន្តក់ ។

ព្រះថេរៈនៅស្ងៀម លោកសូម្បីពេទ្យសួរដដែលៗ ក៏មិននិយាយអ្វី ។ ពេលនោះ ពេទ្យពោលចំពោះលោកថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនធ្វើសប្បាយដល់ខ្លួន តាំងពីថ្ងៃនេះ សូមលោកម្ចាស់កុំពោលថា "ពេទ្យឯណោះ ផ្សំថ្នាំឲ្យយើង" សូម្បីខ្ញុំក៏មិនពោលថា "ខ្ញុំផ្សំថ្នាំប្រគេនលោកម្ចាស់" ។ ព្រះថេរៈត្រូវពេទ្យរំលឹកហើយ ត្រឡប់ទៅកាន់វិហារវិញ ត្រិះរិះថា លោក សូម្បីពេទ្យគេក៏ប្រាប់ច្រើនដងហើយ លោកកុំចូលលះឥរិយាបថឡើយ ហើយក៏ពោលទូន្មានខ្លួនដោយគាថានេះថា ៖

បាលិត: អ្នកត្រូវពេទ្យគេប្រាប់ពីការឈប់រក្សាហើយ

រង់ចាំតែមច្ចុរាជ ដូចម្តេចនៅតែប្រមាទទៀត ។

ដូច្នេះហើយ ក៏ព្យាយាមបំពេញសមណៈធម៌ ។ លំដាប់នោះ ពេលមជ្ឈិមយាមកន្លងទៅហើយ ទាំងកែវភ្នែក ទាំងកិលេសរបស់លោកក៏បែកធ្លាយ មិនមុនមិនក្រោយគ្នា ។ លោកក៏សម្រេចជាព្រះអរហន្តសុក្ខវិបស្សកៈ (ជាព្រះអរហន្តចំណែកវិបស្សនាសុទ្ធៗ) ហើយក៏ចូលទៅអង្គុយក្នុងបន្ទប់ ។

ក្នុងវេលាភិក្ខាចារ ភិក្ខុទាំងឡាយទៅហៅថា “លោកម្ចាស់ដ៏ចម្រើន ដល់វេលាភិក្ខាចារហើយ” ។

ម. ដល់វេលាហើយឬ លោកដ៏មានអាយុទាំងឡាយ ។

ភិ. ករុណាលោកម្ចាស់ ។

ម. បើដូច្នោះ លោកទាំងឡាយទៅចុះ ។

ភិ. ចុះចំណែកលោកម្ចាស់ ។

ម. ភ្នែករបស់ខ្ញុំ វិនាសហើយ លោកដ៏មានអាយុទាំងឡាយ ។

ភិក្ខុទាំងឡាយមើលភ្នែករបស់លោកហើយ ដឹងថាភ្នែករបស់លោកបែកហើយ បានប្រាប់ព្រះថេរៈថា “លោកដ៏ចម្រើន លោកកុំគិតអ្វីឡើយ ខ្ញុំទាំងឡាយនឹងបដិបត្តិលោក” ហើយធ្វើវត្តបដិបត្តិដែលគួរនឹងធ្វើ ទើបចូលទៅកាន់ស្រុក ។ ពួកមនុស្សមិនឃើញព្រះថេរៈ សួរថា “បពិត្រលោកម្ចាស់ លោកម្ចាស់របស់យើងទាំងឡាយ ទៅណា” ។ ជ្រាបដំណឹងនោះហើយ ក៏បញ្ជូនបាយទៅប្រគេនមុន និងកាន់យកបិណ្ឌបាតទៅដោយខ្លួនឯង ថ្វាយបង្គំព្រះថេរៈហើយ យំខ្សឹកខ្សួលនៅទៀបជើង (របស់លោក) ពោល

ថា "បពិត្រលោកម្ចាស់ ខ្ញុំទាំងឡាយនឹងបដិបត្តិចំពោះលោកម្ចាស់ សូមលោកម្ចាស់កុំគិតអ្វីឡើយ" ហើយលាត្រឡប់ ។ តាំងអំពីនោះមក ពួកមនុស្សក៏បញ្ជូនបាយ និងភេសជ្ជៈទៅប្រគេនដល់វិហារជានិច្ច ។ ចំណែកព្រះថេរៈ ក៏ពោលទូន្មានភិក្ខុ ៦០ អង្គក្រៅពីនេះជាប្រចាំ ។ ភិក្ខុទាំងនោះតាំងនៅក្នុងឱវាទរបស់លោក លុះដល់ថ្ងៃបវារណា ក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាគ្រប់អង្គ ។

## ពួកភិក្ខុទៅគាល់ព្រះសាស្ដា

ក៏ឯភិក្ខុទាំងឡាយចេញវស្សាហើយ ប្រាថ្នានឹងទៅគាល់ព្រះសាស្ដា ទើបប្រាប់ព្រះថេរៈថា "ខ្ញុំទាំងឡាយប្រាថ្នាទៅគាល់ព្រះសាស្ដា លោកម្ចាស់" ព្រះថេរៈបានស្ដាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយ គិតថា "យើងជាមនុស្សទុព្វលភាព និងក្នុងចន្លោះផ្លូវ ដងព្រៃ ដែលអមនុស្សក៏សឹងមាន កាលយើងទៅជាមួយភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនឹងលំបាកព្រោះយើងមិនខានឡើយ និងមិនអាចដើម្បីបានសូម្បីភិក្ខា យើងនឹងបញ្ជូនភិក្ខុទាំងនេះទៅមុនចុះ" លំដាប់នោះ លោកទើបពោលនឹងភិក្ខុទាំងឡាយថា អ្នកមានអាយុ

ទាំងឡាយ លោកទាំងឡាយទៅមុនចុះ” ។

ភិ. ពោលថា ករុណាលោកម្ចាស់ ។

ម. ខ្ញុំជាមនុស្សទុព្វល និងក្នុងចន្លោះផ្លូវ តាមដងព្រៃក្រាស់ដែលអមនុស្សស្ថិតនៅសឹងក៏មាន កាលខ្ញុំទៅជាមួយលោកទាំងឡាយ នឹងលំបាកទាំងអស់គ្នាព្រោះខ្ញុំ លោកទាំងឡាយទៅចុះ ។

ភិ. កុំធ្វើយ៉ាងនេះឡើយ ខ្ញុំទាំងឡាយនឹងទៅព្រមគ្នាជាមួយលោកម្ចាស់តែម្តង ។

ព្រះថេរៈពោលថា “លោកទាំងឡាយកុំពេញចិត្តយ៉ាងនេះឡើយ បើដូច្នោះ សេចក្តីមិនសប្បាយនឹងមានដល់ខ្ញុំ ប្អូនប្រុសរបស់ខ្ញុំឃើញលោកទាំងឡាយហើយ គង់នឹងសួរ បើដូច្នោះ លោកទាំងឡាយគប្បីប្រាប់ថាចក្ខុរបស់ខ្ញុំវិនាសហើយដល់គេ គេគង់នឹងបញ្ជូននរណាៗ មកកាន់សំណាក់របស់ខ្ញុំជាមិនខាន ខ្ញុំនឹងទៅជាមួយគេ លោកទាំងឡាយចូរថ្វាយបង្គំព្រះទសពល និងសំពះព្រះអសីតិមហាថេរៈតាមពាក្យរបស់ខ្ញុំ ដូច្នេះ ហើយក៏បញ្ជូនភិក្ខុទាំងនោះទៅ ។

ភិក្ខុទាំងឡាយខមាទោសព្រះថេរៈហើយ ចូលទៅខាងក្នុងស្រុក ។ ពួកមនុស្សនិមន្តឲ្យគង់ ថ្វាយភិក្ខា ហើយសួរថា "លោកម្ចាស់ទាំងឡាយនឹងនិមន្តទៅណាឬ" ។

ភិក្ខុទាំងឡាយឆ្លើយថា "អើ ឧបាសក ឧបាសិកាទាំងឡាយ ពួកអាត្មាប្រាថ្នានឹងទៅគាល់ព្រះសាស្តា" ។ ពួកគេអង្វរជាច្រើនដង បានជ្រាបការពេញចិត្តរបស់ភិក្ខុទាំងឡាយនឹងទៅឲ្យបាន ទើបជូនដំណើរទៅ ហើយនាំគ្នាត្រឡប់មកវិញទាំងយំខ្សឹកខ្សួល ។ ចំណែកភិក្ខុទាំងឡាយ ទៅដល់ព្រះជេតពនតាមលំដាប់ ថ្វាយបង្គំព្រះសាស្តា និងថ្វាយបង្គំព្រះថេរៈទាំងឡាយ តាមពាក្យរបស់ព្រះថេរៈហើយ លុះព្រឹកឡើង ចូលទៅកាន់ទីនៅប្អូនប្រុសរបស់ព្រះថេរៈ ដើម្បីបិណ្ឌបាត ។ កុដុម្ពិកចាំភិក្ខុទាំងឡាយបាននិមន្តឲ្យគង់ ធ្វើបដិសណ្ឋារៈហើយ សួរថា "ព្រះថេរៈ បងប្រុសរបស់ខ្ញុំនៅឯណា" ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏ប្រាប់ដំណឹងនោះ ដល់គេ ។ គេយំខ្សឹកខ្សួលរៀបរាប់ទៀបជើងរបស់ភិក្ខុទាំងឡាយ សួរថា លោកម្ចាស់ទាំងឡាយ ឥឡូវនេះគួរធ្វើយ៉ាងណាល្អ ។

ភិ. ព្រះថេរៈសង្ឃឹមការទៅរបស់នរណាៗ អំពីទីនេះ ក្នុងកាលទៅដល់ហើយ លោកនឹងមកជាមួយគេ ។

កុ. លោកម្ចាស់ បុរសម្នាក់នេះ ជាក្មួយរបស់ខ្ញុំ ឈ្មោះបាលិតៈ សូមលោកម្ចាស់ទាំងឡាយ បញ្ជូនបុរសនេះទៅចុះ ។

ភិ. បញ្ជូនទៅយ៉ាងនេះមិនបាន (ព្រោះ) អន្តរាយតាមផ្លូវមាន ត្រូវឲ្យបួសជាមុនសិនហើយបញ្ជូនទៅ ទើបគួរ ។

កុ. សូមលោកម្ចាស់ទាំងឡាយធ្វើយ៉ាងនោះហើយ បញ្ជូនទៅចុះ ។

គ្រានោះ ភិក្ខុទាំងឡាយក៏ឲ្យគេបួស ហើយបង្រៀនឲ្យសិក្សាវត្តបដិបត្តិ មានការស្លៀកដណ្តប់ចីវរជាដើមប្រមាណកន្លះខែ ហើយប្រាប់ផ្លូវបញ្ជូនទៅ ។ សាមណេរដល់ស្រុកនោះតាមលំដាប់ ឃើញបុរសចាស់ម្នាក់ត្រង់ទ្វារស្រុក ទើបសួរថា "វិហារដែលតាំងនៅក្នុងព្រៃ អាស្រ័យស្រុកនេះ មានដែរឬទេ ។

បុ. មាន លោកម្ចាស់ ។

សា. នរណានៅទីនោះ ។

បុ. ព្រះថេរៈ ឈ្មោះបាលិតៈ លោកម្ចាស់ ។

សា. សូមលោកប្រាប់ផ្លូវដល់ខ្ញុំផង ។

បុ. លោកម្ចាស់ជាអ្វីនឹងព្រះថេរៈដែរ ។

សា. អាត្មាជាក្មួយរបស់ព្រះថេរៈ ។

លំដាប់នោះ គេនាំសាមណេរចូលទៅកាន់វិហារ ។ សាមណេរថ្វាយបង្គំព្រះថេរៈហើយ ធ្វើវត្តបដិបត្តិបម្រើព្រះថេរៈដោយល្អ ប្រមាណកន្លះខែ ទើបពោលថា "លោកម្ចាស់ដ៏ចម្រើន កុដុម្ពិកជាអ៊ុំប្រុសរបស់ខ្ញុំត្រូវការឲ្យលោកម្ចាស់ត្រឡប់ទៅ មក ពួកយើងនឹងទៅជាមួយគ្នា ។ ព្រះថេរៈពោលថា "បើដូច្នោះ អ្នកចូរចាប់ចុងឈើច្រត់របស់យើង ។ សាមណេរចាប់ចុងឈើច្រត់ ចូលទៅក្នុងស្រុកជាមួយព្រះថេរៈ ពួកមនុស្សនិមន្តឲ្យព្រះថេរៈគង់ហើយ ពោលសួរថា "លោកម្ចាស់អ្នកដ៏ចម្រើន លោកម្ចាស់នឹងទៅទីណា" ។ ព្រះថេរៈឆ្លើយថា "អើ ឧបាសកឧបាសិកាទាំងឡាយ អាត្មានឹងទៅថ្វាយបង្គំព្រះសាស្តា ។ ពួកមនុស្សទាំងនោះ អង្វរដោយប្រការផ្សេងៗ កាលមិនបាន (ដូចប្រាថ្នា) ក៏ជូនព្រះថេរៈទៅបានពាក់កណ្តាលផ្លូវ

នាំគ្នាយំត្រឡប់មកវិញ ។

## សាមណេរដល់នូវសីលវិបត្តិ ព្រោះសំឡេងស្ត្រី

សាមណេរ នាំព្រះថេរៈទៅដោយចុងឈើប្រត់ក្នុងចន្លោះផ្លូវ ដល់ស្រុកដែលព្រះថេរៈធ្លាប់ចូលទៅស្នាក់អាស្រ័យ ឈ្មោះសង្កដ្ឋនគរ ជិតដងព្រៃ ។ សាមណេរបានឮសំឡេងច្រៀងរបស់ស្ត្រីម្នាក់ ចេញពីស្រុកនោះច្រៀងបណ្តើរប្រមូលឧសបណ្តើរនៅក្នុងព្រៃ ក៏កាន់យកនិមិត្តក្នុងសំឡេង ។

ពិតហើយ មិនមានសំឡេងដទៃ ដែលអាចផ្សាយទៅទូទាំងសរីរៈរបស់បុរសទាំងឡាយហើយតាំងនៅ ដូចសំឡេងស្ត្រី ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសំឡេងដទៃសូម្បីត្រឹមតែមួយ ដែលនឹងចាប់ចិត្តរបស់បុរសហើយតាំងនៅ ដូចជាសំឡេងស្ត្រី មិនមានឡើយ ។

សាមណេរកាន់យកនិមិត្តក្នុងសំឡេងនោះហើយ ដាក់ឈើប្រត់ចុះហើយពោលថា "លោកម្ចាស់ សូមលោកម្ចាស់រង់ចាំសិន កិច្ចរបស់ខ្ញុំមាន" ដូច្នេះ ហើយទៅកាន់សំណាក់របស់ស្ត្រីនោះ ។ នាងឃើញលោក

ហើយក៏នៅស្ងៀម ។ លោកដល់នូវសីលវិបត្តិជាមួយស្ត្រីនោះ ។ ព្រះថេរៈគិតថា "យើង បានឮសំឡេងប្រៀងនេះឯង ឯសំឡេងនោះ ជាសំឡេងស្ត្រី សូម្បីសាមណេរក៏ទៅបាត់យូរ លោកគង់នឹងដល់សីលវិបត្តិហើយ ។ ចំណែកសាមណេរនោះ ធ្វើកិច្ចរបស់ខ្លួនស្រេច ត្រឡប់មក និយាយថា "លោកម្ចាស់ យើងទាំងឡាយបន្តដំណើរទៅមុខទៀត" ។ ខណៈនោះ ព្រះថេរៈសួរលោកថា "សាមណេរ អ្នកក្លាយជាមនុស្សអាក្រក់ហើយឬ" លោកនៅស្ងៀម សូម្បីត្រូវព្រះថេរៈសួរដដែលៗ ក៏មិននិយាយអ្វីៗ ។ លំដាប់នោះ ព្រះថេរៈពោលនឹងសាមណេរថា "ធុរៈដោយការចាប់ចុងឈើច្រត់របស់យើងអំពីមនុស្សអាក្រក់ដូចអ្នក មិនមាន" ។ លោកដល់នូវសេចក្តីសង្វេគ ដោះសំពត់កាសាយៈចេញ ហើយស្លៀកដណ្តប់ជាគ្រហស្ថ និយាយថា "លោកម្ចាស់ដ៏ចម្រើន កាលមុនខ្ញុំជាសាមណេរ តែឥឡូវនេះខ្ញុំក្លាយជាគ្រហស្ថហើយ មួយទៀត កាលខ្ញុំបួសក៏មិនបានបួសដោយសទ្ធា បួសព្រោះខ្លាចអន្តរាយក្នុងចន្លោះផ្លូវ មក ពួកយើងនឹងទៅជាមួយគ្នា" ។ ព្រះថេរៈនិយាយថា "អ្នកមានអាយុ គ្រហស្ថអាក្រក់ក្តី សមណៈអាក្រក់

ក្តី ក៏អាក្រក់នោះឯង អ្នកសូម្បីតាំងនៅក្នុងភាពជាសមណៈហើយ មិនអាចដើម្បីធ្វើគុណត្រឹមតែសីលឲ្យបរិបូណ៌បាន កាលបើជាគ្រហស្ថហើយ និងធ្វើសេចក្តីល្អអ្វីបាន ធុរៈដោយការចាប់ចុងឈើច្រត់របស់យើង ដោយមនុស្សអាក្រក់ដូចអ្នក រមែងមិនមាន" ។ នាយបាលិតៈឆ្លើយថា "លោកម្ចាស់ដ៏ចម្រើន ក្នុងវាងផ្លូវមានអមនុស្សប្រជុំគ្នា ឯលោកម្ចាស់ក៏ខ្វាក់ភ្នែក នឹងនៅក្នុងទីនេះបានយ៉ាងណា" ។ លំដាប់នោះ ព្រះថេរៈពោលចំពោះគេថា "អ្នកមានអាយុ អ្នកកុំគិតយ៉ាងនេះឡើយ យើងនឹងដេកស្លាប់នៅក្នុងទីនេះក្តី នឹងដើរទៅទៀលនៅក្នុងទីនេះក្តី ឈ្មោះថា ការទៅជាមួយអ្នក រមែងមិនមាន" ដូច្នេះ ហើយទើបពោលគាថាទាំងនេះថា ៖

ណ្ហើយចុះ យើងជាអ្នកមានចក្ខុខ្វាក់ហើយ មកកាន់
ផ្លូវឆ្ងាយកន្តារ ទោះដេកក្តី នឹងមិនទៅ ព្រោះភាព
ជាសំឡាញ់ក្នុងជនពាល រមែងមិនមាន ណ្ហើយចុះ
យើងជាអ្នកមានភ្នែកវិនាសហើយ មកកាន់ផ្លូវឆ្ងាយ
ផ្លូវកន្តារ នឹងព្រមស្លាប់ នឹងមិនទៅ ព្រោះភាពជា

សំឡាញ់ក្នុងជនពាល រមែងមិនមានឡើយ ។

នាយបាលិតៈបានឮពាក្យនោះហើយ កើតសេចក្ដីសង្វេគ នឹកថា "យើងធ្វើកម្មធ្ងន់ដោយភាពល្ងង់ខ្លៅ មិនសមគួរឡើយ" ដូច្នេះហើយ ឱបដៃយំ រត់ចូលក្នុងព្រៃ បានចៀសចេញទៅដោយប្រការដូច្នេះឯង ។

## អាសនៈសក្កទេវរាជក្ដៅ

ដោយតេជៈនៃសីលរបស់ព្រះថេរៈ (ក្នុងខណៈនោះ) បណ្ឌុកម្ពលសិលាសនៈ[១] របស់សក្កទេវរាជ បណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ មានពណ៌ដូចផ្កាជ័យព្រឹក មានប្រក្រតីស្រុកចុះក្នុងវេលាប្រថាប់អង្គុយ និងផុសឡើងក្នុងវេលាដែលស្ដេចក្រោក ក៏សំដែងអាការក្ដៅ ។ សក្កទេវរាជទ្រង់ត្រិះរិះថា "នរណាហ្ន៎ ប្រាថ្នានឹងញ៉ាំងឲ្យយើងឃ្លាតចាកស្ថាន" ដូច្នេះហើយ ទ្រង់សម្លឹងចុះមក បានទតឃើញព្រះថេរៈដោយទិព្វចក្ខុ ។

ព្រោះហេតុនោះ បុរាណាចារ្យទាំងឡាយ ទើបពោលថា ៖

---

១. ផែនសិលាទីប្រថាប់ មានពណ៌ដូចសំពត់រោមសត្វពណ៌លឿង ។

ស្តេចសហស្សនេត្រជាស្តេចនៃទេវតា បញ្ចូនទិព្វចក្ខុ (ទ្រង់ជ្រាបថា) ព្រះបាលត្ថេរអង្គនេះ តិះដៀលមនុស្សបាប ជម្រះគ្រឿងចិញ្ចឹមជីវិតឲ្យបរិសុទ្ធហើយ ស្តេចសហស្សនេត្រជាស្តេចនៃទេវតា បញ្ចូនទិព្វចក្ខុ (ទ្រង់ជ្រាបថា) ព្រះបាល-ត្ថេរអង្គនេះ ធ្ងន់ក្នុងធម៌ ត្រេកអរក្នុងពាក្យទូន្មាន អង្គុយហើយ ។

ខណៈនោះ ស្តេចទ្រង់បានត្រិះរិះថា បើយើងមិនទៅកាន់សំណាក់របស់ព្រះថេរៈជាអ្នកតិះដៀលមនុស្សបាប និងធ្ងន់ក្នុងធម៌បែបនោះ សីសៈរបស់យើងគប្បីបែកជា ៧ ភាគ យើងនឹងទៅកាន់សំណាក់របស់លោក ។

ព្រោះហេតុនោះ (ព្រះបុរាណាចារ្យទាំងឡាយទើពោលថា)

"ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា អ្នកទ្រទ្រង់នូវសិរីរបស់ទេវរាជ ស្តេចមកក្នុងខណៈនោះហើយ បានចូលទៅជិតព្រះចក្ខុបាលត្ថេរ" ។

ក៏គ្រានោះឯង ស្តេចចូលទៅជិត ហើយទ្រង់បានធ្វើសំឡេងព្រះបាទ

ក្នុងទីជិតព្រះថេរៈ ។ លំដាប់នោះ ព្រះថេរៈសួរសក្កទេវរាជថា "នរណាហ្នឹង" ។

ស្តេចទេវរាជត្រាស់តបថា "ខ្ញុំជាអ្នកដើរផ្លូវ លោកម្ចាស់" ។

ម. លោកទៅណា ឧបាសក ។

ទេវ. ទៅក្រុងសាវត្ថី លោកម្ចាស់ ។

ម. ទៅចុះ លោកដ៏មានអាយុ ។

ទេវ. លោកម្ចាស់នឹងទៅក្នុងទីណាដែរ ។

ម. យើងនឹងទៅក្នុងទីនោះដូចគ្នា ។

ទេវ. បើដូច្នោះ ពួកយើងទៅជាមួយគ្នាចុះ ។

ម. យើងជាមនុស្សទុព្វល ភាពយឺតយូរនឹងមានដល់លោកដែលទៅជាមួយយើងជាមិនខាន ។

ទេវ. កិច្ចប្រញាប់របស់ខ្ញុំមិនមាន សូមឲ្យខ្ញុំទៅជាមួយលោកម្ចាស់នឹងបានបុណ្យណាមួយក្នុងបុញ្ញកិរិយាវត្ថុ ១០ ប្រការ ពួកយើងទៅជាមួយគ្នាចុះ លោកម្ចាស់ ។

ព្រះថេរៈគិតថា "បុរសនេះនឹងជាសប្បុរស ទើបពោលថា បើដូច្នោះ ចាប់ចុងឈើប្រត់ចុះឧបាសក" ។ សក្កទេវរាជទ្រង់ធ្វើយ៉ាងនោះ ទ្រង់បាន បង្រួមផែនដី នាំព្រះថេរៈឲ្យដល់វត្តជេតពនក្នុងវេលាល្ងាច ។ ព្រះថេរៈ បានឮសំឡេងជាគ្រឿងប្រគុំមានសង្ខ និងស្គរជាដើម ហើយសួរថា "នោះ សំឡេងមកពីទីណា" ។

ទេវ. ក្នុងក្រុងសាវត្ថី លោកម្ចាស់ ។

ម. ក្នុងវេលាទៅ យើងទៅដោយប្រើវេលាយូរ ។

ទេវ. ខ្ញុំម្ចាស់ដឹងផ្លូវកាត់ លោកម្ចាស់ ។

ខណៈនោះ ព្រះថេរៈកំណត់បានថា "បុគ្គលនេះមិនមែនជាមនុស្ស ប្រាកដជាទេវតា" ។ (ហេតុនោះ ព្រះបុរាណាចារ្យទាំងឡាយទើបពោល ថា) ៖

"ស្ដេចសហស្សនេត្រជាស្ដេចនៃទេវតា អ្នកទ្រទ្រង់នូវសិរី របស់ទេវរាជ បំព្រួមផ្លូវនោះ មួយរំពេចស្ដេចមកដល់ក្រុង សាវត្ថីហើយ" ។

សក្កទេវរាជ នាំព្រះថេរៈទៅកាន់បណ្ណសាលា ដែលកុដុម្ពិកជាប្អូនប្រុសសាងដើម្បីប្រយោជន៍ដល់ព្រះថេរៈ និមន្តឲ្យគង់លើផែនសំពត់ ហើយនិម្មិតជាមិត្តជាទីស្រឡាញ់ ទៅកាន់សំណាក់របស់កុដុម្ពិកចុល្លបាល ស្រែកហៅថា "នែបាលៈសំឡាញ់" ។ កុដុម្ពិកចុល្លបាលសួរថា "អ្វីសំឡាញ់" ។

ទេវ. លោកដឹងថា ព្រះថេរៈមកហើយឬ ។

ចុល្ល. ខ្ញុំមិនទាន់ដឹងទេ ក៏ព្រះថេរៈមកហើយឬ ។

ទេវ. អើ សំឡាញ់ ខ្ញុំទៅកាន់វិហារ ឃើញព្រះថេរៈគង់នៅក្នុងបណ្ណសាលាដែលលោកឲ្យសាង មកតែម្នាក់ឯង ដូច្នេះហើយ ស្តេចក៏គេចចេញទៅ ។ ចំណែកកុដុម្ពិកទៅដល់វិហារ ឃើញព្រះថេរៈហើយ យំខ្សឹកខ្សួលនៅទៀបជើង ពោលថា "លោកអ្នកដ៏ចម្រើន ខ្ញុំឃើញហេតុនេះហើយទើបមិនព្រមឲ្យលោកបួស ដូច្នេះ ជាដើម ហើយធ្វើក្មេងបម្រើ ២ នាក់ឲ្យជាអ្នកជា ឲ្យបួសក្នុងសំណាក់របស់ព្រះថេរៈ ហើយប្រាប់ថា "អ្នកទាំងឡាយ ចូរនាំយករបស់ឆាន់ មានបបរ និងបាយជាដើម មកអំពីខាងក្នុងផ្ទះឧបដ្ឋាកព្រះថេរៈ" ដូច្នេះ ។ សាមណេរទាំងនោះក៏ធ្វើវត្តបដិបត្តិឧបដ្ឋាក

ដល់ព្រះថេរៈ ។

ក្រោយមកថ្ងៃមួយ ភិក្ខុទាំងឡាយអ្នកនៅក្នុងទិស (អ្នកនៅទីដទៃ) មកកាន់ព្រះជេតពនដោយបំណងថា "នឹងគាល់ព្រះសាស្តា" ហើយថ្វាយបង្គំព្រះសាស្តា សួរសុខទុក្ខព្រះអសីតិមហាសាវក ហើយចារិកនៅក្នុងវិហារ ដល់ទីនៅរបស់ព្រះចក្ខុបាលត្ថេរ បានគិតថា "ពួកយើងនឹងមើលសូម្បីទីនេះ" ដូច្នេះ ក្នុងវេលាល្ងាច ទើបឆ្ពោះទៅកាន់ទីនៅរបស់ព្រះថេរៈ ។ ក្នុងខណៈនោះ មហាមេឃក៏តាំងឡើង ។ ពួកលោកគិតថា ឥឡូវនេះល្ងាចហើយ និងមេឃក៏តាំងឡើង យើងនឹងមកមើលអំពីព្រឹកម្តងវិញ ដូច្នេះក៏ត្រឡប់ទៅ ។ ភ្លៀងធ្លាក់ក្នុងបឋមយាម ឈប់ក្នុងមជ្ឈិមយាម ។ ព្រះថេរៈជាអ្នកប្រារព្ធសេចក្តីព្យាយាម ដើរចង្ក្រមជានិច្ច ព្រោះដូច្នោះ ទើបចុះកាន់ទីចង្ក្រមក្នុងបច្ឆិមយាម ។ ក្នុងកាលនោះ មេភ្លៀងជាច្រើន កើតឡើងហើយលើដីដែលមានភ្លៀងធ្លាក់ថ្មីៗ ។ មេភ្លៀងទាំងនោះ កាលព្រះថេរៈចង្ក្រម ក៏បានស្លាប់ដោយច្រើន ។ ពួកអន្តេវាសិកមិនទាន់បានបោសសំអាតទីចង្ក្រមរបស់ព្រះថេរៈពីព្រឹក ។ ចំណែកពួកភិក្ខុក្រៅពីនេះ មក

ដោយបំណងថា នឹងមើលទីនៅរបស់ព្រះថេរៈ ឃើញសត្វទាំងឡាយក្នុងទីចង្ក្រមហើយ សួរថា "នរណា ចង្ក្រមក្នុងទីនេះ" ។ ពួកអន្តេវាសិករបស់ព្រះថេរៈឆ្លើយថា "ឧបជ្ឈាយ៍របស់ពួកខ្ញុំ លោកម្ចាស់" ។ ភិក្ខុទាំងឡាយតិះដៀលថា "លោកទាំងឡាយ ចូរមើលកម្មរបស់សមណៈចុះ ក្នុងវេលាភ្នែកល្អ លោកក៏ដេក មិនធ្វើការងារៗ ក្នុងវេលាភ្នែកខ្វាក់ ទើបគិតថា យើងនឹងចង្ក្រម ដូច្នេះ ហើយធ្វើសត្វមានប្រមាណប៉ុណ្ណោះឲ្យស្លាប់ លោកគិតថា នឹងធ្វើប្រយោជន៍ បែរធ្វើការរកប្រយោជន៍មិនបាន" ។ លំដាប់នោះភិក្ខុទាំងនោះទៅក្រាបទូលព្រះតថាគតថា "បពិត្រព្រះអង្គ ព្រះចក្ខុបាលត្រូវគិតថា យើងនឹងចង្ក្រម ដូច្នេះ បានធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់" ។ ព្រះមានព្រះភាគត្រាស់សួរថា "អ្នកទាំងឡាយ ឃើញលោកកំពុងធ្វើសត្វមានជីវិតដ៏ច្រើនឲ្យស្លាប់ឬ" ។ ភិក្ខុទាំងនោះក្រាបទូលថា "មិនបានឃើញទេ ព្រះអង្គ" ។

ព្រះ. អ្នកទាំងឡាយ មិនឃើញលោក (ធ្វើដូច្នោះ) យ៉ាងណា សូម្បីលោកក៏មិនឃើញសត្វមានជីវិតទាំងនោះ ដូច្នោះ ម្នាលភិក្ខុទាំងឡាយ ដែល

ឈ្មោះថា ចេតនាជាហេតុឲ្យស្លាប់ របស់ព្រះខីណាស្រពទាំងឡាយ (បុគ្គលអ្នកមានអាសវៈអស់ហើយ) មិនមាន ។

ភិ. បពិត្រព្រះអង្គ កាលឧបនិស្ស័យនៃព្រះអរហត្តមាន ហេតុអ្វីលោកទើបក្លាយជាមនុស្សខ្វាក់ភ្នែក ។

ព្រះ. ដោយអំណាចកម្ម ដែលខ្លួនធ្វើទុកហើយនោះឯង ។

ភិ. ក៏លោកបានធ្វើកម្មអ្វីទុកហើយ ព្រះអង្គ ។

ព្រះ. ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ (ទ្រង់ក៏បានត្រាស់រឿងនោះថា) ។

## បុព្វកម្មរបស់ចក្ខុបាលត្ថេរៈ

ក្នុងអតីតកាល គ្រាព្រះបាទពារាណសី ទ្រង់គ្រប់គ្រងរាជនៅក្នុងក្រុងពារាណសី ពេទ្យម្នាក់ចារិកធ្វើវេជ្ជកម្មនៅក្នុងស្រុក និងនិគម ឃើញស្ត្រីទុព្វលភ្នែកម្នាក់ ទើបសួរថា "ការមិនជាសុខរបស់នាង យ៉ាងណា" ។ ស្ត្រីនោះឆ្លើយថា "ភ្នែករបស់ខ្ញុំមើលមិនឃើញ" ។

ពេទ្យ. ខ្ញុំនឹងធ្វើថ្នាំឲ្យនាង ។

ស្ត្រី. ធ្វើចុះ លោក ។

ពេទ្យ. នាងនឹងឲ្យអ្វីដល់ខ្ញុំ ។

ស្ត្រី. បើលោកអាចធ្វើភ្នែករបស់ខ្ញុំឲ្យបានជា ជាប្រក្រតីវិញ ខ្ញុំនឹងបុត្រធីតា នឹងជាទាសីរបស់លោក ។

ពេទ្យទទួលថា "ល្អហើយ" ហើយក៏ផ្សំថ្នាំឲ្យ ។ ភ្នែកត្រឡប់ជាប្រក្រតីត្រឹមតែថ្នាំមួយដំណក់ប៉ុណ្ណោះ ។ ស្ត្រីនោះគិតថា "យើងជាប់មាត់នឹងពេទ្យនោះទុកថា យើងព្រមទាំងបុត្រធីតា នឹងជាទាសីរបស់គេ គេមុខជាមិនហៅយើងដោយវាចាផ្អែមល្ហែមឡើយ យើងនឹងកុហកគេ" ។ កាលពេទ្យមកហើយ សួរថា "យ៉ាងណា នាងដ៏ចម្រើន" នាងឆ្លើយថា កាលមុនភ្នែករបស់ខ្ញុំឈឺតិចៗ ឥឡូវនេះឈឺខ្លាំងឡើង" ។ ពេទ្យគិតថា "ស្ត្រីនេះមានបំណងកុហកយើង ហើយមិនឲ្យអ្វីៗ យើងមិនត្រូវការដោយតម្លៃឈ្នួលដែលស្ត្រីនេះឲ្យ ឥឡូវនេះ យើងនឹងធ្វើនាងឲ្យខ្វាក់ភ្នែក" ដូច្នេះ ហើយទៅផ្ទះ ប្រាប់សេចក្តីនោះដល់ភរិយា ។ ភរិយាបាននៅស្ងៀម ។ ពេទ្យនោះផ្សំថ្នាំមួយតំណក់ ហើយទៅកាន់សំណាក់ស្ត្រីនោះ ប្រាប់ថា "នាងដ៏ចម្រើន

សូមនាងបន្តក់ថ្នាំមួយតំណក់នេះ” ។ កែវភ្នែកទាំងពីរខាង បានរលត់មួយរំពេច ដូចអណ្តាតប្រទីបដែលរលត់ ។ ពេទ្យនោះបាន (មកកើត) ជាចក្ខុបាលត្ថេរៈនេះឯង ។

ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ កម្មដែលបុត្ររបស់តថាគតធ្វើហើយក្នុងកាលនោះ ជាប់តាមក្រោយលោករឿយៗ ពិតហើយឈ្មោះថា បាបកម្មនេះ រមែងជាប់តាមអ្នកធ្វើ ដូចកង់រទេះ វិលតាមដានជើងគោពលិព័ទ្ធ (គោដែលគេទឹមរទេះផ្ទុកទំនិញ) នាំធុរៈទៅ” លុះត្រាស់រឿងនេះហើយ ទ្រង់ជាព្រះធម្មរាជា ក៏ត្រាស់ព្រះគាថាបន្តអនុសន្ធិ ដូចព្រះរាជាប្រថាប់ព្រះរាជសាសន៍ ដែលមានដីស្អិតប្រថាំទុកហើយដោយព្រះរាជលញ្ចករ (ត្រា) ថា ៖

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរ

បំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គល
មានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី
(នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់
តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជាន់ជើង
គោដែលកំពុងអូសរទេះទៅ ដូច្នោះ ។

## អធិប្បាយគាថា

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់ មានកាមាវចរ-កុសលចិត្តជាដើម ឈ្មោះថា **មនោ** (ចិត្ត) ក្នុងព្រះគាថានោះ ។ តែក្នុងបទនេះ ចិត្តដែលនិយមកំណត់ កំណត់ហើយ ដោយអំណាចចិត្តដែលកើតឡើងដល់ពេទ្យនោះក្នុងគ្រានោះ រមែងបានចំពោះចិត្តដែលប្រព្រឹត្តទៅដោយទោមនស្សសម្បយុត្តដោយបដិឃៈ ។ បទថា **បុព្វង្គម** (មានការដល់មុន) បានដល់ ប្រកបដោយចិត្តនោះ ដែលជាធម្មជាតិដល់មុន ។ ក្នុងបទថា **ធម្មា** (ធម៌ទាំងឡាយ) ធម៌ ៤ យ៉ាង គឺ គុណធម៌ ទេសនាធម៌ បរិយត្តិធម៌ និងនិស្សត្តនិជ្ជីវធម៌ ឈ្មោះថា ធម៌ទាំងឡាយ ។ ក្នុងធម៌ ៤ ប្រការនោះ ធម៌ ក្នុងពាក្យថា ៖

ធម៌ និងអធម៌ ២ ប្រការ ឲ្យផលមិនដូចគ្នា អធម៌
រមែងនាំទៅកាន់នរក ធម៌រមែងឲ្យដល់សុគតិ ។

ឈ្មោះថា គុណធម៌ ។ ធម៌នេះ ក្នុងព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ មានលម្អបទដើមដល់អ្នកទាំងឡាយជាដើម ឈ្មោះថា ទេសនាធម៌ ។ ធម៌ ក្នុងព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កុលបុត្រពួកខ្លះក្នុងលោកនេះ រមែងរៀនធម៌ គឺ សុត្តៈ គេយ្យៈ ជាដើម ឈ្មោះថា បរិយត្តិធម៌ ។ ធម៌ ក្នុងព្រះតម្រាស់ថា "ក៏សម័យនោះឯង ធម៌ទាំងឡាយរមែងមាន ខន្ធទាំងឡាយរមែងមាន" ជាដើម នេះឈ្មោះថា និស្សត្តធម៌ ។ ន័យសូម្បីក្នុងពាក្យថា "និជ្ជីវធម៌" ក៏ដូចគ្នា ។ ក្នុងធម៌ ៤ ប្រការនោះ និស្សត្តធម៌ ឬនិជ្ជីវធម៌ ព្រះសាស្តាទ្រង់បំណងហើយក្នុងទីនេះ ។ និស្សត្តធម៌ ឬនិជ្ជីវធម៌នោះ ដោយអត្ថ ក៏គឺ អរូបក្ខន្ធ ៣ ប្រការ បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ។ ក៏អរូបក្ខន្ធ ៣ ប្រការនោះ ឈ្មោះថា មនោបុព្វង្គមាធម្មា (មានចិត្តដល់មុន) ព្រោះអត្ថថា មានចិត្តដល់មុននៃអរូបក្ខន្ធទាំងនោះ ។ មានពាក្យសួរថា "ក៏ចិត្ត មានវត្ថុដូចគ្នា

មានអារម្មណ៍ដូចគ្នា កើតនៅក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ កើតព្រមគ្នាជាមួយធម៌ទាំងនោះ ឈ្មោះថា ដល់មុនបានយ៉ាងណា ។ មានពាក្យឆ្លើយថា ចិត្ត បានឈ្មោះថា ដល់មុន ព្រោះអត្ថថា ជាបច្ច័យ ជាគ្រឿងញុំាងធម៌ឲ្យកើតឡើង ។ ឧបមាថា កាលពួកចោរដ៏ច្រើន ធ្វើចោរកម្ម មានប្លន់អ្នកស្រុកជាដើមជាមួយគ្នា កាលមាននរណាសួរថា "នរណាជាមេរបស់ពួកវា" អ្នកណាជាបច្ច័យរបស់ពួកវា គឺ ពួកចោរអាស្រ័យអ្នកណា ទើបធ្វើកម្មនោះបាន អ្នកនោះឈ្មោះថាទត្តៈក្តី ឈ្មោះមត្តៈក្តី គេហៅថា មេរបស់ពួកចោរ យ៉ាងណា ពាក្យឧបមេយ្យដែលជាគ្រឿងញុំាងអត្ថដល់ព្រមនេះ បណ្ឌិតគប្បីដឹងច្បាស់ ដូច្នោះ ។ ចិត្ត ឈ្មោះថាដល់មុននៃធម៌ទាំងឡាយនោះ ដោយអត្ថថា ជាបច្ច័យជាគ្រឿងញុំាងធម៌ឲ្យកើតឡើង ដូច្នេះ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា មានចិត្តដល់មុន ។ ព្រោះកាលចិត្តមិនកើតឡើង ធម៌ទាំងនោះរមែងមិនអាចនឹងកើតឡើងបានដោយពិត ។ មួយទៀត ចិត្តជាធំនៃធម៌ទាំងឡាយនោះ ដោយអំណាចជាអធិបតី ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **មនោសេដ្ឋា**

(មានចិត្តជាធំ) ។ ដូចឧបមាថា ចោរទាំងឡាយ មានមេចោរជាដើម យ៉ាងណា ចិត្តជាធំនៃធម៌ទាំងនោះ ក៏ដូច្នោះ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា មានចិត្តជាធំ ។ម្យ៉ាងទៀត វត្ថុទាំងឡាយនោះៗ សម្រេចហើយដោយវត្ថុ មានដើមឈើជាដើម ឈ្មោះថា ជាវត្ថុសម្រេចដោយឈើជាដើម យ៉ាងណា សូម្បីធម៌ទាំងនោះ ឈ្មោះថា **មនោមយា** (សម្រេចហើយដោយចិត្ត) ព្រោះសម្រេចអំពីចិត្ត ក៏ដូច្នោះ ។ បទថា **បទុដ្ឋេន** (ប្រទូសហើយ) គឺ ដែលទោសមានអភិជ្ឈាយជាដើម ដែលចូរមកប្រទូសរាយហើយ ។ ពិតហើយ ចិត្តប្រក្រតី ឈ្មោះភវង្គចិត្ត ភវង្គចិត្តនោះ មិនត្រូវទោសប្រទូសរ៉ាយហើយ ដូចទឹកថ្លា សៅហ្មងព្រោះពណ៌ទាំងឡាយ មានពណ៌ខៀវជាដើម ដែលមកដល់ (ត្រឡប់) ជាទឹកផ្សេងដោយប្រភេទ មានទឹកខៀវជាដើម និងឈ្មោះថាទឹកថ្មីក៏មិនមែន និងឈ្មោះថាទឹកថ្លាដូចដើមក៏មិនមែន យ៉ាងណា ឯភវង្គចិត្តនោះ ដែលទោសមានអភិជ្ឈាជាដើម ចូលមកប្រទូសរ៉ាយហើយ នឹងឈ្មោះចិត្តដូងថ្មីក៏មិនមែន និងឈ្មោះថាភវង្គចិត្តដូចខាងដើមក៏មិនមែន ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ទើបត្រាស់ថា "ម្នាលភិក្ខុ

ទាំងឡាយ ចិត្តនេះផូរផង់ តែចិត្តនោះឯងសៅហ្មងហើយ ព្រោះឧបក្កិលេសទាំងឡាយដែលចរមក" ។ បើបុគ្គល មានចិត្តប្រទូសហើយយ៉ាងនេះ ។ បទថា **ភាសតិ វា ករោតិ វា (និយាយក្តី ធ្វើក្តី)** សេចក្តីថា កាលគេនិយាយ រមែងនិយាយតែវចីទុច្ចរិត ៤ យ៉ាង , កាលធ្វើ រមែងធ្វើតែកាយទុច្ចរិត ៣ យ៉ាង កាលមិននិយាយ កាលមិនធ្វើ ព្រោះភាពនៃខ្លួនជាអ្នកមានចិត្តដែលទោស មានអភិជ្ឈាជាដើមប្រទូសរ៉ាយហើយនោះ រមែងធ្វើមនោទុច្ចរិត ៣ យ៉ាង ឲ្យបរិបូណ៌ ។ អកុសលកម្មបថ ១០ យ៉ាងរបស់គេ រមែងដល់នូវការពេញបរិបូណ៌ ដោយប្រការដូច្នេះ ។ បទថា **តតោ នំ ទុក្ខមន្វេតិ (ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ)** សេចក្តីថា ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ព្រោះទុច្ចរិត ៣ យ៉ាងនោះ គឺ ទុក្ខដែលជាផល ទាំងប្រព្រឹត្តទៅតាមផ្លូវកាយ ទាំងប្រព្រឹត្តទៅតាមផ្លូវចិត្ត ដោយបរិយាយនេះថា ទុក្ខមានកាយជាទីតាំងខ្លះ ទុក្ខមានចិត្តក្រៅអំពីនេះជាទីតាំងខ្លះ រមែងជាប់តាមអត្តភាពនោះ ជាអ្នកទៅកាន់អបាយ ៤ ក្តី ក្នុងពួកមនុស្សក្តី ព្រោះអានុភាពនៃទុច្ចរិត ។ ទុក្ខរមែងជាប់តាមបុគ្គលនោះ យ៉ាង

ណា ។ ដូចកង់រទេះវិលតាមជាន់ជើងគោដែលអូសរទេះទៅ ដូច្នោះ ។ បទថា ចក្កំវ វហតោ បទំ (ដូចកង់រទេះវិលតាមជាន់ជើងគោដែលកំពុងអូសទៅ ដូច្នោះ) បានដល់ ដូចកង់រទេះវិលទៅតាមជាន់ជើងគោពលិព័ទ្ទដែលគេទឹមទុកត្រង់នឹម ហើយនាំភារៈទៅ ។ ឧបមាដូច គោអូសទៅមួយថ្ងៃក្តី ពីរថ្ងៃក្តី ដប់ថ្ងៃក្តី កន្លះខែក្តី រមែងមិនអាចឲ្យវិលត្រឡប់ គឺ មិនអាចលះបង់នូវកង់ទៅបាន ដោយន័យថា កាលវាឈានទៅខាងមុខ នឹមក៏បៀតបៀន (សង្កត់) នូវក (របស់វា) , កាលវាថយក្រោយ កង់ក៏ទង្គិច (កកិត) នូវសាច់ភ្លៅរបស់វា ។ កង់បៀតបៀនដោយហេតុ ២ ប្រការនេះ រមែងវិលតាមទៅស្នាមជើងរបស់វា យ៉ាងណា ទុក្ខទាំងដែលប្រព្រឹត្តទៅតាមផ្លូវកាយ ទាំងដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ដែលមានទុច្ចរិតជាមូល រមែងជាប់តាមបុគ្គលអ្នកដែលមានចិត្តប្រទូសហើយ ធ្វើទុច្ចរិត ៣ ប្រការឲ្យពេញបរិបូណ៌ ក្នុងទីដែលគេទៅនោះៗ មាននរកជាដើមនោះឯង ។

ក្នុងកាលចប់គាថា ភិក្ខុ ៣.០០០ រូប បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ។ ព្រះទេសនាបានជាកថា មានប្រយោជន៍ មាន

*ផលដល់បរិស័ទដែលប្រជុំគ្នាហើយនោះឯង ។*

ចប់រឿងព្រះចក្ខុបាលត្ថេរៈ

# ២ រឿងមដ្ឋកុណ្ឌលី

ចំណែកព្រះគាថាទីពីរថា ៖

មនោបុព្វង្គមា ធម្មា     មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន     ភាសតិ វាករោតិ វា
តតោ នំ សុខមន្វេតិ     ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត
សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី
ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់
តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

ឯព្រះគាថាទីពីរថា មនោបុព្វង្គមា ធម្មា (មានចិត្តដល់មុន)[១] ជាដើម ព្រះមានព្រះភាគ ទ្រង់ប្រារព្ធមដ្ឋកុណ្ឌលីមាណព ទើបត្រាស់នូវភាសិតនេះក្នុងក្រុងសាវត្ថីនោះឯង ។

បានស្តាប់មក ក្នុងក្រុងសាវត្ថី មានព្រាហ្មណ៍ម្នាក់ឈ្មោះ អទិន្ន-

---

១ បិដក ប្រែថា ជាប្រធាន ។

បុព្វក: ។ គេមិនធ្លាប់ឲ្យវត្ថុអ្វីៗ ដល់នរណាៗ ព្រោះដូច្នោះ ប្រជុំជនទើបបានដាក់ឈ្មោះគេថា អទិន្នបុព្វក: ។ គេមានបុត្រម្នាក់ជាទីស្រឡាញ់ពេញចិត្ត ក្រោយមក គេប្រាថ្នានឹងធ្វើគ្រឿងប្រដាប់ឲ្យបុត្រ គិតថា “បើយើងជួលជាងមាស ក៏នឹងត្រូវឲ្យថ្លៃឈ្នួល” ដូច្នេះ ទើបដុតមាសជំធ្វើជាក្រវិលរលោងៗ ស្រេចហើយ បានឲ្យ (ដល់បុត្ររបស់ខ្លួន) ។ ព្រោះដូច្នោះ បុត្ររបស់គេទើបបានប្រាកដឈ្មោះថា **មដ្ឋកុណ្ឌលី** ។ ក្នុងវេលាបុត្រនោះអាយុបាន ១៦ ឆ្នាំ កើតរោគស្គមលឿង ។ មាតាក្រឡេកឃើញបុត្រហើយទើបនិយាយចំពោះព្រាហ្មណ៍ (ជាស្វាមី) ថា “ព្រាហ្មណ៍រោគកើតឡើងហើយដល់បុត្ររបស់លោក សូមលោករកពេទ្យមករក្សាគេផងចុះ” ។ ព្រាហ្មណ៍ឆ្លើយថា “នាងដ៏ចម្រើន បើយើងរកពេទ្យមក យើងនឹងត្រូវឲ្យឈ្នួលដល់គេ” នាងមិនមើលនូវការអស់ទ្រព្យរបស់យើង (ខ្វះទេឬ)” ។ នាងព្រាហ្មណីសួរថា “បើដូច្នេះ លោកនឹងធ្វើយ៉ាងណា ព្រាហ្មណ៍” ព្រាហ្មណ៍ឆ្លើយថា “ទ្រព្យរបស់យើងនឹងមិនអស់ទៅបានយ៉ាងណា យើងនឹងធ្វើយ៉ាងនោះ” ព្រាហ្មណ៍នោះទៅកាន់សំណាក់ពួកពេទ្យហើយ សួរថា “ពួកលោកដាក់ថ្នាំ

ប្រភេទណាដល់មនុស្សដែលកើតរោគប្រភេទឯណោះ” ។ លំដាប់នោះ ពួកពេទ្យក៏ប្រាប់ថ្នាំចំណែកសំបកឈើជាដើមដល់គេ ។ គេ (ទៅ) ស្មោះសំបកឈើជាដើម ដែលពួកពេទ្យប្រាប់នោះ មកធ្វើថ្នាំឲ្យដល់បុត្រ ។ កាលព្រាហ្មណ៍ធ្វើដូច្នោះ រោគបានកម្រើកខ្លាំងជាងមុន (រហូត) គេដល់នូវភាពមិនមាននរណាព្យាបាលបាន ។ ព្រាហ្មណ៍ដឹងថា បុត្រទុព្វលហើយ ទើបរកពេទ្យម្នាក់មក ។ ពេទ្យនោះ មកពិនិត្យមើលហើយ ទើបនិយាយ (គេច) ថា ខ្ញុំនៅមានកិច្ច លោកចូររកពេទ្យដទៃមកឲ្យរក្សាចុះ ដូច្នេះ ហើយប្រាប់ដល់ព្រាហ្មណ៍នោះ ក៏លាទៅ ។ ព្រាហ្មណ៍វេលាថា បុត្ររបស់ខ្លួននឹងស្លាប់ បានគិតថា “ពួកជនដែលមក ដើម្បីត្រូវការនឹងសួរសុខទុក្ខបុត្រនេះ នឹងឃើញទ្រព្យសម្បត្តិខាងក្នុងផ្ទះ យើងនឹងយកគេទៅដាក់ខាងក្រៅ ដូច្នេះ ទើបនាំយកបុត្រចេញមក ឲ្យដេកត្រង់រានហាលផ្ទះខាងក្រៅ ។

## ព្រះពុទ្ធប្រមើលមើលឧបនិស្ស័យរបស់មដ្ឋកុណ្ឌលី

ក្នុងវេលាបច្ចុសម័យ (គឺវេលាជិតភ្លឺ) ថ្ងៃនោះ ព្រះមានព្រះភាគស្តេចចេញអំពីព្រះមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោក ដោយ

ពុទ្ធចក្ខុ មើលពួកសត្វដែលជាផៅពង្ស ដែលព្រះអង្គគួរណែនាំបាន ដែលមានកុសលសន្សំទុកមកហើយ មានសេចក្តីប្រាថ្នា[១] ក្នុងព្រះពុទ្ធពីអតីតទាំងឡាយ ។ ទ្រង់បានផ្សាយសំណាញ់ គឺ ញាណទៅក្នុងម៉ឺនចក្រវាឡ ។ មដ្ឋកុណ្ឌលីមាណពប្រាកដហើយ នៅក្នុងសំណាញ់ គឺ ព្រះញាណនោះ ដោយអាការដែលដេកត្រង់របៀងខាងក្រៅផ្ទះនោះ ។ ព្រះសាស្តាទ្រង់ទតឃើញគេហើយ ទ្រង់ជ្រាបថា ព្រាហ្មណ៍ដែលជាបិតា នាំគេមកខាងក្រៅផ្ទះ ហើយឲ្យដេកក្នុងទីនោះ ទ្រង់ត្រិះរិះថា “នឹងមានប្រយោជន៍ខ្លះ ឬមិនមានហ្ន៎ ដោយបច្ច័យដែលតថាគតទៅក្នុងទីនោះ” ទ្រង់កំពុងរំពឹងមើល ទ្រង់បានឃើញហេតុនេះថា មាណពនេះ នឹងធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត ធ្វើកាលៈហើយ នឹងកើតក្នុងវិមានមាសកម្ពស់ប្រមាណ ៣០ យោជន៍ ក្នុងតាវតឹង្សទេវលោក មាននាងអប្សរជាបរិវារមួយពាន់ ចំណែកព្រាហ្មណ៍នឹងធ្វើឈាបនកិច្ចសរីរៈនោះ យំនៅក្នុងព្រៃបច្ឆា ទេវបុត្រនឹងប្រមើលមើលអត្តភាពខ្លួន កម្ពស់ប្រមាណ ៣ គាវុត (១២ យោជន៍) ប្រដាប់ដោយ

---

១ មានអធិការដែលបានធ្វើទុកហើយ។

គ្រឿងអលង្ការ ដែលប្រើរទេះ ៦០ គ្រឿងផ្ទុក មាននាងអប្សរជាបរិវារ មួយពាន់ គិតថា សិរីសម្បត្តិនេះ យើងបានដោយកម្មអ្វីហ្ន៎ ដូច្នេះហើយ ពិចារណាមើល ក៏ជ្រាបថា បានដោយចិត្តជ្រះថ្លាក្នុងតថាគត គិតថា "បិតា យើងមិនឲ្យពេទ្យផ្សំថ្នាំដល់យើង ព្រោះខ្លាចទ្រព្យនឹងអស់ទៅ ឥឡូវនេះ ទៅយំនៅព្រៃបច្ឆា យើងនឹងធ្វើគេឲ្យដល់ប្រការដែលប្លែក" ដូច្នេះ ដោយ សេចក្តីអន់ចិត្តក្នុងបិតា ទើបនិម្មិតខ្លួនដូចមដ្ឋកុណ្ឌលីមាណព មកអង្គុយ យំនៅក្នុងទីជិតព្រៃបច្ឆា ពេលនោះ ព្រាហ្មណ៍នឹងសួរគេថា អ្នកជានរណា គេនឹងឆ្លើយថា ខ្ញុំជាមដ្ឋកុណ្ឌលីមាណព បុត្ររបស់លោក ព្រាហ្មណ៍សួរ ថា លោកទៅកើតក្នុងភពណា? ទេវបុត្រឆ្លើយថា ក្នុងភពតាវត្តឹង្ស កាល ព្រាហ្មណ៍សួរថា ព្រោះធ្វើកម្មអ្វី? គេនឹងប្រាប់ថា កើតព្រោះចិត្តជ្រះថ្លា ក្នុងព្រះតថាគត ។ ព្រាហ្មណ៍នឹងសួរតថាគតថា "ដែលឈ្មោះថា ការធ្វើ ចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ (ប៉ុណ្ណោះ) ហើយទៅក្នុងស្ថានសួគ៌ មានឬ?" ពេលនោះ តថាគតនឹងតបថា "មិនមាននរណា អាចនឹងកំណត់ដោយការ រាប់បានថា មានប្រមាណប៉ុណ្ណេះរយ ឬពាន់ ឬសែនឡើយ ដូច្នេះហើយ

នឹងពោលគាថាក្នុងធម្មបទ ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌នឹងមាន ដល់សត្វប្រមាណ ៨៤.០០០ ។ មដ្ឋកុណ្ឌលីទេវបុត្រនឹងបានជាព្រះសោ-តាបន្ន អទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នា អាស្រ័យកុលបុត្រនេះ ការបូជាធម៌ ដ៏ច្រើននឹងមានដោយប្រការដូច្នេះ ។ កាលទ្រង់ជ្រាបហើយ លុះភ្លឺច្បាស់ ហើយ ទ្រង់ធ្វើការបដិបត្តិ (ជម្រះ) ព្រះសរីរៈស្រេចហើយ មានភិក្ខុពួក ធំហែហមហើយ ស្តេចចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ស្តេចដល់ ទ្វារផ្ទះរបស់ព្រាហ្មណ៍តាមលំដាប់ ។

ក្នុងខណៈនោះ មដ្ឋកុណ្ឌលីមាណព កំពុងដេកបែរមុខទៅខាងក្នុង ផ្ទះ ព្រះសាស្តាទ្រង់ជ្រាបថា មិនឃើញព្រះអង្គ ទើបបានបញ្ចេញព្រះរស្មី ទៅប៉ះនឹងម្ខាងនៃជញ្ជាំង ។ មាណពគិតថា នេះពន្លឺអ្វី ទើបដេកផ្ងារត្រឡប់ មក ឃើញព្រះសាស្តា ហើយគិតថា យើងអាស្រ័យបិតាជាជនអន្ធពាល ទើបមិនបានចូលទៅគាល់ព្រះពុទ្ធ ធ្វើសេចក្តីខ្វល់ខ្វាយដោយកាយ ឬថ្វាយ ទាន ឬស្តាប់ធម៌ ឥឡូវនេះ សូម្បីដៃទាំងពីររបស់យើង ក៏លើកសំពះ មិនបាន កិច្ចដែលគួរធ្វើយ៉ាងដទៃមិនមាន ដូច្នេះ ហើយបានធ្វើចិត្តប៉ុណ្ណោះ

ឲ្យជ្រះថ្លា ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា "ល្មមដោយការដែលមាណព នេះ ធ្វើចិត្តឲ្យជ្រះថ្លាប្រមាណប៉ុណ្ណេះ" ហើយក៏ស្តេចចៀសចេញទៅ ។ កាលព្រះតថាគតស្តេចបាត់ពីក្រខែវក្ភែកទៅ មាណពដែលមានចិត្តជ្រះថ្លា ធ្វើកាលៈហើយ ដូចជាដេកលក់ហើយភ្ញាក់ឡើងវិញ ទៅកើតក្នុងវិមានមាស កម្ពស់ប្រមាណ ៣០ យោជន៍ ក្នុងទេវលោក ។ ចំណែកព្រាហ្មណ៍ធ្វើ ឈាបនកិច្ចសរីរៈមាតណនោះហើយ មានតែការយំជាខាងមុខ ទៅកាន់ទីព្រៃ បច្ឆាពល់ៗ ថ្ងៃ យំរៀបរាប់ថា "កូនប្រុសតែមួយរបស់ពុកនៅទីណា កូន ប្រុសតែមួយរបស់ពុកនៅទីណា" ។

សូម្បីទេវបុត្រ កាលក្រឡេកមើលសម្បត្តិរបស់ខ្លួនហើយ គិតថា "សម្បត្តិនេះ យើងបានមកដោយកម្មអ្វី កាលពិចារណាទៅក៏ដឹងថា បាន ដោយចិត្តដែលជ្រះថ្លាក្នុងព្រះសាស្តា" ដូច្នេះហើយ ទើបគិតតទៅទៀតថា ព្រាហ្មណ៍នេះ ក្នុងកាលដែលយើងមិនសប្បាយ មិនបានរកគ្រូពេទ្យមក ព្យាបាលឡើយ ឥឡូវនេះ បែរជាទៅយំស្រែកនៅព្រៃបច្ឆា យើងគួរធ្វើ គេឲ្យដល់នូវសេចក្តីប្លែក ដូច្នេះ ទើបនិម្មិតខ្លួនដូចជាមដ្ឋកុណ្ឌលីមាណព

មកហើយ បានឱបដៃយំនៅក្នុងទីដែលមិនឆ្ងាយពីបច្ឆា ។ ព្រាហ្មណ៍ឃើញគេហើយ ទើបគិតថា យើងយំ ព្រោះសោកដល់បុត្រដែលស្លាប់ ឯមាណពនោះ យំត្រូវការអ្វីហ្ន៎ យើងនឹងសួរគេមើល ដូច្នេះ កាលនឹងសួរ បានពោលគាថានេះថា ៖

លោកតុបតែងហើយ ដូចមដ្ឋកុណ្ឌលី មានការៈ
គឺ របៀបផ្កាឈើ មានខ្លួនផ្សាយដោយច័ន្ទលឿង ឱប
ដៃទាំងពីរយំនៅក្នុងព្រៃបច្ឆា លោកមានទុក្ខអ្វីឬ ?

មាណពពោលថា ៖

ផ្ទះរថធ្វើដោយមាស ដ៏ផូរផង់ កើតឡើងហើយ
ដល់ខ្ញុំ ខ្ញុំរកគូនៃកង់នោះមិនបាន ខ្ញុំនឹងអស់ជីវិត
ព្រោះសេចក្តីទុក្ខនោះ ។

ពេលនោះ ព្រាហ្មណ៍បាននិយាយនឹងគេថា ៖

ម្នាលមាណពដ៏ចម្រើន គូកង់នោះ នឹងធ្វើដោយ
មាសក្តី ធ្វើដោយកែវក្តី ធ្វើដោយលោហៈក្តី ធ្វើដោយ

ប្រាកដ្ឋ អ្នកចូរប្រាប់ខ្ញុំចុះ ខ្ញុំនឹងជានាឲ្យអ្នកបាននូវ
គូកង់នោះ ។

មាណពបានស្ដាប់ពាក្យនោះ គិតថា ព្រាហ្មណ៍នេះ មិនធ្វើថ្នាំឲ្យ ដល់បុត្រ លុះមកឃើញយើងរូបរាងស្រដៀងបុត្រ ឈរយំ ទើបនិយាយថា យើងនឹងធ្វើកង់រទេះ ដែលធ្វើដោយមាសជាដើមឲ្យ ណ្ហើយចុះ យើងផ្ចាញ់ផ្ចាលគេ ដូច្នេះ ទើបពោលថា លោកនឹងធ្វើគូនៃកង់ឲ្យដល់ខ្ញុំធំប៉ុនណា កាលព្រាហ្មណ៍នោះពោលថា លោកនឹងត្រូវការប៉ុនណា ទើបប្រាប់ថា ៖

ខ្ញុំត្រូវការព្រះច័ន្ទ និងព្រះអាទិត្យទាំងពីរដួង លោក
ដែលខ្ញុំសូមហើយ មេត្តាឲ្យព្រះច័ន្ទ និងព្រះអាទិត្យទាំងពីរ
នោះដល់ខ្ញុំចុះ ។

មាណពនោះពោលដដែលៗ ដល់គេថា

ព្រះច័ន្ទ និងព្រះអាទិត្យ បញ្ចេញពន្លឺជាគូគ្នា ក្នុងវិថី
ទាំងពីរ រថរបស់ខ្ញុំធ្វើដោយមាស រមែងស្អាតសមជាមួយ

គូនៃកង់នោះ ។

លំដាប់នោះ ព្រាហ្មណ៍និយាយជាមួយគេថា ៖

មាណព លោកប្រាថ្នារបស់ដែលមិនគួរប្រាថ្នា ជា
មនុស្សល្ងង់មែនពិត ខ្ញុំយល់ថា សូម្បីលោកស្លាប់ទៅ
ក៏មិនបានព្រះច័ន្ទ និងព្រះអាទិត្យទាំងពីរឡើយ ។

លំដាប់នោះ មាណពទើបនិយាយនឹងព្រាហ្មណ៍នោះថា ក៏បុគ្គលដែលយំដើម្បីត្រូវការវត្ថុដែលប្រាកដ ជាមនុស្សល្ងង់ ឬថា បុគ្គលដែលយំដើម្បីត្រូវការវត្ថុដែលមិនប្រាកដ ជាមនុស្សល្ងង់ ដូច្នេះ ទើបពោលជាគាថាថា ៖

សូម្បីការទៅ និងការមករបស់ព្រះច័ន្ទ និងព្រះ
អាទិត្យក៏ប្រាកដ ធាតុ គឺ វណ្ណៈនៃព្រះច័ន្ទនិងព្រះអាទិត្យ
ក៏ប្រាកដនៅក្នុងវិថីទាំងពីរ (ចំណែក) ជនដែលធ្វើកាលៈ
លៈលោកនេះទៅហើយ នរណាក៏មើលមិនឃើញ បណ្ដា
យើងទាំងពីរ អ្នកយំនៅក្នុងទីនេះ នរណាជាមនុស្សល្ងង់

ជាន ។

ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ កំណត់បានថា មាណពនេះនិយាយនេះត្រូវ ទើបពោលថា ៖

ម្នាលមាណព លោកនិយាយពិតហើយ បណ្តា
យើងទាំងពីរនាក់យំ (ក្នុងទីនេះ) ខ្ញុំជាមនុស្សល្ងង់ជាង
ខ្ញុំប្រាថ្នាបានបុត្រដែលស្លាប់ហើយឲ្យត្រឡប់មក ដូចជា
ទារកយំប្រាថ្នាបានព្រះច័ន្ទ ។

ដូច្នេះហើយ ក៏ជាអ្នកបាត់សេចក្តីសោក ព្រោះពាក្យរបស់មាណពនោះ កាលនឹងធ្វើសេចក្តីសរសើរមាណព បានពោលគាថាទាំងនេះថា ៖

លោកមកស្រោចខ្ញុំដែលជាអ្នកក្តៅខ្លាំង ដូចបុគ្គល
លត់ភ្លើងដែលឆេះដោយទឹក ខ្ញុំរមែងញុំាងសេចក្តីក្រវល់
ក្រវាយទាំងពួងឲ្យរលត់បាន លោកបន្ទោបង់សេចក្តី
សោកព្រោះបុត្ររបស់ខ្ញុំ ដែលសេចក្តីសោកគ្របសង្កត់
ហើយ បានដកនូវកូនសរ គឺ សេចក្តីសោកដែលមុត

ហឫទ័យខ្ញុំចេញបាន ខ្ញុំនោះជាអ្នកមានកូនសរដែលលោក ដកចេញហើយ ជាអ្នកត្រជាក់ស្ងប់ហើយ ម្នាលមាណព ខ្ញុំវិនាសសេចក្ដីសោក វិនាសការយំស្រែក ព្រោះបានស្ដាប់ ពាក្យរបស់លោក ។

ខណៈនោះ ព្រាហ្មណ៍កាលនឹងសួរគេថា លោកឈ្មោះអ្វី? ទើប ពោលថា ៖

លោកជាទេវតា ឬគន្ធព្វ ឬថាជាស្ដេចបរិន្ទទសក្ក-
ទេវរាជ លោកឈ្មោះអ្វី ឬជាបុត្ររបស់នរណា ខ្ញុំនឹង
ស្គាល់លោកបានដូចម្ដេច?

លំដាប់នោះ មាណពប្រាប់ដល់គេថា ៖

លោកដុតបុត្រណា ក្នុងបច្ចាដោយខ្លួនឯងហើយ
រមែងយំរៀបរាប់ដល់បុត្រណា បុត្រអ្នកនោះ គឺ ខ្ញុំដែល
ធ្វើកុសលធម៌ហើយ ដល់ភាពជាមិត្ររបស់ពួកត្រៃទស
(ទេវតា) ។

ព្រាហ្មណ៍បានពោលថា ៖

កាលលោកឲ្យទានតិច ឬច្រើនក្នុងផ្ទះរបស់ខ្លួន ឬរក្សាឧបោសថកម្ម ដូច្នោះ ខ្ញុំមិនដែលឃើញ លោកទៅទេវលោកបាន ព្រោះកម្មអ្វី ។

មាណពពោលថា ៖

ខ្ញុំមានរោគ ជាទុក្ខ ឈឺចុកចាប់ មានកាយសោប់សេល់ នៅក្នុងផ្ទះរបស់ខ្លួន បានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលី គឺ កិលេស ឆ្លងសេចក្តីសង្ស័យចេញបាន ស្តេចទៅល្អហើយ មានព្រះបញ្ញាមិនអន់ថយ ខ្ញុំនោះ មានចិត្តរីករាយហើយ មានចិត្តជ្រះថ្លាហើយ បានថ្វាយអញ្ជលី ចំពោះព្រះតថាគត ខ្ញុំបានធ្វើកុសលកម្មនោះឯង ទើបបានដល់ភាពជាមិត្ររបស់ពួកត្រៃទស (ទេវតា) ។

កាលមាណពនោះ កំពុងនិយាយរៀបរាប់នោះឯង សរីរៈទាំងអស់របស់ព្រាហ្មណ៍ ក៏ពេញហើយដោយបីតិ ។ គេកាលនឹងប្រកាសបីតិនោះ

ទើបពោលថា ៖

គួរអស្ចារ្យហ្ន៎ គួរចម្លែកហ្ន៎ វិបាកនៃការធ្វើអញ្ជលីនេះ ប្រព្រឹត្តទៅបានដូច្នេះ សូម្បីខ្ញុំ មានចិត្តរីករាយហើយ មានចិត្តជ្រះថ្លាហើយ ដល់ព្រះពុទ្ធថា ជាសរណៈក្នុងថ្ងៃនេះឯង ។

លំដាប់នោះ មាណពបានពោលនឹងគេថា ៖

លោកចូរជាអ្នកមានចិត្តជ្រះថ្លាចុះ ដល់ព្រះពុទ្ធ ទាំងព្រះធម៌ ទាំងសង្ឃ ថាជាសរណៈក្នុងថ្ងៃនេះឯង លោកចូរជាអ្នកមានចិត្តជ្រះថ្លាយ៉ាងនោះឯង សមាទានសិក្ខាបទ ៥ កុំឲ្យដាច់ធ្លុះធ្លាយ ចូរប្រញាប់វៀរចាកបាណាតិបាត (ការសម្លាប់សត្វ) ចូរវៀររបស់ដែលម្ចាស់គេមិនបានឲ្យក្នុងលោក ចូរកុំផឹកទឹកស្រវឹង ចូរកុំនិយាយកុហក និងចូរជាអ្នកពេញចិត្តក្នុងកិរិយារបស់ខ្លួន ។

គេទទួលថា "សាធុ" បានពោលភាសិតគាថាទាំងនេះថា ៖

យក្ស[1] លោកជាអ្នកប្រាថ្នាប្រយោជន៍ដល់ខ្ញុំ ទេវតា លោកជាអ្នកប្រាថ្នាវត្ថុដែលចម្រើនដល់ខ្ញុំ ខ្ញុំនឹងធ្វើ (តាម) ពាក្យរបស់លោក លោកជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមដល់នូវព្រះពុទ្ធជាសរណៈផង ខ្ញុំសូមដល់នូវព្រះធម៌ ដែលមិនមានវត្ថុដទៃក្រៃលែងជាងជាសរណៈផង ខ្ញុំសូមដល់នូវព្រះសង្ឃរបស់ព្រះពុទ្ធដែលជាអគ្គបុគ្គល ដូចជាទេវតាថា ជាសរណៈផង ខ្ញុំនឹងប្រញាប់វៀរចាកបាណាតិបាត វៀរកាន់យករបស់ដែលម្ចាស់របស់គេមិនបានឲ្យក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយកុហក និងជាអ្នកពេញចិត្តក្នុងភរិយារបស់ខ្លួន ។

លំដាប់នោះ ទេវតាពោលនឹងគេថា ព្រាហ្មណ៍ ទ្រព្យក្នុងផ្ទះរបស់លោកមានច្រើន លោកចូរចូលទៅគាល់ព្រះសាស្តា ហើយថ្វាយទាន ចូរស្តាប់ធម៌ ចូរសួរធម៌ ដូច្នេះ ហើយក៏អន្តរធានទៅក្នុងទីនោះឯង ។

---

១. ពាក្យនេះក្នុងទីដទៃសំដៅដល់បុគ្គលកាច តែក្នុងទីនេះសំដៅដល់បុគ្គលគួរបូជា ។

# ព្រាហ្មណ៍ថ្វាយទានដល់ព្រះពុទ្ធ

ចំណែកព្រាហ្មណ៍ទៅផ្ទះហើយ ហៅនាងព្រាហ្មណីមក និយាយថា នាងដ៏ចម្រើន ខ្ញុំនឹងនិមន្តព្រះសមណគោតមហើយទូលសួរបញ្ហា ឯងចូលធ្វើ (ត្រៀម) សក្ការៈ ដូច្នេះ បានទៅកាន់វិហារមិនថ្វាយបង្គំព្រះសាស្តាឡើយ មិនធ្វើបដិសណ្ឋារៈ ឈរនៅក្នុងទីដ៏សមគួរមួយ ហើយក្រាបទូលថា ព្រះគោតមដ៏ចម្រើន សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទ្រង់ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គដើម្បីសោយក្នុងថ្ងៃនេះ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ គេបានជ្រាបថា ព្រះសាស្តាទ្រង់ទទួលហើយ ទើបប្រញាប់ត្រឡប់មកផ្ទះ ប្រើមនុស្សឲ្យតាក់តែងខាទនីយៈ ភោជនីយាហារទុកក្នុងផ្ទះរបស់ខ្លួន ។ ព្រះសាស្តា មានពួកភិក្ខុសង្ឃហែហមហើយ ស្តេចយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ ប្រថាប់គង់លើអាសនៈដែលគេក្រាលទុក ។ ព្រាហ្មណ៍អង្គៀសហើយដោយគោរព ។ មហាជនក៏បានប្រជុំគ្នា ។ បានឮថា កាលព្រះតថាគតដែលព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិនិមន្តហើយ ពួកជន ២ ពួក ក៏មកប្រជុំគ្នា គឺ ពួកជនជាមិច្ឆាទិដ្ឋិ ប្រជុំគ្នាដោយតាំងចិត្តថា ថ្ងៃនេះ ពួកយើង

នឹងមើលព្រះសមណគោតម ដែលត្រូវព្រាហ្មណ៍បៀតបៀនដោយការសួរបញ្ហា ។ ពួកជនជាសម្មាទិដ្ឋិ ក៏ប្រជុំគ្នាដោយតាំងចិត្តថា ថ្ងៃនេះ ពួកយើងនឹងមើលពុទ្ធវិស័យ ពុទ្ធលីលា ។ លំដាប់នោះ ព្រាហ្មណ៍ចូលទៅគាល់ព្រះតថាគត ដែលទ្រង់ធ្វើភត្តកិច្ចស្រេចហើយ អង្គុយលើអាសនៈទាប បានទូលសួរបញ្ហាថា ព្រះគោតមដ៏ចម្រើន មានឬ ដែលឈ្មោះថាពួកជនដែលមិនបានថ្វាយទានដល់ព្រះអង្គ មិនបានបូជាព្រះអង្គ មិនបានស្តាប់ធម៌ មិនបានរក្សាឧបោសថឡើយ បានទៅកើតក្នុងស្ថានសួគ៌ ដោយត្រឹមតែធ្វើចិត្តឲ្យជ្រះថ្លាតែម្យ៉ាងប៉ុណ្ណោះ ។ ព្រះសាស្តាត្រាស់ថា ព្រាហ្មណ៍ហេតុណាលោកមកសួរតថាគត ការដែលខ្លួនធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយកើតក្នុងស្ថានសួគ៌ ដែលមដ្ឋកុណ្ឌលីបុត្ររបស់លោកប្រាប់ដល់លោកហើយមិនមែនឬ ។ ព្រាហ្មណ៍សួរថា ក្នុងកាលណា ព្រះគោតមដ៏ចម្រើន ។ ព្រះសាស្តាត្រាស់ថា ថ្ងៃនេះ លោកទៅកាន់ព្រៃខ្មោចយំរៀបរាប់ ឃើញមាណពម្នាក់ឱបដៃយំនៅក្នុងទីមិនឆ្ងាយ ហើយសួរថា

លោកតាក់តែងហើយដូចមដ្ឋកុណ្ឌលី មានភារៈ គឺ

របៀបផ្កាឈើ មានខ្លួនផង្សាយដោយច័ន្ទលឿង ។

ដូច្នេះជាដើម មិនមែនឬ ។ កាលទ្រង់ប្រកាសពាក្យដែលជនទាំងពីរពោលជាមួយគ្នាហើយ ទ្រង់បានត្រាស់រឿងមដ្ឋកុណ្ឌលីទាំងអស់ ។ ព្រោះដូច្នោះរឿងមដ្ឋកុណ្ឌលីនោះ ទើបបានឈ្មោះថា ជាពុទ្ធភាសិត ។ កាលព្រះសាស្ដាត្រាស់រឿងមដ្ឋកុណ្ឌលីនោះហើយ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកសត្វដែលធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយ ទៅកើតក្នុងស្ថានសួគ៌ រាប់ថា មានមួយរយ ឬពីររយក៏ទេ ដោយពិត ពួកសត្វដែលធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត ហើយទៅកើតក្នុងស្ថានសួគ៌ មានចំនួនរាប់មិនបានឡើយ ។ មហាជនក៏កើតសេចក្ដីសង្ស័យហើយ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ជ្រាបដល់មហាជនទាំងនោះនៅមានសេចក្ដីសង្ស័យ ទ្រង់បានអធិដ្ឋានថា សូមមដ្ឋកុណ្ឌលីទេវបុត្រ ចូរមកព្រមទាំងវិមាន ។ ទេវបុត្រមានអត្តភាពដែលប្រដាប់ហើយដោយគ្រឿងអករណៈទិព្វ កម្ពស់ប្រមាណ ៣ គាវុត មកហើយ ចុះចាកវិមាន ថ្វាយបង្គំព្រះសាស្ដា ហើយបានឈរនៅក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់សួរទេវបុត្រនោះថា លោកធ្វើ

កម្មអ្វី ទើបបានសម្បត្តិនេះ ទ្រង់បានត្រាស់ព្រះគាថាថា ៖

ទេវតា លោកមានកាយស្រស់ល្អក្រៃលែង ឈរធ្វើទិស

ទាំងពួងឲ្យភ្លឺស្វាង ដូចផ្កាយព្រឹក ទេវតា យើងសូមសួរ

លោកដែលមានអានុភាពច្រើន (កាល) លោកនៅជា

មនុស្ស បានធ្វើបុណ្យអ្វីទុក ។

ទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សម្បត្តិនេះ ខ្ញុំព្រះអង្គបានហើយ ព្រោះញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា សម្បត្តិនេះ លោកបានហើយ ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគតឬ ។ ទេវតាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនពិតមែន ។ មហាជនក្រឡេកមើលទេវបុត្រហើយ បានប្រកាសសេចក្ដីត្រេកអរថា នៃបា! ពុទ្ធគុណគួរអស្ចារ្យពិតហ្ន៎ បុត្ររបស់អទិន្នបុព្វកព្រាហ្មណ៍មិនបានធ្វើបុណ្យអ្វីៗ យ៉ាងដទៃ ញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះតថាគតហើយ បានសម្បត្តិបែបនេះ ។

## ចិត្តជាធំក្នុងកម្មគ្រប់យ៉ាង

លំដាប់នោះ ព្រះសាស្ដាត្រាស់ដល់មហាជនទាំងនោះថា ក្នុងការ

ធ្វើកម្មដែលជាកុសល និងអកុសល ចិត្តមានសភាពដល់មុន ចិត្តជាធំ ព្រោះថា កម្មដែលធ្វើដោយចិត្តថ្លាផង់ហើយ រមែងមិនលះបុគ្គលដែលទៅកាន់ទេវលោក មនុស្សលោក ដូចស្រមោល ដូច្នោះ ។ លុះត្រាស់រឿងនេះចប់ហើយ ទ្រង់ជាធម្មរាជា ត្រាស់ព្រះគាថានេះបន្តអនុសន្ធិ ដូចជាព្រះរាជាប្រថាប់ព្រះរាជសាសន៍ ដែលមានដីស្អិតប្រថាំទុកហើយដោយព្រះរាជលញ្ចករថា ៖

មនោបុព្វង្គមា ធម្មា     មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន     ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ     ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តដល់មុន មានចិត្តជាធំ សម្រេច[១]
ហើយដោយចិត្ត បើបុគ្គលមានចិត្តថ្លាផង់ហើយ ពោលក្ដី
ធ្វើក្ដី សេចក្ដីសុខរមែងទៅតាមគេព្រោះហេតុនោះ ដូច
ស្រមោលអន្ទោលតាមប្រាណ ដូច្នោះ ។

---

១ ប្រែសេចក្ដីតាមអដ្ឋកថា ។

## អធិប្បាគាថា

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤[១] សូម្បីទាំងអស់ហៅថា ចិត្តក្នុងព្រះគាថានោះ ដោយមិនលាយឡំគ្នាសូម្បីក៏ពិត តែកាលនិយម កំណត់កំណត់ចុះ ក្នុងពាក្យនេះ រមែងមានបានដល់ ចិត្ត ជាកាមាវចរកុសល ៨ ដួង ក៏កាលពោលដោយអំណាចវត្ថុ រមែងបានដល់ចិត្ត ដែលសហគតៈដោយសោមនស្សប្រកបដោយញាណ អំពីកាមាវចរកុសលចិត្ត ៨ ដួងនោះ ។ បទថា **បុព្វង្គមា (មានសភាពដល់មុន)** បានដល់ ប្រកបដោយចិត្តនោះ ដែលជាធម្មជាតិដល់មុន ។ ខន្ធ ៣ មានវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធជាដើម ឈ្មោះថា **ធម្មា (ធម៌ទាំងឡាយ)** ។ ពិតហើយ ចិត្តមានសភាពដល់មុនអរូបក្ខន្ធទាំង ៣ មានវេទនាក្ខន្ធជាដើមនោះ ដោយអត្ថថា ជាបច្ច័យ ជាគ្រឿងឲ្យកើតឡើង ព្រោះហេតុនោះ ខន្ធទាំង ៣ ប្រការនោះ ទើបឈ្មោះថា **មនោបុព្វង្គមា (មានចិត្តដល់មុន)** ។ ដូចពោលថា កាលទាយកជាច្រើនកំពុងធ្វើបុណ្យរួមគ្នា មានថ្វាយបាត្រ និងចីវរជាដើមដល់ភិក្ខុសង្ឃពួកធំក្តី មានការបូជា ស្តាប់ធម៌ តាំងប្រទីប និង

---

១. គឺ កាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ លោកុត្តរភូមិ ។

ធ្វើសក្ការៈដោយកម្រងផ្កាដ៏ឱឡារិកជាដើមក្តី កាលមានអ្នកពោលថា នរណា ជាប្រធានរបស់ទាយកទាំងនោះ ។ ទាយកណាជាបច្ច័យរបស់ពួកគេ គឺ ពួកគេអាស្រ័យទាយកណា ទើបធ្វើបុណ្យទាំងនោះបាន ទាយកនោះឈ្មោះ តិស្សៈក្តី ឈ្មោះបុស្សៈក្តី ប្រជុំជនរមែងហៅថា ជាប្រធានរបស់ពួកគេ យ៉ាងណា ពាក្យឧបមេយ្យដែលជាគ្រឿងឲ្យយល់អត្ថដល់ព្រមនេះ បណ្ឌិត គប្បីជ្រាបដូច្នោះ ។ ចិត្តឈ្មោះថា មានការដល់មុនធម៌ទាំងនោះ ដោយ អត្ថថា ជាបច្ច័យ ជាគ្រឿងឲ្យកើតឡើងដោយប្រការដូច្នេះ ហេតុនោះ ធម៌ទាំងនេះ ទើបឈ្មោះថា មានចិត្តដល់មុន ។ ពិតហើយ ធម៌ពួកនេះ កាលចិត្តមិនកើតឡើង រមែងមិនអាចនឹងកើតឡើងបាន ចំណែកចិត្ត កាល ចេតសិកធម៌ពួកខ្លះ សូម្បីមិនកើតឡើង ក៏កើតឡើងបាន ។ ចិត្ត ឈ្មោះ ថា ជាធំជាងធម៌ទាំងនេះ ដោយអំណាចជាអធិបតិ ព្រោះដូច្នោះ ធម៌ ទាំងនេះទើបឈ្មោះថា **មនោសេដ្ឋា (មានចិត្តជាធំ)** ។ ដូចពោលថា បុរស ជាអធិបតីនៃប្រជុំជន មានគណៈជាដើម ក៏ហៅថា ជាធំនៃគណៈ ជាធំ នៃកងទ័ព យ៉ាងណា ចិត្តក៏ជាធំសូម្បីនៃធម៌ទាំងនោះ ព្រោះហេតុនោះ

ធម៌ទាំងនេះទើបមានឈ្មោះថា មានចិត្តជាធំ ដូច្នោះ ។ មយ៉ាងទៀត វត្ថុទាំងឡាយនោះៗ សម្រេចហើយដោយវត្ថុមានមាសជាដើម ក៏ឈ្មោះថាសម្រេចហើយដោយមាសជាដើម យ៉ាងណា សូម្បីធម៌ទាំងនោះ ក៏បានឈ្មោះថា **មនោមយា** (សម្រេចហើយដោយចិត្ត) ព្រោះជារបស់សម្រេចហើយអំពីចិត្ត ដូច្នោះ ។ បទថា **បសន្នេន** (ផូរផង់ហើយ) បានដល់ផូរផង់ហើយដោយគុណទាំងឡាយ មានការមិនសម្ញឹងរំពៃជាដើម ។ បទថា **ភាសតិ វា ករោតិ វា** (និយាយក្តី ធ្វើក្តី) សេចក្តីថា បុគ្គលមានចិត្តបែបនេះ កាលនឹងនិយាយ រមែងនិយាយតែវចីសុចរិត ៤ យ៉ាង កាលនឹងធ្វើ រមែងធ្វើតែកាយសុចរិត ៣ យ៉ាង កាលមិននិយាយ កាលមិនធ្វើ រមែងធ្វើតែមនោសុចរិត ៣ យ៉ាង ឲ្យបរិបូណ៌ ព្រោះខ្លួនមានចិត្តផូរផង់ហើយដោយគុណទាំងឡាយ មានការមិនសម្ញឹងរំពៃជាដើមនោះ ។ កុសលកម្មបថ ១០ របស់គេ រមែងដល់នូវសេចក្តីបរិបូណ៌ ដោយប្រការយ៉ាងនេះ ។ បទថា **តតោ នំ សុខមន្វេតិ** (សេចក្តីសុខរមែងជាប់តាមគេព្រោះហេតុនោះ) បានដល់ សេចក្តីសុខ រមែងជាប់តាមបុគ្គលនោះទៅ

ព្រោះសុចរិត ៣ យ៉ាងនោះ ។ កុសលទាំង ៣ ភូមិ[១] ព្រះមានព្រះភាគទ្រង់បំណងហើយក្នុងទីនេះ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអធិប្បាយថា សេចក្ដីសុខដែលជាផល ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងប្រព្រឹត្តទៅតាមផ្លូវចិត្ត (ដោយបរិយាយនេះ) ថា សេចក្ដីសុខដែលមានកាយជាទីតាំងខ្លះ សេចក្ដីសុខមានចិត្តក្រៅពីនេះជាទីតាំងខ្លះ រមែងជាប់ទៅតាម គឺថា រមែងមិនលះបង់បុគ្គលនោះ ដែលកើតហើយក្នុងសុគតិភពក្ដី តាំងនៅហើយក្នុងទីដែលសោយសុខក្នុងសុគតិក្ដី ព្រោះអានុភាពនៃសុចរិតដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ដូចអ្វី ។ ដូចស្រមោលអន្ទោលតាមប្រាណ **ឆាយាវ អនុបាយិនី** ។ អធិប្បាយថា ធម្មតាស្រមោលជារបស់ជាប់តាមសរីរៈ កាលសរីរៈដើរទៅ វាក៏ដើរទៅ កាលសរីរៈឈប់ វាក៏ឈប់ កាលសរីរៈអង្គុយ វាក៏អង្គុយ មិនមាននរណាអាចពោលចំពោះស្រមោលនោះដោយពាក្យដ៏ល្អិតក្ដី ដោយពាក្យគ្រោតគ្រាតក្ដីថា "ឯងចូរត្រឡប់ទៅ" ឬវាយ ហើយឲ្យត្រឡប់ទៅបាន ព្រោះហេតុអ្វី? ព្រោះស្រមោលជារបស់

---

១. គឺ កាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ។

ជាប់ដោយសរីរៈ យ៉ាងណា សេចក្តីសុខដែលប្រព្រឹត្តទៅតាមផ្លូវកាយ និង ប្រព្រឹត្តទៅតាមផ្លូវចិត្ត ផ្សេងដោយសុខ មានកាមាវចរសុខជាដើម ដែល មានកុសល នៃកុសលកម្មបថទាំង ១០ នេះ ដែលបុគ្គលប្រព្រឹត្តច្រើន ហើយ និងប្រព្រឹត្តល្អហើយ ជាឫសគល់ រមែងមិនលះបង់ (បុគ្គលនោះ) ក្នុងទីដែលគេទៅហើយ ដូចស្រមោលជាប់តាមខ្លួន ក៏ដូច្នោះដែរ ។

ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌ បានមានហើយដល់ពួកសត្វ ៨៤.០០០ មដ្ឋកុណ្ឌលីទេវបុត្រ តាំងនៅហើយក្នុងសោតាបត្តិផល អទិន្ន-បុព្វកព្រាហ្មណ៍ក៏ដូចគ្នា ។ គេបានបូជាទ្រព្យសម្បត្តិដ៏ច្រើននោះទុកក្នុងព្រះ សាសនាហើយនោះឯង ។

ចប់ រឿងមដ្ឋកុណ្ឌលី

# ៣ រឿងព្រះតិស្សត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុង រឿងព្រះតិស្សត្ថេរ ដូចតទៅនេះ ៖*

*ព្រះសាស្តាកាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***អក្កោច្ឆិ មំ អវធិ មំ (ជនឯណោះបានជេរអញ ជនឯណោះបានវាយអញ)*** *ជាដើម ។*

*បានឮថា ព្រះតិស្សត្ថេរនោះ ជាឱរសរបស់ព្រះបិតុច្ឆារបស់ព្រះ-មានព្រះភាគ បួសក្នុងកាលខ្លួនចាស់ បរិភោគលាភសក្ការៈដែលកើតឡើងហើយក្នុងព្រះពុទ្ធសាសនា មានរាងកាយធំធាត់ មានចីវរជណ្តប់រៀបរយហើយ[១] ដោយច្រើនអង្គុយនៅក្នុងរោងឆាន់កណ្តាលវិហារ ។ ភិក្ខុអាគន្តុកៈទាំងឡាយមកហើយ កាលត្រូវការនឹងគាល់ព្រះតថាគត ទៅកាន់សំណាក់របស់លោក ដោយសំគាល់ថា លោកជាព្រះថេរៈមានវស្សាចាស់ ដូច្នេះហើយសួរដោយការអើពើដល់វត្ត[២] សួរដោយការអើពើដល់កិច្ចគួរធ្វើ មានការគក់ប្របាច់ជើងជាដើម ។ លោកអង្គុយស្ងៀម ។ លំដាប់នោះ ភិក្ខុ*

---

*១ អាកោដិតប្បច្ចាកោដិតេហិ ប្រែថា វាយហើយ និងវាយចំពោះហើយ ២ ការសំដែងវត្ត ។*

កំលោះមួយរូបសួរលោកថា លោកម្ចាស់មានវស្សាប៉ុន្មានហើយ ។ កាល លោកឆ្លើយ លោកមិនឆ្លើយថា "ខ្ញុំមិនទាន់មានវស្សាទេ ខ្ញុំបួសហើយក្នុង កាលដែលខ្លួនចាស់" តែពោលថា "អ្នកដ៏មានអាយុ ទូន្មានលំបាក លោក មិនស្គាល់ប្រមាណ លោកឃើញព្រះថេរៈអ្នកធំប៉ុណ្ណេះហើយ មិនធ្វើវត្ត សូម្បីតែសាមីចិកម្ម កាលវត្តដែលព្រះថេរៈទាំងនេះសួរដោយអើពើ លោក នៅស្ងៀម សូម្បីត្រឹមតែការរង្កៀសក៏មិនមានដល់លោក" ដូច្នេះ ទើបផ្ទាត់ ម្រាមដៃ (ដោយការរុកកួន) ។ លោកធ្វើខត្តិយមានះឲ្យកើតឡើងហើយ សួរថា ពួកលោកមកកាន់សំណាក់នរណា កាលអាគន្តុកភិក្ខុទាំងនោះឆ្លើយ ថា មកកាន់សំណាក់របស់ព្រះសាស្តា ទើបពោលថា ក៏ពួកលោកស្គាល់ ខ្ញុំថាជានរណា ។ ខ្ញុំនឹងកាត់មូល (កាត់ភាពសមណៈ) របស់លោកចេញ ឲ្យបាន ដូច្នេះ ហើយយំ ជាទុក្ខ ទាស់ចិត្ត បានទៅកាន់សំណាក់របស់ ព្រះសាស្តា ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរលោកថា តិស្សៈ មាន អ្វីកើតឡើង ទើបអ្នកមានទុក្ខ ទាស់ចិត្ត មានទឹកភ្នែកស្រោចមុខ យំមក ដូច្នេះ ។ ចំណែកភិក្ខុទាំងនោះ (គឺពួកភិក្ខុអាគន្តុកៈ) គិតថា ភិក្ខុនេះគង់

ទៅធ្វើកម្មអាក្រក់អ្វីៗ ទើបទៅជាមួយព្រះតិស្សត្ថេរនោះ ថ្វាយបង្គំព្រះសាស្តាហើយ បានអង្គុយនៅក្នុងទីដ៏សមគួរមួយ ។ ព្រះតិស្សត្ថេរនោះ ដែលព្រះសាស្តាត្រាស់សួរហើយ បានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនោះ ជេរខ្ញុំព្រះអង្គ ។

ព្រះសាស្តា. ក៏អ្នកអង្គុយក្នុងទីណា ។

តិស្សភិក្ខុ. ត្រង់រោងឆាន់កណ្តាលវិហារ ព្រះអង្គ ។

ព្រះសាស្តា. ភិក្ខុទាំងនេះមក អ្នកបានឃើញឬ ។

តិស្សភិក្ខុ. ឃើញ ព្រះអង្គ ។

ព្រះសាស្តា. អ្នកបានក្រោកឡើងធ្វើការទទួលរាក់ទាក់ទេ ។

តិស្សភិក្ខុ. មិនបានធ្វើទេ ព្រះអង្គ ។

ព្រះសាស្តា. អ្នកបានសួរដោយការអើពើ ដល់ការទទួលបរិក្ខាររបស់ភិក្ខុទាំងនេះទេ ។

តិស្សភិក្ខុ. ខ្ញុំព្រះអង្គមិនបានសួរដោយអើពើទេ ព្រះអង្គ ។

ព្រះសាស្តា. អ្នកបានសួរដោយអើពើដល់ធម្មទំនៀម ឬទឹកផឹកទេ ។

តិស្សភិក្ខុ. ខ្ញុំព្រះអង្គមិនបានសួរដោយអើពើទេ ព្រះអង្គ ។

ព្រះសាស្តា. អ្នកនាំអាសនៈមក ហើយធ្វើការគក់ប្របាច់ជើងឲ្យទេ ។

តិស្សភិក្ខុ. មិនបានធ្វើទេ ព្រះអង្គ ។

ព្រះសាស្តា. ម្នាលតិស្សៈ វត្តទាំងពួងនោះ អ្នកគួរធ្វើដល់ភិក្ខុចាស់ កាលអ្នកមិនបានធ្វើវត្តទាំងពួងនោះ អង្គុយនៅក្នុងកណ្តាលវិហារ មិនសមគួរ ទោសរបស់អ្នកមាន អ្នកចូរសូមខមាទោសភិក្ខុទាំងឡាយនោះចុះ ។

តិស្សភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុនេះបានជេរខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ មិនសូមខមាទោសលោកទេ ។

ព្រះសាស្តា. ម្នាលតិស្សៈ អ្នកកុំធ្វើយ៉ាងនេះឡើយ ទោសរបស់អ្នកមាន អ្នកចូរសូមខមាទោសភិក្ខុទាំងនោះចុះ ។

តិស្សភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនសូមខមាទោសភិក្ខុទាំងនេះទេ ។

លំដាប់នោះ ព្រះសាស្តាកាលភិក្ខុទាំងឡាយក្រាលទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតិស្សត្ថេរនេះ ជាមនុស្សទូន្មានលំបាក ដូច្នេះហើយ

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តិស្សភិក្ខុនេះ មិនមែនជាអ្នកទូន្មានដោយលំបាកក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន តិស្សភិក្ខុនេះក៏ជាអ្នកទូន្មានលំបាកដូចគ្នា កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ជ្រាបសេចក្តីដែលលោកជាបុគ្គលទូន្មានបានដោយក្រតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ លោកបានធ្វើអ្វីទុកក្នុងកាលអតីត ដូច្នេះទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ទើបទ្រង់នាំរឿងអតីតកាលមក ។

## បុព្វកម្មរបស់ព្រះតិស្សត្ថេរៈ

ក្នុងអតីតកាល កាលព្រះរាជាក្រុងពារាណសី សោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី តាបសឈ្មោះទេវលៈ នៅក្នុងហិមវន្តប្រទេស ៨ ខែ ប្រាថ្នានឹងចូលទៅអាស្រ័យព្រះនគរ ៤ ខែ ដើម្បីត្រូវការរសជូរ និងប្រៃ ទើបចេញចាកហិមវន្តប្រទេស ជួបអ្នករក្សាទ្វារនគរ បានសួរថា ពួកបព្វជិតមកដល់នគរនេះហើយ រមែងស្នាក់នៅទីណា ។ គេទាំងឡាយប្រាប់ថា ត្រង់រោងស្មូនឆ្នាំង លោកម្ចាស់ ។ លោកក៏ទៅកាន់រោងស្មូនឆ្នាំង

ហើយឈរទ្រង់ទ្វារ ពោលថា បើលោកមិនមានការចង្អៀតចង្អល់ ខ្ញុំសូមស្នាក់នៅក្នុងរោងនេះត្រឹមមួយរាត្រីបានឬទេ ។ នាយស្មូនឆ្នាំងពោលថា ពេលយប់ កិច្ចរបស់ខ្ញុំក្នុងរោងមិនមាន រោងជារោងធំ និមន្តលោកម្ចាស់នៅតាមសប្បាយចុះ ដូច្នេះ ហើយប្រគល់រោងថ្វាយ ។ កាលលោកចូលទៅអង្គុយហើយ តាបសដទៃម្នាក់ទៀត ឈ្មោះនារទៈ មកពីហិមវន្តប្រទេស បានសូមស្នាក់នៅមួយរាត្រីពីនាយស្មូនឆ្នាំង ។ នាយស្មូនឆ្នាំងគិតថា តាបសដែលមកមុន លោកពេញចិត្តនឹងនៅជាមួយតាបសនេះឬទេហ្ន៎ (ក៏មិនជ្រាប) យើងនឹងដោះខ្លួនចេញ ដូច្នេះហើយ ទើបពោលថា បើលោកម្ចាស់ដែលចូលទៅមុន ពេញចិត្តសោត លោកម្ចាស់ចូរស្នាក់នៅតាមសេចក្តីពេញចិត្តរបស់តាបសនោះចុះ ។ នារទតាបសនោះ ចូលទៅរកលោក ហើយពោលថា "លោកអាចារ្យ បើលោកមិនចង្អៀតចង្អល់ទេ ខ្ញុំសូមស្នាក់នៅក្នុងរោងនេះមួយរាត្រីផង" កាលលោកពោលថា "រោងជារោងធំ លោកចូរចូលទៅនៅត្រង់ចំណែកម្ខាងចុះ" ដូច្នេះ ទើបចូលទៅអង្គុយត្រង់ចំណែកម្ខាងទៀតនៃតាបសដែលចូលទៅនៅមុន ។ តាបសសូម្បីទាំងពីរនាក់ ក៏

និយាយប្រាស្រ័យនូវពាក្យគួរឲ្យរីករាយដល់គ្នានឹងគ្នាហើយ ក្នុងវេលាដេក នារទតាបសកំណត់ទីដេកនៃទេវលតាបស និងទ្វារហើយ ទើបដេក ចំណែកទេវលតាបសនោះ កាលនឹងដេក រកមិនបានកន្លែងដេក ទើបដេកទទឹងត្រង់កណ្តាលទ្វារ ។ នារទតាបស កាលចេញទៅក្នុងរាត្រី បានជាន់ជដារបស់លោក ។ ទេវលតាបសពោលថា "នរណាជាន់យើង" នារទតាបសពោលថា "លោកអាចារ្យ ខ្ញុំ" ។ ទេវលតាបសពោលថា "ជដិលកោង លោកមកអំពីព្រៃហើយ ជាន់ត្រង់ជដារបស់យើង" ។ នារទតាបសឆ្លើយថា "លោកអាចារ្យ ខ្ញុំមិនដឹងថាលោកដេកត្រង់ទីនេះទេ សូមលោកអត់ទោសឲ្យខ្ញុំផងចុះ" កាលលោកកំពុងនិយាយនោះឯង លោកក៏ចេញទៅខាងក្រៅទៅ ។ ទេវលតាបសនេះគិតថា "តាបសនេះ កាលគេមកវិញនឹងគប្បីជាន់យើង" ដូច្នេះហើយ ទើបដេកត្រឡប់សីសៈទៅផ្លូវខាងជើង ។ ចំណែកនារទតាបស កាលនឹងចេញទៅ គិតថា "កាលដំបូង យើងបានខុសហើយ ក្នុងលោកអាចារ្យ ឥឡូវនេះ យើងនឹងចូលទៅតាមផ្លូវខាងជើងរបស់លោក" ដូច្នេះ កាលមក បានជាន់ត្រង់ករបស់ទេវលតាបស

កាលលោកពោលថា "នេះនរណា" ទើបពោលថា "លោកអាចារ្យ គឺខ្ញុំ" កាលលោកពោលថា "ជដិលកោង មុនដំបូងលោកជាន់ត្រង់ជដារបស់យើង ហើយឥឡូវនេះ ជាន់ត្រង់កយើងទៀត យើងនឹងធ្វើឲ្យលោកវិនាស" នារទ-តាបសពោលថា "លោកអាចារ្យ ទោសរបស់ខ្ញុំមិនមានទេ ខ្ញុំមិនដឹងថា លោកដេកយ៉ាងនេះ ខ្ញុំចូលមកដោយគិតថា សូម្បីដំបូងកំហុសរបស់យើង មាន ឥឡូវនេះ យើងនឹងចូលទៅដោយផ្លូវខាងជើងលោក ដូច្នេះ សូម លោកចូរអត់ទោសដល់ខ្ញុំផងចុះ" ។ ទេវលតាបសពោលថា "ជដិលកោង យើងនឹងធ្វើឲ្យលោកវិនាស" ។ នារទតាបសពោលថា "លោកអាចារ្យ លោកកុំធ្វើយ៉ាងនេះឡើយ" ។

ទេវលតាបសមិនអើពើក្នុងពាក្យរបស់នារទតាបសនោះ បានដាក់បណ្តាសានារទតាបសនោះ (ដោយគាថា) ថា ៖

ព្រះអាទិត្យ មានរស្មីទាំង ១.០០០ មានតេជៈទាំង ១០០
មានប្រក្រតីកម្ចាត់សេចក្តីងងឹត ពេលព្រះអាទិត្យរះឡើង
មកក្នុងវេលាព្រឹក សូមសីសៈរបស់លោកបែកជា ៧ ភាគ ។

នារទតាបសពោលថា "លោកអាចារ្យ ទោសរបស់ខ្ញុំមិនមានទេ កាលខ្ញុំកំពុងនិយាយ លោកបានផ្តាសាហើយ ទោសរបស់នរណាមាន សូមសីសៈរបស់អ្នកនោះចូរបែក អ្នកមិនមានទោស ចូរកុំបែក" ដូច្នេះ ហើយបានផ្តាសា (ដោយគាថា) ថា ៖

ព្រះអាទិត្យ មានរស្មីទាំង ១.០០០ មានតេជៈទាំង ១០០

មានប្រក្រតីកម្ចាត់សេចក្តីងងឹត ពេលព្រះអាទិត្យរះឡើង

មកក្នុងវេលាព្រឹក សូមសីសៈរបស់លោកបែកជា ៧ ភាគ ។

ក៏នារទតាបសនោះ មានអានុភាពច្រើន តាមរឭកជាតិបាន ៨០ កប្ប គឺ ក្នុងអតីតកាល ៤០ កប្ប ក្នុងអនាគតកាល ៤០ កប្ប ព្រោះដូច្នោះ លោកគិតថា ពាក្យបណ្តាសាធ្លាក់ទៅខាងលើនៃនរណាហ្ន៎ កាលពិចារណាទៅ ក៏ជ្រាបថា នឹងធ្លាក់ទៅលើទេវលតាបស ដូច្នេះ អាស្រ័យសេចក្តីករុណាក្នុងតាបសនោះ ទើបបានឃាត់អរុណមិនឲ្យរះឡើងដោយកម្លាំងឫទ្ធិ ។

អ្នកនគរ កាលអរុណមិនរះឡើង ក៏នាំគ្នាទៅកាន់ទ្វារព្រះរាជវាំង

ហើយទូលបង្គំអុកថា "បពិត្រព្រះសម្មតិទេព កាលព្រះអង្គទ្រង់គ្រប់គ្រងរាជសម្បត្តិ ហេតុអ្វីអរុណមិនរះឡើង សូមព្រះអង្គទ្រង់ព្រះករុណាប្រោសឲ្យអរុណរះឡើង ដើម្បីខ្ញុំព្រះអង្គទាំងឡាយផង" ព្រះរាជាទ្រង់ពិចារណាចរិយានុវត្ត មានកាយកម្មជាដើមរបស់ព្រះអង្គ ទ្រង់មិនបានឃើញការមិនសមគួរអ្វីៗ ទើបទ្រង់ត្រិះរិះថា "មានហេតុអ្វីហ្ន៎" ទ្រង់ពិចារណាថា "ច្បាស់ជាមានការវិវាទរបស់ពួកបព្វជិត" ដូច្នេះ ទើបត្រាស់សួរថា "ពួកបព្វជិតមានក្នុងនគរនេះខ្លះទេ" ។ កាលមានអ្នកក្រាបទូលថា កាលល្ងាចថ្ងៃម្សិលមិញ មានពួកបព្វជិតមកកាន់រោងនាយស្មូនឆ្នាំង ព្រះអង្គ" ។ ព្រះរាជាហែហមដោយរាជបុរសកាន់គប់ភ្លើងនាំស្តេចទៅកាន់ទីនោះ ក្នុងទីនោះឯងទ្រង់អភិវាទព្រះនារទតាបសហើយ ប្រថាប់នៅក្នុងទីដ៏សមគួរមួយ ហើយសួរថា ៖

លោកម្ចាស់នារទៈ ការងារទាំងឡាយរបស់ពួកជនជម្ពូទ្វីប

រមែងប្រព្រឹត្តទៅមិនបាន លោកកើតងងឹតហើយព្រោះហេតុ

អ្វី លោកម្ចាស់ដែលខ្ញុំសួរហើយ សូមមេត្តាប្រាប់ហេតុនោះ

ដល់ខ្ញុំផងចុះ ។

នារទតាបសនិយាយរឿងទាំងពួងថ្វាយស្តេចហើយ ថ្វាយព្រះពរថា "អាត្មាភាព ដែលតាបសនេះដាក់បណ្តាសាហើយ ព្រោះហេតុនេះ ពេលនោះ អាត្មាភាពទើបបានដាក់បណ្តាសាខ្លះថា ទោសរបស់ខ្ញុំមិនមាន ទោសរបស់នរណាមាន ពាក្យបណ្តាសាចូរធ្លាក់លើនៃអ្នកនោះចុះ លុះបានដាក់បណ្តាសារហើយ ទើបគិតថា ពាក្យបណ្តាសានឹងធ្លាក់ទៅលើនៃនរណាហ្ន៎ កាលពិចារណាទៅ ក៏ឃើញថា ក្នុងវេលាដែលព្រះអាទិត្យរះឡើង សីសៈរបស់ទេវលតាបសនឹងបែកចេញជា ៧ ភាគ ខ្ញុំអាស្រ័យសេចក្តីករុណាក្នុងលោកនោះ ទើបមិនឲ្យព្រះអាទិត្យរះឡើង ។

ព្រះរាជា. ធ្វើយ៉ាងណា អន្តរាយនឹងមិនកើតមានដល់តាបសនោះ ។

នារទៈ. បើតាបសសូមខមាទោសអាត្មាភាព អន្តរាយនឹងមិនគប្បីមាន ។

ព្រះរាជា. បើដូច្នោះ លោកម្ចាស់ (ទេវលតាបស) ចូរសូមខមា-ទោសនារទតាបសចុះ ។

ទេវល. ជដិលនេះជាន់អាត្មាភាពត្រង់ជង្គង់ និងត្រង់ក អាត្មាមិនសូមខមាទោសជដិលកោងនោះទេ ។

ព្រះរាជា. លោកម្ចាស់ ចូរសូមខមាទោសចុះ លោកម្ចាស់កុំធ្វើយ៉ាងនេះឡើយ ។

ទេវលតាបសទូលថា "អាត្មាភាព មិនព្រមសូមទោស" សូម្បីកាលព្រះរាជាត្រាស់ថា "សីសៈរបស់លោកនឹងបែកជា ៧ ភាគ" ក៏នៅតែមិនព្រមសូមទោសនោះឯង ។ លំដាប់នោះ ព្រះរាជាត្រាស់ជាមួយតាបសនោះថា "លោកមិនព្រមសូមទោស តាមសេចក្ដីពេញចិត្តរបស់ខ្លួនចុះ ។ ដូច្នេះទើបត្រាស់បង្គាប់ឲ្យរាជបុរសចាប់ទេវលតាបសនោះត្រង់ដៃ ត្រង់ជើង ត្រង់ពោះ ត្រង់ក ក៏ឲ្យក្រាបចុះទៀបជើងនារទតាបស ។ នារទតាបសពោលថា "លោកអាចារ្យ សូមលោកក្រោកឡើងចុះ" ខ្ញុំព្រមលើកទោសឲ្យដល់លោក" ហើយព្រះពរថា "មហាបពិត្រ តាបសនេះមិនបានសូមទោសអាត្មាដោយចិត្តស្មោះ មានស្រះនៅទីជិតនេះមួយកន្លែង សូមព្រះអង្គ ត្រាស់បង្គាប់ឲ្យតាបសនោះឈរទូលដុំដីស្អិត មុជទឹកក្នុងស្រះនោះត្រឹមក" ។ ព្រះ

រាជាត្រាស់បង្គាប់ឲ្យធ្វើយ៉ាងនោះ ។ នារទតាបសជាស់តឿន ទេវលតាបស ហើយពោលថា "លោកអាចារ្យ ពេលដែលខ្ញុំស្រាយឫទ្ធិហើយ កាលព្រះអាទិត្យបញ្ចេញពន្លឺ លោកគប្បីនៅស្ងៀមក្នុងស្រះទឹកនោះ ហើយផុសឡើងដោយទីដទៃ" ។ ដុំដីស្អិតនៅលើសីសៈរបស់ទេវលតាបសនោះ ស្មើគ្នានឹងរស្មីនៃព្រះអាទិត្យពាល់ត្រូវប៉ុណ្ណោះ ក៏បែកជា ៧ ភាគចេញពីគ្នា ។ ទេវលតាបសនោះ ឱនមុខចុះចៀសចេញទៅទីដទៃទៅ ។

## ពៀរមិនរម្ងាប់ដោយការចងពៀរ

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះរាជាក្នុងកាលនោះបានជាអានន្ទ ទេវលតាបសបានជាតិស្សភិក្ខុ នារទតាបសបានជាតថាគតនោះឯង សូម្បីក្នុងកាលនោះ តិស្សភិក្ខុ ក៏ជាអ្នកប្រដៅក្រ ដូច្នេះ" ។ ហើយត្រាស់ឲ្យហៅតិស្សត្ថេរៈថា "តិស្សៈ ក៏កាលភិក្ខុគិតថា យើងត្រូវអ្នកឯណោះជេរហើយ ត្រូវអ្នកឯណោះប្រហារហើយ ត្រូវអ្នកឯណោះឈ្នះហើយ អ្នកឯណោះបានលួចវត្ថុរបស់យើងទៅហើយ ដូច្នេះ ឈ្មោះថា ពៀររមែងមិនរម្ងាប់បាន តែកាលភិក្ខុ

មិនចូលទៅចងទុកយ៉ាងនោះឯង ពៀររមែងរម្ងាប់បាន” ដូច្នេះ ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។
អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះ បានលួចទ្រព្យរបស់អញទៅហើយ បើអ្នកណាចងសេចក្ដីក្រោធបែបនោះទុក (ដូច្នេះ) ពៀររបស់អ្នកនោះ មិនរម្ងាប់ឡើយ ។ ចំណែកជនពួកណា មិនបានចងសេចក្ដីក្រោធនោះទុកថា អ្នកឯណោះបានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះ បានឈ្នះអញ អ្នកឯណោះ បានលួចទ្រព្យរបស់អញទៅហើយ ពៀររបស់ជននោះ រមែងរម្ងាប់បាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អក្កោច្ឆិ (បានជេរ)** គឺ បានជេរហើយ ។ បទថា **អវធិ (បានវាយ)** គឺ ធ្វើបាបកាយហើយ ។ បទថា **អជិនិ (បានឈ្នះ)** គឺ បានឈ្នះយើងដោយការអាងសាក្សីកោងខ្លះ ដោយការពោលប្រកែកខ្លះ ដោយការធ្វើឲ្យក្រៃលែងជាងការធ្វើខ្លះ ។ បទថា **អហាសិ (បានលួចទ្រព្យអញ)** គឺ ជនឯណោះបានលួចទ្រព្យ គឺ បណ្តាវត្ថុទាំងឡាយមានសំពត់ជាដើម ទ្រព្យណាមួយរបស់យើង ។ បទថា **យេ ច តំ (ក៏ជនពួកណា "ចូលទៅចងៈ" សេចក្តីក្រោធនោះ)** ជាដើម សេចក្តីថា ជនពួកណាមួយ គឺ ទេវតា ឬមនុស្ស គ្រហស្ថ ឬបព្វជិត ចូលទៅចងសេចក្តីក្រោធនោះ មានវត្ថុជាដើមថា ជនឯណោះបានជេរយើង ដូច្នេះ ដូចពួកអ្នកបរទេះចងនឹមរទេះដោយកូនកំព្រា និងដូចពួកអ្នកនេសាទចងវត្ថុ មានត្រីស្អុយជាដើមដោយវត្ថុមានស្បូវក្លាំងជាដើម ពៀររបស់ពួកគេដែលកើតឡើងហើយមួយគ្រា រមែងមិនរម្ងាប់ គឺថា រមែងមិនស្ងប់បាន ។ បទថា **យេ ច តំ នូបនយ្ហន្តិ (ចំណែកជនពួកណាមិនចូលទៅចងសេចក្តីក្រោធ

នោះទុក) សេចក្ដីថា ជនពួកណាមិនចូលទៅចងសេចក្ដីក្រោធនោះ គឺ មានពាក្យជេរជាដើមជាទីតាំង ដោយអំណាចការមិនរឭកដល់ និងការមិនធ្វើទុកក្នុងចិត្តខ្លះ ដោយអំណាចការពិចារណាឃើញកម្ម យ៉ាងនេះថា "នរណាៗដែលមិនមានទោសបាន សូម្បីខ្លួនឯងក៏គង់នឹងជេរហើយក្នុងភពមុន គង់នឹងប្រហារហើយ (ក្នុងភពមុន) គង់នឹងអាងសាក្សីកោងឈ្នះហើយ (ក្នុងភពមុន) ទ្រព្យរបស់អ្វីៗ របស់នរណាៗ ដែលខ្លួនឯងគង់នឹងសង្កត់សង្កិនយកហើយ (ក្នុងភពមុន) ព្រោះដូច្នោះ លោកសូម្បីជាបុគ្គលមិនមានទោស (ក្នុងបច្ចុប្បន្ន) ក៏បានទទួលផលដែលមិនគួរប្រាថ្នា មានការជេរជាដើម" ។ ពៀររបស់ជននោះ សូម្បីកើតហើយព្រោះសេចក្ដីប្រមាទ រមែងស្ងប់បានដោយការមិនចងសេចក្ដី (ក្រោធ) នេះ ដូចភ្លើងមិនមានឧស កើតឡើងហើយក៏រលត់ទៅ ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា ភិក្ខុមួយសែនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនាបានជាកថាមានប្រយោជន៍ដល់មហាជនហើយ ។ ព្រះតិស្សត្ថេរ សូម្បីជាមនុស្សទូន្មានលំបាក ក៏ក្លាយ

ជាមនុស្សទ្រូទ្រានបានដោយងាយ ។

ចប់រឿងព្រះតិស្សៈ

# ៤ រឿងរបស់នាងកាឡីយក្ខិនី

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្ដ្រីម្នាក់ដែលគ្មានកូន ទើបត្រាស់ព្រះធម្មទេសនានេះថា **ន ហិ វេរេន វេរានិ** (ពៀរទាំងឡាយ "ក្នុងលោកនេះរមែងមិនស្ងប់" ដោយពៀរឡើយ) ជាដើម ។*

*បានស្ដាប់មកហើយ បុត្ររបស់កុដុម្ពីក៍ម្នាក់ កាលបិតាធ្វើកាលៈហើយ ធ្វើការងារទាំងពួង ទាំងទីស្រែទាំងទីផ្ទះដោយខ្លួនឯង ចិញ្ចឹមមាតាតមក មាតាបានប្រាប់ដល់គេថា "កូន ម៉ែនឹងនាំនាងកុមារិកាមកឲ្យកូន" ។*

*កូន. ម៉ែ កុំនិយាយយ៉ាងនេះឡើយ ខ្ញុំនឹងថែរក្សាម៉ែរហូតអស់មួយជីវិត ។*

*មាតា. កូនសំឡាញ់ កូនតែម្នាក់ធ្វើការងារ ឯទីស្រែផង និងទាំងនៅផ្ទះផង ព្រោះហេតុនោះ ទើបម៉ែមិនមានសេចក្ដីសប្បាយចិត្តឡើយ ម៉ែនឹងនាំនាងទារិកាមកឲ្យកូន ។*

*គេសូម្បីហាម (មាតា) ច្រើនដងហើយមិនបានក៏នៅស្ងៀម ។ មាតានោះ ចេញចាកផ្ទះដើម្បីទៅកាន់ត្រកូលមួយ ។ លំដាប់នោះ បុត្រសួរមាតា*

ថា "ម៉ែនឹងទៅត្រកូលណា" មាតាប្រាប់ថា នឹងទៅត្រកូលឈ្មោះឯណោះ ដូច្នេះ គេក៏ហាមការទៅកាន់ត្រកូលនោះ ហើយប្រាប់ត្រកូលដែលខ្លួនពេញចិត្ត ។ មាតាបានទៅត្រកូលនោះ ដណ្ដឹងនាងកុមារិកាទុក ហើយកំណត់ថ្ងៃ (រៀបការ) នាំនាងកុមារិកានោះមក ឲ្យនៅក្នុងផ្ទះរបស់បុត្រ ។ នាងកុមារិកានោះជាស្ត្រីអារ ។ ពេលនោះ មាតាទើបនិយាយនឹងបុត្រថា "បា! កូនឲ្យម៉ែនាំនាងកុមារិកាមក តាមការពេញចិត្តរបស់កូនហើយ ឥឡូវនេះ នាងកុមារិកានោះជាស្រីគ្មានកូន ក៏ធម្មតាត្រកូលដែលមិនមានបុត្រ រមែងវិនាស តំណវង្សរមែងមិនជាប់ទៅបាន ព្រោះហេតុនោះ ម៉ែនឹងនាំនាងកុមារិកាដទៃមកឲ្យកូន" សូម្បីបុត្រនោះក៏ពោលហាមថា "កុំឡើយ ម៉ែ" ដូច្នេះ តែម្ដាយគេនៅតែពោល (យ៉ាងនោះ) រឿយៗ ។ ស្ត្រីអារនោះបានឮពាក្យនោះ ទើបគិតថា ធម្មតាបុត្ររមែងមិនអាចប្រឆាំងពាក្យមាតាបិតាបាន ឥឡូវនេះ សូម្បីម្ដាយក្មេកគិតនឹងនាំស្ត្រីដទៃមិនមែនជាស្ត្រីអារមក ហើយនឹងប្រើយើងដូចជាទាសី បើដូច្នោះ យើងគប្បីនាំនាងកុមារិកាម្នាក់មកដោយខ្លួនឯង ដូច្នេះ ទើបទៅកាន់ត្រកូលមួយ សូមនាងកុមារិកាដើម្បី

ប្រយោជន៍ដល់ស្វាមី ត្រូវពួកជនក្នុងត្រកូលនោះហាមថា នាងនិយាយអ្វី ដូច្នោះ ទើបនិយាយអង្វរថា ខ្ញុំជាស្ត្រីអារ ត្រកូលដែលមិនមានបុត្ររមែង វិនាស បុត្រីរបស់លោកបានបុត្រហើយ នឹងបានជាម្ចាស់នៃទ្រព្យសម្បត្តិ សូមលោកមេត្តាលើកបុត្រីនោះឲ្យដល់ស្វាមីខ្ញុំចុះ ។ ដូច្នេះ ហើយញ៉ាំង ត្រកូលនោះឲ្យយល់ព្រម ទើបនាំមកទុកក្នុងផ្ទះរបស់ស្វាមី ។ ក្រោយមក ស្ត្រីនោះ មានបរិវិតក្កៈថា “បើនាងម្នាក់នេះបានបុត្រ ឬបុត្រី នឹងបានជា ម្ចាស់នៃទ្រព្យសម្បត្តិតែម្នាក់ឯង គួរយើងធ្វើនាងកុំឲ្យបានទារកឡើយ” ។ លំដាប់នោះ ស្ត្រីអារទើបនិយាយចំពោះនាងនោះថា “គភ៌តាំងឡើងក្នុងផ្ទៃ នាងកាលណា សូមនាងប្រាប់ដល់ខ្ញុំកាលនោះ” ។ នាងនោះទទួលថា “ចា៎” កាលតាំងគភ៌ហើយ បានប្រាប់ដល់ស្ត្រីអារនោះ ។ ចំណែកស្ត្រីអារនោះ ឲ្យបបរ និងបាយដល់នាងនោះជានិច្ច ។ ក្រោយមក នាងបានឲ្យថ្នាំសម្រាប់ ធ្វើគភ៌ឲ្យធ្លាក់ លាយជាមួយអាហារដល់នាងនោះ ។ គភ៌ក៏ធ្លាក់ ។ កាល តាំងគភ៌ជាលើកទី ២ នាងក៏បានប្រាប់ដល់នាងស្ត្រីអារនោះទៀត ។ សូម្បី ស្ត្រីអារនោះ ក៏បានធ្វើគភ៌ឲ្យធ្លាក់ដោយឧបាយនោះឯងជាលើកទី ២ ។ លំដាប់

នោះ ពួកស្ត្រីដែលស្និទ្ធស្នាលជាមួយនាង បានសួរនាងថា "ស្ត្រីរួមស្វាមីធ្វើអន្តរាយដល់នាងមិនមែនឬ?" នាងដឹងសេចក្តីនោះហើយ ត្រូវស្រីទាំងនោះពោលថា "ស្រីល្ងង់ ហេតុអ្វីទើបនាងធ្វើយ៉ាងនោះហ្ន៎ ស្ត្រីអារនេះបានផ្សំថ្នាំសម្រាប់ធ្វើគភ៌ឲ្យធ្លាក់ដល់នាង ព្រោះខ្លាចនាងជាធំ ហេតុនោះឯងគភ៌របស់នាងទើបធ្លាក់ នាងកុំធ្វើយ៉ាងនេះទៀត" ។ ក្នុងលើកទី ៣ ទើបមិនប្រាប់ ។ តមក (ចំណែក) ស្ត្រីអារឃើញពោះរបស់នាងនោះហើយ ទើបពោលថា "ហេតុអ្វីនាងមិនប្រាប់នៅការតាំងគភ៌ដល់ខ្ញុំ" នាងនោះពោលថា "នាងនាំខ្ញុំមកហើយ ធ្វើគភ៌ឲ្យវិនាសអស់ ២ ដងហើយ ខ្ញុំនឹងប្រាប់ដល់នាងធ្វើអ្វី" ។ ស្ត្រីអារគិតថា "ឥឡូវនេះ យើងវិនាសហើយ" ដូច្នេះ រង់ចាំការប្រមាទរបស់នាងកុមារិកានោះ កាលគភ៌គ្រប់ខែហើយ ពេលបានចន្លោះ ក៏បានផ្សំថ្នាំឲ្យ ។ គភ៌មិនអាចធ្លាក់ ព្រោះគភ៌ចាស់ ទើបដេកទទឹង (ទ្វារ) ។ វេទនាដ៏ខ្លាំងកើតឡើង ។ នាងដល់នៅសេចក្តីសង្ស័យក្នុងជីវិត (ថាអញរស់ឬទេ) ។ នាងតាំងសេចក្តីប្រាថ្នាថា "យើងត្រូវស្ត្រីអារធ្វើឲ្យវិនាសហើយ នាងនាំយើងមក ធ្វើទារករបស់យើងឲ្យវិនាសអស់ ៣ ដង

ឥឡូវនេះ ខ្លួនយើងក៏វិនាស បើយើងឃ្លាតចាកអត្តភាពនេះ សូមឲ្យកើតជានាងយក្ខិនី ហើយទំពារស៊ីទារករបស់នាងនោះវិញ" ដូច្នេះ ហើយបានស្លាប់ទៅកើតជាមេឆ្មាក្នុងផ្ទះនោះឯង ។ ចំណែកស្វាមី ចាប់ស្ត្រីអារនោះហើយពោលថា "នាងបានធ្វើការផ្តាច់ត្រកូលរបស់យើងឲ្យវិនាស ហើយវាយដោយអវយវៈទាំងឡាយ មានដៃ និងជើងជាដើមឲ្យរបួស ។ ស្រីអារនោះស្លាប់ព្រោះសេចក្តីឈឺចាប់នោះឯង ហើយបានកើតជាមេមាន់ក្នុងផ្ទះនោះដូចគ្នា ។

## ព្រាត់គ្នាស្វែងរកគ្នាព្រោះការចងពៀរមួយជាតិ

ក្នុងកាលមិនយូរ មេមាន់បានកើតពងជាច្រើន ។ មេឆ្មាក៏មកស៊ីពងមាន់ទាំងនោះអស់ ។ សូម្បីលើកទី ២ លើកទី ៣ ឆ្មាក៏បានស៊ីដូចគ្នា ។ មេមាន់បានធ្វើសេចក្តីប្រាថ្នាថា "វាស៊ីពងរបស់យើងអស់ ៣ ដងហើយ ម្តងនេះវាក៏ប្រាថ្នាស៊ីខ្លួនយើងទៀត កាលបើយើងឃ្លាតចាកអត្តភាពនេះហើយ គប្បីបានស៊ីវាជាមួយកូនរបស់វា" ដូច្នេះ កាលឃ្លាតចាកអត្ត-ភាពនោះ បានកើតជាមេខ្លា ។ ចំណែកមេឆ្មា បានកើតជាមេម្រឹគ ។ ក្នុង

វេលាដែលមេម្រឹគនោះកើតកូនហើយ មេខ្លា បានមកស៊ីកូនទាំងឡាយអស់ ៣ លើក ។ វេលានឹងស្លាប់ មេម្រឹគធ្វើសេចក្តីប្រាថ្នាថា "ពួកកូនរបស់យើងត្រូវមេខ្លានេះស៊ីអស់ ៣ ដងហើយ ឥឡូវនេះវាស៊ីទាំងខ្លួនយើងផង យើងឃ្លាតចាកអត្តភាពនេះហើយ នឹងបានស៊ីវា និងកូនរបស់វាផងចុះ" ដូច្នេះ ហើយបានស្លាប់ទៅកើតជានាងយក្ខិនី ។ ចំណែកមេខ្លា ឃ្លាតចាកអត្តភាពនេះហើយ បានកើតជាកុលធីតា[១] ក្នុងក្រុងសាវត្ថី ។ នាងដល់នូវសេចក្តីចម្រើនហើយ បានទៅកាន់ ត្រកូលស្វាមីឯស្រុកជិតទ្វារក្រុង ។ ក្នុងកាលតមកនាងបានប្រសូត្របុត្រម្នាក់ ។ នាងយក្ខិនីបានក្លែងខ្លួនជាស្រីសំឡាញ់ដែលស្រឡាញ់នាងមកយូរហើយ សួរថា "សំឡាញ់របស់នាងខ្ញុំនៅទីណា" ។ ពួកអ្នកស្រុកបានប្រាប់ថា "នាង ប្រសូតបុត្រនៅខាងក្នុងបន្ទប់" ។ នាងយក្ខិនីស្តាប់ពាក្យនោះ បានពោលថា "ស្រីជាសំឡាញ់របស់ខ្ញុំប្រសូតបុត្រប្រុស ឬស្រី ខ្ញុំនឹងទៅមើលក្មេងនោះ" ក៏ចូលទៅមើល ចាប់ទារកនោះស៊ី ហើយក៏គេចចេញទៅ សូម្បីក្នុងលើកទី ២ ក៏បានស៊ីដូចគ្នា ។

---

១ ស្រីក្រមុំរបស់ត្រកូល ស្រីក្រមុំក្នុងត្រកូល ឬស្រីមានស្វាមីក្នុងត្រកូល ។

ក្នុងលើកទី ៣ នាងកុលធីតាមានគភ៌ចាស់ ហៅស្វាមីមកប្រាប់ថា “អ្នកស្វាមី នាងយក្ខិនីម្នាក់ស៊ីបុត្ររបស់ខ្ញុំអស់ ២ ដងហើយ ម្ដងនេះ ខ្ញុំនឹងទៅកាន់ផ្ទះនៃត្រកូលរបស់ខ្ញុំប្រសូតបុត្រ” ហើយទៅកាន់ផ្ទះនៃត្រកូលខ្លួនប្រសូត្របុត្រក្នុងទីនោះ ។ ក្នុងកាលនោះ នាងយក្ខិនីនោះដល់វេនជញ្ជូនទឹក ។ ព្រោះថា នាងយក្ខិនីទាំងឡាយ ត្រូវជញ្ជូនទឹកអំពីស្រះអនោតត្តទូលលើសីសៈមកដើម្បីថ្វាយស្ដេចវេស្សវ័ណតាមវារៈ អស់ ៤ ខែខ្លះ ៥ ខែខ្លះ ទើបរួច (ចាកវារៈ) បាន ។ នាងយក្ខិនីពួកដទៃមានកាយរបួសរហូតដល់អស់ជីវិតខ្លះក៏មាន ។ ចំណែកនាងយក្ខិនីនោះ កាលផុតចាកវារៈជញ្ជូនទឹកនោះ ក៏ប្រញាប់ទៅកាន់ផ្ទះនោះ សួរថា “ស្រីសំឡាញ់របស់ខ្ញុំនៅទីណា” ។ ពួកអ្នកស្រុកប្រាប់ថា “នាងនឹងបានជួបនាងក្នុងទីណា នាងយក្ខិនីម្នាក់ស៊ីកូនរបស់នាងដែលប្រសូតនៅទីនេះ ព្រោះដូច្នេះ នាងទើបទៅកាន់ផ្ទះនៃត្រកូល” ។ នាងយក្ខិនីនោះគិតថា “នាងទៅក្នុងទីណាៗ ក៏ដោយ មិនផុតអំពីយើងឡើយ” ដូច្នេះ ដោយកម្លាំងពៀរឲ្យឧស្សាហ៍ ហើយ ក៏រត់ប្រះពួយទៅកាន់ក្រុង ។ ចំណែកកុលធីតា ក្នុងថ្ងៃដាក់ឈ្មោះ

ក៏ឲ្យទារកនោះងូតទឹក ដាក់ឈ្មោះហើយ ពោលចំពោះស្វាមីថា "អ្នកជាស្វាមី ឥឡូវនេះ យើងនាំគ្នាទៅកាន់ផ្ទះរបស់យើងចុះ" ប្តីប្រពន្ធដើរទៅតាមផ្លូវកាត់តាមកណ្តាលវិហារជាមួយស្វាមី ប្រគល់បុត្រឲ្យស្វាមី ហើយចុះងូតទឹកក្នុងស្រះបោក្ខរណីម្ខាងនៃវិហារ ឡើងមកទទួលបុត្រ កាលស្វាមីកំពុងងូតទឹក ឈរឲ្យបុត្របៅដោះ ក្រឡេកឃើញនាងយក្ខិនី កំពុងមកចាំបាន ក៏ស្រែកដោយសំឡេងខ្លាំងៗ ថា "នាយ ប្រញាប់មកឲ្យលឿននេះនាងយក្ខិនីនោះ" មិនអាចឈររង់ចាំដល់ស្វាមីនោះមក ទើបត្រឡប់ថយក្រោយរត់ទៅកាន់ខាងក្នុងវិហារ ។

## ពៀរមិនរម្ងាប់ដោយពៀរ តែរម្ងាប់ដោយការមិនចងពៀរ

ក្នុងសម័យនោះ ព្រះសាស្តាទ្រង់សំដែងធម៌នៅក្នុងជំនុំបរិស័ទ ។ នាងកុលធីតានោះ ឲ្យបុត្រដេកចុះក្បែរជិតខ្នងព្រះបាទនៃព្រះតថាគត ហើយបានក្រាបទូលថា "នាងខ្ញុំសូមថ្វាយបុត្រនេះដល់ព្រះអង្គ សូមព្រះអង្គប្រទានជីវិតដល់បុត្រខ្ញុំព្រះអង្គផងចុះ" ។ សុមនទេវតាអ្នកថែរក្សាត្រង់ខ្លោងទ្វារមិនព្រមឲ្យយក្ខិនីចូលទៅខាងក្នុង ។ ព្រះសាស្តាទ្រង់ហៅព្រះអានន្ទមក ហើយ

ត្រាស់ថា អានន្ទអ្នកចូរទៅហៅនាងយក្ខិនីនោះមក ។ ព្រះថេរៈហៅនាងយក្ខិនីនោះមក ។ ព្រះអានន្ទហៅនាងយក្ខិនីនោះមកហើយ ។ នាងកុលធីតាក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន នាងយក្ខិនីមកហើយ ។ ព្រះសាស្តាត្រាស់ថា នាងយក្ខិនីមកចុះ នាងកុំមានសេចក្តីលំបាកអ្វី ទើបបានត្រាស់ចំពោះនាងយក្ខិនីដែលឈរហើយនោះថា “ហេតុអ្វី នាងទើបធ្វើយ៉ាងនោះ ប្រសិនបើពួកនាងមិនមកនៅចំពោះព្រះភក្រ្តព្រះពុទ្ធដូចជាតថាគតទេ ពៀររបស់ពួកនាងនឹងបានជាកម្មតាំងនៅអស់នៃកប្ប ដូចពៀររបស់ពស់ និងស្ការ , របស់ខ្លាឃ្មុំ និងដើមពង្រ និងរបស់ក្អែកជាមួយសត្វមៀម ហេតុអ្វី ពួកនាងទើបធ្វើពៀរចំពោះគ្នានឹងគ្នា ។ ព្រោះពៀររមែងស្ងប់ទៅបានដោយការមិនចងពៀរ មិនមែនរម្ងាប់បានដោយការចងពៀរទេ” ហើយបានត្រាស់ព្រះគាថានេះថា ៖

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ក្នុងកាលណាៗ ពៀរទាំងឡាយក្នុងលោកនេះ រមែងមិនរម្ងាប់

*ដោយពៀរឡើយ ក៏ប៉ុន្តែរមែងរម្ងាប់បាន ដោយការមិនចងពៀរ*

*ធម៌នេះ មានជាយូរមកហើយ ។*

## អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា ន ហិ វេរេន (រមែងមិនរម្ងាប់ដោយពៀរឡើយ) ជាដើម សេចក្ដីថា ឧបមាថា បុគ្គល សូម្បីកាលលាងទីដែលប្រឡាក់ហើយដោយរបស់មិនស្អាត មានទឹកមាត់ និងទឹកសំបោរជាដើម ព្រោះរបស់មិនស្អាតទាំងនោះឯង រមែងមិនអាចធ្វើឲ្យជាទីស្អាត កម្ចាត់បង់ក្លិនអាក្រក់បាន ដោយពិត ទីនោះត្រឡប់ជាទីមិនស្អាត និងមានក្លិនស្អុយកាន់ខ្លាំងឡើង យ៉ាងណា បុគ្គលកាលជេរតបចំពោះជនដែលបានជេរ ប្រហារតបចំពោះជនដែលបានប្រហារ រមែងមិនអាចញុំាងពៀរឲ្យរម្ងាប់ដោយពៀរបាន ដោយពិត គេឈ្មោះថា ធ្វើពៀរនោះឯងឲ្យក្រៃលែងឡើង ដូច្នោះ ។ សូម្បីក្នុងកាលណាៗ ដែលឈ្មោះថា ពៀរទាំងឡាយ រមែងមិនស្ងប់ទៅបានដោយពៀរ តាមពិត ពៀររមែងចម្រើនតែម្យ៉ាង ដោយប្រការដូច្នេះ ។ បទថា អវេរេន ច សម្មន្តិ (ក៏ពៀររមែងរម្ងាប់បានដោយការមិនចងពៀរ)*

សេចក្ដីថា ឧបមាដូចរបស់មិនស្អាត មានទឹកមាត់ជាដើមនោះឯង ត្រូវបុគ្គលលាងដោយទឹកដែលថាស្អាត រមែងកម្ចាត់ក្លិនស្អុយបាន ទីនោះរមែងជាទីដែលស្អាត មិនមានក្លិនស្អុយ យ៉ាងណា ពៀរទាំងឡាយរម្ងាប់ គឺរមែងស្ងប់ បានដល់ រមែងដល់ការមិនមាន ដោយការមិនមានពៀរ គឺដោយទឹក គឺ ខន្តិ និងមេត្តា ដោយការធ្វើទុកក្នុងចិត្តដោយឧបាយ (និង) ដោយការពិចារណា ដូច្នោះដូចគ្នា ។ បទថា **ឯស ធម្មោ សនន្តនោ** **(ធម៌នេះជារបស់ចាស់)** សេចក្ដីថា ធម៌នេះ គឺ ការស្ងប់ពៀរដោយការមិនចងពៀរជារបស់បុរាណ គឺ ជាផ្លូវនៃព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដំណើរទៅហើយ ។

ក្នុងកាលចប់ព្រះគាថា នាងយក្ខិនីក៏តាំងនៅក្នុងសោតាបត្តិផល ។ ទេសនាបានជាកថាមានប្រយោជន៍សូម្បីដល់បរិស័ទអ្នកប្រជុំគ្នាហើយ ។

ព្រះសាស្ដាបានត្រាស់ចំពោះនាងកុលធីតាថា នាងចូរឲ្យបុត្ររបស់នាងដល់នាងយក្ខិនីនោះចុះ ។

កុលធីតា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គខ្លាច ។

ព្រះសាស្តា. កុំខ្លាចឡើយ អន្តរាយរមែងមិនមានដល់នាង ព្រោះអាស្រ័យនាងយក្ខិនីនោះឡើយ ។

នាងក៏បានឲ្យបុត្រដល់នាងយក្ខិនីនោះ ។ នាងយក្ខិនីនោះឱបទារកនោះថើប ហើយឲ្យត្រឡប់ទៅមាតាវិញ ក៏បានស្រែកយំ ។ លំដាប់នោះព្រះសាស្តាក៏ត្រាស់សួរនាងយក្ខិនីនោះថា "ហេតុអ្វីបាននាងយំ" ។ នាងយក្ខិនីនោះបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលមុន ខ្ញុំព្រះអង្គសូម្បីសម្រេចការចិញ្ចឹមជីវិតព្រោះមិនដឹងផ្លូវ មិនដែលបានអាហារពេញផ្ទៃឥឡូវនេះ ខ្ញុំព្រះអង្គនឹងចិញ្ចឹមជិវិតបានដោយដូចម្តេច ។ លំដាប់នោះ ព្រះសាស្តាត្រាស់តបទៅនាងយក្ខិនីថា "នាងកុំគិតឡើយ" ហើយត្រាស់នឹងនាងកុលធីតាថា "នាងចូរនាំនាងយក្ខិនីនេះទៅកាន់ផ្ទះរបស់ខ្លួន ហើយចូរបដិបត្តិដោយបាយ និងបបរឲ្យល្អ" ។ នាងកុលធីតានាំនាងយក្ខិនីទៅហើយឲ្យស្នាក់នៅក្នុងរោងត្បាល់ជាន់ បានបដិបត្តិដោយបាយ និងបបរដោយល្អហើយ ។ ក្នុងវេលាត្បាល់បុកស្រូវ អង្រែ ប្រាកដដល់នាងយក្ខិនីនោះឯងហាក់ដូចវាយត្រូវសីសៈ ។ នាងទើបហៅនាងកុលធីតាដែលជាសំឡាញ់មក

ហើយនិយាយថា ខ្ញុំមិនអាចនៅក្នុងទីនេះបាន សូមនាងឲ្យខ្ញុំស្នាក់នៅទីដទៃផងចុះ ។ សូម្បីនាងជាសំឡាញ់ក៏ឲ្យស្នាក់នៅក្នុងទីនេះ គឺ ក្នុងរោងត្បាល់ជាន់ ជិតពាងទឹក ក្បែរចង្ក្រាន ក្រោមសំយ៉ាបផ្ទះ ក្បែរគំនរសម្រាម នាមាត់ទ្វារផ្ទះ ។ នាងពោលថា "ក្នុងរោងត្បាល់នេះ អង្រែរមែងប្រាកជដូចជាវាយសីសៈខ្ញុំ , ឯក្បែរពាងទឹកនេះ ពួកក្មេងៗ រមែងជះទឹកជាក់គ្នាធ្លាក់ត្រូវខ្ញុំ , ចំណែកនៅជិតចង្ក្រាននេះ ហ្វូងសុនខរមែងមកដេក , ឯក្រោមសំយ៉ាបផ្ទះវិញ ពួកក្មេងរមែងធ្វើឲ្យជាស្មោកគ្រោក , ត្រង់គំនរសម្រាមជនទាំងឡាយរមែងចោលសម្រាម , ឯត្រង់ទ្វារផ្ទះនោះ ពួកក្មេងអ្នកស្រុករមែងលេងល្បែងក្នាល់" ហើយបានហាមទីទាំងពួងនោះឯង ។ គ្រានោះនាងកុលធីតាទើបឲ្យនាងយក្ខិនីនោះស្នាក់នៅក្នុង ទីដែលស្ងាត់ខាងក្រៅស្រុក ហើយនាំភោជន មានបបរ និងបាយជាដើមយ៉ាងល្អទៅឲ្យនាងយក្ខិនីនោះរក្សាឲ្យនៅក្នុងទីនោះឯង ។ នាងយក្ខិនីគិតយ៉ាងនេះថា "ម្តងនេះ មិត្តស្រីរបស់យើងជាអ្នកមានឧបការៈដល់យើងច្រើន យើងនឹងធ្វើការតបគុណដល់នាង ដូច្នេះ ហើយបានប្រាប់ដល់នាងជាមិត្តថា ក្នុងឆ្នាំនេះ មានភ្លៀង

ល្អ នាងចូរធ្វើស្រូវក្នុងទីទួលចុះ ក្នុងឆ្នាំនេះមិនមានភ្លៀង នាងចូរធ្វើស្រូវក្នុងទីទំនាបចុះ ។ ស្រូវដែលពួកជនដ៏សេសធ្វើហើយ រមែងវិនាសដោយទឹកច្រើនខ្លះ ដោយទឹកតិចខ្លះ ។ ចំណែកស្រូវរបស់នាងកុលធីតានោះ រមែងបរិបូណ៌ដោយលើសលុប ។ គ្រានោះ ពួកជនដ៏សេសទាំងនោះនាំគ្នាសួរនាងថា "នាង ស្រូវដែលនាងធ្វើហើយ រមែងមិនវិនាសដោយទឹកច្រើនខ្លះ រមែងមិនវិនាសដោយទឹកតិចខ្លះ នាងដឹងកាលនៃភ្លៀងធ្លាក់ និងភ្លៀងមិនធ្លាក់ឬ ទើបធ្វើការងារ" ។ សេចក្ដីនេះយ៉ាងណាហ្ន៎ ។ នាងប្រាប់ថា "នាងយក្ខិនីជាសំឡាញ់របស់ខ្ញុំ ប្រាប់កាលនៃភ្លៀងធ្លាក់ និងភ្លៀងមិនធ្លាក់ដល់ខ្ញុំ ខ្ញុំធ្វើស្រូវទាំងឡាយក្នុងទីទួល និងទីទំនាប់តាមពាក្យរបស់នាងយក្ខនោះ ព្រោះហេតុនោះ ស្រូវរបស់ខ្ញុំទើបបរិបូណ៌ ពួកលោកមិនឃើញភោជនមានបបរ និងបាយជាដើម ដែលខ្ញុំនាំទៅអំពីផ្ទះជានិច្ចជាកាលទេឬ វត្ថុទាំងអស់នោះ ខ្ញុំនាំទៅឲ្យនាងយក្ខជាសំឡាញ់នោះឯង សូម្បីពួកលោកក៏ចូរនាំភោជនមានបបរ និងបាយជាដើមយ៉ាងល្អៗ ទៅឲ្យនាងយក្ខផងចុះ នាងយក្ខនឹងមើលការងាររបស់ពួក" ។ គ្រានោះ ពួកជនក្នុងស្រុកនាំគ្នាធ្វើ

*សក្ការៈដល់នាងយក្ខិនីនោះឯង ។ តអំពីនោះមក នាងយក្ខិនីបានជួយរក្សាការងារទាំងឡាយរបស់ជនទាំងពួង បានជាអ្នកមានលាភដ៏ច្រើន និងមានបរិវារដ៏ច្រើន ។ ចាំតាំងអំពីនោះមក នាងយក្ខនោះផ្ដើមធ្វើសលាកកត្ត ៨ កន្លែង ។ សលាកកត្តនោះ ជនទាំងឡាយបានថ្វាយរហូតមកដល់សព្វថ្ងៃនេះឯង ។*

ចប់រឿងនាងយក្ខិនី

# ៥ រឿងភិក្ខុអ្នកក្រុងកោសម្ពី

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកអ្នកស្រុកកោសម្ពី ត្រាស់ព្រះធម្មទេសនានេះថា **បរេ ន ច វិជានន្តិ (ពួកជនដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួន)** ជាដើម ។

សេចក្តីពិស្តារថា ភិក្ខុ ២ រូប គឺ ព្រះវិន័យធរ ១ រូប ព្រះធម្មកថិក ១ រូប មានបរិវារមួយរូបៗ ៥០០ បាននៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ ថ្ងៃមួយ ក្នុងភិក្ខុ ២ រូបនោះ ព្រះធម្មកថិកទៅបង្គន់ បានបន្សល់ទឹកទុកក្នុងភាជនៈត្រង់ទ្វារបង្គន់ហើយចេញមក ។ ក្រោយមកព្រះវិន័យធរ ចូលទៅត្រង់ទ្វារបង្គន់នោះ ឃើញទឹកនោះ ចេញមកសួរព្រះធម្មកថិកថា "អ្នកមានអាយុលោកបន្សល់ទឹកនេះឬ" ។

ធម្ម. ករុណា លោកមានអាយុ ។

វិ. ក៏លោកមិនដឹងថាអាបត្តិ ព្រោះការបន្សល់ទឹកទុកទេឬ ។

ធម្ម. ករុណា ខ្ញុំមិនដឹង ។

វិ. មិនដឹងក៏ហើចុះ អ្នកមានអាយុ នេះជាអាបត្តិក្នុងប្រការនេះ ។

ធម្ម. បើដូច្នោះ ខ្ញុំនឹងសំដែងអាបត្តិនោះចេញ ។

វិ. អ្នកមានអាយុ បើសេចក្តីនោះលោកមិនពេញចិត្តធ្វើ ព្រោះការមិនមានសតិ មិនជាអាបត្តិ ។

ព្រះធម្មកថិកនោះយល់ថា អាបត្តិ មិនមែនជាអាបត្តិ ។ ចំណែកព្រះវិន័យធរ បានប្រាប់ដល់ពួកនិស្សិតរបស់ខ្លួនថា "ព្រះធម្មកថិករូបនោះសូម្បីត្រូវអាបត្តិក៏មិនដឹង" ។ ពួកនិស្សិតរបស់ព្រះវិន័យធរនោះ ឃើញពួកនិស្សិតរបស់ព្រះធម្មកថិកនោះហើយ បានពោលថា "ព្រះឧបជ្ឈាយ៍ របស់ពួកលោក សូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថាជាអាបត្តិ" ។ ពួកនិស្សិតរបស់ព្រះធម្មកថិកនោះ បានប្រាប់ដល់ព្រះឧបជ្ឈាយ៍របស់ខ្លួន ។ ព្រះធម្មកថិកនោះពោលយ៉ាងនេះថា "ព្រះវិន័យធររូបនេះ កាលមុននិយាយថា មិនជាអាបត្តិ តែឥឡូវនេះនិយាយថា ជាអាបត្តិ ព្រះវិន័យធរនោះ និយាយមុសា" ។ ពួកនិស្សិតរបស់ព្រះធម្មកថិកនោះបានពោលថា "ព្រះឧបជ្ឈាយ៍របស់ពួកលោកនិយាយមុសា" ។ ពួកនិស្សិតរបស់ព្រះវិន័យធរ និងរបស់ព្រះធម្មកថិកនោះ ធ្វើការទាស់ទែងគ្នានឹងគ្នាឲ្យចម្រើនឡើង ដោយប្រការ

យ៉ាងនេះ ។ ក្រោយមក ព្រះវិន័យធរបានឱកាស ទើបបានធ្វើឧក្ខេប-នីយកម្ម (កម្មដែលសង្ឃគប្បីធ្វើដល់ភិក្ខុដែលសង្ឃហាមការគប់រក) ដល់ព្រះធម្មកថិក ព្រោះទោសដែលមិនឃើញអាបត្តិ ។ ក្នុងកាលនោះ សូម្បីពួកឧបដ្ឋាកដែលថ្វាយបច្ច័យបួនដល់ភិក្ខុ ២ រូបនោះ ក៏បានបែកជា ២ ចំណែក ។ ពួកភិក្ខុនីអ្នកទទួលឱវាទក្តី ពួកអារក្ខទេវតាក្តី[១] ពួកអាកាស-ដ្ឋទេវតាក្តី[២] ដែលជាសំឡាញ់របស់អារក្ខទេវតាទាំងនោះក្តី ពួកបុថុជ្ជនទាំងអស់រហូតដល់ព្រហ្មលោកក្តី ក៏បែកជា ២ ចំណែក ។ សភាពកោ-លាហលក៏កកងមានសំឡេងតែមួយ ប្រព្រឹត្តទៅរហូតដល់អកនិដ្ឋភព ។

## ព្រះសាស្តាត្រាស់ទូន្មានឱ្យសាមគ្គីគ្នា

គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះសាស្តា ក្រាបទូលការឃើញរបស់ពួកភិក្ខុអ្នកលើកវត្តថា "ព្រះធម្មកថិករូបនេះ ត្រូវសង្ឃលើកវត្តហើយដោយកម្មដែលត្រូវតាមធម៌នោះឯង" និងការដែលឃើញរបស់ពួកភិក្ខុអ្នកប្រព្រឹត្តតាមធម្មកថិកអ្នកដែលត្រូវសង្ឃលើកវត្តហើយថា "ព្រះឧបជ្ឈាយ៍

---

១. ទេវតាអ្នកគ្រប់គ្រងថែរក្សា ២. ទេវតាអ្នកស្ថិតនៅក្នុងអាកាស ។

របស់ពួកយើងត្រូវសង្ឃលើកវត្តហើយ ដោយកម្មមិនត្រូវតាមធម៌” និង ដែលពួកភិក្ខុអ្នកប្រព្រឹត្តតាមទាំងនោះ សូម្បីត្រូវពួកភិក្ខុលើកវត្តហាមហើយ ក៏ចូលដៃដើរតាមហែហមព្រះធម្មកថិកនោះ ។ ព្រះមានព្រះភាគទ្រង់បញ្ជូនឱវាទទៅថា “ន័យថា ម្នាលភិក្ខុទាំងឡាយ ចូរព្រមព្រៀងគ្នា” សូម្បី ២ ដង ទ្រង់ជ្រាបថា “បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយនឹងមិនប្រាថ្នាជាអ្នកព្រមព្រៀងគ្នាទេ” ក្នុងលើកទី ៣ ទ្រង់ជ្រាបថា “ភិក្ខុសង្ឃបែកគ្នាហើយ ភិក្ខុសង្ឃបែកគ្នាហើយ” ទើបស្តេចទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយនោះ ត្រាស់ទោសក្នុងការលើកវត្តរបស់ពួកភិក្ខុអ្នកលើកវត្ត និងទោសក្នុងការមិនឃើញអាបត្តិរបស់ពួកភិក្ខុក្រៅពីនេះ ទើបទ្រង់អនុញ្ញាតសង្ឃកម្មទាំងឡាយ មានឧបោសថជាដើមក្នុងសីមាជាមួយគ្នា ត្រង់ឃោសិតារាមនោះឯង ដល់ភិក្ខុទាំងឡាយទៀត ហើយទ្រង់បញ្ញត្តិវត្តក្នុងរោងឆាន់ថា “ម្នាលភិក្ខុទាំងឡាយ គប្បីអង្គុយក្នុងជួរមានអាសនៈមួយៗ ក្នុងចន្លោះៗ[១] ដូច្នេះជាដើម ដល់ភិក្ខុទាំងឡាយដែលកើតការបែកបាក់គ្នាក្នុងទីទាំងឡាយ

---

១. អង្គុយជាជួរ ទុកចន្លោះឱ្យភិក្ខុដទៃជ្រៀតចូលអង្គុយចានមួយរូប ។ ក្នុងចន្លោះ ។

មានភេទដាច់ជាដើម ហើយទ្រង់ស្ដាប់ថា "សូម្បីម្ដងនេះ ភិក្ខុទាំងឡាយ ក៏នៅតែមានការបែកបាក់គ្នា" ទើបស្ដេចយាងទៅកាន់ភេទដាច់ជាដើមនោះ ហើយត្រាស់ហាមថា "កុំឡើយ ភិក្ខុម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំមានការបែកបាក់គ្នា" ជាដើម ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាការបែកបាក់គ្នា ការឈ្លោះគ្នា ការមិនចុះសម្រុងគ្នា និងការវិវាទគ្នានោះ រមែងធ្វើសេចក្ដីវិនាសឲ្យដោយពិត សូម្បីនាងបក្សីនកលដ្ដុកិកា[១] អាស្រ័យការឈ្លោះគ្នា អាចធ្វើស្ដេចដំរីឲ្យដល់នូវសេចក្ដីស្លាប់បាន" ហើយត្រាស់លដ្ដុកិកជាតក[២] ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូមពួកអ្នកចូលព្រមព្រៀងគ្នាចុះ កុំវិវាទគ្នាឡើយ ព្រោះថា សូម្បីសត្វចាបទាំងឡាយច្រើនពាន់ អាស្រ័យការវិវាទគ្នា ក៏បានដល់នូវការអស់ជីវិត" ហើយទ្រង់ត្រាស់វដ្ដកជាតក[៣] ។

លុះពួកភិក្ខុទាំងនោះ មិនជឿ មិនស្ដាប់ព្រះតម្រាស់សូម្បីយ៉ាងនេះ

---

១. សត្វចាបចៀបកប្បាស ២. ខុទ្ទកនិកាយ ជាតក បញ្ចកនិបាត តនដ្ឋកថា ។
៣. ខុទ្ទកនិកាយ ជាតក ឯកនិបាត គួរដាសមោទមានជាតក ។

កាលភិក្ខុអ្នកជាធម្មវាទីរូបណាមួយ មិនប្រាថ្នាឲ្យព្រះតថាគតទ្រង់លំបាក ក៏ក្រាលទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ជាម្ចាស់នៃធម៌ ទ្រង់រង់ចាំសិន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់មានសេចក្ដីខ្វល់ខ្វាយតិច ទ្រង់ប្រកបដោយធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ចុះ ពួកខ្ញុំព្រះអង្គនឹងប្រាកដ (បានទទួលផល) ព្រោះការបែកបាក់ ការឈ្លោះ ការមិនចុះសម្រុង និងការវិវាទគ្នានោះ" ។ ព្រះមានព្រះភាគត្រាស់ដល់រឿងដែលព្រះបាទទីឃីតិកោសលរាជ ត្រូវព្រះបាទព្រហ្មទត្តដណ្ដើមយករាជសម្បត្តិ បន្ទំខ្លួនមិនឲ្យអ្នកណាដឹងថាជាស្ដេច ហើយចាប់ផ្ដាច់ព្រះជន្មនិងព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារទាំងនោះព្រមព្រៀងគ្នា ផ្ដើមពីកាលទីឃាវុកុមារថ្វាយព្រះជន្មរបស់ព្រះអង្គវិញ ថា "ម្នាលភិក្ខុទាំងឡាយ រឿងនេះធ្លាប់មានមកហើយ ក្នុងក្រុងពារាណសី មានព្រះរាជាក្រុងកាសី (មួយព្រះអង្គ) ទ្រង់ព្រះនាមថា ព្រហ្មទត្ត" ដូច្នេះជាដើម សូម្បីត្រាស់ទូន្មានថា "ម្នាលភិក្ខុទាំងឡាយ សេចក្ដីអត់ធន់ និងសេចក្ដីស្ងប់ស្ងៀមបែបនោះ មានហើយដល់ព្រះរាជាទាំងនោះ អ្នកមានអាជ្ញាកាន់ទុកហើយ អ្នកមានសស្ត្រា

កាន់ទុកហើយ សភាពដែលអ្នកទាំងឡាយបួសហើយក្នុងធម្មវិន័យ ដែលពោលល្អយ៉ាងនេះ គួរជាអ្នកអត់ធន់ ជាអ្នកស្ងប់ស្ងៀម និងគប្បីប្រព្រឹត្តស្អាតក្នុងធម្មវិន័យនេះឯង” ដូច្នេះ ក៏មិនអាចនឹងធ្វើភិក្ខុទាំងឡាយឲ្យព្រមព្រៀងគ្នាបានឡើយ ។

ព្រះអង្គទ្រង់នឿយណាយព្រះទ័យ ព្រោះការនៅក្នុងសភាពប្រចបូកប្រចល់នោះ ទ្រង់មានព្រះតម្រិះថា “ឥឡូវនេះ តថាគតនៅដោយការប្រចបូកប្រចល់រមែងលំបាក ទាំងភិក្ខុពួកនេះមិនតាមពាក្យរបស់តថាគត បើដូច្នោះតថាគតគប្បីចៀសចេញពីពួកភិក្ខុទាំងនេះនៅតែម្នាក់ឯង” ដូច្នេះ ស្ដេចត្រាច់បិណ្ឌបាតក្នុងក្រុងកោសម្ពី មិនត្រាស់ប្រាប់ដល់ព្រះភិក្ខុសង្ឃ ទ្រង់ប្រដាប់បាត្រ និងចីវររបស់ព្រះអង្គ ស្ដេចយាងទៅពាលកលោណការាមតែមួយព្រះអង្គឯង ត្រាស់ឯកចារិកវត្ត (វត្តបដិបត្តិរបស់ភិក្ខុអ្នកនៅម្នាក់ឯង) ដល់ព្រះភគុថេរៈត្រង់ពាលកលោណការាមនោះហើយ ត្រាស់អានិសង្សនៃការសាមគ្គីដល់កុលបុត្រ ៣ នាក់ ត្រង់មិគទាយវ័ន[១] ឈ្មោះបាចីនវង្សៈ ហើយ

---

១. ព្រៃដែលប្រទានឲ្យពួកម្រឹគអាស្រ័យនៅ ព្រៃប្រភេទនេះ នរណាក៏ធ្វើអន្តរាយដល់ពួកសត្វមិនបាន ។

ស្ដេចយាងទៅតាមផ្លូវស្រុកបារិលេយ្យកៈ ។ ដូចបានស្ដាប់មក គ្រានោះ ព្រះមានព្រះភាគទ្រង់អាស្រ័យស្រុកបារិលេយ្យកៈ ដែលបានដំរីបារិលេ-យ្យកៈឧបដ្ឋាក ស្ដេចចាំវស្សាគង់នៅជាសុខត្រង់គល់ដើមសាលព្រឹក្សធំ ក្នុងដងព្រៃរក្ខិតវ័ន ។

ចំណែកពួកឧបាសកឧបាសិកា អ្នកនៅក្នុងស្រុកកោសម្ពី ទៅកាន់វិហារមិនឃើញព្រះសាស្ដា ទើបសួរថា លោកម្ចាស់ដ៏ចម្រើន ព្រះសាស្ដាស្ដេចនៅទីណា ។ ភិក្ខុទាំងឡាយនោះពោលថា ព្រះអង្គស្ដេចទៅកាន់ព្រៃបារិលេយ្យកៈហើយ ។

ឧបា. ព្រោះហេតុអ្វី លោកម្ចាស់ ។

ភិ. ព្រះអង្គទ្រង់ព្យាយាមនឹងធ្វើពួកយើងឲ្យព្រមព្រៀងគ្នា តែពួកយើងមិនព្រមព្រៀងគ្នា ។

ឧបា. បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយបួសក្នុងសំណាក់របស់ព្រះសាស្ដាហើយ សូម្បីព្រះអង្គទ្រង់សមានសាមគ្គីហើយ ក៏មិនបានជាអ្នកសាមគ្គីគ្នាទៀតឬ ។

ភិ. យ៉ាងនោះហើយ អ្នកមានអាយុ ។

ពួកមនុស្សគិតគ្នាថា "ភិក្ខុពួកនេះ បួសក្នុងសំណាក់របស់ព្រះសាស្តាហើយ កាលព្រះអង្គទ្រង់សមានសាមគ្គី ក៏មិនអាចសាមគ្គីគ្នាបាន ពួកយើងមិនបានឃើញព្រះសាស្តា ព្រោះអាស្រ័យពួកភិក្ខុទាំងនេះ ពួកយើងនឹងមិនថ្វាយអាសនៈ នឹងមិនធ្វើសាមីចិកម្ម មានការសំពះជាដើមដល់ពួកភិក្ខុពួកនេះ" ដូច្នេះ ចាប់តាំងពីនោះមក ក៏មិនធ្វើសូម្បីតែសាមីចិកម្មដល់ភិក្ខុពួកនោះ ។ ភិក្ខុទាំងឡាយស្គមស្គាំងព្រោះមានអាហារតិច ត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ ក៏ជាអ្នកត្រង់ សំដែងទោសដែលកន្លងល្មើសដល់គ្នានឹងគ្នា ភិក្ខុផ្សេងទៀតក៏សូមទោស ហើយពោលថា "ឧបាសកឧបាសិកាទាំងឡាយ ពួកយើងសាមគ្គីគ្នាហើយ ចំណែកពួកលោក សូមឲ្យជាដូចដើមដល់ពួកយើង ។

ឧបា. លោកម្ចាស់ដ៏ចម្រើន ពួកលោកទូលសូមទោសព្រះសាស្តាហើយឬ ។

ភិក្ខុ. មិនទាន់បានទូលសូមទោសនៅឡើយទេ អ្នកមានអាយុ ។

ឧបា. បើដូច្នោះ សូមពួកលោកចូរទូលសូមទោសព្រះសាស្តា ចំណែកពួកខ្ញុំម្ចាស់នឹងជាដូចដើមចំពោះលោកម្ចាស់វិញ ក្នុងកាលពួកលោកម្ចាស់ទូលសូមទោសព្រះសាស្តាហើយ ។

ភិក្ខុទាំងឡាយ មិនអាចទៅកាន់សំណាក់របស់ព្រះសាស្តាបាន ព្រោះនៅក្នុងវស្សា ព្រោះក្នុងវស្សានោះទៅដោយលំបាក ។

## ដំរីចារិលេយ្យកៈឧបដ្ឋាកព្រះសាស្តា

ចំណែកព្រះសាស្តាទ្រង់បានដំរីនោះឧបដ្ឋាកហើយ ប្រថាប់គង់នៅជាសុខ ។ ឯដំរីនោះ លះបង់ហ្វូងចូលទៅកាន់ដងព្រៃនោះ ដើម្បីត្រូវការនៅជាសុខ ។ ព្រះធម្មសង្គាហកាចារ្យពោលទុកយ៉ាងណា ។ លោកពោលទុកថា (គ្រានោះ សេចក្តីត្រិះរិះបានមានដល់ស្តេចដំរីនោះថា) "យើងនៅប្រឡូកប្រឡល់ដោយពួកដំរីឈ្មោល ដំរីញី ដំរីស្ទាវ និងកូនដំរី ទំពាស៊ីនូវស្មៅដែលមានចុងរិចហើយ និងពួកគេរង់ចាំស៊ីមែកឈើ ដែលយើងកាច់ឲ្យ និងយើងផឹកទឹកដែលល្អក់ កាលយើងចុះ និងឡើងពីកំពង់ ពួកដំរីញីដែលខ្លួនប្រឡាក់ដោយភក់មកត្រដុសនឹងកាយយើង បើដូច្នោះ យើងនឹង

ចៀសចេញពីពួកនៅតែម្នាក់ឯង ។ គ្រានោះឯង ស្តេចដំរីនោះគេចចេញចាកហ្វូងដំរី ចូលទៅនៅស្រុកបារិលេយ្យកៈ នាដងព្រៃរក្ខិតវ័ន ក្រោមដើមសាលព្រឹក្សធំ ត្រង់កន្លែងដែលព្រះមានព្រះភាគស្តេចប្រថាប់នៅ លុះចូលទៅហើយ ថ្វាយបង្គំព្រះមានព្រះភាគ ក្រឡេកមើលមិនឃើញមានវត្ថុអ្វីៗដទៃ ទើបឈូសពង្រាបត្រង់គល់សាលព្រឹក្សដោយជើង ឲ្យរាបរាយ យកប្រមោយចាប់មែកឈើបោសសំអាត តាំងពីនោះមក ស្តេចដំរីនោះយកប្រមោយចាប់ឆ្នាំងដងទឹកឆាន់ ទឹកប្រើមកតម្កល់ទុក កាលទ្រង់ព្រះបំណងដោយទឹកក្តៅ ក៏ចាត់ចែងទឹកក្តៅថ្វាយ ។ ស្តេចដំរី នោះចាត់ចែងទឹកក្តៅបានយ៉ាងណា ។ ស្តេចដំរីនោះយកប្រមោយចាប់ឈើស្ងួតមកកួតឲ្យមានភ្លើង ដាក់ឧសឲ្យជាភ្នក់ភ្លើង ដុតសិលាក្នុងគំនរភ្លើងនោះ ហើយប្រមៀលដុំសិលានោះដោយកំណាត់ឈើ ទម្លាក់ចុះក្នុងត្រពាំងតូច ដែលបានកំណត់ទុក តមក ក៏យកប្រមោយជ្រលក់ចុះទៅដឹងថា ទឹកក្តៅហើយ ទើបទៅថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា "បារិលេយ្យកៈ អ្នកដាំទឹកហើយឬ ដូច្នេះ ទើបបានស្តេចយាងទៅស្រង់ក្នុងទីនោះ ។ ក្នុងកាលនោះ

ស្ដេចដំរីនោះនាំផ្លែឈើផ្សេងៗ មកថ្វាយចំពោះព្រះសាស្ដា ។ ក៏កាលព្រះសាស្ដាស្ដេចចូលកាន់ស្រុកដើម្បីបិណ្ឌបាត្រ ស្ដេចដំរីនោះកាន់បាត្រ ចីវររបស់ព្រះសាស្ដាទុកលើ (ខ្នង) តាមព្រះសាស្ដាទៅ ។ ព្រះសាស្ដាស្ដេចយាងទៅដល់ដែនស្រុកហើយត្រាស់ថា "បារិលេយ្យក: តាំងពីនេះ អ្នកមិនអាចទៅបានទេ អ្នកចូរយកបាត្រចីវររបស់តថាគតមក ហើយឲ្យស្ដេចដំរីនោះយកបាត្រចីវរមកថ្វាយ ស្ដេចយាងចូលកាន់ស្រុកដើម្បីបិណ្ឌបាត្រ ។ ចំណែកស្ដេចដំរីនោះ ឈរនៅទីនោះឯងរហូតដល់ព្រះសាស្ដា ស្ដេចយាងចេញមក ក្នុងវេលាដែលព្រះសាស្ដាស្ដេចយាងចេញមក ធ្វើការក្រោកទទួលហើយកាន់បាត្រចីវរ ដូចន័យមុននោះឯង (នាំទៅ) ដាក់ចុះត្រង់ទីប្រថាប់ហើយសំដែងវត្ត បក់ថ្វាយដោយមែកឈើ ។ ការពារអន្តរាយអំពីសត្វកាចក្នុងរាត្រី ស្ដេចដំរីនោះយកប្រមោយចាប់កំណាត់ឈើធំ ត្រាច់ទៅក្នុងចន្លោះៗ នៃដងព្រៃរហូតដល់អរុណរះឡើង ដោយតាំងចិត្តថា "យើងនឹងរក្សាព្រះសាស្ដា" ។ បានឮថា ដងព្រៃនោះឈ្មោះថា រក្ខិតវនសណ្ឌ: តាំងពីកាលនោះមក ។ ពេលអរុណរះឡើងហើយ ស្ដេចដំរីនោះ ធ្វើវត្តទាំង

ពួនដោយឧបាយនោះឯង តាំងពីការថ្វាយទឹកលប់ព្រះភ័ក្ត្រ ។

គ្រានោះ ស្វាមួយបានឃើញដំរីនោះខ្នះខ្នែង ធ្វើអភិសមាចារវត្ត (គឺការបដិបត្តិ) ចំពោះព្រះសាស្តាហើយ គិតថា "សូម្បីយើងក៏នឹងធ្វើអ្វីៗថ្វាយខ្លះ" ត្រាច់ទៅអស់មួយថ្ងៃ ឃើញសំបុកឃ្មុំត្រង់មែកឈើមិនមានរមេ ក៏កាច់មែកឈើ ហើយនាំសំបុកឃ្មុំព្រមទាំងមែកឈើទៅកាន់សំណាក់ព្រះសាស្តា បានក្តិចស្លឹកចេកទ្រាប់ថ្វាយ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ ពានរក្រឡេកឃើញ បានគិតថា "ព្រះសាស្តាទ្រង់ធ្វើការសោយឬទេ" ឃើញព្រះសាស្តាទ្រង់ទទួលហើយគង់ស្ងៀម គិតថា "មានហេតុអ្វីហ្ន៎" ទើបចាប់ចុងមែកឈើត្រឡប់មើល ឃើញកូនឃ្មុំហើយ ទើបថ្នមៗ នាំកូនឃ្មុំទាំងនោះចេញ ទើបបានថ្វាយជាថ្មី ។ ព្រះសាស្តាទ្រង់សោយហើយ ។ ពានរនោះមានចិត្តរីករាយ បានចាប់មែកឈើនោះៗ ឈររាំ ។ ក្នុងកាលនោះ មែកឈើដែលពានរនោះចាប់ហើយក្តី មែកឈើដែលពានរនោះជាន់លើហើយក្តី ក៏បានបាក់ ។ ពានរនោះធ្លាក់ចុះត្រង់ចុងជន្លត់មួយ ត្រូវចុងជន្លត់មុតជាប់ ទាំងចិត្តកំពុងជ្រះថ្លាក៏ធ្វើកាលកិរិយាទៅ បានទៅកើតនៅ

ក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ ក្នុងភពតាវត្តឹង្ស មានទេពអប្សរជាបរិវារមួយពាន់ ។

ព្រះសាស្ដាដែលបានស្ដេចដំរីឧបដ្ឋាក ប្រថាប់នៅក្នុងដងព្រៃរក្ខិតវននោះ ក៏បានប្រាកដក្នុងជម្ពូទ្វីបទាំងមូល ។ ត្រកូលធំៗ ជាដើមយ៉ាងនេះគឺ លោកសេដ្ឋីអនាថបិណ្ឌិកៈ និងនាងវិសាខាមហាឧបាសិកា បានបញ្ជូនដំណឹងពីនគរសាវត្ថីទៅដល់ព្រះអានន្ទត្ថេរថា បពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់ ចូរសំដែងព្រះសាស្ដាដល់ពួកខ្ញុំព្រះអង្គ ។ ចំណែកភិក្ខុ ៥០០ រូប អ្នកនៅក្នុងទិស ចេញវស្សាហើយចូលទៅរកព្រះអានន្ទត្ថេរ អង្វរសូមថា "អានន្ទដ៏មានអាយុ ធម្មីកថាចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគ ខ្ញុំទាំងឡាយខានបានស្ដាប់យូរមកហើយ អានន្ទដ៏មានអាយុ សូមឱកាស ខ្ញុំទាំងឡាយគប្បីបានស្ដាប់ធម្មីកថាក្នុងទីចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគផងចុះ" ។ ព្រះថេរៈនាំភិក្ខុទាំងនោះទៅក្នុងទីនោះ ហើយគិតថា "ការចូលទៅកាន់សំណាក់ព្រះតថាគត ស្ដេចនៅមួយព្រះអង្គឯងរហូតត្រៃមាស ព្រមជាមួយភិក្ខុមានប្រមាណប៉ុណ្ណេះ មិនសមគួរ" ដូច្នេះ ទើបនាំភិក្ខុទាំងនោះឲ្យ

ចាំនៅខាងក្រៅ ហើយចូលទៅគាល់ព្រះសាស្តាតែមួយអង្គឯងប៉ុណ្ណោះ ។ ស្តេចដំរីបារិលេយ្យកៈ ឃើញព្រះអានន្ទត្ថេរហើយ ចាប់កំណាត់ឈើរត់ទៅរក ។ ព្រះសាស្តាទត្តឃើញហើយ ត្រាស់ថា ឈប់បារិលេយ្យកៈ កុំឃាត់ឡើយ ភិក្ខុនោះជាពុទ្ធុបដ្ឋាក" ។ ស្តេចដំរីបារិលេយ្យកៈ ទម្លាក់កំណាត់ឈើចោលនៅក្នុងទីនោះឯង ហើយបានសម្តែងអាការអើពើ ដល់ការទទួលបាត្រចីវរ ។ ព្រះថេរៈមិនបានឲ្យទេ ។ ស្តេចដំរីគិតថា "បើភិក្ខុរូបនេះ មានវត្តដែលបានរៀនហើយ លោកនឹងមិនដាក់បរិក្ខាររបស់ខ្លួនទុកលើផែនសិលា ទីប្រថាប់របស់ព្រះសាស្តាឡើយ" ។ ព្រះថេរៈបានដាក់បាត្រចីវរទុកលើផ្ទៃដីហើយ ។ ពិតហើយ បុគ្គលអ្នកដល់ព្រមហើយដោយវត្តរមែងមិនដាក់បរិក្ខាររបស់ខ្លួនទុកលើទីអង្គុយ ឬលើទីដេករបស់គ្រូ ។ ស្តេចដំរីឃើញអាការនោះ ក៏មានចិត្តជ្រះថ្លា ។ ព្រះថេរៈ អភិវាទព្រះសាស្តាហើយ អង្គុយនៅក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាត្រាស់សួរថា អានន្ទអ្នកមកតែម្នាក់ឯងទេឬ ទ្រង់ស្តាប់ថា ព្រះថេរៈមកព្រមជាមួយភិក្ខុ ៥០០ រូប ហើយត្រាស់ថា ក៏ភិក្ខុទាំងនោះនៅទីណា កាលព្រះថេរៈទូលថា ខ្ញុំ

ព្រះអង្គមិនជ្រាបទឹកព្រះទ័យរបស់ព្រះអង្គ ទើបឲ្យភិក្ខុទាំងឡាយឈប់ចាំខាងក្រៅ ហើយចូលមកតែម្នាក់ឯង ។ ត្រាស់ថា ហៅភិក្ខុទាំងឡាយមកចុះ ។ ព្រះថេរៈបានធ្វើតាមព្រះតម្រាស់ហើយ ។ ភិក្ខុទាំងនោះមកថ្វាយបង្គំព្រះសាស្ដា ហើយអង្គុយនៅក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈទទួលភិក្ខុទាំងឡាយហើយ កាលភិក្ខុទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគព្រះអង្គទ្រង់ប្រកបដោយសុខមាលជាតិនិងជាក្សត្រិយសុខមាលជាតិ ព្រះអង្គស្ដេចប្រថាប់ឈរ និងប្រថាប់គង់មួយព្រះអង្គឯងអស់ត្រៃមាស ធ្វើកិច្ចដែលធ្វើបានដោយលំបាក អ្នកធ្វើវត្តតូចធំក្ដី អ្នកថ្វាយទឹកលប់ព្រះភ័ក្ត្រក្ដី សូម្បីតែម្នាក់ក៏មិនមានឡើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងពួងរបស់តថាគត ស្ដេចដំរីបារិលេយ្យកៈធ្វើហើយ ក៏បុគ្គលដែលបានមិត្តបែបនេះ នៅជាមួយគ្នាគួរហើយ កាលមិនបានមិត្ត (បែបនេះ) ភាពជាអ្នកត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះប្រសើរជាង ហើយបានភាសិត ៣ គាថា ក្នុងនាគវគ្គទាំងនេះថា ៖

បើបុគ្គលបានសំឡាញ់អ្នកមានបញ្ញារក្សាខ្លួន មានបញ្ញា

ជាគ្រឿងចងចាំ មានគុណធម៌ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេច ទុកជាអ្នកត្រាច់ទៅជាមួយគ្នាសោត (បុគ្គលអ្នកបានសំឡាញ់បែបនោះ) គួរមានចិត្តត្រេកអរ មានសតិគ្របសង្កត់អន្តរាយ ដែលធ្លាប់បៀតបៀនជុំវិញទាំងពួងបានហើយ ត្រាច់ទៅជាមួយសំឡាញ់នោះ បើបុគ្គលមិនបានសំឡាញ់អ្នកមានបញ្ញារក្សាខ្លួន មានបញ្ញាជាគ្រឿងចងចាំ មានគុណធម៌ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេច ទុកជាត្រាច់ទៅជាមួយគ្នាសោត បុគ្គលនោះគួរតែត្រាច់ទៅតែម្នាក់ឯង ដូចព្រះរាជាទ្រង់លះដែនដែលព្រះអង្គទ្រង់ឈ្នះហើយ ស្តេចនៅតែម្នាក់ឯង (និង) ដូចស្តេចដំរីឈ្មោះថាមាតង្គៈត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ការត្រាច់ទៅតែម្នាក់ឯងប្រសើរជាង (ព្រោះថា) ភាពជាមិត្តមិនមានក្នុងជនពាល បុគ្គលមិនបានសំឡាញ់បែបនោះ គួរមានសេចក្តីខ្វល់ខ្វាយតិច ត្រាច់ទៅតែម្នាក់ឯង និងមិនគួរធ្វើបាបទាំង

ឡាយ ដូចស្តេចដំរីឈ្មោះមាតង្គៈ ដែលមានសេចក្តីខ្វល់
ខ្វាយតិច ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង មិនបានធ្វើបាប ។

ក្នុងកាលចប់គាថា ភិក្ខុទាំង ៥០០ រូប ក៏តាំងនៅក្នុងព្រះអរហត្ត ។ ព្រះអានន្ទត្ថេរ ក្រាបទូលដំណឹងដែលត្រកូលធំៗ មានអនាថបិណ្ឌិកសេដ្ឋីជាដើមបញ្ជូនមកហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវក ៥ កោដិ មានអនាថបិណ្ឌិកសេដ្ឋីជាប្រធាន រង់ចាំការស្តេចយាងរបស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ អ្នកចូរទទួលបាត្រចីវរ ហើយឲ្យព្រះថេរៈទទួលបាត្រចីវរ ស្តេចក៏យាងចេញទៅ ។ ស្តេចដំរីបានទៅឈរឃាំងផ្លូវ ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ក៏ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ស្តេចដំរីធ្វើអ្វី ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំរីប្រាថ្នានឹងថ្វាយភិក្ខារដល់អ្នកទាំងឡាយ ក៏ស្តេចដំរីនេះបានធ្វើឧបការៈដល់តថាគតអស់កាលដ៏យូរ ការធ្វើចិត្តរបស់ស្តេចដំរីនេះឲ្យទាស់មិនគួរឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រឡប់ទៅចុះ ។ ព្រះសាស្តាទ្រង់នាំភិក្ខុទាំងឡាយស្តេចយាងត្រឡប់ហើយ ។ ចំណែកស្តេចដំរី

ក៏ចូលទៅកាន់ដងព្រៃ ប្រមូលផ្លែឈើផ្សេងៗ មានផ្លែខ្នុរ និងផ្លែកចេក ជាដើមមក ធ្វើឲ្យជាគំនរទុក ក្នុងពេលអរុណរះឡើង បានថ្វាយដល់ភិក្ខុទាំងឡាយ ។ ភិក្ខុ ៥០០ រូប មិនអាចឆាន់ផ្លែឈើទាំងឡាយអស់បាន ។ ក្នុងកាលសម្រេចភត្តកិច្ច ព្រះសាស្តាទ្រង់ប្រដាប់បាត្រ និងចីវរ ហើយស្តេចចេញទៅ ។ ស្តេចដំរីដើរជែងទៅមុខតាមចន្លោះផ្លូវនៃភិក្ខុទាំងឡាយ បានឈរចំពោះព្រះភក្ត្រព្រះសាស្តា ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ស្តេចដំរីធ្វើអ្វី ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ស្តេចដំរីនេះនឹងជូនពួកអ្នកទៅ តែអង្វរឲ្យតថាគតត្រឡប់ ។

ភិក្ខុ. យ៉ាងនោះឬ ព្រះអង្គ ។

ព្រះសាស្តា. យ៉ាងនោះឯង ភិក្ខុទាំងឡាយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងដំរីនោះថា បារិលេយ្យកៈ នេះជាការទៅមិនត្រឡប់របស់តថាគត ឈានក្តី វិបស្សនាក្តី មគ្គ និងផលក្តី រមែងមិនមានដល់អ្នកដោយអត្តភាពនេះ អ្នកនៅទីនេះចុះ ។ ស្តេចដំរីបាន

ស្ដាប់ព្រះតម្រាស់ដូច្នោះហើយ បានស៊កប្រមោយចូលមាត់ស្រេចយំ ដើរតាមអំពីខាងក្រោយៗ ។ ក៏ស្ដេចដំរីនោះ កាលយាងព្រះសាស្ដាត្រឡប់មិនបាន ក៏បដិបត្តិដោយអាការនោះឯងរហូតអស់ជីវិត ។ ឯព្រះសាស្ដាស្ដេចយាងដល់ដែននៃស្រុកនោះហើយ ត្រាស់ថា បារិលេយ្យកៈ ចាប់អំពីទីនេះទៅ មិនមែនជាដែនរបស់អ្នកឡើយ ជាទីនៅរបស់ពួកមនុស្ស មានអន្តរាយបៀបបៀតដោយជុំវិញ អ្នកចូរឈប់ត្រង់នេះចុះ ។ ដំរីនោះឈរយំនៅក្នុងទីនោះឯង កាលព្រះសាស្ដាទ្រង់ផុតពីគន្លងចក្ខុទៅ ស្ដេចដំរីក៏បែកបេះដូងស្លាប់ បានទៅកើតនៅក្នុងកណ្ដាលនាងទេពអប្សរមួយពាន់ ក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ ក្នុងភពតាវតឹង្ស ព្រោះសេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា ។ ទេវបុត្រនោះមានឈ្មោះថា បារិលេយ្យកទេវបុត្រ ។ ចំណែកព្រះសាស្ដា ស្ដេចយាងដល់វត្តជេតពនហើយដោយលំដាប់ ។

## ភិក្ខុអ្នកក្រុងកោសម្ពីទូលសូមទោសព្រះសាស្ដា

ភិក្ខុអ្នកស្រុកកោសម្ពីស្ដាប់ថា បានឮថា ព្រះសាស្ដាស្ដេចយាងដល់ក្រុងសាវត្ថីហើយ បានទៅកាន់ក្នុងទីនោះ ដើម្បីនឹងក្រាបទូលសូមខមាទោស

ព្រះសាស្តា ។ ស្តេចកោសលស្តាប់ថា បានឮថា ពួកភិក្ខុអ្នកក្រុងកោសម្ពី ជាអ្នកបង្កការបាក់បែកគ្នាទាំងនោះមក ទើបចូលទៅគាល់ព្រះសាស្តា ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនព្រមឲ្យភិក្ខុទាំងនោះចូលមកកាន់ដែនរបស់ខ្ញុំព្រះអង្គឡើយ ។ ព្រះសាស្តាត្រាស់តបថា មហារាជ ភិក្ខុទាំងនោះជាអ្នកមានសីល តែមិនកាន់យកពាក្យរបស់តថាគត ព្រោះវិវាទគ្នានឹងគ្នាប៉ុណ្ណោះ ឥឡូវនេះ ភិក្ខុទាំងឡាយមកដើម្បីសូមខមាទោសតថាគត មហារាជ សូមភិក្ខុទាំងនេះចូលមកចុះ ។ ចំណែកអនាថបិណ្ឌិកសេដ្ឋីទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏មិនព្រមឲ្យភិក្ខុទាំងនោះចូលមកកាន់វិហារ ក៏ត្រូវព្រះសាស្តាទ្រង់ហាមយ៉ាងនោះដូចគ្នា ។ បានអង្គុយហើយ ។ ក៏កាលភិក្ខុទាំងនោះដល់ក្រុងសាវត្ថីតាមលំដាប់ហើយ ព្រះមានព្រះភាគត្រាស់បង្គាប់ឲ្យប្រទានសេនាសនៈនៅក្នុងទីសមគួរមួយ ធ្វើឲ្យជាទីស្ងាត់ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុពួកដទៃមិនអង្គុយ មិនឈរ រួមជាមួយភិក្ខុពួកនោះ ។ ពួកជនដែលមកហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ឯណាពួកភិក្ខុអ្នកក្រុងកោសម្ពី ដែលឈ្លោះទាស់ទែងគ្នា

នោះ ។ ព្រះសាស្តាទ្រង់ត្រាស់ថា "ភិក្ខុពួកនោះ" ។ ភិក្ខុអ្នកក្រុងកោសម្ពី ទាំងនោះត្រូវពួកជនអ្នកមកហើយ ចង្អុលថា បានឮថា នុ៎ះពួកភិក្ខុអ្នកក្រុងកោសម្ពីដែលឈ្លោះទាស់ទែងគ្នា មិនអាចងើបសីសៈឡើង ព្រោះសេចក្តីអៀនខ្មាស ក្រាបចុះទៀបបាទមូលនៃព្រះមានព្រះភាគ ទូលសូមខមាទោសព្រះមានព្រះភាគហើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្វើកម្មធ្ងន់ហើយ ឈ្មោះថា អ្នកទាំងឡាយសូម្បីបួសហើយក្នុងសំណាក់របស់ព្រះពុទ្ធដូចតថាគត កាលតថាគតសមានសាមគ្គី មិនធ្វើ (តាម) ពាក្យរបស់តថាគត ចំណែកបណ្ឌិតដែលមាននៅក្នុងកាលមុន មិនស្តាប់ឱវាទរបស់មាតា និងបិតាអ្នកត្រូវទោសប្រហារជីវិត កាលមាតាបិតានោះសូម្បីត្រូវប្រហារជីវិត ក៏មិនកន្លងឱវាទនោះ ខាងក្រោយមក បានគ្រងរាជសម្បត្តិក្នុងដែន ២ ទើបត្រាស់ទីឃាវុកុមារជាតក[១] ម្តងទៀត ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារ សូម្បីព្រះជនក និងព្រះជននីត្រូវផ្តាច់ព្រះជន្មយ៉ាងនោះ ក៏មិនកន្លងឱវាទរបស់ព្រះជនក និងព្រះជននីទាំងនោះឡើយ ក្រោយមកបានធីតារបស់ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជក្នុង

ដែនកាសី និងដែនកោសលទាំងពីរ ចំណែកពួកអ្នកទាំងឡាយមិនធ្វើតាម ពាក្យរបស់តថាគត ធ្វើកម្មធូន់" ទើបត្រាស់ព្រះគាថានេះថា ៖

បរេ ន ច វិជានន្តិ មយមេត្ថ យមាមសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

ជនទាំងឡាយដទៃ (ក្រៅពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់ អំពីជនទាំងឡាយនោះ ។

## អធិប្បាយគាថា

ក្នុងបទទាំងនោះ បទថា បរេ (ជនពួកដទៃ) ជាដើម សេចក្ដីថា ពួកជនអ្នកធ្វើការឈ្លោះទាស់ទែង វៀរបណ្ឌិតទាំងឡាយចេញ គឺ បុគ្គលដទៃក្រៅអំពីបណ្ឌិតនោះ ឈ្មោះថា ជនពួកដទៃ ។ ជនពួកដទៃនោះ ធ្វើ

សេចក្តីខ្វល់ខ្វាយក្នុងជំនុំសង្ឃនោះ រមែងមិនដឹងថា យើងទាំងឡាយរមែងលំបាក គឺ វិនាស បានដល់ ចូលទៅកាន់ទីជិត គឺ សំណាក់មច្ចុជានិច្ច ។ បទថា **យេ ច តត្ថ វិជានន្តិ** (ចំណែកជនពួកណាក្នុងសង្ឃនោះ រមែងដឹងច្បាស់) សេចក្តីថា ជនពួកណាដែលជាបណ្ឌិតក្នុងសង្ឃនោះ រមែងដឹងថា យើងទាំងឡាយទៅកាន់ទីជិតមច្ចុ ។ បទថា **តតោ សម្មន្តិ មេធគា** (សេចក្តីឈ្លោះទាស់ទែងគ្នានឹងគ្នា រមែងស្ងប់ ព្រោះការបដិបត្តិរបស់ជនពួកនោះ) សេចក្តីថា ជនទាំងនោះដឹងយ៉ាងនេះហើយ ញុំាងការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃឲ្យកើតឡើង រមែងបដិបត្តិដើម្បីសេចក្តីស្ងប់ គឺ ការទាស់ទែងគ្នានោះ គឺ ការឈ្លោះគ្នា កាលដូច្នោះ ការឈ្លោះគ្នាទាំងនោះរមែងស្ងប់ ព្រោះការបដិបត្តិនោះ របស់បណ្ឌិតទាំងនោះ ។ មយ៉ាងទៀត គប្បីជ្រាបអធិប្បាយក្នុងព្រះគាថានេះថា បទថា **បរេ ច** (ក៏ជនពួកដទៃ) ជាដើម សេចក្តីថា ជនទាំងឡាយ សូម្បីយើង (តថាគត) ពោលទូន្មានក្នុងកាលមុនថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូលកុំធ្វើការវិវាទគ្នានឹងគ្នាឡើយ” ដូច្នេះជាដើម ក៏មិនកាន់យក ព្រោះមិនទទួលឱវាទរបស់

តថាគត ឈ្មោះថា ជនពួកដទៃ ។ ជនពួកដទៃនោះ រមែងមិនដឹងថា យើងទាំងឡាយប្រកាន់ខុសដោយអំណាចអគតិ មានឆន្ទាគតិជាដើម រមែងលំបាកបានដល់ ព្យាយាមដើម្បីសេចក្តីចម្រើននៃហេតុដែលធ្វើឲ្យវិនាស មានការបាក់បែកគ្នាជាដើម ក្នុងជំនុំសង្ឃនេះ ។ តែឥឡូវនេះ បុរសជាបណ្ឌិតពួកណាក្នុងចំណោមនៃអ្នកទាំងឡាយក្នុងសង្ឃនោះ កាលពិចារណាដោយប្រពៃហើយ ក៏ដឹងច្បាស់ថា "កាលមុនយើងទាំងឡាយព្យាយាម ដោយអំណាចអគតិ មានឆន្ទាគតិជាដើម បដិបត្តិមិនប្រពៃ ទីនោះ ការប្រកាន់នោះ គឺ ការវិវាទគ្នាក្នុងកាលឥឡូវនេះ រមែងស្ងប់ ព្រោះអាស្រ័យបុរសជាបណ្ឌិតទាំងនោះ ដែលមានក្នុងនៃសំណាក់បណ្ឌិតទាំងឡាយនោះឯង ។

ក្នុងកាលចប់ព្រះគាថា ភិក្ខុដែលប្រជុំគ្នាបានតាំងនៅក្នុងអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមនោះឯង ។

ចប់រឿងភិក្ខុក្រុងកោសម្ពី

# ៦ រឿងចុល្លកាល និងមហាកាល

*ព្រះសាស្តា កាលស្តេចចូលទៅអាស្រ័យសេតព្យនគរ ប្រថាប់នៅក្នុងជងព្រៃធ្នង់ ទ្រង់ប្រារព្ធចុល្លកាល និងមហាកាលត្រាស់ព្រះធម្មទេសនានេះថា* ***សុភានុបស្សឹ វិហរន្តំ*** *(អ្នកតាមឃើញអារម្មណ៍ថាស្អាត)* ជាដើម ។

*សេចក្តីពិស្តារថា កុដុម្ពីក៍[១]អ្នកស្រុកសេតព្យនគរ ៣ នាក់បងប្អូន គឺ ចុល្លកាល ១ មជ្ឈិមកាល ១ មហាកាល ១ ។ ក្នុងបងប្អូន ៣ នាក់នោះ បងប្រុសជាមួយប្អូនប្រុសពៅ ត្រាច់ទៅក្នុងទិសទាំងឡាយ ផ្ទុកទំនិញមកដោយរទេះ ៥០០ រទេះ ។ មជ្ឈិមកាលលក់ទំនិញដែលបង និងប្អូនទាំងពីរនាំមក ។ តមកសម័យមួយ បងប្អូនទាំងពីរនោះ ដឹកទំនិញផ្សេងៗដោយរទេះ ៥០០ រទេះ ទៅកាន់ក្រុងសាវត្ថី (ឈប់សម្រាក) រទេះទាំងឡាយក្នុងរវាងក្រុងសាវត្ថី និងវត្តជេតពន ។*

*ក្នុងបងប្អូនទាំងពីរនាក់នោះ មហាកាលឃើញអរិយសាវកទាំងឡាយអ្នកក្រុងសាវត្ថី កាន់យកកម្រងផ្កា និងរបស់ក្រអូបជាដើម ទៅដើម្បីស្តាប់*

១. *កុដុម្ពីក៍ គឺ អ្នកស្តុកស្តម្ភ អ្នកមានទ្រព្យសម្បត្តិច្រើន អ្នកគ្រប់គ្រងផ្ទះ ម្ចាស់ផ្ទះ អ្នកមើលការងារ ។*

ធម៌ក្នុងវេលាល្ងាច ទើបសួរថា ជនទាំងនេះនាំគ្នាទៅណា ។ បានស្ដាប់ពាក្យទាំងនោះ គិតថា សូម្បីយើងក៏នឹងទៅ ។ ហៅប្អូនប្រុសមក ហើយប្រាប់ថា "ប្អូន ឯងកុំប្រមាទក្នុងរទេះទាំងឡាយ ចំណែកយើងនឹងទៅស្ដាប់ធម៌" ហើយទៅថ្វាយបង្គំព្រះតថាគត អង្គុយខាងក្រោយបរិស័ទ ។ ថ្ងៃនោះព្រះសាស្ដា កាលនឹងត្រាស់អនុបុព្វិកថាតាមអធ្យាស្រ័យរបស់មហាកាលនោះ ទើបត្រាស់អំពីទោសនៃការស្វែងរកដែលថោកទាប និងសេចក្ដីសៅហ្មងនៃកាមទាំងឡាយដោយបរិយាយដ៏ច្រើន ដោយអំណាចនៃសូត្រ មានទុក្ខក្ខន្ធសូត្រជាដើម ។ មហាកាលបានស្ដាប់ព្រះធម្មទេសនានោះហើយគិតថា "ន័យថា មនុស្សយើងនឹងត្រូវលះបង់វត្ថុទាំងពួងហើយទៅ ភោគៈ (និង) ញាតិទាំងឡាយរមែងមិនជាប់តាមបុគ្គលអ្នកទៅបរលោកឡើយ យើងត្រូវការអ្វីដោយការនៅគ្រប់គ្រងផ្ទះ យើងនឹងបួស" កាលមហាជនថ្វាយបង្គំចៀសចេញទៅហើយ ទូលសូមបព្វជាចំពោះព្រះសាស្ដា ព្រះសាស្ដាត្រាស់ថា មនុស្សដែលអ្នកគួរលាណាៗ មានដែរឬ ។ ទូលថា "ខ្ញុំព្រះអង្គមានប្អូនប្រុស" ព្រះអង្គត្រាស់ថា "បើដូច្នោះ អ្នកចូរលាគេសិនចុះ ទូលទទួល

ថា កុរុណាព្រះអង្គ ។ ត្រឡប់មកផ្ទះ ហើយប្រាប់ប្អូនប្រុសថា "ប្អូនអ្នកចូរគ្រប់គ្រងសម្បត្តិទាំងអស់នេះចុះ" ។ ចុល្លកាលពោលថា "ក៏បងទៅណា" ។ មហាកាលឆ្លើយថា "បងនឹងបួសក្នុងសម្នាក់ព្រះសាស្ដា" ។ គេអង្វរបងនោះដោយប្រការផ្សេងៗ ក៏មិនអាចឲ្យត្រឡប់ចិត្តបាន ទើបពោលថា "ល្អហើយបង សូមបងធ្វើតាមអធ្យាស្រ័យចុះ" ។ មហាកាលទៅបួសក្នុងសំណាក់របស់ព្រះសាស្ដាហើយ ។ ចំណែកចុល្លកាល ក៏ (ទៅ) បួសដោយតាំងចិត្តថា "យើងនឹងដឹកនាំបងប្រុសឲ្យសឹក" ។ ក្នុងកាលតមកមហាកាលបានឧបសម្បទាហើយ ចូលទៅគាល់ព្រះសាស្ដាទូលសួរដល់ធុរៈក្នុងព្រះសាសនា កាលព្រះសាស្ដាត្រាស់ប្រាប់ធុរៈ ២ យ៉ាងហើយ ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចបំពេញគន្ថធុរៈបាន ព្រោះខ្ញុំព្រះអង្គបួសក្នុងកាលជាមនុស្សចាស់ តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូរ" ទូលសូមឲ្យព្រះអង្គត្រាស់ប្រាប់សោសានិកធុតង្គរហូតដល់ព្រះអរហត្ត លុះកន្លងបឋមយាម កាលជនទាំងឡាយដេកលក់គ្រប់គ្នាហើយ ទៅកាន់ព្រៃបោលខ្មោច វេលាអរុណជិតរះ កាលជនទាំងឡាយនៅមិនទាន់ក្រោកឡើង

(ក្លាក់) ក៏ត្រឡប់មកកាន់វិហារវិញ ។

គ្រានោះ ស្ត្រីម្នាក់ជាអ្នករកស៊ីរៀបចំខ្មោច ឈ្មោះកាឡី អ្នកចាំព្រៃខ្មោច ឃើញទីឈរ ទីអង្គុយ និងទីចង្រ្កមរបស់ព្រះថេរៈ បានគិតថា "នរណាហ្ន៎ មកក្នុងទីនេះ យើងនឹងឃ្លាំចាំចាប់" កាលមិនអាចចាប់បានថ្ងៃមួយ ទើបតាំងប្រទីបទុកត្រង់ខ្ទមជិតព្រៃខ្មោច នាំបុត្រធីតាទៅលាក់ក្នុងទីម្ខាង ឃើញព្រះថេរៈដើរមកក្នុងមជ្ឈិមយាម ទើបទៅថ្វាយបង្គំ ហើយទូលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ជាអ្នកស្នាក់នៅក្នុងទីរបស់ពួកខ្ញុំនេះឬ" ។

មហាកាល. អើ ឧបាសិកា ។

ស្ត្រី. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម្មតាអ្នកនៅក្នុងព្រៃខ្មោចទាំងឡាយ រៀនរបៀប (មុន) ទើបគួរ ។

ព្រះថេរៈមិនពោលថា "ក៏អាត្មានឹងប្រព្រឹត្តក្នុងរបៀបដែលញោមប្រាប់ធ្វើអ្វី" ត្រឡប់ជាពោលថា "ធ្វើយ៉ាងណា ទើបគួរ ឧបាសិកា" ។

ស្ត្រី. លោកម្ចាស់ដ៏ចម្រើន ធម្មតាអ្នកនៅក្នុងព្រៃខ្មោចទាំងឡាយ

គួរដឹងច្បាស់នូវការដែលខ្លួននៅក្នុងព្រៃខ្មោចដល់អ្នកចាំព្រៃខ្មោច ព្រះមហាថេរៈនៅក្នុងវិហារ និងម្ចាស់ផ្ទះ ។

មហាកាល. ព្រោះហេតុអ្វី ។

ស្ត្រី. ព្រោះពួកចោរធ្វើកម្ម (ប្លន់គេ) ហើយ ត្រូវពួកម្ចាស់របស់ទ្រព្យដេញតាមស្នាមជើងទៅ ទើបលះបង់ចោលភណ្ឌៈ (របស់) ទុកក្នុងព្រៃខ្មោចហើយគេចចេញទៅ ហេតុនោះ ពួកមនុស្សក៏ (ប្រចោម) ធ្វើអន្តរាយដល់អ្នកនៅក្នុងព្រៃខ្មោច តែកាលបានប្រាប់សេចក្តីដល់ជនទាំងនោះហើយ ជនទាំងនោះនឹងជួយការពារអន្តរាយបាន ដោយពោលធានាថា ពួកខ្ញុំ ជ្រាបរឿងដែលលោកម្ចាស់ដ៏ចម្រើននៅក្នុងទីនេះ អស់កាលប្រមាណប៉ុណ្ណេះ លោកម្ចាស់មិនមែនជាចោរ ព្រោះដូច្នោះ គួរប្រាប់ដល់គេទាំងនោះ ។

មហាកាល. កិច្ចដទៃអ្វី ដែលខ្ញុំគួរធ្វើ ។

ស្ត្រី. លោកម្ចាស់ ធម្មតាភិក្ខុដែលនៅក្នុងព្រៃខ្មោច ត្រូវវៀរវត្ថុទាំងឡាយ មានត្រី សាច់ ម្សៅ ល្ងរ និងទឹកអំពៅជាដើមចេញ មិនគួរ

ធ្វើវត្តពេលថ្ងៃ មិនគួរជាអ្នកខ្ជិលច្រអូស គួរប្រារព្ធសេចក្តីព្យាយាម គួរជាអ្នកមិនអួតអាង មិនមានមាយា ជាអ្នកមានអធ្យាស្រ័យល្អ វេលាល្ងាចកាលជនត្រឡប់ទៅវិញអស់ហើយ គប្បីមកពីវិហារ វេលាអរុណរះ កាលពួកមនុស្សគ្រប់គ្នាមិនទាន់ក្រោក (ភ្ញាក់ពីដេក) នៅឡើយ គប្បីចូលកាន់វិហារ លោកម្ចាស់ដ៏ចម្រើន បើភិក្ខុជាអ្នកនៅក្នុងទីនេះដោយអាការយ៉ាងនេះសោត និងអាចញុំាងកិច្ចបព្វជិតឲ្យដល់ទីបំផុតបាន បើពួកមនុស្សនាំសពមកចោល ខ្ញុំម្ចាស់នឹងលើកឡើងកាន់ផ្ទះកំពូលដែលក្រាលដោយសំពត់កម្ពល[១] ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានរបស់ក្រអូប និងផ្កាកម្រងជាដើម និងធ្វើការដុតសាកសព ប្រសិនបើភិក្ខុជាអ្នកមិនអាចញុំាងកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានទេ នាងខ្ញុំនឹងលើកឡើងកាន់ជើងថ្ករ ហើយបង្កាត់ភ្លើងដុត យកទម្ពក់ទាញ (សាកសព) ថ្ពក់ទាញមកទុកខាងក្រៅ ចិញ្ច្រាំដោយពូថៅ ជ្រៀកឲ្យជាបន្ទះតូចធំហើយដាក់ក្នុងភ្លើង សំដែងដល់លោក (ម្ចាស់) ហើយទើបដុត ។ ពេលនោះ ព្រះថេរៈប្រាប់នាងកាឡីនោះថា

---

១. សំពត់ធ្វើដោយរោមសត្វ ។

“ល្អហើយ នាងដ៏ចម្រើន ក៏នាងឃើញរូបារម្មណ៍ណាមួយហើយ ចូរប្រាប់ដល់អាត្មា” ។ នាងកាឡីទទួលថា “បានលោកម្ចាស់” ។ ព្រះថេរៈ ធ្វើសមណធម៌នៅក្នុងព្រៃខ្មោចតាមអធ្យាស្រ័យរបស់ខ្លួន ។ ចំណែកព្រះចុល្ល-កាល ដេកក្រោកៗ ពិចារណាដល់ឃរាវាស គិតដល់បុត្រ និងភរិយា គិតថា “បងប្រុសរបស់យើងនេះ ធ្វើកម្មធ្ងន់ក្រៃលែង” ។

លំដាប់នោះ កុលធីតាម្នាក់ បានស្លាប់ក្នុងវេលាល្ងាច នៅមិនទាន់ស្មោកស្មាំង ព្រោះព្យាធិកម្រើកឡើងក្នុងគ្រាមួយរំពេចនោះ ។ ពួកញាតិហែសពកុលធីតានោះទៅកាន់ព្រៃខ្មោចក្នុងវេលាល្ងាច ព្រមទាំងគ្រឿងដុតផ្សេងៗមានឧស និងប្រេងជាដើម ឲ្យឈ្នួលដល់ស្ត្រីដុតសពដោយប្រាប់ថា “នាងចូរចាត់ចែងការដុតសពនេះ” ហើយប្រគល់ (សព) ឲ្យ ទើបនាំគ្នាចេញទៅ ។ នាងផ្លាស់សំពត់ដណ្តប់របស់កុលធីតានោះចេញហើយ ឃើញសរីរៈដែលទើបតែស្លាប់ភ្លាមៗ សែនប្រណីត មានពណ៌ដូចមាស ទើបគិតថា “អារម្មណ៍នេះគួរនឹងសំដែងដល់លោកម្ចាស់ហើយ” ហើយទៅសំពះព្រះថេរៈពោលថា “លោកម្ចាស់ អារម្មណ៍បែបនេះមានហើយ សូមលោកម្ចាស់គប្បី

(ទៅ) ពិចារណាចុះ" ។ ព្រះថេរៈទទួលថា "ចម្រើនពរ" ដូច្នេះ ហើយទៅឲ្យទាញសំពត់ដណ្តប់ចេញ ពិចារណាតាំងអំពីចុងជើងដល់ចុងសក់ ហើយនិយាយថា "រូបនេះប្រណីតក្រៃលែង មានពណ៌ដូចជាមាស នាងគប្បីដាក់រូបនេះក្នុងភ្លើង ក្នុងកាលដែលរូបនោះត្រូវអណ្តាតភ្លើងធំឆេះហើយ គប្បីប្រាប់ដល់អាត្មា" ក៏ទៅកាន់ទីដែលខ្លួននៅវិញ ហើយអង្គុយ ។ នាងធ្វើយ៉ាងនោះ ហើយប្រាប់ដល់ព្រះថេរៈ ។ ព្រះថេរៈទៅពិចារណា ។ ក្នុងទីដែលអណ្តាតភ្លើងពាល់ត្រូវហើយ ពណ៌នៃសរីរៈប្រាកដដូចជាមេគោដាង ។ ជើងទាំងពីរពត់ខ្វៀនខ្វង់សំយុងចុះ ដៃទាំងពីរក្តាប់ចូល ថ្ងាស់មានស្បែករបកចេញ ។ ព្រះថេរៈពិចារណាថា "សរីរៈនេះជាធម្មជាតិធ្វើមិនឲ្យអស់សេចក្តីស្រើបស្រាលដល់បុគ្គលដែលមើលត្រឹមតែម្តង តែឥឡូវនេះ ដល់នូវការអស់ទៅ សូន្យទៅហើយ" ព្រះថេរៈត្រឡប់ទៅកាន់ទីនៅក្នុងវេលាយប់ អង្គុយពិចារណាដល់ការអស់ទៅ និងការសូន្យទៅ ពោលគាថាថា ៖

សង្ខារទាំងឡាយមិនទៀងហ្ន៎ មានការកើតឡើង និងវិនាស
ទៅវិញជាធម្មតា លុះកើតឡើងហើយរមែងរលត់ទៅ ការ

សួប់នៃសង្ខារទាំងនោះជាសុខ ។

ចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ។

កាលលោកសម្រេចព្រះអរហត្តហើយ ព្រះសាស្តាមានភិក្ខុសង្ឃបែហែ-ហម ស្តេចចារិកទៅកាន់សេតព្យនគរ ស្តេចចូលទៅកាន់ព្រៃធ្នង់ ។ ពួកករិយារបស់ព្រះចុល្លកាលឮដំណឹងថា ព្រះសាស្តាស្តេចយាងមកដល់ហើយ គិតថា "ពួកយើងនឹង (ជួយគ្នា) ចាប់ស្វាមីរបស់ពួកយើង" ដូច្នេះ ហើយបញ្ជូន (មនុស្ស) ឲ្យទៅទូលនិមន្តព្រះសាស្តា ។ ក៏ក្នុងស្ថានទីដែលព្រះពុទ្ធទាំងឡាយទ្រង់មិនធ្លាប់ជ្រាប គប្បីមានភិក្ខុមួយរូបអ្នកប្រាប់ការក្រាលអាសនៈត្រូវទៅមុន ។ ក៏អាសនៈសម្រាប់ព្រះពុទ្ធទាំងឡាយ គប្បីឲ្យក្រាលក្នុងទីពាក់កណ្តាល អាសនៈសម្រាប់ព្រះសារីបុត្រគប្បីឲ្យក្រាលខាងស្តាំ អាសនៈសម្រាប់មហាមោគ្គល្លានគប្បីឲ្យក្រាលខាងឆ្វេង នៃអាសនៈរបស់ព្រះពុទ្ធ អាសនៈសម្រាប់ភិក្ខុសង្ឃ គប្បីឲ្យក្រាលទាំងពីរខាងបន្ទាប់អំពីទីនោះទៅ ព្រោះដូច្នោះ ព្រះមហាកាលថេរៈនៅក្នុងទីស្លៀកដណ្តប់ចីវរ ក៏ប្រាប់ព្រះចុល្លកាលថា "អ្នកចូរទៅមុនប្រាប់ការក្រាលអាសនៈ" ពួកជនក្នុងផ្ទះធ្វើការ

សើចចំអកឲ្យលោក តាំងពីកាលដែលពួកគេឃើញលោក (បន្ទំ) ក្រាលអាសនៈទាបក្នុងទីរបស់ព្រះសង្ឃត្ថេរៈ ក្រាលអាសនៈខ្ពស់ក្នុងទីរបស់ព្រះសង្ឃនវកៈ[១] ។ ព្រះចុល្លកាលប្រាប់ថា "ពួកនាងកុំធ្វើយ៉ាងនោះ ចូរក្រាលអាសនៈខ្ពស់ក្នុងខាងដើម ក្រាលអាសនៈទាបក្នុងទីខាងចុង" ។ ពួកស្រីៗទាំងនោះធ្វើដូចមិនបានឮពាក្យរបស់លោក ពោលថា "លោកម្ចាស់ចាំបាច់ធ្វើអ្វី នាទីក្រាលអាសនៈមិនសមគួរដល់លោកម្ចាស់ឬ លោកម្ចាស់លានរណាបួស នរណាអនុញ្ញាតឲ្យលោកបួស មកក្នុងទីនេះធ្វើអ្វី" ហើយនាំគ្នាចាប់ស្បង់ និងចីវរទាញចេញ ហើយឲ្យស្លៀកដណ្តប់សំពត់ស ពាក់ផ្កាកម្រងលើសីសៈ បញ្ជូនទៅដោយពាក្យថា "លោកចូរទៅនាំព្រះសាស្តាមក ពួកខ្ញុំនឹងក្រាលអាសនៈ" ។ ព្រះចុល្លកាលតាំងនៅក្នុងភាវៈនៃភិក្ខុអស់កាលមិនយូរប៉ុន្មាន មិនទាន់មានវស្សានៅឡើយ ក៏សឹក ទើបមិនខ្មាសអៀន ព្រោះដូច្នោះ គេទើបមិនមានសេចក្តីរង្កៀសដោយកិរិយានោះ ទៅថ្វាយបង្គំព្រះសាស្តា នាំភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានមក ។ ក៏ក្នុងកាល

១. អ្នកបួសថ្មីក្នុងសង្ឃ សេចក្តីថា អ្នកមានវស្សាតិចជាងភិក្ខុគ្រប់រូបក្នុងពួកនោះ ។

កាលស្រេចភត្តកិច្ចរបស់ភិក្ខុសង្ឃ ពួកភរិយារបស់ព្រះមហាកាល គិតគ្នាថា "ស្រីៗ ទាំងនេះរួមគ្នាចាប់ស្វាមីរបស់ខ្លួន (ចុល្លកាល) បាន ពួកយើងនឹងចាប់ស្វាមីរបស់ពួកយើង (មហាកាល) ដែរ" ។ ទើបនិមន្តព្រះសាស្តាដើម្បីប្រយោជន៍ដល់ការសោយភត្តាហារក្នុងថ្ងៃស្អែក ។ ក៏ក្នុងកាលនោះ ភិក្ខុអង្គដទៃបានទៅ (ប្រាប់) ឲ្យក្រាលអាសនៈ ។ ស្រីទាំងនោះមិនបានឱកាសក្នុងខណៈនោះ និមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យគង់ ហើយថ្វាយភិក្ខា ។ ក៏ចុល្លកាលមានភរិយា ២ នាក់ , មជ្ឈិមកាលមានភរិយា ៤ នាក់ មហាកាលមានភរិយា ៨ នាក់ ចំណែកភិក្ខុទាំងឡាយអ្នកប្រាថ្នាធ្វើភត្តកិច្ច បានគង់ធ្វើភត្តកិច្ចហើយ ភិក្ខុដែលប្រាថ្នាទៅខាងក្រៅ ក៏បានក្រោកទៅហើយ ចំណែកព្រះសាស្តាប្រថាប់គង់ ទ្រង់ធ្វើភត្តកិច្ច ។ ក្នុងកាលស្រេចភត្តកិច្ចរបស់ព្រះអង្គ ស្រីទាំងនោះទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកាលធ្វើអនុមោទនាដល់ពួកខ្ញុំព្រះអង្គហើយ ទើបនឹងទៅ សូមព្រះអង្គស្តេចយាងទៅមុនចុះ" ។ ព្រះសាស្តាត្រាស់ថា "ល្អហើយ" ស្តេចទ្រង់យាងត្រឡប់ទៅ ។ កាលដល់ទ្វារស្រុក ភិក្ខុសង្ឃក៏លើកទោស

ថា “ហេតុអ្វី ព្រះសាស្តាទ្រង់ទើបធ្វើដូច្នេះ ព្រះអង្គទ្រង់ជ្រាបហើយទើបទ្រង់ធ្វើ ឬទ្រង់មិនជ្រាបទើបទ្រង់ធ្វើ កាលមុនវិលមិញ អន្តរាយនៃបព្វជ្ជាកើតឡើងដល់ចុល្លកាល ព្រោះការទៅមុន ថ្ងៃនេះ អន្តរាយរមែងមិនមានព្រោះភិក្ខុដទៃនិមន្តទៅមុន ឥឡូវនេះ ព្រះសាស្តាទ្រង់ត្រាស់ឲ្យព្រះមហាកាលនៅ ហើយស្តេចមក ក៏ភិក្ខុអ្នកមានសីល ដល់ព្រមហើយដោយអាចារៈស្រីទាំងនោះនឹងធ្វើអន្តរាយនៃបព្វជ្ជាដល់ព្រះមហាកាលនោះបាន ឬទេហ្ន៎” ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទ្រង់ស្តេចត្រឡប់មកប្រថាប់ឈរ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពិភាក្សារឿងអ្វី” ភិក្ខុទាំងនោះទូលសេចក្តីនោះហើយ ។ ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នកសំគាល់មហាកាលដូចចុល្លកាលឬ” ។ ភិក្ខុទាំងឡាយក្រាបទូលថា “យ៉ាងនោះហើយ ព្រះអង្គ ព្រោះចុល្លកាលនោះ មានភរិយា ២ នាក់ (ចំណែក) ព្រះមហាកាលមានដល់ ៨ នាក់ លោកត្រូវភរិយាទាំង ៨ រួមគ្នាចាប់ទុកហើយនឹងធ្វើអ្វីបាន ព្រះអង្គ” ។ ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំពោលយ៉ាងនោះឡើយ ចុល្លកាលដេក

ក្រោកៗ ច្រើនទៅដោយអារម្មណ៍ថាស្អាត ដូចជាដើមឈើមួយដើមដែល មានកម្លាំងខ្សោយ (ដុះ) នៅតាមមាត់ជ្រោះ ចំណែកមហាកាលបុត្ររបស់ តថាគត តាមឃើញអារម្មណ៍ថាមិនស្អាត ជាអ្នកមិនរវើរវាយឡើយ ដូច ភ្នំថ្មតាន់ ហើយបានត្រាស់គាថានេះថា ៖

-សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវិរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។

-អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវិរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុង ឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គល នោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។

ឯបុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួម
ប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មាន
សទ្ធា ប្រារព្ធព្យាយាម កិលេសមារតែងគ្របសង្កត់បុគ្គល
នោះមិនបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្មតាន់មិនបាន ដូច្នោះ ។

## អធិប្បាយគាថា

ក្នុងបទទាំងនោះ បទថា សុភានុបស្សឺ (អ្នកតាមឃើញអារម្មណ៍ថាល្អ) បានដល់ អ្នកតាមពិចារណាឃើញអារម្មណ៍ថាស្អាត អធិប្បាយថា អ្នកបណ្តោយចិត្តទៅក្នុងអារម្មណ៍ដែលគួរប្រាថ្នា ។ ក៏បុគ្គលណា កាលកាន់យកដោយនិមិត្ត[១] ដោយអនុព្យញ្ជនៈ[២] រមែងសម្គាល់ថា មាត់ទាំងឡាយស្អាត សម្គាល់ថាម្រាមដៃទាំងឡាយស្អាត សម្គាល់ថាដៃទាំងពីរ ជើងទាំងពីរ ស្មងទាំងពីរ ភ្លៅទាំងពីរ ចង្កេះ ពោះ ដោះទាំងពីរ កបបូរមាត់ ធ្មេញទាំងឡាយ មាត់ ច្រមុះ ភ្នែកទាំងពីរ ត្រចៀកទាំងពីរ ចិញ្ចើមទាំងពីរ ថ្ងាស សក់ទាំងឡាយល្អស្អាត ។ សម្គាល់ថាសក់ រោម

---

១. កាន់យកចំណែកទាំងអស់ ។

២. កាន់យកជាចំណែកមួយៗ ដូចជា សក់ស្អាត ក្រចកស្អាតជាដើម ។

ក្របក ឆ្ពេញ ស្បែក ស្អាត (ឬ) សម្គាល់ថា ពណ៌សម្បុរស្អាត ទ្រង់ទ្រាយស្អាត បុគ្គលនេះ ឈ្មោះថា តាមឃើញអារម្មណ៍ថាស្អាត ។ បុគ្គលតាមឃើញអារម្មណ៍ថាស្អាត យ៉ាងនោះនុ៎ះឯង ។ បទថា **ឥន្ទ្រិយេសុ (ក្នុងឥន្ទ្រិយទាំងឡាយ)** បានដល់ ក្នុងឥន្ទ្រិយ[១] ៦ មានចក្ខុជាដើម ។ បទថា **អសំវុតំ (មិនសង្រួម)** បានដល់ អ្នកមិនរក្សាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ។ បទថា **អមត្តញ្ញុំ (មិនដឹងប្រមាណ)** សេចក្តីថា ឈ្មោះថា បុគ្គលមិនដឹងប្រមាណក្នុងភោជន ព្រោះមិនដឹងប្រមាណនេះ គឺ ប្រមាណក្នុងការស្វែងរក ប្រមាណក្នុងការទទួល ប្រមាណក្នុងការបរិភោគ ។ ន័យម្យ៉ាងទៀត ឈ្មោះថា អ្នកមិនដឹងប្រមាណ ព្រោះមិនដឹងប្រមាណសូម្បីនេះ គឺ ប្រមាណក្នុងការពិចារណា ប្រមាណក្នុងការលះបង់ គឺ មិនដឹងថា ភោជននេះប្រកបដោយធម៌ នេះមិនប្រកបដោយធម៌ ។ បទថា **កុសីតំ (ខ្ជិលច្រអូស)** បានដល់ ឈ្មោះថា អ្នកខ្ជិលច្រអូស ព្រោះជាអ្នកធ្លាក់ទៅក្នុងអំណាចកាមវិតក្កៈ ព្យាបាទវិតក្កៈ និងវិហឹង្សាវិតក្កៈ ។ បទថា **ហីន-**

---

១. ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ ។

**វិរិយំ** (មានសេចក្តីព្យាយាមថយ) បានដល់ អ្នកមិនមានសេចក្តីព្យាយាម គឺ អ្នកវៀរចាកការធ្វើសេចក្តីព្យាយាមក្នុងឥរិយាបថទាំងបួន ។

បទថា **បសហតិ** (បៀតបៀន) បានដល់ រមែងគ្របសង្កត់ គឺ ញាំញី ។ បទថា **វាតោ រុក្ខំវ ទុព្វលំ** (ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ) បានដល់ ដូចខ្យល់មានកម្លាំងខ្លាំងបៀតបៀនដើមឈើដែលទុព្វល កើតត្រង់មាត់ជ្រោះ ។ សេចក្តីថា ខ្យល់នោះធ្វើចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកជាដើមរបស់ដើមនោះឲ្យរលំចុះខ្លះ បាក់មែកតូចខ្លះ បាក់មែកធំខ្លះ សណ្តកទាំងដើមព្រមទាំងឫសខ្លះ ធ្វើឲ្យឫសឡើងទៅខាងលើ មែកចុះក្រោមខ្លះ យ៉ាងណា មារ គឺ កិលេស ដែលកើតក្នុងខាងក្នុង រមែងបៀតបៀនបុគ្គលអ្នកឃើញបែបនោះបាន ក៏ដូចគ្នា គឺ កិលេសមារ ធ្វើឲ្យត្រូវអាបត្តិតូចៗ ដូចខ្យល់មានកម្លាំងខ្លាំង បក់ចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកជាដើមរបស់ដើមឈើ ដែលមានកម្លាំងទុព្វលឲ្យរលំចុះខ្លះ ធ្វើឲ្យត្រូវអាបត្តិ មាននិស្សគ្គិយៈជាដើម ដូចខ្យល់មានកម្លាំងខ្លាំង ធ្វើការបំបាក់មែកតូចៗ ខ្លះ ធ្វើឲ្យត្រូវអាបត្តិសង្ឃាទិសេស ១៣ ដូចខ្យល់មាន

កម្លាំងខ្លាំង ធ្វើការកាច់បំបាក់មែកធំៗ ខ្លះ ធ្វើឲ្យត្រូវអាបត្តិបារាជិក នាំចេញចាកសាសនាដែលព្រះមានព្រះភាគត្រាស់ល្អហើយ ឲ្យដល់នូវភាពជាគ្រហស្ថត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ ដូចខ្យល់មានកម្លាំងខ្លាំង ដក (ដើមឈើ) ធ្វើឲ្យរលំចុះក្រោម មានឫសឡើងខាងលើ មានមែកចុះខាងក្រោមខ្លះ ។ អធិប្បាយថា កិលេសមារ រមែងធ្វើបុគ្គលបែបនោះឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។

បទថា ***អសុភានុបស្សឹ*** ***(អ្នកតាមឃើញអារម្មណ៍ថាមិនល្អ)*** បានដល់ អ្នកឃើញអារម្មណ៍យ៉ាងណាមួយ ក្នុងអារម្មណ៍ដែលមិនស្អាត ១០ យ៉ាង[១]ថា មិនស្អាត គឺ ប្រកបមនសិការដោយភាពជារបស់បដិកូល បានដល់ ឃើញសក់ទាំងឡាយមិនស្អាត ឃើញរោម ក្រចក ធ្មេញ ស្បែក ពណ៌សម្បុរ ទ្រង់ទ្រាយ ជារបស់មិនស្អាត ។ បទថា ***ឥន្ទ្រិយេសុ*** ***(ក្នុង***

---

អារម្មណ៍ដែលមិនស្អាតមាន ១០ គឺ ៖

១.**ឧទ្ធុមាតកអសុភ** អសុភដែលហើមប៉ោង
២.**វិនីលកអសុភ** អសុភដែលមានពណ៌ខៀវ
៣.**វិបុព្វកអសុភ** អសុភមានខ្ទុះហូរចេញ
៤.**វិច្ឆិទ្ទកអសុភ** អសុភដែលដាច់ចេញពីគ្នាៗ
៥.**វិក្ខាយិតកអសុភ** អសុភដែលសត្វហែកស៊ី
៦.**វិក្ខិត្តកអសុភ** អសុភដែលដាច់ពាក់កណ្ដាល
៧.**ហតវិក្ខិត្តកអសុភ** អសុភដែលដាច់រាត់រាយ
៨.**លោហិតកអសុភ** អសុភមានឈាមហូរចេញ
៩.**បុឡុវកអសុភ** អសុភដែលពួកដង្កូវរូងជញ្ជក់
១០.**អដ្ឋិកអសុភ** អសុភដែលមានតែរាងឆ្អឹង ។

ឥន្ទ្រិយទាំងឡាយ) បានដល់ ក្នុងឥន្ទ្រិយ ៦ ។ បទថា **សុសំវុតំ** (សង្រួមល្អ) បានដល់ ជាអ្នកវៀរចាកការកាន់យកនិមិត្តជាដើម គឺ ជាអ្នកមានទ្វារដែលបិទហើយ ។ ឈ្មោះថា **ភោជនម្ហិ ច មត្តញ្ញុំ** (ដឹងប្រមាណក្នុងភោជន) ព្រោះផ្សំយជាមួយបុគ្គលមិនដឹងប្រមាណ ។ បទថា **សទ្ធំ** (មានសទ្ធា) បានដល់ អ្នកប្រកបដោយលោកិយសទ្ធា មាន ការជឿកម្ម និងផលរបស់កម្មជាលក្ខណៈ និងប្រកបដោយលោកុត្តរសទ្ធា គឺ សេចក្តីជ្រះថ្លាដែលមិនញាប់ញ័រក្នុងវត្ថុ ៣[១] ។ បទថា **អារទ្ធវិរិយំ** (និងការប្រារព្ធព្យាយាម) បានដល់ អ្នកផ្គងសេចក្តីព្យាយាម គឺ អ្នកមានសេចក្តីព្យាយាមបរិបូណ៌ ។ បទថា **តំ វេ** (នោះឯង) បានដល់ បុគ្គលនោះ គឺ ឃើញយ៉ាងនោះ ។ អធិប្បាយថា ខ្យល់មានកម្លាំងខ្សោយ បក់ស្រាលៗ រមែងមិនអាចធ្វើថ្មតាន់ឲ្យញាប់ញ័របាន យ៉ាងណា កិលេសមារ ដែលមានកម្លាំងខ្សោយ សូម្បីកើតឡើងក្នុងខាងក្នុង រមែងបៀតបៀន (បុគ្គលនោះ) មិនបាន គឺ មិនអាចឲ្យញាប់ញ័រ កម្រើក រលំដួលបាន ដូច្នោះ ។

---

១. វត្ថុ ៣ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ពួកស្រីៗ ទាំងនោះឯង ដែលជាកិរិយាចាស់របស់ព្រះមហាកាល ព័ទ្ធព្រះថេរៈហើយ ពោលពាក្យជាដើមថា "លោកលានរណាបួស ឥឡូវនេះ លោកនឹងជាគ្រហស្ថ ឬមិនជាគ្រហស្ថ" ហើយត្រូវការនឹងដោះសំពត់កាសាយៈទាំងឡាយ (របស់ព្រះថេរៈ) ចេញ ។ ព្រះថេរៈកំណត់អាការរបស់ស្រីៗ ទាំងនោះបានហើយ ក្រោកចាកអាសនៈដែលអង្គុយ ហើយហោះឡើងដោយឫទ្ធិ ទម្លាយដំបូលផ្ទះកំពូល ទៅតាមផ្លូវអាកាស ។ ក្នុងកាលព្រះសាស្តាត្រាស់ព្រះគាថាចប់ ក៏សរសើរព្រះសរីរៈដែលមានវណ្ណៈដូចជាមាសរបស់ព្រះសាស្តា ចុះមក ថ្វាយបង្គំព្រះយុគលបាទរបស់ព្រះតថាគតហើយ ។

ក្នុងកាលចប់គាថា ភិក្ខុអ្នកប្រជុំគ្នាតាំងនៅក្នុងអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

ចប់រឿងព្រះចុល្លកាល និងមហាកាល

# ៧ រឿងព្រះទេវទត្ត

*ព្រះសាស្ដាកាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបានសំពត់កាសាវៈ ដែលបុគ្គលនាំមកអំពីដែនគន្ធារៈចំពោះព្រះទេវទត្ត ក្នុងក្រុងរាជគ្រឹះ ត្រាស់ព្រះធម្មទេសនានេះថា* ***អនិក្កសាវោ (មានកិលេសដូចទឹកចត់នៅមិនទាន់ដកចេញ)*** *ជាដើម ។*

*សេចក្ដីពិស្ដារថា សម័យមួយ ព្រះអគ្គសាវកទាំងពីរនាំបរិវាររបស់ខ្លួន មួយអន្លើ ៥០០ រូប ទូលលាព្រះសាស្ដា ចេញចាកវត្តជេតពនទៅកាន់ក្រុងរាជគ្រឹះ ។ អ្នកក្រុងរាជគ្រឹះ រួមជាក្រុម មានគ្នា ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើននាក់ខ្លះ ថ្វាយអាគន្តុកទាន[១] អស់មួយថ្ងៃ ព្រះសារីបុត្រកាលនឹងធ្វើអនុមោទនា សំដែងធម៌យ៉ាងនេះថា ឧបាសក និងឧបាសិកាទាំងឡាយ ទាយកម្នាក់ថ្វាយទានដោយខ្លួនឯង (តែ) មិនបបួលអ្នកដទៃ ទាយកនោះរមែងបានភោគៈសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយៗ (តែ) មិនបានបរិវារសម្បត្តិ ឯទាយកខ្លួនឯង បបួលអ្នកដទៃ ចំណែកខ្លួនឯងមិនថ្វាយ*

---

*១. ទានដែលថ្វាយដល់ភិក្ខុអ្នកមកថ្មី គឺ អ្នកជាភ្ញៀវ ។*

ទាយកនោះ រមែងបានបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយៗ (តែ) មិនបានភោគសម្បត្តិ ចំណែកទាយកម្នាក់ទៀត សូម្បីខ្លួនឯងក៏មិនថ្វាយ និងមិនបបួលសូម្បីអ្នកដទៃ ទាយកនេះ រមែងមិនបានសូម្បីវត្ថុត្រឹមតែបាយចុងអង្ករល្មមឆ្អែតពោះ រមែងជាមនុស្សអនាថា រកបច្ច័យមិនបានក្នុងទីដែលខ្លួនកើតហើយៗ ។ ទាយកម្នាក់ទាំងខ្លួនឯងក៏ថ្វាយ ទាំងបបួលអ្នកដទៃ ទាយកនោះ រមែងបានទាំងភោគសម្បត្តិ ទាំងបរិវារសម្បត្តិ អស់រយអត្តភាពខ្លះ ពាន់អត្តភាពខ្លះ សែនអត្តភាពខ្លះ ក្នុងទីដែលខ្លួនកើតហើយៗ ។ បុរសជាបណ្ឌិតម្នាក់ ស្តាប់ព្រះធម្មទេសនានោះហើយ គិតថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះធម្មទេសនានេះគួរអស្ចារ្យណាស់ លោកម្ចាស់សារីបុត្រពោលហេតុនៃសេចក្តីសុខ យើងគួរធ្វើកម្មដែលញុំាងសម្បត្តិទាំងពីរនេះឲ្យសម្រេច" ដូច្នេះ ទើបនិមន្តព្រះថេរៈថា "លោកម្ចាស់ ព្រឹកនេះ សូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំផងចុះ" ។ ព្រះថេរៈសួរថា "លោកត្រូវការភិក្ខុប៉ុន្មាន ឧបាសក" ។ ឧបាសកសួរវិញថា "ភិក្ខុដែលបរិវាររបស់លោកម្ចាស់មានប៉ុន្មាន ។ ព្រះថេរៈបានឆ្លើយថា "មានប្រមាណមួយពាន់រូប ឧបាសក" ។

ឧបាសកឆ្លើយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ព្រមទាំងភិក្ខុទាំងអស់អង្គ ប្រោសទទួលភិក្ខា (របស់ខ្ញុំ)" ។ ព្រះថេរៈទទួលនិមន្តហើយ ។ ឧបាសកត្រាច់ទៅតាមផ្លូវនគរ បបួលដោយពាក្យថា ពុកម៉ែទាំងឡាយ ខ្ញុំនិមន្តភិក្ខុមួយពាន់រូប លោកទាំងឡាយនឹងអាចថ្វាយភិក្ខាដល់ភិក្ខុចំនួនប៉ុនណា លោកទាំងឡាយនឹង អាចថ្វាយភិក្ខាដល់ភិក្ខុមានចំនួនប៉ុណ្ណោះ ។ ពួកមនុស្សពោលដោយល្មមសមគួរ (ដល់កម្លាំង) រៀងៗខ្លួនថា ពួកខ្ញុំនឹងថ្វាយដល់ភិក្ខុ ១០ រូប ពួកខ្ញុំ ២០ រូប ពួកខ្ញុំ ១០០ រូប ។ ឧបាសកពោលថា បើដូច្នោះ យើងទាំងឡាយនឹងប្រជុំរួមគ្នាក្នុងទីកន្លែងមួយ សូមលោកគ្រប់ៗ គ្នានាំវត្ថុផ្សេងៗ មានប្រេង ល្ង អង្ករ ទឹកដោះថ្លា ទឹកអំពៅជាដើម មករួមគ្នា ហើយឲ្យនាំមករួមទុកក្នុងទីកន្លែងមួយ ។ គ្រានោះ កុដុម្ពិក៍ម្នាក់ឲ្យសំពត់កាសាវៈដែលនាំមកពីដែនគន្ធារៈដែលមានតំលៃមួយសែនដល់ឧបាសកនោះ ហើយប្រាប់ថា បើវត្ថុទាន (វត្ថុសម្រាប់ធ្វើបុណ្យ) របស់លោកមិនទាន់គ្រប់ លោកគប្បីចំណាយសំពត់នេះបន្ថែមឲ្យគ្រប់គ្រាន់ចុះ បើវត្ថុទានរបស់លោកគ្រប់គ្រាន់ហើយ លោក

គប្បីថ្វាយ (សំពត់ផ្ទាំងនេះ) ដល់ភិក្ខុរូបណាតាមដែលលោកប្រាថ្នា ។ ក្នុងកាលនោះ ទានវត្ថុគ្រប់យ៉ាងរបស់ឧបាសកនោះគ្រប់ល្មម អ្វីៗ ឈ្មោះថាខ្វះខាតរមែងមិនមាន ។ ឧបាសកនោះទើបសួរមនុស្សទាំងឡាយថា សំពត់កាសាវៈដ៏ប្រសើរកាត់ថ្លៃមិនបានផ្ទាំងនេះ ដែលកុដុម្ពិក៍ម្នាក់ពោលយ៉ាងនេះហើយប្រគល់ឲ្យ ទានវត្ថុ (របស់ពួកយើង) ក៏គ្រប់គ្រាន់ល្មមហើយ យើងទាំងឡាយនឹងថ្វាយសំពត់កាសាវៈផ្ទាំងនេះដល់ភិក្ខុរូបណាហ្ន៎ ។ ជនពួកខ្លះពោលថា "ថ្វាយដល់ព្រះសារីបុត្រ" ។ ពួកខ្លះពោលថា "ព្រះថេរៈដែលមកក្នុងវេលាសន្ទូងចាស់ ហើយក៏ទៅ ព្រះទេវទត្តជាសំឡាញ់ក្នុងការងារជាមង្គល និងអវមង្គលទាំងឡាយរបស់ពួកយើង តាំងនៅជានិច្ច ដូចជាថ្នាំងទឹកធំ (ពាងទឹក) ពួកយើងនឹងថ្វាយផ្ទាំងសំពត់នោះដល់លោក" ។ សូម្បីកាលពាក្យប្រព្រឹត្តទៅច្រើនផ្លូវ (យ៉ាងនោះ) ពួកដែលពោលថា "គួរថ្វាយដល់ព្រះទេវទត្ត" មានចំនួនច្រើនជាង ។ ដូច្នោះ ពួកគេទើបបានថ្វាយសំពត់កាសាវៈនោះដល់ព្រះទេវទត្ត ។ ព្រះទេវទត្តកាត់សំពត់នោះហើយដេរ ជ្រលក់ ស្លៀកដណ្តប់ត្រាច់ទៅ ។ ពួកមនុស្សឃើញលោកហើយ ទើប

និយាយគ្នាថា "សំពត់ផ្ទាំងនេះមិនសមគួរដល់ព្រះទេវទត្តទេ សមគួរដល់ព្រះសារីបុត្រ ព្រះទេវទត្តស្លៀកដណ្តប់សំពត់ដែលមិនសមគួរដល់ខ្លួន ត្រាច់ទៅ" ។

គ្រានោះ ភិក្ខុអ្នកនៅទិសផ្សេងមួយរូប[១] (ចេញ) ចាកក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថី ថ្វាយបង្គំព្រះសាស្តាហើយ ជាអ្នកដែលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈ ត្រាស់សួរដល់ការនៅជាសុខរបស់ព្រះអគ្គសាវ័កទាំងពីរហើយ ទើបក្រាបទូលរឿងនោះទាំងអស់តាំងអំពីដើម ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុ ទេវទត្តនោះប្រើសំពត់ដែលមិនសមគួរដល់ខ្លួន មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន គេក៏ប្រើហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមក (ត្រាស់ថា) ៖

## គ្រាមុនព្រះទេវទត្តជាព្រានដំរី

ក្នុងអតីតកាល កាលស្តេចព្រហ្មទត្តគ្រប់គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ព្រានដំរីអ្នកនគរពារាណសីម្នាក់ សម្លាប់ដំរីហើយ នាំភ្លុក ស្បែក

---

១. ភិក្ខុអ្នកនៅក្រុងផ្សេង ។

ពោះវៀនធំ និងសាច់ មកលក់ចិញ្ចឹមជីវិត ។ គ្រានោះដំរីច្រើនពាន់ ដើររកអាហារនៅក្នុងព្រៃមួយកន្លែង ជួបព្រះបច្ចេកពុទ្ធច្រើនអង្គ តាំងពីនោះមកកាលទៅ ក៏លុតជង្គង់ក្រាបចុះ[១] ក្នុងកាលដែលចូងកាត់ទៅមក (គ្រប់គ្រា) ទើបចូងទៅ ។ ថ្ងៃមួយ ព្រានដំរី ឃើញអាការនោះហើយគិតថា "យើងចាប់ដំរីទាំងនេះបានដោយលំបាក ក៏ក្នុងកាលចូងកាត់ទៅ និងមក ដំរីទាំងនេះរមែងជួបព្រះបច្ចេកពុទ្ធទាំងឡាយ ដំរីឃើញអ្វីហ្ន៎ទើបគោរព" កំណត់បានថា "ឃើញសំពត់កាសាវៈ" ដូច្នេះ បានគិតថា "ឥឡូវនេះ សូម្បីយើងគួរបានសំពត់កាសាវៈ" កាលព្រះបច្ចេកពុទ្ធមួយអង្គចុះកាន់ជាតស្រះ[២]ស្រង់ទឹក ដាក់សំពត់កាសាវៈទាំងឡាយលើមាត់ច្រាំង (ព្រាន) ទើបលួចយកចីវរមួយផ្ទាំង អង្គុយដណ្តប់គ្របជិតខ្លួនក្បែរមាត់ផ្លូវ ដែលដំរីទាំងនោះទៅមក ។ ពួកដំរីឃើញគេហើយ ទើបគោរពដោយសំគាល់ថាជាព្រះបច្ចេកពុទ្ធ ។ ហើយក៏ចូងទៅ ។ ព្រានដំរីនោះ ពួយលំពែងទៅត្រូវដំរីខាងក្រោយគេឲ្យស្លាប់ ហើយកាន់យកចំណែកផ្សេងៗ មានភ្លុកជាដើម ចំណែកដ៏សេសកប់ក្នុងដែនដី

---

១. កិរិយារបស់ដំរីដែលធ្វើសេចក្តីគោរព ត្រូវជាមួយពាក្យថា សំពះ ។
២.ជាតស្រះ ស្រះដែលមិនមាននរណាជីក ។

ហើយទៅ ។ ក្នុងកាលកន្លងមក ព្រះពោធិសត្វចាប់បដិសន្ធិក្នុងកំណើតដំរី បានជាប្រធានដំរី ជាមេហ្វូង ។ ក្នុងកាលនោះ ព្រានដំរីនោះក៏គង់ធ្វើយ៉ាងនោះ ។ ព្រះមហាបុរសឈរវេងចាំការទៅនៃបរិស័ទរបស់ខ្លួន ទើបសួរថា “ដំរីទាំងនេះទៅណា ទើបសល់តិចទៅៗ” កាលពួកដំរីទាំងនោះឆ្លើយថា ”មិនដឹងទេ” ទើបគិតថា “ដំរីទាំងឡាយទៅណាមិនប្រាប់យើង (មុន) ប្រហែលមានអន្តរាយ” នឹកសង្ស័យថា “អន្តរាយគប្បីមានពីសម្នាក់បុរសដែលអង្គុយឃ្មុំសំពត់កាសាវៈក្នុងទីកន្លែងមួយ” ដើម្បីនឹងចាប់បុរសនោះ ទើបបញ្ជាដំរីទាំងអស់ឲ្យទៅខាងមុខមុន ចំណែកខ្លួនមកខាងក្រោយ ។ ព្រានដំរីនោះ កាលដំរីដ៏សេសគោរពហើយដើរទៅ ឃើញព្រះមហាបុរសកំពុងដើរមកដល់ ក៏លាត់ចីវរពួយលំពែងទៅ ។ ព្រះមហាបុរសតាំងសតិដើរចូល ហើយត្រឡប់ថយទៅខាងក្រោយ គេចពីលំពែង ទើបរត់ចូលទៅដើម្បីចាប់ព្រានដំរី ដោយសំគាល់ថា “មនុស្សនេះឯងឲ្យដំរីពួកយើងវិនាស” ។ ព្រានដំរីនោះក៏គេចឯបទីងដើមឈើមួយដើម ។ ពេលនោះព្រះមហាបុរស យកប្រមោយចាប់ព្រានរួបនឹងដើមឈើ ដោយតាំងចិត្តថា

ចាប់បោកនឹងផែនដី (លុះ) ឃើញសំពត់កាសាវៈដែលគេនាំចេញមក ទើបមិនបោក ដោយគិតឃើញថា "បើយើងប្រទូសរ៉ាយ ក្នុងបុរសនេះសោត ឈ្មោះថា សេចក្តីអៀនខ្មាសក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព ច្រើនពាន់អង្គ ក៏ឈ្មោះថា យើងជាអ្នកបំផ្លាញហើយ" ទើបសួរថា "ញាតិរបស់យើងប្រមាណប៉ុណ្ណេះ អ្នកធ្វើឲ្យវិនាសឬ" ។ ព្រានដំរីទទួលសារភាពថា "បាទ នាយ" ។ ព្រះមហាបុរសពោលថា "ព្រោះហេតុអ្វី អ្នកទើបធ្វើកម្មដ៏អាក្រក់យ៉ាងនេះ អ្នកដណ្តប់សំពត់ដែលមិនសមគួរដល់ខ្លួន ដែលសមគួរចំពោះតែលោកអ្នកប្រាសចាករាគៈទាំងឡាយ កាលធ្វើបាបកម្មបែបនេះ ឈ្មោះថា ធ្វើកម្មដ៏អាក្រក់" លុះពោលយ៉ាងនេះហើយ កាលនិងញាំញីឲ្យខ្លាំងឡើង ទើបពោលគាថានេះថា ៖

អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។
យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតា
ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

អ្នកណា នៅមានទឹកចត់ គឺ រាគទិក្កិលេស (ក្នុងសន្តាន) ជាអ្នកបោះបង់ការទូន្មានទូវឥន្ទ្រិយ និងសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។

លុះតែអ្នណា មានទឹកចត់ គឺ រាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បា-រិសុទ្ធិសីល ប្រកបដោយការទូន្មានទូវឥន្ទ្រិយ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់នូវសំពត់កាសាវៈបាន ។

ដូច្នេះហើយពោលថា "អ្នកធ្វើកម្មដែលមិនសមគួរ" ហើយក៏លែងគេទៅ ។

ព្រះសាស្តាលុះទ្រង់នាំព្រះធម្មទេសនានេះមក (សំដែង) ហើយ ទ្រង់សរុបជាតកថា "ព្រានដំរីក្នុងកាលនោះ បានជាទេវទត្ត (ក្នុងកាលឥឡូវនេះ) ដំរីដ៏ប្រសើរជាអ្នកញាំញីព្រានដំរីនោះ គឺ តថាគតនេះឯង" ហើយត្រាស់ថា "ម្នាលភិក្ខុ មិនមែនតែក្នុងកាលនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុននោះ

ទេវទត្តក៏ប្រើសំពត់មិនសមគួរដល់ខ្លួនដូចគ្នា” ហើយបានភាសិតព្រះគាថាទាំងនេះថា ៖

យោ ច វន្តកសាវស្ស    សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន    ស វេ កាសាវមរហតិ ។

លុះតែអ្នកណា មានទឹកចត់ គឺ រាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់នូវសំពត់កាសាវៈបាន ។

សេចក្តីនេះ បណ្ឌិតគប្បីសំដែងដោយឆទ្ទន្តជាតក ដូច្នេះឯង ។

## អធិប្បាយគាថា

ក្នុងបទទាំងនោះ បទថា **អនិក្កសាវោ** (មានកិលេសដូចទឹកចត់ដែលនៅមិនទាន់ខ្ជាក់ចេញ) បានដល់ មានកិលេសដូចទឹកចត់ ព្រោះកិលេសដូចទឹកចត់ទាំងឡាយ មានកាមរាគៈជាដើម ។ បទថា **បរិទហេស្សតិ** (នឹង

*ស្ងៀកដណ្តប់)* បានដល់ នឹងប្រើប្រាស់ដោយអំណាចនៃការស្ងៀកដណ្តប់និងការក្រាល ។ ព្រះបាលីថា *"បរិទហិស្សតិ"* ក៏មាន ។ បទថា **អបេតោ ទមសច្ចេន (ប្រាសចាកទមៈ និងសច្ចៈ)** បានដល់ ប្រាសចាកការទូន្មានឥន្ទ្រិយ និងវចីសច្ចៈដែលជាចំណែកបរមត្ថសច្ចៈ អធិប្បាយថា ឫសគល់ ។ បទថា **ន សោ (អ្នកនោះរមែងមិនគួរ)** ជាដើម បានដល់ បុគ្គលនោះ គឺ បុគ្គលបែបនោះ រមែងមិនគួរស្ងៀកដណ្តប់សំពត់កាសាវៈ ។

បទថា *វន្តកសាវស្ស* **(អ្នកមានកិលេសដូចទឹកចត់ខ្ជាក់ចេញហើយ)** បានដល់ គប្បីជាអ្នកមានកិលេសដូចទឹកចត់ដែលខ្ជាក់ចេញហើយ គឺ មានកិលេសដូចទឹកចត់ដែលខ្ជាក់ចេញហើយ បានដល់ មានកិលេសដូចទឹកចត់ដែលខ្ជាក់អស់ហើយ ដោយមគ្គ ៤ ។ បទថា **សីលេសុ (តាំងមាំល្អ)** បានដល់ ជាអ្នកតាំងមាំដោយល្អ គឺ តាំងនៅដោយល្អ ។ បទថា **ឧបេតោ (ប្រកប)** បានដល់ ប្រកបដោយការទូន្មានឥន្ទ្រិយ និងវចីសច្ចៈមានប្រការដូចពោលមកហើយ ។ បទថា **ស វេ (អ្នកនោះឯង)** ជាដើម បានដល់ បុគ្គលនោះ គឺ បុគ្គលបែបនោះ រមែងសមគួរ (ស្ងៀកដណ្តប់) សំពត់

កាសាវនោះ ។

ក្នុងកាលចប់គាថា ភិក្ខុអ្នកនៅក្នុងទិសផ្សេងៗ នោះ ក៏បានសម្រេចជាព្រះសោតាបន្ន ។ ជនសូម្បីពួកដទៃមានចំនួនច្រើន សម្រេចអរិយផលទាំងឡាយ មានសោតបត្តិផលជាដើម ។ ទេសនាបានសម្រេចប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់រឿងព្រះទេវទត្ត

# ៨ រឿងសញ្ជ័យ

ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធការមិនមករបស់សញ្ជ័យ (បរិព្វាជក) ដែលព្រះអគ្គសាវ័កទាំងពីរក្រាបទូលហើយ ត្រាស់ធម្មទេសនានេះថា **អសារេ សារមតិនោ** (មានប្រក្រតីដឹងក្នុងវត្ថុដែលមិនជាសារៈថា ជាសារៈ) ជាដើម ។ អនុបុព្វិកថាក្នុងរឿងសញ្ជ័យនោះ មានដូចតទៅនេះ ៖

សេចក្តីពិស្តារថា ក្នុងទីបំផុតនៃ ៤ អសង្ខេយ្យមួយសែនកប្ប រាប់ថយក្រោយពីកប្បនេះទៅ ព្រះសាស្តារបស់យើងទាំងឡាយ ជាព្រាហ្មណ-កុមារ នាមថា សុមេធៈ ក្នុងអមរវតីនគរ ដល់នូវការសម្រេចសិល្បៈគ្រប់យ៉ាង កាលមាតាបិតាធ្វើមរណកាលទៅ ក៏បរិច្ចាគទ្រព្យរាប់បានដោយច្រើនកោដិ បួសជាឥសីនៅក្នុងព្រៃហិមពាន្តប្រទេស ធ្វើឈាន និងអភិញ្ញាឲ្យកើតឡើង ទៅតាមអាកាស ឃើញមនុស្សត្រាយផ្លូវ ដើម្បីប្រយោជន៍ស្តេច (យាង) ចាកសុទស្សនវិហារ ចូលទៅកាន់អមរវតីនគរ នៃព្រះទសពល ទ្រង់ព្រះនាមថា **ទីបង្ករ** សូម្បីខ្លួនឯងក៏កាន់យក (ត្រាយផ្លូវ) ក្នុងទីមួយ

កន្លែង ទីនោះនៅមិនទាន់សម្រេច ក្រាលស្បែកខ្លាពណ៌លឿងលើកក់ល្បាប់ ដេកសន្ធឹងខ្លួន ធ្វើជាស្ពានដើម្បីព្រះសាស្តាស្តេចមក ដោយបំណងថា សូមព្រះសាស្តាព្រមទាំងព្រះសង្ឃសាវ័ក ទ្រង់កុំប្រឡាក់ភក់ ចូរទ្រង់ជាន់លើយើង ហើយស្តេចយាងចុះ ។ ពេលព្រះសាស្តាទតព្រះនេត្រឃើញ ក៏ទ្រង់ព្យាករណ៍ថា បុគ្គលនេះជាពុទ្ធង្កូរ[១] នឹងជាព្រះពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមថា **គោតម** ក្នុងទីបំផុត ៤ អសង្ខេយ្យមួយសែនកប្ប ក្នុងកាលជាអនាគត ។ ក្នុងសម័យតមកនៃព្រះសាស្តាព្រះអង្គនោះ ក៏បានទទួលព្យាករណ៍ក្នុងសំណាក់ព្រះពុទ្ធ ២៣ ព្រះអង្គ ដែលស្តេចឧប្បត្តិឡើង ញុំាងលោកឲ្យភ្លឺស្វាងទាំងនេះ គឺ ៖

១.ព្រះកោណ្ឌញ្ញៈ ២.ព្រះសុមង្គលៈ ៣.ព្រះសុមនៈ

៤.ព្រះរេវតៈ ៥.ព្រះសោភិតៈ ៦.ព្រះអនោមទស្សី

៧.ព្រះបទុមៈ ៨.ព្រះនារទៈ ៩.ព្រះបទុមុត្តរៈ

១០.ព្រះសុមេធៈ ១១.ព្រះសុជាតៈ ១២.ព្រះបិយទស្សី

---

១. ជាពូជពង្ស ខ្សែស្រឡាយ នៃព្រះពុទ្ធ ។

១៣.ព្រះអត្ថទស្សី ១៤.ព្រះធម្មទស្សី ១៥.ព្រះសិទ្ធត្ថៈ

១៦.ព្រះតិស្សៈ ១៧.ព្រះបុស្សៈ ១៨.ព្រះវិបស្សី

១៩.ព្រះសិខី ២០.ព្រះវេសភូ ២១.ព្រះកកុសន្ធៈ

២២.ព្រះកោនាគមនៈ ២៣.ព្រះកស្សបៈ

ទ្រង់បំពេញបារមីគ្រប់ ៣០ គឺ បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ (កាល) តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ឲ្យមហាទានធ្វើផែនដីឲ្យញាប់ញ័រ ៧ ដង ទ្រង់បរិចាគព្រះឱរស និងព្រះជាយា ក្នុងទីបំផុតព្រះជន្មាយុ ក៏ទ្រង់ឧប្បត្តិក្នុងសួគ៌ជាន់តុសិត តាំងនៅក្នុងតុសិតសួគ៌នោះរហូតអស់ព្រះជន្មាយុ កាលទេវតាក្នុងមួយម៉ឺនចក្រវាឡប្រជុំគ្នាអារាធនាថា ៖

បពិត្រព្រះមហាវីរៈ កាលនេះ ជាកាលរបស់ព្រះអង្គ សូមព្រះអង្គចូរស្តេចឧប្បត្តិក្នុងព្រះគភ៌ព្រះមាតា ត្រាស់ដឹងអមតបទ ញ៉ាំងលោកនេះ និងទេវលោកឲ្យឆ្លងផង ។

ទ្រង់ពិចារណានូវឋានៈធំៗ ដែលគួរពិចារណា[១] ៥ ស្តេចចុតិចាក

---

១.ឋានៈធំដែលគួរជ្រើសរើស ៥ គឺ ១.កាល ២.ប្រទេស ៣.ទ្វីប ៤.ត្រកូល ៥.មាតា ។

តុសិតសួគ៌នោះហើយ ទ្រង់ចាប់បដិសន្ធិក្នុងសក្យរាជត្រកូល ដែលព្រះញាតិវង្សបម្រើហើយដោយមហាសម្បត្តិក្នុងសក្យរាជត្រកូលនោះ ទ្រង់ដល់ការចម្រើនវ័យដោយលំដាប់ សោយសិរីរាជសម្បត្តិក្នុងប្រាសាទទាំងបី ដែលសមគួរដល់រដូវទាំងបី ដូចសោយសិរីសម្បត្តិក្នុងទេវលោក ។

ក្នុងសម័យដែលស្ដេចទៅដើម្បីប្រពាតព្រះឧទ្យាន ទ្រង់ឃើញទេវទូត ៣ គឺ មនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ ដោយលំដាប់ ទ្រង់កើតសេចក្ដីសង្វេគ ស្ដេចក៏យាងត្រឡប់មកវិញ ។ ក្នុងវារៈទី ៤ ទ្រង់ឃើញបព្វជិត ទ្រង់មានការពេញព្រះទ័យក្នុងការបព្វជ្ជាឲ្យកើតឡើងថា ការបព្វជ្ជាជាការល្អ ស្ដេចទៅកាន់ព្រះឧទ្យាន ញុំាងថ្ងៃឲ្យអស់ទៅក្នុងព្រះឧទ្យាននោះ ប្រថាប់អង្គុយក្បែរមាត់ស្រះបោក្ខរណីដែលជាមង្គល ដែលវិស្សុកម្មទេវបុត្រក្លែងភេទជាជាងកាត់សក់ មកតាក់តែងព្រះអង្គថ្វាយ ទ្រង់ជ្រាបដំណឹងប្រសូតរបស់ព្រះរាហុលកុមារ ទ្រង់ជ្រាបដល់ការស្រឡាញ់ក្នុងព្រះឱរសមានកម្លាំង ទ្រង់ត្រិះរិះថា "យើងនឹងកាត់គ្រឿងចងនេះ មិនឲ្យជាគ្រឿងចង (យើង) បាន" វេលាល្ងាចស្ដេចចូលទៅកាន់ព្រះនគរ ទ្រង់ស្ដាប់គាថានេះ ដែល

ព្រះធីតារបស់ស្តេចតូព្រះនាមថា កេសាគោតមី ភាសិតថា ៖

ព្រះរាជកុមារនេះ ជាព្រះរាជឱរសនៃព្រះជននីណា ព្រះជនកណា និងជាព្រះស្វាមីរបស់ព្រះនាងណា ព្រះជននី និងព្រះជនកនោះៗ រលត់ (ត្រជាក់ចិត្ត) ដោយពិតហើយ ។

ទ្រង់ព្រះតម្រិះថា យើង ដែលព្រះនាងកេសាគោតមីនេះ (សូត្រ) ឲ្យបានឮនិព្វុតបទហើយ ទើបដោះកែវមុក្តាហារពីព្រះក បញ្ជូនទៅប្រទានឲ្យព្រះនាង ហើយស្តេចចុះទៅកាន់ទីនៅរបស់ព្រះអង្គ ប្រថាប់អង្គុយលើក្រឡាបន្ទំដ៏មានសិរី ទតឃើញប្រការដែលចម្លែករបស់ពួកស្រីរបាំ ដែលដល់នៅការលក់ហើយ ទ្រង់មានព្រះទ័យនឿយណាយ ទើបដាស់នាយឆន្នៈឲ្យក្រោកឡើង ឲ្យនាំសេះកណ្ឋកៈ (កន្ថកៈ) មក ស្តេចឡើងជិះសេះកណ្ឋកៈ មាននាយឆន្នៈជាសំឡាញ់ មានទេវតាក្នុងមួយម៉ឺនចក្រវាឡហែហមហើយ ស្តេចចេញមហាភិនេស្ក្រមណ៍ ទ្រង់បព្វជ្ជាត្រង់មាត់ប្រាំងស្ទឹងអនោមា ស្តេចទៅដល់ក្រុងរាជគ្រឹះដោយលំដាប់ ស្តេចយាងបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះនោះ ប្រថាប់គង់ត្រង់ញកភ្នំបណ្ឌវៈ ដែលព្រះចៅផែនដីមគធៈទ្រង់ថ្វាយ

ដោយរាជសម្បត្តិ ទ្រង់បដិសេធការថ្វាយនោះ ទ្រង់ឲ្យប្តេជ្ញាដល់ព្រះរាជា ដើម្បីប្រយោជន៍ដល់ការបានសម្រេចព្រះសព្វញ្ញុតញ្ញាណ ហើយក៏ស្តេចយាងមកកាន់ដែនរបស់ព្រះអង្គ ស្តេចចូលទៅរកអាឡារតាបស និងឧទ្ទក-តាបស ទ្រង់មិនពេញព្រះទ័យក្នុងគុណវិសេស ដែលទ្រង់បានសម្រេចក្នុងសំណាក់របស់តាបសទាំងពីរនោះ ទ្រង់តាំងសេចក្តីព្យាយាមធំ ៦ ឆ្នាំ ក្នុងថ្ងៃវិសាខបុណ្ណមី ពេលព្រឹកសោយបាយបាយាស ដែលនាងសុជាតាថ្វាយហើយ ទ្រង់បណ្តែតថាសមាសក្នុងស្ទឹងនេរញ្ជរា ឲ្យចំណែកនៃថ្ងៃកន្លងទៅដោយសមាបត្តិផ្សេងៗ ក្នុងព្រៃមហាវ័ន ក្បែរមាត់ស្ទឹងនេរញ្ជរា វេលាល្ងាចទ្រង់ទទួលស្បូវក្តាំងដែលនាយសោត្ថិយថ្វាយ មានព្រះគុណ ដែលស្តេចកាឡនាគរាជសរសើរហើយ ស្តេចឆ្ពោះទៅកាន់ដើមពោធិ ទ្រង់ក្រាលស្បូវក្តាំងហើយ ធ្វើប្តេជ្ញាថា យើងនឹងមិនទម្លាយភ្នែននេះ រហូតវេលាដែលចិត្តរបស់យើងមិនទាន់រួចផុតចាកអាសវៈទាំងឡាយ ដោយការមិនប្រកាន់មាំនោះ ប្រថាប់គង់ពត់ភ្នែនមានព្រះភ័ក្ត្រឆ្ពោះទៅកាន់ទិសបូព៌ា កាលព្រះអាទិត្យមិនទាន់អស្តង្គត ទ្រង់កម្ចាត់មារ និងពលមារ ទ្រង់បានសម្រេចបុព្វេនិវាស-

ញ្ញាណ[១]ក្នុងបឋមយាម សម្រេចចុតូបបាតញ្ញាណ[២]ក្នុងមជ្ឈិមយាម ញ៉ាំង ព្រះញាណចុះក្នុងបច្ចយាការក្នុងទីបំផុតបច្ឆិមយាម ក្នុងវេលាអរុណរះឡើង ទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណ ដែលប្រដាប់ដោយគុណគ្រប់យ៉ាង មានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាអាទិ៍ ទ្រង់ញ៉ាំងកាលឲ្យកន្លងទៅត្រង់គល់ពោធិព្រឹក្សអស់ ៧ សប្តាហ៍ ។ ក្នុងសប្តាហ៍ ទី ៨ ប្រថាប់គង់ត្រង់គល់ឈើអជបាលនិគ្រោធ ទ្រង់ដល់ភាពជាអ្នកខ្វល់ខ្វាយតិច ដោយពិចារណាឃើញថា ធម៌មានសភាពជ្រាលជ្រៅ ដែលស្ដេចសហម្បតីព្រហ្មមានព្រហ្មមួយម៉ឺនជាបរិវារ អារាធនាទ្រង់សំដែងធម៌ ទ្រង់ពិចារណាមើលសត្វលោកដោយពុទ្ធចក្ខុហើយ ទ្រង់ទទួលការអារាធនារបស់ព្រហ្ម ទ្រង់មានព្រះតម្រិះថា "តថាគតគប្បីសំដែងធម៌ដល់នរណា ជាមនុស្សដំបូង" ។ កាលទ្រង់ពិចារណា ជ្រាបថា អាឡារតាបស និងឧទកៈតាបសធ្វើកាលៈហើយ ទ្រង់ត្រឡប់រឭកដល់ឧបការៈច្រើនរបស់ភិក្ខុបញ្ចវគ្គិយៈ ស្ដេចក្រោកចាកអាសនៈយាងទៅកាន់កាសីបុរី ក្នុងរវាងផ្លូវ បានសន្ទនាជាមួយ

---

១. ញាណក្នុងការរឭកជាតិបាន. ២. ញាណក្នុងការកំណត់ចុតិ និងឧប្បត្តិ ។

ឧបកាជីវក ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ស្តេចដល់ទីនៅរបស់ភិក្ខុបញ្ចវគ្គិយ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ញ៉ាំងភិក្ខុបញ្ចវគ្គិយទាំងនោះ ដែលស្រែកហៅ (ព្រះអង្គ) ដោយពាក្យដែលមិនសមគួរ ឲ្យភ្ញាក់រឭកហើយ កាលនឹងញ៉ាំងព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាន ឲ្យផឹកទឹកអមតៈ ទើបទ្រង់សំដែងព្រះធម្មចក្ក ទ្រង់មានធម្មចក្កដ៏បវរឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងតិថីទី ៥ នៃបក្ខ ទ្រង់ញ៉ាំងភិក្ខុទាំងអស់នោះ ឲ្យតាំងនៅក្នុងព្រះអរហត្ត ក្នុងថ្ងៃជាមួយគ្នានោះ ទ្រង់ឃើញការដល់ព្រមនៃឧបនិស្ស័យរបស់យសកុលបុត្រហើយ ត្រាស់ហៅគេដែលនឿយណាយនឹងផ្ទះចេញមកក្នុងពេលយប់ថា "មកទីនេះចុះ យស" ធ្វើគេឲ្យសម្រេចសោតាបត្តិផលក្នុងវេលាយប់នោះឯង ក្នុងវេលាអរុណរះឡើង ឲ្យបានសម្រេចព្រះអរហត្ត ទ្រង់ញ៉ាំងសំឡាញ់របស់យសកុលបុត្រនោះ សូម្បីពួកដទៃ ៥៤ នាក់ទៀត ឲ្យបព្វជ្ជាជាឯហិភិក្ខុឧបសម្បទា ហើយឲ្យបានសម្រេចព្រះអរហត្ត ។

# ព្រះសាស្តាទ្រង់បញ្ជូនសាវ័កឱ្យប្រកាសព្រះសាសនា

*ព្រះអរហន្ត ៦១ អង្គ កើតឡើងក្នុងលោក ដោយប្រការយ៉ាងនេះហើយ ព្រះសាស្តាស្តេចចាំវស្សាបវារណាហើយ ទ្រង់បញ្ជូនភិក្ខុ ៦០ អង្គទៅក្នុងទិសទាំងឡាយដោយព្រះពុទ្ធតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូលចារិកទៅចុះ ដូច្នេះជាដើម ចំណែកព្រះអង្គស្តេចទៅ កាន់ឧរុវេលាប្រទេស ក្នុងរវាងផ្លូវទ្រង់បានណែនាំភទ្ទវគ្គិយកុមារ ៣០ នាក់ នៅឯព្រៃកប្បាសិកវ័ន (ព្រៃកប្បាស) ។ បណ្តាភទ្ទវគ្គិយកុមារ ៣០ នាក់ នោះយ៉ាងទាបបំផុតត្រឹមសោតាបន្ន ខ្ពស់ជាងគេបង្អស់ បានជាព្រះអនាគាមី ។ ព្រះពុទ្ធ ទ្រង់ឲ្យភទ្ទវគ្គិយទាំងអស់នោះបព្វជ្ជាដោយភាពជាឯហិភិក្ខុនោះឯងហើយទ្រង់បញ្ជូនទៅក្នុងទិសទាំងឡាយ ចំណែកព្រះអង្គ ស្តេចយាងទៅកាន់ឧរុវេលាប្រទេស ទ្រង់សំដែងបាដិហារិយ៍ ៣.៥០០ យ៉ាង ណែនាំជដិល ៣នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម ដែលមានជដិលមានមួយពាន់នាក់ជាបរិវារ ឲ្យបព្វជ្ជាដោយភាពជាឯហិភិក្ខុនោះឯង ទើបបានឲ្យប្រជុំគ្នាត្រង់គយាសីសៈប្រទេស ឲ្យតាំងនៅក្នុងព្រះអរហត្តដោយអាទិត្តបរិយាយទេសនា*

មានព្រះអរហន្តមួយពាន់អង្គហែហម ស្ដេចយាងទៅកាន់ឧទ្យានលដ្ឋិវ័ន ជិតក្រុងរាជគ្រឹះ ដោយទ្រង់ព្រះតម្រិះថា "នឹងដោះបេក្ខជ្ញាដែលទ្រង់ថ្វាយទុកដល់ព្រះបាទពិម្ពិសារ" ត្រាស់ព្រះធម្មកថាដ៏ពីរោះដល់ព្រះរាជា ដែលទ្រង់ទទួលដំណឹងថា "ក្រាបថា ព្រះសាស្ដាស្ដេចយាងមកហើយ" ស្ដេចក៏មកគាល់ព្រមទាំងព្រាហ្មណ៍ និងគហបតី ១២ នហុត[១] ញ៉ាំងព្រះរាជា និងព្រាហ្មណ៍ និងគហបតី ១១ នហុត ឲ្យតាំងនៅក្នុងសោតាបត្តិផល ១ នហុតទៀត ឲ្យតាំងនៅក្នុងសរណៈ ៣ ។ ស្អែកឡើង ស្ដេចសក្កទេវរាជដែលទ្រង់ក្លែងភេទជាមាណពសរសើរហើយ ស្ដេចចូលកាន់ក្រុងរាជគ្រឹះ ទ្រង់ធ្វើភត្តកិច្ចក្នុងព្រះរាជនិវេសន៍ ទ្រង់ទទួលវេឡុវនារាម[២] ប្រថាប់នៅក្នុងវេឡុវនារាមនោះឯង ។ ព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន ចូលទៅគាល់ព្រះអង្គក្នុងវេឡុវនារាមនោះ ។ អនុបុព្វិកថាក្នុងរឿងព្រះសារីបុត្តនិងព្រះមហាមោគ្គល្លាននោះ ដូចតទៅនេះ ៖

---

១. មួយនហុត = ១០.០០០ នាក់ ។

២. ជាមូលហេតុនៃការថ្វាយវត្តក្នុងព្រះពុទ្ធសាសនាក្នុងកាលតៗ មក ។

# ប្រវត្តិព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន

*សេចក្តីពិស្តារថា កាលព្រះពុទ្ធទ្រង់មិនទាន់បានឧប្បត្តិឡើងហើយនោះឯង ។ មានស្រុកព្រាហ្មណ៍ ២ ត្រកូល គឺ ឧបតិស្សគ្រាម ១ និងកោលិតគ្រាម ១ ក្នុងទីមិនឆ្ងាយអំពីក្រុងរាជគ្រឹះ ។ ក្នុងស្រុកពីរនោះ ក្នុងថ្ងៃដែលនាងព្រាហ្មណីឈ្មោះសារី ក្នុងឧបតិស្សគ្រាមតាំងគភ៌ សូម្បីនាងព្រាហ្មណីឈ្មោះមោគ្គល្លី ក្នុងកោលិតគ្រាមក៏តាំងគភ៌ ។ បានឮថា ត្រកូលទាំងពីរនោះ បានជាសំឡាញ់ជាប់ទំនាក់ទំនងនឹងគ្នារហូតអស់ ៧ ជួរត្រកូលមកហើយ ។ ព្រាហ្មណ៍ជាស្វាមី បានឲ្យពិធីរក្សាគភ៌ដល់ព្រាហ្មណីទាំងពីរនោះ ក្នុងថ្ងៃមួយជាមួយគ្នានោះឯង ។ ដោយកាលកន្លងទៅ ១០ ខែ នាងព្រាហ្មណីទាំងពីនោះក៏ប្រសូតបុត្រ ។ ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិតាំងឈ្មោះបុត្ររបស់នាងសារីព្រាហ្មណីថា ឧបតិស្សៈ ព្រោះជាបុត្ររបស់ត្រកូលម្ចាស់ស្រុក ក្នុងតំបន់ឧបតិស្សគ្រាម , តាំងឈ្មោះរបស់មោគ្គល្លីព្រាហ្មណីថា កោលិតៈ ព្រោះជាបុត្រនៃត្រកូលម្ចាស់ស្រុក ក្នុងតំបន់កោលិតគ្រាម ។ ក្មេងទាំងពីរនោះ ដល់វ័យចម្រើនហើយ ក៏បានដល់ការសម្រេចនូវសិល្បៈ*

គ្រប់យ៉ាង ។ ក្នុងវេលាទៅកាន់ស៊ីង ឬសួន ដើម្បីទឹងលេង ឧបតិស្ស-
មាណពមានសង្រែកមាស ៥០០ ជាគ្រឿងហែហម កោលិតមាណពមាន
រថទឹមដោយសេះអាជានេយ្យ ៥០០ ជាគ្រឿងហែហម ជនទាំងពីរ មាន
មាណពជាបរិវារម្នាក់ ៥០០ ។ ក៏ក្នុងក្រុងរាជគ្រឹះ មានមហោស្រពរាល់ៗ
ឆ្នាំ ។ ពួកញាតិបានយកគ្រែតម្រួតគ្នាដើម្បីកុមារទាំងពីរនោះ នៅក្នុងទី
ជាមួយគ្នានោះឯង ។ សូម្បីកុមារទាំងពីរ ក៏អង្គុយមើលមហោស្រពជា
មួយគ្នា រមែងសើចក្នុងឋានៈដែលគួរសើច រមែងដល់នូវការសង្វេគក្នុង
ឋានៈដែលគួរសង្វេគ រមែងឲ្យរង្វាន់ក្នុងឋានៈដែលគួរឲ្យរង្វាន់ ។ ថ្ងៃមួយ
កាលកុមារទាំងពីរនាក់នោះមើលមហោស្រពតាមទំនងនេះ ការសើចក្នុង
ឋានៈដែលគួរសើច ឬការសង្វេគក្នុងឋានៈដែលគួរសង្វេគ ឬការឲ្យរង្វាន់
ក្នុងឋានៈដែលគួរឲ្យរង្វាន់ មិនបានមានដូចក្នុងថ្ងៃមុនៗ ព្រោះញាណដល់
នូវភាពចាស់ក្លាហើយ ។ ក៏ជនទាំងពីរនាក់គិតគ្នាយ៉ាងនេះថា "នឹងមាន
អ្វីដែលគួរមើលក្នុងទីនេះ ជនសូម្បីទាំងអស់នេះ កាលនៅមិនទាន់ដល់
១០០ ឆ្នាំ ក៏នឹងដល់នូវការបញ្ញត្តិមិនបាន ក៏យើងទាំងពីរគួរស្វែងរកធម៌

ជាគ្រឿងរួចផុតដ៏ឯក” ដូច្នេះ ហើយកាន់យកជាអារម្មណ៍ ក៏អង្គុយចុះ ។ លំដាប់នោះ កោលិតៈនិយាយចំពោះឧបតិស្សៈថា ឧបតិស្សៈសំឡាញ់ ដូចម្តេចលោកទើបមិនសើច សប្បាយដូចក្នុងថ្ងៃមុនៗ ថ្ងៃនេះ លោកមានចិត្តមិនរីករាយ លោកកំណត់អ្វីបានឬ ។ ឧបតិស្សៈពោលថា កោលិតៈសំឡាញ់ យើងអង្គុយគិតដល់ហេតុនេះថា ក្នុងការមើលមនុស្សទាំងនេះ រកសារៈមិនបាន ការមើលនេះមិនមានប្រយោជន៍ យើងគួរស្វែងរកមោក្ខធម៌ដើម្បីខ្លួន ឯលោក ព្រោះហេតុអ្វីមិនរីករាយ ។ សូម្បីកោលិតៈនោះ ក៏ប្រាប់យ៉ាងនោះដូចគ្នា ។ លំដាប់នោះ ឧបតិស្សៈជ្រាបសេចក្តីដល់កោលិតៈនោះ មានអធ្យាស្រ័យដូចគ្នានឹងខ្លួន ទើបពោលថា “សំឡាញ់អើយ យើងទាំងពីរគិតល្អហើយ ក៏យើងគួរស្វែងរកមោក្ខធម៌ ធម្មតាអ្នកស្វែងរក ត្រូវតែបានបព្វជ្ជាកេទសិនទើបគួរ យើងទាំងពីរនឹងបព្វជ្ជាក្នុងសំណាក់អ្នកណាហ្ន៎ ។

## ព្រះអស្សជិសំដែងបេះដូងព្រះសាសនា

ក៏សម័យនោះឯង សញ្ជ័យបរិព្វាជកអាស្រ័យនៅក្នុងក្រុងរាជគ្រឹះ

ជាមួយបរិព្វាជកបរិស័ទពួកធំ ។ ឧបតិស្សៈ និងកោលិតៈ ទាំងពីរនាក់នោះ សន្យាគ្នាថា យើងនឹងបួសក្នុងសំណាក់សញ្ជ័យនោះ បញ្ជូនមាណព ៥០០ ទៅ ដោយពាក្យថា អ្នកទាំងឡាយចូលយកសង្រែក និងរថទៅចុះ ។ ព្រមដោយមាណព ៥០០ បួសហើយក្នុងសំណាក់របស់សញ្ជ័យ ។ តាំងពីគេទាំងពីរនាក់បួសហើយ សញ្ជ័យក៏បានដល់នូវការប្រសើរដោយលាភនិងយសដ៏លើសលុប ។ ទាំងពីរនាក់រៀនចប់លទ្ធិសម័យរបស់សញ្ជ័យគ្រប់យ៉ាង តែពីរបីថ្ងៃប៉ុណ្ណោះ ទើបសួរថា លោកអាចារ្យ លទ្ធិដែលលោកដឹង មានត្រឹមប៉ុណ្ណោះ ឬមានក្រៃលែងជាងនេះទៀត ។ កាលសញ្ជ័យឆ្លើយថា មានត្រឹមតែប៉ុណ្ណោះ អ្នកទាំងពីររៀនចប់អស់ហើយ គេទាំងពីរទើបគិតគ្នាថា បើដូច្នេះ ការប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់របស់លោកនេះក៏មិនមានប្រយោជន៍ យើងទាំងពីរចេញមកដើម្បីស្វែងរកមោក្ខធម៌ មោក្ខធម៌នោះ យើងមិនអាចឲ្យកើតឡើងបានក្នុងសំណាក់របស់លោក ជម្ពូទ្វីបនេះធំណាស់ យើងនឹងទៅកាន់គាម និគម ជនបទ និងរាជធានី គង់នឹងបានអាចារ្យអ្នកស្វែងរកមោក្ខធម៌មិនខានឡើយ តាំងពីនោះ នរណានិយាយ

ក្នុងទីណាៗ ថា សមណព្រាហ្មណ៍ជាបណ្ឌិតមាន គេទាំងពីររមែងទៅធ្វើសាកច្ឆាក្នុងទីនោះៗ ។ បញ្ហាដែលគេទាំងពីរសួរទៅ អាចារ្យពួកដទៃមិនអាចឆ្លើយតបបាន តែគេទាំងពីរនាក់រមែងឆ្លើយបញ្ហារបស់អាចារ្យទាំងនោះបាន ។ គេសាកសួរទូទាំងជម្ពូទ្វីបយ៉ាងនោះហើយ ត្រឡប់មកកាន់ទីនៅរបស់ខ្លួន ទើបធ្វើកតិកាគ្នាថា កោលិតៈសំឡាញ់ ក្នុងយើងទាំងពីរនាក់ អ្នកណាបានសម្រេចអមតធម៌មុន អ្នកនោះចូរប្រាប់ (ដល់គ្នា) ។

កាលគេទាំងពីរនាក់ធ្វើកតិកាគ្នាយ៉ាងនេះហើយ ព្រះសាស្ដាស្ដេចយាងដល់ក្រុងរាជគ្រឹះដោយលំដាប់ ដូចបានពោលហើយ ទ្រង់ទទួលវេឡុវ័នហើយ ប្រថាប់នៅក្នុងវេឡុវ័ន ។ ក្នុងកាលនោះ ព្រះអស្សជិថេរៈ ក្នុងចំនួនព្រះបញ្ចវគ្គិយ ចំណោមព្រះអរហន្ត ៦១ អង្គ ដែលព្រះសាស្ដាទ្រង់បញ្ជូនទៅដើម្បីប្រកាសគុណព្រះរតនត្រ័យ ដោយព្រះតម្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅដើម្បីប្រយោជន៍ដល់ជនដ៏ច្រើនចុះ” បានត្រឡប់មកនៅក្រុងរាជគ្រឹះហើយ ។ ក្នុងថ្ងៃស្អែកនោះ ក៏ប្រដាប់បាត្រ និងចីវរទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាតអំពីព្រឹក ។ សម័យនោះ ឧបតិស្សៈ

បរិព្វាជកធ្វើកត្តកិច្ចអំពីព្រឹករួចហើយ ទៅកាន់អារាមរបស់បរិព្វាជក ជួប ព្រះថេរៈ ទើបគិតថា “អ្នកបួសបែបនេះយើងនៅមិនធ្លាប់បានជួប ភិក្ខុរូបនេះ (គង់) នឹងជាមនុស្សម្នាក់ក្នុងបណ្តាអ្នកដែលជាព្រះអរហន្ត ឬជាអ្នកបានសម្រេចព្រះអរហត្តមគ្គក្នុងលោក យ៉ាងណាហ្ន៎ យើងគប្បីចូលទៅរកភិក្ខុនេះ ហើយសួរថា លោកអ្នកមានអាយុ លោកបួសឧទ្ទិសចំពោះអ្នកណា អ្នកណាជាសាស្តារបស់លោក ឬថា លោកពេញចិត្តក្នុងធម៌របស់អ្នកណា” ។ ពេលនោះ បរិវិតក្កៈនេះ បានមានដល់គេថា កាលនេះមិនមែនជាកាលគួរសួរបញ្ហាចំពោះភិក្ខុនេះទេ ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះស្រុកដើម្បីត្រាច់បិណ្ឌបាត បើដូច្នេះ យើងកាលស្វែងរកមោក្ខធម៌ ដែលជាអ្នកត្រូវការនឹងដឹង គួរជាប់តាមភិក្ខុរូបនេះអំពីខាងក្រោយៗ ។ គេឃើញព្រះថេរៈបានបិណ្ឌបាតហើយ ទៅកាន់ឱកាសកន្លែងមួយ ហើយជ្រាបសេចក្តីដែលព្រះថេរៈនោះប្រាថ្នានឹងអង្គុយ ទើបបានចាត់ចែងតាំងរបស់បរិព្វាជកសម្រាប់ខ្លួនថ្វាយ ។ សូម្បីក្នុងវេលាដែលលោកឆាន់ស្រេចហើយ ក៏បានថ្វាយទឹកក្នុងកុណ្ឌោរបស់ខ្លួនដល់ព្រះថេរៈ លុះធ្វើអាចរិយវត្តយ៉ាងនេះហើយ

ទើបធ្វើបដិសណ្ឋារៈយ៉ាងរាក់ទាក់ជាមួយព្រះថេរៈ ដែលធាន់ស្រេចហើយ ផ្តើមសួរយ៉ាងនេះថា “លោកមានអាយុ ឥន្ទ្រិយរបស់លោកថ្លូវផង់ណាស់ ពណ៌សម្បុរក៏បរិសុទ្ធថ្លូវផង់ លោកអ្នកមានអាយុ លោកបួសឧទ្ទិសចំពោះអ្នកណា អ្នកណាជាសាស្តារបស់លោក ឬលោកពេញចិត្តក្នុងធម៌របស់អ្នកណា” ។ ព្រះថេរៈគិតថា បណ្តាបរិព្វាជកទាំងនេះ រមែងជាអ្នកបដិបក្ខចំពោះព្រះសាស្តា យើងនឹងសំដែងធម៌ដ៏មានជម្រៅក្នុងព្រះសាសនាដល់បរិព្វាជកនេះ កាលនឹងសំដែងការដែលខ្លួនបួសថ្មី ទើបពោលថា “អ្នកមានអាយុ យើងនេះឯងជាអ្នកបួសថ្មី បួសហើយមិនយូរ ទើបតែមកកាន់ធម្មវិន័យនេះ យើងមិនអាចសំដែងធម៌ដោយពិស្តារបានទេ” ។ បរិព្វាជកឆ្លើយថា “ខ្ញុំឈ្មោះឧបតិស្សៈ សូមលោកម្ចាស់ចូរពោលតិច ឬច្រើនតាមសេចក្តីដែលអាចចុះ ប្រការនោះ ជាការៈរបស់ខ្ញុំដើម្បីចាក់ធ្លុះដោយរយន័យ ពាន់ន័យ” ហើយពោលថា ៖

នឹងច្រើន ឬតិចក៏ដោយ សូមលោកម្ចាស់ចូរពោលចុះ ចូរប្រាប់
ដល់ខ្ញុំត្រឹមតែសេចក្តីប៉ុណ្ណោះ ខ្ញុំត្រូវការសេចក្តី នឹងធ្វើព្យញ្ជនៈ

ឲ្យច្រើនទៅធ្វើអ្វី ៗ

កាលគេនិយាយយ៉ាងនេះហើយ ព្រះថេរៈទើបពោលគាថាថា ៖

ធម៌ពួកណា មានហេតុជាដែនកើត ព្រះតថាគតត្រាស់ហេតុ

នៃធម៌ទាំងនោះ និងហេតុនៃការរលត់នៃធម៌ទាំងនោះ ព្រះ

មហាសមណៈមានប្រក្រតី ត្រាស់យ៉ាងនេះ ៗ

## សំឡាញ់ពីរនាក់សម្រេចព្រះសោតាបន្ន

បរិព្វាជកស្តាប់ត្រឹមតែ ២ បទខាងដើមប៉ុណ្ណោះ ក៏តាំងនៅក្នុងសោតាបត្តិផល ដល់ព្រមដោយពាន់ន័យ ព្រះថេរៈញុំាង ២ បទក្រោយនេះឲ្យចប់ស្រេចក្នុងវេលាដែលគេជាព្រះសោតាបន្នហើយ ៗ គេជាព្រះសោតាបន្នហើយ កាលគុណវិសេសជាន់ខ្ពស់នៅមិនទាន់ប្រព្រឹត្តទៅ ក៏ឃាត់ថា “ហេតុក្នុងវត្ថុនេះនឹងមាន” ទើបសួរព្រះថេរៈថា “លោកម្ចាស់ លោកមិនចាំបរិយាយធម្មទេសនាឲ្យក្រៃលែងឡើងទេ ត្រឹមតែប៉ុណ្ណេះក៏ល្មម ព្រះសាស្តារបស់ពួកយើងប្រថាប់នៅទីណា” ៗ ព្រះថេរៈឆ្លើយថា “ប្រថាប់នៅក្នុងវត្តវេឡុវ័ន អ្នកមានអាយុ” គេសួរថា “លោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូម

លោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំមានមិត្រម្នាក់ទៀត ហើយខ្ញុំទាំងពីរបានធ្វើកតិកាចំពោះគ្នានឹងគ្នាទុកថា អ្នកណាសម្រេចអមតធម៌មុន អ្នកនោះចូលប្រាប់គ្នា ខ្ញុំដោះបដ្ញានោះហើយ នឹងនាំសំឡាញ់ទៅកាន់សំណាក់របស់ព្រះសាស្តាតាមដែលលោកម្ចាស់ទៅហើយនោះឯង ហើយក្រាបចុះទៀបព្រះបាទទាំងពីររបស់ព្រះថេរៈថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន [១] ធ្វើប្រទក្សិណ ៣ ជុំ និមន្តព្រះថេរៈទៅហើយ បានបែរមុខទៅកាន់អារាមរបស់បរិព្វាជកហើយ ។ កោលិតបរិព្វាជកឃើញគេមកអំពីចម្ងាយ គិតថា ថ្ងៃនេះសម្បុរមុខសំឡាញ់របស់យើងមិនដូចថ្ងៃដទៃៗ គេគង់បានសម្រេចអមតៈដោយពិតទើបសួរដល់ការសម្រេចអមតៈ ។ សូម្បីឧបតិស្សៈបរិព្វាជកនោះ ក៏ទទួលថា "អើ អ្នកមានអាយុ អមតៈយើងបានសម្រេចហើយ" បានពោលភាសិតនោះឯង ដល់កោលិតបរិព្វាជកនោះ ។ ក្នុងកាលចប់គាថា កោលិតៈក៏តាំងនៅក្នុងសោតាបត្តិផល ហើយពោលថា "សំឡាញ់ ដឹងថាព្រះសាស្តា

---

១. បញ្ចង្គបតិស្ឋាន បានដល់ ការតាំងទុកចំពោះអវយវៈ ៥ គឺ ក្បាល ១ ដៃទាំងពីរ និងជើងទាំងពីរ ក្រាបដល់ផែនដី ។

របស់ពួកយើងប្រថាប់នៅទីណា” ។ ឧបតិស្សៈពោលថា “ឮថា ប្រថាប់នៅក្នុងវត្តវេឡុវ័ន សំឡាញ់” ដំណឹងនេះ ព្រះអស្សជិជាអាចារ្យរបស់យើងបានប្រាប់ ។ កោលិតៈពោលថា “សំឡាញ់ បើដូច្នោះ យើងទៅគាល់ព្រះសាស្តាចុះ ។ ក៏បណ្ដាព្រះសារីបុត្រថេរៈនេះ រមែងជាអ្នកបូជាអាចារ្យសូម្បីគ្រប់កាលវេលា ព្រោះដូច្នោះ ទើបពោលចំពោះសំឡាញ់យ៉ាងនេះថា “សំឡាញ់ យើងនឹងប្រាប់អមតៈដែលយើងទាំងពីរបានសម្រេច ដល់សញ្ជ័យបរិព្វាជកដែលជាអាចារ្យរបស់យើងខ្វះ លោកដឹងហើយក៏នឹងចាក់ធ្លុះ កាលបានចាក់ធ្លុះ ជឿពួកយើងហើយ នឹងទៅកាន់សំណាក់របស់ព្រះសាស្តា ស្តាប់ទេសនារបស់ពុទ្ធបុគ្គល (ព្រះពុទ្ធ) ទាំងឡាយហើយ នឹងធ្វើការចាក់ធ្លុះនូវមគ្គ និងផល” ។ លំដាប់នោះ ទាំងពីរនាក់ក៏បានទៅកាន់សំណាក់សញ្ជ័យ ។ សញ្ជ័យពេលឃើញគេមកដល់ សួរថា “បា ទាំងពីរពួកអ្នក បាននរណាសំដែងផ្លូវអមតៈហើយឬ ។ សំឡាញ់ទាំងពីរឆ្លើយថា “បានហើយ លោកអាចារ្យ ព្រះពុទ្ធស្តេចឧប្បត្តិឡើងហើយក្នុងលោក ព្រះធម៌ក៏ឧបត្តិឡើងហើយ ព្រះសង្ឃក៏ឧបត្តិឡើងហើយ លោកអាចារ្យប្រព្រឹត្ត

ធម៌ទេ គ្មានសារៈ សូមលោកមកចុះ យើងទាំងឡាយនឹងទៅកាន់សម្នាក់ព្រះសាស្តា” ។

សញ្ជ័យ. អ្នកទាំងពីរទៅចុះ ខ្ញុំមិនទៅទេ ។

ឧប-កោ. ព្រោះហេតុអ្វី ។

សញ្ជ័យ. យើងធ្លាប់ជាអាចារ្យរបស់មហាជនហើយ ការនៅជាអន្តេវាសិករបស់យើងនោះ ដូចជាការរញ្ជួយនៃទឹកក្នុងពាង យើងមិនអាចនៅជាអន្តេវាសិកបានទេ ។

ឧប-កោ. កុំធ្វើយ៉ាងនោះឡើយ លោកអាចារ្យ ។

សញ្ជ័យ. ណ្ហើយចុះ បា! បានាំគ្នាទៅចុះ យើងមិនអាចទៅបាន ។

ឧប-កោ. លោកអាចារ្យ តាំងពីកាលនៃព្រះពុទ្ធស្តេចឧប្បត្តិឡើងក្នុងលោក មហាជនកាន់យករបស់ក្រអូប កម្រងផ្កាជាដើម ទៅបូជាព្រះអង្គប៉ុណ្ណោះ សូម្បីខ្ញុំទាំងពីរក៏នឹងទៅក្នុងទីនោះដូចគ្នា លោកអាចារ្យនឹងធ្វើអ្វី ។

សញ្ជ័យ. អ្នកទាំងពីរ ក្នុងលោកនេះ មានមនុស្សល្ងង់ច្រើន ឬមាន

មនុស្សឆ្លាតច្រើន ។

ឧប-កោ. មនុស្សល្ងង់ច្រើនជាង លោកអាចារ្យ មនុស្សដែលឆ្លាតមានត្រឹមតែតិចតួច ។

សញ្ជ័យ. អ្នកទាំងពីរ បើដូច្នោះ ពួកអ្នកឆ្លាតៗ នឹងទៅកាន់សម្នាក់ព្រះគោតម ពួកមនុស្សល្ងង់ៗ នឹងមកកាន់សំណាក់យើង បា! ទៅជាមួយគ្នាចុះ យើងមិនទៅទេ ។

សំឡាញ់ទាំងពីរនោះ ទើបពោលថា លោកអាចារ្យ លោកប្រាកដហើយឬ ហើយក៏ចៀសចេញទៅ ។ កាលសំឡាញ់ទាំងពីរនោះទៅ ។ បរិស័ទរបស់សញ្ជ័យក៏បែកគ្នា ។ ខណៈនោះអារាមនៅទទេ ។ សញ្ជ័យនោះឃើញអារាមទទេហើយ ក៏ក្អួតចេញឈាមក្តៅៗ ។ ក្នុងបរិព្វាជក ៥០០ នាក់ ដែលទៅជាមួយសំឡាញ់ទាំងពីរនោះ បរិស័ទ ២៥០ នាក់ ត្រឡប់មកវិញដើម្បីសញ្ជ័យ ។ សំឡាញ់ទាំងពីរបានទៅកាន់វត្តវេឡុវ័ន ព្រមទាំងបរិព្វាជក ២៥០ នាក់ ដែលជាអន្តេវាសិករបស់ខ្លួន ។

ព្រះសាស្តាប្រថាប់គង់សំដែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ទតឃើញ

បរិព្វាជកទាំងនោះអំពីចំងាយហើយ ត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សំឡាញ់ទាំងពីរនាក់នោះកំពុងមក គឺកោលិតៈ និងឧបតិស្សៈ ទាំងពីរនាក់នោះឯង ជាគូនៃសាវ័កដ៏ប្រសើររបស់តថាគត ។ សំឡាញ់ទាំងពីរថ្វាយបង្គំព្រះសាស្តាហើយ អង្គុយនៅក្នុងទីដ៏សមគួរមួយ ។ គេទាំងពីរបានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគថា ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជា គប្បីបានឧបសម្បទាក្នុងសំណាក់របស់ព្រះមានព្រះភាគផងចុះ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា "អ្នកទាំងឡាយចូរជាភិក្ខុចុះ ធម៌តថាគតសំដែងល្អហើយ ចូរប្រព្រឹត្តព្រហ្មចារ្យដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃចុះ" ។ ជនទាំងអស់ បានជាអ្នកទ្រទ្រង់បាត្រចីវរដែលសម្រេចដោយឫទ្ធិ៍ ដូចព្រះថេរៈមានវស្សា ១០០ ។ គ្រានោះព្រះសាស្តាទ្រង់បរិយាយព្រះធម្មទេសនា ដោយអំណាចចរិយានៃបរិស័ទរបស់សំឡាញ់ទាំងពីរនោះ ។ វៀរព្រះអគ្គសាវ័កទាំងពីរចេញ ជនដ៏សេសក៏សម្រេចព្រះអរហត្តហើយ ។ ក៏កិច្ចដោយមគ្គជាន់ខ្ពស់របស់ព្រះអគ្គសាវ័កទាំងពីរ មិនបានសម្រេចឡើយ ។ ព្រោះហេតុអ្វី ។ ព្រោះសាវ័កបារមីជា

របស់ធំ ។ តមកក្នុងថ្ងៃទី ៧ អំពីថ្ងៃដែលបួសហើយ ព្រះមហាមោគ្គ-
ល្លានត្ថេរ ចូលទៅអាស្រ័យស្រុកកល្លវាលៈ ក្នុងដែនមគធៈ កាលថីន
មិទ្ធៈគ្របសង្កត់ លោកដែលព្រះសាស្តាទ្រង់ឲ្យសង្វេគហើយ ក៏បន្ទោបង់
ថីនមិទ្ធៈបាន ក្នុងកាលកំពុងស្តាប់ព្រះធាតុកម្មដ្ឋាន ដែលព្រះសាស្តាប្រទាន
ហើយ បានញុំាងកិច្ចក្នុងមគ្គ ៣ ខាងលើឲ្យសម្រេច សម្រេចនូវទីបំផុត
នៃសាវកបារមីញាណហើយ ។ ចំណែកព្រះសារីបុត្រ កន្លងទៅបានកន្លះខែ
អំពីថ្ងៃបួស ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះឯង ត្រង់ល្អាងក្នុំសូករខាតា
ជាមួយព្រះសាស្តា កាលព្រះសាស្តាទ្រង់សំដែងវេទនាបរិគ្គហសូត្រ ដល់
ទីឃនខបរិព្វាជកដែលជាក្មួយរបស់ខ្លួន បញ្ជូនញាណទៅតាមក្រសែនៃព្រះ
សូត្រ ក៏បានសម្រេចទីបំផុតនៃសាវកបារមីញាណ ដូចជាអ្នកបរិភោគកត្ត
ដែលអ្នកដទៃដួសឲ្យ ។ ក៏ព្រះសារីបុត្រជាអ្នកមានបញ្ញាច្រើនមែនឬ បើ
ដូច្នោះ ព្រោះហេតុអ្វី? ទើបសម្រេចសាវកបារមីក្រោយព្រះមោគ្គលាន ។
ព្រោះមានការបរិកម្មច្រើន ។ ដូចឧបមាថា ពួកមនុស្សទុគ៌ត ប្រាថ្នានឹង
ទៅកាន់ទីណាៗ ក៏ចេញទៅបានរហ័ស ចំណែកព្រះរាជា ត្រូវបានត្រៀម

ច្រើន មានការត្រៀមសេះព្រះរាជពាហនៈជាដើម ។ ទើបគួរ យ៉ាងណា ឧបមេយ្យនេះ ក៏គប្បីជ្រាបដូច្នោះ ។ ក៏ក្នុងវេលាថ្ងៃត្រង់នោះឯង ព្រះសាស្តាទ្រង់ប្រជុំសាវ័កត្រង់វត្តវេឡុវ័ន ប្រទានតំណែងព្រះអគ្គសាវ័កដល់ព្រះថេរៈទាំងពីរ ហើយទ្រង់សំដែងព្រះបាតិមោក្ខ ។

## ពួកភិក្ខុតិះដៀលព្រះសាស្តា

ពួកភិក្ខុអ្នកតិះដៀលពោលថា "ព្រះសាស្តាប្រទាន (តំណែង) ដល់ភិក្ខុទាំងឡាយ ដោយយល់មុខ ធម្មតាព្រះអង្គកាលនឹងប្រទានតំណែងអគ្គសាវ័ក គួរប្រទានដល់បញ្ចវគ្គិយអ្នកបួសមុន បើមិនមើលដល់បញ្ចវគ្គិយទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៥៥ រូប មានព្រះយសថេរៈជាប្រធាន ។ កាលមិនមើលដល់ភិក្ខុទាំងនោះ ក៏គួរប្រទានដល់ពួកភទ្ទវគ្គិយ កាលមិនមើលដល់ពួកព្រះភទ្ទវគ្គិយទាំងនោះ ក៏គួរប្រទានដល់ពួកភិក្ខុ ៣ នាក់បងប្អូន មានព្រះឧរុវេលកស្សបៈជាដើម តែព្រះសាស្តាទ្រង់លះភិក្ខុទាំងនោះមានប្រមាណប៉ុណ្ណេះ កាលនឹងប្រទានតំណែងអគ្គសាវ័ក ក៏ទ្រង់យល់ដល់មុខ ប្រទានដល់អ្នកបួសក្រោយគេបង្អស់ ។

## បុព្វកម្មរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ

ព្រះសាស្ដាត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយគ្នាពីអ្វី” ។ កាលភិក្ខុទាំងនោះក្រាបទូលថា “រឿងដូច្នេះ” ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានយល់ដោយមុខ (ហើយឲ្យតំណែង) ដល់ភិក្ខុបួសថ្មី តែតថាគតឲ្យតំណែងតាមដែលបុគ្គលម្នាក់ៗ ប្រាថ្នាហើយនោះឯង ដល់ភិក្ខុទាំងនេះ ក៏អញ្ញាកោណ្ឌញ្ញៈ កាលថ្វាយទានជាប់ទាក់ទងដោយស្រូវដ៏ប្រសើរ ៩ ដង ក្នុងពេលធ្វើស្រែមួយរដូវ ក៏មិនបានប្រាថ្នាតំណែងអគ្គសាវក តែបានប្រាថ្នាដើម្បីចាក់ធ្លុះព្រះអរហត្ត ដែលជាធម៌ដ៏ប្រសើរមុនសាវកទាំងអស់បុណ្ណោះ” ។ ភិក្ខុទាំងឡាយទូលថា “កាលណាព្រះអង្គ” ។ ព្រះសាស្ដាទ្រង់សួរថា “ពួកអ្នកនឹងស្ដាប់ឬ” ភិក្ខុទាំងនោះទូលទទួលថា “ស្ដាប់ ព្រះអង្គ” ។

ព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ រាប់អំពីកប្បនេះថយទៅក្រោយ ៩១ កប្ប ព្រះមានព្រះភាគទ្រង់ព្រះនាមថា វិបស្សី ស្ដេចឧប្បត្តិឡើងហើយក្នុងលោក ។ ក្នុងកាលនោះ មានកុដុម្ពិក ២ នាក់បង-

ប្អូន គឺ មហាកាល និងចុល្លកាល ឲ្យព្រោះស្រូវសាលីទុកជាច្រើន ។ ត មកថ្ងៃមួយ ចុល្លកាលទៅស្រែស្រូវសាលី ហែកស្រូវសាលីកំពុងផើមមួយ ដើម ហើយភ្លក់មើល ។ ដឹងថារសឆ្ងាញ់ ។ គេប្រាថ្នានឹងថ្វាយសាលី គព្ភទាន(២) ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ ទើបចូលទៅរកបងប្រុស ហើយពោលថា "បង ខ្ញុំនឹងបកស្រូវសាលីដើមណាផើម ធ្វើជារបស់គួរដល់ ព្រះពុទ្ធទាំងឡាយ ហើយថ្វាយទាន" ។ បងប្រុសពោលថា "អ្នកនិយាយអ្វី ការដែលបកស្រូវសាលីកំពុងផើមធ្វើទាន មិនធ្លាប់មានទេក្នុងអតីត និង មិនមានក្នុងអនាគត អ្នកកុំធ្វើស្រូវសាលីឲ្យវិនាសឡើយ" ។ គេក៏អង្វរ ហើយ អង្វរទៀត ។ គ្រានោះ បងប្រុសទើបនិយាយចំពោះគេថា "បើ ដូច្នោះ អ្នកត្រូវបែងជា ២ ចំណែក កុំប៉ះពាល់ចំណែករបស់យើង ចូរ ធ្វើចំណែកដែលអ្នកប្រាថ្នា ក្នុងស្រែដែលជាចំណែករបស់ខ្លួនចុះ" ។ គេ ទទួលថា "ល្អហើយ" ទើបបែងចែកគ្នា ហើយបានជួលមនុស្សជាច្រើនឲ្យ បកស្រូវសាលីដែលផើម ឲ្យកិនជាទឹកដោះរហូតដល់ខាប់ ផ្សំជាមួយទឹក

---

១. ទានអំពីស្រូវសាលីដែលកំពុងផើម ។

ដោះថ្វា ទឹកឃ្មុំ និងស្ករត្នោត ថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ក្នុងកាលសម្រេចកត្តកិច្ច ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ទានដ៏ប្រសើររបស់ខ្ញុំព្រះអង្គនេះ ចូរប្រព្រឹត្តទៅដើម្បីដល់ការចាក់ធ្លុះធម៌ដ៏ប្រសើរមុនសាវកទាំងពួង" ។ ព្រះសាស្តាត្រាស់ថា "ចូរជាយ៉ាងនោះចុះ" ហើយទ្រង់បានធ្វើការអនុមោទនា ។ គេទៅស្រែដើរមើល ឃើញស្រែដុះពេញដោយកួរស្រូវសាលី ដូចគេចងទុកជាជួរៗ ក្នុងស្រែទាំងអស់ បានបីតិ ៥ យ៉ាង ហើយគិតថា "ជាលាភរបស់យើងហ្ន៎" ដល់រដូវអំបុក បានថ្វាយទានដ៏ប្រសើរដោយអំបុក បានថ្វាយទានទាក់ទងដោយសន្ទូងដ៏ប្រសើរព្រមជាមួយពួកអ្នកស្រុកទាំងឡាយ រដូវច្រូតបានថ្វាយទានដ៏ប្រសើរក្នុងកាលច្រូត ក្នុងកាលធ្វើជាកណ្តាប់បានថ្វាយទានដ៏ប្រសើរក្នុងកាលធ្វើកណ្តាប់ ក្នុងកាលជញ្ជូនកណ្តាប់ដាក់លាន ក៏បានថ្វាយទានដ៏ប្រសើរក្នុងកាលនោះដែរ ក្នុងកាលបែន (បោកបញ្ជាន់) ក៏បានថ្វាយទានដ៏ប្រសើរ ក្នុងការនាំស្រូវទុកក្នុងជង្រុក បានថ្វាយទានដ៏ប្រសើរ រួមជា ៩ ដង ក្នុងរដូវស្រូវតែម្តង ដោយប្រការដូច្នេះ ។ ទីស្រែដែលគេកាន់យកហើយ បានដុះស្រូវពេញដូច

ដើមគ្រប់ៗ គ្រា ។ ស្រូវបានដុះលូតលាស់សម្បូណ៌ឡើងយ៉ាងក្រៃលែង ។ ឈ្មោះថា ធម៌នេះរមែងរក្សានូវអ្នកដែលរក្សាខ្លួន ។ (សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា) ៖

ធម៌នោះឯង រមែងរក្សាអ្នកដែលមានប្រក្រតីប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយរមែងនាំសុខមកឲ្យ នេះជាអានិសង្សក្នុងធម៌ដែលគេប្រព្រឹត្តល្អ អ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងមិនទៅកាន់ទុគ្គតិ ។

អញ្ញាកោណ្ឌញ្ញៈប្រាថ្នាដើម្បីចាក់ធ្លុះធម៌ដ៏ប្រសើរមុន (គេ) ទើបបានថ្វាយទានដ៏ប្រសើរ ៩ ដង ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាម **វិបស្សី** ដោយប្រការនេះឯង ។ មួយទៀត សូម្បីក្នុងកាលនៃព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ ក្នុងហង្សវតីនគរ ក្នុងទីបំផុត ១ សែនកប្បអំពីកប្បនេះទៅ គេថ្វាយមហាទាន ៧ ថ្ងៃ ក្រាបចុះទៀបព្រះបាទមូលរបស់ព្រះមានព្រះភាគអង្គនោះ តាំងប្រាថ្នា ដើម្បីចាក់ធ្លុះធម៌ដ៏ប្រសើរមុន (គេ) ដូចគ្នា ។ តថាគតបានឲ្យផលដែលអញ្ញាកោណ្ឌញ្ញៈនេះ ប្រាថ្នាហើយតែម្យ៉ាង ដោយប្រការ

ដូច្នេះ ។ តថាគតមិនបាន ឃើញដោយយល់មុខហើយឲ្យតំណែងទេ ។

## បុព្វកម្មរបស់ជន ៥៥ នាក់ មានយសកុលបុត្តជាដើម

ភិក្ខុទាំងឡាយសួរថា "ជន ៥៥ នាក់មានយសកុលបុត្រជាប្រធាន ធ្វើកម្មអ្វីទុក ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "សូម្បីជន ៥៥ នាក់នោះ ប្រាថ្នាព្រះអរហត្តក្នុងសំណាក់ព្រះពុទ្ធមួយព្រះអង្គ ធ្វើកម្មដែលជាបុណ្យទុកច្រើនហើយ ក្រោយមក កាលព្រះពុទ្ធទ្រង់មិនទាន់ឧប្បត្តិឡើង ជាសំឡាញ់គ្នា ធ្វើបុណ្យរួមគ្នា ដើរចាត់ចែងសពមនុស្សគ្មានទីពឹង ថ្ងៃមួយ ពួកគេជួបស្រីស្លាប់ទាំងមានគភ៌ បានព្រមព្រៀងគ្នាថា "នឹងដុត" ទើបនាំទៅព្រៃខ្មោច ។ ក្នុងពួកជនទាំងនោះ ក៏ទុកឲ្យស្នាក់ (នៅ) ក្នុងព្រៃខ្មោច ៥ នាក់ ដោយប្រាប់ថា ពួកអ្នកចូរដុត អ្នកដ៏សេសចូលទៅស្រុកវិញ ។ យសយកឈើសួលចាក់សពនោះ ប្រែត្រឡប់ទៅត្រឡប់មក ក៏បាននូវអសុភសញ្ញា ។ គេសំដែងដល់សំឡាញ់ ៤ នាក់ទៀតថា "លោកដ៏ចម្រើន ពួកលោកចូរមើលសពនេះ មានស្បែកត្រូវភ្លើងកម្ទាត់ហើយក្នុងទីនោះៗ ដូចជាគោដាង មិនស្អាត ស្អុយ គួរខ្ពើម" ។ ជនទាំង ៤ នាក់នោះ ក៏បាននូវ

អសុភសញ្ញាក្នុងសពនោះ ។ គេទាំង ៥ នាក់ ទៅស្រុកប្រាប់ដល់សំឡាញ់ដ៏សេស ។ ចំណែកយសមាណពទៅផ្ទះហើយ បានប្រាប់ដល់មាតាបិតា និងភរិយា ។ មនុស្សទាំងអស់នោះ ក៏ចម្រើនបានអសុភសញ្ញា ។ នេះជាបុព្វកម្មរបស់មនុស្ស ៥៥ នាក់ មានយសកុលបុត្រជាប្រធាន ។ ព្រោះដូច្នោះ ការសម្គាល់ក្នុងផ្ទះដែលច្រើនដោយស្ត្រីនោះ ដូចជាព្រៃខ្មោច ទើបកើតមានដល់យសមាណព ។ ដោយការដល់ព្រមនៃឧបនិស្ស័យនោះ ការសម្រេចគុណនូវវិសេសទើបកើតឡើងដល់ពួកគេទាំងនោះ ។ ជនទាំងនេះបានទទួលផលដែលខ្លួនប្រាថ្នាហើយ ដោយប្រការដូច្នេះ ។ តថាគត មិនបានយល់ដោយមុខ ហើយឲ្យតំណែងនោះទេ ។

## បុព្វកម្មរបស់ភទ្ទវគ្គិយ ៣០ នាក់

ភិក្ខុទាំងឡាយក្រាបទូលថា "ក៏ព្រះភទ្ទវគ្គិយដែលជាសំឡាញ់នឹងគ្នាបានធ្វើកម្មអ្វីទុកដែរ ព្រះអង្គ" ។ ព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូម្បីពួកភទ្ទវគ្គិយនោះ ក៏ប្រាថ្នាព្រះអរហត្តក្នុងសំណាក់នៃព្រះពុទ្ធក្នុងកាលមុន ហើយធ្វើបុណ្យ ខាងក្រោយមក កាលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើងក្នុង

លោក ជាអ្នកលេង ៣០ នាក់ ស្ដាប់គុណនៃលោវាទសូត្រហើយ បានរក្សា សីល ៥ អស់ ៦០.០០០ ឆ្នាំ ។ សូម្បីកទូវគ្គិយទាំងនេះ ក៏បានផលដែល ខ្លួនប្រាថ្នាហើយៗ ដូចគ្នា ដោយប្រការយ៉ាងនេះ តថាគតមិនបានយល់មុខ ហើយឲ្យតំណែងទេ ។

## បុព្វកម្មរបស់ជដិល ៣ នាក់

ភិក្ខុទាំងឡាយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ក៏កស្សបៈ ៣ នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម ធ្វើកម្មអ្វីទុក" ។ ព្រះអង្គត្រាស់ ថា "គេប្រាថ្នាជាព្រះអរហត្តដូចគ្នា ធ្វើបុណ្យហើយ ។ ក៏ក្នុង ៩២ កប្ប អំពីកប្បនេះទៅ ព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះតិស្សៈ ១ ព្រះផុស្សៈ[១] ១ ស្ដេចឧប្បត្តិហើយ ។ ព្រះរាជាព្រះនាមថា មហិន្ទៈបានជាព្រះបិតារបស់ ព្រះពុទ្ធទ្រង់ព្រះនាមថា ផុស្សៈ ។ ក៏កាលព្រះអង្គទ្រង់បានសម្រេចសម្មា- សម្ពោធិញ្ញាណហើយ ព្រះឱរសតូចរបស់ព្រះរាជា បានជាព្រះអគ្គសាវកទី ១ បុត្របុរោហិត បានជាអគ្គសាវកទី ២ ។ ព្រះរាជាស្ដេចទៅកាន់សំណាក់

---

១. ខុ.ពុទ្ធវង្ស ក្នុងទីនោះប្រាកដនាមថា បុស្សៈ និងព្រះបិតាព្រះនាមថា ជយសេន ។

ព្រះសាស្តា ទ្រង់ពិនិត្យមើលជនទាំងនោះថា "រាជឱរសអង្គច្បងរបស់យើងជាព្រះពុទ្ធ រាជឱរសតូចជាអគ្គសាវកទី ១ បុត្របុរោហិតជាអគ្គសាវកទី ២" ទ្រង់បន្លឺឧទាន ៣ ដងថា "ព្រះពុទ្ធជារបស់ខ្ញុំប៉ុណ្ណោះ ព្រះធម៌ជារបស់ខ្ញុំប៉ុណ្ណោះ ព្រះសង្ឃជារបស់ខ្ញុំប៉ុណ្ណោះ ខ្ញុំសូមនមស្ការដល់ព្រះមានព្រះភាគទ្រង់ជាព្រះអរហន្ត ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង" ហើយក្រាបចុះទៀបព្រះបាទមូលរបស់ព្រះសាស្តា ទ្រង់ទទួលប្តេជ្ញាថា "បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ ដូចជាវេលាដែលខ្ញុំព្រះអង្គអង្គុយលក់ ក្នុងទីបំផុតអាយុប្រមាណ ៩ ម៉ឺនឆ្នាំ សូមព្រះអង្គស្តេចកុំទៅកាន់ទ្វារផ្ទះរបស់ជនពួកដទៃ សូមទ្រង់ទទួលបច្ច័យ ៤ របស់ខ្ញុំព្រះអង្គ អស់វេលាដែលខ្ញុំព្រះអង្គនៅមានជីវិត" ហើយទ្រង់បានធ្វើជាពុទ្ធុបដ្ឋាកជាប្រចាំ ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់មានព្រះរាជឱរសដទៃ ៣ ព្រះអង្គទៀត ។ បណ្តាព្រះរាជឱរស ៣ អង្គនោះព្រះអង្គបងមានបរិវារ ៥០០ ព្រះអង្គកណ្តាលមាន ៣០០ ព្រះអង្គតូចមាន ២០០ ។ ព្រះរាជឱរស ៣ ព្រះអង្គនោះ ទូលសូមឱកាសចំពោះបិតាថា "សូមឱ្យខ្ញុំព្រះអង្គទាំងឡាយ នឹងនិមន្តម្ចាស់បងសោយ" សូមឱ្យទូលអង្វរ

រឿយៗ ក៏មិនបាន កាលបច្ចន្តជនបទកម្រើក ត្រូវបញ្ជូនទៅដើម្បីប្រយោជន៍ រម្ងាប់បច្ចន្តជនបទនោះ បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់ស្ងាត់ហើយ មកកាន់សំណាក់បិតា ។ គ្រានោះ ព្រះបិតាទ្រង់ឱបឱរសទាំងបីនោះ បើបត្រង់សីសៈ ត្រាស់ថា "បា! ទាំងឡាយ បិតាឲ្យពរដល់ពួកបុត្រ" ។ ព្រះឱរសទាំងបីនោះទូលថា "ព្រះករុណា ព្រះអង្គ" បង្អោនទទួលព្រះពរ ។ ដោយកាលកន្លងទៅពីរបីថ្ងៃ បិតាត្រាស់ទៀតថា "បា! ទាំងឡាយ ពួកបុត្រនឹងទទួលពរចុះ" ក្រាបទូលថា "បពិត្រព្រះអង្គ សេចក្ដីប្រាថ្នាដោយវត្ថុអ្វីៗដទៃ របស់ខ្ញុំព្រះអង្គមិនមានទេ តែឥឡូវនេះ ខ្ញុំព្រះអង្គនឹងនិមន្តម្ចាស់បងសោយ សូមព្រះអង្គប្រោសមេត្តាព្រះរាជទានពរនេះដល់ខ្ញុំព្រះអង្គចុះ" ។

ព្រះរាជា. ឲ្យមិនបានទេ បា! ។

ព្រះរាជឱរស. កាលមិនព្រះរាជទានរហូត ក៏សូមព្រះរាជទានត្រឹមតែ ៧ ឆ្នាំ ។

ព្រះរាជា. ឲ្យមិនបានទេ ។

ព្រះឱរស. បើដូច្នោះ សូមព្រះរាជទានត្រឹម ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ

៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ។

ព្រះរាជា. ឲ្យមិនបានទេ បា! ។

ព្រះឱរស. បើដូច្នោះ សូមទ្រង់ព្រះរាជទានត្រឹមតែ ៣ ខែ ដល់ខ្ញុំព្រះអង្គទាំងឡាយ ម្នាក់មួយខែៗ ។

ព្រះរាជា. ប្រពៃហើយ បា! បើដូច្នោះ បុត្រចូរនិមន្តព្រះមានព្រះភាគសោយ ៣ ខែចុះ ។

ព្រះរាជបុត្រទាំងបីអង្គនោះ មាននាយឃ្លាំងម្នាក់ និងអ្នកចាត់ចែងកិច្ចការម្នាក់ ។ អ្នកទាំងពីរនោះ មានបុរស ១២ នហុតជាបរិវារ ។ ព្រះរាជឱរសទាំងបី ត្រាស់បង្គាប់ឲ្យហៅមនុស្សទាំងពីរនោះមក ហើយត្រាស់ថា "យើងទាំងបីនឹងទទួលសីល ១០ ស្លៀកដណ្តប់សំពត់កាសាវៈ ២ ផ្ទាំង នៅរួមជាមួយព្រះសាស្តារហូតអស់ត្រៃមាសនេះ ពួកអ្នកគប្បីប្រើប្រាស់តម្លៃមានប្រមាណប៉ុណ្ណេះ ញុំាងរបស់ទំពារ និងរបស់បរិភោគគ្រប់យ៉ាងឲ្យប្រព្រឹត្តទូទៅដល់ភិក្ខុ ៩ ម៉ឺនរូប និងអ្នកបម្រើយើងមួយពាន់នាក់ផង ព្រោះតាំងពីនេះទៅ ពួកយើងនឹងមិននិយាយអ្វីៗ" ។ ព្រះរាជឱរស

ទាំងបីនោះ នាំបុរសជាបរិវារមួយពាន់សមាទានសីល ១០ ស្លៀកដណ្តប់សំពត់កាសាវៈ នៅក្នុងវិហារ ។ នាយឃ្លាំង និងអ្នកចាត់ចែងកិច្ចការងាររួមគ្នាបើកស្បៀងតាមវារៈៗ ពីឃ្លាំងទាំងឡាយរបស់ព្រះរាជបុត្រ បងប្អូនទាំងបីថ្វាយទាន ។

## បរិភោគអាហារដែលគេឧទ្ទិសចំពោះភិក្ខុសង្ឃ ស្លាប់ទៅកើតជាប្រេត

ក៏បុត្ររបស់ពួកអ្នកបម្រើការងារ យំទារបបរ និងកត្តជាដើម ។ ពួកអ្នកបម្រើការងារទាំងនោះ កាលភិក្ខុសង្ឃមិនទាន់មក ក៏ឲ្យវត្ថុមានបបរ និងកត្តជាដើមដល់បុត្រទាំងនោះ ។ ក្នុងវេលាដែលភិក្ខុសង្ឃឆាន់ស្រេចហើយ មិនដែលមានរបស់អ្វីសេសសល់ឡើយ ។ ក្នុងកាលតមក ពួកអ្នកបម្រើការងារទាំងនោះនិយាយអាងថា យើងនឹងឲ្យដល់ពួកក្មេងតូចៗ ហើយក៏យកទៅបរិភោគខ្លួនឯង ឃើញអាហារដែលពេញចិត្ត ក៏មិនអាចអត់ទ្រាំបាន ។ ក៏ពួកគេបានមានប្រមាណប្រាំបីម៉ឺនបួនពាន់នាក់ ។ ពួកគេបរិភោគអាហារដែលសម្រាប់ថ្វាយសង្ឃ ព្រោះកាយ (បែកធ្លាយ) បានទៅកើតក្នុង

ហេតុវិស័យ , ចំណែកព្រះរាជឱរសទាំង ៣ នាក់បងប្អូន ព្រមដោយបុរស មួយពាន់ ធ្វើកាលៈហើយ កើតក្នុងទេវលោក ចុតិពីទេវលោក ទៅកាន់ ទេវលោក ញ៉ាំងកាលឲ្យអស់ទៅ ៩២ កប្ប ។ ព្រះរាជឱរសទាំង ៣ នាក់ បងប្អូននោះ ប្រាថ្នាព្រះអរហត្ត បានធ្វើកល្យាណកម្មក្នុងកាលនោះ ដោយ ប្រការដូច្នេះ ។ ជដិល ៣ នាក់បងប្អូននោះ បានទទួលផលដែលខ្លួនប្រាថ្នា ហើយដូចគ្នា ។ តថាគតមិនយល់ដល់មុខ ហើយឲ្យតំណែងឡើយ ។

ចំណែកអ្នកចាត់ចែងកិច្ចការរបស់រាជឱរសទាំង ៣ អង្គនោះ ក្នុង កាលនោះ បានមកជាព្រះបាទពិម្ពិសារ ។ នាយឃ្លាំង បានមកជាវិសាខ-ឧបាសក ។ ពួកអ្នកបម្រើការងាររបស់អ្នកទាំង ២ នោះ ក្នុងកាលនោះ កើតហើយក្នុងពួកប្រេត ត្រាច់រង្គាត់ទៅដោយអំណាចសុគតិ និងទុគ្គតិ ក្នុង កប្បនេះ កើតជាប្រេតនោះឯងអស់ ៤ ពុទ្ធន្តរ ។ ប្រេតទាំងនោះចូលគាល់ ព្រះមានព្រះភាគព្រះនាមថា **កក្កុសន្ធៈ** ដែលទ្រង់ព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ស្តេចឧប្បត្តិឡើងមុនព្រះពុទ្ធគ្រប់ព្រះអង្គក្នុងកប្បនេះ ទូលថា "សូមព្រះអង្គ មេត្តាប្រោស ប្រាប់កាលដែលត្រូវបានអាហារដល់ខ្ញុំព្រះអង្គទាំងឡាយ" ។

ព្រះមានព្រះភាគត្រាស់ថា “ពួកម្ចាស់មិនទាន់បានក្នុងកាលរបស់តថាគតទេ តែខាងក្រោយនៃតថាគត កាលមហាបឋវីដុះឡើងប្រមាណបាន ១ យោជន៍ ព្រះពុទ្ធព្រះនាមថា **កោនាគមនៈ** នឹងឧប្បត្តិឡើង ពួកអ្នកគប្បីទូលសួរព្រះអង្គចុះ” ។ ប្រេតទាំងនោះ ញាំងកាលមានប្រមាណប៉ុណ្ណោះឲ្យអស់ទៅ ។ កាលព្រះពុទ្ធទ្រង់ព្រះនាមថា **កោនាគមនៈ** ស្ដេចឧប្បត្តិឡើងហើយ ទើបបានទូលសួរព្រះអង្គ សូម្បីព្រះពុទ្ធអង្គនោះ ក៏ត្រាស់ថា “ពួកអ្នកនឹងមិនទាន់បានក្នុងកាលរបស់តថាគត តែខាងក្រោយនៃតថាគត កាលមហាបឋវីដុះឡើងប្រមាណបាន ១ យោជន៍ ព្រះពុទ្ធទ្រង់ព្រះនាមថា **កស្សបៈ** ទ្រង់ឧប្បត្តិឡើង ពួកអ្នកគប្បីទូលសួរព្រះអង្គចុះ” ។ ប្រេតទាំងនោះ ក៏ញាំងកាលមានប្រមាណប៉ុណ្ណោះឲ្យអស់ទៅហើយ កាលព្រះពុទ្ធព្រះនាមថា **កស្សបៈ** ស្ដេចឧប្បត្តិឡើងហើយក្នុងលោក ទើបទូលសួរព្រះអង្គ ។ សូម្បីព្រះពុទ្ធអង្គនោះ ក៏ត្រាស់ថា “ពួកអ្នកនឹងមិនទាន់បានក្នុងកាលរបស់តថាគត តែក្រោយនៃតថាគត កាលមហាបឋវីដុះឡើងបានប្រមាណបាន ១ យោជន៍ ព្រះពុទ្ធព្រះនាមថា **គោតម** ស្ដេចនឹងឧប្បត្តិឡើង ក្នុងកាលនោះ ញាតិ

របស់ពួកអ្នកនឹងជាព្រះរាជា ព្រះនាមថា **ពិម្ពិសារ** ព្រះរាជាពិម្ពិសារនោះ ថ្វាយទានដល់ព្រះសាស្ដាហើយ នឹងឲ្យចំណែកកុសលទានដល់ពួកអ្នក ពួកអ្នកនឹងបាន (អាហារ) ក្នុងគ្រានោះ ។ ពុទ្ធន្តរមួយ បានប្រាកដដល់ប្រេតទាំងនោះដូចជាថ្ងៃស្អែក ។ ប្រេតទាំងនោះ កាលព្រះតថាគតស្ដេចឧប្បត្តិឡើងហើយ កាលព្រះបាទពិម្ពិសារថ្វាយទានក្នុងថ្ងៃដំបូង ក្នុងចំណែករាត្រីបញ្ចេញសំឡេងយំគួរឲ្យខ្លាច សំដែងខ្លួនដល់ព្រះរាជា ។ លុះព្រឹកឡើងស្ដេចមកកាន់វត្តវេឡុវ័ន ក្រាបទូលរឿងនោះដល់ព្រះតថាគត ។ ព្រះសាស្ដាត្រាស់ថា “មហាបពិត្រ ក្នុងទីបំផុត ៩២ កប្ប រាប់ថយអំពីកប្បនេះទៅក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា **ផុស្សៈ** ពួកប្រេតនោះ ជាញាតិរបស់ព្រះអង្គ បរិភោគអាហារដែលគេថ្វាយដល់ភិក្ខុសង្ឃ កើតក្នុងបេត្តលោកនេះ ហើយត្រាច់រង្គាត់ទៅមក បានទូលសួរព្រះពុទ្ធច្រើនព្រះអង្គដែលស្ដេចឧប្បត្តិឡើង មានព្រះពុទ្ធព្រះនាមកកុសន្ធៈជាអាទិ៍ ដែលព្រះពុទ្ធទាំងនោះត្រាស់ប្រាប់ពាក្យនេះៗ ហើយសង្ឃឹមដល់ទានរបស់ព្រះអង្គរហូតអស់កាលប៉ុណ្ណោះ ថ្ងៃនេះ កាលព្រះអង្គទ្រង់ថ្វាយទានហើយ ពួកគេមិនបានទទួល

ចំណែកបុណ្យ ទើបបានធ្វើយ៉ាងនេះ” ។ ព្រះរាជាទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន ក៏កាលខ្ញុំព្រះអង្គថ្វាយទានសូម្បីក្នុងកាលឥឡូវនេះ ប្រេតទាំងនោះនឹងបានទទួលឬ” ។ ព្រះសាស្តាត្រាស់ថា “បាន មហាបពិត្រ” ។ ព្រះរាជាទ្រង់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានក្នុងថ្ងៃស្អែក ហើយបានព្រះរាជទានចំណែកបុណ្យថា “បពិត្រព្រះអង្គដ៏ចម្រើន សូមបាយនិងទឹកដែលជាទិព្វ ចូរសម្រេចដល់ពួកប្រេតទាំងនោះអំពីមហាទាននេះ” ។ លុះព្រឹកឡើង ប្រេតទាំងនោះអាក្រាតកាយ សំដែងខ្លួនហើយ ។ ព្រះរាជាទូលសួរថា “ថ្ងៃនេះប្រេតទាំងនោះអាក្រាតកាយ សំដែងខ្លួន ព្រះអង្គ” ។ ព្រះសាស្តាត្រាស់ថា “មហាបពិត្រ ព្រះអង្គមិនបានថ្វាយសំពត់” ។ ព្រឹកឡើង ព្រះរាជាទ្រង់ថ្វាយសំពត់ចីវរទាំងឡាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់ឧទ្ទិសចំណែកបុណ្យថា “សូមសំពត់ជាទិព្វទាំងឡាយ ចូរសម្រេចដល់ប្រេតទាំងនោះ អំពីចីវរទាននេះចុះ ។ ក្នុងខណៈនោះឯង សំពត់ទិព្វ ក៏កើតឡើងដល់ប្រេតទាំងនោះ ។ ព្រះសាស្តា កាលទ្រង់អនុមោទនា ទ្រង់បានធ្វើការអនុមោទនាដោយតិរោកុឌ្ឌសូត្រថា “**តិរោកុឌ្ឌេសុ តិដ្ឋន្តិ**”

ជាអាទិ៍ ។ ក្នុងទីបំផុតការអនុមោទនា ធម្មាភិសម័យ បានមានដល់សត្វ ៨៤.០០០ នាក់ ។ ព្រះសាស្តា លុះត្រាស់រឿងរបស់ជដិល ៣ នាក់បងប្អូនហើយ ទ្រង់នាំព្រះធម្មទេសនាសូម្បីនេះមក ដោយប្រការដូច្នេះ ។

## បុព្វកម្មរបស់ព្រះអគ្គសាវ័កទាំងពីរ

ភិក្ខុទាំងឡាយទូលសួរថា "ក៏ព្រះអគ្គសាវ័កទាំងពីរ បានធ្វើកម្មអ្វីទុក ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "អគ្គសាវ័កទាំងពីរធ្វើសេចក្តីប្រាថ្នាដើម្បីជាព្រះអគ្គសាវ័ក ។ ពិតហើយ ក្នុងទីបំផុតមួយអសេង្ខយ្យក្រៃលែងដោយសែនកប្ប រាប់អំពីនេះទៅ សារីបុត្រកើតនៅក្នុងត្រកូលព្រាហ្មណ៍មហាសាល មាននាមថា សរទមាណព ។ មោគ្គល្លាន កើតក្នុងត្រកូលគហបតិមហាសាល មាននាមថា សិរីវឌ្ឍកុដុម្ពិក៍ ។ មាណពទាំងពីរនោះបានជាសំឡាញ់លេងធូលីរួមគ្នា ។ សរទមាណពកាលបិតាស្លាប់ទៅ ក៏បានគ្រប់គ្រងទ្រព្យដ៏ច្រើនដែលជាមត៌ករបស់ត្រកូល ថ្ងៃមួយ នៅក្នុងទីស្ងាត់គិតថា "យើងរមែងដឹងអត្តភាពតែក្នុងលោកនេះប៉ុណ្ណោះ មិនដឹងអត្តភាពក្នុងលោកខាងមុខទេ ធម្មតាសេចក្តីស្លាប់របស់សត្វដែលកើតហើយទាំងឡាយ

ជារបស់មិនទៀង យើងគប្បីបួសជាបព្វជិត ធ្វើការស្វែងរកមោក្ខធម៌" ។ សរទមាណពនោះ ចូលទៅរកសំឡាញ់ហើយនិយាយថា "សិរិវឌ្ឍសំឡាញ់ ខ្ញុំនឹងបួសស្វែងរកមោក្ខធម៌ លោកអាចបួសជាមួយយើង ឬមិនអាច" ។ សិរិវឌ្ឍឆ្លើយថា "ខ្ញុំមិនអាចទេសំឡាញ់ លោកបួសម្នាក់ឯងចុះ" ។ សរទមាណពនោះគិតថា "ធម្មតាអ្នកទៅកាន់បរលោក នាំសំឡាញ់ ឬញាតិមិត្ត ទៅជាមួយមិនបាន កម្មដែលខ្លួនធ្វើហើយរមែងជារបស់ខ្លួនឯង" ។ តពីនោះ សរទមាពណទើបឲ្យបើកឃ្លាំងកែវ ហើយឲ្យមហាទានដល់មនុស្ស កំព្រា អ្នកដើរផ្លូវ ស្មូមយាចកទាំងឡាយ ចូលទៅកាន់ជើងភ្នំ ហើយបួសជាឥសី ។ ជនទាំងឡាយបួសតាមសរទនោះដោយអាការយ៉ាងនេះ គឺ ១ នាក់ ២ នាក់ ៣ នាក់ រហូតមានជដិលប្រមាណប្រាំពីរម៉ឺនបួនពាន់នាក់ ។ សរទជដិលទាំងនោះ ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ និងបានប្រាប់កសិណបរិកម្មជដិលទាំងនោះ ។ សូម្បីជដិលទាំងនោះ ក៏ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងដែរ ។ ក្នុងសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមថា **អនោមទស្សី** ស្តេចឧប្បត្តិឡើងហើយក្នុងលោក ព្រះនគរ

មានឈ្មោះថា **ចន្ទវតី** ក្សត្រិយព្រះនាមថា **យសវន្ត:** ជាព្រះបិតា ព្រះទេវី ព្រះនាមថា **យសោធរា** ជាព្រះមាតា **ដើមអង្គ្រែង** ជាទីត្រាស់ដឹង ព្រះអគ្គសាវកទាំងពីរ ឈ្មោះ **និសភ:** ១ ឈ្មោះ **អនោម:** ១ ឧបដ្ឋាកឈ្មោះ **វរុណ:** អគ្គសាវិកាទាំងពីរ ឈ្មោះ **សុន្ទរា** ១ **សុមនា** ១ ព្រះជន្មាយុមួយសែនឆ្នាំ ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះរស្មីនៃសរីរៈផ្សាយទៅរហូត ១២ យោជន៍ ភិក្ខុមួយសែនអង្គជាបរិវារ ។ ថ្ងៃមួយ ក្នុងវេលាជិតភ្លឺ ព្រះពុទ្ធអនោមទស្សី ស្ដេចចេញចាកមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលសត្វលោក ទតឃើញសរទតាបសហើយ ទ្រង់ព្រះតម្រិះថា "ព្រោះតថាគតទៅកាន់សំណាក់សរទតាបសក្នុងថ្ងៃនេះជាបច្ច័យ ព្រះធម្មទេសនានឹងមានគុណធំ ឯសរទតាបសនោះ នឹងប្រាថ្នាតំណែងជាព្រះអគ្គសាវក សិរិវឌ្ឍកុដុម្ពីក៏ដែលជាសំឡាញ់តាបសនោះ នឹងប្រាថ្នាតាំងតំណែងអគ្គសាវកទី ២ ក្នុងពេលចប់ទេសនា ជដិលប្រាំពីរម៉ឺនបួនពាន់ជាបរិវាររបស់តាបសនោះ នឹងសម្រេចព្រះអរហត្ត តថាគតគួរទៅក្នុងទីនោះ" ដូច្នេះ ហើយទ្រង់ប្រដាប់បាត្រ និងចីវររបស់ព្រះអង្គ មិនត្រាស់ហៅភិក្ខុដទៃៗ ស្ដេចយាងទៅមួយ

ព្រះអង្គឯងដូចស្ដេចរាជសីហ៍ កាលអន្តេវាសិកទាំងឡាយរបស់សរទតាបស ទៅរកផ្លែឈើ ទ្រង់អធិដ្ឋានថា "សូមសរទតាបសចូរជ្រាបថា តថាគតជាព្រះពុទ្ធ" កាលសរទតាបសឃើញហើយនោះឯង ស្ដេចចុះចាកអាកាសប្រថាប់ឈរលើផែនដី ។ សរទតាបសឃើញព្រះពុទ្ធានុភាព និងសេចក្ដីសម្រេចនៃព្រះសរីរៈ ស្វាធ្យាយមន្តសម្រាប់ទាយលក្ខណៈ ក៏ជ្រាបបានថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្ដេចចក្រពត្តិ កាលចេញបួស រមែងបានជាព្រះសព្វញ្ញុពុទ្ធ ជាអ្នកមានកិលេសជាគ្រឿងប្រក់បាំងបើកហើយក្នុងលោក បុរសនេះ ជាព្រះពុទ្ធដោយមិនមានសង្ស័យ ទើបធ្វើការក្រោកទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន បានចាត់អាសនៈថ្វាយហើយ ។ ព្រះមានព្រះភាគប្រថាប់គង់លើអាសនៈដែលចាត់ចែងទុក ។ សូម្បីសរទតាបស ក៏កាន់យកអាសនៈដ៏សមគួរដល់ខ្លួនហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ក្នុងសម័យនោះ ជដិលប្រាំពីរម៉ឺនបួនពាន់នាក់ យកផលាផលទាំងឡាយដ៏ប្រណីតៗ ដែលមានឱជា មកដល់សំណាក់អាចារ្យ ហើយក្រឡេកមើលអាសនៈដែលព្រះពុទ្ធទ្រង់ប្រថាប់ និង

អាចារ្យរបស់ខ្លួន ទើបនិយាយថា “លោកអាចារ្យ ពួកខ្ញុំត្រាច់ទៅដោយតាំងចិត្តថា ក្នុងលោកនេះអ្នកដែលធំជាងលោកអាចារ្យ រមែងមិនមាន ក៏បុរសនេះ ជាអ្នកធំជាងលោកអាចារ្យឬ” ។ សរទតាបសឆ្លើយថា បា! ទាំងឡាយ ពួកអ្នកនិយាយអ្វី ពួកអ្នកប្រាថ្នាធ្វើភ្នំសិនេរុដែលមានកម្ពស់ប្រាំមួយលានប្រាំបីសែនយោជន៍ ឲ្យស្មើនឹងគ្រាប់ស្ពៃ (ដូច្នេះឬ) អ្នកទាំងឡាយ ពួកអ្នកកុំធ្វើការប្រៀបធៀបយើងជាមួយព្រះសព្វញ្ញុពុទ្ធឡើយ ។ គ្រានោះតាបសទាំងនោះគិតថា បើបុរសនេះជាអ្នកតូចសោត លោកអាចារ្យរបស់ពួកយើងគង់មិនយកវត្ថុបែបនេះមកឧបមា បុរសនេះនឹងធំប៉ុណ្ណាហ្ន៎ ដូច្នេះ ទាំងអស់គ្នាទើបក្រាបចុះទៀបព្រះបាទទាំងពីរ ថ្វាយបង្គំដោយសិរសា ។ គ្រានោះ អាចារ្យពោលចំពោះតាបសទាំងនោះថា អ្នកទាំងឡាយ ទេយ្យ-ធម៌ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយរបស់យើងមិនមាន ឯព្រះសាស្តាក៏ស្តេចយាងមកក្នុងទីនេះក្នុងវេលាភិក្ខា ពួកយើងនឹងថ្វាយទេយ្យធម៌តាមដែលអាច តាមកម្លាំង ពួកអ្នកចូរនាំផលាផលដ៏ប្រណីតដែលមានមក លុះឲ្យនាំមកហើយ ក៏បានលាងដៃទាំងពីរ លើកតម្កល់ទុកក្នុងបាត្ររបស់ព្រះ

តថាគតដោយខ្លួនឯង ។ កាលព្រះសាស្តាទ្រង់ទទួលផលាផល ទេវតាទាំងឡាយក៏ដាក់ឱជាជាទិព្វចុះ ។ តាបសនោះ បានត្រងទឹកថ្វាយដោយខ្លួនឯង ។ តអំពីនោះ កាលព្រះសាស្តាប្រថាប់គង់ធ្វើកត្តកិច្ចហើយ តាបសនោះ ហៅអន្តេវាសិកទាំងអស់មក ហើយពោលសារណីយកថាក្នុងទីជិតព្រះសាស្តា ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា សូមអគ្គសាវកទាំងពីរ ចូរមកព្រមដោយភិក្ខុសង្ឃ ។ ព្រះអគ្គសាវកទាំងពីរនោះជ្រាបព្រះតម្រិះរបស់ព្រះសាស្តាហើយ មានព្រះខីណាស្រពមួយសែនអង្គជាបរិវារ មកថ្វាយបង្គំព្រះសាស្តា នឹងបានឈរនៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ សរទតាបសហៅអន្តេវាសិកទាំងឡាយមក ពោលថា អ្នកទាំងឡាយ សូម្បីអាសនៈដែលព្រះពុទ្ធប្រថាប់គង់ក៏នៅទាប ឯអាសនៈសម្រាប់សមណៈមួយសែន ក៏មិនមាន ពួកអ្នកគួរធ្វើពុទ្ធសក្ការៈឲ្យឱឡារក្នុងថ្ងៃនេះ ចូរនាំផ្កាឈើទាំងឡាយដល់ព្រមដោយពណ៌ និងក្លិនមកអំពីជើងភ្នំ ។ វេលាដែលនិយាយដូចជាយឺតយូរ តែវិស័យរបស់អ្នកមានឫទ្ធិបុគ្គលមិនគួរគិត ព្រោះដូច្នោះ ដោយកាលត្រឹមតែមួយរំពេចប៉ុណ្ណោះ ។ តាបសទាំងនោះ នាំផ្កាឈើទាំងឡាយ

ដែលដល់ព្រមដោយពណ៌ និងក្លិនមកហើយ តាក់តែងអាសនៈផ្កាសម្រាប់ព្រះពុទ្ធទាំងឡាយ ប្រមាណកម្ពស់ ១ យោជន៍ សម្រាប់ព្រះអគ្គសាវកទាំងពីរប្រមាណ ៣ គាវុត[១] សម្រាប់ភិក្ខុដ៏សេសមានប្រមាណផ្សេងៗគ្នា មានប្រមាណកន្លះយោជន៍[២] ជាដើម សម្រាប់ភិក្ខុបួសថ្មីក្នុងសង្ឃមានប្រមាណ ១ ឧសភៈ[៣] នរណាៗ មិនគប្បីគិតថា ក្នុងអាស្រមបទតែមួយនឹងតាក់តែងអាសនៈធំតូចដល់ម្ល៉ឹងបានយ៉ាងណា ព្រោះថា នេះជាវិស័យរបស់ឫទ្ធិ៍ កាលតាក់តែងអាសនៈស្ដេចហើយយ៉ាងនោះ សរទតាបសឈរផ្គងអញ្ជលីឆ្ពោះព្រះភ័ក្ត្រព្រះតថាគត ហើយក្រាបទូលថា "បពិត្រព្រះអង្គចម្រើន សូមព្រះអង្គស្ដេចឡើងកាន់អាសនៈផ្កានេះ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះអង្គអស់រាត្រីយូរ" ។ ព្រោះដូច្នោះ ព្រះបុរាណាចារ្យទើបពោលទុកថា ៖

សរទតាបសយកផ្កាឈើផ្សេង ៗ និងរបស់ក្រអូបរួមគ្នា
តាក់តែងអាសនៈផ្កាឈើ ហើយបានក្រាបទូលពាក្យនេះថា

---

១. មួយគាវុតស្មើ ១០០ សិ្ស ២. មួយយោជន៍ស្មើ ៤ គាវុត ៣. មួយឧសភៈស្មើ ២៥ ព្យាម ។

បពិត្រព្រះវីរៈ អាសនៈដែលខ្ញុំព្រះអង្គតាក់តែងហើយនេះ
សមគួរដល់ព្រះអង្គ ព្រះអង្គកាលនឹងញ៉ាំងចិត្តរបស់ខ្ញុំ
ព្រះអង្គឲ្យជ្រះថ្លា សូមទ្រង់ប្រថាប់គង់លើអាសនៈផ្កា
ព្រះពុទ្ធ ទ្រង់បានញ៉ាំងចិត្តរបស់ខ្ញុំព្រះអង្គឲ្យជ្រះថ្លាហើយ
ញ៉ាំងលោកនេះព្រមទាំងទេវលោកឲ្យរីករាយហើយ ទើប
ប្រថាប់គង់លើអាសនៈផ្ការហូត ៧ យប់ ៧ ថ្ងៃ ។

កាលព្រះសាសនាប្រថាប់គង់ហើយ ព្រះអគ្គសាវកទាំងពីរ និងភិក្ខុសង្ឃដ៏សេស ក៏គង់លើអាសនៈដែលសមគួររៀងៗ ខ្លួន ។ សរទតាបសបានកាន់ឆ័ត្រផ្កាដ៏ធំ ឈរបាំងព្រះសីសៈរបស់ព្រះតថាគត ។ ព្រះសាស្ដាទ្រង់អធិដ្ឋានថា “សូមសក្ការៈនេះ របស់ជដិលចូរមានផលច្រើន” ដូច្នេះហើយទ្រង់ចូលនិរោធសមាបត្តិ ។ អគ្គសាវកទាំងពីរក្ដី ភិក្ខុដ៏សេសក្ដី បានជ្រាបថា ព្រះសាស្ដាទ្រង់ចូលសមាបត្តិហើយ ក៏ចូលសមាបត្តិ ។ កាលព្រះតថាគតប្រថាប់គង់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ពួកអន្តេវាសិកកាលដល់វេលាភិក្ខា ក៏បរិភោគមូលផលាផលក្នុងព្រៃនោះ ហើយឈរផ្គង

អញ្ជលីចំពោះពុទ្ធបុគ្គលទាំងឡាយ រហូតកាលដ៏សេស ។ ចំណែកសរទ-តាបស មិនបានសូម្បីចូលទៅកាន់ភិក្ខា ប៉ាំងឆត្រផ្កានៅមួយកន្លែង ឲ្យវេលាកន្លងទៅដោយបីតិ និងសុខរហូតអស់ ៧ ថ្ងៃ ។ ព្រះសាស្តាស្តេចចេញចាកនិរោធសមាបត្តិហើយ ត្រាស់ហៅនិសភត្ថេរ អគ្គសាវកស្តាំដែលគង់ជិតព្រះហស្តខាងស្តាំ ត្រាស់ថា “និសភៈ អ្នកចូរធ្វើអនុមោទនាអាសនៈផ្កាដល់តាបសទាំងឡាយអ្នកធ្វើសក្ការៈនេះចុះ” ។ ព្រះថេរៈមានចិត្តរីករាយដូចជាមេទ័ពធំប្រសព្វលាភធំអំពីសំណាក់ស្តេចចក្រពត្តិ តាំងនៅក្នុងសាវកបារមីញាណ រីករាយអនុមោទនាអាសនៈផ្កាហើយ ។ ក្នុងទីបំផុតទេសនារបស់ព្រះនិសភៈនោះ ព្រះសាស្តាត្រាស់ហៅព្រះអគ្គសាវកទី ២ ត្រាស់ថា “ភិក្ខុ សូម្បីអ្នកក៏ចូរសំដែងធម៌” ។ ព្រះអនោមត្ថេរ ពិចារណាព្រះពុទ្ធ-វចនៈ គឺ ព្រះត្រៃបិដក ពោលធម៌ហើយ ។ ដោយទេសនារបស់ព្រះអគ្គសាវកទាំងពីរ ការត្រាស់ដឹងក៏មិនបានមានសូម្បីដល់តាបសមួយរូប ។ គ្រានោះ ព្រះសាស្តាទ្រង់តាំងនៅក្នុងពុទ្ធវិស័យមិនមានប្រមាណ ទ្រង់ផ្តើមព្រះធម្មទេសនា ។ ក្នុងកាលចប់ធម្មទេសនា ជដិលប្រាំពីរម៉ឺនបួនពាន់នាក់ វៀរ

សរទតាបសចេញ ក៏បានសម្រេចព្រះអរហត្ត ។ ព្រះសាស្តាទ្រង់ដាក់ព្រះហស្តត្រាស់ថា "អ្នកទាំងឡាយ ចូរជាភិក្ខុចុះ" ។ ក្នុងរំពេចនោះឯងសក់និងពុកមាត់របស់ជដិលទាំងនោះ បានអន្តរធានអស់ទៅ ។ បរិក្ខារ ៨ បានប្រាកដដល់កាយព្រមគ្នា ។ ព្រោះហេតុអ្វី សរទតាបសទើបមិនបានសម្រេចព្រះអរហត្ត ។ ព្រោះមានចិត្តរាយមាយ ។ បានឮថា ផ្តើមតាំងពីកាលដែលសរទតាបសនោះ ស្តាប់ធម៌ទេសនារបស់ព្រះអគ្គសាវកដែលគង់លើអាសនៈទី ២ នៃពុទ្ធបុគ្គលទាំងឡាយ តាំងនៅក្នុងសាវកបារមីញាណសំដែងធម៌ហើយ កើតការគិតថា "ឱហ្ន៎! សូម្បីយើងក៏គប្បីបានទទួលធុរៈដែលព្រះសាវករូបនេះ បានទទួលក្នុងសាសនារបស់ព្រះពុទ្ធ ដែលស្តេចនឹងឧប្បត្តិក្នុងអនាគត" ។ ដោយបរិវិតក្កៈនោះ សរទតាបសនោះទើបមិនអាចចាក់ធ្លុះមគ្គ និងផលបាន ។ ក៏លោកឈរថ្វាយការបាំងមុខព្រះតថាគតក្នុងទីចំពោះព្រះភ័ក្ត្រ ទើបក្រាបទូលថា "ព្រះអង្គដ៏ចម្រើន ភិក្ខុដែលគង់លើអាសនៈក្នុងលំដាប់នៃព្រះអង្គ មានឈ្មោះថាជានរណា ក្នុងសាសនារបស់ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "ភិក្ខុ ជាអ្នកញុំាងធម្មចក្កដែល

តថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅបាន សម្រេចទីបំផុតនៃសាវក បារមីញាណ ចាក់ធ្លុះដោយបញ្ញា ១៦ យ៉ាង តាំងនៅ ភិក្ខុនេះឈ្មោះថា ជាអគ្គសាវកក្នុងសាសនារបស់តថាគត ។ តាបសក៏បានធ្វើសេចក្តីប្រាថ្នា ថា "បពិត្រព្រះអង្គ ដោយផលនៃសក្ការៈដែលខ្ញុំព្រះអង្គឈរបាំងឆ័ត្រផ្កា រហូត ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាជាសក្កទេវរាជ ឬជាព្រាហ្មណ៍ ដទៃណាទេ តែខ្ញុំព្រះអង្គ គប្បីបានជាអគ្គសាវករបស់ព្រះពុទ្ធមួយព្រះអង្គ ក្នុងអនាគត ដូចព្រះនិសភត្ថេរផងចុះ" ។ ព្រះសាស្តាទ្រង់បញ្ជូនព្រះអនាគតង្សញ្ញាណ ពិចារណាថា "សេចក្តីប្រាថ្នារបស់បុរសនេះ នឹងសម្រេច ឬហ្ន៎" ទ្រង់បានជ្រាបថា កន្លងទៅ ១ អសង្ខេយ្យ ក្រៃលែងមួយសែនកប្ប នឹងបានសម្រេច លុះទ្រង់ជ្រាបហើយ ទើបត្រាស់ចំពោះសរទតាបសថា "ការ ប្រាថ្នារបស់អ្នក នឹងមិនឥតប្រយោជន៍ឡើយ ក៏ក្នុងអនាគតកន្លងទៅ មួយ អសង្ខេយ្យ និងមួយសែនកប្ប ព្រះពុទ្ធព្រះនាមថា **គោតម** ស្តេចនឹងឧប្បត្តិ ឡើងក្នុងលោក ព្រះមាតារបស់ព្រះអង្គ មានព្រះនាមថា **មហាមាយាទេវី** ព្រះបិតារបស់ព្រះអង្គព្រះនាមថា **សុទ្ធោទនមហារាជ** ព្រះឱរសមានព្រះនាម

ថា **រាហុល** ពុទ្ធុប្បដ្ឋាកមាននាមថា **អានន្ទ** ព្រះសាវកទី ២ មាននាមថា **មោគ្គល្លាន** ចំណែកខ្លួនអ្នកនឹងជាព្រះអគ្គសាវករបស់ព្រះអង្គ នាមថា **ធម្ម-សេនាបតីសារីបុត្រ**" ។ លុះទ្រង់ព្យាករណ៍ តាមសយ៉ាងនោះហើយ ទ្រង់ត្រាស់ធម្មកថា មានភិក្ខុសង្ឃហែហម ហោះទៅហើយ ។

ចំណែកសរទតាបស ទៅកាន់សំណាក់របស់ព្រះថេរៈដែលជាអន្តេ-វាសិក ហើយបញ្ជូនតំណឹងទៅដល់សិរីវឌ្ឍកុដុម្ពិក៍ជាសំឡាញ់ថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយចូរប្រាប់ដល់សំឡាញ់របស់ខ្ញុំថា "សរទតាបស ដែលជាសំឡាញ់របស់លោក បានប្រាថ្នាតំណែងព្រះអគ្គ-សាវកក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថា **គោតម** ដែលទ្រង់នឹងឧប្បត្តិឡើងក្នុងអនាគត ទៀបបាទមូលរបស់ព្រះមានព្រះភាគព្រះនាម **អនោមទស្សី** ហើយ លោកចូរប្រាថ្នាតំណែងព្រះអគ្គសាវកទី ២" ចុះ ។ ក៏ក្នុងគ្រាពោលយ៉ាងនេះហើយ បានធ្វើដំណើរទៅមុនព្រះថេរៈទាំងឡាយ បានឈរនៅត្រង់មាត់ទ្វារផ្ទះរបស់សិរីវឌ្ឍ ។ សិរីវឌ្ឍពោលថា "យូរណាស់ហើយ លោកម្ចាស់របស់យើងទើបមក" ហើយនិមន្តឲ្យគង់លើអាសនៈ ខ្លួនអង្គុយលើ

អាសនៈទាបជាង ផ្តើមសួរថា "ហេតុអ្វី អន្តេវាសិកបរិស័ទរបស់លោកម្ចាស់បាត់ទៅណាអស់ហើយ" ។

សរទៈ. សំឡាញ់ ព្រះអនោមទស្សីស្តេចយាងមកកាន់អាស្រមរបស់ខ្ញុំទាំងឡាយ ពួកខ្ញុំធ្វើសក្ការៈចំពោះព្រះអង្គតាមកម្លាំងរបស់ខ្លួន ព្រះសាស្តាទ្រង់សំដែងធម៌ប្រោសពួកខ្ញុំគ្រប់ៗ គ្នា ក្នុងកាលចប់ទេសនា វៀរតែខ្ញុំចេញដ៏សេសសម្រេចព្រះអរហត្ត ហើយបួស ខ្ញុំឃើញព្រះនិសភត្ថេរ អគ្គសាវករបស់ព្រះសាស្តា ទើបបានប្រាថ្នាតំណែងអគ្គសាវកក្នុងសាសនារបស់ព្រះពុទ្ធគោតម ដែលព្រះអង្គនឹងឧប្បត្តិឡើងក្នុងអនាគត សូម្បីលោកក៏ចូរប្រាថ្នាតំណែងសាវកទី ២ ក្នុងសាសនារបស់ព្រះអង្គចុះ ។

សិរីវឌ្ឍ. ខ្ញុំមិនមានការស្និទ្ធស្នាលនឹងព្រះពុទ្ធទាំងឡាយឡើយ ។

សរទៈ. រឿងដែលនឹងទូលចំពោះព្រះអង្គជាភារៈរបស់ខ្ញុំ ឯលោកចូរត្រៀមសក្ការៈធំទុកចុះ ។

សិរីវឌ្ឍស្តាប់ពាក្យរបស់សរទតាបសនោះហើយ ឲ្យចាត់ចែងធ្វើស្ថានទីប្រមាណ ៨ ករីសៈ[១] ដូចលានហ្លួងត្រង់ទ្វារផ្ទះរបស់ខ្លួនឲ្យមានផ្ទៃរាប

ស្មើ កៀវខ្សាច់ រោយផ្កាឈើ មានលាជជាទី ៥ ឲ្យធ្វើមណ្ឌបប្រក់ដោយផ្កាឧប្បលខៀវ តុបតែងពុទ្ធាសនៈ ចាត់ចែងអាសនៈសូម្បីដល់ភិក្ខុដ៏សេសត្រៀមសក្ការៈ និងគ្រឿងទទួលជាច្រើន ទើបបានឲ្យសញ្ញាដល់សរទតាបសដើម្បីក្រាបទូលនិមន្តព្រះពុទ្ធទាំងឡាយ ។ ព្រះតាបសបាននាំភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទៅកាន់ទីនៅរបស់សិរីវឌ្ឍកុដុម្ពិក៍នោះឯង ។ ចំណែកសិរីវឌ្ឍកុដុម្ពិក៍ ធ្វើការទទួលរាក់ទាក់ ទទួលបាត្រអំពីព្រះហស្តរបស់ព្រះតថាគត និមន្តស្តេចឲ្យចូលទៅកាន់មណ្ឌប ថ្វាយទឹកទក្ខិណោទកដល់ភិក្ខុ-សង្ឃមានព្រះពុទ្ធជាប្រធាន ដែលប្រថាប់គង់លើអាសនៈដែលចាត់ចែងទុកអង្គៀសដោយភោជនដ៏ប្រណីត ក្នុងវេលាស្រេចភត្តកិច្ច និមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យទ្រង់ស្លៀកដណ្តប់សំពត់ដែលមានតំលៃច្រើន បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរីករាយនេះមិនបានប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់តំណែងមានប្រមាណតិចតួចឡើយ សូមព្រះអង្គទ្រង់ធ្វើសេចក្តីអនុគ្រោះដោយទំនងនេះរហូត ៧ ថ្ងៃ" ។ ព្រះសាស្តាទ្រង់ទទួល

---

១. ករីសៈជាមាត្រាមួយប្រភេទ ១ ករីសៈ=១២៥ ហស្ត ឬ ១ ខ្សែ ១១ ព្យាម ១ ហត្ថ ។

ហើយ ។ គេញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅដោយទំនងនោះ រហូតអស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះមានព្រះភាគហើយ ឈរផ្គងអញ្ជលី ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សរទតាបសសំឡាញ់របស់ខ្ញុំព្រះអង្គប្រាថ្នាថា យើងគប្បីជាអគ្គសាវករបស់ព្រះសាស្ដាព្រះអង្គណា ខ្ញុំព្រះអង្គគប្បីជាអគ្គសាវកទី ២ របស់ព្រះសាស្ដាអង្គនោះដូចគ្នា” ។ ព្រះសាស្ដាទ្រង់ពិចារណាដល់អនាគតកាល ទ្រង់ឃើញការៈ គឺ សេចក្ដីសម្រេចនៃសេចក្ដីប្រាថ្នារបស់គេ ទើបទ្រង់ព្យាករណ៍ថា “តាំងអំពីនេះទៅ ១ អសង្ខេយ្យនិងមួយសែនកប្បសូម្បីអ្នក ក៏នឹងជាព្រះសាវកទី ២ របស់ព្រះពុទ្ធគោតម” ។ សិរិវឌ្ឍស្ដាប់ពាក្យព្យាករណ៍របស់ព្រះពុទ្ធហើយ ក៏រីករាយក្រៃលែង ។ ភិក្ខុទាំងឡាយនេះជាមានសេចក្ដីប្រាថ្នា ដែលបុត្ររបស់យើងប្រាថ្នាហើយក្នុងកាលនោះ អគ្គសាវកទាំងពីរនោះ បានតំណែងតាមដែលខ្លួនប្រាថ្នាហើយនោះៗ ឯងតថាគតមិនបានយល់ដល់មុខ ហើយឲ្យតំណែងឡើយ ។

កាលព្រះសាស្ដាត្រាស់ព្រះពុទ្ធវចនៈយ៉ាងនេះហើយ ព្រះអគ្គសាវកទាំងពីរថ្វាយបង្គំព្រះមានព្រះភាគ ទូលសួររឿងដែលជាបច្ចុប្បន្ន (ដែលកើត

ឡើងចំពោះមុខ) ទាំងអស់ថា "បពិត្រព្រះអង្គដ៏ចម្រើន (គ្រា) ខ្ញុំព្រះអង្គនៅជាអ្នកគ្រប់គ្រងផ្ទះ ទៅមើលមហោស្រពលើកំពូលភ្នំ" ដូច្នេះជាដើមរហូតដល់ការចាក់ធ្លុះសោតាបត្តិផល អំពីសំណាក់ព្រះអស្សជិត្ថេរ ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរនាក់ទៅកាន់សម្នាក់របស់លោកអាចារ្យសញ្ជ័យ ប្រាថ្នានឹងធ្វើលោកឲ្យមកកាន់បាទមូលរបស់ព្រះអង្គ ដោយដឹងថា លទ្ធិរបស់លោកមិនមានសារៈ ហើយពោលអានិសង្សក្នុងការមកកាន់ទីនេះ អាចារ្យសញ្ជ័យឆ្លើយថា ឥឡូវនេះឈ្មោះថា ការនៅជាអន្តេវាសិករបស់យើង រមែងដូចជាការកម្រើកនៃទឹកក្នុងពាង យើងមិនអាចនៅជាអន្តេវាសិកបានឡើយ កាលខ្ញុំព្រះអង្គប្រាប់ថា លោកអាចារ្យវេលានេះ មហាជន កាន់យកវត្ថុមានរបស់ក្រអូប និងផ្កាកម្រងជាដើមទៅបូជាចំពោះព្រះសាស្តា លោកនឹងនៅយ៉ាងណា ឆ្លើយថា ក៏ក្នុងលោកនេះមនុស្សឆ្លាតច្រើន ឬមនុស្សល្ងង់ច្រើន កាលខ្ញុំព្រះអង្គឆ្លើយថា មនុស្សល្ងង់ច្រើន ក៏ពោលថា បើដូច្នោះ មនុស្សឆ្លាតៗ នឹងទៅកាន់សំណាក់របស់ព្រះសមណគោតម ពួកមនុស្សល្ងង់នឹងមកកាន់សំណាក់របស់យើង លោក

ទាំងពីរទៅចុះ មិនប្រាថ្នានឹងមកទេ ព្រះអង្គ ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យនេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សញ្ជ័យប្រកាន់វត្ថុដែលមិនមានសារៈ ថាមានសារៈ និងវត្ថុដែលមានសារៈ ថាមិនមានសារៈទៅវិញ ព្រោះខ្លួនជាមិច្ឆាទិដ្ឋិ ចំណែកអ្នកទាំងឡាយ ដឹងវត្ថុដែលជាសារៈ ថាជាសារៈ និងវត្ថុដែលមិនមែនជាសារៈ ថាមិនមែនជាសារៈ លះបង់វត្ថុដែលមិនមានសារៈចេញ កាន់យកវត្ថុដែលមានសារៈប៉ុណ្ណោះ ព្រោះខ្លួនបណ្ឌិត ហើយទ្រង់ត្រាស់ភាសិតព្រះគាថាទាំងនេះថា ៖

អសារេ សារមតិនោ សារេ ចាសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។
សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

ជនទាំងឡាយ ដែលយល់ឃើញ ក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវ ធម៌ដែលមានខ្លឹមឡើយ ។ ជនទាំងឡាយ ដែលយល់

*ឃើញនូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញ*

*នូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹម ជាអ្នកមានតម្រិះត្រូវ*

*ជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **អសារេ សារមតិនោ** (មានប្រក្រតីដឹង ក្នុងវត្ថុដែលមិនជាសារៈ ថាជាសារៈ) សេចក្តីថា សភាពនេះ គឺ បច្ច័យ ៤ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ធម្មទេសនាដែលជាឧបនិស្ស័យនៃមិច្ឆាទិដ្ឋិនោះ ឈ្មោះថា វត្ថុដែលមិនមានសារៈ អធិប្បាយថា អ្នកមានប្រក្រតីឃើញវត្ថុ ដែលមិនជាសារៈនោះ "ថាជាសារៈ" ។ បទថា **សារេ ចាសារទស្សិនោ** (ឃើញក្នុងវត្ថុដែលជាសារៈ ថាមិនជាសារៈ) សេចក្តីថា សភាពនេះ គឺ សម្មាទិដ្ឋិមានវត្ថុ ១០ ធម្មទេសនាដែលឧបនិស្ស័យនៃសម្មាទិដ្ឋិនោះ ឈ្មោះ ថា វត្ថុដែលជាសារៈ អធិប្បាយថា អ្នកមានប្រក្រតីឃើញក្នុងវត្ថុដែលជា សារៈនោះ ថាជាវត្ថុមិនជាសារៈ "ថានេះមិនជាសារៈ" ។ បទថា **តេ សារំ** (ជនទាំងនោះ... វត្ថុដែលជាសារៈ) ជាដើម សេចក្តីថា ជនទាំងនោះ គឺ*

ជនអ្នកប្រកាន់មិច្ឆាទិដ្ឋិនោះឯង ជាអ្នកមានការត្រិះរិះខុសជាគោចរ ដោយអំណាចនៃវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើម រមែងមិនលុះក្នុងសីលសារៈ សមាធិសារៈ បញ្ញាសារៈ វិមុត្តិសារៈ វិមុត្តិញាណទស្សនសារៈ និងព្រះនិព្វានដែលជាបរមត្ថសារៈ ។

បទថា *សារញ្ច (វត្ថុដែលជាសារៈ)* សេចក្តីថា ដឹងសារៈ មានសីលសារៈជាដើមនោះៗ ឯងថា "នេះឈ្មោះថាសារៈ" និងដឹងវត្ថុដែលមិនជាសារៈ មានប្រការដូចដែលពោលហើយថា "នេះមិនជាសារៈ" ។ បទថា *តេ សារំ (ជនទាំងនោះ... វត្ថុដែលជាសារៈ)* ជាដើម សេចក្តីថា ជនទាំងនោះ គឺ បណ្ឌិតអ្នកមានសម្មាទស្សនៈយ៉ាងនោះ ជាអ្នកមានការត្រិះរិះត្រូវជាគោចរ ដោយអំណាចសេចក្តីត្រិះរិះទាំងឡាយ មានការត្រិះរិះចេញចាកកាមជាដើម រមែងលុះក្នុងវត្ថុដែលជាសារៈ មានប្រការដូចដែលពោលហើយនោះឯង ។

ក្នុងកាលចប់ព្រះគាថា ជនដ៏ច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានជាប្រយោជន៍ដល់ជន ដែលប្រជុំគ្នា

*ហើយនោះឯង ៗ*

ចប់រឿងសញ្ជ័យ

# ៩. រឿងព្រះនន្ទត្ថេរៈ

*ព្រះសាស្ដាកាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនន្ទ ត្រាស់ព្រះធម្មទេសនានេះថា* ***យថា អគារំ ទុច្ឆន្នំ*** *(ផ្ទះដែលប្រក់មិនបានល្អ) ជាដើម ។*

*សេចក្ដីពិស្ដារថា ព្រះសាស្ដាញុំាងព្រះធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅហើយ ស្ដេចទៅកាន់ក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងវត្តវេឡុវ័ន បណ្ដាទូត ១០ នាក់ មានបរិវារម្នាក់ ១.០០០ ដែលព្រះបាទសុទ្ធោទនៈមហារាជទ្រង់បញ្ជូនទៅដោយត្រាស់បង្គាប់ថា "អ្នកទាំងឡាយចូរនាំបុត្ររបស់យើងមកចុះ" ។ ព្រះកាឡុទាយីទៅក្រោយទូតទាំងនោះ បានសម្រេចព្រះអរហត្តហើយ ជ្រាបកាលដែលព្រះមានព្រះភាគទ្រង់ចារិក ក៏បានពណ៌នានូវគាថាប្រមាណ ៦០ គាថា នាំស្ដេច (ព្រះសាស្ដា) មានព្រះខីណាស្រពពីរម៉ឺនហែហមហើយ ទៅកាន់ក្រុងកបិលវត្ថុ ទ្រង់ធ្វើភ្លៀងបោក្ខរព័ស្សឲ្យជាហេតុកើតនៃរឿង ហើយត្រាស់មហាវេស្សន្តរជាតកក្នុងសមាគមព្រះញាតិ ។ លុះថ្ងៃស្អែក ស្ដេចយាងបិណ្ឌបាត ប្រោសព្រះបិតាឲ្យតាំងនៅក្នុងសោតាបត្តិផល*

ដោយព្រះគាថាថា **ឧត្តិដ្ឋេ នប្បមជ្ជេយ្យ** ជាដើម ប្រោសព្រះនាងមហាបជាបតិគោតមីឲ្យតាំងនៅក្នុងសោតាបត្តិផល និងប្រោសព្រះរាជា (ព្រះបិតា) ឲ្យតាំងនៅក្នុងសកទាគាមិផល ដោយព្រះគាថាថា **ធម្មញ្ចរេ សុចរិតំ** ជាដើម ។ ក៏ក្នុងកាលភត្តកិច្ចស្រេចហើយ ទ្រង់អាស្រ័យការពណ៌នាព្រះគុណរបស់រាហុលមាតា ត្រាស់ចន្ទកន្នរីជាតក ក្នុងថ្ងៃទី ៣ ថ្ងៃនោះ ជាថ្ងៃវិវាហមង្គល អភិសេកនន្ទកុមារ ។ ស្តេចយាងទៅដើម្បីបិណ្ឌបាត ប្រទានបាត្រទុកក្នុងព្រះហត្ថរបស់នន្ទកុមារ ត្រាស់មង្គល (ឲ្យពរ) រួចស្តេចក្រោកចាកអាសនៈចៀសចេញទៅ ទ្រង់មិនបានទទួលបាត្រអំពីដៃរបស់នន្ទកុមារ ។ ចំណែកនន្ទកុមារនោះ ដោយសេចក្តីគោរពក្នុងព្រះតថាគត ទើបមិនអាចទូល (ប្រាប់) ថា សូមព្រះអង្គទទួលបាត្រវិញ ព្រះអង្គ ។ តែគិតយ៉ាងនេះថា ព្រះសាស្តាទ្រង់គង់នឹងទទួលបាត្រត្រង់ក្បាលជណ្តើរ ។ សូម្បីក្នុងទីនោះ ព្រះសាស្តាក៏ទ្រង់មិនបានទទួល ។ នន្ទកុមារក៏គិតទៀតថា គង់នឹងទ្រង់ទទួលត្រង់មាត់ជណ្តើរ ។ សូម្បីក្នុងទីនោះ ព្រះសាស្តាក៏ទ្រង់មិនទទួល ។ នន្ទកុមារក៏គិតថា ទ្រង់នឹងទទួលត្រង់ព្រះលានហ្លួង ។ សូម្បីក្នុង

ទីនោះ ព្រះសាស្តាក៏ទ្រង់មិនទទួល ។ ព្រះកុមារបំណាងនឹងត្រឡប់ (តែ) តាមស្តេចទៅដោយការមិនពេញព្រះទ័យ ព្រោះមានសេចក្តីគោរពក្នុងព្រះតថាគត ទើបមិនអាចទូលថា "សូមព្រះអង្គទ្រង់ទទួលបាត្រ" ទ្រង់ដើរផងគិតផងថា "ព្រះអង្គទ្រង់នឹងទទួលក្នុងទីនេះ ព្រះអង្គទ្រង់នឹងទទួលក្នុងទីនេះ ។ ក្នុងខណៈនោះ ស្ត្រីពួកដទៃឃើញអាការនោះហើយ ទើបប្រាប់ដល់នាងជនបទកល្យាណីថា "ម៉ែម្ចាស់ ព្រះមានព្រះភាគទ្រង់នាំនន្ទកុមារទៅហើយ គង់នឹងព្រាត់ចេញពីម៉ែម្ចាស់" ។ ចំណែកនាងជនបទកល្យាណីនោះ បានឮពាក្យនោះហើយ មានទឹកភ្នែកហូរចេញតែម្យ៉ាង ដែលមានផ្នួងសក់ក្រងបានពាក់កណ្តាល ប្រញាប់ទៅទូលថា "បពិត្រព្រះអយ្យបុត្រ សូមព្រះអង្គងាប់ត្រឡប់វិញ ។ ពាក្យរបស់នាងនោះ ដូចជាធ្លាក់ទៅតាំងនៅទទឹងក្នុងហឫទ័យរបស់នន្ទកុមារ ។ សូម្បីព្រះសាស្តាក៏ទ្រង់មិនទទួលបាត្រអំពីដៃរបស់នន្ទកុមារនោះឡើយ ទ្រង់នាំនន្ទកុមារនោះទៅកាន់វិហារ ហើយត្រាស់ថា "នន្ទ អ្នកបួសទេ" ។ នន្ទកុមារ ដោយសេចក្តីគោរពក្នុងព្រះពុទ្ធ ទើបមិនទូលថា "មិនបួស" បានទូលទទួលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ

ព្រះអង្គបួស ព្រះអង្គ” ព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរឲ្យនន្ទបួសចុះ” ។

## រាហុលកុមារទូលសូមសម្បត្តិចំពោះសាស្ដា

ព្រះសាស្ដាស្ដេចទៅកាន់ក្រុងកបិលវត្ថុ ក្នុងថ្ងៃទី ៣ ទ្រង់ញុំាងនន្ទកុមារឲ្យបួសហើយ ក្នុងថ្ងៃទី ៧ ព្រះមាតារបស់រាហុលទ្រង់តាក់តែងព្រះកុមារហើយ ទ្រង់បញ្ជូនទៅកាន់សំណាក់របស់ព្រះមានព្រះភាគដោយព្រះតម្រាស់ថា “បា! កូនចូរមើលព្រះសមណៈ ដែលមានសមណៈពីរម៉ឺនហែហម ទ្រង់មានវណ្ណៈដូចមាស ទ្រង់មានវណ្ណៈនៃព្រះរូបដូចព្រហ្មនោះ ព្រះសមណៈនេះជាបិតារបស់កូន កំណប់ទ្រព្យធំបានមានហើយក្នុងវេលាដែលព្រះបិតារបស់កូននោះប្រសូត តាំងពីព្រះអង្គចេញបួស ម៉ែមិនបានជួបឡើយ កូនចូរទៅទូលសូមមត៌កចំពោះព្រះអង្គថា បពិត្រព្រះបិតា ខ្ញុំព្រះអង្គជាកុមារដល់នូវការអភិសេកហើយ នឹងជាស្ដេចចក្រពត្តិ ខ្ញុំព្រះអង្គត្រូវការទ្រព្យ សូមព្រះបិតាប្រទានទ្រព្យដល់ខ្ញុំព្រះអង្គ ព្រោះបុត្រ រមែងជាម្ចាស់នៃសម្បត្តិរបស់ព្រះបិតា” ។ ព្រះកុមារ ស្ដេចទៅកាន់សំណាក់របស់

ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក៏បាននូវសេចក្តីស្រឡាញ់ក្នុងព្រះបិតា មានចិត្តរីករាយ ទូលថា "បពិត្រព្រះសមណៈ ព្រះឆាយារបស់ព្រះបិតា គួរឲ្យរីករាយ" បានឈរទូលពាក្យដទៃដ៏ច្រើន ដែលសមគួរដល់ខ្លួន ។ ព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់អនុមោទនា ស្តេចក្រោកចាកអាសនៈចៀសចេញទៅ ។ សូម្បីព្រះកុមារក៏ទូលសូមថា "បពិត្រព្រះសមណៈ សូមបានប្រទានមត៌កដល់ខ្ញុំព្រះអង្គផងចុះ ។ បពិត្រព្រះសមណៈ សូមបានប្រទានមត៌កដល់ខ្ញុំព្រះអង្គផងចុះ" ដូច្នេះ ហើយស្តេចជាប់តាមព្រះមាន-ព្រះភាគទៅ ។ សូម្បីព្រះមានព្រះភាគ ក៏ស្តេចមិនឲ្យកុមារត្រឡប់ ។ ចំណែកបរិជន (អ្នកជិតខាង) ក៏មិនអាចនឹងយាងព្រះកុមារដែលស្តេចទៅជាមួយព្រះមានព្រះភាគឲ្យត្រឡប់បាន ។ ព្រះកុមារនោះ ស្តេចបានដល់អារាមជាមួយព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។ លំដាប់នោះ ព្រះមាន-ព្រះភាគទ្រង់ព្រះតម្រិះថា "កុមារនេះប្រាថ្នាទ្រព្យដែលជាសម្បត្តិរបស់បិតា ទ្រព្យនោះប្រព្រឹត្តទៅក្នុងវដ្តៈ មានសេចក្តីចង្អៀតចង្អល់ច្រើន ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានចំពោះត្រង់គល់ព្រះ

ពោធិដល់គេ និងធ្វើគេឲ្យជាម្ចាស់នៃមគ្គិកដែលជាលោកុត្តរៈ” ។

គ្រានោះឯង ព្រះមានព្រះភាគត្រាស់បង្គាប់ឲ្យរកព្រះសារីបុត្រមក ហើយត្រាស់ថា “សារីបុត្រ អ្នកចូរឲ្យរាហុលកុមារបួសចុះ” ។ ព្រះថេរៈញ៉ាំងកុមារនោះឲ្យបួសហើយ ។ ក៏កាលព្រះកុមារបួសហើយ ទុក្ខមានប្រមាណក្រៃលែងបានកើតឡើងដល់ព្រះរាជា ព្រោះទ្រង់បានស្តាប់ដំណឹងនោះ ។ ព្រះរាជាទ្រង់មិនអាចអត់ទ្រាំក្នុងសេចក្តីទុក្ខនោះបាន ។ ស្តេចក៏បានទៅកាន់សំណាក់ព្រះមានព្រះភាគ ទូលប្រាប់ ហើយសូមប្រទានពរថា “ព្រះអង្គ ខ្ញុំព្រះអង្គសូមប្រទានឱកាស ភិក្ខុទាំងឡាយមិនគប្បីញ៉ាំងបុត្រដែលមាតាបិតាមិនអនុញ្ញាតិឲ្យបួស” ។ ព្រះមានព្រះភាគ ប្រទានពរនោះដល់ព្រះរាជាហើយ ។ ស្អែកឡើង ព្រះរាជាទ្រង់សោយព្រះក្រយាហារពេលព្រឹកក្នុងព្រះរាជនិវេសន៍ហើយ កាលព្រះរាជាប្រថាប់នៅក្នុងទីដ៏សមគួរមួយ ទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវេលាដែលព្រះអង្គបំពេញទុក្ករកិរិយា ទេវតាមួយអង្គចូលមករកខ្ញុំព្រះអង្គ ប្រាប់ថា ព្រះឱរសរបស់ព្រះអង្គទិវង្គតហើយ ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះ ទើបជំទាស់នឹង

ទេវតានោះថា បុត្ររបស់ខ្ញុំនៅមិនទាន់សម្រេចពោធិញ្ញាណ រមែងមិនធ្វើកាលៈឡើយ” ព្រះមានព្រះភាគត្រាស់ថា “មហាបពិត្រ ឥឡូវនេះព្រះអង្គនឹងជឿម្តេចបាន សូម្បីក្នុងកាលមុន កាលគេសំដែងរាងឆ្អឹងដល់ព្រះអង្គទូលថា បុត្ររបស់ព្រះអង្គចូលទិវង្គតហើយ ព្រះអង្គក៏ទ្រង់មិនជឿ” បានត្រាស់មហាធម្មបាលជាតក ព្រោះហេតុកើតនៃរឿងនេះ ។ ក្នុងកាលចប់កថា ព្រះរាជាតាំងនៅក្នុងអនាគាមិផល ។ ព្រះមានព្រះភាគ ប្រោសព្រះបិតាឲ្យតាំងនៅក្នុងផល ៣ ដោយប្រការដូច្នេះឯង ។ ទ្រង់មានភិក្ខុសង្ឃហែហមហើយ ស្តេចក៏ត្រឡប់ទៅកាន់ក្រុងរាជគ្រឹះម្តងទៀត តពីនោះ ទ្រង់បេ្តជ្ញាទុកជាមួយអនាថបិណ្ឌិកសេដ្ឋី ដើម្បីប្រយោជន៍ដល់ព្រះអង្គយាងមកកាន់ក្រុងសាវត្ថី លុះព្រះជេតពនវិហារសម្រេចហើយ ស្តេចទៅចាំវស្សាក្នុងវត្តជេតពនមហាវិហារនោះ ។

## ព្រះនន្ទត្រាថ្នាសឹក

កាលព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតពន ព្រះនន្ទក៏កើតការអផ្សុក ទើបប្រាប់សេចក្តីនោះដល់ភិក្ខុទាំងឡាយថា “លោកមានអាយុ ខ្ញុំមិនត្រេកអរ

ក្នុងការប្រព្រឹត្តព្រហ្មចារ្យ មិនអាចនឹងបន្តព្រហ្មចារ្យទៅបានទេ ខ្ញុំនឹងពោលលាសិក្ខា ហើយសឹក” ។ ព្រះមានព្រះភាគទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ទទួលត្រាស់ឲ្យហៅព្រះនន្ទមកគាល់ ទ្រង់ត្រាស់ថា “ពិតឬនន្ទ បានឮថា អ្នកពោលប្រាប់ដល់ភិក្ខុច្រើនរូបយ៉ាងនេះថា លោកមានអាយុ ខ្ញុំមិនត្រេកអរប្រព្រឹត្តព្រហ្មចារ្យ មិនអាចនឹងបន្តព្រហ្មចារ្យទៅបាន ខ្ញុំនឹងពោលលាសិក្ខា ហើយសឹក ។

ព្រះនន្ទ. ពិតដូច្នោះមែន ព្រះអង្គ ។

ព្រះ. នន្ទ ក៏អ្នកមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចារ្យ មិនអាចនឹងបន្តព្រហ្មចារ្យទៅបាន នឹងពោលលាសិក្ខាហើយសឹក ព្រោះអ្វី ។

ព្រះនន្ទ. បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គចេញចាកផ្ទះ នាងជនបទកល្យាណីដែលជាសក្យៈ មានសក់ក្រងបានពាក់កណ្តាល បានស្រែកហៅដោយពាក្យនេះចំពោះខ្ញុំព្រះអង្គថា “បពិត្រអយ្យបុត្រ សូមអយ្យបុត្រឆាប់ត្រឡប់មកវិញ” បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរឭកដល់ពាក្យនោះទើបមិនត្រេកអរប្រព្រឹត្តព្រហ្មចារ្យ មិនអាចនឹងបន្តព្រហ្មចារ្យទៅបាន នឹង

ពោលលាសិក្ខា ដើម្បីសឹក ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចាប់នន្ទៈត្រង់ព្រះពាហា ហើយនាំទៅកាន់តាវត្តិង្សទេវលោកដោយកម្លាំងឫទ្ធិ ក្នុងរវាងផ្លូវ ទ្រង់សំដែងមេស្វារបោចរោមមួយ មានត្រចៀក ច្រមុះ និងកន្ទុយដាច់ អង្គុយនៅលើចុងជង្គត់ឈើភ្លើងឆេះ ក្នុងស្រែដែលភ្លើងឆេះមួយកន្លែង ហើយទ្រង់សំដែងស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងនៃសត្វព្រាប មកកាន់ទីទំនុកបម្រុងរបស់សក្កទេវរាជក្នុងកពតាវត្តិង្ស ។ លុះទ្រង់សំដែងហើយ ត្រាស់យ៉ាងនេះថា "នន្ទៈ អ្នកសំគាល់សេចក្តីនោះយ៉ាងណា ចំណែកណា មានរូបស្អាតជាង គួរមើលជាង និងគួរពេញចិត្តជាង រវាងនាងជនបទកល្យាណីដែលជាសក្យៈ ឬនាងអប្សរ ៥០០ ដែលមានជើងដូចជើងនៃសត្វព្រាបនេះ" ព្រះននទ្ទបានស្តាប់ព្រះតម្រាស់នោះ ហើយទូលថា "បពិត្រព្រះអង្គដ៏ចម្រើន មេស្វាមានខ្លួនរបោចរោម មានត្រចៀក ច្រមុះ និងកន្ទុយដាច់នោះ យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណី ដែលជាសក្យៈក៏ដូចគ្នានឹងស្វានោះ ដោយការប្រៀបធៀបគ្នា នាងរមែងមិនដល់ការ

រាប់ខ្វះ មិនបានទូវចំរៀកខ្វះ មិនដល់នូវចំណែកខ្វះ នៃនាងអប្សរ ៥០០ នេះ ដែលពិត នាងអប្សរ ៥០០ នេះឯង មានរូបស្អាតជាង គួរមើលជាង និងគួរពេញចិត្តជាង" ។

ព្រះ. នន្ទ អ្នកចូរត្រេកអរ នន្ទ អ្នកចូរត្រេកអរ តថាគតជាអ្នកធានារបស់អ្នកដើម្បីបាននូវនាងអប្សរ ៥០០ ដែលមានជើងដូចជាជើងនៃសត្វព្រាប ។

ព្រះនន្ទ. បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគជាអ្នកធានាដល់ខ្ញុំព្រះអង្គ ដើម្បីបាននាងអប្សរ ៥០០ នាក់ មានជើងដូចជាជើងនៃសត្វព្រាបសោត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងត្រេកអរក្នុងព្រហ្មចារ្យ ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់នាំព្រះនន្ទត្រឡប់វិញ បានប្រាកដនៅក្នុងព្រះជេតពនដូចដើម ។

ភិក្ខុទាំងឡាយបានស្តាប់ហើយថា "ឮដំណឹងថា ព្រះនន្ទជាព្រះភាតារបស់ព្រះមានព្រះភាគ ឱរសព្រះមាតុច្ឆា ប្រព្រឹត្តព្រហ្មចារ្យព្រោះហេតុនៃនាងអប្សរទាំងឡាយ ន័យថា ព្រះមានព្រះភាគទ្រង់ជាអ្នកធានារបស់ព្រះនន្ទ

នោះ ដើម្បីការបានចំពោះស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជាជើងនៃសត្វព្រាប ។ គ្រានោះឯង ពួកភិក្ខុដែលជាសំឡាញ់របស់ព្រះនន្ទ ហៅព្រះនន្ទដោយវាទៈថា ជាអ្នកទទួលឈ្នួលខ្លះ ដោយវាទៈថា ជាអ្នកដែលព្រះមានព្រះភាគទ្រង់លោះទុកខ្លះ ថា "ន័យថា ព្រះនន្ទជាអ្នកស៊ីឈ្នួល ន័យថា ព្រះនន្ទជាអ្នកដែលព្រះសាស្តាលោះទុក ព្រះនន្ទៈប្រព្រឹត្តព្រហ្មចារ្យព្រោះហេតុនៃស្រីទេពអប្សរ ៥០០ បានឮថា ព្រះមានព្រះភាគទ្រង់ជាអ្នកធានារបស់លោក ដើម្បីបានស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជាជើងនៃសត្វព្រាប" ។ គ្រានោះ ព្រះនន្ទអៀនខ្មាស រង្កៀសដោយការទទួលវាទៈថា ជាអ្នកស៊ីឈ្នួលខ្លះ ដោយវាទៈថា ជាអ្នកដែលព្រះសាស្តាទ្រង់លោះទុកខ្លះ របស់ពួកភិក្ខុទាំងឡាយ ក៏គេចចេញទៅតែម្នាក់ឯង មិនប្រមាទ មានសេចក្តីព្យាយាម មានខ្លួនបញ្ជូនទៅហើយ ក្នុងកាលមិនយូរប្រមាណ បានធ្វើឲ្យជាក់ច្បាស់នៅទីបំផុតនៃព្រហ្មចារ្យដ៏កំពូល ដែលកុលបុត្រទាំងឡាយចេញចាកផ្ទះ បួសមិនមានផ្ទះត្រូវការហើយ ដោយបញ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្ន ចូលដល់ហើយ ដឹងច្បាស់ថា "ជាតិអស់ហើយ ព្រហ្មចរិយៈ

នៅចប់ហើយ កិច្ចដែលត្រូវធ្វើ ធ្វើស្រេចហើយ កិច្ចដទៃទៀតដើម្បីសភាព ជាយ៉ាងនេះ មិនមាន" ព្រោះថា ព្រះនន្ទបានជាព្រះអរហន្តមួយអង្គ ក្នុងបណ្ដាព្រះអរហន្តទាំងឡាយ ។

គ្រានោះ ទេវតាមួយអង្គ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាងក្នុងចំណែកនៃរាត្រី ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទ ជាព្រះភាតារបស់ព្រះមានព្រះភាគ ឱរសរបស់ព្រះមាតុច្ឆា ធ្វើឲ្យជាក់ច្បាស់នៅចេតោវិមុត្តិ[១] បញ្ញាវិមុត្តិ[២] ជាអ្នកមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងឯងក្នុងបច្ចុប្បន្ន ចូលដល់ហើយ" ។ ព្រះនន្ទនោះ ដោយកន្លងទៅនៃរាត្រីនោះ បានចូលគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ បានក្រាបទូលពាក្យនេះថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ធានាខ្ញុំព្រះអង្គ ដើម្បីបាននាងស្រីអប្សរ ៥០០ ដែលមានជើងដូចជាជើងនៃសត្វព្រាប ដោយការធានាណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានដោះព្រះ

---

១. ផុតចាកកិលេសដោយចិត្ត (សមថៈ) ២.ផុតចាកកិលេសដោយបញ្ញា ។

មានព្រះភាគអំពីការជានានោះហើយ" ។ ព្រះមានព្រះភាគត្រាស់ថា "នន្ទ សូម្បីតថាគតក៏កំណត់ក្នុងចិត្តរបស់អ្នកដោយចិត្ត (របស់តថាគត) ជ្រាបហើយថា នន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្ន ចូលដល់ហើយ ដូច្នេះ សូម្បីទេវតាក៏ប្រាប់សេចក្តីនេះដល់តថាគតថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទ ធ្វើឲ្យជាក់ច្បាស់នូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ ដែលរកអាសវៈមិនបាន ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងឯងក្នុងបច្ចុប្បន្ន ចូលដល់ហើយ" នន្ទ កាលណាចិត្តរបស់អ្នកផុតហើយចាកអាសវៈទាំងឡាយ ព្រោះមិនមានការប្រកាន់មាំ កាលនោះឯង តថាគតក៏ចាកការជានានោះ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនេះហើយ ទ្រង់បន្លឺឧទាននេះក្នុងវេលានោះថា

ភក់ គឺ កាមដែលបុគ្គលណាឆ្លងបានហើយ បន្លា គឺ កាម
ដែលបុគ្គលណាញាំញីបានហើយ បុគ្គលនោះ សម្រេចការ
អស់ទៅនៃមោហៈ រមែងមិនញាប់ញ័រព្រោះសុខ និងទុក្ខ ។

តមកថ្ងៃមួយ ភិក្ខុទាំងឡាយសួរព្រះនន្ទថា នន្ទមានអាយុ កាលមុន លោកពោលថា ខ្ញុំជាអ្នកអផ្សុកហើយ ឥឡូវនេះ ចិត្តរបស់លោកដូចម្តេច ។ ព្រះនន្ទឆ្លើយថា លោកមានអាយុ ការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថរបស់ខ្ញុំមិនមានឡើយ ។ ពួកភិក្ខុបានស្តាប់ពាក្យនោះហើយ ពោលថា ព្រះនន្ទនិយាយមិនពិត រមែងព្យាករណ៍អរហត្តផល ក្នុងថ្ងៃមុនៗ ពោលថា ខ្ញុំជាអ្នកអផ្សុកហើយ (តែ) ឥឡូវនេះពោលថា ការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថរបស់ខ្ញុំមិនមានទេ ដូច្នេះ បានទៅក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះ-ភាគ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃមុនៗ នោះ អត្តភាពរបស់នន្ទ ប្រាកដដូចជាផ្ទះដែលគេប្រក់មិនល្អ (តែ) ឥឡូវនេះ ដូចជាផ្ទះដែលគេប្រក់ល្អហើយ ព្រោះថា នន្ទនេះ តាំងពីខ្លួនបានឃើញស្រីទេពអប្សរហើយ ក៏ព្យាយាម ដើម្បីសម្រេចទីបំផុតនៃកិច្ចរបស់បព្វជិត បានសម្រេចកិច្ចនោះហើយ ទើបទ្រង់បានភាសិតព្រះគាថានេះថា ៈ-

យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

*ផ្ទះដែលប្រក់ខ្ជីខ្ជាយហើយ ដំណក់ទឹកភ្លៀង រមែងលិច*

*រហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុក*

*ហើយ រាគៈរមែងចាក់ធ្លុះបានយ៉ាងនោះឯង ។*

*យថា អគារំ សុច្ឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ*

*ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។*

*ផ្ទះដែលប្រក់ល្អហើយ ដំណក់ទឹកភ្លៀង រមែងមិនលិច*

*រហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អ*

*ហើយ រាគៈរមែងចាក់ធ្លុះមិនបាន យ៉ាងនោះឯង ។*

## អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា **អគារំ** (ផ្ទះ) គឺ ផ្ទះប្រភេទណាមួយ ។ បទថា **ទុច្ឆន្នំ** (ដែលប្រក់មិនល្អ) គឺ ដែលប្រក់រង្វើលៗ នៅមានចន្លោះប្រហោង ។ បទថា **សមតិវិជ្ឈតិ** (រមែងលិច) គឺ គ្រាប់ភ្លៀងរមែងលិចបាន ។ បទថា **អភាវិតំ** (ដែលមិនបានអប់រំ) ជាដើម សេចក្ដីថា រាគៈរមែងចាក់ធ្លុះចិត្ត ដែលឈ្មោះថា មិនបានអប់រំ ព្រោះជាធម្មជាតិឃ្លាត*

ឆ្ងាយពីភាវនា ប្រៀបដូចជាភ្លៀង (លិចស្រក់) ក្នុងផ្ទះនោះបាន ដូច្នោះ មិនមែនតែរាគៈតែប៉ុណ្ណោះទេ កិលេសទាំងអស់មានទោសៈ មោហៈ និង មានះជាអាទិ៍ ក៏ចាក់ដោតចិត្តបែបនោះដូចគ្នា ។

បទថា *សុភាវិតំ (ដែលអប់រំល្អហើយ)* បានដល់ ដែលអប់រំល្អ ហើយ ដោយសមថភាវនា និងវិបស្សនាភាវនា កិលេសទាំងឡាយមាន រាគៈជាដើម រមែងមិនអាចចាក់ដោតចិត្តបែបនោះបាន ប្រៀបដូចជាភ្លៀង មិនអាចស្រក់លិចផ្ទះ ដែលប្រក់ល្អហើយបាន ដូច្នោះ ។

ក្នុងកាលចប់គាថា ជនដ៏ច្រើនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ។ ទេសនាបានសម្រេចប្រយោជន៍ដល់ជនច្រើន ។

តមក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អាវុសោ ឈ្មោះ ថា ព្រះពុទ្ធទាំងឡាយជាអច្ឆរិយបុគ្គល ព្រះនន្ទ ឈ្មោះថាអាស្រ័យនាង ជនបទកល្យាណី ក៏អផ្សុកហើយ ត្រូវព្រះសាស្ដាធ្វើពួកនាងទេពអប្សរឲ្យជា អាមិស (នុយ) ណែនាំហើយ" ។ ព្រះសាស្ដាស្ដេចមក ត្រាស់សួរថា "ម្នាល ភិក្ខុទាំងឡាយ ពេលនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វី" ។ កាលភិក្ខុ

ទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទ្រង់បានត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ននូនេះតថាគតក៏បានបញ្ឆោតដោយមាតុគ្រាម ណែនាំហើយដូចគ្នា ។ កាលភិក្ខុទាំងនោះទូលអង្វរ ទើបទ្រង់នាំអតីតនិទាន ត្រាស់ថា ៈ-

## បុព្វកម្មរបស់ព្រះនន្ទ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងក្រុងពា-រាណសី មានឈ្មួញអ្នកក្រុងពារាណសី (ម្នាក់) ឈ្មោះថា កប្បកៈ ។ សត្វលារបស់គេមួយក្បាល នាំភារៈ (របស់) ទៅ បានមួយកុម្ភៈ វាដើរទៅបានក្នុងមួយថ្ងៃ ៧ យោជន៍ ។ សម័យមួយ គេទៅកាន់ក្រុងតក្កសិលា (ព្រម) ទាំងភារៈដែលនាំទៅដោយសត្វលា បណ្តោយលាឲ្យដើរទៅជរាបលក់ទំនិញអស់ ។ គ្រានោះ លារបស់គេនោះត្រាច់ទៅលើខ្នងប្រឡាយ បានឃើញមេលាមួយក្បាល ទើបចូលទៅរក ។ នាងលា កាលនឹងធ្វើបដិ-សណ្ឋារៈជាមួយលានោះ ទើបពោលថា "អ្នកមកអំពីណា" ។

លាឈ្មោល. មកអំពីក្រុងពារាណសី ។

មេឃា. អ្នកមកដោយកម្មអ្វី ។

ឃាណ្ហាល. ដោយកម្មរបស់ឈ្នួញ ។

មេឃា. អ្នកនាំការៈទៅបានប៉ុន្មាន ។

ឃាណ្ហាល. ការៈប្រមាណមួយកុម្ភៈ ។

មេឃា. អ្នកកាលនាំការៈប្រមាណប៉ុណ្ណោះទៅ ទៅបានប្រមាណយោជន៍ ។

ឃាណ្ហាល. បាន ៧ យោជន៍ ។

មេឃា. ក្នុងទីដែលអ្នកទៅ មានមេឃាណាខ្លះ ដែលជាអ្នកធ្វើការគក់ប្រេបាច់ជើង ឬថ្នាក់ថ្នមដល់អ្នក ។

ឃាណ្ហាល. មិនមានទេ នាងដ៏ចម្រើន ។

មេឃា. បើដូច្នោះ អ្នកគង់បានទទួលទុក្ខច្រើន ។

ពិតហើយ ដែលឈ្មោះថា អ្នកធ្វើកម្មមានការគក់ប្រេបាច់ជើងជាដើមសម្រាប់សត្វតិរច្ឆានទាំងឡាយ រមែងមិនមានដោយពិត តែមេឃាពោលពាក្យនោះដោយទាក់ទងដល់កាមសំយោជនៈ ។ ឃានោះ ក៏កើតសេចក្តី

រសោប់រសល់ដោយពាក្យរបស់មេលានោះឯង ។ ចំណែកកប្បកពាណិជ្ជ លក់កណ្ឌៈអស់ហើយ ទៅកាន់ទីដែលលាសម្រាក ពោលថា "មកចុះ បា! យើងនឹងទៅ" ។ លានោះតបថា "លោកចូរទៅចុះ ខ្ញុំមិនទៅទេ" ។ លំដាប់ នោះ កប្បកៈអង្វរលានោះហើយអង្វរទៀត រួចគិតថា "យើងនឹងញាំងលា នេះ ដែលមិនប្រាថ្នានឹងទៅ ឲ្យតក់ស្លុតហើយនឹងទៅឲ្យបាន" ដូច្នេះ ហើយ ពោលគាថានេះថា ៖

យើងនឹងធ្វើជន្លួញមានបន្លាស្រួចប្រវែង ១៦ ម្រាមដល់ឯង
យើងនឹងចាក់កាយរបស់ឯង នែលា អ្នកចូលដឹងយ៉ាងនេះ
ចុះ ។

លាបានស្តាប់ពាក្យនោះហើយ ពោលតបថា "បើដូច្នោះ ខ្ញុំនឹងដឹង កិច្ចដែលត្រូវធ្វើដល់លោក" ដូច្នេះ ទើបពោលគាថានេះថា ៖

លោកធ្វើជន្លួញមានបន្លាស្រួចប្រវែង ១៦ ម្រាមដល់ខ្ញុំ
ខ្ញុំនឹងទុបជ្រែងខាងមុខ ហើយលើកបំបះខាងក្រោយឡើង
ធ្វើកណ្ឌៈរបស់លោកឲ្យធ្លាក់ កប្បកៈ លោកចូរដឹងយ៉ាង

នេះ ៗ

ឈ្មួញបានស្តាប់ពាក្យនោះ ទើបត្រិះរិះថា "ព្រោះហេតុអ្វី ទើបលានេះ ពោលយ៉ាងនេះចំពោះយើង" ដូច្នេះ កាលក្រឡេកមើលជុំវិញៗ ក៏បានឃើញមេលានោះ ទើបគិតថា "លានេះគង់នឹងត្រូវមេលានោះដឹកនាំហើយ យើងនឹងលួងវាដោយមាតុគ្រាមថា "ខ្ញុំនឹងនាំមេលាមានរូបយ៉ាងនេះមកឲ្យអ្នក ហើយក៏នាំទៅ" ដូច្នេះ ទើបពោលគាថានេះថា ៖

យើងនឹងនាំមេលាក្មេង មានជើង ៤ មានមុខដូចស័ង្ខ

មានសព្វាង្គកាយស្អាត មកជាភរិយាអ្នក នែលាសំឡាញ់

អ្នកចូរដើរយ៉ាងនេះចុះ ៗ

លាបានស្តាប់ពាក្យនោះ មានចិត្តត្រេកអរ ពោលគាថានេះថា ៖

លោកនឹងនាំនាងលាក្មេង មានជើង ៤ មានមុខដូចសង្ខ

មានសព្វាង្គកាយស្អាត មកជាភរិយារបស់ខ្ញុំ បពិត្រកប្បកៈ

លោកចូរដើរយ៉ាងនេះ ខ្ញុំនឹងទៅដោយរហ័សរហូតដល់ ១៤

យោជន៍ កប្បកៈ ៗ

ពេលនោះ នាយកប្បកៈទើបពោលចំពោះលានោះថា "បើដូច្នោះ អ្នកចូរមកចុះ" ដូច្នេះ ហើយបានទាញទៅកាន់ទីរបស់ខ្លួន ។ ដោយការកន្លងទៅពីរបីថ្ងៃ លានោះទើបពោលចំពោះនាយកប្បកៈថា "លោកបាននិយាយចំពោះខ្ញុំថា នឹងនាំកិរិយាមកឲ្យខ្ញុំ ដូច្នេះ មិនមែនឬ" ។ នាយកប្បកៈឆ្លើយថា "អើ យើងពោលហើយ យើងនឹងមិនទម្លាយពាក្យរបស់ខ្លួនទេ នឹងនាំកិរិយាមកឲ្យអ្នក តែយើងឲ្យអាហារដល់អ្នកប៉ុណ្ណោះ អាហារនោះគ្រប់គ្រាន់ដល់អ្នក ដែលមានខ្លួនជាទីពីរ ឬមិនគ្រប់គ្រាន់ក៏ដោយ អ្នកគប្បីដឹងដោយខ្លួនឯងចុះ សូម្បីកូនទាំងឡាយ អាស្រ័យការរួមសង្វាសរបស់អ្នកទាំងពីរ ក៏នឹងកើតឡើង អាហារនោះគ្រប់គ្រាន់ដល់អ្នក និងកូនដ៏ច្រើនក្តី មិនគ្រប់គ្រាន់ក្តី អ្នកគប្បីដឹងដោយខ្លួនឯងចុះ" ។ កាលនាយកប្បកៈពោលដូច្នោះ លាក៏បានជាអ្នកអស់អាល័យហើយ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ញ៉ាំងជាតកឲ្យចប់ដោយព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មេលាក្នុងគ្រានោះបានមកជានាងជនបទកល្យាណី លាឈ្មោលបានមកជានន្ទ ឈ្មួញបានមក

*ជាតថាគតនោះឯង សូម្បីក្នុងកាលមុន ទន្ទ្រនេះ តថាគតក៏បានលួងដោយមាតុគ្រាមណែនាំហើយ ដោយប្រការដូច្នេះឯង" ។*

ចប់រឿងព្រះនន្ទត្ថេរៈ

# ១០. រឿងចុន្ទសូករិក

*ព្រះសាស្តាកាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរសឈ្មោះចុន្ទសូករិក ត្រាស់ព្រះធម្មទេសនានេះថា **ឥធ សោចតិ បេច្ច សោចតិ (រមែងសោកសៅក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១)** ជាដើម ។*

*បានឮថា នាយចុន្ទសូករិកនោះ សម្លាប់ជ្រូកទាំងឡាយបរិភោគខ្លះ លក់ខ្លះ ចិញ្ចឹមជីវិតអស់ ៥៥ ឆ្នាំ ។ ក្នុងវេលាស្រូវថ្លៃ គេដឹកស្រូវដោយរទេះទៅកាន់ជនបទ ដូរជាមួយកូនជ្រូកដោយស្រូវនោះប្រមាណ ១ នាឡិខ្លះ ២ នាឡិខ្លះ ដាក់ពេញរទេះហើយត្រឡប់មក ព័ទ្ធទីកន្លែងមួយដូចជាទ្រុងខាងក្រោយទីនៅ ហើយដាំបន្លែនៅក្នុងទីនោះឯងដើម្បីកូនជ្រូកទាំងនោះ កាលកូនជ្រូកទាំងនោះស៊ីបន្លែផ្សេងៗ រូបរាងក៏ធាត់ធំឡើង (គេ) មានបំណងនឹងសម្លាប់ជ្រូកមួយណា ក៏សម្លាប់ជ្រូកនោះ ក្នុងទីសម្លាប់ វាយដោយដំបង ៤ ជ្រុង ដើម្បីឲ្យសាច់ជ្រូករីកប៉ោងឡើង ដឹងថា សាច់រីកប៉ោងឡើងហើយ ក៏ទាញបើកមាត់ស៊កកំណាត់ឈើចូលទៅក្នុងចន្លោះធ្មេញ ចាក់ទឹកដ៏ក្តៅដាំពុះ ចូលទៅក្នុងមាត់ដោយនាឡិលោហៈ ទឹកក្តៅនោះចូល*

ទៅក្នុងពោះ នាំឧច្ចារៈចេញមកតាមទ្វារធំ ឧច្ចារៈតិចតួចនៅមានសល់ត្រឹមណា រមែងចេញមកដូចជាទឹកល្អក់ត្រឹមនោះ កាលពោះស្អាតហើយ ទើបចេញមកជាទឹកថ្លា ទើបចាក់ទឹកដែលនៅសល់ខាងលើខ្នងជ្រូកនោះ ទឹកនោះបាននាំយកស្បែកដែលខ្មៅៗ ចេញ ។ បន្ទាប់ពីនោះ ទើបរោលរោមដោយគប់ភ្លើងស្មៅ ហើយកាត់ក្បាលដោយកាំបិតដ៏មុត ត្រងឈាមដែលហូរចេញដោយភាជនៈ ប្រឡាក់សាច់នឹងឈាមចូលគ្នាចំអិន ហើយអង្គុយបរិភោគជាមួយបុត្រ និងភរិយា និងលក់ចំណែកដ៏សេស ។ កាលគេចិញ្ចឹមជីវិតដោយទំនងនោះឯង វេលាបានកន្លងទៅ ៥៥ ឆ្នាំ ។ កាលព្រះតថាគតប្រថាប់នៅក្នុងវិហារជិតៗ ទីនោះ ការបូជាដោយផ្កាឈើត្រឹមតែមួយក្តាប់ក្តី ការថ្វាយភិក្ខាត្រឹមតែមួយវែកក្តី ធ្វើបុណ្យដទៃតិចតួចក្តី ក៏មិនមានសូម្បីត្រឹមតែម្តង ។ គ្រានេះ រោគកើតឡើងក្នុងរាងកាយរបស់គេ ។ កំដៅក្នុងអវិចីមហានរកក៏ប្រាកដដល់គេទាំងដែលនៅរស់ ។ ដែលឈ្មោះថា សភាពក្តៅក្នុងអវិចី រមែងក្តៅរហូតទម្លាយគ្រាប់ភ្នែករបស់អ្នកឈរមើលក្នុងទីប្រមាណ ១០០ យោជន៍បាន ។ សមដូចព្រះមានព្រះភាគ

ត្រាស់ទុកដូច្នេះថា ៖

សភាពក្តៅក្នុងអវិចី ផ្សាយទៅរហូត ១០០ យោជន៍

ដោយជុំវិញ តាំងនៅគ្រប់កាល ។

ម្យ៉ាងទៀត ព្រោះហេតុកំដៅនោះក្នុងអវិចីនោះ មានប្រមាណក្រៃលែងជាងកំដៅរបស់ភ្លើងដោយប្រក្រតី ទើបព្រះនាគសេនត្ថេរ ពោលឧបមាទុកថា "មហាបពិត្រ សូម្បីថ្មប្រមាណប៉ុនផ្ទះកំពូល ដែលបុគ្គលបោះទៅក្នុងរណ្តៅនរក រមែងដល់នូវការរលាយមួយរំពេច យ៉ាងណា ចំណែកសត្វដែលកើតនៅក្នុងនរកនោះ ហាក់ដូចជានៅក្នុងគភ៌មាតា ព្រោះកម្លាំងនៃកម្មរមែងបែកធ្លាយទៅដូច្នោះ មិនបាន ។ កំដៅនោះ ប្រាកដដល់នាយចុន្ទ-សូករិកនោះហើយ អាការដែលសមគួរដល់កម្មក៏កើតឡើង ។ គេស្រែកមានសំឡេងដូចជ្រូក បម្រះនទៀលលូនក្នុងកណ្តាលផ្ទះនោះឯង ទៅកាន់ទិសខាងកើតខ្លះ ទៅកាន់ទិសខាងលិចខ្លះ ។ លំដាប់នោះ ពួកមនុស្សក្នុងផ្ទះរបស់គេ ចាប់គេទុកហើយបិទមាត់ ។ ធម្មតាផលនៃកម្មដែលនរណាៗមិនអាចនឹងហាមបាន ។ គេស្រែកយំម្តងទៅខាងនេះ ម្តងទៅខាងនោះ ។

មនុស្សនៅជុំវិញ ៧ ខ្នងផ្ទះ រមែងមិនអាចដេកលក់បាន ។ មួយទៀត មនុស្សនៅក្នុងផ្ទះទាំងអស់ កាលមិនអាចហាមការចេញទៅខាងក្រៅរបស់គេដែលត្រូវមរណភ័យគ្របសង្កត់បាន ទើបបិទទ្វារផ្ទះ នៅរក្សាខាងក្រៅផ្ទះ ដោយប្រការដែលគេនៅខាងក្នុង មិនអាចនឹងដើរទៅខាងក្រៅបាន ។ សូម្បីនាយចុន្ទសូករិកៈ ដើរស្រែកទៅខាងនេះខ្លះ ទៅខាងនោះខ្លះ ខាងក្នុងផ្ទះនោះឯង ព្រោះប្រសព្វការក្តៅដូចនៅក្នុងនរក ។ គេដើរទៅយ៉ាងនោះអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ក៏បានស្លាប់ទៅ ហើយកើតក្នុងអវិចីនរក ។ អវិចីនរកនោះ បណ្ឌិតគប្បីពណ៌នាតាមទេវទូតសូត្រចុះ ។ ពួកភិក្ខុដើរទៅតាមផ្លូវត្រង់ទ្វារផ្ទះរបស់គេ បានឮសំឡេងនោះហើយ ក៏មានការសម្គាល់ថា គេចិញ្ចឹមជ្រូក ទៅកាន់វិហារ អង្គុយក្នុងសំណាក់ព្រះសាស្តា ហើយក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន កាលជ្រូកទាំងឡាយដែលចុន្ទសូករិកៈបិទទ្វារផ្ទះសម្លាប់ ថ្ងៃនេះជាទីថ្ងៃទី ៧ មង្គលកិរិយាណា ៗ នឹងមានក្នុងផ្ទះរបស់គេ បពិត្រព្រះអង្គដ៏ចម្រើន មេត្តាចិត្ត ឬសេចក្តីករុណា សូម្បីត្រឹមតែម្យ៉ាងរបស់គេដែលជាអ្នកសម្លាប់ជ្រូកទាំងឡាយ មិនធ្លាប់មាន

ឡើយ" ។ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ គេសម្លាប់ជ្រូក ត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះក៏មិនមែន ដែលផលដ៏សមគួរដល់កម្មកើតឡើង ហើយដល់គេ សភាពក្ដៅក្នុងអវិចីមហានរករមែងប្រាកដដល់គេ ទាំងនៅ មានជីវិតនោះឯង ព្រោះសេចក្ដីក្ដៅនោះ គេក៏ស្រែកដូចជាជ្រូក ដើរចុះឡើង ខាងក្នុងនិវេសន៍អស់ ៧ ថ្ងៃហើយ ថ្ងៃនេះបានស្លាប់ ហើយទៅកើតក្នុង អវិចី" ។ កាលពួកភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន គេសោហ្មង យ៉ាងនេះក្នុងលោកនេះហើយ នៅទៅកើតក្នុងឋានៈដែលជាកន្លែងសោហ្មង ដូចគ្នាទៀតឬ" ។ ទ្រង់ត្រាស់ថា "យ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ដែល ឈ្មោះថា អ្នកប្រមាទហើយ ជាគ្រហស្ថក្ដី បព្វជិតក្ដី រមែងសោហ្មងក្នុង លោកទាំងពីរដោយពិត" ។ ហើយត្រាស់ព្រះគាថានេះ ៖

ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ សោចតិ
សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។

បុគ្គលអ្នកធ្វើបាប តែងសោកស្ដាយ ក្នុងលោកទាំងពីរ គឺ
សោកស្ដាយក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គល

*នោះ រមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើ*

*សៅហ្មងរបស់ខ្លួន ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា* ***បាបការី*** *(អ្នកធ្វើបាបជាប្រក្រតី) មានសេចក្តីថា បុគ្គលអ្នកធ្វើបាបមានប្រការផ្សេងៗ រមែងសោកសៅក្នុងលោកនេះ ក្នុងសម័យជិតស្លាប់ ក៏គិតតែម្យ៉ាងថា "កម្មល្អយើងមិនបានធ្វើទុក កម្មអាក្រក់យើងធ្វើទុកហើយ" នេះជាសេចក្តីសោកសៅព្រោះកម្មរបស់គេ ក៏កាលគេសោយផលហើយ ឈ្មោះថា ស្លាប់ទៅហើយ រមែងសោកសៅ នេះជាសេចក្តីសោកសៅ ព្រោះវិបាកក្នុងលោកខាងមុខរបស់គេ គេរមែងសោកសៅក្នុងលោកទាំងពីរយ៉ាងនេះឯង ។ ព្រោះហេតុនោះឯង សូម្បីនាយចុន្ទសូករិកៈនោះ ឈ្មោះថា រមែងសោកសៅទាំងមានជីវិតរស់នៅនៅឡើយ ។ បទថា* ***ទិស្វា កម្មកិលិដ្ឋមត្តនោ*** *(ឃើញកម្មសៅហ្មងរបស់ខ្លួន) សេចក្តីថា គេឃើញកម្មសៅហ្មងរបស់ខ្លួនហើយ រមែងសោកសៅត្អូញត្អែរ រៀបរាប់ដោយប្រការផ្សេង ៗ ឈ្មោះថា រមែងក្តៅក្រហាយ គឺ*

រមែងលំបាក ។

ក្នុងកាលចប់ព្រះគាថា ភិក្ខុដ៏ច្រើនបានសម្រេចជាសោតាបន្នជាដើម ហើយ ព្រះទេសនាមានប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះឯង ។

ចប់រឿងចន្ទសូករិកៈ

# ១១ រឿងធម្មិកឧបាសក

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធម្មិកឧបាសក ត្រាស់ព្រះគាថានេះថា **ឥធ មោទតិ បេច្ច មោទតិ (រមែងរីករាយក្នុងលោកនេះ រមែងរីករាយក្នុងលោកខាងមុខ)** ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី មានឧបាសកអ្នកបដិបត្តិធម៌ប្រមាណ ៥០០ នាក់ ។ បណ្ដាឧបាសកទាំងនោះ ម្នាក់ៗ មានឧបាសកជាបរិវារ ៥០០ នាក់ ។ ឧបាសកជាប្រធាននៃឧបាសកទាំងនោះមានបុត្រ ៧ នាក់ ធីតា ៧ នាក់ ។ បណ្ដាបុត្រ និងធីតាទាំងនោះ ។ ម្នាក់ៗ មានសលាកយាគូ សលាកភត្ត បក្ខិកភត្ត សង្ឃភត្ត ឧបោសថិកភត្ត អាគន្តុកភត្ត វស្សាវាសិកភត្ត ដូចគ្នា ។ ជនសូម្បីទាំងនោះ ក៏បានឈ្មោះថា អនុជាតបុត្រ ដូចគ្នាទាំងអស់ ។ (ដែលថា) សលាកយាគូជាដើម ១៦ គឺ របស់បុត្រ ១៤ នាក់ របស់ភរិយាមួយ របស់ឧបាសកមួយ រមែងប្រព្រឹត្តទៅដោយប្រការដូច្នេះ ។ គេព្រមទាំងបុត្រ និងភរិយា ក៏ជាអ្នកមានសីល មានកល្យាណធម៌ មានសេចក្ដីត្រេកអរក្នុងការចែកទាន ដោយប្រការដូច្នេះ ។

តមកក្នុងសម័យមួយ រោគកើតឡើងដល់គេ ។ អាយុសង្ខារវិនាសដោយជុំវិញហើយ គេប្រាថ្នានឹងស្តាប់ធម៌ ទើបបញ្ជូន (មនុស្ស) ទៅកាន់សម្នាក់ព្រះសាស្តា ដោយក្រាបទូលថា "សូមព្រះអង្គអនុគ្រោះបញ្ជូនភិក្ខុ ៨ រូប ឬ ១៦ រូប ប្រោសដល់ខ្ញុំព្រះអង្គផង" ។ ព្រះសាស្តាទ្រង់បញ្ជូនភិក្ខុទៅ ។ ភិក្ខុទាំងនោះទៅហើយ គង់លើអាសនៈដែលតាក់តែងទុក ជុំវិញគ្រែរបស់គេ ឧបាសកពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ការឃើញលោកម្ចាស់ទាំងឡាយ របស់ខ្ញុំព្រះករុណាបានដោយលំបាក ព្រោះខ្ញុំព្រះករុណាជាអ្នកទុព្វល សូមលោកម្ចាស់ទាំងឡាយមេត្តាស្វាធ្យាយព្រះសូត្រណាមួយប្រោសខ្ញុំព្រះករុណាផង" ។ ភិក្ខុទាំងឡាយទើបសួរថា "លោកបំណងនឹងស្តាប់សូត្រណា ឧបាសក" ។ គេពោលថា "សតិប្បដ្ឋានសូត្រ" ដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់មិនលះបង់" ។ ទើបផ្តើមសូត្រព្រះសូត្រថា "**ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា**" ជាដើម (ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ) ។ ខណៈនោះ រថ ៦ គ្រឿង ប្រដាប់ដោយអលង្ការគ្រប់យ៉ាង ទឹមដោយសេះសិន្ធពមួយ

ពាន់ ទំហំប្រមាណ ១៥០ យោជន៍ មកអំពីទេវលោក ៦ ជាន់ ។ ទេវតាឈរនៅលើរថទាំងនោះ ក៏ពោលថា "ខ្ញុំនឹងនាំទៅកាន់ទេវលោករបស់ខ្ញុំ ខ្ញុំនឹងនាំទៅកាន់ទេវលោករបស់ខ្ញុំ លោកដ៏ចម្រើន សូមកើតក្នុងទីនេះៗ ដើម្បីសេចក្តីរីករាយក្នុងទេវលោករបស់ខ្ញុំ ដូចបុគ្គលទម្លាយភាជនៈដី ហើយកាន់យកភាជនៈមាស" ។ ឧបាសកមិនប្រាថ្នានឹងឲ្យសេចក្តីអន្តរាយដល់ការស្តាប់ធម៌ ទើបពោលថា "លោកទាំងឡាយ ចូររង់ចាំសិន ចូររង់ចាំសិន" ។ ភិក្ខុទាំងឡាយក៏ឈប់ ដោយយល់ថា "ឧបាសកនិយាយជាមួយពួកយើង" ។ លំដាប់នោះ បុត្រ និងធីតារបស់គេគិតថា "បិតារបស់ពួកយើង ពីមុនជាអ្នកមិនឆ្អែតដោយការស្តាប់ធម៌ តែឥឡូវនេះ ឲ្យនិមន្តភិក្ខុមកស្វាធ្យាយ ហើយហាមដោយខ្លួនឯង ឈ្មោះថា សត្វដែលមិនខ្លាចចំពោះមរណៈមិនមាន" ដូច្នេះ ហើយក៏យំ" ។ ពួកភិក្ខុប្រឹក្សាគ្នាថា "ឥឡូវនេះ មិនមែនជាឱកាសទេ" ទើបក្រោកចាកអាសនៈចៀសចេញទៅ ។ ឧបាសកញ៉ាំងវេលាតិចតួចឲ្យកន្លងទៅ ត្រឡប់បានសតិ សួរកូនៗ ថា "ព្រោះហេតុអ្វីពួកកូនទើបយំ" ។ ពួកបុត្រទើបពោលថា "ពុក ពុកឲ្យនិមន្តភិក្ខុមកហើយ

ស្តាប់ធម៌ ស្រាប់តែហាមដោយខ្លួនឯង ដូច្នោះ ពួកខ្ញុំទើបគិតថា ឈ្មោះថាសត្វដែលមិនខ្លាចចំពោះមរណៈ រមែងមិនមាន ដូច្នេះ ទើបនាំគ្នាយំ" ។

ឧបាសក. លោកម្ចាស់ទាំងឡាយ ទៅណាហើយ ។

បុត្រ. ពុក លោកម្ចាស់ទាំងឡាយ លោកនិយាយគ្នាថា "មិនមែនជាឱកាស" ក៏ក្រោកចាកអាសនៈចេញទៅហើយ ។

ឧបាសក. ពុកមិនបាននិយាយនឹងលោកម្ចាស់ទេ ។

បុត្រ. បើដូច្នោះ ពុកនិយាយជាមួយនរណា ។

ឧបាសក. ទេវតាប្រដាប់រថ ៦ គ្រឿង នាំមកអំពីទេវលោក ៦ ជាន់ស្ថិតក្នុងអាកាស ហើយបន្លឺសំឡេងថា "សូមលោកចូរត្រេកអរក្នុងទេវលោករបស់ខ្ញុំ សូមលោកចូរត្រេកអរក្នុងទេវលោករបស់ខ្ញុំ ពុកនិយាយនឹងទេវតាទាំងនោះឯង ។

បុត្រ. ពុក រថនៅទីណា ពួកខ្ញុំមិនឃើញ ។

ឧបាសក. តើកម្រងផ្កាដើម្បីពុកមានទេ ។

បុត្រ. មាន ពុក ។

ឧបាសក. ទេវលោកជាន់ណា គួរជាទីមនោរម្យ ។

បុត្រ. តុសិតពិភព ដែលជាទីប្រថាប់នៅរបស់ព្រះពោធិសត្វគ្រប់ព្រះអង្គ របស់ព្រះពុទ្ធមាតា និងព្រះពុទ្ធបិតា ជាទីមនោរម្យ ពុក ។

ឧបាសក. បើដូច្នោះ ពួកកូនចូរពោលថា សូមកម្រងផ្កាចូរជាប់ត្រង់រថដែលមកអំពីស្ថានតុសិត ដូច្នេះ ហើយបោះកម្រងផ្កាទៅចុះ ។

បុត្រទាំងនោះបានបោះទៅហើយ ។ កម្រងផ្កានោះបានព្យួរជាប់ត្រង់នឹមនៃរថ ក្នុងអាកាស ។ មហាជនឃើញតែកម្រងផ្កានោះ មិនឃើញរថ ។ ឧបាសកនិយាយថា "អ្នកទាំងឡាយឃើញកម្រងផ្កានោះទេ" កាលបុត្រឆ្លើយថា "ឃើញ" ទើបពោលថា "កម្រងផ្កានេះព្យួរត្រង់រថដែលមកអំពីតុសិត យើងនឹងទៅកាន់ស្ថានតុសិត ពួកអ្នកកុំទុក្ខសោកឡើយ បើពួកអ្នកមានសេចក្តីប្រាថ្នាទៅកាន់សំណាក់របស់យើង ក៏ចូរធ្វើបុណ្យទាំងឡាយតាមទំនងដែលយើងធ្វើហើយចុះ" ដូច្នេះ ហើយធ្វើកាលកិរិយា តាំងនៅលើរថដែលមកពីស្ថានតុសិត ។ អត្តភាពរបស់គេខ្ពស់ប្រមាណ ៣ គាវុត ប្រដាប់ដោយអលង្ការ មានទម្ងន់ប្រមាណ ៦០ រទេះ កើតនៅក្នុងទីនោះ

ឯងមួយរំពេច មានស្រីទេពអប្សរមួយពាន់ហែហមហើយ វិមានកែវប្រមាណ ២៥ យោជន៍ប្រាកដហើយ ។ ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះ ដែលមកដល់វិហារហើយដោយលំដាប់ថា "ម្នាលភិក្ខុទាំងឡាយ ឧបាសកបានស្តាប់ទេសនាហើយឬ ។

ភិក្ខុ. ស្តាប់ហើយព្រះអង្គ តែឧបាសក បានហាមនៅក្នុងចន្លោះនោះថា "សូមលោករង់ចាំសិន" លំដាប់នោះ បុត្រ និងធីតារបស់ឧបាសកទាំងនោះ ក៏នាំគ្នាយំ ពួកខ្ញុំព្រះអង្គប្រឹក្សាគ្នាថា ឥឡូវនេះមិនមែនជាឱកាសទើបក្រោកចាកអាសនៈចេញមក ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ឧបាសកនោះមិនបានពោលចំពោះពួកអ្នកទេ ក៏ទេវតាប្រដាប់ដោយរថ ៦ គ្រឿង នាំមកពីទេវលោក ៦ ជាន់អញ្ជើញឧបាសកនោះ ឯឧបាសកនោះមិនប្រាថ្នានឹងធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌ ទើបពោលចំពោះទេវតាទាំងនោះ ។

ភិក្ខុ. យ៉ាងនោះឬ ព្រះអង្គ ។

ព្រះសាស្តា. យ៉ាងនោះឯង ភិក្ខុទាំងឡាយ ។

ភិក្ខុ. ឥឡូវនេះ គេកើតហើយក្នុងទីណា ព្រះអង្គ ។

ព្រះសាស្តា. ក្នុងភពតុសិតហើយ ភិក្ខុទាំងឡាយ ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកនោះ រីករាយហើយក្នុងកណ្តាលញាតិក្នុងលោកនេះហើយ ក៏កើតក្នុងឋានៈដែលជាទីរីករាយនោះទៀតឬ ។

ព្រះសាស្តាត្រាស់ថា "យ៉ាងនោះហើយ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលមិនប្រមាទទាំងឡាយ សូម្បីគ្រហស្ថក្តី ជាបព្វជិតក្តី រមែងរីករាយក្នុងទីទាំងពួងតែម្យ៉ាង" ដូច្នេះ ទើបត្រាស់គាថានេះថា ៖-

ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើដ៏បរិសុទ្ធរបស់ខ្លួន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កតបុញ្ញោ** (អ្នកធ្វើបុណ្យទុកហើយ) ជាដើម សេចក្ដីថា បុគ្គលអ្នកធ្វើកុសលមានប្រការផ្សេងៗ រមែងរីករាយ ដោយសេចក្ដីរីករាយ ព្រោះកម្មក្នុងលោកនេះថា "កម្មអាក្រក់យើងមិនបានធ្វើឡើយ កម្មល្អយើងបានធ្វើហើយ" ស្លាប់ទៅ រមែងរីករាយដោយសេចក្ដីរីករាយព្រោះវិបាក ឈ្មោះថា រមែងរីករាយក្នុងលោកទាំងពីរ យ៉ាងនេះ ។ បទថា **កម្មវិសុទ្ធឹ** (សេចក្ដីបរិសុទ្ធនៃកម្ម) ជាដើម សេចក្ដីថា សុម្បីធម្មិកឧបាសកឃើញកម្មដែលបរិសុទ្ធ គឺ ការដល់ព្រមនៃបុញ្ញកម្មរបស់ខ្លួនមុននឹងស្លាប់ រមែងរីករាយក្នុងលោកនេះ ស្លាប់ហើយក៏រមែងរីករាយ គឺ រមែងរីករាយដោយពិតសូម្បីក្នុងលោកខាងមុខ ។

ក្នុងកាលចប់គាថា ជនដ៏ច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ព្រះធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់រឿងធម្មិកឧបាសក

# ១២. រឿងព្រះទេវទត្ត

*ព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតពន ទ្រង់ប្រារព្ធព្រះទេវទត្ត ត្រាស់ព្រះធម្មទេសនានេះថា **ឥធ តប្បតិ បេច្ច តប្បតិ** (ក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១) ជាដើម ។*

*រឿងព្រះទេវទត្ត ព្រះសាស្តាត្រាស់ជាតកទាំងអស់ ដែលទ្រង់ប្រារព្ធព្រះទេវទត្តឲ្យពិស្តារ តាំងពីវេលាបួសរហូតដល់ផែនដីស្រូប ។ ក៏សេចក្តីសង្ខេបនៅក្នុងរឿងព្រះទេវទត្តនេះ មានដូចតទៅនេះ ៖*

*កាលព្រះសាស្តាទ្រង់អាស្រ័យនិគមឈ្មោះអនុបិយៈ នៃមល្លក្សត្រិយ៍ប្រថាប់នៅក្នុងអនុបិយអម្ពវ័ននោះឯង ក្នុងថ្ងៃទទួលព្រះលក្ខណៈនៃព្រះ-តថាគតនោះ ត្រកូលព្រះញាតិប្រាំបីម៉ឺនប្រគល់ព្រះឱរសប្រាំបីម៉ឺនឲ្យ ដោយពាក្យថា "សិទ្ធត្ថកុមារ ជាព្រះរាជាក្តី ជាព្រះពុទ្ធក្តី នឹងមានក្សត្រិយ៍ជាបរិវារត្រោចទៅ" ។ កាលព្រះឱរសទាំងនោះបួសហើយដោយច្រើន ពួកញាតិឃើញសក្យៈ ៦ ព្រះអង្គនេះ គឺ ភទ្ទិយរាជា អនុរុទ្ធៈ អានន្ទៈ ភគុ កិម្ពិលៈ ទេវទត្ត នៅមិនទាន់បានបួស ទើបសន្ទនាគ្នាថា "ពួកយើងនឹងឲ្យ*

កូនៗ របស់ខ្លួនបួស សក្យៈទាំង ៦ នេះ ប្រហែលជាមិនមែនព្រះញាតិទេដឹង ព្រោះដូច្នោះ ទើបទ្រង់មិនបួស" ។ គ្រានោះ មហានាមសក្យៈចូលទៅរកព្រះអនុរុទ្ធ ត្រាស់ថា "ប្អូន! អ្នកចេញបួសអំពីត្រកូលរបស់យើងនៅមិនទាន់មាន ប្អូននឹងបួស ឬថា បងនឹងបួស" ។ ព្រះអនុរុទ្ធកុមារនោះជាក្សត្រីយ៍សុខុមាល មានភោគៈបរិបូណ៌ សូម្បីពាក្យថា "មិនមាន" ក៏ព្រះអង្គមិនធ្លាប់បានឮ ។ ពិតហើយ ថ្ងៃមួយកាលក្សត្រីយ៍ ៦ ព្រះអង្គនោះ ទ្រង់លេងកីឡាកូនខ្លុប (លេងឃ្លី) ព្រះអនុរុទ្ធទ្រង់បរាជ័យដោយនំហើយបញ្ជូន (មនុស្ស) ទៅដើម្បីត្រូវការនំ ។ គ្រានោះ ព្រះមាតារបស់ទ្រង់ចាត់ចែងនំបញ្ជូនទៅឲ្យ ។ ក្សត្រីយ៍ទាំង ៦ សោយហើយ ក៏ទ្រង់លេងតទៅទៀត ។ ព្រះអនុរុទ្ធនោះឯងជាអ្នកចាញ់ ។ ចំណែកព្រះមាតា ទ្រង់បញ្ជូនមនុស្សឲ្យនាំនំទៅអស់ ៣ ដង ក្នុងវារៈទី ៤ បញ្ជូនទៅថា "នំមិនមាន" ។ ព្រះកុមារទ្រង់សម្គាល់ថា "នំសូម្បីនេះនឹងជានំមួយប្រភេទ" (នំមិនមាន) ព្រោះមិនធ្លាប់ទ្រង់បានឮពាក្យថា "មិនមាន" ។ ទើបបញ្ជូនមនុស្សទៅថា "ចូរនាំនំមិនមាននោះឯងមកចុះ" ។ ចំណែកព្រះមាតារបស់

លោក កាលគេទូលថា "បពិត្រព្រះនាងម្ចាស់ សូមព្រះនាងម្ចាស់ចូរប្រទាននំមិនមាន" ទើបទ្រង់ព្រះតម្រិះថា "កូនរបស់យើង មិនធ្លាប់បានឮពាក្យថា មិនមាន តែយើងនឹងឲ្យដឹងសេចក្តីនោះដោយឧបាយនេះ" ទើបទ្រង់បិទថាសមាសទទេ ដោយថាសមាសដទៃ ហើយបញ្ជូនទៅ ។ ពួកទេវតាដែលរក្សាព្រះនគរគិតថា "ព្រះអនុរុទ្ធសក្យៈបានថ្វាយកត្តដែលជាចំណែកខ្លួនដល់ព្រះបច្ចេកពុទ្ធនាមថា ឧបរិដ្ឋៈ ក្នុងកាលដែលខ្លួនជានាយអន្នភារៈ ទ្រង់ធ្វើសេចក្តីប្រាថ្នាទុកថា សូមកុំឲ្យខ្ញុំបានឮពាក្យថា មិនមាន កុំឲ្យស្គាល់ទីកើតនៃភោជនៈ ប្រសិនបើ ព្រះអនុរុទ្ធនេះទ្រង់នឹងឃើញថាសទទេរសោត ពួកយើងក៏នឹងមិនបានចូលទៅកាន់ទេវសមាគម ទាំងសីសៈរបស់ពួកយើងក៏នឹងគប្បីបែកជា ៧ ភាគ" ។ ពេលនោះ ទើបបានធ្វើថាសនោះឲ្យពេញដោយនំទិព្វ ល្មមពេលគេដាក់ថាសនោះចុះត្រង់កន្លែងលេងល្បែងហើយ បើកឡើង ក្លិននំក៏ផ្សាយត្រឡប់ទៅទូទាំងព្រះនគរ ។ ដុំនំល្មមក្សត្រីយ៍ទាំង ៦ ចាប់ដាក់ចូលក្នុងព្រះឱស្ឋប៉ុណ្ណោះ ក៏ផ្សព្វផ្សាយទូទាំងបសាទដែលទទួលរសទាំង ៧.០០០ ។ ព្រះកុមារនោះទ្រង់ត្រិះរិះថា "យើងមិនជាទីស្រឡាញ់

របស់ព្រះមាតាឬ បានជាព្រះមាតា ទ្រង់មិនរៀបចំនំឈ្មោះមិនមាននេះប្រទាន ដល់យើងអស់កាលវេលាប៉ុណ្ណេះ ចាប់ពីពេលនេះទៅ យើងនឹងមិនបរិ-ភោគនំដទៃ" ដូច្នេះ ហើយស្ដេចទៅកាន់ព្រះដំណាក់ ទូលសួរព្រះមាតាថា ម៉ែ ខ្ញុំជាទីស្រឡាញ់របស់ម៉ែ ឬមិនមែនជាទីស្រឡាញ់ ។

មាតា. កូន កូនជាទីស្រឡាញ់ក្រៃលែងរបស់ម៉ែ ដូចភ្នែករបស់មនុស្សតែម្ខាង និងដូចជាបេះដូង (របស់ម៉ែ) ដូច្នោះ ។

អនុរុទ្ធ. បើដូច្នោះ ហេតុអ្វី ម៉ែទើបមិនចាត់ចែងនំមិនមាន ប្រទានដល់កូន រហូតអស់វេលាប៉ុណ្ណេះ ។

ព្រះនាងត្រាស់សួរព្រះកុមារដែលជិតស្និទថា "នំអ្វីៗ មាននៅក្នុងថាសឬ កូន" គេទូលថា "បពិត្រអ្នកម៉ែ ថាសពេញព្រៀបដោយនំ ឈ្មោះថា នំបែបនេះ ខ្ញុំព្រះអង្គក៏មិនធ្លាប់ឃើញ" ។ ព្រះនាងទ្រង់ព្រះតម្រិះថា "បុត្ររបស់យើងជាអ្នកមានបុណ្យ មានអភិនិហារបានធ្វើទុកហើយ ទេវតាទាំងឡាយប្រាកដជាដាក់នំពេញថាសទើបបញ្ជូនទៅ" ។ លំដាប់នោះ ព្រះឱរស ទើបទូលព្រះមាតាថា "មាតា តាំងអំពីនេះទៅ ខ្ញុំព្រះអង្គមិនសោយនំដទៃ

សូមមាតាតាក់តែងតែទំមិនមានតែម៉្យាង" ។ តាំងអំពីនោះមក កាលព្រះកុមារនោះទូលថា "ខ្ញុំព្រះអង្គត្រូវការសោយទំ" សូម្បីព្រះនាងក៏ទ្រង់គ្របថាសទទេនោះឯងដោយថាសដទៃ បញ្ជូនទៅឲ្យព្រះកុមារនោះ ។ ទេវតាទាំងឡាយដាក់នំទិព្វថ្វាយព្រះកុមារនោះរហូត ក្នុងវេលាដែលលោកនៅជាឃរាវាស ។

ព្រះកុមារនោះ កាលទ្រង់មិនជ្រាបសូម្បីពាក្យមានប្រមាណប៉ុណ្ណេះ នឹងទ្រង់ជ្រាបដល់ការបួសបានដូចម្ដេច ព្រោះដូច្នោះ ព្រះកុមារទើបទូលសួរថាព្រះភាតាថា "ការបួសនេះដូចម្ដេច" កាលព្រះមហានាមត្រាស់ថា "អ្នកបួស ត្រូវកោរសក់ និងពុកមាត់ ត្រូវស្លៀកដណ្ដប់សំពត់កាសាយៈ ត្រូវដេកលើគម្រាលដោយឈើ ឬលើគ្រែដែលក្រងដោយផ្ដៅ ដើរបិណ្ឌបាតនេះឈ្មោះថា ការបួស" ទើបទូលថា "ម្ចាស់បង ខ្ញុំជាសុខុមាលជាតិ ខ្ញុំមិនអាចបួសបានទេ" ។ ព្រះមហានាមត្រាស់ថា "ប្អូន បើដូច្នោះ ប្អូនចូលរៀនការងាររបស់ឃរាវាសចុះ" ។ ក៏ក្នុងយើងទាំងពីរ បើមិនបួសនរណាម្នាក់ មិនសមគួរឡើយ ។ ខណៈនោះ អនុរុទ្ធកុមារ ទូលសួរម្ចាស់បងថា

ឈ្មោះថា "ការងារនេះយ៉ាងណា" កុលបុត្រអ្នកមិនដឹងសូម្បីស្ថានទីកើតនៃភត្ត នឹងដឹងការងារបានដូចម្តេច ។ ក៏ថ្ងៃមួយ ការសន្ទនាកើតឡើងដល់ក្សត្រិយ៍ ៣ អង្គថា "ឈ្មោះថា ភត្តកើតឡើងពីទីណា" កិម្ពិលកុមារទូលថា "កើតឡើងក្នុងជង្រុកស្រូវ" ។ គ្រានោះ ភទ្ទិយកុមារត្រាស់ជំទាស់កិម្ពិលកុមារនោះថា "លោកមិនជ្រាបការកើតឡើងនៃភត្តទេ ឈ្មោះថា ភត្តរមែងកើតឡើងត្រង់ឆ្នាំងបាយ" ។ អនុរុទ្ធត្រាស់ជំទាស់ថា "លោកទាំងពីរក៏នៅមិនទ្រង់ជ្រាប ធម្មតា ភត្តរមែងកើតឡើងក្នុងថាសមាសប្រមាណមួយហត្ថក្តាប់" ។ បានឮថា បណ្តាក្សត្រ ៣ ព្រះអង្គនោះ ថ្ងៃមួយ កិម្ពិល-កុមារទ្រង់ឃើញគេដឹកស្រូវចេញពីជង្រុក ទ្រង់យល់ថា "ស្រូវទាំងនេះកើតឡើងហើយក្នុងជង្រុកនោះឯង" ។ ចំណែកព្រះភទ្ទិយកុមារ ថ្ងៃមួយ ទ្រង់ឃើញគេដួសភត្តចេញអំពីឆ្នាំងបាយ ក៏យល់ថា "ភត្តនេះកើតឡើងក្នុងឆ្នាំងបាយនោះឯង" ។ ចំណែកអនុរុទ្ធកុមារ ទ្រង់មិនធ្លាប់ឃើញអ្នកបុកស្រូវ អ្នកដាំបាយ ឬអ្នកដួសបាយ ទ្រង់ឃើញ តែបាយដែលគេដួសហើយតាំងទុកចំពោះព្រះភក្ត្រប៉ុណ្ណោះ ។ ទ្រង់ទើបយល់ថា "ភត្តកើតក្នុងថាស ក្នុង

វេលាដែលត្រូវការបរិភោគ" ។ ក្សត្រទាំង ៣ ព្រះអង្គនោះ ទ្រង់មិនជ្រាបសូម្បីទីកើតនៃកត្ត ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ អនុរុទ្ធកុមារនេះ ទើបទូលសួរថា ឈ្មោះថា "ការងារនេះដូចម្តេច" ។ លុះទ្រង់បានស្តាប់កិច្ចការដែលយកវាសនឹងគប្បីធ្វើជាប្រចាំក្នុងឆ្នាំ មានជាអាទិ៍ថា ជាដំបូងត្រូវឲ្យភ្ជួរស្រែ ទើបត្រាស់ថា "កាលណា ទីបំផុតនៃការងារទាំងឡាយទើបនឹងប្រាកដ កាលណា ខ្ញុំព្រះអង្គនឹងមានសេចក្តីខ្វល់ខ្វាយតិច ហើយប្រើប្រាសភោគៈបានហ្ន៎" កាលព្រះមហានាមត្រាស់ប្រាប់ការមិនមានទីបំផុតនៃការងារទាំងឡាយហើយ ក៏បានទូលថា "បើដូច្នោះ សូមម្ចាស់បងទ្រង់គ្រប់គ្រងយកវាសចុះ ខ្ញុំមិនត្រូវការដោយយកវាសទេ" ដូច្នេះ ទើបចូលគាល់ព្រះមាតា ក្រាបទូលថា "ព្រះមាតា សូមព្រះមាតាអនុញ្ញាតខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងបួស" កាលព្រះនាងទ្រង់ហាមដល់ ២ ដង ហើយត្រាស់ថា "បើព្រះភទ្ទិយៈ សំឡាញ់របស់កូនបួស កូនចូលបួសជាមួយព្រះអង្គចុះ" ទើបចូលទៅជួបព្រះភទ្ទិយៈនោះ ត្រាស់ថា "សំឡាញ់ ការបួសរបស់ខ្ញុំជាប់ដោយព្រះអង្គ ។ ហើយបានញ៉ាំងភទ្ទិយៈនោះឲ្យទ្រង់ត្រេកអរដោយ

ប្រការផ្សេងៗ ក្នុងថ្ងៃទី ៧ ទ្រង់ទទួលប្ដេជ្ញាដើម្បីប្រយោជន៍នឹងបួសជាមួយព្រះអង្គ ។

តពីនោះ ក្សត្រទាំងប្រាំមួយអង្គនេះ គឺ ភទ្ទិយសក្យរាជ អនុរុទ្ធ អានន្ទ ភគុ កិម្ពិលៈ និងទេវទត្ត គម្រប់ ៧ ទាំងឧបាលីនាយភូសាមាលា ទ្រង់សោយមហាសម្បត្តិអស់ ៧ ថ្ងៃ ដូចទេវតាសោយទិព្វសម្បត្តិ ហើយស្ដេចចេញទៅដោយចតុរង្គិនីសេនា ហាក់ដូចជាស្ដេចទៅកាន់ឧទ្យាន ដល់ព្រំដែនក្សត្រអង្គដទៃ ទ្រង់បញ្ជូនកងទ័ពទាំងអស់ឲ្យត្រឡប់ ដោយព្រះរាជ-អាជ្ញា ហើយស្ដេចចូលកាន់ដែនក្សត្រដទៃ ។ ក្នុង ៧ នាក់នោះ ក្សត្រ ៦ ព្រះអង្គ ទ្រង់ដោះអាភរណៈរៀងៗ ខ្លួន វិចជាបង្វិច ហើយត្រាស់បង្គាប់ថា "នែ៎ឧបាលី សូមអ្នកត្រឡប់ទៅវិញចុះ ទ្រព្យទាំងនេះ ល្មមចិញ្ចឹមជីវិតរបស់អ្នកបាន" ហើយទ្រង់ក៏ប្រទានដល់គេ ។ ឧបាលីយំខ្សឹកខ្សួលក្រាបជិតព្រះបាទរបស់ក្សត្រទាំង ៦ អង្គនោះ កាលមិនអាចកន្លងអាជ្ញារបស់ក្សត្រទាំងនោះ ទើបក្រោកឡើង កាន់បង្វិចនោះត្រឡប់ទៅ ។ ក្នុងកាលនៃជនទាំងនោះបែកគ្នាជា ២ ពួក ព្រៃក៏ហាក់ដូចជាដល់នូវការយំ ផែនដី

ហាក់ដូចជាមានអាការញាប់ញ័រ ។ ចំណែកឧបាលីនាយកូសាមាលាទៅបាន បន្តិចក៏ត្រឡប់វិញ គិតយ៉ាងនេះថា "ពួកសក្យៈនឹងប្រទូសជាមួយយើង ហើយគប្បីសម្លាប់យើង ដោយទ្រង់យល់ថា "កុមារទាំងឡាយមុខជាត្រូវមនុស្សនេះផ្តាច់ព្រះជន្មហើយ" ដូច្នេះក៏បាន ព្រោះធម្មតាថា សក្យៈទាំងនោះ ទ្រង់លះបង់សម្បត្តិបែបនេះ លះបង់អាភរណៈដែលមិនអាចកាត់ថ្លៃបានទាំងនេះចេញ ដូចស្តោះទឹកមាត់ចោល ហើយបួស ចាំបាច់ពោលថ្វីដល់យើង" លុះគិត (ដូច្នេះ) ទើបស្រាយបង្វិចចេញ យកអាភរណៈទាំងនោះព្យួរទុកលើដើមឈើ ហើយពោលថា "អ្នកមានសេចក្តីត្រូវការទាំងឡាយ ចូរកាន់យកចុះ" ហើយទៅកាន់សំណាក់របស់សក្យកុមារទាំងនោះ ត្រូវសក្យកុមារទាំងនោះសួរថា "អ្នកត្រឡប់មកធ្វើអ្វី" ក៏ក្រាបទូលសេចក្តីនោះ ។ លំដាប់នោះ សក្យកុមារទាំងនោះ ទ្រង់នាំគេទៅកាន់សំណាក់របស់ព្រះសាស្តា ថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ឈ្មោះថា ជាពួកសក្យៈ មានការប្រកាន់ខ្លួនជាប្រចាំ (សន្ដាន) បុគ្គលនេះជាអ្នកបម្រើរបស់ពួកខ្ញុំព្រះអង្គអស់

រាត្រីយូរ សូមព្រះអង្គប្រោសឲ្យបុគ្គលនេះបួសមុន ខ្ញុំព្រះអង្គទាំងឡាយនឹងធ្វើសាមីចិកម្ម មានការអភិវាទជាដើមដល់គេ ការប្រកាន់ខ្លួនរបស់ខ្ញុំព្រះអង្គនឹងអស់ទៅដោយអាការយ៉ាងនេះ" ហើយឲ្យឧបាលីនោះបួសមុន ក្រោយមកទើបទ្រង់បួស ។ បណ្ដាសក្យៈភិក្ខុ ៦ រូបនោះ ព្រះភទ្ទិយៈបានជាព្រះអរហន្តតេវិជ្ជា[១] ក្នុងចន្លោះវស្សានោះឯង ។ ព្រះអនុរុទ្ធជាអ្នកមានទិព្វចក្ខុ ក្រោយមកលោកស្ដាប់មហាបុរិសវិតក្កសូត្រ ក៏បានសម្រេចជាព្រះអរហន្ត ។ ព្រះអានន្ទ បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះភគុនិងព្រះកិម្ពិលៈ ក្រោយមកចម្រើនវិបស្សនាសម្រេចក៏បានជាព្រះអរហន្ត ។ ព្រះទេវទត្តសម្រេចឫទ្ធិដែលជារបស់បុថុជ្ជន ។

ក្នុងកាលតមក កាលព្រះសាស្ដាប្រថាប់នៅក្នុងក្រុងកោសម្ពី លាភនិងសក្ការៈដ៏ច្រើន កើតឡើងដល់ព្រះតថាគតព្រមទាំងព្រះសង្ឃសាវ័ក ។ មនុស្សទាំងឡាយក្នុងក្រុងកោសម្ពីនោះ យកសំពត់ និងភេសជ្ជៈជាដើមចូលទៅកាន់វិហារ ហើយសួរគ្នាថា "ព្រះសាស្ដាប្រថាប់នៅក្នុងទីណា ព្រះ

---

១. វិជ្ជា ៣ គឺ បុព្វេនិវាសានុស្សតិញ្ញាណ ១ ចុតូបបាតញ្ញាណ ១ អាសវក្ខយញ្ញាណ ១ ។

សារីបុត្រនៅក្នុងទីណា ព្រះមហាមោគ្គល្លាននៅក្នុងទីណា ព្រះមហាកស្សបៈនៅក្នុងទីណា ព្រះភទ្ទិយៈនៅទីណា ព្រះអនុរុទ្ធនៅទីណា ព្រះអានន្ទនៅទីណា ព្រះភគុនៅទីណា ព្រះកិម្ពិលៈនៅទីណា ហើយដើរមើលទីអង្គុយនៃព្រះអសីតិមហាសាវ័ក ។ មានអ្នកសួរថា "ព្រះទេវទត្តគង់ ឬឈរទីណា ដូច្នេះ មិនមាន" ។ ព្រះទេវទត្ត ទើបគិតថា យើងបួសជាមួយសក្យៈទាំងនេះដូចគ្នា សូម្បីសក្យៈទាំងនេះ ជាខត្តិយបព្វជិត សូម្បីយើងក៏ជាខត្តិយបព្វជិត ពួកមនុស្សនាំលាភ និងសក្ការៈស្វែងរកលោកទាំងនេះ អ្នកដែលសួរដល់ឈ្មោះរបស់យើងមិនមាន យើងនឹងសេពគប់ជាមួយនរណាហ្ន៎ គប្បីញុំាងនរណាឲ្យជ្រះថ្លា ហើយញុំាងលាភ និងសក្ការៈឲ្យកើតឡើងដល់យើងបាន ។ ពេលនោះ សេចក្តីសម្រេចចិត្តកើតមានដល់លោកថា ព្រះបាទពិម្ពិសារនេះព្រមទាំងបរិវារ ១១ នហុត ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ ដោយការឃើញជាលើកដំបូងនោះឯង យើងមិនអាចសេពគប់ជាមួយព្រះរាជានោះបានឡើយ សូម្បីជាមួយព្រះបាទកោសល យើងក៏មិនអាចនឹងសេពគប់បាន ចំណែកព្រះបាទអជាសត្រូវកុមារ ជាព្រះឱរសរបស់

ព្រះរាជា (ព្រះបាទពិម្ពិសារ) នេះឯង មិនទាន់ដឹងគុណ និងទោសរបស់នរណាៗ យើងនឹងសេពគប់ជាមួយព្រះកុមារនោះ ។ ព្រះទេវទត្ត ចេញពីក្រុងកោសម្ពីទៅកាន់ក្រុងរាជគ្រឹះ និម្មិតភេទជាកុមារតូច រុំអសិរពិស ៤ ក្បាល ត្រង់ដៃ និងជើងទាំងបួន និងរុំត្រង់ក រុំធ្វើជាមកុដលើសីសៈ ធ្វើជាខ្សែចៀងស្មា (សង្វារ) ចុះពីអាកាស ដោយសង្វារពស់នេះ អង្គុយលើភ្លៅរបស់អជាសត្រូវកុមារ កាលព្រះកុមារនោះទ្រង់ភ័យខ្លាចហើយ ត្រាស់ថា "លោកជានរណា" ទើបថ្វាយព្រះពរថា អាត្មា គឺ "ទេវទត្ត" ដើម្បីនឹងបន្ទោបង់សេចក្តីភ័យខ្លាចរបស់ព្រះកុមារ ក៏ត្រឡប់អត្តភាពនោះវិញ ជាភិក្ខុទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរ ឈរនៅខាងមុខ ញ៉ាំងព្រះកុមារនោះឲ្យជ្រះថ្លា ហើយញ៉ាំងលាភ និងសក្ការៈឲ្យកើតឡើង ។

## ព្រះទេវទត្តព្យាយាមសម្លាប់ព្រះពុទ្ធ

ព្រះទេវទត្តនោះ ត្រូវលាភ និងសក្ការៈគ្របសង្កត់ហើយ ក៏ញ៉ាំងការគិតដ៏លាមកឲ្យកើតឡើងថា "យើងនឹងគ្រប់គ្រងភិក្ខុសង្ឃ" ដូច្នេះ ទើបវិនាសចាកឫទ្ធិព្រមដោយចិត្តុប្បាទនោះ ថ្វាយបង្គំព្រះសាស្តា ដែលទ្រង់

កំពុងសំដែងធម៌ដល់បរិស័ទព្រមទាំងព្រះរាជាក្នុងព្រះវេឡុវ័នវិហារ ក្រោកចាកអាសនៈហើយ ផ្គងអញ្ជលីក្រាបទូលថា "បពិត្រព្រះអង្គ វេលានេះព្រះមានព្រះភាគទ្រង់ជរាដល់វ័យចាស់ហើយ សូមព្រះមានព្រះភាគទ្រង់ជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិច ប្រកបរឿយៗ នូវធម៌ជាគ្រឿងនៅសប្បាយក្នុងទិដ្ឋធម៌ចុះ ខ្ញុំព្រះអង្គនឹងរក្សាភិក្ខុសង្ឃ សូមព្រះអង្គប្រោសប្រគល់ភិក្ខុ-សង្ឃដល់ខ្ញុំព្រះអង្គចុះ" ដូច្នេះ ត្រូវព្រះសាស្ដាទ្រង់រារាំងដោយខេឡាសិ-កវាទ[១] ទ្រង់ហាមហើយ លោកមិនពេញចិត្ត បានចងអាឃាតនេះក្នុងព្រះតថាគតជាលើកដំបូង ហើយចៀសចេញទៅ ។ គ្រានោះព្រះមានព្រះភាគត្រាស់ឲ្យធ្វើបកាសនីយកម្ម[២] ក្នុងក្រុងរាជគ្រឹះដល់លោក ។ លោកគិតថា "ឥឡូវនេះយើងត្រូវព្រះសមណគោតមកម្ចាត់ចេញហើយ យើងនឹងធ្វើសេចក្ដីវិនាសដល់ព្រះសមណគោតមនោះ" ដូច្នេះ ទើបទៅគាល់ព្រះបាទអជាសត្រូវកុមារ ទូលថា "ព្រះកុមារ កាលមុនមនុស្សទាំងឡាយមានអាយុវែង ឥឡូវនេះមានអាយុខ្លី ឯព្រះអង្គគប្បីចូលទិវង្គតតាំងពីព្រះរាជកុមារ

---

១. ដោយអត្ថថា អ្នកបរិភោគបច្ច័យដូចទឹកមាត់ ។ ២. កម្មដែលសង្ឃគួរប្រកាស ។

នោះជាឋានៈរបស់ព្រះរាជកុមារ បើដូច្នោះ ព្រះអង្គគួរសម្រេចទោសព្រះបិតា ហើយតាំងជាព្រះរាជាចុះ អាត្មាសម្រេចទោសព្រះមានព្រះភាគហើយនឹងធ្វើជាព្រះពុទ្ធ" កាលព្រះកុមារនោះតាំងនៅក្នុងរាជសម្បត្តិហើយ បានតែងតាំងបុរសទាំងឡាយដើម្បីសម្លាប់ព្រះតថាគត លុះបុរសទាំងនោះសម្រេចសោតាបត្តិផលត្រឡប់ទៅហើយ គេទើបបានឡើងភ្នំគិជ្ឈកូដដោយខ្លួនឯងប្រមៀលថ្ម ដោយតាំងចិត្តថា "យើងនឹងផ្តាច់ព្រះជន្មព្រះសមណគោតម" បានធ្វើកម្ម គឺ ញុំាងព្រះលោហិតឲ្យពុរពងឡើង កាលមិនអាចសម្លាប់ដោយឧបាយសូម្បីនេះ ទើបឲ្យលែងដំរីនាឡាគិរីទៀត ។ កាលដំរីនោះកំពុងដើរមក ព្រះអានន្ទត្ថេរព្រមលះបង់ជីវិតរបស់ខ្លួន ថ្វាយព្រះសាស្តាបានឈរឃាំងអំពីខាងមុខ ។ ព្រះសាស្តាទ្រង់ទូន្មានដំរីហើយ ស្តេចចេញចាកព្រះនគរមកកាន់វិហារ សោយមហាទាន ដែលពួកឧបាសកឧបាសិកាច្រើនពាន់នាំមកហើយ ទ្រង់សំដែងអនុបុព្វិកថាប្រោសអ្នកក្រុងរាជគ្រិះរាប់បាន ១៨ កោដិ ដែលប្រជុំគ្នាក្នុងថ្ងៃនោះ ។ ធម្មាភិសម័យ កើតមានដល់សត្វ ៨៤.០០០ នាក់ ។ ព្រះមានព្រះភាគទ្រង់ស្តាប់កថាពណ៌នាគុណរបស់

ព្រះថេរៈថា "អស្ចារ្យណាស់ហ្ន៎ ព្រះអានន្ទមានគុណច្រើន កាលស្តេចដំរីនោះមកហើយ ហ៊ានលះបង់ជីវិតរបស់ខ្លួនឈរឃាំងអំពីខាងមុខព្រះសាស្តា" ដូច្នេះ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន អានន្ទនេះ ក៏ហ៊ានលះបង់ជីវិតដើម្បីប្រយោជន៍ដល់តថាគតដូចគ្នា" កាលភិក្ខុទាំងឡាយក្រាបទូលអង្វរហើយ ទើបត្រាស់ចុល្លហង្សជាតក មហាហង្សជាតក និងកក្កដកជាតក ។

កម្មសូម្បីរបស់ទេវទត្ត ព្រោះញុំាងព្រះអជាសត្រូវកុមារឲ្យសម្រេចទោសរបស់ព្រះរាជា (សម្លាប់ព្រះបិតា) ចេញក្តី ព្រោះតែងតាំងនាយខ្មាន់ធ្នូក្តី ព្រោះប្រមៀលថ្មក្តី មិនបានប្រាកដដូចការបញ្ជូនដំរីនាឡាគិរីឡើយ ។ គ្រានោះឯង មហាជនបានប្រជុំគ្នាឡើងថា "សូម្បីព្រះរាជា ក៏ព្រះទេវទត្តនោះឯង ជាអ្នកឲ្យសម្រេចទោសហើយ សូម្បីនាយខ្មាន់ធ្នូក៏ព្រោះព្រះទេវទត្តនោះតែងតាំងឡើង សូម្បីសិលាក៏ព្រះទេវទត្តប្រមៀលចុះដូចគ្នា និងឥឡូវនេះ លោកបានឲ្យលែងដំរីនាឡាគិរី ព្រះរាជាទ្រង់សេពគប់មនុស្សលាមកបែបនេះ" ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់មហាជនហើយ ទើបឲ្យ

នាំសម្រាប់ ៥០០ រទេះមក ស្តេចមិនបានទៅកាន់ទីឧបដ្ឋាករបស់ព្រះទេវទត្ត នោះទៀតទេ ។ ពួកអ្នកនគរក៏មិនបានថ្វាយសូម្បីវត្ថុត្រឹមតែភិក្ខាដល់លោក ដែលចូលទៅកាន់ត្រកូល ។ ព្រះទេវទត្តនោះវិនាសចាកលាភ និងសក្ការៈ ហើយ ប្រាថ្នានឹងផ្តាច់ជីវិតដោយការកុហក ទើបចូលទៅគាល់ព្រះសាស្តា ទូលសូមវត្ថុ ៥ ប្រការ ដែលព្រះមានព្រះភាគទ្រង់ហាមថា "កុំឡើយ ទេវទត្ត អ្នកណាប្រាថ្នា អ្នកនោះក៏ចុះនៅព្រៃចុះ" ដូច្នេះ ហើយពោលថា "អ្នកមានអាយុពាក្យរបស់នរណានឹងត្រឹមត្រូវ របស់ព្រះតថាគត ឬរបស់ខ្ញុំ ក៏ខ្ញុំពោលដោយអំណាចវត្តបដិបត្តិដ៏ឧក្រិដ្ឋយ៉ាងនេះថា បពិត្រព្រះអង្គ សូមព្រះអង្គប្រទានឱកាស សូមភិក្ខុទាំងឡាយចូរអ្នកនៅព្រៃ ត្រាច់បិណ្ឌបាតជាវត្ត ទ្រទ្រង់សំពត់បង្សុកូល នៅក្រោមគល់ឈើ កុំគប្បីឆាន់ត្រី និងសាច់អស់មួយជីវិត ។ អ្នកណាប្រាថ្នានឹងរួចផុតចាកទុក្ខ អ្នកនោះចូលមកជាមួយយើង" ដូច្នេះ ហើយក៏ចៀសចេញទៅ ។ ភិក្ខុពួកខ្លះបួសថ្មី មានការដឹងតិចតួច បានស្តាប់ពាក្យរបស់ព្រះទេវទត្តនោះហើយ បបួលគ្នាថា "ព្រះទេវទត្តនិយាយត្រូវ" ពួកយើងនឹងទៅជាមួយព្រះទេវទត្តនោះ ។

ដូច្នេះ ហើយក៏បានសមាគមជាមួយលោក ។ ព្រះទេវទត្តនោះ ព្រមដោយភិក្ខុ ៥០០ រូប ញ៉ាំងជនអ្នកជ្រះថ្លាក្នុងរបស់សៅហ្មង ឲ្យព្រមទទួលដោយវត្ថុ ៥ ប្រការនោះ ដើរសូម (បច្ច័យ) ក្នុងត្រកូលមកបរិភោគ ព្យាយាមដើម្បីបំបែកសង្ឃហើយ ។ លោកដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា "ទេវទត្ត បានឮថា អ្នកព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីទម្លាយចក្រពិតមែនឬ" ។ ទូលថា "ពិតមែន ព្រះមានព្រះភាគ" សូម្បីព្រះអង្គទ្រង់ឲ្យឱវាទដោយព្រះពុទ្ធវចនៈមានជាអាទិ៍ថា "ទេវទត្ត ការបំបែកសង្ឃ មានទោសច្រើន" ក៏មិនជឿ មិនកាន់យកព្រះវាចារបស់ព្រះសាស្តា ហើយគេចចេញទៅ ជួបព្រះអានន្ទដែលកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទើបពោលថា "អានន្ទដ៏មានអាយុ តាំងពីថ្ងៃនេះទៅជាដើម ខ្ញុំនឹងធ្វើឧបោសថនិងធ្វើសង្ឃកម្ម វៀរចាកព្រះមានព្រះភាគ វៀរចាកភិក្ខុសង្ឃ" ។ ព្រះថេរៈទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់ជ្រាបសេចក្តីនោះហើយ ទ្រង់កើតធម្មសង្វេគ ទ្រង់បរិវិតក្កៈថា "ទេវទត្តធ្វើកម្មជាហេតុឲ្យខ្លួនឆេះក្នុងអវិចី ដែលទាក់ទងដល់សេចក្តីវិនាសដល់សត្វលោកទាំងទេវ-

លោក ដូច្នេះ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖-

កម្មទាំងឡាយដែលមិនល្អ និងមិនជាប្រយោជន៍ដល់ខ្លួន
ធ្វើបានងាយ កម្មឯណាជាប្រយោជន៍ផង ល្អផង កម្មនោះ
ឯង ធ្វើបានលំបាកក្រៃលែង ។

ទ្រង់បន្លឺព្រះឧទាននេះទៀតថា ៖-

កម្មល្អមនុស្សល្អធ្វើបានដោយងាយ កម្មល្អមនុស្សអាក្រក់
ធ្វើបានដោយលំបាក កម្មអាក្រក់ មនុស្សអាក្រក់ធ្វើបាន
ដោយងាយ កម្មអាក្រក់ព្រះអរិយទាំងឡាយធ្វើបានលំបាក ។

គ្រានោះឯង ព្រះទេវទត្តគង់នៅក្នុងទីដ៏សមគួរមួយព្រមដោយបរិស័ទរបស់ខ្លួន ក្នុងថ្ងៃឧបោសថ ពោលថា "វត្ថុ ៥ ប្រការទាំងនេះ រមែងពេញចិត្តដល់អ្នកណា អ្នកនោះចូរចាប់ស្លាក" កាលពួកភិក្ខុវជ្ជីបុត្រ ៥០០ រូប អ្នកបួសថ្មី នៅមិនទាន់ដឹងធម៌វិន័យដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទូទៅ ក៏នាំគ្នាចាប់ស្លាក ក៏បានបំបែកសង្ឃហើយ បាននាំភិក្ខុទាំងនោះទៅកាន់គយាសីសៈប្រទេស ។ ព្រះសាស្តាទ្រង់ស្តាប់ការដែលទេវទត្តនោះទៅ

ទីនោះហើយ ទើបទ្រង់បញ្ជូនព្រះអគ្គសាវកទាំងពីរទៅដើម្បីប្រយោជន៍នាំភិក្ខុទាំងនោះមកវិញ ។ ព្រះអគ្គសាវកទាំងពីរទៅកាន់ទីនោះហើយ ពោលទូន្មានដោយពាក្យទូន្មានដែលជាអាទេសនាបាដិហារ្យ និងឥទ្ធិបាដិហារ្យ ញុំាងភិក្ខុទាំងនោះឲ្យផឹកអមតធម៌ហើយ បាននាំមកតាមផ្លូវអាកាស ។ ចំណែកព្រះកោកាលិកៈពោលថា "ទេវទត្តដ៏មានអាយុ ក្រោកឡើង ព្រះសារីបុត្រ និងព្រះមោគ្គល្លាន នាំយកភិក្ខុទាំងនេះទៅអស់ហើយ ខ្ញុំប្រាប់លោកហើយមិនមែនឬថា អ្នកមានអាយុ លោកកុំទុកចិត្តព្រះសារីបុត្រ និងព្រះមោគ្គ-ល្លាន (ព្រោះ) ព្រះសារីបុត្រ និងព្រះមោគ្គល្លានមានសេចក្តីប្រាថ្នាលាមកលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក" ដូច្នេះ ហើយយកជង្គង់បុកត្រង់ដើមទ្រូង (ព្រះទេវទត្ត) ។ លោហិតក្តៅៗ បានផុលចេញអំពីមាត់របស់ព្រះទេវទត្តក្នុងទីនោះឯង ។

## បុព្វកម្មរបស់ព្រះទេវទត្ត

ចំណែកពួកភិក្ខុ ឃើញព្រះសារីបុត្រមានភិក្ខុសង្ឃហែហមមកតាមផ្លូវអាកាសហើយ បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្រ

ក្នុងវេលាទៅមានខ្លួនជាគម្រប់ ២ ប៉ុណ្ណោះ ឥឡូវនេះ មានបរិវារជាច្រើន មកជាមួយ អស្ចារ្យហ្ន៎" ។ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន កាលលោកកើតក្នុងកំណើតសត្វតិរច្ឆាន បុត្ររបស់យើង មកកាន់សំណាក់របស់យើង ក៏រមែងអស្ចារ្យដូចគ្នា" ដូច្នេះ ហើយបានត្រាស់ជាតកនេះថា ៖-

សេចក្ដីចម្រើន រមែងមានដល់អ្នកមានសីលទាំងឡាយ
អ្នកប្រព្រឹត្តបដិសណ្ឋារៈ អ្នកចូរមើលម្រឹគឈ្មោះលក្ខណៈ
ដែលពួកញាតិហែហមមកហើយ អ្នកចូរមើលម្រឹគឈ្មោះ
កាលៈនេះ ដែលវិនាសចាកញាតិទាំងឡាយ ។

ដូច្នេះជាដើម កាលពួកភិក្ខុក្រាបទូលទៀតថា "បពិត្រព្រះអង្គដ៏ចម្រើន បានជ្រាបថា ព្រះទេវទត្តឲ្យអគ្គសាវក ២ អង្គនោះ គង់សងខាង ហើយពោលថា យើងនឹងសំដែងធម៌ដោយពុទ្ធលីលា ធ្វើកិរិយាតាមព្រះអង្គ" ។ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តនេះក៏ព្យាយាមធ្វើត្រាប់តាមតថាគតដែរ តែមិន

អាច" ដូច្នេះ ទើបបានត្រាស់នទីចរកាកជាតក ថា ៖-

អើ វីរកៈ អ្នករមែងឃើញបក្សីឈ្មោះសវិដ្ឋកៈ ដែលស្រែក

យំមានសំឡេងពីរោះ មានសម្រេង.កដូចជាសត្វក្ងោក ដែល

ជាស្វាមីរបស់ខ្ញុំទេ បក្សីសវិដ្ឋកៈ ធ្វើត្រាប់តាមបក្សីដែល

ត្រាច់ទៅបានទាំងក្នុងទឹក និងលើគោក ស៊ីត្រីស្រស់ជានិច្ច

នោះ ត្រូវសារាយព័ន្ធស្លាប់ហើយ ។

ដូច្នេះជាដើម សូម្បីក្នុងថ្ងៃដទៃៗ ទៀត ទ្រង់ប្រារព្ធកថានោះដូចគ្នា ត្រាស់

ជាតកទាំងឡាយជាដើមយ៉ាងនេះថា ៖-

សត្វត្រសេះនេះ កាលទឹងចោះនូវដើមឈើទាំងឡាយ បាន

ត្រាច់ទៅហើយហ្ន៎ ត្រង់ដើមឈើដែលមានមែកជាឈើងាប់

មិនមានខ្លឹម ក្រោយមកត្រាច់ទៅដល់ដើមឈើដែលមានខ្លឹម

ហើយ ក៏បានទម្លាយនូវក្បាលហើយ ។

និងថា

ខួរក្បាលរបស់អ្នកធ្លាយចេញផង អំបែងក្បាលរបស់អ្នក ដែល

ដំរីជាន់ហើយ គ្រោងឆ្អឹងគ្រប់ចំណែករបស់អ្នកដែលដំរី

កាច់បំបាក់ហើយ គ្រានេះអ្នកនៅមានមុខស្រស់អ្វីទៀត

សំឡាញ់ ។

ទ្រង់ប្រារព្ធកថាថា "ទេវទត្តជាបុគ្គលអកតញ្ញូ" ទើបត្រាស់ជាតក

ទាំងឡាយមានជាអាទិ៍ទៀតថា :-

ខ្ញុំបានធ្វើកិច្ចឲ្យដល់អ្នករហូតអស់កម្លាំងរបស់ខ្ញុំដែលមាន

ហើយ បពិត្រមិគរាជ ខ្ញុំសូមនមស្ការចំពោះលោក តើខ្ញុំ

នឹងបានអ្វីៗ ខ្លះទេ ។ ប្រការដែលអ្នកនៅក្នុងចន្លោះនៃ

ធ្មេញរបស់យើង ដែលមានលោហិតជាកក្បា ធ្វើកម្មដ៏

អាក្រក់ជានិច្ច ក៏នៅជាអ្នករស់បាន នេះជាលាភរបស់

អ្នកហើយ ។

ទ្រង់ប្រារព្ធការគោងឡើង ដើម្បីនឹងសម្លាប់ (ព្រះអង្គ) របស់ព្រះទេវទត្ត

នោះទៀត ក៏ត្រាស់ជាតកទាំងឡាយជាដើមថា :-

ម្នាលដើមចំបក់ ប្រការដែលអ្នកជម្រុះផ្លែមកនេះ យើង

ដឹងហើយ យើងនឹងទៅនៅដើមចំបក់ដទៃ ព្រោះថា ផ្លែ

របស់អ្នក យើងមិនពេញចិត្ត ។

កថានៅប្រព្រឹត្តទៅទៀតថា "ព្រះទេវទត្តវិនាសចាកផល ២ ប្រការ គឺ ចាកលាភ និងសក្ការៈប្រការមួយ ចាកសាមញ្ញផលប្រការមួយ" ព្រះមាន-ព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏វិនាសហើយដូចគ្នា" ដូច្នេះ ទើបទ្រង់ត្រាស់ជាតកទាំងឡាយថា ៈ-

ភ្នែកទាំងពីរបែកហើយ សំពត់ក៏វិនាសហើយ ទាំងមិត្រ

អ្នកស្រុកក៏ទាស់ទែងគ្នា ប្តី និងព្រះពន្ធទាំងពីរនោះ មាន

ការងារវិនាសហើយទាំងពីរផ្លូវ គឺ ទាំងផ្លូវទឹក ទាំងផ្លូវ

គោក ។

ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ទ្រង់ប្រារព្ធព្រះទេវទត្ត ត្រាស់ជាតកដ៏ច្រើនដោយប្រការយ៉ាងនេះហើយ ស្តេចយាង (ចេញ) ចាកក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថី ប្រថាប់នៅក្នុងព្រះជេតពនមហាវិហារ ។

## ព្រះទេវទត្តឱ្យសាវ័កនាំទៅគាល់ព្រះសាស្ដា

ចំណែកព្រះទេវទត្តនោះឯង មានជំងឺអស់ ៩ ខែ ក្នុងគ្រាចុងក្រោយប្រាថ្នានឹងគាល់ព្រះសាស្ដា ទើបប្រាប់ពួកសាវ័ករបស់ខ្លួនថា "យើងប្រាថ្នានឹងទៅគាល់ព្រះសាស្ដា អ្នកទាំងឡាយចូរសំដែងព្រះសាស្ដាដល់យើងចុះ" ។ កាលសាវ័កទាំងនោះឆ្លើយថា "លោកម្ចាស់ក្នុងពេលដែលអាច លោកម្ចាស់បានប្រព្រឹត្តជាអ្នកមានពៀរជាមួយព្រះសាស្ដា ខ្ញុំទាំងឡាយនាំលោកម្ចាស់ទៅក្នុងទីដែលព្រះសាស្ដាប្រថាប់មិនបានទេ" ព្រះទេវទត្តក៏ពោលថា "អ្នកទាំងឡាយកុំឲ្យខ្ញុំវិនាសឡើយ ខ្ញុំចងអាឃាតក្នុងព្រះសាស្ដា (ក៏ពិត) តែចំពោះព្រះសាស្ដាមិនមានអាឃាតនឹងខ្ញុំឡើយ សូម្បីត្រឹមតែចុងសក់" ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ៖-

ទ្រង់មានព្រះទ័យស្មើក្នុងបុគ្គលទូទៅ គឺ ក្នុងនាយខ្មាន់ធ្នូ
ក្នុងព្រះទេវទត្ត ក្នុងចោរអង្គុលិមាល ក្នុងដំរីធនបាល និង
ក្នុងព្រះរាហុល ។

ព្រោះដូច្នោះ ព្រះទេវទត្តទើបអង្វរហើយអង្វរទៀតថា "សូមអ្នកទាំងឡាយ

ចូរសម្តែងព្រះមានព្រះភាគដល់ខ្ញុំ” ។ ពេលនោះ សាវ័កទាំងនោះទើបនាំព្រះទេវទត្តចេញទៅដោយគ្រែស្នែងតូច ។ ភិក្ខុទាំងឡាយ បានឮដំណឹងការមករបស់ព្រះទេវទត្តនោះ ទើបក្រាបទូលព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន ឮដំណឹងថា ព្រះទេវទត្តមកដើម្បីត្រូវការនឹងគាល់ព្រះអង្គ” ។ ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនបានឃើញតថាគតដោយអត្តភាពនេះ” ។ ន័យថា ព្រះទេវទត្ត រមែងមិនបានឃើញព្រះពុទ្ធទៀត ផ្តើមតាំងពីកាលដែលសូមវត្ថុ ៥ ប្រការម្ល៉េះ ។ ពួកភិក្ខុក្រាបទូលថា “ព្រះទេវទត្តមកដល់ទីនោះ និងទីនោះហើយ ព្រះអង្គ” ។

ព្រះសាស្តា. ទេវទត្តចូរធ្វើវត្ថុដែលខ្លួនប្រាថ្នាចុះ (តែយ៉ាងណា) គេក៏នឹងមិនបានឃើញតថាគត ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ព្រះទេវទត្តមកដល់ទីប្រមាណមួយយោជន៍អំពីទីនេះហើយ (និងទូលតៗ ទៅទៀតថា) មកដល់កន្លះយោជន៍ហើយ មួយគាវុតហើយ មកដល់ទីជិតស្រះបោក្ខរណីហើយ ព្រះអង្គ ។

ព្រះសាស្តា. សូម្បីទេវទត្តនឹងចូលមកខាងក្នុងព្រះជេតពន ក៏មិន

បានឃើញតថាគតដែរ ។

ពួកសាវកនាំព្រះទេវទត្តមក ដាក់គ្រែស្នែងចុះត្រង់មាត់ស្រះបោក្ខរណី ជិតវត្តជេតពនហើយ ក៏ចុះទៅដើម្បីងូតទឹកក្នុងស្រះបោក្ខរណី ។ សូម្បីព្រះទេវទត្តនោះឯង ក៏ក្រោកចាកគ្រែហើយអង្គុយដាក់ជើងទាំងពីរលើផែនដី ជើងទាំងពីរនោះក៏លិចចុះក្នុងផែនដី ។ លោកបានលិចចុះក្នុងផែនដីដោយលំដាប់ ត្រឹមកជើង ត្រឹមក្លៅ ត្រឹមចង្កេះ ត្រឹមដោះរហូតដល់ក ក្នុងវេលាដែលឆ្អឹងចង្កាដល់ផែនដី បានពោលគាថានេះថា ៖-

ខ្ញុំព្រះអង្គសូមដល់ព្រះពុទ្ធអង្គនោះ ព្រះអង្គជាបុគ្គល
ដ៏ប្រសើរ ជាទេវតាក្រៃលែងជាទេវតា ជាសារថីហ្វឹក
ហាត់នរជន មានព្រះចក្ខុដោយជុំវិញ មានព្រះលក្ខណៈ
តែមួយកើតពីបុណ្យទាំងរយ ថាជាទីពឹង ព្រមដោយ
ឆ្អឹងទាំងនេះ និងខ្យល់ដង្ហើមចេញចូល ។

ន័យថា ព្រះតថាគតទ្រង់ឃើញឋានៈនេះឯង ទើបទ្រង់ព្រះមេត្តាឲ្យព្រះទេវទត្តបួស ។ ប្រសិនបើព្រះទេវទត្តនោះ មិនបានបួសទេ ហើយនៅ

ជាគ្រហស្ថ នឹងបានធ្វើកម្មធ្ងន់ (ច្រើនជាងនេះ) នឹងមិនអាចធ្វើបច្ច័យនៃការអស់កពបាន លុះបួសហើយ សូម្បីធ្វើកម្មធ្ងន់ក៏ពិត តែនឹងអាចធ្វើបច្ច័យនៃការអស់កពបាន ព្រោះដូច្នោះ ព្រះសាស្តាទើបអនុញ្ញាតឲ្យលោកបួសហើយ ។ ពិតហើយ ព្រះទេវទត្តនោះ នឹងជាព្រះបច្ចេកពុទ្ធមាននាមថា **អដ្ឋិស្សរៈ** ក្នុងទីបំផុតនៃសែនកប្បអំពីកប្បនេះ ។ ព្រះទេវទត្តនោះលិចចុះក្នុងដីហើយកើតក្នុងអវិចី លោកជាអ្នកកម្រើកមិនបាន ត្រូវភ្លើងឆេះ ព្រោះជាអ្នកធ្វើខុសក្នុងព្រះពុទ្ធដែលទ្រង់មិនញាប់ញ័រ ។ សរីរៈរបស់លោកមានកម្ពស់ប្រមាណ ១០០ យោជន៍ កើតក្នុងរណ្តៅអវិចី ដែលមានប្រមាណ ៣០០ យោជន៍ សីសៈកប់ចូលទៅកាន់ផែនដែកក្នុងខាងលើរហូតដល់គុម្ពត្រចៀក ។ ជើងទាំងពីរលិចចុះក្នុងផែនដែកចុះទៅខាងក្រោមរហូតដល់កជើង លំពែងដែកមានប្រមាណប៉ុនដើមត្នោតធំ ចេញអំពីជញ្ជាំងខាងក្រោយចាក់ទម្លុះខ្នងធ្លាយមកខាងទ្រូង ដោតជាប់ជញ្ជាំងខាងមុខ លំពែងមួយទៀតចេញអំពីជញ្ជាំងខាងស្តាំ ចាក់ទម្លុះពីខាងស្តាំធ្លាយចេញខាងឆ្វេង ដោតជាប់ជញ្ជាំងខាងឆ្វេង លំពែងមួយទៀត ចេញពីផ្ទៃខាងលើ ចាក់ទម្លុះត្រង់

ក្បាលចុះទៅចំណែកខាងក្រោម ដោតចុះទៅក្នុងផែនដែក ។ ព្រះទេវទត្ត នោះមិនអាចកម្រើកបាន ត្រូវភ្លើងឆេះក្នុងអវិចីនោះ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា "ព្រះទេវទត្តដល់ឋានៈប្រមាណប៉ុណ្ណេះ មិនទាន់បានគាល់ព្រះសាស្តា ផែនដីក៏ស្រូបទៅហើយ" ។ ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទេវទត្តប្រព្រឹត្តខុសក្នុងតថាគត ផែនដីស្រូបទៅ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន គេក៏ត្រូវផែនដីស្រូបហើយ ដូចគ្នា" ទើបទ្រង់សំដែងរឿងកាលដែលបុរសវង្វេងផ្លូវ ដែលព្រះអង្គស្រោចស្រង់ហើយ លើកដាក់លើខ្នងរបស់ខ្លួននាំឲ្យដល់ទីក្សេម ត្រឡប់ជាមកកាត់អស់ក្លុក ៣ ដង យ៉ាងនេះ គឺ ត្រង់ចុង ត្រង់កណ្តាល ត្រង់គល់ ក្នុងវារៈទី ៣ កាលកន្លងផុតគន្លងចក្ខុនៃមហាបុរសហើយ ក៏ត្រូវផែនដីស្រូប ក្នុងកាលព្រះអង្គជាស្តេចដំរី ទើបត្រាស់ជាតកនេះជាដើមថា ៖-

ប្រសិនបើនឹងឲ្យផែនដីទាំងអស់ដល់បុគ្គលអកតញ្ញូ អ្នក

សម្លឹងទោសជានិច្ច ក៏មិនញុំាងគេឲ្យត្រេកអរបានឡើយ ។

កាលកថាតាំងឡើងហើយដូច្នោះទៀត ទ្រង់ទើបត្រាស់ខន្តិវាទិជាតក ដើម្បីទ្រង់សំដែងដល់ព្រះទេវទត្តនោះ កាលនៅជាព្រះបាទកលាពុ ប្រព្រឹត្តខុសក្នុងព្រះអង្គដែលជាខន្តិវាទីតាបស ហើយក៏ត្រូវផែនដីស្រូប និងត្រាស់ចុល្លធម្មបាលជាតក ដើម្បីទ្រង់ចំពោះព្រះទេវទត្តនោះ កាលជាព្រះបាទមហាបតាបៈ ប្រព្រឹត្តខុសក្នុងព្រះអង្គដែលជាចុល្លធម្មបាល ក៏ត្រូវផែនដីស្រូប ។

ក៏កាលព្រះទេវទត្តលិចចុះក្នុងផែនដីហើយ មហាជនរីករាយត្រេកអរឲ្យលើកទង់ជ័យ ទង់បដា និងដើមចេក តាំងថ្នាំងទឹកដែលពេញហើយលេងមហោស្រពធំ ដោយប្រារព្ធថា "ជាលាភរបស់ពួកយើងហ្ន៎" ។ ពួកភិក្ខុក្រាបទូលសេចក្ដីដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលព្រះទេវទត្តស្លាប់ហើយ មហាជនត្រេកអរមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ត្រេកអរហើយដូចគ្នា ។ ដើម្បីទ្រង់សំដែងដល់មហាជនដែលជាអ្នកត្រេកអរ ក្នុងកាលជាព្រះរាជាព្រះនាមថា បិង្គលៈ ក្នុងក្រុងពារាណសីដែលកាចសាហាវ មិន

ជាទីស្រឡាញ់របស់ជនទូទៅចូលទិវង្គតហើយ ទើបត្រាស់បិង្គលជាតកនេះ

ជាដើមថា ៖-

ព្រះពោធិសត្វពោលសួរថា

ជនទាំងអស់ ដែលព្រះបាទបិង្គលៈបៀតបៀនហើយ កាល

ស្ដេចចូលទិវង្គតហើយ ជនទាំងឡាយរមែងសោយបីតិ ព្រះ

បាទបិង្គលៈមានព្រះនេត្រមិនខ្មៅ បានជាទីស្រឡាញ់របស់អ្នក

ឬ នៃនាយទ្វារបាល ហេតុអ្វី អ្នកទើបយំ ។

នាយទ្វារបាលពោលតបថា

ព្រះរាជា មានព្រះនេត្រមិនខ្មៅ មិនជាទីស្រឡាញ់របស់ខ្ញុំទេ

ខ្ញុំខ្លាចការត្រឡប់មករបស់ព្រះរាជានោះ ព្រោះថា ព្រះរាជា

អង្គនោះ ស្ដេចទៅកាន់ទីនោះហើយ គប្បីបៀតបៀនមច្ចុរាជ

មច្ចុរាជនោះត្រូវបៀតបៀនហើយ គប្បីនាំព្រះអង្គត្រឡប់មក

ទីនេះម្ដងទៀត ។

ភិក្ខុទាំងឡាយ ទូលសួរព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន

ឥឡូវនេះ ព្រះទេវទត្តកើតហើយនៅក្នុងទីណា" ។ ព្រះសាស្តាត្រាស់ថា "ក្នុងអវិចីមហានរក ភិក្ខុទាំងឡាយ" ។ ភិក្ខុទាំងនោះក្រាបទូលថា "ព្រះទេវទត្តប្រព្រឹត្តក្តៅក្រហាយក្នុងលោកនេះហើយ ក៏ទៅកើតក្នុងទីដែលក្តៅក្រហាយនោះឯងទៀតឬ ។ ព្រះសាស្តាត្រាស់ថា "យ៉ាងនោះឯង ភិក្ខុទាំងឡាយ ជនទាំងឡាយ ទោះជាបព្វជិតក្តី ជាគ្រហស្ថក្តី មានប្រក្រតីនៅដោយសេចក្តីប្រមាទ រមែងក្តៅក្រហាយក្នុងលោកទាំងពីរតែម្យ៉ាង" ដូច្នេះ ទើបត្រាស់គាថានេះថា ៖-

ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺ ក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

# អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **ឥធ តប្បតិ (រមែងក្តៅក្រហាយក្នុងលោកនេះ)** សេចក្តីថា រមែងក្តៅក្រហាយក្នុងលោកនេះ ព្រោះហេតុត្រឹមតែទោមនស្ស ដោយសេចក្តីក្តៅក្រហាយព្រោះកម្ម ។ បទថា **បេច្ច (លះលោកនេះហើយ)** សេចក្តីថា ចំណែកក្នុងលោកខាងមុខ រមែងក្តៅក្រហាយព្រោះទុក្ខក្នុងអបាយដែលលំបាកដ៏ក្រៃលែង ។ ដោយសេចក្តីក្តៅក្រហាយព្រោះវិបាក ។ បទថា **បាបការី (អ្នកធ្វើបាបជាប្រក្រតី)** សេចក្តីថា អ្នកធ្វើបាបមានប្រការផ្សេងៗ ។ បទថា **ឧភយត្ថ (ទាំងពីរ)** សេចក្តីថា ឈ្មោះថា រមែងក្តៅក្រហាយក្នុងលោកទាំងពីរ ដោយសេចក្តីក្តៅក្រហាយ មានប្រការដូចពោលហើយនេះឯង ។ ពីរបទថា **បាបំ មេ (កម្មអាក្រក់យើងបានធ្វើទុកហើយ)** សេចក្តីថា ក៏បុគ្គលមានប្រក្រតីធ្វើអាក្រក់នោះ កាលក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយព្រោះកម្ម ឈ្មោះថា រមែងក្តៅក្រហាយ ដោយគិតថា "កម្មអាក្រក់យើងបានធ្វើទុកហើយ" ប្រការនោះជាសេចក្តីក្តៅក្រហាយមានប្រមាណតិចតួច តែកាលក្តៅក្រហាយ ដោយ

សេចក្តីក្តៅក្រហាយព្រោះវិបាក ទៅកាន់ទុគ្គតិហើយ គឺ រមែងក្តៅក្រហាយដ៏លើសលុប ព្រោះសេចក្តីក្តៅក្រហាយដ៏គ្រោតគ្រាតក្រៃលែង ។

ក្នុងកាលចប់ព្រះគាថា ជនដ៏ច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើមហើយ ។ ព្រះទេសនាមានប្រយោជន៍ដល់មហាជនដូច្នេះ ។

ចប់រឿងព្រះទេវទត្ត

# ១៣ រឿងនាងសុមនាទេវី

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងសុ-មនាទេវី ត្រាស់ព្រះធម្មទេសនានេះថា **ឥធ នន្ទតិ បេច្ច នន្ទតិ** (រមែងត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១) ជាដើម ។

សេចក្តីពិស្តារថា ភិក្ខុសង្ឃពីរពាន់អង្គ រមែងឆាន់ក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីក្នុងក្រុងសាវត្ថីរាល់ៗ ថ្ងៃ ក្នុងផ្ទះរបស់នាងវិសាខាមហាឧបាសិកាក៏ដូច្នោះ ។ ក៏បុគ្គលណាៗ ក្នុងក្រុងសាវត្ថី ជាអ្នកប្រាថ្នានឹងថ្វាយទាន បុគ្គលនោះៗ ត្រូវសូមឱកាសអំពីលោកទាំងពីរនោះមុន ទើបធ្វើបាន ។ ព្រោះហេតុអ្វី ។ ព្រោះអ្នកដទៃៗ សួរថា "លោកអនាថបិណ្ឌិក-សេដ្ឋី ឬនាងវិសាខមកកាន់រោងទានរបស់អ្នកហើយឬ" ។ កាលគេឆ្លើយថា "មិនបានមក" រមែងតិះដៀលសូម្បីទានដែលបុគ្គលលះបង់ទ្រព្យទាំងសែនហើយធ្វើ ថា "នេះឈ្មោះថាទានអ្វី" ។ ព្រោះថា លោកទាំងពីរនោះរមែងជាអ្នកដឹងនូវសេចក្តីពេញចិត្តរបស់ភិក្ខុសង្ឃ និងកិច្ចដែលសមគួរដល់ភិក្ខុសង្ឃ ។ កាលលោកទាំងពីរនោះនៅហើយ ពួកភិក្ខុសង្ឃឆាន់បានតាម

ការពេញចិត្ត ។ ព្រោះដូច្នោះ គ្រប់ៗ មនុស្សដែលប្រាថ្នានឹងថ្វាយទាន ទើបអញ្ជើញលោកទាំងពីរនោះទៅ ។ លោកទាំងពីរនោះ រមែងមិនបានដើម្បីនឹងអង្គាសភិក្ខុសង្ឃទាំងឡាយក្នុងផ្ទះរបស់ខ្លួន ព្រោះហេតុនោះ នាងវិសាខាកាលពិចារណាថា "នរណាហ្ន៎ នឹងតាំងនៅក្នុងតំណែងរបស់យើង អង្គាសភិក្ខុសង្ឃ" ឃើញធីតារបស់បុត្រហើយ ទើបតាំងគេទុកក្នុងតំណែងរបស់ខ្លួន ។ នាងអង្គាសភិក្ខុសង្ឃក្នុងផ្ទះរបស់នាងវិសាខានោះឯង ។ ចំណែកលោកអនាថបិណ្ឌិកសេដ្ឋី ក៏តាំងធីតាធំឈ្មោះមហាសុភទ្ទា ។ ក៏នាងមហាសុភទ្ទានោះ ធ្វើការខ្វល់ខ្វាយដល់ភិក្ខុសង្ឃទាំងឡាយ (និង) ស្ដាប់ធម៌បានជាព្រះសោតាបន្ន ហើយបានទៅកាន់ត្រកូលនៃស្វាមី ។ បន្ទាប់នោះ លោកសេដ្ឋីទើបតាំងនាងចុល្លសុភទ្ទា (ជំនួស) ។ សូម្បីនាងចុល្លសុភទ្ទាក៏ធ្វើយ៉ាងនោះដូចគ្នា ជាសោតាបន្នហើយ ក៏ទៅកាន់ត្រកូលនៃស្វាមី ។ លំដាប់នោះ លោកសេដ្ឋីទើបតាំងធីតាតូចនាមថា សុមនាទេវី (ជំនួស) ។ ឯនាងសុមនាទេវី ស្ដាប់ធម៌ហើយ សម្រេចជាសកទាគាមិផល នៅជាកុមារិកា (វ័យក្រមុំ) នៅឡើយ ក៏សោប់សោយដោយសេចក្ដីមិនសប្បាយ បរិភោគអាហារមិនបាន

មានបំណងចង់ឃើញបិតា ទើបឲ្យអញ្ជើញបិតាមក ។ លោកសេដ្ឋីពេលបានឃើញបាយរបស់ធិតាក្នុងពេងទានមួយកន្លែង ក៏មករក ហើយសួរថា "កូនកើតអ្វីឬ សុមនា" ។ ធីតាឆ្លើយប្រាប់បិតាថា "មិនមានអ្វីទេ ប្អូនប្រុស"

បិតា. កូនរវើយរវាយឬ ។

សុមនា. មិនរវើរវាយទេ ប្អូនប្រុស ។

បិតា. កូនភ័យខ្លាចឬ ។

សុមនា. មិនភ័យខ្លាចទេ ប្អូនប្រុស ។

នាងសុមនាទេវីពោលបានត្រឹមតែប៉ុណ្ណោះ ក៏បានស្លាប់ទៅ លោកសេដ្ឋីនោះ សូម្បីជាព្រះសោតាបន្ន ក៏មិនអាចនឹងរារាំងសេចក្តីសោកដែលកើតឡើងព្រោះធីតាបាន ឲ្យធ្វើការបញ្ចុះសពរបស់ធីតាស្រេចហើយ ដើរយំទៅកាន់សំណាក់ព្រះសាស្តា កាលព្រះអង្គត្រាស់ថា "គហបតី ហេតុអ្វីលោកទើបមានទុក្ខ ខូចចិត្ត មានមុខជោកដោយទឹកភ្នែក ដើរយំ ដូច្នេះ" ទើបក្រាបទូលថា សុមនាទេវីកូនរបស់ខ្ញុំព្រះអង្គ ស្លាប់ហើយព្រះអង្គ ។

ព្រះសាស្តា. បើដូច្នោះ ហេតុអ្វីលោកទើបសោក សេចក្តីស្លាប់រមែង

ប្រព្រឹត្តទៅដោយពិតដល់សព្វសត្វ មិនមែនឬ ។

អនាថ. ខ្ញុំព្រះអង្គដឹង ព្រះអង្គ តែធីតារបស់ខ្ញុំព្រះអង្គដល់ព្រម ដោយហិរិ និងឱត្តប្បៈបែបនេះ ក្នុងវេលាជិតស្លាប់ នាងមិនអាចគ្រប់គ្រងសតិទុកបាន និយាយវង្វេងវង្វាយហើយស្លាប់ ព្រោះហេតុនោះ ទោមនស្សដ៏ខ្លាំង ទើបកើតឡើងដល់ខ្ញុំព្រះអង្គ ។

ព្រះសាស្តា. មហាសេដ្ឋី ក៏នាងនិយាយអ្វីខ្លះ ។

អនាថ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសួរនាងថា "មានរឿងអ្វីឬ សុមនាកូន" ពេលនោះ នាងក៏ពោលចំពោះខ្ញុំព្រះអង្គថា "អ្វី ប្អូនប្រុស" តអំពីនោះ ខ្ញុំព្រះអង្គពោលថា "កូនវង្វេងវង្វាយឬ" នាងឆ្លើយថា "មិនវង្វេងវង្វាយទេ ប្អូនប្រុស" ។ កាលខ្ញុំព្រះអង្គសួរថា "កូនភ័យខ្លាចឬ" នាងឆ្លើយថា "មិនភ័យខ្លាចទេ ប្អូនប្រុស" ។ ពេលពោលបានប៉ុណ្ណោះ ក៏ស្លាប់ទៅ ។

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ចំពោះអនាថបិណ្ឌិកសេដ្ឋីថា "មហាសេដ្ឋី ធីតារបស់លោក មិនបានវង្វេងវង្វាយទេ" ។

អនាថ. បើដូច្នោះ ហេតុអ្វីនាងទើបពោលយ៉ាងនេះ ព្រះអង្គ ។

ព្រះសាស្ដា. ព្រោះលោកជាប្អូនរបស់នាងពិតៗ (ទើបនាងនិយាយដូច្នោះចំពោះលោក) គហបតី ក៏ធីតារបស់លោកធំជាងលោកដោយមគ្គនិងផល ព្រោះលោកត្រឹមតែជាសោតាបន្ន ចំណែកធីតារបស់លោកជាសកទាគាមិនី ព្រោះនាងជាធំដោយមគ្គ និងផល នាងទើបពោលដូច្នោះចំពោះលោក ។

អនាថ. ដូច្នោះឬ ព្រះអង្គ ។

ព្រះសាស្ដា. ដូច្នោះឯង គហបតី ។

អនាថ. ពេលនេះនាងកើតទីណា ព្រះអង្គ ។

កាលព្រះសាស្ដាត្រាស់ថា "ក្នុងភពតុសិត គហបតី" លោកសេដ្ឋីទើបក្រាបទូលថា ធីតារបស់ខ្ញុំព្រះអង្គ រីករាយហើយក្នុងពពួកញាតិក្នុងលោកនេះ សូម្បីទៅអំពីលោកនេះ ក៏កើតក្នុងទីដែលគួររីករាយដូចគ្នាឬព្រះអង្គ ។ ពេលនោះ ព្រះសាស្ដាត្រាស់ចំពោះសេដ្ឋីនោះថា "យ៉ាងនោះឯង គហបតី ធម្មតាបុគ្គលមិនប្រមាទ ជាគ្រហស្ថក្ដី ជាបព្វជិតក្ដី រមែង

រីករាយក្នុងលោកនេះ និងលោកខាងមុខដោយពិត" ទើបទ្រង់ត្រាស់គាថា

នេះថា ៖-

ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ
បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ
គឺ ត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ
១ បុគ្គលនោះរមែងត្រេកអរ ដោយគិតឃើញថា បុណ្យ
អញបានធ្វើទុកហើយ លុះធ្វើមរណកាលទៅកាន់សុគតិ
ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ឥធ (ក្នុងលោកនេះ) សេចក្ដីថា រមែងត្រេកអរក្នុងលោក ដោយសេចក្ដីត្រេកអរព្រោះកម្ម ។ បទថា បេច្ច (ស្លាប់ទៅហើយ) សេចក្ដីថា រមែងត្រេកអរក្នុងលោកខាងមុខ ដោយសេចក្ដីត្រេកអរព្រោះវិបាក ។ បទថា កតបុញ្ញោ (ធ្វើបុណ្យទុកហើយ) គឺ អ្នក

ដែលធ្វើបុណ្យមានប្រការផ្សេងៗ ។ បទថា **ឧភយត្ថ (ក្នុងលោកទាំងពីរ)** សេចក្ដីថា រមែងត្រេកអរក្នុងលោកនេះ ដោយគិតថា "កុសលយើងបានធ្វើទុកហើយ បាបយើងមិនបានធ្វើ" ។ កាលសោយវិបាក ឈ្មោះថា រមែងត្រេកអរក្នុងលោកខាងមុខ ។ ពីរបទថា **បុញ្ញំ មេ (បុណ្យយើងបានធ្វើទុកហើយ)** សេចក្ដីថា ក៏កាលត្រេកអរក្នុងលោកនេះ ឈ្មោះថា រមែងត្រេកអរ អាស្រ័យហេតុព្រោះសេចក្ដីត្រេកអរក្នុងកម្ម ដោយហេតុត្រឹមតែសោមនស្សប៉ុណ្ណោះ ថា "បុណ្យយើងធ្វើទុកហើយ" ។ បទថា **ភិយ្យោ (ក្រៃលែងឡើង)** ជាដើម សេចក្ដីថា ក៏គេទៅកាន់សុគតិហើយ កាលសោយទិព្វសម្បត្តិ រហូត ៥៧ កោដិឆ្នាំខ្លះ ៦ លានឆ្នាំខ្លះ រមែងឈ្មោះថា ត្រេកអរយ៉ាងក្រៃលែងក្នុងតុសិតសួគ៌ ដោយសេចក្ដីត្រេកអរ ព្រោះវិបាក ។

ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ព្រះធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់រឿងសុមនាទេវី

# ១៤. រឿងភិក្ខុ ២ រូបជាសំឡាញ់នឹងគ្នា

ព្រះសាស្តាកាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ២ រូប ជាសំឡាញ់នឹងគ្នា ទើបត្រាស់ធម្មទេសនានេះថា **ពហុម្បិ ចេ សហិតំ ភាសមានោ** (ប្រសិនបើ នរជនពោលព្រះពុទ្ធវចនៈដែលមានប្រយោជន៍ សូម្បីច្រើន) ជាដើម ។

សេចក្តីពិស្តារ កុលបុត្រ ២ នាក់ អ្នកក្រុងសាវត្ថី ជាសំឡាញ់នឹងគ្នា ទៅកាន់វិហារ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ក៏លះបង់កាមទាំងឡាយ បួសថ្វាយជីវិតក្នុងសាសនារបស់ព្រះសាស្តា នៅក្នុងសំណាក់ព្រះអាចារ្យ និងព្រះឧបជ្ឈាយ៍រហូត ៥ ឆ្នាំហើយ ចូលទៅគាល់ព្រះសាស្តា ទូលសួរដល់ធុរៈក្នុងព្រះសាសនា បានស្តាប់វិបស្សនាធុរៈ និងគន្ថធុរៈដោយពិស្តារ មួយអង្គក្រាបទូលមុនថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបួសហើយក្នុងកាលខ្លួនចាស់ មិនអាចនឹងបំពេញគន្ថធុរៈបាន តែនឹងបំពេញវិបស្សនាធុរៈ" ដូច្នេះហើយ ទូលសូមព្រះសាស្តាត្រាស់វិបស្សនារហូតដល់ព្រះអរហត្ត ទើបព្យាយាមរហូតដល់សម្រេចព្រះអរហត្ត ព្រមទាំង

បដិសម្ភិទាទាំងឡាយ ។ ចំណែកភិក្ខុក្រៅពីនេះ គិតគ្នាថា “យើងនឹងបំពេញគន្ថធុរៈ” ដូច្នេះ ទើបរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ដោយលំដាប់ពោលធម៌ សូត្រសរភញ្ញក្នុងទីដែលខ្លួនទៅហើយៗ ដើរប្រាប់ធម៌ដល់ភិក្ខុ ៥០០ រូប បានជាអាចារ្យរបស់គណៈធំ ១៨ គណៈ ភិក្ខុទាំងឡាយរៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តាហើយ ទៅកាន់ទីនៅរបស់ព្រះថេរៈមួយអង្គទៀត (អង្គដែលបំពេញវិបស្សនា) តាំងនៅក្នុងឱវាទរបស់លោក ក៏សម្រេចព្រះអរហត្តហើយ នមស្ការព្រះថេរៈពោលថា “ខ្ញុំទាំងឡាយបំណងនឹងគាល់ព្រះសាស្តា” ។ ព្រះថេរៈពោលថា “ទៅចុះ អ្នកមានអាយុ អ្នកទាំងឡាយចូរថ្វាយបង្គំព្រះសាស្តា នមស្ការព្រះមហាថេរៈទាំង ៨០ អង្គតាមពាក្យរបស់យើង ចូរប្រាប់ព្រះថេរៈ ដែលជាសំឡាញ់របស់យើងថា “លោកអាចារ្យរបស់ខ្ញុំទាំងឡាយ សូមនមស្ការលោកម្ចាស់” ដូច្នេះហើយបញ្ជូនទៅ ។ ភិក្ខុទាំងនោះទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តា និងនមស្ការព្រះអសីតិមហាសាវកហើយ ក៏ទៅកាន់សំណាក់ព្រះគន្ថិកត្ថេរ ពោលថា “លោកម្ចាស់ លោកអាចារ្យរបស់ពួកខ្ញុំសូមថ្វាយបង្គំលោកម្ចាស់ ទៀបព្រះ

បាទ” ។ ក៏កាលព្រះថេរៈសួរថា “អាចារ្យរបស់ពួកលោកជានរណា” ។ ភិក្ខុទាំងនោះពោលថា “ជាសំឡាញ់របស់លោកម្ចាស់” ។ កាលព្រះថេរៈ (វិបស្សនាភិក្ខុ) បញ្ចូនដំណឹងសួរសុខទុក្ខយ៉ាងនេះរឿយៗ ភិក្ខុនោះ (គន្ថិកៈ) អត់ទ្រាំបានក្នុងកាលតិចតួច ក្រោយមកមិនអាចអត់ទ្រាំបាន ពេលដែលពួកអាគន្តុកភិក្ខុពោលថា “លោកអាចារ្យរបស់ពួកខ្ញុំសូមនមស្ការលោកម្ចាស់” ដូច្នេះ ទើបពោលថា “អាចារ្យរបស់ពួកលោកនោះជានរណា” កាលភិក្ខុទាំងឡាយប្រាប់ថា “ភិក្ខុជាសំឡាញ់របស់លោកម្ចាស់” ។ ទើបពោលថា “ហេតុអ្វី ក៏ពួកលោករៀនក្នុងសំណាក់របស់ភិក្ខុនោះ ។ បណ្តានិកាយ មានទីឃនិកាយជាដើម និកាយណាមួយ ឬបណ្តាបិដកទាំង ៣ បិដកណាមួយឬ” ដូច្នេះ ហើយគិតថា “សំឡាញ់របស់យើងរមែងមិនចេះគាថាសូម្បីប្រកបដោយ ៤ បាទ សមាទានបង្សុកូលចូលព្រៃតាំងតែអំពីកាលបួសហើយ នៅមានអន្តេវាសិកច្រើនទៀតហ្ន៎ ក្នុងកាលដែលលោកមក យើងគួរសួរបញ្ហាខ្លះមើល ។ ក្នុងកាលតមក ព្រះថេរៈ (វិបស្សកៈ) បានមកគាល់ព្រះសាស្តាទុកដាក់បាត្រចីវរក្នុងសំណាក់របស់ព្រះថេរៈដែលជាសំឡាញ់ហើយ ក៏ទៅ

ថ្វាយបង្គំព្រះសាស្តា និងនមស្ការព្រះអសីតិមហាសាវក ហើយក៏ត្រឡប់មកទីនៅរបស់ព្រះថេរៈជាសំឡាញ់ ។ លំដាប់នោះ ព្រះគន្ធិកត្ថេរឲ្យភិក្ខុទាំងឡាយធ្វើវត្តដល់លោកហើយ ក៏កាន់យកអាសនៈមានប្រមាណស្មើគ្នាអង្គុយដោយតាំងចិត្តថា នឹងសួរបញ្ហា ។ ខណៈនោះ ព្រះសាស្តាទ្រង់ជ្រាបថា គន្ធិកភិក្ខុនេះ បៀតបៀនបុត្ររបស់តថាគតមួយរូបនេះហើយ នឹងទៅកើតក្នុងនរក ។ ដោយទ្រង់មេត្តាក្នុងភិក្ខុនោះ ក៏ទ្រង់ស្តេចចារិកទៅក្នុងវិហារ ស្តេចដល់ស្ថានទីដែលភិក្ខុទាំងពីរអង្គុយហើយ ទ្រង់ប្រថាប់គង់លើពុទ្ធាសនៈដែលភិក្ខុទាំងឡាយរៀបចំហើយ ។ ពិតណាស់ ភិក្ខុទាំងឡាយកាលនឹងអង្គុយក្នុងទីនោះៗ ក៏បានរៀបចំអាសនៈសម្រាប់ព្រះពុទ្ធមុនទើបអង្គុយ ។ ព្រោះហេតុនោះ ព្រះសាស្តាទើបប្រថាប់គង់លើពុទ្ធាសនៈដែលព្រះគន្ធិកភិក្ខុនោះចាត់ចែងទុកដោយប្រក្រតីនោះឯង ។ លុះទ្រង់ប្រថាប់គង់ហើយ ទើបត្រាស់សួរបញ្ហាក្នុងបឋមឈានចំពោះគន្ធិកភិក្ខុ កាលលោកទូលឆ្លើយមិនបាន ទើបត្រាស់សួរបញ្ហាក្នុងរូបសមាបត្តិ និងអរូបសម្បត្តិទាំងប្រាំបី តាំងអំពីទុតិយឈានជាដើមទៅ ។ គន្ធិកភិក្ខុក៏មិនអាចទូលឆ្លើយ

បានសួរឡើងត្រឹមតែមួយបញ្ហា ។ ព្រះវិបស្សកត្ថេរ ទូលឆ្លើយបញ្ហានោះបានទាំងអស់ ។ ពេលនោះ ព្រះសាស្ដាត្រាស់សួរបញ្ហាក្នុងសោតាបត្តិមគ្គចំពោះលោក ព្រះគន្ថិកភិក្ខុក៏មិនអាចទូលឆ្លើយបាន ។ ទើបត្រាស់សួរចំពោះព្រះខីណាសវត្ថេរ ។ ព្រះថេរៈក៏ទូលឆ្លើយបាន ។ ព្រះសាស្ដាទ្រង់អនុមោទនាថា សាធុៗ ហើយត្រាស់សួរបញ្ហាសួរឡើងក្នុងមគ្គដ៏សេសទាំងឡាយតាមលំដាប់ ។ ព្រះគន្ថិកត្ថេរក៏មិនអាចឆ្លើយបញ្ហាដែលត្រាស់សួរហើយនោះៗ បាន ។ ព្រះសាស្ដាបានប្រទានសាធុការដល់ព្រះខីណាស្រពនោះ ក្នុងឋានៈទាំងបួន ។ ទេវតាទាំងឡាយតាំងអំពីភុម្មទេវតារហូតដល់ព្រហ្មលោក នាគ និងគ្រុឌ បានឮសាធុការនោះហើយ ក៏បានឲ្យសាធុការតាម ។ ពួកអន្តេវាសិក និងពួកសទ្ធិវិហារិករបស់ព្រះគន្ថិកត្ថេរ បានឮសាធុការនោះហើយ លើកទោសរបស់ព្រះសាស្ដាថា ព្រះសាស្ដាទ្រង់ធ្វើកម្មអ្វីនេះ ព្រះអង្គបានប្រទានសាធុការដល់ព្រះមហល្លកត្ថេរ (ព្រះថេរៈចាស់) ដែលមិនដឹងអ្វីៗ ក្នុងឋានៈទាំងបួន ចំណែកលោកអាចារ្យរបស់ពួកយើង ជាអ្នកទ្រទ្រង់នូវព្រះបរិយត្តិធម៌ទុកបានទាំងអស់ ជាប្រធានភិក្ខុ

ប្រមាណ ៥០០ រូប ព្រះអង្គទ្រង់មិនបានធ្វើសូម្បីត្រឹមតែការសរសើរ ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វី” កាលភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះហើយ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អាចារ្យរបស់ពួកអ្នកដូចគ្នានឹងអ្នករក្សាគោទាំងឡាយ ដើម្បីថ្លៃឈ្នួលក្នុងសាសនារបស់តថាគត ចំណែកបុត្ររបស់តថាគតដូចជាម្ចាស់ ជាអ្នកបរិភោគបញ្ចគោរស[១] តាមពេញចិត្ត” ។ ដូច្នេះ ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ
គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជន ពោលព្រះពុទ្ធវចនៈដែលមានប្រយោជន៍សូម្បីច្រើន
តែជាអ្នកប្រមាទហើយ មិនធ្វើតាមព្រះពុទ្ធវចនៈនោះ គេរមែង

---

១ បញ្ចគោរស ៥ យ៉ាង ទឹកដោះស្រស់ , ទឹកដោះជូរ , ទឹកដោះចម្រិនមួយរំពុះ , ទឹកដោះថ្លា , ទឹកដោះខាប់ ។

ជាអ្នកមិនមានចំណែកនៃសាមញ្ញផលឡើយ ដូចជាអ្នករក្សាគោ រាប់គោទាំងឡាយប្រគល់ឲ្យអ្នកដទៃ រមែងជាអ្នកមិនមានចំណែក នៃបញ្ចគោរស ដូច្នោះ ។

អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស  ហោតិ  អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ   សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មាន ចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំក្នុង លោកនេះនិងលោកខាងមុខ នរជននោះ រមែងជាអ្នកមានចំណែក

នៃសាមញ្ញផល ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា *សហិតំ* (ដែលមានប្រយោជន៍) នេះជាឈ្មោះនៃព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក នរជនចូលទៅរកអាចារ្យទាំងឡាយរៀនព្រះពុទ្ធវចនៈនោះហើយ ពោល គឺ ប្រាប់ បានដល់ ការសំដែងនូវព្រះពុទ្ធវចនៈសូម្បីច្រើនដល់ជនពួកដទៃ (តែ) ជាអ្នកមិនធ្វើកិច្ចដែលការកបុគ្គលស្ដាប់ធម៌នោះហើយនឹងគប្បីធ្វើមិនបាន គឺ មិនញុំាំងការធ្វើទុកក្នុងចិត្តឲ្យប្រព្រឹត្តទៅដោយអំណាចនៃត្រៃលក្ខណៈ មានអនិច្ចលក្ខណៈជាដើមសូម្បីខណៈត្រឹមតែមាន់ទទះស្លាប នរជននោះ រមែងជាអ្នកមានចំណែកនៃផលត្រឹមតែការធ្វើវត្តបដិបត្តិ អំពីសំណាក់នៃអន្តេវាសិកទាំងឡាយតែម្យ៉ាង គឺ ជាអ្នកមិនមានចំណែកនៃគុណរបស់សមណៈ ដូចជាអ្នករក្សាគោ រក្សាគោទាំងឡាយដើម្បីថ្លៃឈ្នួលប្រចាំថ្ងៃ ដេញ (គោ) ទៅអំពីព្រឹក វេលាល្ងាចរាប់ (គោ) ប្រគល់ឲ្យម្ចាស់គេ ទទួលយកត្រឹមតែតម្លៃចាយវាយប្រចាំថ្ងៃ តែមិនបានដើម្បីបរិភោគបញ្ចគោរសតាមការពេញចិត្ត ដូច្នោះឯង ។ ឧបមា

ថា ម្ចាស់របស់គោម្នាក់ រមែងបរិភោគបញ្ចគោរសនៃគោទាំងឡាយ ដែលនាយគោបាលប្រគល់ឲ្យហើយ យ៉ាងណា ការកបុគ្គលទាំងឡាយស្តាប់ធម៌ដែលនរជននោះពោលហើយ បដិបត្តិតាមនរជននោះទូន្មានហើយ ក៏ដូច្នោះ ពួកខ្លះសម្រេចបឋមឈានជាដើម ពួកខ្លះចម្រើនវិបស្សនាហើយសម្រេចមគ្គនិងផល ក៏ចាត់ថា ជាអ្នកមានចំណែកនៃគុណរបស់សមណៈ ដូចពួកម្ចាស់គោ រមែងជាអ្នកមានចំណែកនៃបញ្ចគោរស ដូច្នោះ ។ ព្រះសាស្តាត្រាស់គាថាទី ១ ដោយអំណាចនៃភិក្ខុអ្នកបរិបូណ៌ដោយសីល អ្នកមានសុត្តៈច្រើន (តែ) មានប្រក្រតីនៅដោយសេចក្តីប្រមាទ មិនប្រព្រឹត្តក្នុងការធ្វើទុកក្នុងចិត្តដោយឧបាយត្រឹមត្រូវដោយអំណាចនៃត្រៃលក្ខណ មានអនិច្ចលក្ខណៈជាដើម ទ្រង់មិនបានត្រាស់ដល់ភិក្ខុអ្នកទ្រុស្តសីល ដោយប្រការដូច្នេះ ។

ចំណែកគាថាទី ២ ព្រះអង្គត្រាស់ដោយអំណាចនៃការកបុគ្គល សូម្បីជាអ្នកមានសុត្តៈតិច (តែ) ធ្វើកម្មក្នុងការធ្វើទុកក្នុងចិត្តដោយឧបាយត្រឹមត្រូវ ។ ក្នុងបទទាំងនោះ បទថា **អប្បម្បិ ចេ** (ប្រសិនបើ... សូម្បីតិច) សេចក្តីថា តិច គឺ សូម្បីត្រឹមតែ ១ វគ្គ ឬ ២ វគ្គ ។ បទថា **ធម្មស្ស**

*ហោតិ អនុធម្មចារី (អ្នកមានប្រក្រតីប្រព្រឹត្តធម៌សមគួរដល់ធម៌) ជាដើម សេចក្តីថា នរជនដឹងអត្ថ ដឹងធម៌ហើយ រមែងប្រព្រឹត្តធម៌ដែលសមគួរដល់ លោកុត្តរធម៌ ៩ គឺ ប្រភេទនៃធម៌ មានបារិសុទ្ធិសីល ៤ ធុតង្គគុណ និង អសុភកម្មដ្ឋានជាដើម ដែលរាប់ថា ជាវត្តបដិបត្តិចំណែកខាងដើម រមែង ជាអ្នកឈ្មោះថា មានប្រក្រតីប្រព្រឹត្តធម៌សមគួរដល់ធម៌ គឺ រមែងប្រព្រឹត្ត សង្ឃឹមដល់ការចាក់ធ្លុះថា "យើងនឹងចាក់ធ្លុះក្នុងថ្ងៃនេះ យើងនឹងចាក់ធ្លុះ ក្នុងថ្ងៃនេះឯង" ។ នរជននោះ លះរាគៈ ទោសៈ និងមោហៈ ដោយវត្ត- បដិបត្តិត្រឹមត្រូវនេះហើយ កំណត់ដឹងធម៌ដែលគួរកំណត់ដឹងដោយល្អ គឺ ដោយហេតុ ដោយន័យ មានចិត្តរួចផុតស្រឡះល្អហើយដោយអំណាចនៃ តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណ- វិមុត្តិ អស់ការប្រកាន់មាំក្នុងលោកនេះ ឬក្នុងលោកដទៃ គឺ មិនចូលដល់ ការប្រកាន់ខន្ធ អាយតនៈ និងធាតុទាំងឡាយ ដែលរាប់បញ្ចូលក្នុងលោក នេះ និងលោកដទៃ ឬដែលជាខាងក្នុង និងខាងក្រៅ ដោយឧបាទាន[១] ៤ ឈ្មោះថា ជាមហាខីណាស្រព រមែងជាអ្នកមានចំណែកនៃគុណរបស់សមណៈ*

---

*១. បានដល់ កាមុបាទាន (ការប្រកាន់ក្នុងកាម ១) , ទិដ្ឋុបាទាន (ការប្រកាន់ដោយទិដ្ឋិ ១) , សីល- ព្វតុបាទាន (ការប្រកាន់ក្នុងសីលវត្ត ១) , អត្តវាទុបាទាន (ការប្រកាន់ក្នុងវាទៈថាខ្លួន ១) ។*

គឺ ផល ដែលមកហើយដោយអំណាចនៃគុណរបស់សមណៈ ពោលគឺ មគ្គនិងនៃគុណរបស់សមណៈ គឺ គំនរនៃអសេក្ខធម៌[២] ៥ ។ ព្រះសាស្ដាទ្រង់រួបរួមកំពូលនៃព្រះទេសនាដោយព្រះអរហត្ត ដូចមេជាងកាន់យកកំពូលនៃផ្ទះ ដោយកំពូលកែវ ដូច្នោះឯង ។

ក្នុងកាលចប់ព្រះគាថា ជនដ៏ច្រើនបានជាអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

ចប់រឿងភិក្ខុ ២ រូបជាសំឡាញ់នឹងគ្នា

## ចប់យមកវគ្គវណ្ណនា វគ្គទី ១

ក្នុងវគ្គនេះរួមមាន ១៤ រឿង

| | |
|---|---|
| ១. រឿងព្រះចក្ខុបាលត្ថេរៈ | ២. រឿងមដ្ឋកុណ្ឌលី |
| ៣. រឿងព្រះតិស្សត្ថេរៈ | ៤. រឿងនាងកាឡីយក្ខិណី |
| ៥. រឿងភិក្ខុក្រុងកោសម្ពី | ៦. រឿងចុល្លកាល-មហាកាល |
| ៧. រឿងព្រះទេវទត្ត | ៨. រឿងសញ្ជ័យ |
| ៩. រឿងព្រះនន្ទត្ថេរៈ | ១០. រឿងនាយចុន្ទសូករិកៈ |
| ១១. រឿងធម្មិកឧបាសក | ១២. រឿងទេវទត្ត |
| ១៣. រឿងនាងសុមនាទេវី | ១៤. រឿងភិក្ខុជាសំឡាញ់ ២ រូប |

១. បានដល់ សីលក្ខន្ធ (គុណគឺសីល ១) , សមាធិក្ខន្ធ (គុណគឺសមាធិ ១) , បញ្ញាក្ខន្ធ (គុណគឺបញ្ញា ១) , វិមុត្តិក្ខន្ធ (គុណគឺវិមុត្តិ ១) , វិមុត្តិញ្ញាណទស្សនក្ខន្ធ (គុណគឺវិមុត្តិញ្ញាណទស្សនៈ ១) ។

# អប្បមាទវគ្គ ទី ២

## ១. រឿងព្រះនាងសាមាវតី

(ពោលដោយសេចក្ដីមិនប្រមាទ និងសេចក្ដីប្រមាទ)

[១២] *ព្រះសាស្ដា កាលទ្រង់អាស្រ័យក្នុងក្រុងកោសម្ពីប្រថាប់នៅក្នុងឃោសិតារាម ទ្រង់ប្រារព្ធសេចក្ដីវិនាស គឺ សេចក្ដីស្លាប់របស់ស្ត្រី ៥០០ នាក់ មានព្រះនាងសាមាវតីជាប្រធាន និងញាតិ ៥០០ របស់ព្រះនាងមាគន្ទិយានោះ មាននាងគន្ទិយាជាប្រធាន ត្រាស់ព្រះធម្មទេសនានេះថា* ***អប្បមាទោ អមតំ បទំ*** *(សេចក្ដីមិនប្រមាទ ជាគ្រឿងដល់អមតៈ) ជាដើម ។ ក្នុងរឿងនោះ មានអនុបព្វីកថាដូចតទៅនេះ ៖*

### ប្រវត្តិព្រះចានឧទេន

*ក្នុងអតីតកាល មានព្រះរាជា ២ ព្រះអង្គ គឺ ក្នុងដែនអល្លកប្បៈព្រះរាជាទ្រង់ព្រះនាមថា* ***អល្លកប្បៈ*** *ក្នុងដែនវេដ្ឋទីបកៈព្រះរាជាទ្រង់ព្រះនាមថា* ***វេដ្ឋទីបកៈ*** *ជាសំឡាញ់នឹងគ្នាតាំងពីវេលានៅទ្រង់វ័យក្មេង ទ្រង់សិក្សា*

សិល្បៈក្នុងសំណាក់អាចារ្យជាមួយគ្នា ដោយកាលកន្លងទៅ ព្រះរាជបិតារៀងៗ ខ្លួន បានឲ្យលើកស្វេតច័ត្រឡើងអភិសេកទ្រង់ជាព្រះរាជាក្នុងដែនមានប្រមាណក្នុងដែនមួយ ១០ យោជន៍ ។ ព្រះរាជា ២ ព្រះអង្គនោះស្ដេចមកប្រជុំគ្នាតាមកាលសមគួរ ទ្រង់ឈរ អង្គុយ ទ្រង់ផ្ទុំរួមគ្នា ទតឃើញមហាជនអ្នកកើត និងស្លាប់ ទើបទ្រង់ប្រឹក្សាគ្នាថា "ឈ្មោះថា អ្នកតាមបុគ្គលទៅកាន់បរលោករមែងមិនមាន ទីបំផុតសូម្បីសរីរៈរបស់ខ្លួន ក៏តាមទៅមិនបាន ត្រូវលះបង់វត្ថុគ្រប់យ៉ាង ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់យើង យើងបួស" ដូច្នេះ ទើបទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ព្រះឱរស និងព្រះមហេសី ចេញបួសជាឥសីនៅក្នុងព្រៃហិមវន្តប្រទេសទ្រង់បានប្រឹក្សាគ្នាថា "ពួកយើងលះបង់រាជសម្បត្តិ ចេញបួស មិនមែនអស់ផ្លូវចិញ្ចឹមជីវិតទេ យើងទាំងពីរ កាលនៅក្នុងទីជាមួយគ្នា ក៏ដូចគ្នានឹងអ្នកដែលមិនបានបួសនោះឯង ព្រោះដូច្នោះ យើងនឹងបែកគ្នារស់នៅលោកចូរនៅត្រង់កូនភ្នំនោះ យើងនឹងនៅត្រង់កូនភ្នំនេះ តែនឹងរួមគ្នាក្នុងថ្ងៃឧបោសថរាល់កន្លះខែម្ដង" ។ គ្រានោះ ឥសីទាំងពីរនោះកើតមានសេចក្ដី

ត្រិះរិះយ៉ាងនេះថា "សូម្បីដូច្នេះ ការស្និទ្ធស្នាលដោយគណៈនឹងមានដល់យើងទាំងឡាយ លោកគប្បីដុតភ្លើងឲ្យឆេះឡើងត្រង់ក្អំរបស់លោក យើងនឹងដុតភ្លើងឲ្យឆេះឡើងត្រង់ក្អំរបស់យើង ដោយសញ្ញានោះ យើងក៏នឹងដឹងថា យើងនៅមានជីវិត" ។ ឥសីទាំងពីរនោះ ក៏ធ្វើយ៉ាងនោះឯង ។

លុះកាលតមក វេជ្ជទីបកតាបសធ្វើកាលកិរិយា កើតជាទេវតាអ្នកមានសក្តិធំ ។ តពីនោះ គ្រាដល់កន្លះខែ អល្លកប្បតាបសពេលមើលមិនឃើញភ្លើង ក៏ដឹងបានថា សំឡាញ់របស់យើងស្លាប់ហើយ ។ សូម្បីតាបសវេជ្ជទីបកៈពិចារណាមើលទិព្វសិរីរបស់ខ្លួនក្នុងខណៈដែលកើត ពិចារណាដល់កម្ម ឃើញកិរិយាដែលខ្លួនធ្វើផ្តើមតាំងពីការចេញមកបួស ក៏គិតថា ឥឡូវនេះ យើងនឹងទៅសួរសុខទុក្ខសំឡាញ់របស់យើង ។ ក្នុងខណៈនោះ ទើបក្លែងខ្លួន ធ្វើដូចជាអ្នកវង្វេងផ្លូវ ទៅកាន់សំណាក់របស់អល្លកប្បតាបសនោះ ថ្វាយបង្គំហើយ បានឈរនៅក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ អល្លកប្បតាបសនោះ ទើបសួរបុរសនោះថា "លោកមកអំពីទីណា" ។

បុរស. លោកម្ចាស់ដ៏ចម្រើន ខ្ញុំជាអ្នកវង្វេងផ្លូវ ដើរមកអំពីទីឆ្ងាយ

ក៏លោកម្ចាស់នៅតែម្នាក់ឯងប៉ុណ្ណោះក្នុងទីនេះ ឬមានអ្នកដទៃដែរ ។

អល្លៈ. មានសំឡាញ់របស់យើងម្នាក់ទៀត ។

បុរស. អ្នកនោះនៅទីណា ។

អល្លៈ. គេនៅត្រង់កូនភ្នំនោះ តែក្នុងថ្ងៃឧបោសថ មិនឃើញគេដុតភ្លើងឲ្យជាសញ្ញា គេប្រាកដជាស្លាប់ហើយ ។

បុរស. យ៉ាងនោះឬ លោកម្ចាស់ ។

អល្លៈ. អ្នកមានអាយុ យ៉ាងនោះឯង ។

បុរស. ខ្ញុំគឺគេនោះឯង លោកម្ចាស់ ។

អល្លៈ. លោកកើតក្នុងទីណា ។

បុរស. ខ្ញុំកើតជាទេវតាអ្នកមានស័ក្តិធំក្នុងទេវលោក លោកម្ចាស់ ខ្ញុំមកទីនេះទៀតក៏ដោយបំណងថា នឹងសួរសុខទុក្ខលោកម្ចាស់ តើលោកម្ចាស់នៅក្នុងទីនេះ ឧបទ្រវៈអ្វីមានខ្លះដែរឬ ។

អល្លៈ. អាវុសោ យើងលំបាក ព្រោះអាស្រ័យដំរី ។

បុរស. លោកម្ចាស់ដ៏ចម្រើន ក៏ដំរីធ្វើអ្វីដល់លោក ។

អល្ល:. វាបន្ទោបង់លាមកក្នុងទីយើងបោសសម្អាតហើយ យកជើងដាក់កកាយធូលីឡើង ខ្ញុំជញ្ជូនលាមកដំរីទាំងនោះចោល កាយពង្រាបដីឲ្យស្មើ ក៏រមែងលំបាក ។

បុរស. លោកម្ចាស់ប្រាថ្នាមិនឲ្យដំរីទាំងនោះមកទៀតទេ ។

អល្ល:. អើ! អាវុសោ ។

បុរសពោលថា បើដូច្នោះ ខ្ញុំនឹងធ្វើមិនឲ្យដំរីទាំងនោះមក បានថ្វាយពិណាសម្រាប់ឲ្យដំរីស្រឡាញ់ និងបង្រៀនមន្តសម្រាប់ឲ្យដំរីស្រឡាញ់ ដល់ព្រះតាបស ក៏កាលនឹងឲ្យ បានប្រាប់ខ្សែពិណា ៣ ខ្សែ ឲ្យរៀនមន្ត ៣ បទ ហើយប្រាប់ថា "កាលដេញខ្សែពិណានេះ រាយមន្តបទនេះហើយ ដំរីមិនអាចនឹងបែរមើលក្រោយ រមែងរត់ចេញទៅ , កាលដេញខ្សែពិណានេះ រាយមន្តបទនេះ ដំរីនឹងត្រឡប់មើលមកខាងក្រោយ ហើយរត់ចេញទៅ , កាលដេញខ្សែពិណានេះ រាយមន្តដូច្នេះហើយ ដំរីមេហ្វូងរមែងបង្អោនខ្នងចូលមករក" ហើយពោលទៀតថា "វត្ថុណាដែលលោកពេញចិត្ត លោកគប្បីធ្វើវត្ថុនោះចុះ" សំពះតាបសហើយ ក៏ចៀសចេញទៅ ។ ព្រះតាបស

រាយបទមន្តសម្រាប់ដេញដំរី ដេញខ្សែពិណសម្រាប់ដេញដំរី ញ៉ាំងដំរីឲ្យគេចចេញទៅ ។

## ព្រះចាទឧទេន និងបក្សីហត្ថីលិង្គ

ក្នុងសម័យនោះ ក្នុងក្រុងកោសម្ពី មានព្រះរាជាទ្រង់នាមថា ព្រះបាទបរន្តប: ។ ថ្ងៃមួយ ព្រះបាទបរន្តប:ទ្រង់អង្គុយកំដៅភ្លើង នៅត្រង់ទីវាលជាមួយព្រះទេវីដែលទ្រង់គភ៌ ។ ព្រះរាជទេវីទ្រង់ដណ្តប់សំពត់កម្ពលក្រហមមានតម្លៃមួយសែន ដែលជាព្រះពស្ត្រសម្រាប់ដណ្តប់របស់ព្រះរាជា ទ្រង់អង្គុយប្រាស្រ័យជាមួយព្រះរាជា ដោះព្រះទម្រង់ដែលមានតម្លៃមួយសែនអំពីព្រះអង្គុលីរបស់ព្រះរាជា មកពាក់ត្រង់ម្រាមដៃរបស់ព្រះទេវី ។ ក្នុងសម័យនោះ សត្វហត្ថីលិង្គ (ជាសត្វស្ទាប) ហើរមកតាមផ្លូវអាកាស ឃើញព្រះរាជទេវី ទើបសម្ទបស្ទាបបោះពួយចុះមកដោយសំគាល់ថា ដុំសាច់ ។ ព្រះរាជាទ្រង់ស្ទុតព្រះទ័យដោយសំឡេងបោះពួយរបស់សត្វនោះ ទើបស្តេចគេចចូលទៅខាងក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជទេវីមិនអាចទៅដោយរហ័សបាន ព្រោះទ្រង់មានគភ៌ចាស់ផង និងព្រោះជាស្ត្រីមានជាតិជាអ្នកខ្លាចផង ។

គ្រានោះ បក្សីនោះទើបចាបយកព្រះនាងនោះទុកក្នុងក្រញាំជើង ហើរទៅកាន់អាកាស ។ បានឮថា ពួកបក្សីទាំងនោះ មានកម្លាំងស្មើនឹងដំរី ៥ ព្រោះដូច្នោះ ទើបនាំចំណីទៅតាមផ្លូវអាកាស ទំនៅក្នុងទីណាដែលពេញចិត្ត ហើយ រមែងទំពាស៊ីនូវសាច់នោះ ។ សូម្បីព្រះទេវីនោះដែលសត្វនាំទៅទ្រង់ភ័យខ្លាចដល់មរណៈ ទើបទ្រង់ត្រិះរិះថា “បើយើងស្រែក ធម្មតាសំឡេងមនុស្សជារបស់គួរខ្លាចនៃពួកសត្វតិរច្ឆាន សត្វនេះឮសំឡេងនោះហើយ នឹងទម្លាក់យើង បើដូច្នោះ យើងនឹងដល់នៅសេចក្ដីស្លាប់ព្រមជាមួយទារកក្នុងគភ៌ ចាំសត្វនេះចុះក្នុងទីណា ហើយផ្ដើមនឹងស៊ីយើង ក្នុងទីនោះយើងនឹងស្រែកឡើង ហើយទះដៃឲ្យវាផ្អើលរត់ចេញ” ។ ព្រះនាងក៏នៅស្ងៀមបាន ព្រោះព្រះនាងជាបណ្ឌិត ។ ក៏ក្នុងកាលនោះ ត្រង់ហិមវន្តប្រទេស មានដើមជ្រៃធំមួយដើម ចម្រើនឡើងតិចតួចតាំងនៅដូចជាមណ្ឌប ។ បក្សីនោះនាំចំណីមានសាច់ជាដើមទៅ ហើយរមែងស៊ីត្រង់ដើមជ្រៃនោះ ព្រោះដូច្នោះ សត្វហត្ថីលិង្គនោះ ទើបនាំព្រះរាជទេវីនោះ ទៅត្រង់ដើមជ្រៃនោះឯង ដាក់ទុកក្នុងចន្លោះនៃមែកឈើ ក្រឡេកមើលផ្លូវដែលខ្លួនហើរមកហើយ ។ ន័យ

ថា ការក្រឡេកមើលផ្លូវហើរមក គឺ ជាធម្មតារបស់សត្វទាំងនោះ ។ ក្នុងខណៈនោះ ព្រះទេវីទ្រង់ត្រិះរិះថា "ឥឡូវនេះគួរដេញសត្វនេះឲ្យរត់ហើយ" ទើបទ្រង់លើកព្រះហស្តទាំង ២ ឡើងទះផ្ទប់គ្នា ព្រមទាំងស្រែកបង្អើលឲ្យសត្វនោះរត់ចេញទៅ ។ គ្រានោះ ក្នុងវេលាព្រះអាទិត្យអស់ស្តង្គត ខ្យល់កម្មជវាទបក់បោកហើយក្នុងព្រះគភ៌របស់ព្រះទេវីនោះ ។ មហាមេឃស្រែកគំរាម ហើយតាំងឡើងគ្រប់ទិស ។ ឈ្មោះថា ការលក់រមែងមិនមានអស់មួយយប់ទល់ភ្លឺដល់ព្រះទេវីដែលធ្លាប់តែតាំងនៅក្នុងសេចក្តីសុខ មិនបានត្រឹមតែពាក្យពោលថា "កុំខ្លាចឡើយ ព្រះនាងម្ចាស់" ចំពោះបុគ្គលដែលមានសេចក្តីទុក្ខគ្របសង្កត់ហើយ ។ តែកាលកន្លងរាត្រីហើយ ការភ្លឺស្រឡះចាកវលាហកក្តី ការរះឡើងនៃអរុណក្តី ការប្រសូត្រនៃសត្វដែលនៅក្នុងគភ៌របស់ព្រះនាងក្តី បានមានហើយក្នុងខណៈជាមួយគ្នានោះឯង ។ ព្រះនាងបានតាំងឈ្មោះព្រះឱរសថា "ឧទេន" ព្រោះកាន់យកកាលនៃមេឃនិងកាលនៃអរុណរះឡើង ហើយប្រសូត្រ ។

ទីនៅសូម្បីរបស់អល្លកប្បតាបស ក៏នៅមិនឆ្ងាយអំពីទីនោះ ។ ជា

ប្រក្រតីក្នុងថ្ងៃមានភ្លៀង ព្រះតាបសនោះរមែងមិនទៅកាន់ព្រៃដើម្បីប្រយោជន៍ដល់ផលាផល ព្រោះខ្លាចរងា ទៅកាន់គល់ឈើនោះ រើសឆ្អឹង និងសាច់ដែលសត្វស៊ីហើយ ជំស្ងោរឲ្យមានរសហើយ ក៏បរិភោគ ព្រោះដូច្នោះ សូម្បីក្នុងថ្ងៃនោះ ព្រះតាបសក៏គិតថា នឹងរើសឆ្អឹង ទើបទៅត្រង់ដើមឈើនោះ ស្វែងរកឆ្អឹងត្រង់គល់ឈើ បានឮសំឡេងក្មេងខាងលើ ទើបក្រឡេកមើលឃើញព្រះទេវី ទើបសួរថា "អ្នកជានរណា" ។

ព្រះទេវី. ខ្ញុំជាមនុស្សស្រី ។

តាបស. នាងមកបានយ៉ាងណា? កាលព្រះនាងពោលថា "សត្វហត្ថីលិង្គនាំខ្ញុំមក" ទើបពោលថា "នាងចូរចុះមក" ។

ព្រះទេវី. ខ្ញុំខ្លាចដល់ការលាយដោយជាតិ លោកម្ចាស់ ។

តាបស. នាងជានរណា ។

ព្រះទេវី. ខ្ញុំជាក្សត្រ ។

តាបស. សូម្បីខ្ញុំក៏ជាក្សត្រដូចគ្នា ។

ព្រះទេវី. បើដូច្នោះ លោកចូរថ្លែងមាយាក្សត្រមកមើល ។

ព្រះតាបសនោះ ក៏បានថ្លែងហើយ ។

ព្រះទេវី. បើដូច្នោះ លោកចូរឡើងមកនាំបុត្រតូចរបស់ខ្ញុំចុះ ។

ព្រះតាបសនោះក៏ធ្វើផ្លូវឡើងទៅហើយ ទទួលយកក្មេង កាលព្រះរាជទេវីពោលហាមថា "កុំយកដៃប៉ះខ្ញុំ" ក៏មិនប៉ះព្រះនាងឡើយ ហើយឱបក្មេងចុះមក ។ សូម្បីព្រះរាជទេវីក៏ចុះដែរ ។ គ្រានោះ ព្រះតាបសនាំព្រះនាងទៅកាន់អាស្រមបទ មិនធ្វើសីលភេទឡើយ ទំនុកបម្រុងដោយសេចក្តីអនុគ្រោះ នាំទឹកឃ្មុំដែលមិនមានកូនមក នាំស្រូវសាលីដែលកើតឯងមកបានដាំជាយាគូឲ្យហើយ ។ កាលព្រះតាបសនោះទំនុកបម្រុងយ៉ាងនោះ ក្នុងកាលដទៃ ព្រះនាងទើបគិតថា យើងមិនស្គាល់ផ្លូវមក និងផ្លូវទៅឡើយ សូម្បីហេតុត្រឹមតែការធ្លាប់ស្គាល់របស់យើងជាមួយតាបសនេះ ក៏មិនមានឡើយ ប្រសិនបើ ព្រះតាបសនេះនឹងទុកយើងចោល ទៅណាបាត់ យើងទាំងពីរនាក់ក៏នឹងដល់សេចក្តីស្លាប់ក្នុងទីនេះឯង គួរយើងធ្វើឧបាយណាមួយទម្លាយសីលរបស់ព្រះតាបសរូបនេះចេញ ធ្វើដោយអាការដែលតាបសរូបនេះមិនអាចលះបង់យើងបាន ។ ពេលនោះ ព្រះរាជទេវីទើបប្រលោមលួង

លោមតាបសដោយការសំដែង (ធ្វើឲ្យ) សំពត់ស្លៀក សំពត់ដណ្តប់របូត ឲ្យដល់នូវការវិនាសនៃសីលហើយ ។ តាំងពីថ្ងៃនោះមក ជនទាំងពីរក៏នៅសមគ្គសង្វាស (ជាស្វាមីភរិយា) ជាមួយគ្នាទៅ ។

តមកថ្ងៃមួយ ព្រះតាបសត្រួតមើលការប្រកបនៃផ្កាយនក្ខត្តឫក្ស ឃើញការស្រអាប់នៃផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបរន្តបៈ ទើបពោលថា "នាងដ៏ចម្រើន ព្រះបាទបរន្តបៈក្នុងក្រុងកោសម្ពីសុគតហើយ ។

ព្រះទេវី. ហេតុអ្វី លោកម្ចាស់ទើបពោលយ៉ាងនេះ លោកម្ចាស់មានសេចក្តីអាឃាតជាមួយព្រះបាទបរន្តបៈនោះឬ ។

តាបស. មិនមានទេ នាងដ៏ចម្រើន យើងឃើញសេចក្តីសៅហ្មងរបស់ផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបរន្តបៈ ទើបនិយាយយ៉ាងនេះ ។

ព្រះរាជទេវីក៏ទ្រង់កន្សែងហើយ ។ គ្រានោះ ព្រះតាបសទើបសួរព្រះទេវីនោះថា "ព្រោះហេតុអ្វី ទើបនាងយំ" កាលព្រះរាជទេវីត្រាស់ប្រាប់សេចក្តីដែលព្រះបាទបរន្តបៈនោះជាព្រះស្វាមីរបស់ព្រះនាងហើយ ទើបពោលថា "កុំយំអី នាងដ៏ចម្រើន ធម្មតាសត្វដែលកើតហើយ រមែងស្លាប់ដោយ

ពិត" ។

ព្រះរាជទេវី. នាងខ្ញុំដឹង លោកម្ចាស់ ។

តាបស. បើដូច្នេះ ហេតុអ្វីនាងទើបយំ ។

ព្រះរាជទេវី. បុត្ររបស់នាងខ្ញុំជាអ្នកគួរដល់រាជសម្បត្តិដែលជារបស់ត្រកូល ប្រសិនបើគេនៅក្នុងក្រុងនោះ គេនឹងឲ្យលើស្វេតច្ឆត្រឡើង ឥឡូវនេះ គេកើតជាអ្នកវិនាសធំហើយ ព្រោះសេចក្ដីសោកនេះឯង ខ្ញុំទើបយំលោកម្ចាស់ ។

តាបស. ណ្ហើយចុះ នាងដ៏ចម្រើន កុំគិតឡើយ បើនាងប្រាថ្នារាជសម្បត្តិឲ្យបុត្រ ខ្ញុំនឹងធ្វើឲ្យគេបានរាជសម្បត្តិ (សមដូចតាមប្រាថ្នា) ។

គ្រានោះ ព្រះតាបសបានឲ្យពិណ និងមន្តដែលញ៉ាំងដំរីឲ្យគាប់ចិត្តដល់បុត្ររបស់ព្រះនាងហើយ ។ ក្នុងកាលនោះ ដំរីច្រើនសែនមកប្រជុំគ្នានៅក្រោមដើមឈើជ្រៃក្រឹម ។ លំដាប់នោះ ព្រះតាបសទើបពោលជាមួយកុមារនោះថា "កាលដំរីទាំងឡាយមិនទាន់មកដល់ កូនចូលឡើងដើមឈើកាលដំរីទាំងឡាយមកដល់ហើយ ចូរាយមន្តបទនេះ ដេញខ្សែពិណនេះ

ដំរីទាំងអស់មិនអាចនឹងងាកមកមើល នឹងរត់ចេញទៅ ពេលនោះ កូនគប្បី ចុះមក" ។ កុមារនោះទ្រង់ធ្វើតាមនោះ ហើយត្រឡប់មកទូលប្រាប់ការប្រព្រឹត្ត ទៅនោះឯង ។ លុះថ្ងៃទី ២ ព្រះតាបស ទើបពោលជាមួយកុមារនោះថា "ក្នុងថ្ងៃនេះ កូនចូរវាយមន្តបទនេះ ដេញខ្សែពិណនេះ ដំរីនឹងត្រឡប់មើល ខាងក្រោយបណ្ដើរ រត់ទៅបណ្ដើរ" ។ សូម្បីក្នុងកាលនោះ ព្រះកុមារក៏ទ្រង់ ធ្វើតាមនោះ ហើយត្រឡប់មកទូលប្រាប់ការប្រព្រឹត្តទៅនោះ ។ គ្រានោះ ព្រះតាបសហៅព្រះមាតារបស់កុមារនោះមក ហើយពោលថា នាងដ៏ចម្រើន នាងចូរឲ្យដំណឹងដល់បុត្ររបស់នាង គេទៅអំពីនេះហើយ នឹងជាស្ដេចផែន ដី ។ ព្រះទេវីត្រាស់ហៅព្រះឱរសមក ហើយត្រាស់ថា កូនជាឱរសរបស់ ព្រះបាទបរន្តបៈក្នុងក្រុងកោសម្ពី សត្វហត្ថីលិង្គ នាំយើងមកខណៈដែលមាន គភ៌ ហើយត្រាស់ប្រាប់ឈ្មោះរបស់សេនាបតីជាដើម និងត្រាស់ថា បើគេ មិនជឿ កូនគប្បីសំដែងសំពត់កម្ពលដែលជាព្រះភូសាជណ្ដប់ និងព្រះទម្រង់ ដែលជាគ្រឿងប្រដាប់របស់ព្រះបិតានេះ ទើបឲ្យទ្រង់យានទៅ ។ ព្រះកុមារ ទើបទូលសួរព្រះតាបសថា ឥឡូវនេះ ខ្ញុំនឹងធ្វើអ្វី ។ តាបសពោលថា កូន

ចូរអង្គុយស្ងៀមក្រោមដើមឈើ រាយមន្តបទនេះ ដេញខ្សែពិណនេះ ដំរីដែលជាមេហ្វូងនឹងបង្អោនខ្នងមករកកូន កូនអង្គុយលើខ្នងមេដំរីនោះហើយ ចូរទៅកាន់យករាជសម្បត្តិចុះ ។ ព្រះកុមារនោះថ្វាយបង្គំព្រះរាជបិតា ព្រះរាជមាតាហើយ ទ្រង់ក៏ធ្វើតាមនោះ អង្គុយខាងលើខ្នងដំរីដែលមកហើយ ខ្សឹបប្រាប់ត្រចៀកដំរីថា ខ្ញុំជាបុត្ររបស់ព្រះបាទបរន្តបៈក្នុងក្រុងកោសម្ពី សូមអ្នកចូរកាន់យករាជសម្បត្តិដែលជារបស់បិតាឲ្យដល់ខ្ញុំផងចុះ ។ ដំរីជាមេហ្វូងស្តាប់ពាក្យនោះហើយ ទើបស្រែកជាសំឡេងដំរីថា ដំរីចូរមកប្រជុំគ្នាច្រើនៗពាន់ ។ ដំរីច្រើនពាន់មកប្រជុំគ្នាហើយ ។ ស្រែកទៀតថា ដំរីចាស់ៗ ចូរថយក្រោយទៅ ។ ដំរីចាស់ៗ ក៏នាំគ្នាថយក្រោយ ។ ស្រែកទៀតថា ដំរីក្មេងៗ ចូរមក ។ សូម្បីដំរីទាំងនោះក៏នាំគ្នាមកហើយ ។ ព្រះកុមារដែលដំរីចម្បាំងច្រើនរយពាន់ នាំគ្នាហែហមហើយ មកដល់ស្រុកជាយដែន ក៏បានប្រកាសថា យើងជាឱរសរបស់ស្តេចផែនដី អ្នកដែលប្រាថ្នាសម្បត្តិចូរមកជាមួយយើង ។ តាំងអំពីនេះមក ទ្រង់ក៏ធ្វើការរួបរួមមនុស្សទៅឡោមព័ទ្ធព្រះនគរ ហើយបញ្ជូនដំណឹងទៅថា នឹងឲ្យចម្បាំង ឬនឹងឲ្យរាជសម្បត្តិ ។ ពួក

អ្នកស្រុកទាំងឡាយពោលថា យើងមិនឲ្យទាំងពីរយ៉ាង ព្រោះថា ព្រះទេវី របស់ពួកយើងមានព្រះគភ៌ចាស់ ត្រូវសត្វហត្ថីលិង្គនាំយកទៅ យើងទាំងឡាយ មិនដឹងថា ព្រះនាងនៅមានព្រះជន្ម ឬថាអស់ព្រះជន្មនៅឡើយ អស់កាល ដែលយើងមិនជ្រាបរឿងរាវរបស់ព្រះនាង យើងនឹងមិនឲ្យទាំងការច្បាំង និងរាជសម្បត្តិ ។ បានឮថា ភាពជាស្តេចផែនដី ព្រោះការបន្តវង្សស្រឡាយ បានមានហើយក្នុងកាលនោះ ។ លំដាប់នោះ ព្រះកុមារទើបត្រាស់ថា យើងជាបុត្ររបស់ព្រះនាង ហើយរឭកឈ្មោះរបស់សេនាបតីជាដើម ។ កាលជនទាំងនោះមិនជឿ ទើបសំដែងសំពត់កម្ពលក្រហម និងព្រះទម្រង់ ។ ពួកអ្នកក្រុងចាំសំពត់កម្ពលក្រហម និងព្រះទម្រង់នោះបាន អស់ការសង្ស័យ ទើបបើកទ្វារ អភិសេកកុមារនោះទុកក្នុងរាជសម្បត្តិ ។

" នេះជារឿងនៃព្រះឧទេន "

## ប្រវត្តិឃោសកសេដ្ឋី

ក៏កាលទុរ្ភិក្ខភ័យកើតហើយក្នុងដែនអល្លកប្បៈ បុរសម្នាក់ឈ្មោះថា កោតុហលិកៈ មិនអាចនឹងរស់នៅបាន ទើបនាំភរិយាឈ្មោះកាឡី និងបុត្រតូច រៀបចំស្បៀងចេញទៅហើយ ដោយបំណងថា នឹងទៅរកស៊ីក្នុងក្រុងកោសម្ពី ។ អាចារ្យពួកខ្លះពោលថា គេចេញទៅហើយ ក្នុងកាលមហាជនកំពុងស្លាប់ដោយរោគអហិវាត ។ ពីរនាក់ស្វាមីភរិយានោះដើរទៅ កាលស្បៀងដើរផ្លូវអស់ហើយ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ មិនអាចនឹងនាំក្មេងទៅបាន ។ គ្រានោះ ស្វាមីទើបពោលចំពោះភរិយាថា នាង កាលយើងមានជីវិតក៏នឹងបានកូនទៀត ទុកគេចោលទៅ ហើយទៅចុះ ។ ធម្មតាថា ទឹកចិត្តរបស់មាតាជាធម្មជាតិទន់ ព្រោះហេតុនោះ នាងទើបនិយាយថា ខ្ញុំមិនអាចបោះបង់កូនដែលនៅមានជីវិតបានទេ ។

ស្វាមី. បើដូច្នោះ យើងនឹងធ្វើដូចម្តេច ។

ភរិយា. យើងគប្បីផ្លាស់ប្តូរគ្នា (បី) នាំគេទៅ ។ មាតាលើកកូនឡើងប្រៀបបីដូចជាកម្រងផ្កា ក្នុងវារៈនៃខ្លួន ក៏ឱបផ្ទប់ត្រង់ទ្រូងឲ្យក្បាល

ផ្អែកត្រង់.កខ្វះ បីកូនត្រង់ចង្កេះខ្វះ ហើយទៅ ទើបឲ្យដល់បិតា ។ វេទនាមានដ៏កម្លាំងខ្លាំងជាងសេចក្តីស្រេកឃ្លាន បានកើតដល់បុរសជាស្វាមីនោះក្នុងពេលដែលគេទទួលកូន ហើយបី ។ គេក៏និយាយចំពោះភរិយានោះនិយាយថា នាង កាលយើងនៅមានជីវិតនៅ នឹងបានកូន (ទៀត) យើងលះបង់កូននេះចុះ ។ សូម្បីភរិយា ក៏ហាមស្វាមីច្រើនដង ហើយក៏ស្ងៀមដើរទៅ ។ កុមារតូចត្រូវផ្លាស់ប្តូរគ្នាតាមវារៈ អស់កម្លាំងក៏ដេកលក់នៅក្នុងដៃរបស់បិតា ។ បុរសជាស្វាមីដឹងថា កូនប្រុសនោះលក់ ទើបប្រាប់ឲ្យភរិយាដើទៅខាងមុខមុន ហើយយកកូនដាក់ឲ្យដេកលើកម្រាលស្លឹកឈើត្រង់គុម្ពោតឈើមួយកន្លែងហើយក៏ដើរតាមទៅ ។ ភរិយាក្រឡេកមើលមកខាងក្រោយ មិនឃើញកូន ទើបសួរថា នាយ កូនរបស់យើងទៅណា ។

ស្វាមី. ខ្ញុំឲ្យគេដេកនៅក្រោមគុម្ពោតឈើមួយកន្លែង ។

ភរិយាពោលថា នាយ កុំធ្វើឲ្យខ្ញុំវិនាសឡើយ ខ្ញុំបាត់បង់កូនហើយមិនអាចរស់នៅបានឡើយ នាយនាំកូនខ្ញុំមកវិញ ។ ហើយឱបក្បាលជន្គង់យំរៀបរាប់ ។ គ្រានោះ បុរសជាស្វាមីទើបត្រឡប់ទៅយកកូននោះមក ។

កូននោះក៏បានស្លាប់ហើយក្នុងរវាងផ្លូវនោះ ។ នាយកោតុហលិកៈបង់បោះកូនចោលក្នុងឋានៈមានប្រមាណប៉ុណ្ណោះ ទើបត្រូវគេបង់បោះបង់ចោលអស់ ៧ ដង ក្នុងរវាងភព ដោយផលនៃកម្មនោះ ដោយប្រការដូច្នេះ ។ ឈ្មោះថា បាបកម្មនេះ បុគ្គលមិនគប្បីប្រមាទថា "តិចតួច" ។ ពីរនាក់ស្វាមីភរិយានោះ ដើរផ្លូវទៅដល់ត្រកូលរបស់អ្នកចិញ្ចឹមគោមួយកន្លែង ។

ក៏ក្នុងថ្ងៃនោះ មានការធ្វើបុណ្យខួបមេគោយកទឹកដោះរបស់នាយគោបាល ។ ក្នុងផ្ទះរបស់នាយគោបាល មានព្រះបច្ចេកពុទ្ធមួយព្រះអង្គនិមន្តឆាន់ជានិច្ច ។ នាយគោបាលនោះ និមន្តព្រះបច្ចេកពុទ្ធឆាន់ស្រេចហើយ ទើបបានធ្វើមង្គល ។ គេចាត់ចែងបាយបាយាសទុកដ៏ច្រើន ។ នាយគោបាលឃើញ ២ នាក់ស្វាមីភរិយានោះមក ទើបសួរថា លោកមកអំពីទីណា ។ ជ្រាបរឿងនោះហើយ ដែលលោកជាកុលបុត្រមានចិត្តមេត្តា ទើបធ្វើសេចក្តីអនុគ្រោះក្នុង ២ នាក់ស្វាមីភរិយានោះ ឲ្យបាយបាយាសលាយជាមួយទឹកដោះដ៏ច្រើន ។ ភរិយាបានពោលនឹងស្វាមីថា នាយ កាលលោកមានជីវិតហើយ ខ្ញុំក៏ឈ្មោះថា មានជីវិតដែរ លោកអត់អាហារមកយូរហើយ

ចូរបរិភោគតាមសេចក្តីត្រូវការចុះ ទើបបានដាក់បាយបាយាសទុកខាងមុខគេ ព្រមទាំងទឹកដោះ ខ្លួនឯងបរិភោគសប្បិរាវតែបន្តិចបន្តួចប៉ុណ្ណោះ ។ ចំណែក នាយកោតុហលិកៈបរិភោគច្រើនហើយ ក៏មិនអាចបំបាត់សេចក្តីលំបាកក្នុង អាហារបាន ព្រោះខ្លួនឃ្លានមកអស់ ៧-៨ ថ្ងៃមកហើយ ។ នាយគោបាល គ្រាឲ្យបាយបាយាសដល់ ២ ប្តីប្រពន្ធនោះហើយ ខ្លួនឯងទើបផ្តើមបរិភោគ ។ នាយកោតុហលិកៈអង្គុយមើលគេហើយ ឃើញដុំបាយបាយាសដែលនាយ គោបាលដាក់ឲ្យដល់មេឆ្កែ ដែលដេកនៅខាងក្រោមតាំង ទើបគិតថា មេឆ្កែ នេះមានបុណ្យ ទើបបានភោជនបែបនេះជានិច្ច ។ ក្នុងកណ្តាលយប់ នាយ កោតុហលិកៈនោះ មិនអាចទឹងញាំងបាយបាយាសនោះឲ្យរលាយបាន ទើប ធ្វើកាលៈ ទៅកើតក្នុងពោះនៃមេឆ្កែនោះ ។ គ្រានោះ ភរិយារបស់គេធ្វើ សរីរកិច្ច (ដុត) ហើយ ក៏ធ្វើជាអ្នកបម្រើក្នុងផ្ទះនោះឯង បានអង្ករមួយ នាឡិ ចម្អិនហើយ យកដាក់បាត្រព្រះបច្ចេកពុទ្ធហើយពោលថា លោកម្ចាស់ សូមកុសលនេះចូរសម្រេចដល់ទាសៈរបស់លោកម្ចាស់ផង ។ ដូច្នេះ ទើប គិតថា យើងគួរនឹងនៅក្នុងទីនេះឯង ព្រោះលោកម្ចាស់អង្គនេះរមែងមកក្នុង

ទីនេះរឿយៗ ទោះបីធម៌មាន ឬមិនមានក៏ដោយចុះ យើងនឹងថ្វាយបង្គំធ្វើសេចក្ដីខ្វល់ខ្វាយ ញុំាងចិត្តឲ្យជ្រះថ្លារាល់ថ្ងៃ និងបានបុណ្យច្រើន (គិតដូច្នេះហើយ) នាងទើបធ្វើជាអ្នកបម្រើនៅក្នុងផ្ទះនោះឯង ។

ក្នុងខែទី ៦ ឬទី ៧ មេឆ្កែនោះឯងក៏កើតកូនបានមួយ ។ នាយគោបាល ទើបឲ្យទឹកដោះរបស់មេគោមួយក្បាលដល់កូនឆ្កែនោះ ។ មិនយូរប៉ុន្មាន កូនឆ្កែនោះក៏ធំឡើង ។ គ្រានោះ ព្រះបច្ចេកពុទ្ធកាលឆាន់ រមែងឲ្យដុំបាយដល់សុនខនោះមួយដុំៗ ជានិច្ច ។ នាយគោបាលរមែងទៅកាន់ទំនុកបម្រុងរបស់ព្រះបច្ចេកពុទ្ធ (មួយថ្ងៃ) ២ ដងជានិច្ច ។ នាយគោ-បាលនោះ សូម្បីដើរទៅ ក៏យកឈើវាយត្រង់គុម្ពោតព្រៃ និងផែនដី ក្នុងទីដែលមានសត្វសាហាវក្នុងរវាងផ្លូវ បញ្ចេញសំឡេងថា "សុ សុ" ៣ ដងដេញសត្វសាហាវឲ្យចៀសចេញទៅ ។ សូម្បីសុនខក៏ទៅជាមួយនាយគោ-បាលនោះ ។ ក្នុងថ្ងៃមួយ នាយគោបាលនោះពោលនឹងព្រះបច្ចេកពុទ្ធ ថាលោកម្ចាស់ដ៏ចម្រើន កាលណាខ្ញុំម្ចាស់មិនមានឱកាសទំនេរ កាលនោះខ្ញុំម្ចាស់នឹងបញ្ជូនសុនខនេះមក ។ សូមលោកម្ចាស់គប្បីនិមន្តមកដោយគ្រឿង

សម្គាល់នៃសុនខនេះ ដែលខ្ញុំម្ចាស់បញ្ជូនមកហើយ ។ តអំពីនោះមក ក្នុងថ្ងៃដែលមិនមានឱកាស នាយគោបាលនោះក៏បញ្ជូនសុនខទៅថា បាចូរទៅ ចូរនាំលោកម្ចាស់មក ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ សុនខនោះក៏រត់ទៅ ដល់ទីដែលនាយគេបាលវាយគុម្ពោតព្រៃ និងផែនដី ក៏ព្រុសឡើង ៣ ដង ដឹងថា សត្វសាហាវចៀសចេញទៅហើយដោយសំឡេងនោះ ទៅដល់ទីនៅ របស់ព្រះបច្ចេកពុទ្ធដែលទ្រង់ធ្វើសរីរៈបដិបត្តិអំពីព្រឹកព្រលឹម ហើយចូល ទៅកាន់បណ្ណសាលាគង់ចាំ ពេលទៅដល់ទ្វារបណ្ណសាលា ទើបព្រុស ៣ ដង បញ្ជូនសញ្ញាឲ្យដល់ព្រះអង្គដឹងថា ខ្ញុំនមកហើយ ដេកនៅត្រង់ចំណែក ម្ខាង ។ ព្រះបច្ចេកពុទ្ធកាលទតឃើញសុនខ ទើប (ធ្វើជា) និមន្តទៅផ្លូវ ដទៃក្នុងចន្លោះៗ នៃផ្លូវ ។ ពេលនោះ សុនខទើបឈរពាំងអំពីខាងមុខ របស់ព្រះបច្ចេកពុទ្ធ ហើយនាំលោកទៅកាន់ផ្លូវក្រៅពីនេះ ។ តមកថ្ងៃមួយ ព្រះបច្ចេកពុទ្ធកាលទតឃើញសុនខនោះ ទើបដើរទៅតាមផ្លូវដទៃ សូម្បី សុនខនោះឈរពាំងអំពីខាងមុខ ក៏ទ្រង់មិនត្រឡប់ យកជើងកៀសសុនខ ហើយនិមន្តទៅ ។ សុនខដឹងថា ព្រះបច្ចេកពុទ្ធមិនត្រឡប់ ទើបរត់ទៅខាំ

ទាញជាយសំពត់នាំមក នាំលោកមកកាន់ផ្លូវដទៃវិញ ។ សុនខនោះបាន ញុំាងសេចក្ដីស្រឡាញ់ដ៏មានកម្លាំងឲ្យកើតឡើងហើយ ក្នុងព្រះបច្ចេកពុទ្ធ នោះ ដោយប្រការដូច្នេះ ។ តមកក្នុងកាលដទៃ ចីវររបស់ព្រះបច្ចេកពុទ្ធ ចាស់ហើយ ។ គ្រានោះ នាយគោបាលបានថ្វាយសំពត់សម្រាប់ធ្វើចីវរ ដល់លោក ។ ព្រះបច្ចេកពុទ្ធពោលជាមួយនាយគោបាលនោះថា អ្នកមាន អាយុ ឈ្មោះថា ការធ្វើចីវរ ដែលបុគ្គលម្នាក់ធ្វើបានដោយលំបាក អាត្មា ទៅកាន់ទីដែលសប្បាយហើយ នឹងធ្វើ ។

នាយគោបាល. លោកម្ចាស់ដ៏ចម្រើន និមន្តធ្វើទីនេះចុះ ។

ព្រះបច្ចេកពុទ្ធ. អ្នកមានអាយុ អាត្មាមិនអាច ។

នាយគោបាល. លោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់ កុំទៅយូរពេក ។

សុនខបានឈរស្ដាប់ពាក្យរបស់អ្នកទាំងពីរនោះ ។ ព្រះបច្ចេកពុទ្ធ ពោលចំពោះនាយគោបាលនោះថា ចូរឈប់ចុះ ឧបាសក ឲ្យនាយគោបាល ត្រឡប់វិញហើយ ក៏ហោះឡើងកាន់វេហាស៍ ឆ្ពោះមុខទៅកាន់ភ្នំគន្ធមាទន៍

លោកនិមន្តទៅហើយ ។ សុនខសម្លឹងមើលព្រះបច្ចេកពុទ្ធ ដែលហោះទៅតាមអាកាស ឈរសម្លឹងមើលរហូត កាលព្រះបច្ចេកពុទ្ធនោះកន្លងចក្ខុទៅ ហឫទ័យក៏បែក (ស្លាប់) ។

## សុនខទៅកើតជាឃោសកទេវបុត្រ

ឈ្មោះថា សត្វតិរច្ឆានទាំងឡាយនោះ ជាសត្វមានជាតិស្មោះត្រង់មិនវៀចវេរ ចំណែកមនុស្សចិត្តគិតផ្សេង មាត់និយាយផ្សេង (មិនដូចគ្នា) ព្រោះហេតុនោះ នាយបេសរ្ស:ជាបុត្ររបស់ហ្មដំរីទើបពោលថា "បពិត្រព្រះអង្គដ៏ចម្រើន ពិតហើយ ខ្ញុំបព្វក: គឺ មនុស្សនេះ សាំញ៉ាំ បពិត្រព្រះអង្គដ៏ចម្រើន ពិតហើយ ខ្ញុំបព្វក: គឺ សត្វចិញ្ចឹមនេះស្លូតត្រង់" ។ សុនខនោះធ្វើកាល:ហើយ ទៅកើតក្នុងស្ថានតាវតឹង្ស មាននាងអប្សរ ១ ពាន់ហែហម បានសោយសម្បត្តិធំ ក៏ព្រោះជាសត្វមានការឃើញត្រង់ (និង) មិនវៀចវេរ ដោយប្រការដូចច្នោះ ។ កាលទេវបុត្រនោះខ្សឹបត្រង់ត្រចៀករបស់នរណាៗ សំឡេងរមែងឮបានចម្ងាយ ១៦ យោជន៍ ចំណែកសំឡេងនិយាយដោយប្រក្រតី រមែងឮទូទាំងទេវនគរទាំងនោះឯង ដែលមានប្រមាណ

មួយម៉ឺនយោជន៍ ព្រោះហេតុនោះ ទេវបុត្រនោះទើបបានឈ្មោះថា “ឃោសក-ទេវបុត្រ” នេះជាផលនៃអ្វី ។ ជាផលនៃការព្រួសដោយសេចក្ដីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ។ ឃោសកទេវបុត្រនោះ តាំងនៅក្នុងទេវនគរនោះមិនយូរក៏ចុតិហើយ ។

ពិតហើយ ទេវបុត្រទាំងឡាយរមែងចុតិចាកទេវលោក ដោយហេតុ ៤ យ៉ាង គឺ ៖

១. ដោយការអស់អាយុ

២. ដោយការអស់បុណ្យ

៣. ដោយការអត់អាហារ

៤.ដោយសេចក្ដីក្រោធ

ក្នុងហេតុ ៤ យ៉ាងនោះ ទេវបុត្តអង្គណា ធ្វើបុណ្យទុកច្រើន ទេវបុត្តអង្គនោះ កើតក្នុងទេវលោកតាំងនៅដរាបអស់អាយុ ក៏កើតក្នុងទេវលោកជាន់ខ្ពស់ៗ ឡើងទៅ ឈ្មោះថា រមែងចុតិដោយការអស់អាយុ ។ ទេវបុត្រអង្គណា ធ្វើបុណ្យតិច បុណ្យនោះរបស់ទេវបុត្រនោះ រមែងអស់ទៅក្នុងរវាង

ពាក់កណ្ដាលអាយុ ដូចធញ្ញជាតិ ដែលបុគ្គលដាក់ទុកក្នុងជង្រុកជំត្រឹមតែ ៤-៥ នាទ្បិ ទេវបុត្រនោះរមែងចុតិក្នុងវិមាននោះឯង យ៉ាងនេះ ឈ្មោះថា រមែងចុតិព្រោះការអស់បុណ្យ ។ ទេវបុត្រអង្គខ្លះ ស្រវឹងដោយការបរិភោគកាមគុណ មិនបរិភោគអាហារ ព្រោះការភ្លេចសតិ មានកាយហត់នឿយ ក៏ចុតិ យ៉ាងនេះឈ្មោះថា រមែងចុតិព្រោះការអត់អាហារ ។ ទេវបុត្រអង្គខ្លះ អត់ទ្រាំមិនបានក្នុងសម្បត្តិអ្នកដទៃ ក៏ខឹងក្រោធ រមែងចុតិ យ៉ាងនេះ ឈ្មោះថា រមែងចុតិព្រោះសេចក្ដីក្រោធ ។ ក៏ឃោសកទេវបុត្រនេះស្រវឹងក្នុងការបរិភោគកាមគុណ ភ្លេចសតិ ទើបចុតិដោយការអត់អាហារ ។ ក៏គ្រាចុតិហើយ ទៅបដិសន្ធិក្នុងផ្ទៃនៃស្រីសោភិនីម្នាក់ក្នុងក្រុងកោសម្ពី ។ ក្នុងថ្ងៃប្រសូត្រ នាងសួរទាសីថា ភេទអ្វី ។ កាលនាងទាសីឆ្លើយថា កូនប្រុសនាងម្ចាស់ ។ ទើបប្រាប់ឲ្យនាងទាសីយកទៅចោល ដោយពាក្យថា នាងយកទារកនេះដាក់ចង្អេរហើយ យកទៅចោលត្រង់គំនរសម្រាម ។ ពិតហើយ ស្ត្រីផ្កាមាសទាំងឡាយ រមែងចិញ្ចឹមកូនស្រី មិនចិញ្ចឹមកូនប្រុស ព្រោះការបន្តវង្សរបស់ពួកនាងនឹងជាប់ទៅបានក៏ដោយកូនស្រី ។ ក្អែកខ្លះ

សុនខខ្វះ នាំគ្នាជាក្រុមហោមព័ទ្ធការពារទារកនោះ ។ ដោយផលនៃការព្រុស (ដោយផលបុណ្យ) ដែលកើតពីសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ សត្វសូម្បីតែមួយក៏មិនអាចចូលជិតបាន ។ ក្នុងខណៈនោះ បុរសម្នាក់ចេញទៅខាងក្រៅស្រុក ឃើញក្រុមនៃពពួកក្អែក និងសុនខនោះ គិតថា តើមានហេតុអ្វីហ្ន៎ ទើបដើរទៅទីនោះ ឃើញទារក ក៏កើតសេចក្តីស្រឡាញ់ដូចជាកូន ទើបនាំទៅកាន់ផ្ទះដោយរីករាយថា យើងបានកូនប្រុសហើយ ។

## ឃោសកទារកត្រូវបោះបង់ចោល

ក្នុងសម័យនោះ សេដ្ឋីអ្នកក្រុងកោសម្ពី ទៅកាន់រាជត្រកូល ជួបបុរោហិតដើរមកពីរាជវាំង ទើបសួរថា លោកអាចារ្យ ថ្ងៃនេះលោកមិនត្រួតមើលផ្កាយនក្ខត្តឫក្ស ដែលជាហេតុនៃគ្រោះល្អ និងអាក្រក់ទេឬ ។

បុរោហិត. លោកមហាសេដ្ឋី កិច្ចអ្វីដទៃរបស់ពួកយើងមិនមាន ។

សេដ្ឋី. អ្វីនឹងមានដល់ជនបទឬ លោកអាចារ្យ ។

បុរោហិត. យ៉ាងដទៃមិនមាន តែទារកដែលកើតក្នុងថ្ងៃនេះ នឹងបានជាសេដ្ឋីដ៏ប្រសើរក្នុងក្រុងនេះ ។

គ្រានោះ ភរិយារបស់សេដ្ឋីក៏មានគភ៌ចាស់ ព្រោះដូច្នោះ សេដ្ឋីនោះទើបបញ្ជូនមនុស្សទៅកាន់ផ្ទះដោយរហ័សដោយពាក្យថា ចូរទៅ ចូរទៅមើលថា ភរិយារបស់យើងប្រសូត្រហើយឬនៅ ឬមិនទាន់ប្រសូត្រ ពេលដឹងថា នៅមិនទាន់ប្រសូត្រ គាល់ព្រះរាជាស្រេចហើយ ក៏ប្រញាប់ត្រឡប់មកផ្ទះ ហៅស្រីបម្រើឈ្មោះកាឡីមក ហើយឲ្យទ្រព្យ ១ ពាន់ ពោលថា នាងចូរទៅ ចូរដើរមើលក្នុងស្រុកនេះ ឲ្យទ្រព្យ ១ ពាន់ យកទារកដែលកើតក្នុងថ្ងៃនេះមក ។ នាងកាឡីនោះត្រួតមើល ទៅដល់ផ្ទះនោះ ឃើញក្មេងហើយ ទើបសួរស្រីមេផ្ទះថា ក្មេងនេះ កើតពេលណា ។ កាលស្រីនោះឆ្លើយថា កើតក្នុងថ្ងៃនេះ ។ ទើបនិយាយថា ចូរឲ្យក្មេងនេះមកខ្ញុំ ទើបប្រមូលតម្លៃតាំងពី ១ កហាបណៈ រហូតដល់ ១ ពាន់កហាបណៈ ហើយនាំក្មេងនោះទៅប្រគល់ឲ្យសេដ្ឋី ។ សេដ្ឋីគិតថា បើកូនរបស់យើងកើតមកជាកូនស្រី យើងនឹងឲ្យទារកនេះធ្វើជាស្វាមីកូនស្រី ហើយធ្វើឲ្យទារកនេះជាម្ចាស់ក្នុងតំណែងសេដ្ឋី បើកូនរបស់យើងកើតមកជាកូនប្រុស យើងនឹងសម្លាប់ទារកនេះ ដូច្នេះហើយ ទើបឲ្យចិញ្ចឹមក្មេងនោះទុកក្នុងផ្ទះ ។ តមក

ភរិយារបស់សេដ្ឋីនោះប្រសូត្របានកូនប្រុស ដោយកន្លងទៅ ២-៣ ថ្ងៃ ។ សេដ្ឋីទើបគិតថា ប្រសិនបើមិនមានក្មេងនេះ កូនប្រុសរបស់យើងនឹងបាន តំណែងជាសេដ្ឋី ឥឡូវនេះ យើងគួរនឹងសម្លាប់វា ។ ដូច្នេះហើយ ទើប ហៅនាងកាឡីមក ហើយពោលថា នាង ចូរទៅ ក្នុងវេលាដែលពួកគោ ចេញពីក្រោល នាងចូរយកក្មេងនេះឲ្យដេកត្រង់កណ្តាលទ្វារក្រោល មេគោ ទាំងឡាយនឹងជាន់វាឲ្យស្លាប់ តែ (នាង) ត្រូវចាំមើលថា តើគោជាន់វា ឬ មិនជាន់ សឹមមក ។ នាងកាឡីនោះទៅហើយ ពេលនាយគោបាលបើក ទ្វារក្រោលប៉ុណ្ណោះ ក៏ដាក់ក្មេងនោះឲ្យដេក (ដូចដែលសេដ្ឋីបង្គាប់) ។ គោឧសភៈដែលជាមេហ្វូង សូម្បីចេញក្រោយគោទាំងឡាយក្នុងវេលាមុនៗ (តែ) ក្នុងថ្ងៃនោះ ក៏ចេញទៅមុនគោដទៃ បានឈរគ្របទារកទុកក្នុងចន្លោះ ជើងទាំងបួន ។ មេគោច្រើនរយ ក៏នាំគ្នាដើរប្រជ្រៀតចេញត្រង់ចន្លោះ ទាំងពីរខាងរបស់គោឧសភៈនោះ ។ នាយគោបាល គិតថា គោឧសភៈនេះ កាលមុនចេញខាងក្រោយគោទាំងឡាយ តែថ្ងៃនេះ ចេញទៅមុនគេទាំងអស់ ហើយឈរស្ងៀមនៅត្រង់កណ្តាលទ្វារក្រោល តើមានហេតុអ្វីហ្ន៎ ទើបដើរ

ទៅ ឃើញទារកដេកនៅក្រោមពោះគោនោះ ក៏កើតសេចក្តីស្រឡាញ់ដូចបុត្រ ទើបនាំទៅកាន់ផ្ទះ ដោយគិតថា យើងបានកូនប្រុសហើយ ។ នាងកាឡីទៅហើយ ត្រូវសេដ្ឋីសួរ ទើបនិយាយរឿងនោះ ។ សេដ្ឋីពោលថា នាងចូរទៅ ចូរឲ្យទ្រព្យគេ ១ ពាន់កហាបណៈ ហើយនាំវាត្រឡប់មកវិញដូច្នោះ ហើយឲ្យទ្រព្យ ១ ពាន់កណាបណៈ បាននាំត្រឡប់មកឲ្យវិញ ។

គ្រានោះ សេដ្ឋីពោលចំពោះនាងកាឡីថា នាងកាឡី ក្នុងស្រុកនេះមានពួក (ឈ្មួញ) រទេះ ៥០០ ក្រោកឡើងពីងងឹត រមែងទៅជួញ នាងចូរយកក្មេងនេះទៅដាក់ឲ្យដេកត្រង់ផ្លូវរទេះ (ផ្លូវកង់) ពួកគោនឹងជាន់វាឬកង់រទេះនឹងកិន (ខ្ទេចវា) ពេលនាងដឹងរឿងរបស់វាហើយ សឹមត្រឡប់មក ។ នាងកាឡីនោះនាំកូននោះទៅហើយ ឲ្យដេកនៅត្រង់ផ្លូវរទេះ ។ ក្នុងកាលនោះ ប្រធានរទេះបានបរទៅខាងមុខ ។ គ្រានោះ គោរបស់គេទៅដល់ទីនោះហើយ នាំគ្នាជ្រែងចេញពីនឹម សូម្បីត្រូវនាយរទេះនោះដេញទៅច្រើនដង ក៏មិនដើរទៅមុខ ។ កាលគេនោះព្យាយាមជាមួយគោទាំងពីរនោះយ៉ាងនេះហើយ អរុណក៏រះឡើង ។ គេទើបគិតថា គោទាំងពីរនោះ

មិនទៅមុខព្រោះហេតុអ្វី ទើបមើលទៅផ្លូវ ឃើញទារក ទើបគិតថា កម្ម របស់យើងធ្ងន់ណាស់ ក៏មានចិត្តរីករាយថា យើងបានកូនប្រុសហើយ ទើប នាំក្មេងនោះទៅកាន់ផ្ទះ ។ នាងកាឡីទៅហើយ ត្រូវសេដ្ឋីសួរ ទើបការណ៍ នោះ ។ សេដ្ឋីក៏បញ្ជាថា នាងចូរទៅ ឲ្យទ្រព្យ (គេ) ១ ពាន់កហាបណៈ ហើយនាំក្មេងនោះត្រឡប់មក ដូច្នេះ នាងកាឡីបានធ្វើតាមនោះឯង ។

គ្រានោះ សេដ្ឋីពោលចំពោះនាងកាឡីនោះថា ឥឡូវនេះ នាងចូរនាំ វាទៅកាន់ព្រៃខ្មោច ហើយដាក់ឲ្យដេកត្រង់ចន្លោះគុម្ពឈើ វានឹងត្រូវសត្វ មានឆ្កែព្រៃជាដើមស៊ី ឬត្រូវអមនុស្សប្រហារឲ្យស្លាប់នៅក្នុងទីនោះ នាងដឹង ថា វាស្លាប់ហើយ ឬមិនទាន់ស្លាប់ ចាំត្រឡប់មក ។ នាងកាឡីនោះនាំ ក្មេងនោះទៅ ឲ្យដេកនៅត្រង់ព្រៃខ្មោចហើយ បានឈរក្នុងកន្លែងមួយ ។ ឆ្កែខ្លះ ក្អែកខ្លះ អមនុស្សខ្លះ មិនអាចចូលជិតទារកនោះបាន ។ មានពាក្យ សួរថា ក៏មាតាបិតា និងបណ្តាបងប្អូនជាដើម នរណាៗ ឈ្មោះថាជាអ្នក រក្សាក្មេងនោះមិនមានមិនមែនឬ នរណារក្សាក្មេងនោះទុក ។ ឆ្លើយថា កម្ម ត្រឹមតែការព្រុសប៉ុណ្ណោះ ដែលទារកនោះឲ្យប្រព្រឹត្តទៅហើយដោយសេចក្តី

ស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធក្នុងវេលាជាសុនខ រក្សាទារកនោះ ។ គ្រានោះ អ្នកចិញ្ចឹមពពែម្នាក់ នាំមេពពែច្រើនសែនក្បាលទៅរកស៊ីចំណី ដើរទៅជិតព្រៃខ្មោចនោះ ។ មេពពែមួយក្បាលស៊ីស្លឹកឈើជាដើម ហើយចូលទៅកាន់គុម្ពឈើឃើញទារក ក៏លុតជង្គង់ឲ្យទឹកដោះដល់ទារក ។ សូម្បីអ្នកចិញ្ចឹមពពែធ្វើសំឡេងថា ហែ ហែ ក៏ពពែមិនចេញទៅ ។ គេគិតថា នឹងយកឈើវាយដេញវាចេញ ទើបចូលទៅកាន់គុម្ពឈើ ឃើញមេពពែកំពុងឲ្យទឹកដោះដល់ទារក ទើបក៏កើតសេចក្តីស្រឡាញ់ក្នុងទារកដូចបុត្រ ទើបនាំយកទារកនោះទៅ ដោយគិតថា យើងបានកូនប្រុសហើយ ។ នាងកាឡីឃើញហេតុនោះហើយ ទើបទៅ , ត្រូវសេដ្ឋីសួរ ទើបប្រាប់ការប្រព្រឹត្តទៅនោះ ។ សេដ្ឋីក៏បញ្ជាថា នាងចូរឲ្យទ្រព្យ ១ ពាន់កហាបណៈដល់ (គេ) ហើយនាំទារកនោះត្រឡប់មកវិញ នាងបានធ្វើតាមនោះហើយ ។

គ្រានោះ សេដ្ឋីពោលចំពោះនាងទាសីនោះថា នាង ចូរនាងយកក្មេងនេះទៅ ហើយឡើងលើភ្នំដែលជាកន្លែងចោលចោរ ចូរបោះវាចុះទៅក្នុងជ្រោះវាប៉ះថ្មភ្នំ ក៏នឹងបែកជាចំណែកតូចៗ ធ្លាក់លើផែនដី នាងដឹងថា វាស្លាប់

ឬមិនទាន់ស្លាប់ គប្បីត្រឡប់មក ។ នាងកាឡីនោះ នាំក្មេងនោះទៅកាន់ទីនោះ ហើយឈរនៅលើកំពូលភ្នំ បោះចុះទៅ ។ ក៏ឫស្សីមួយគុម្ពធំដែលអាស្រ័យភ្នំនោះឯង ចម្រើនព្រោះភ្នំនោះឯង ។ គុម្ពនៃវល្លិ៍ទំពាំងបាយជូរដ៏ក្រាស់ ដុះគ្របនៅអំពីខាងលើគុម្ពឫស្សីធំនោះ ។ ទារកកាលធ្លាក់ ទើបធ្លាក់ចុះលើគុម្ពឫស្សីនោះ ដូចធ្លាក់ចុះលើសំពត់រោមសត្វ ។ ក្នុងថ្ងៃនោះមេជាងតម្បាញមានសេចក្ដីត្រូវការដោយឫស្សី ។ គេទៅជាមួយកូនប្រុសផ្ដើមនឹងកាប់គុម្ពឫស្សីនោះ ។ កាលគុម្ពឫស្សីនោះញ័រ ក្មេងក៏បានស្រែកយំឡើង ។ គេទើបនិយាយថា ឮដូចសំឡេងក្មេង ទើបឡើងទៅតាមផ្លូវមួយ ឃើញក្មេងនោះ មានចិត្តត្រេកអរ ទើបនាំយកទៅដោយគិតថា យើងបានកូនប្រុសហើយ ។ នាងកាឡីទៅកាន់សំណាក់របស់សេដ្ឋី ត្រូវសេដ្ឋីសួរ ទើបប្រាប់រឿងនោះ ត្រូវសេដ្ឋីបញ្ជាថា នាងចូរទៅយកទ្រព្យឲ្យគេ ១ ពាន់កហាបណៈ ហើយនាំទារកនោះត្រឡប់មក នាងកាឡីក៏បានធ្វើតាមពាក្យនោះទៀត ។

ឱ្យទុក្ខដល់គេ ទុក្ខនោះក៏មានដល់ខ្លួនឯង

កាលសេដ្ឋីធ្វើកម្មនេះៗ ឯង ក្មេងក៏ចម្រើនធំធាត់ឡើង ។ គេមានឈ្មោះថា "ឃោសកៈ" ឃោសកកុមារនោះប្រាកដដល់សេដ្ឋី ហាក់ដូចជាបន្ទាចាក់ភ្នែក ។ សេដ្ឋីមិនអាចនឹងមើលគេចំៗ បាន ។ គ្រានោះ សេដ្ឋីស្វែងរកឧបាយដើម្បីសម្លាប់ឃោសកកុមារនោះ ទើបបានទៅកាន់សំណាក់របស់នាយស្មូនឆ្នាំងជាសំឡាញ់របស់ខ្លួន ហើយសួរថា កាលណាលោកនឹងដុតចង្ក្រាន ។ កាលគេឆ្លើយថា ព្រឹកនេះ ទើបពោលថា បើដូច្នោះលោកចូរយកទ្រព្យ ១ ពាន់កហាបណៈនេះ ហើយចូរធ្វើការងារឲ្យខ្ញុំមួយ ។

នាយស្មូនឆ្នាំ. ការងារអ្វី លោកសេដ្ឋី ។

សេដ្ឋី. ខ្ញុំមានបុត្រជាតិអាក្រក់ម្នាក់ ខ្ញុំនឹងបញ្ជូនវាមកកាន់សំណាក់របស់លោក ពេលនោះ លោកចូរឲ្យវាចូរទៅកាន់បន្ទប់ យកកាំបិតដ៏មុតកាត់ឲ្យជាចំណែកតូចធំ យកដាក់ក្នុងពាង ហើយដុតក្នុងចង្ក្រាន ទ្រព្យ ១ ពាន់កហាបណៈនេះនឹងជារង្វាន់របស់លោក ក្នុងកាលខាងក្រោយ ខ្ញុំនឹងធ្វើវត្ថុដែលគួរធ្វើដល់លោកឲ្យក្រៃលែងជាងនេះទៀត ។

នាយស្មូនឆ្នាំងទទួលថា បាន ។ ក្នុងថ្ងៃស្អែកឡើង សេដ្ឋីទើបហៅ

ឃោសកកុមារមក ហើយពោលថា បា! ថ្ងៃនេះ យើងឲ្យការងារនាយស្ទូនឆ្នាំងមួយ កូនចូរទៅ ចូរទៅកាន់សំណាក់របស់គេ ហើយនិយាយយ៉ាងនេះថា បានឮថា លោកទទួលការងារដែលលោកឪពុករបស់ខ្ញុំបានប្រាប់ពីថ្ងៃម្សិលមិញ ចូរធ្វើឲ្យសម្រេចចុះ ដូច្នេះ ទើបបានបញ្ជូនឲ្យទៅ ។ ឃោសកកុមារនោះទទួលថា "បាទ" បានទៅហើយ ។ ចំណែកកូនប្រុសរបស់សេដ្ឋីកំពុងលេងឃ្លីជាមួយពួកក្មេងៗ ឃើញឃោសកកុមារនោះដើរទៅក្នុងទីនោះទើបហៅឃោសកកុមារនោះ ហើយសួរថា "បង ទៅណា" កាលឃោសកកុមារឆ្លើយថា យកដំណឹងរបស់ឪពុកទៅកាន់សំណាក់របស់នាយស្ទូនឆ្នាំងទើបនិយាយថា "ខ្ញុំនឹងទៅក្នុងទីនោះ ព្រោះពួកក្មេងៗ ទាំងនេះឈ្នះខ្ញុំច្រើនដងហើយ បងចូរយកឈ្នះឲ្យខ្ញុំ ។

ឃោសកកុមារ. បងខ្លាចលោកឪពុក ។

កូនសេដ្ឋី. កុំខ្លាចអី ខ្ញុំនឹងនាំដំណឹងនោះទៅដោយខ្លួនឯង ក្មេងៗឈ្នះខ្ញុំហើយ បងចូរយកឈ្នះឲ្យខ្ញុំ រហូតដល់ខ្ញុំនឹងត្រឡប់មកវិញ ។

បានឮថា ឃោសកៈជាអ្នកឆ្លាតក្នុងការលេងឃ្លី ព្រោះដូច្នោះ កូន

ប្រុសរបស់សេដ្ឋីទើបបានអង្វរឃោសកកុមារយ៉ាងនោះ ។ ចំណែកឃោសកៈនោះ បាននិយាយជាមួយកូនប្រុសសេដ្ឋីនោះថា បើដូច្នោះ ចូរទៅប្រាប់នាយស្នូនធ្នាំងថា "ជម្រាបថា កាលថ្ងៃម្សិលមិញ ឪពុកខ្ញុំបានប្រាប់ឲ្យលោកធ្វើការងារមួយ លោកចូរញុំាងការងារនោះឲ្យសម្រេច ដូច្នេះហើយ ក៏ឲ្យគេទៅ ។ កូនប្រុសរបស់សេដ្ឋីនោះ ទៅកាន់សំណាក់របស់នាយស្នូនធ្នាំងនោះ ហើយបានពោលយ៉ាងនោះ ។ គ្រានោះ នាយស្នូនធ្នាំងបានសម្លាប់កូនប្រុសសេដ្ឋីនោះ តាមពាក្យរបស់សេដ្ឋីត្រង់កន្លែងនោះ ហើយបោះទៅក្នុងចង្ក្រាន ។ ចំណែកឃោសកកុមារ លេង (ល្បែង) រហូតមួយថ្ងៃ ពេលល្ងាច ក៏ត្រឡប់មកផ្ទះវិញ កាលសេដ្ឋីឃើញហើយ ទើបសួរថា "មិនបានទៅទេឬ បា" ។ ក៏ប្រាប់ដល់ហេតុដែលខ្លួនមិនបានទៅ និងហេតុដែលប្អូនប្រុសទៅជំនួសឲ្យជ្រាប ។ សេដ្ឋីស្តាប់ពាក្យនោះហើយ ក៏ស្រែកយំខ្លាំងៗថា "សូមកុំសម្លាប់ៗ" ហាក់ដូចជាមានលោហិតក្តៅៗ ពុះឡើងក្នុងសរីរៈទាំងអស់ ផ្គងដៃយំរៀបរាប់ថា "ស្នូនធ្នាំងដ៏ចម្រើន កុំឲ្យយើងវិនាសឡើយកុំឲ្យយើងវិនាសឡើយ" ហើយក៏បានទៅកាន់សំណាក់របស់នាយស្នូនធ្នាំង

នោះ ។ នាយស្នូនធ្នាំងឃើញសេដ្ឋីនោះមកដោយអាការយ៉ាងនោះ ទើបនិយាយថា "លោកសេដ្ឋី លោកកុំធ្វើសំឡេងខ្លាំងពេក ការងាររបស់លោកសម្រេចហើយ" ។ សេដ្ឋីនោះត្រូវសេចក្តីសោកបៀតបៀន ដូចក្នុងធំសន្ធត់ហើយ សោយទុក្ខទោមនស្សមានប្រការមិនតិច ដូចបុគ្គលអ្នកមានចិត្តប្រទូស្តចំពោះបុគ្គលអ្នកមិនប្រទូស្តតប ដូច្នោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ៖

បុគ្គលប្រទូស្តក្នុងអ្នកដែលមិនប្រទូស្តតប មិនមានអាជ្ញាដោយអាជ្ញា រមែងវិនាសដោយឋានៈ ១០ យ៉ាងណាមួយដោយពិត គឺ គប្បីទទួលនូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាស ១ ការបែកបាក់នៃសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡុកចិត្ត (ឆ្កួត) ១ ការរឹបអូសពីព្រះរាជា ១ ការពោលបង្កាច់ដ៏អាក្រក់ ១ វិនាសដោយជុំវិញនៃពួកញាតិ ១ ការពុកផុយនៃភោគៈ ១ ប្រការមួយទៀត ភ្លើងព្រៃរមែងឆេះផ្ទះរបស់បុគ្គលនោះ ព្រោះការបែកធ្លាយនៃកាយ គេរមែង

មានបញ្ញាទ្រុឌទ្រោម រមែងចូលដល់នរក ។

## កាលឧបាយថ្មីរបស់សេដ្ឋី

ដល់ថ្នាក់នេះហើយ សេដ្ឋីមិនអាចសម្លឹងមើលឃោសកៈនោះត្រង់ៗបាន ដេកគិតរកឧបាយថា ធ្វើដូចម្តេច ទើបសម្លាប់វាបាន ក៏ឃើញឧបាយថា យើងនឹងបញ្ជូនវាឲ្យទៅកាន់សំណាក់របស់អ្នករក្សាសួយ (ស្មៀន) ក្នុង ១០០ ស្រុករបស់យើង បញ្ជូនឲ្យស្មៀននោះសម្លាប់ ដូច្នេះហើយ ទើបសរសេរសំបុត្រទៅឲ្យស្មៀននោះថា "បុគ្គលនេះ ជាកូនមានជាតិដ៏អាក្រក់របស់យើង សូមលោកសម្លាប់វា ហើយចូរបោះចុះទៅក្នុងរណ្តៅលាមក កាលធ្វើកិច្ចការនេះស្រេចហើយ ខ្ញុំនឹងដឹងវត្ថុដែលគួរតបគុណលោក ក្នុងកាលជាខាងក្រោយ" ដូច្នេះ ទើបពោលថា "ឃោសកកូន ស្មៀនរបស់ឪពុក នៅឯស្រុកសួយ ១០០ កូនចូរនាំសំបុត្រមួយច្បាប់នេះទៅឲ្យគេ" ។ ទើបយកសំបុត្រចងទុកត្រង់ជាយសំពត់របស់គេ ។

នាយឃោសកៈនោះ មិនចេះអក្សរសម័យ ព្រោះតាំងពីក្មេងសេដ្ឋីក៏មានគំនិតសម្លាប់គេជានិច្ច (តែ) មិនអាចសម្លាប់បាន នឹងឲ្យគេសិក្សា

អក្សរសម័យបានដូចម្តេច ។ នាយឃោសកៈនោះ ត្រូវចងសំបុត្រសម្ងាប់ត្រង់ជាយសំពត់ ដោយប្រការដូច្នេះ កាលនឹងចេញដើរ ទើបនិយាយថា "ពុក ខ្ញុំមិនមានស្បៀងក្នុងការដើរផ្លូវ" ។

សេដ្ឋី. កូនមិនចាំបាច់កន្សល់ដោយស្បៀងដើរផ្លូវ ក្នុងស្រុកឈ្មោះឯណោះក្នុងចន្លោះផ្លូវ សេដ្ឋីជាសំឡាញ់របស់ពុកមានហើយ កូនចូរទៅបរិភោគអាហារព្រឹកត្រង់ផ្ទះរបស់គេហើយ សឹមធ្វើដំណើរតទៅទៀត ។

ឃោសកៈនោះទទួលថា បាទ ថ្វាយបង្គំបិតាហើយ ចេញដើរទៅដល់ស្រុកនោះ សួររកផ្ទះសេដ្ឋី ដើរទៅជួបភរិយារបស់សេដ្ឋី កាលនាងពោលថា "អ្នកមកអំពីណា" ទើបឆ្លើយថា "មកពីក្នុងក្រុង" ។

ភរិយារបស់សេដ្ឋី. អ្នកជាកូនរបស់នរណា ។

ឃោសកៈ. ខ្ញុំជាកូនសេដ្ឋីជាសំឡាញ់របស់លោកសេដ្ឋី ក្នុងស្រុកនេះ ។

ភរិយារបស់សេដ្ឋី. អ្នកឈ្មោះឃោសកៈឬ ។

ឃោសកៈ. បាទ ។

ព្រមគ្នាក្នុងវេលាឃើញនោះ សេចក្តីស្រឡាញ់ដូចជាកូនក្នុងឃោសកៈនោះ ក៏កើតឡើងដល់នាង ។

ក៏សេដ្ឋីមានកូនក្រមុំម្នាក់ នាងមានអាយុ ១៥-១៦ ឆ្នាំ រូបរាងស្អាត គួរស្រឡាញ់ ។ សេដ្ឋីឲ្យស្រីបម្រើម្នាក់ដើម្បីរក្សានាង ហើយឲ្យនៅត្រង់បន្ទប់ដ៏មានសិរី ជាន់ខាងលើនៃប្រសាទ ៧ ជាន់ ។ ក្នុងខណៈនោះ កូនក្រមុំសេដ្ឋីប្រើស្រីបម្រើឲ្យទៅផ្សារ ។ គ្រានោះ ភរិយារបស់សេដ្ឋីឃើញស្រីនោះហើយ ទើបសួរថា "នាងទៅណា" កាលនាងឆ្លើយថា បពិត្រនាងម្ចាស់ ខ្ញុំទៅដោយម្ចាស់ស្រីប្រើ នាងម្ចាស់ ។ ទើបពោលថា "នាងចូរមកនេះ ផ្អាកការប្រើនោះសិន ចូរក្រាលតាំង លាងជើង លាបប្រេង ក្រាលទីដេក ឲ្យបុត្ររបស់យើង សឹមធ្វើកិច្ចការជាខាងក្រោយ ។ នាងបានធ្វើតាមពាក្យបញ្ជាហើយ ។ គ្រានោះ កូនក្រមុំរបស់សេដ្ឋីបានជេរស្រីបម្រើនោះដែលមកយូរ ។ ពេលនោះ ស្រីបម្រើនោះបានប្រាប់ដល់នាងថា "នាងម្ចាស់ កុំខឹងនឹងនាងខ្ញុំ បុត្ររបស់សេដ្ឋីឈ្មោះឃោសកៈមកហើយ នាងខ្ញុំធ្វើកិច្ចនេះៗ ដល់គេហើយ ទើបបានទៅផ្សារ ។ គ្រាន់តែបានឮឈ្មោះ

ថា "ឃោសកៈ" ចិត្តរបស់សេដ្ឋីនោះ ក៏កើតសេចក្ដីស្រឡាញ់ (ផ្សាយឡើង) ទូទៅដល់ស្បែកជាដើម រហូតដល់ខួរក្នុងឆ្អឹង តាំងឡើងដល់កូនក្រមុំសេដ្ឋីនោះឯង ។ ពិតហើយ កូនក្រមុំសេដ្ឋីនោះ ជាភរិយារបស់នាយឃោសកៈនោះក្នុងវេលាដែលគេជានាយកោតុហលិកៈ ដែលបានថ្វាយបាយមួយនាឡិដល់ព្រះបច្ចេកពុទ្ធ ។ ដោយអានុភាពនៃផលទាននោះ នាងទើបមកកើតក្នុងត្រកូលសេដ្ឋីនេះ ។ សេចក្ដីស្រឡាញ់ក្នុងកាលមុននោះ បានជក់ជាប់រហូតមកដល់កំណើតជាកូនសេដ្ឋីនេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា ៖

> សេចក្ដីស្រឡាញ់នោះ រមែងកើតដោយហេតុ ២ ប្រការ
> យ៉ាងនេះ គឺ ដោយការនៅរួមគ្នាក្នុងកាល ១ ដោយការ
> ប្រព្រឹត្តនូវអំពើជាប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ដូចផ្កាឧប្បល
> (អាស្រ័យភក់ និងទឹក) កើតក្នុងទឹក ដូច្នោះ ។

ពេលនោះ នាងក៏សួរស្រីបម្រើនោះថា (ឥឡូវនេះ) គេនៅទីណានាង ។

ស្រីបម្រើ. គេដេកលក់នៅត្រង់ទីដេកឯណោះ អ្នកនាង ។

ធិតាសេដ្ឋី. ក៏ក្នុងដៃរបស់គេ មានអ្វីខ្លះ ។

ស្រីបម្រើ. មានសំបុត្រនៅត្រង់ជាយសំពត់ អ្នកនាង ។

ធិតាសេដ្ឋីនោះទើបគិតថា "នោះជាសំបុត្រអ្វីហ្ន៎" កាលនាយឃោសកៈកំពុងដេកលក់ កាលមាតាបិតាមិនមើលឃើញ ព្រោះរវល់គិតក្នុងរឿងដទៃ ក៏ចូលទៅកាន់សំណាក់ (របស់គេ) ហើយស្រាយយកលិខិតនោះចូលទៅបន្ទប់របស់ខ្លួន បិទទ្វារ បិតបង្អួច អានសំបុត្រនោះ ព្រោះនាងឆ្លាតក្នុងអក្ខរសម័យ ហើយគិតថា "ស្លាប់ហើយ! មនុស្សល្ងង់ ចងសំបុត្រសម្រាប់សម្លាប់ខ្លួនត្រង់ជាយសំពត់ហើយ ក៏ហ៊ានដើរទៅ ប្រសិនបើយើងមិនបានឃើញសំបុត្រនេះទេ គេគង់នឹងមិនមានជីវិតរស់នៅឡើយ" ដូច្នេះ ទើបហែកសំបុត្រនោះចោល សរសេរសំបុត្រថ្មីមួយច្បាប់ជំនួស ដោយសំនួនរបស់សេដ្ឋីថា "កូនប្រុសរបស់ខ្ញុំនេះ ឈ្មោះឃោសកៈ លោកចូរឲ្យនាំគ្រឿងបណ្ណាការមកពីស្រុក (សួយ) ១០០ ធ្វើមង្គលជាមួយបុត្រសេដ្ឋីក្នុងជនបទនេះ ឲ្យសង់ផ្ទះឡើង ២ ជាន់ត្រង់កណ្ដាលស្រុកជាទីនៅរបស់ខ្លួន ធ្វើការ

រក្សាយ៉ាងរឹងមាំដោយគ្រឿងលោមព័ទ្ធ គឺ កំពែង និងដោយការការពារ គឺ បុរស និងចូរបញ្ជូនដំណឹងឲ្យដល់ខ្ញុំថា ការនេះ ការនេះ ខ្ញុំធ្វើស្រេចហើយ កាលលោកធ្វើកម្មយ៉ាងនេះហើយ ខ្ញុំនឹងដឹងវត្ថុដែលគួរធ្វើដល់លោកក្នុងកាលជាខាងក្រោយ ។ ក៏ឯងគ្រាសរសេរស្រេចហើយ នាងទើបបត់សំបុត្រយកទៅចងទុកត្រង់ជាយសំពត់របស់នាយឃោសកៈនោះដូចដើម ។

នាយឃោសកៈនោះដេកលក់អស់មួយថ្ងៃ ក្រោកឡើងបរិភោគអាហារទើបចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង គេក៏ចូលទៅកាន់ស្រុកនោះអំពីព្រឹកព្រលឹមក្រឡេកឃើញនាយស្មៀនធ្វើកិច្ចក្នុងស្រុកមួយ ។ នាយស្មៀនឃើញនាយឃោសកៈនោះហើយ ទើបសួរថា "មានការអ្វី បា" នាយឃោសកៈពោលថា "ឪពុករបស់ខ្ញុំបញ្ជូនសំបុត្រមកជូនលោក" ។ នាយស្មៀនទើបសួរថា "សំបុត្រអ្វី បា ចូរនាំមក" ។ ទទួលយកសំបុត្រហើយ អានក៏មានសេចក្តីពេញចិត្ត ទើបពោលចំពោះគហបតីទាំងឡាយថា "អ្នកដ៏ចម្រើនទាំងឡាយសូមអញ្ជើញមើល សេចក្តីស្រឡាញ់ក្នុងយើងរបស់ចៅហ្វាយយើង លោកសេដ្ឋីបញ្ជូនបុត្រប្រុសមកកាន់សំណាក់របស់យើងដោយបញ្ជាក់ថា ចូរធ្វើ

មង្គលដល់បុត្រតូចរបស់យើង ពួកលោកចូរប្រញាប់យកឈើជាដើមមកឲ្យរហ័ស ។ ដូច្នេះហើយ ឲ្យសង់ផ្ទះមានប្រការដូចពោលហើយ ក្នុងកណ្ដាលស្រុក ឲ្យនាំគ្រឿងបណ្ណាការមកទំពីស្រុកទាំង ១០០ នាំកូនក្រមុំរបស់សេដ្ឋីក្នុងជនបទមកធ្វើមង្គលការហើយ ។ ទើបបញ្ជូនដំណឹងឲ្យដល់លោកសេដ្ឋីថា "ការនេះ ការនេះ ខ្ញុំធ្វើស្រេចហើយ" ។

ព្រោះបានស្ដាប់ដំណឹងនោះ ការខូចចិត្តដ៏ធំកើតឡើងហើយដល់សេដ្ឋីថា "យើងឲ្យធ្វើវត្ថុណា វត្ថុនោះមិនសម្រេច វត្ថុណាមិនឲ្យធ្វើ វត្ថុនោះក៏ត្រឡប់ជាសម្រេច" ។ សេចក្ដីសោកនោះ ជាមួយសេចក្ដីសោកដល់បុត្ររួមគ្នា ញ៉ាំងសេចក្ដីក្ដៅក្នុងទ្រូងឲ្យកើតឡើង ឲ្យកើតរោគអតិសារ[១] ។ ឯកូនស្រីរបស់សេដ្ឋីក៏បង្គាប់ពួកអ្នកបម្រើថា "បើមាននរណាៗ មកពីសំណាក់របស់សេដ្ឋី លោកមិនទាន់ប្រាប់ដល់យើង ចូរកុំប្រាប់ដល់បុត្រសេដ្ឋីមុន" ។ សូម្បីសេដ្ឋីក៏គិតថា "ឥឡូវនេះ យើងនឹងធ្វើបុត្រដ៏អាក្រក់នោះ មិនឲ្យជាម្ចាស់នៃសម្បត្តិរបស់យើង ទើបប្រាប់ស្មៀនម្នាក់ទៀតថា "ខ្ញុំប្រាថ្នានឹងជួប

---

១. រោគញ៉ាំងលោហិតឲ្យពុះពុរឡើង រោគធ្លាក់ឈាម ។

បុត្ររបស់ខ្ញុំ លោកចូរអ្នកបម្រើម្នាក់ទៅ ឲ្យហៅបុត្ររបស់ខ្ញុំមក" ។ គេទទួលថា "បាទលោកម្ចាស់" ។ ឲ្យសំបុត្រ ហើយបញ្ជូនមនុស្សម្នាក់ទៅ ។ ចំណែកកូនស្រីរបស់សេដ្ឋីជ្រាបថា បុរសនោះមកឈរនៅត្រង់ទ្វារ ក៏ឲ្យហៅគេមក ហើយសួរថា "មានការអ្វី បា" ។

អ្នកបម្រើ. សេដ្ឋីមិនសប្បាយ ឲ្យហៅកូនប្រុសត្រឡប់ដើម្បីត្រូវការឃើញ (គេ) នាងម្ចាស់ ។

ធីតាសេដ្ឋី. បា! សេដ្ឋីនៅមានកម្លាំង ឬខ្សោយកម្លាំង ។

អ្នកបម្រើ. នៅមានកម្លាំង នៅបរិភោគអាហារបាន នាងម្ចាស់ ។

កូនស្រីសេដ្ឋីនោះមិនឲ្យបុត្រសេដ្ឋីជ្រាបឡើយ បានឲ្យទីស្នាក់នៅ និងស្បៀងដើរផ្លូវដល់អ្នកបម្រើហើយ ពោលថា លោកនឹងទៅបានក្នុងវេលាដែលខ្ញុំឲ្យទៅ ចូរស្នាក់នៅសិនចុះ ។ មហាសេដ្ឋីបានពោលចំពោះស្មៀននោះទៀតថា "លោកមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សំណាក់បុត្ររបស់ខ្ញុំហើយឬ" ។

ស្មៀន. បញ្ជូនទៅហើយ លោកម្ចាស់ អ្នកដែលទៅមិនទាន់ត្រឡប់

មក ។

សេដ្ឋី. បើដូច្នោះ លោកចូរបញ្ជូនអ្នកដទៃទៅថែមទៀត ។

នាយស្មៀននោះបញ្ជូនទៅហើយ ។ កូនក្រមុំរបស់សេដ្ឋីក៏ធ្វើសួម្បី ក្នុងបុរសនោះយ៉ាងនោះដូចគ្នា ។ ក្នុងកាលនោះ រោគរបស់សេដ្ឋីកាន់តែខ្លាំងឡើង ភាជនៈ (អាហារ) មួយចូល ភាជនៈ (អាហារ) មួយចេញ ។ សេដ្ឋីទើបសួរនាយស្មៀនទៀតថា "លោកនៅមិនទាន់បញ្ជូនសំបុត្រទៅកាន់សំណាក់បុត្ររបស់ខ្ញុំទេឬ" ។

ស្មៀន. បញ្ជូនទៅហើយ លោកម្ចាស់ តែអ្នកដែលទៅនៅមិនទាន់ត្រឡប់ ។

សេដ្ឋី. បើដូច្នោះ លោកចូរបញ្ជូនអ្នកដទៃទៅទៀត ។

នាយស្មានោះបញ្ជូនទៅហើយ ។ កូនស្រីសេដ្ឋីសួរដល់ការប្រព្រឹត្តទៅនោះ សួម្បីបុរសដែលមកក្នុងវារៈទី ៣ ។ បុរសនោះប្រាប់ថា "លោកម្ចាស់ លោកសេដ្ឋីឈឺធ្ងន់ បរិភោគអាហារមិនបាន មានសេចក្ដីស្លាប់ជាខាងមុខ ។ ភាជនៈមួយចេញ ភាជនៈមួយចូល" ។ កូនក្រមុំរបស់សេដ្ឋី

ទើបគិតថា "ដឹងថា ឪពុករបស់លោកឈឺ" កាលគេពោលថា "និយាយអ្វីនាង" ទើបប្រាប់ថា ការមិនសប្បាយកើតមានដល់បិតារបស់លោកហើយ" ។

ឃោសកៈ. ឥឡូវនេះ ខ្ញុំគួរធ្វើយ៉ាងណា ?

ធីតាសេដ្ឋី. នាយ យើងនឹងការយកគ្រឿងបណ្ណាការដែលកើតអំពីស្រុកសួយ ១០០ ស្រុក ទៅសួរសុខទុក្ខគាត់ ។

នាយឃោសកៈក៏យល់ព្រម ហើយឲ្យមនុស្សនាំគ្រឿងបណ្ណាការដាក់ពេញរទេះនាំទៅ ។ គ្រានោះ កូនក្រមុំរបស់សេដ្ឋីនិយាយនឹងឃោសកៈថា បិតារបស់លោកខ្សោយកម្លាំងហើយ កាលយើងកាន់យកគ្រឿងបណ្ណាការមានប្រមាណប៉ុណ្ណេះទៅមុខជាយឺតយូរ សូមលោកចូរបញ្ជូនគ្រឿងបណ្ណាការនេះត្រឡប់ទៅវិញចុះ ។ ដូច្នេះ ទើបបញ្ជូនគ្រឿងបណ្ណាការទាំងអស់នោះទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ។ ហើយនិយាយទៀតថា នាយ លោកគប្បីឈរខាងចុងជើងនៃបិតារបស់លោក ខ្ញុំនឹងឈរខាងក្បាល ។ កាលគេទៅកាន់ផ្ទះនោះហើយ នាងក៏បង្គាប់ពួកមនុស្សរបស់ខ្លួនថា ពួកលោកចូរនៅចាំទាំងខាងមុខផ្ទះ ទាំងខាងក្រោយផ្ទះ ។ ក៏ក្នុងវេលាដែលចូលទៅ

បុត្រសេដ្ឋីបានឈរនៅត្រង់ខាងជើងរបស់បិតា ។ ចំណែកកកិរិយាបានឈរ ផ្នែកខាងសីសៈ ។

ក្នុងខណៈនោះ បានសេដ្ឋីដេកផ្ងារ ។ ចំណែកនាយស្មៀនកំពុងតែប្រាប់ជើងឲ្យសេដ្ឋីនោះ ទើបនិយាយថា លោកម្ចាស់ បុត្រប្រុសរបស់លោកម្ចាស់មកហើយ ។

សេដ្ឋី. គេនៅទីណា ?

នាយស្មៀន. គេឈរនៅត្រង់ចុងជើង ។

គ្រានោះ សេដ្ឋីឃើញបុត្រប្រុសនោះហើយ ទើបហៅនាយស្មៀនមកហើយសួរថា ក្នុងផ្ទះរបស់ខ្ញុំមានទ្រព្យប៉ុន្មាន? កាលនាយស្មៀនប្រាប់ថា លោកម្ចាស់ ទ្រព្យមាន ៤០ កោដិប៉ុណ្ណោះ តែគ្រឿងឧបភោគបរិភោគ ដីភូមិ ដីស្រែ សត្វជើង ២ សត្វជើង ៤ យានពាហនៈ មានចំនួនប៉ុណ្ណោះៗ បំណងនឹងនិយាយថា ខ្ញុំមិនឲ្យទ្រព្យមានប្រមាណប៉ុណ្ណោះដល់ឃោសកៈបុត្ររបស់ខ្ញុំ (ក៏ត្រឡប់) និយាយថា ខ្ញុំឲ្យ ។ កូនក្រមុំសេដ្ឋីស្តាប់ពាក្យនោះហើយគិតថា សេដ្ឋីនេះ កាលបើនិយាយទៀត នឹងគប្បីនិយាយ

ពាក្យអ្វីដទៃវិញ ក៏ធ្វើអាការដូចជាភេលភលដោយសេចក្ដីសោក រំសាយសក់យំថា លោកពុក និយាយអ្វីនេះ ពួកយើងស្ដាប់ពាក្យរបស់លោកពុកសូម្បីទាំងអស់នេះហើយ ពួកយើងជាអ្នកមិនមានបុណ្យទេ ដូច្នេះហើយទើបយកសីសៈប្រហារសេដ្ឋីនោះត្រង់ទ្រូង ក្រាបចុះ យកសីសៈបោកផ្ទប់ត្រង់ទ្រូងរបស់សេដ្ឋីនោះ សំដែងអាការខ្សឹកខ្សួល រហូតដល់សេដ្ឋីមិនអាចនិយាយបានទៀត ។ សូម្បីសេដ្ឋីក៏បានធ្វើកាលៈក្នុងខណៈនោះឯង ។

## ព្រះបាទឧទេនប្រទានតំណែងសេដ្ឋីដល់នាយឃោសកៈ

ជនទាំងឡាយស្ដាប់ថា សេដ្ឋីអនិច្ចកម្មហើយ ទើបទៅក្រាបទូលព្រះបាទឧទេន ។ ព្រះបាទឧទេនទ្រង់ធ្វើឈាបនកិច្ចសរីរៈរបស់សេដ្ឋីនោះហើយត្រាស់សួរថា ក៏កូនប្រុស ឬកូនស្រីរបស់សេដ្ឋីនោះ មានទេ? ជនទាំងឡាយក្រាបទូលថា មានព្រះអង្គ កូនប្រុសរបស់សេដ្ឋីនោះឈ្មោះថាឃោសកៈ សេដ្ឋីនោះប្រគល់ទ្រព្យសម្បត្តិទាំងអស់ឲ្យដល់ឃោសកៈនោះឯង ហើយក៏អនិច្ចកម្មទៅ ព្រះអង្គ ។ ព្រះរាជាទ្រង់ឲ្យហៅបុត្ររបស់សេដ្ឋីមកហើយក្នុងកាលដទៃ ។ ក៏ក្នុងថ្ងៃនោះមានភ្លៀងធ្លាក់ មានទឹកដក់នៅត្រង់

ព្រះលានហ្លួងដោយកន្ទែងៗ ។ បុត្រសេដ្ឋីទៅហើយដោយសង្ស័យថា នឹងគាល់ព្រះរាជា ។ ព្រះរាជាទ្រង់បើកបង្អួច ទតឃើញនាយឃោសកៈនោះដើរមក ទ្រង់ឃើញគេលោតកន្ទងទឹកត្រង់ព្រះលានហ្លួងដើរមក ទើបត្រាស់សួរគេដែលមកថ្វាយបង្គំហើយឈរថា "បា អ្នកឈ្មោះឃោសកៈឬ" កាលគេទូលថា "ខ្ញុំព្រះអង្គនេះឯង" ។ ទ្រង់លួងលោមគេថា អ្នកកុំខូចចិត្តថាបិតារបស់យើងអនិច្ចកម្មហើយ យើងនឹងឲ្យតំណែងសេដ្ឋីដែលជារបស់បិតារបស់អ្នកដល់អ្នក ដូច្នេះហើយ ទ្រង់ត្រាស់នឹងគេថា "ចូរទៅចុះ បា" ។ ហើយព្រះរាជាបានប្រថាប់ឈរទតមើលគេ ដែលដើរទៅ ។ គេមិនលោតកន្ទងទឹកដែលគេលោតកន្ទងក្នុងវេលាមក បានដើរសន្សឹមៗ លុយទឹកនោះទៅ ។ គ្រានោះ ព្រះរាជត្រាស់បង្គាប់ឲ្យហៅនាយឃោសកៈនោះឲ្យត្រឡប់មក ហើយត្រាស់សួរថា "ព្រោះហេតុអ្វី បា! កាលអ្នកមកកាន់សំណាក់របស់យើងទើបលោតកន្ទងទឹក កាលទៅ ទើបចុះទឹក (ដើរលុយ) ទៅវិញ?" នាយឃោសកៈទូលថា "ដូច្នោះមែន ព្រះអង្គ ខ្ញុំព្រះអង្គនៅក្មេងក្នុងខណៈនោះ នេះឈ្មោះថា ជាវេលាលេង , ក៏ក្នុងកាលនេះ ខ្ញុំព្រះអង្គ

បានទទួលតំណែងអំពីព្រះអង្គហើយ ព្រោះដូច្នោះ ការដែលខ្ញុំព្រះអង្គមិនទៅដូចក្នុងកាលមុន ហើយដើរទៅដូចក្នុងកាលឥឡូវនេះ ទើបគួរ" ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា "បុរសនេះមានបញ្ញា យើងនឹងឲ្យតំណែងសេដ្ឋីដល់គេក្នុងកាលឥឡូវនេះ" ហើយប្រទានភោគៈដែលបិតាបរិភោគហើយ បានប្រទានតំណែងសេដ្ឋី ព្រមទាំងសព្វវត្ថុមួយមុខៗ ១០០ ។ នាយឃោសកៈនោះឈរខាងលើរថ បានធ្វើប្រទក្សិណព្រះនគរហើយ ។ ក្នុងទីដែលនាយឃោសកៈនោះក្រឡេកមើលហើយ រមែងញាប់ញ័រ ។ សូម្បីកូនក្រមុំរបស់សេដ្ឋីអង្គុយប្រឹក្សាគ្នាជាមួយនាងកាឡីស្រីបម្រើថា "កាឡី សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចហើយដល់បុត្ររបស់លោកសេដ្ឋី ក៏ព្រោះអាស្រ័យយើង" ។

កាឡី. ព្រោះហេតុអ្វី នាងម្ចាស់?

ធីតាសេដ្ឋី. ព្រោះឃោសកៈនេះ ចងសំបុត្រសម្លាប់ខ្លួនទុកត្រង់ជាយសំពត់មកកាន់ផ្ទះរបស់ពួកយើង គ្រានោះ ខ្ញុំហែកសំបុត្រមួយច្បាប់នោះរបស់គេ សរសេរសំបុត្រមួយច្បាប់ទៀត ដើម្បីធ្វើមង្គលជាមួយខ្ញុំ ហើយ

ធ្វើការរក្សាគេរហូតអស់កាលប៉ុណ្ណោះ ។

កាឡី. នាងម្ចាស់ដឹងរឿងត្រឹមប៉ុណ្ណោះ តែសេដ្ឋីបំណងនឹងសម្លាប់គេតែគេនៅក្មេង ក៏មិនអាចដើម្បីនឹងសម្លាប់បាន ព្រោះតែនាយឃោសកៈនេះឯង បានចំណាយទ្រព្យដ៏ច្រើន ។

ធីតាសេដ្ឋី. នែនាង សេដ្ឋីធ្វើកម្មធ្ងន់ណាស់ហ្ន៎ ។

ធីតាសេដ្ឋីនោះ ឃើញនាយឃោសកៈនោះធ្វើប្រទក្សិណព្រះនគរ ហើយចូលទៅកាន់ផ្ទះ ទើបសើចដោយគិតថា "សម្បត្តិប្រមាណប៉ុណ្ណេះៗ សម្រេចហើយក៏ព្រោះអាស្រ័យយើង" ។ គ្រានោះ បុត្ររបស់សេដ្ឋីឃើញអាការនោះ ទើបសួរថា "នាងសើចធ្វើអ្វី?" ។

ធីតាសេដ្ឋី. ព្រោះអាស្រ័យហេតុមួយ ។

បុត្រសេដ្ឋី. ចូរប្រាប់ហេតុនោះ ។

ធីតាសេដ្ឋីនោះមិនប្រាប់ ។ បុត្ររបស់សេដ្ឋីនោះ ទើបគំរាមថា "បើមិនប្រាប់ ខ្ញុំនឹងកាត់នាងជា ២ កំណាត់" ហើយហូតដាវចេញមក ។ ធីតាសេដ្ឋីនោះទើបប្រាប់ថា "ខ្ញុំនាងសើច ក៏ព្រោះគិតថា ទ្រព្យសម្បត្តិមាន

ប្រមាណប៉ុណ្ណេះនេះ លោកបានហើយក៏ព្រោះអាស្រ័យខ្ញុំ" ។ សេដ្ឋីពោលថា "តែថា ឪពុករបស់ខ្ញុំបានប្រគល់មត៌ករបស់ខ្លួនឲ្យដល់ខ្ញុំ តើនាងជាប់ទាក់ទងអ្វីក្នុងទ្រព្យនោះ" ។ បានឮថា សេដ្ឋីមិនបានដឹងរឿងអ្វីអស់កាលប៉ុណ្ណេះ ព្រោះដូច្នោះទើបមិនជឿពាក្យរបស់ធីតាសេដ្ឋីនោះ ។ គ្រានោះធីតាសេដ្ឋីនោះ បាននិយាយរឿងនោះទាំងអស់ដល់បុត្រសេដ្ឋីនោះថា "បិតារបស់លោក ឲ្យសំបុត្រសម្លាប់ (ខ្លួន) បញ្ជូនលោកមកហើយ ខ្ញុំធ្វើកម្មយ៉ាងនេះៗ ហើយបានរក្សាលោក" ។ បុត្រសេដ្ឋីមិនជឿ និយាយថា "នាងនិយាយមិនពិត" ទើបគិតថា "យើងនឹងសួរនាងកាឡី" ដូច្នោះ ទើបពោលថា "បានឮថា យ៉ាងនោះមែនឬនាង?" នាងកាឡីទើបប្រាប់ថា "មែនហើយលោកប្រុស តាំងពីលោកប្រុសនៅក្មេង សេដ្ឋីប្រាថ្នានឹងសម្លាប់លោក តែមិនអាចនឹងសម្លាប់បាន អាស្រ័យលោក សេដ្ឋីចំណាយអស់ទ្រព្យដ៏ច្រើន លោកប្រុសរួចផុតអំពីការស្លាប់ក្នុងទី ៧ កន្លែង ឥឡូវនេះ មកអំពីស្រុកសួយ ហើយបានតំណែងជាសេដ្ឋី ព្រមទាំងសព្វវត្ថុមួយមុខៗ ១០០" ។ សេដ្ឋីស្តាប់ពាក្យនោះហើយគិតថា "កម្មរបស់យើងធ្ងន់ណាស់ យើងរួចពី

សេចក្តីស្លាប់បែបនេះ ហើយជាអ្នកនៅដោយសេចក្តីប្រមាទ មិនគួរឡើយ យើងនឹងមិនប្រមាទ” ដូច្នេះ បានលះបង់ទ្រព្យមួយថ្ងៃមួយពាន់ ផ្តើមតាំងទានទុកដើម្បីមនុស្សដើរផ្លូវឆ្ងាយ និងមនុស្សកំព្រាជាដើម ។ កុដុម្ពិកឈ្មោះមិត្ត: បានជាអ្នកខ្វល់ខ្វាយក្នុងការឲ្យទានរបស់សេដ្ឋីនោះឯង ។

(នេះជារឿងកើតឡើងរបស់សេដ្ឋី)

## ប្រវត្តិព្រះនាងសាមាវតី

ក្នុងកាលនោះ សេដ្ឋីឈ្មោះថា ភទ្ទវតិយ: ក្នុងភទ្ទវតីនគរ បានជាសំឡាញ់ដែលមិនធ្លាប់ឃើញគ្នារបស់ឃោសកសេដ្ឋី ។ ឃោសកសេដ្ឋីបានស្តាប់សម្បត្តិ និងវ័យ និងប្រទេសរបស់ភទ្ទវតិយសេដ្ឋីក្នុងសំណាក់របស់ពួកឈ្មួញមកហើយអំពីភទ្ទវតីនគរ ប្រាថ្នាភាពជាសំឡាញ់ក្នុងសេដ្ឋីនោះ ទើបបញ្ជូនបណ្ណាការទៅហើយ ។ សូម្បីភទ្ទវតិយសេដ្ឋី បានស្តាប់សម្បត្តិ និងវ័យ និងប្រទេសរបស់ឃោសកសេដ្ឋី ក្នុងសំណាក់របស់ពួកឈ្មួញដែលមកអំពីក្រុងកោសម្ពី ប្រាថ្នាភាពជាសំឡាញ់ជាមួយសេដ្ឋីនោះ

ទើបបញ្ជូនគ្រឿងបណ្ណាការឲ្យទៅដែរ ។ សេដ្ឋីទាំងពីរនោះបានជាសំឡាញ់ ដែលមិនធ្លាប់ឃើញគ្នានឹងគ្នាយ៉ាងនេះ ។ ក្នុងកាលដទៃ អហិវាតករោគ កើតឡើងហើយក្នុងផ្ទះរបស់កទូវតិយសេដ្ឋី កាលអហិវាតករោគនោះកើត ហើយ សត្វរុយរមែងស្លាប់មុន តពីនោះពលជាលដល់កណ្ដុរ មាន់ ជ្រូក ឆ្កែ ឆ្មា គោ ទាសី ទាសៈ រមែងស្លាប់ទៅដោយលំដាប់នោះឯង អ្នក ដែលជាម្ចាស់ផ្ទះរមែងស្លាប់ក្រោយគេបង្អស់ ។ ក្នុងជនទាំងនោះ ពួកណា ទម្លាយជញ្ជាំងផ្ទះរត់ចេញទៅ ពួកនោះរមែងបានជីវិត ។ សូម្បីក្នុងកាល នោះ សេដ្ឋី ភរិយា និងកូនក្រមុំ ក៏ចៀសចេញទៅដោយវិធីនោះ ប្រាថ្នា នឹងឃើញឃោសកសេដ្ឋី ទើបធ្វើដំណើរទៅកាន់ក្រុងកោសម្ពី ។ ទាំង ៣ នាក់នោះមានស្បៀងអស់ក្នុងរវាងផ្លូវ មានសរីរៈហត់នឿយ ត្រូវខ្យល់ និង កំដៅថ្ងៃ និងដោយការហេវហត់ ដល់ក្រុងកោសម្ពីដោយសេចក្ដីលំបាក ផឹក ទឹកក្នុងទីដែលមានទឹកសម្បូរហើយ ចូលទៅកាន់សាលាមួយខាងនៅជិតទ្វារ ក្រុង ។ នៅក្នុងទីនោះ សេដ្ឋីពោលនឹងភរិយាថា "នាងដ៏ចម្រើន ការមក ដោយទំនងនេះ រមែងមិនត្រូវចិត្តសូម្បីដល់មាតាអ្នកបង្កើត បានជ្រាបថា

សំឡាញ់របស់យើងលះបង់ទ្រព្យមួយថ្ងៃមួយពាន់ ឲ្យទានដល់មនុស្សអ្នកដើរផ្លូវ និងកំព្រាជាដើម យើងនឹងបញ្ជូនកូនស្រីទៅក្នុងទីនោះឲ្យនាំអាហារមក ទំនុកបម្រុងសរីរៈនៅក្នុងទីនេះឯង ត្រឹមតែមួយថ្ងៃពីរថ្ងៃហើយ ទើបនឹងជួបសំឡាញ់" ។ នាងទទួលថា "ល្អហើយ នាយ" ។ ពួកគេក៏បានស្នាក់នៅត្រង់សាលានោះឯង ។ ក្នុងថ្ងៃស្អែកឡើង កាលគេដល់វេលាហើយ កាលមនុស្សកំព្រា និងអ្នកដើរផ្លូវជាដើម នាំគ្នាទៅដើម្បីត្រូវការអាហារ មាតា និងបិតាទើបបញ្ជូនកូនស្រីទៅដោយពាក្យថា "កូន ចូរទៅនាំអាហារមកដើម្បីពួកយើង" ។ ធីតារបស់ត្រកូលដែលមានភោគៈច្រើន មិនអៀនខ្មាសហើយ ព្រោះខ្លួនមានសេចក្តីអៀនខ្មាសត្រូវវិបត្តិកាត់ផ្តាច់ហើយ កាន់ថាសទៅព្រមជាមួយនឹងមនុស្សកំព្រាដើម្បីត្រូវការអាហារ អ្នកដែលជាមិត្តកុដុម្ពីក៏សួរថា "នាងនឹងទទួលប៉ុន្មានចំណែក?" ក៏ប្រាប់ថា "៣ ចំណែក" ពេលនោះ មិត្តកុដុម្ពីទើបឲ្យភត្តាហារ ៣ ចំណែកដល់នាង ។ កាលនាងនាំភត្តមកហើយ ទាំង ៣ នាក់ ក៏អង្គុយបរិភោគអាហាររួមគ្នា ។ គ្រានោះ មាតា និងកូនស្រីបានពោលនឹងសេដ្ឋីថា "នាយព្រោះសេចក្តីវិបត្តិរមែងកើត

ឡើងសូម្បីដល់ត្រកូលធំ នាយកុំគិតដល់ពួកខ្ញុំ ចូរបរិភោគចុះ” អង្វរដោយប្រការផ្សេងៗ ញុំាងសេដ្ឋីនោះឲ្យបរិភោគ ដោយប្រការដូច្នេះ ។ សេដ្ឋីនោះបរិភោគហើយ មិនអាចនឹងឲ្យអាហាររលាយបាន កាលអរុណរះឡើងក៏បានធ្វើកាលៈហើយ ។ មាតា និងកូនស្រី បានយំរៀបរាប់ដោយប្រការផ្សេងៗ ។ ក្នុងថ្ងៃស្អែកឡើង នាងកុមារិកាដើរបណ្តើរយំបណ្តើរ ទៅដើម្បីត្រូវការអាហារ អ្នកដែលជាមិត្តកុដុម្ពីនោះឃើញនាងហើយ សួរថា “នាងទទួលប៉ុន្មានចំណែក?” ទើបប្រាប់ថា “២ ចំណែក” ។ មិត្តកុដុម្ពីក៏ទើបបានឲ្យ ២ ចំណែក ។ នាងនាំមកហើយ ក៏អង្វរឲ្យមាតាបរិភោគ ។ មាតាត្រូវធីតារបស់ខ្លួននោះអង្វរហើយ ក៏បរិភោគ មិនអាចនឹងធ្វើឲ្យអាហារនោះរលាយបាន ក្នុងថ្ងៃនោះ ក៏បានធ្វើកាលៈទៅ ។ ក្មេងស្រីម្នាក់ប៉ុណ្ណោះ យំ ខ្សឹកខ្សួល ជាអ្នកមានទុក្ខព្រោះសេចក្តីស្រេកឃ្លានដែលកើតឡើងក្រៃ-លែងជាងការកើតឡើងនៃទុក្ខនោះ ក្នុងស្អែកឡើង ទើបដើរយំទៅជាមួយនឹងពួកយាចកដើម្បីត្រូវការអាហារ អ្នកជាមិត្រកុដុម្ពីក៏សួរថា “នាងនឹងទទួលប៉ុន្មានចំណែក?” ទើបឆ្លើយថា “មួយចំណែក” ។ មិត្រកុដុម្ពីក៏ចាំ

នាងដែលជាអ្នកដែលជាអ្នកទទួលកត្តបានទាំង ៣ ថ្ងៃ ព្រោះហេតុនោះទើបពោលនឹងនាងថា "ស្រីកំហូច នាងឯងចូរវិនាសទៅ ថ្ងៃនេះនាងឯងទើបស្គាល់ប្រមាណក្នុងផ្ទៃរបស់ខ្លួនឬ" ។ ធីតាអ្នកមានត្រកូល សម្បូរដោយហិរិឧត្តប្បៈ ដូចត្រូវប្រហារដោយលំពែងត្រង់ទ្រូង និងដូចចាក់ដោយទឹកក្រុតត្រង់ដំបៅ ស្រែកយំ ហើយសួរថា "អ្វី នាយ" ។

មិត្តកុដុម្ពិក៍. ថ្ងៃមុននាងទទួលដល់ ៣ ចំណែក ថ្ងៃបន្ទាប់ទទួល ២ ចំណែក ថ្ងៃនេះទទួលមួយចំណែក នាងដឹងប្រមាណផ្ទៃរបស់ខ្លួនហើយឬ ។

កុលធីតា. លោកកុំយល់ថា "ខ្ញុំទទួលទៅដើម្បីខ្លួនឯងតែម្នាក់" ។

មិត្តកុដុម្ពិក៍. បើដូច្នោះ ហេតុអ្វីទើបទទួល ៣ ចំណែក ។

កុលធីតា. ក្នុងថ្ងៃមុន ពួកខ្ញុំមានគ្នា ៣ នាក់ ម្សិលមិញមាន ២ នាក់ ថ្ងៃនេះមានខ្ញុំតែម្នាក់ឯងប៉ុណ្ណោះ ។

មិត្តកុដុម្ពីទើបសួរថា "ព្រោះហេតុអ្វី" ស្តាប់រឿងទាំងអស់ដែលនាងប្រាប់ហើយ (តាំងពីដើម) មិនអាចនឹងទប់ទឹកភ្នែកបាន កើតសេចក្តីសោក

យ៉ាងខ្លាំង ទើបប្រាប់ថា "នាង បើមានហេតុយ៉ាងនេះ ចូរកុំគិតអ្វីឡើយ នាងជាធីតារបស់កទ្ទវតិយសេដ្ឋី តាំងពីថ្ងៃនេះទៅ ចូរជាធីតារបស់យើងចុះ" ដូច្នេះហើយ ទើបបើបត្រង់សីសៈ នាំនាងទៅកាន់ផ្ទះតាំងទុកក្នុងតំណែងជាធីតាធំរបស់ខ្លួន ។

ធីតាសេដ្ឋីនោះ បានឮសំឡេងអ៊ឹងកងនៅក្នុងរោងទាន ទើបសួរថា "ពុក ហេតុអ្វីពុកមិនធ្វើជនទាំងនេះឲ្យស្ងាត់ហើយឲ្យទាន" ។

មិត្តកុដុម្ពិក៍. "មិនអាចធ្វើបានទេ កូន" ។

ធីតា. អាចធ្វើបាន ពុក ។

មិត្តកុដុម្ពិក៍. ធ្វើដូចម្តេច កូន ។

ធីតា. ពុក សូមពុកព័ទ្ធរោងទាន បិទ (ធ្វើ) ទ្វារទុក ២ កន្លែងល្មមប្រមាណមនុស្សម្នាក់ចូលទៅបានប៉ុណ្ណោះ ហើយចូរប្រាប់ថា "ពួកអ្នកចូរចូលទៅតាមទ្វារមួយ ចេញតាមទ្វារមួយ" ដោយប្រការយ៉ាងនេះ ជនទាំងឡាយក៏នឹងស្ងប់ស្ងៀមទទួលទាន ។

មិត្តកុដុម្ពិក៍នោះ ស្តាប់ពាក្យនោះហើយ ទើបពោលថា "ឧបាយនេះ

ល្អ” ហើយឲ្យធ្វើតាមដូច្នោះ ។ សុម្បីសេដ្ឋីធីតានោះ ក្នុងកាលមុន នាងឈ្មោះ សាមា តែព្រោះនាងឲ្យធ្វើរបង ទើបឈ្មោះថា សាមាវតី ។ តាំងអំពីនោះ ភាពកោលាហលក្នុងរោងទានក៏វិនាសទៅ ។ ឃោសកសេដ្ឋីបានឮសំឡេងនោះក្នុងកាលមុន ក៏ពេញចិត្តថា “សំឡេងក្នុងរោងទានរបស់យើង” តែកាលមិនបានឮសំឡេង ២-៣ ថ្ងៃ ទើបសួរមិត្តកុដុម្ពិក៍ដែលមកកាន់ទីទំនុកបម្រុងរបស់ខ្លួនថា “លោកនៅឲ្យទានដល់អ្នកកំព្រា និងអ្នកដើរផ្លូវឆ្ងាយជាដើមទេឬ ។

មិត្តកុដុម្ពិក៍. បាទ លោកសេដ្ឋី ។

ឃោសកសេដ្ឋី. បើដូច្នេះ ហេតុអ្វី ទើបខ្ញុំមិនឮសំឡេង ២-៣ ថ្ងៃហើយ ។

មិត្ត. ខ្ញុំមានឧបាយ ដោយធ្វើពួកគេមិនឲ្យឮសំឡេងក្នុងការទទួលទាន ។

ឃោសកៈ. បើដូច្នេះ ហេតុអ្វីលោកទើបមិនធ្វើក្នុងកាលមុន ។

មិត្ត. ព្រោះមិនបានដឹង លោកសេដ្ឋី ។

ឃោសកៈ. ឥឡូវនេះ លោកដឹងបានដូចម្តេច ។

មិត្ត. កូនស្រីរបស់ខ្ញុំប្រាប់ ។

ឃោសកៈ. ឈ្មោះថាកូនស្រីរបស់លោក ដែលខ្ញុំមិនស្គាល់ មានឬ ។

មិត្តកុដុម្ពិក៍នោះ និយាយរឿងរបស់កទូវតិយសេដ្ឋីទាំងអស់ ផ្តើមតាំងពីកើតអហិវាតករោគ ហើយក៏ប្រាប់កាលដែលខ្លួនតាំងធីតារបស់សេដ្ឋីនោះទុកក្នុងតំណែងកូនស្រីធំរបស់ខ្លួន ។ គ្រានោះ សេដ្ឋីពោលនឹងមិត្ត-កុដុម្ពិក៍នោះថា បើដូច្នេះ ហេតុអ្វីលោកទើបមិនប្រាប់ដល់ខ្ញុំ ធីតាសំឡាញ់របស់ខ្ញុំ ក៏ឈ្មោះថាជាធីតារបស់ខ្ញុំ ដូច្នេះ ទើបឲ្យហៅនាងសាមាវតីនោះមក សួរថា “នាង នាងជាកូនស្រីសេដ្ឋីឬ” នាងសាមាវតីពោលថា “ចាស លោកពុក” ។ ឃោសកសេដ្ឋីពោលថា “បើដូច្នោះ នាងកុំគិតឡើយ នាងក៏ធីតារបស់ខ្ញុំដែរ” ទើបថើបនាងសាមាវតីនោះត្រង់សីសៈ ឲ្យស្រី ៥០០ នាក់ដល់នាងសាមាវតីនោះ ដើម្បីប្រយោជន៍ជាបរិវារ តាំងនាងសាមាវតីនោះទុកក្នុងតំណែងធីតាធំរបស់ខ្លួន ។

តមកក្នុងថ្ងៃមួយ ក្នុងនគរនោះ មានការប្រកាសនក្ខត្តប្ញក្ស ។ ក៏ក្នុងការងារនក្ខត្តប្ញក្សនោះ សូម្បីធីតានៃត្រកូលទាំងឡាយមិនបានចេញទៅខាងក្រៅ ក៏នាំគ្នាធ្វើដំណើរទៅកាន់ស្ទឹង ងូតទឹកជាមួយបរិវាររបស់ខ្លួន ។ ព្រោះហេតុនោះ ក្នុងថ្ងៃនោះ សូម្បីនាងសាមាវតី មានស្រ្តី ៥០០ នាក់ ហែហមហើយ ក៏បានទៅដើម្បីងូតទឹក តាមផ្លូវព្រះលានហ្លួងដូចគ្នា ។ ឯព្រះបាទឧទេនប្រថាប់នៅត្រង់សីហបញ្ជរ ទតឃើញនាងសាមាវតីនោះ ទើបត្រាស់សួរថា "ពួកនាងទាំងនេះ ជាស្រីបាំរបស់នរណា" ។

រាជបុរសក្រាបទូលថា "មិនមែនជាស្រីបាំរបស់នរណាទេ ព្រះអង្គ ។

ព្រះបាទឧទេន. បើដូច្នោះ ជាកូនស្រីរបស់នរណា ។

រាជបុរស. ជាកូនស្រីរបស់ឃោសកសេដ្ឋី ព្រះអង្គ នាងឈ្មោះថាសាមាវតី ។

ព្រះបាទឧទេន គ្រាន់តែទតឃើញ ក៏ទ្រង់កើតសេចក្តីស្នេហា ទើបបញ្ជូនរាជសាសន៍ទៅឲ្យសេដ្ឋីថា "សូម លោកសេដ្ឋីចូរបញ្ជូនធីតាមកឲ្យយើង" ។

សេដ្ឋី. បញ្ជូនមិនបានទេ ព្រះអង្គ ។

ព្រះបាទឧទេន. សូមលោកសេដ្ឋីកុំធ្វើយ៉ាងនេះឡើយ សូមលោកសេដ្ឋី បញ្ជូននាងមកចុះ ។

សេដ្ឋី. ពួកខ្ញុំព្រះអង្គឈ្មោះថាជាគហបតី មិនហ៊ានថ្វាយ ព្រោះខ្លាចដល់ការវាយធ្វើបាប ហើយបណ្តេញនាងកុមារិកាចេញទៅ ព្រះអង្គ ។

ព្រះរាជាទ្រង់ខ្ញាល់ ទើបត្រាស់បង្គាប់ឲ្យបិទទ្វារផ្ទះ ចាប់សេដ្ឋីនិងភរិយារបស់សេដ្ឋីអូសចេញទៅខាងក្រៅ ។ នាងសាមាវតីងូតទឹកហើយត្រឡប់មក មិនបានឱកាសដើម្បីចូលកាន់ផ្ទះបាន ទើបសួរថា "មានរឿងអ្វីពុក" បិតាឆ្លើយថា "កូន ព្រះរាជាបញ្ជូនសាសន៍មកព្រោះហេតុតែកូន កាលពួកយើងពោលថា មិនថ្វាយ ទើបត្រាស់បង្គាប់ឲ្យបិទទ្វារផ្ទះ ហើយទ្រង់ត្រាស់បង្គាប់ធ្វើឲ្យពួកយើងនៅខាងក្រៅ" ។ នាងសាមាវតីទើបពោលថា "លោកពុក នេះជាកម្មធ្ងន់ដែលពុកធ្វើហើយ ធម្មតាព្រះរាជាកាលបញ្ជូនសាសន៍មកហើយ កុំទូលថា ខ្ញុំនឹងមិនថ្វាយ គួរទូលថា បើព្រះអង្គទទួលធីតារបស់ខ្ញុំព្រមទាំងបរិវារ ខ្ញុំព្រះអង្គនឹងថ្វាយ យ៉ាងនេះពុក" ។ សេដ្ឋី

ពោលថា "ល្អហើយ កូន កាលបើកូនពេញចិត្ត ពុកក៏នឹងធ្វើតាមយ៉ាងនោះ" ដូច្នេះ ទើបឲ្យបញ្ជូនសាសន៍ទៅថ្វាយព្រះរាជាតាមសេចក្តីនោះ ។ ព្រះរាជាទ្រង់ទទួលថា "ប្រពៃហើយ" ទ្រង់នាំនាងសាមាវតីនោះមកព្រមទាំងបរិវារ ទ្រង់អភិសេកតាំងទុកក្នុងតំណែងជាអគ្គមហេសី ។ ស្ត្រីដ៏សេសក៏បានជាបរិវាររបស់នាងនោះឯង ។

(នេះជារឿងរបស់ព្រះនាងសាមាវតី)

## ប្រវត្តិព្រះនាងវាសុលទត្តា

ក៏ព្រះបាទឧទេនមានព្រះរាជទេវីមួយព្រះអង្គទៀត ទ្រង់ព្រះនាមថា ព្រះនាងវាសុលទត្តា ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌបជ្ជោត ។ សេចក្តីពិស្តារថា ក្នុងក្រុងឧជ្ជេនី មានព្រះរាជាទ្រង់ព្រះនាមថា ព្រះបាទចណ្ឌ-បជ្ជោត ។ ថ្ងៃមួយ ព្រះអង្គស្តេចមកអំពីព្រះរាជឧទ្យាន ទ្រង់ទតមើលសម្បត្តិរបស់ព្រះអង្គហើយ ត្រាស់ថា "សម្បត្តិដូច្នេះ របស់បុគ្គលដទៃណា

មានឬទេហ្ន៎" ។ កាលអាមាត្យក្រាបទូលថា "នេះឈ្មោះថាជាសម្បត្តិអ្វី សម្បត្តិរបស់ព្រះបាទឧទេនក្នុងក្រុងកោសម្ពីច្រើនក្រៃលែង" ដូច្នេះហើយ ត្រាស់ថា "បើដូច្នោះ យើងនឹងចាប់ព្រះបាទឧទេននោះ" ។

អាមាត្យ. នរណាៗ ក៏មិនអាចនឹងចាប់ព្រះរាជាអង្គនោះបានឡើយ ព្រះអង្គ ។

ព្រះរាជា. យើងនឹងធ្វើឧបាយ ចាប់ឲ្យបាន ។

អាមាត្យ. មិនអាចទេ ព្រះអង្គ ។

ព្រះរាជា. ព្រោះហេតុអ្វី ។

អាមាត្យ. ព្រោះព្រះបាទឧទេននេះ ចេះសិល្បៈឈ្មោះហត្ថិកន្តៈ ទ្រង់រាយមន្តហើយដេញពិណហត្ថិកន្តៈ នឹងឲ្យដំរីនោះរត់ទៅបាន នឹងចាប់យកក៏បាន អ្នកទៅដោយពាហនៈដំរី ឈ្មោះថា ស្មើដោយព្រះអង្គមិនមាន ។

ព្រះរាជា. យើងមិនអាចចាប់គេបានទេឬ ។

អាមាត្យ. ព្រះពរព្រះអង្គ ប្រសិនបើព្រះអង្គមានព្រះទ័យបំណងដូច្នេះពិតមែន បើដូច្នោះ សូមព្រះអង្គត្រាស់បង្គាប់ឲ្យជាងធ្វើជាដំរីឈើ ហើយ

បញ្ជូនទៅកាន់ទីនៅរបស់ព្រះបាទឧទេននោះ ព្រះរាជាទ្រង់ស្ដាប់រឿងពាហនៈដំរី ឬពាហនៈសេះហើយ ស្ដេចក៏យាងទៅកាន់ទីឆ្ងាយ យើងនឹងអាចចាប់ស្ដេចឧទេនដែលស្ដេចមកកាន់ក្នុងទីនោះបាន ។ ព្រះរាជាត្រាស់ថា "ឧបាយនេះ ប្រើបាន" ដូច្នេះ ទើបត្រាស់បង្គាប់ឲ្យជាងធ្វើដំរីយន្តសម្រេចដោយឈើយកសំពត់ចាស់រំពីខាងក្រៅ ហើយធ្វើជាក្បូរក្បាច់ ឲ្យលែងទៅត្រង់មាត់ស្រះមួយកន្លែង ក្នុងទីជិតដែនរបស់ព្រះបាទឧទេននោះ ។ បុរស ៦០ នាក់ដើរទៅមកក្នុងពោះដំរីបាន (ដំរីយន្ត) ពួកគេនាំអាចម៍ដំរីមកចោលទុកក្នុងទីនោះៗ ។ ព្រានព្រៃម្នាក់ឃើញដំរីហើយ គិតថា "ដំរីនេះគួរដល់ស្ដេចផែនដីរបស់យើង" ដូច្នេះហើយ ទើបទៅក្រាបទូលព្រះបាទឧទេនថា "បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជួបដំរីដ៏ប្រសើរមួយក្បាលជាដំរីស មានចំណែកប្រៀបដោយកំពូលភ្នំកៃលាស គួរដល់ព្រះអង្គតែម្យ៉ាង" ។ ព្រះបាទឧទេនឲ្យព្រានព្រៃនោះឯងជាអ្នកនាំផ្លូវ ទ្រង់ឡើងសេះព្រមដោយបរិវារ ស្ដេចចេញទៅហើយ ។ ពួកចារបុរសជ្រាបការដែលមករបស់ស្ដេចឧទេន ទើបទៅក្រាបទូលព្រះបាទចណ្ឌបជ្ជោត ។ ព្រះបាទចណ្ឌបជ្ជោត ស្ដេចមកហើយ បាន

ប្រជុំពលនិកាយទុក ២ ចំណែក ដាក់ដំរីទុកត្រង់កណ្ដាល ។ ព្រះបាទឧទេនទ្រង់មិនបានជ្រាបដល់ការមករបស់ព្រះបាទចណ្ឌបជ្ជោត ។ ទើបដេញទៅតាមដំរី ។ មនុស្សដែលនៅខាងក្នុង ក៏ប្រញាប់នាំដំរីឈើរត់ទៅយ៉ាងរហ័ស កាលព្រះរាជាទ្រង់រាយមន្តដេញពិណ ដំរីធ្វើដូចជាមិនបានឮសំឡេងនៃខ្សែពិណ គឺ រត់ទៅតែម្យ៉ាង ។ ព្រះរាជាទ្រង់មិនអាចចាប់ស្ដេចដំរីបានទើបស្ដេចឡើងសេះដេញតាមទៅ ។ កាលព្រះបាទឧទេនដេញតាមដោយប្រញាប់យ៉ាងនេះ ពលនិកាយរបស់ព្រះអង្គក៏អស់កម្លាំង ។ នៅតែព្រះរាជាមួយព្រះអង្គឯងប៉ុណ្ណោះ ។ គ្រានោះ ពួកបុរសរបស់ព្រះបាទចណ្ឌបជ្ជោតដែលស្ទាក់ចាំនៅសងខាង (ផ្លូវ) ក៏ចាប់ព្រះបាទឧទេនថ្វាយស្ដេចផែនដីរបស់ខ្លួន ។ តមក ពលនិកាយរបស់ព្រះបាទឧទេនជ្រាបថា ព្រះរាជារបស់ខ្លួនធ្លាក់ទៅក្នុងអំណាចនៃសត្រូវហើយ ទើបតាំងជំរុំនៅខាងក្រៅ ។

ចំណែកព្រះបាទចណ្ឌបជ្ជោត ទ្រង់បញ្ជាឲ្យចាប់ព្រះបាទឧទេនហើយទ្រង់ត្រាស់ឲ្យយកទៅដាក់ក្នុងគុកដែលសម្រាប់ដាក់ចោរមួយកន្លែង ឲ្យបិទទ្វារ ទ្រង់ផឹកទឹកជ័យបានៈអស់ ៣ ថ្ងៃ ។ ក្នុងថ្ងៃទី ៣ ព្រះបាទឧទេនទ្រង់

សួរអ្នកយាមថា "បាទាំងឡាយ ស្តេចផែនដីរបស់ពួកអ្នកទៅណា" ។

ពួកអ្នកយាម. ស្តេចផែនដីទ្រង់ផឹកទឹកជ័យបានៈព្រោះទ្រង់ត្រេកអរថា "យើងចាប់បច្ចាមិត្របាន" ។

ឧទេន. ស្តេចផែនដីរបស់ពួកអ្នកមានកិរិយាអ្វី ដូចជាស្រី ការចាប់ស្តេចផែនដីដែលជាសត្រូវបានហើយ នឹងលែង ឬសម្លាប់ទើបគួរមិនមែន ឬ បែរជាឲ្យយើងអង្គុយទទួលទុក្ខ ហើយទៅផឹកទឹកជ័យបានៈទៅវិញ" ។

អ្នកយាមនោះ ក៏នាំគ្នាទៅទូលសេចក្តីនោះដល់ព្រះរាជា ។ ព្រះអង្គស្តេចទៅ ត្រាស់សួរថា "បានឮថា លោកនិយាយយ៉ាងនេះ ពិតឬ"

ឧទេន. ត្រូវហើយ មហារាជ ។

ចណ្ឌបជ្ជោត. ល្អហើយ យើងនឹងលែងលោក យើងដឹងថា លោកមានមន្តដូច្នេះ លោកនឹងឲ្យមន្តនោះដល់យើងទេ ។

ឧទេន. លែងហើយ ខ្ញុំព្រះអង្គនឹងឲ្យ ក្នុងវេលារៀន ចូរថ្វាយបង្គំខ្ញុំព្រះអង្គ ហើយរៀនមន្តនោះ តើលោកថ្វាយបង្គំខ្ញុំព្រះអង្គឬទេ ។

ច. យើងនឹងថ្វាយបង្គំលោកដូចម្តេច ។

ឧ. លោកមិនថ្វាយបង្គំឬ ។

ច. យើងមិនថ្វាយបង្គំទេ ។

ឧ. សូម្បីខ្ញុំព្រះអង្គ ក៏មិនឲ្យ ។

ច. បើដូច្នេះ យើងនឹងដាក់អាជ្ញាដល់លោក ។

ឧ. សូមធ្វើចុះ ព្រោះលោកជាធំលើរាងកាយរបស់ខ្ញុំ តែមិនមែនជាធំលើចិត្តខ្ញុំទេ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យដ៏អង់អាចរបស់ព្រះបាទឧទេនហើយ ទើបទ្រង់ត្រិះរិះថា "យើងនឹងរៀនមន្តរបស់ស្តេចឧទេននេះបានដូចម្តេចហ្ន៎" ។ ហើយទ្រង់គិតបានថា "យើងមិនអាចឲ្យអ្នកដទៃចេះមន្តនេះទេ យើងនឹងធីតារបស់យើងរៀនក្នុងសម្នាក់ស្តេចឧទេននេះ ហើយទើបរៀនក្នុងសម្នាក់របស់នាង ។ លំដាប់នោះ ព្រះបាទចណ្ឌបជោតទើបត្រាស់ចំពោះព្រះបាទឧទេននោះថា "លោកនឹងបង្រៀនដល់មនុស្សដទៃដែលថ្វាយបង្គំលោកឬ"

ឧ. យ៉ាងនោះឯង មហារាជ ។

ច. បើដូច្នោះ ក្នុងផ្ទះរបស់យើងមានស្រីគមម្នាក់ នាងឈរនៅខាង

ក្រៅវាំងនួន ចូរប្រាប់មន្តដល់ស្រីនោះដែលអង្គុយនៅខាងក្នុងវាំងននោះចុះ ។

ឧ. ល្អហើយ មហារាជ នាងជាមនុស្សគមឬ មនុស្សគមក៏ដោយចុះ កាលនាងថ្វាយបង្គំ ខ្ញុំព្រះអង្គនឹងបង្រៀន ។

លំដាប់នោះ ព្រះរាជាស្តេចយាងទៅត្រាស់ប្រាប់ព្រះនាងវាសុលទត្តា រាជធីតាថា "កូនស្រី បុរសមានរោគឃ្លង់ម្នាក់ ចេះមន្តកាត់ថ្ងៃមិនបាន ពុកមិនអាចឲ្យអ្នកដទៃចេះមន្តនោះទេ កូនអង្គុយនៅខាងក្នុងវាំងននថ្វាយបង្គំបុរសនោះហើយរៀនមន្ត បុរសនោះឈរនៅខាងក្រៅវាំងនន នឹងបង្រៀន (មន្ត) ដល់កូន ពុកនឹងរៀនពីសំណាក់របស់កូន" ។ ស្តេចចណ្ឌបជ្ជោត ត្រាស់ធ្វើព្រះរាជធីតាថាជាស្រីគម ចំណែកព្រះបាទឧទេនថាជាបុរសកើតឃ្លង់ ដូច្នេះ ព្រោះទ្រង់ខ្លាចអ្នកទាំងពីរនោះនឹងធ្វើសន្ថវៈដល់គ្នានឹងគ្នា ។ ព្រះបាទឧទេនប្រថាប់ឈរនៅខាងក្រៅវាំងនន បានបង្រៀនមន្តដល់ព្រះនាងដែលបានថ្វាយបង្គំហើយ អង្គុយខាងក្នុងវាំងនន ។

តមកថ្ងៃមួយ ព្រះបាទឧទេនត្រាស់នឹងព្រះនាង សូម្បីស្តេចត្រាស់

ប្រាប់រឿយៗ ក៏ព្រះនាងមិនអាចនឹងពោលបទនៃមន្តបាន ទើបទ្រង់ត្រាស់ថា "ណ៎ស្រីគម! បបូរមាត់របស់នាងឯងក្រាស់ណាស់ នាងឯងចូរពោលយ៉ាងនេះ" ។ ព្រះនាងទ្រង់ខ្ញាល់ ទើបត្រាស់ថា "យើ! អាគម្ពង់ មានជាតិអាក្រក់ ឯងនិយាយអ្វី មនុស្សដូចយើងជាស្រីគមឬ" ដូច្នេះ ហើយទ្រង់បើកវាំងននឡើង កាលព្រះបាទឧទេនត្រាស់សួរថា "នាងជានរណា" ទើបត្រាស់ប្រាប់ថា "យើងឈ្មោះវាសុលទត្តា ធីតារបស់ស្តេចដែនដី" ។

ព្រះបាទឧទេន. បិតារបស់នាង កាលត្រាស់ដល់យើង បានត្រាស់ប្រាប់ថា "នាងស្រីគម" ។

វាសុលទត្តា. សូម្បីទ្រង់ត្រាស់ដល់យើង ព្រះបិតាក៏ទ្រង់ត្រាស់ថា លោកជាបុរសឃ្លង់ ។

ទាំងពីរព្រះអង្គនោះ ទ្រង់ត្រិះរិះថា "ព្រះរាជាទ្រង់ត្រាស់ពាក្យនោះ ព្រោះខ្លាចយើងធ្វើសន្ថវៈនឹងគ្នា" ។ ហើយទ្រង់ធ្វើសន្ថវៈជាមួយគ្នាខាងក្នុងវាំងននោះឯង ។ តាំងអំពីនោះមក ការរៀនមន្ត ឬការរៀនសិល្បៈទើបមិនមាន ។ ចំណែកព្រះរាជាទ្រង់សួរព្រះធីតាជារឿយៗ ថា កូនរៀនសិល្បៈ

យូរទៀតឬកូន ។ ព្រះនាងត្រាស់ថា "បពិត្រព្រះបិតា ខ្ញុំព្រះអង្គនៅរៀនទៀត" ។ តមកថ្ងៃមួយ ព្រះបាទឧទេនត្រាស់នឹងព្រះនាងថា "នាងដ៏ចម្រើន ឈ្មោះថា នាទីដែលស្វាមីគប្បីធ្វើ មាតាបិតា បងប្អូនប្រុស និងបងប្អូនស្រី មិនអាចធ្វើបានឡើយ ប្រសិនបើនាងឲ្យជីវិតដល់យើង យើងនឹងស្រី ៥០០ នាក់ជាបរិវារ ហើយនឹងឲ្យតំណែងជាអគ្គមហេសីដល់នាង" ។ ព្រះនាងត្រាស់ថា "បើព្រះអង្គតាំងនៅក្នុងព្រះតម្រាស់នេះ ខ្ញុំព្រះអង្គ ក៏នឹងថ្វាយជីវិតទាននេះដល់ព្រះអង្គ" ។ ព្រះបាទឧទេនត្រាស់តបថា "ប្អូនស្រី យើងអាច" ។ ព្រះនាងទ្រង់ទទួលព្រះតម្រាស់ថា "យល់ព្រម" ដូច្នេះ ហើយក៏ស្ដេចទៅកាន់សំណាក់របស់ព្រះរាជបិតា ថ្វាយបង្គំហើយ បានឈរនៅក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះរាជាត្រាស់សួរព្រះនាងថា "សិល្បៈសម្រេចហើយឬ កូនស្រី" ។

វាសុលទត្តា. បពិត្រព្រះបិតា សិល្បៈនៅមិនទាន់សម្រេចទេ ។

លំដាប់នោះ ព្រះបាទចណ្ឌបជ្ជោតត្រាស់សួរព្រះនាងថា ហេតុអ្វីកូនស្រី ។

វាសុលទត្តា. បពិត្រព្រះបិតា នាងខ្ញុំគួរនឹងបានទ្វារណាមួយ (សិទ្ធិពិសេសក្នុងការចូលចេញ) ជាមួយពាហនៈមួយក្បាល ។

ចណ្ឌបជ្ជោត. ហេតុអ្វី កូនស្រី ។

វាសុលទត្តា. បពិត្រព្រះបិតា ព្រោះថា មានឱសថមួយប្រភេទត្រូវរក្សាក្នុងវេលាយប់ ដោយសញ្ញាតាមផ្កាយ ដើម្បីជាប្រយោជន៍ឧបការៈដល់ការរៀនមន្ត ព្រោះដូច្នោះ ក្នុងវេលាដែលខ្ញុំព្រះអង្គចេញទៅក្នុងវេលា ឬខុសវេលា ទើបគួរនឹងបានទ្វារណាមួយ ជាមួយពាហនៈមួយក្បាល ។

ព្រះរាជាត្រាស់ថា "បាន" ។

ព្រះឧទេន និងព្រះនាងវាសុលទត្តា ទ្រង់បានកាន់យកទ្វារមួយដែលខ្លួនពេញចិត្តទុកក្នុងដៃរបស់ខ្លួន ។

ឯព្រះរាជា មានពាហនៈ ៥ គឺ ដំរីញី ១ ឈ្មោះភទ្ទវតី ទៅបានមួយថ្ងៃ ៥០ យោជន៍ , ទាសៈឈ្មោះកាកៈ ទៅបានមួយថ្ងៃ ៦០ យោជន៍ , សេះ ២ ក្បាល គឺ សេះវេលកង្សិ និងសេះមុញ្ជកេសិ ទៅបានមួយថ្ងៃ ១០០ យោជន៍ , ដំរីនាឡាគិរី ទៅបានថ្ងៃមួយ ១២០ យោជន៍ ។

បានឮមកថា ព្រះរាជាអង្គនោះ ក្នុងកាលព្រះពុទ្ធទ្រង់មិនទាន់ឧប្បត្តិឡើង ទ្រង់ជាអ្នកបម្រើរបស់ឥស្សរជនម្នាក់ ។ តមកថ្ងៃមួយ កាលឥស្សរ-ជននោះចេញទៅក្រៅព្រះនគរ ងូតទឹកហើយត្រឡប់មក ព្រះបច្ចេកពុទ្ធមួយព្រះអង្គចូលកាន់ព្រះនគរដើម្បីបិណ្ឌបាត មិនបានភិក្ខាសូម្បីត្រឹមតែបន្តិច ព្រោះពួកអ្នកស្រុកទាំងអស់ត្រូវមារបណ្ដាលចិត្ត មានបាត្រដូចជាលាងទុកហើយ (បាត្រ) ទ្រង់ក៏និមន្តចេញទៅ ។ លំដាប់នោះ មារចូលទៅរកព្រះបច្ចេកពុទ្ធ ដោយភេទដែលមិនមាននរណាស្គាល់ ហើយសួរលោកក្នុងខណៈដែលលោកនិមន្តដល់ទ្វារព្រះនគរថា “លោកម្ចាស់ លោកបានអ្វីៗ ខ្លះទេ”? ព្រះបច្ចេកពុទ្ធតបថា “អ្នក ជាអ្នកធ្វើឲ្យយើងមិនបានអ្វីមិនមែនឬ?” ។

មារ. បើដូច្នោះ សូមលោកម្ចាស់ចូរនិមន្តត្រឡប់ទៅវិញម្ដងទៀតចុះ ខ្ញុំព្រះអង្គមិនធ្វើទេ ។

ព្រះបច្ចេកពុទ្ធ. យើងមិនត្រឡប់ទៅវិញទៀតទេ ។

ប្រសិនបើព្រះបច្ចេកពុទ្ធ ព្រះអង្គគប្បីនិមន្តត្រឡប់ទៅវិញ មារនោះនឹងបណ្ដាលអ្នកស្រុកទាំងអស់នោះ ឲ្យទះដៃសើចចំអកដល់ព្រះអង្គ កាល

ព្រះបច្ចេកពុទ្ធមិននិមន្តចូលទៅ មារក៏វិនាសក្នុងពេលនោះឯង ។ ខណៈនោះ ឥស្សរជននោះ គ្រាន់តែឃើញព្រះបច្ចេកពុទ្ធទ្រង់និមន្តមកហើយដោយបាត្រទទេ ទើបថ្វាយបង្គំ ហើយសួរថា "បពិត្រលោកម្ចាស់ លោកម្ចាស់បានអ្វីៗ ខ្លះទេ? លោកឆ្លើយថា "អ្នកមានអាយុ អាត្មានិមន្តទៅហើយ ហើយនិមន្តមកវិញ" ។ គេគិតថា "លោកម្ចាស់មិនឆ្លើយតបតាមពាក្យដែលយើងសួរ ត្រឡប់ជាឆ្លើយពាក្យដទៃវិញ លោកប្រាកដជានៅមិនទាន់បានអ្វីៗ ក្នុងវេលានោះ គេក្រឡេកមើលបាត្ររបស់លោក ឃើញបាត្រទទេ ក៏ជាអ្នកក្លៀវក្លា (មានសទ្ធា) តែមិនអាចទទួលបាត្រ ព្រោះនៅមិនទាន់ដឹងថា កត្តក្នុងផ្ទះរបស់ខ្លួនសម្រេចហើយ ឬនៅមិនទាន់សម្រេច ទើបពោលថា "លោកម្ចាស់ សូមលោកម្ចាស់រង់ចាំបន្តិច" ដូច្នេះ ក៏ប្រញាប់រត់ទៅផ្ទះ សួរថា "កត្តសម្រាប់យើងមានហើយឬ" កាលអ្នកបម្រើប្រាប់ថា "មានហើយ" ទើបពោលនឹងអ្នកបម្រើនោះថា "បា! អ្នកដទៃដែលរហ័សជាងអ្នករមែងមិនមាន ដោយសន្ទុះដើងដ៏រហ័ស អ្នកចូរទៅឲ្យដល់លោកម្ចាស់ឯណោះ ពោលថា លោកម្ចាស់ សូមលោកម្ចាស់ចូរឲ្យបាត្រ ហើយទទួលបាត្រមក

ឲ្យរហ័ស” ។ គេក៏រត់ទៅតាមពាក្យដែលប្រាប់នោះត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ទទួលបាត្រនាំមកហើយ ។ សុមនសេដ្ឋីឥស្សរជន ក៏ធ្វើបាត្រឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា “អ្នកចូរប្រញាប់ទៅ ថ្វាយបាត្រនេះដល់លោកម្ចាស់ យើងនឹងចែកចំណែកបុណ្យដែលកើតពីទាននេះដល់អ្នក” ។ គេទទួលបាត្រនោះហើយ ទៅដោយជើងយ៉ាងរហ័ស ថ្វាយបាត្រដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា “បពិត្រលោកម្ចាស់ វេលាដ៏ប្រញាប់យ៉ាងនេះ ខ្ញុំព្រះអង្គទៅមកដោយសន្ទុះជើងដ៏រហ័ស ដោយផលនៃសន្ទុះជើងដ៏រហ័សរបស់ខ្ញុំនេះ សូមពាហនៈទាំងឡាយ ៥ ដែលនឹងអាចទៅបានមួយថ្ងៃ ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ ចូរកើតឡើងដល់ខ្ញុំព្រះអង្គ មួយវិញទៀត រាងកាយរបស់ខ្ញុំព្រះអង្គដែលមក និងទៅ ត្រូវកំដៅព្រះអាទិត្យហើយ ដោយផលនៃការត្រូវកំដៅព្រះអាទិត្យនោះ សូមឲ្យខ្ញុំព្រះអង្គមានតេជៈផ្សាយទៅដូចជាពន្លឺនៃព្រះអាទិត្យ ក្នុងទីដែលបានកើតហើយ ចំណែកបុណ្យព្រោះបិណ្ឌបាតនេះ ដែលចៅហ្វាយនាយឲ្យហើយដល់ខ្ញុំ ដោយផលដែលហូរចេញអំពីចំណែកបុណ្យនោះ សូមឲ្យខ្ញុំព្រះអង្គ

ចូរជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ” ។ ព្រះបច្ចេកពុទ្ធ ពោលថា “សូមសេចក្តីប្រាថ្នាដែលអ្នកតាំងទុកនេះ ចូរសម្រេច” ហើយបាន ធ្វើអនុមោទនាថា ៖

វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេច
ដោយឆាប់រួសរាន់ដល់អ្នក សូមតម្រិះទាំងពួងចូរពេញ
ដូចព្រះច័ន្ទ ដែលមានក្នុងតិថីទី ១៥ កើត វត្ថុដែលអ្នក
ត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេចដោយឆាប់រួស
រាន់ដល់អ្នក សូមតម្រិះទាំងពួង ចូរពេញដូចកែវមណី
ឈ្មោះជោតិរស ។

បានជ្រាបថា គាថា ២ គាថានេះឯង ឈ្មោះថា គាថាអនុមោទនា របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ រតនៈ គឺ កែវមណី ដែលឲ្យសម្រេច នូវវត្ថុតាមប្រាថ្នាទាំងពួង ហៅថា “កែវមណីជោតិរស” ក្នុងគាថានោះ ។ នេះជាបុព្វចរិយានៃបុរសអ្នកបម្រើនោះ ។ គេបានជាស្តេចចណ្ឌបជ្ជោតក្នុង កាលឥឡូវនេះ ។ម្យ៉ាងទៀត ព្រោះផលដែលហូរចេញនៃកម្មនោះ ពាហនៈ

ទាំង ៥ នេះទើបកើតឡើង ។

តមកថ្ងៃមួយ ព្រះរាជាស្តេចទៅដើម្បីត្រាច់កម្សាន្តក្នុងព្រះរាជឧទ្យាន ព្រះបាទឧទេនទ្រង់ត្រិះរិះថា "យើងគប្បីនឹងរត់ចេញទៅក្នុងថ្ងៃនេះ" ទើបទ្រង់ដាក់ថង់ស្បែកធំៗ ឲ្យពេញដោយមាស និងប្រាក់លើខ្នងសេះ ហើយនាំព្រះនាងវាសុលទត្តាចេញទៅ ។ ទាហានរក្សាវាំងទាំងឡាយឃើញព្រះបាទឧទេនរត់ចេញទៅ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនពលទៅដោយព្រះតម្រាស់បញ្ជាថា "ពួកអ្នក ចូរដេញតាមឲ្យលឿន" ។ ព្រះបាទឧទេនទ្រង់ដឹងថាពលនិកាយដេញតាម ទើបទ្រង់ស្រាយថង់កហាបណៈធ្វើកហាបណៈឲ្យធ្លាក់ (រាយប៉ាយ) ។ ពួកពលនិកាយក៏នាំគ្នាឈប់រើសកហាបណៈ ហើយទើបដេញតាមទៀត ។ ចំណែកព្រះបាទឧទេន ក៏ស្រាយថង់មាសហើយធ្វើឲ្យធ្លាក់ទៀត កាលពលនិកាយទាំងនោះមានដំណើរយឺតយូរ ព្រោះល្មោភក្នុងមាស ស្តេចក៏យាងដល់ជំរំរបស់ព្រះអង្គដែលតាំងនៅខាងក្រៅ ។ ខណៈនោះ ពលនិកាយកាលបានឃើញព្រះរាជារបស់ខ្លួនមក ក៏ហែហមស្តេចឲ្យយាងចូលកាន់ព្រះនគររបស់ខ្លួនវិញ ។ លុះព្រះរាជាស្តេច

យានដល់ហើយ ក៏អភិសេកព្រះនាងវាសុលទត្តា តាំងទុកក្នុងតំណែងជា អគ្គមហេសី ។

(នេះជារឿងរបស់ព្រះនាងវាសុលទត្តា)

## ប្រវត្តិព្រះនាងមាគន្ទិយា

មួយវិញទៀត ស្ត្រីដទៃឈ្មោះថា នាងមាគន្ទិយា ក៏បានតំណែងជាអគ្គមហេសីអំពីសំណាក់របស់ព្រះរាជា (ព្រះបាទឧទេន) ។ បានឮថា នាងជាធីតារបស់ព្រាហ្មណ៍ឈ្មោះ គន្ទិយៈ ក្នុងដែនកុរុ សូម្បីមាតារបស់នាងក៏ឈ្មោះថា មាគន្ទិយា ដូចគ្នា ។ សូម្បីឱពុកមារបស់នាងក៏ឈ្មោះថា មាគន្ទិយៈដែរ ។ នាងជាស្ត្រីមានរូបរាងស្អាតប្រៀបដូចទេពអប្សរ ។ បិតារបស់នាង មិនអាចរកស្វាមីដ៏សមគួរដល់នាងបាន សូម្បីត្រូវត្រកូលធំៗសូមអង្វរ ក៏ត្រឡប់ឆ្លើយថា "ពួកលោកមិនសមគួរដល់កូនស្រីរបស់ខ្ញុំទេ" ហើយដេញឲ្យទៅវិញ ។ តមកថ្ងៃមួយ ព្រះសាស្តាទ្រង់ពិចារណាមើលសត្វ

លោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃអនាគាមិផលរបស់មាគន្ទិយ-ព្រាហ្មណ៍ ព្រមទាំងភរិយា ទ្រង់ប្រដាប់បាត្រ និងចីវររបស់ព្រះអង្គហើយ ស្ដេចបានយាងទៅកាន់ស្ថានទីបម្រើភ្លើងរបស់ព្រាហ្មណ៍នោះ ក្នុងខាងក្រៅនិគម ។ ព្រាហ្មណ៍នោះក្រឡេកឃើញអត្តភាពដ៏អស្ចារ្យ ដោយភាពស្អាតនៃព្រះរូបកាយរបស់ព្រះតថាគតហើយ ក៏គិតថា "ឈ្មោះថា បុរសដទៃស្មើដោយបុរសនេះ រមែងមិនមានក្នុងលោក បុរសនេះទើបសមគួរដល់ធីតារបស់យើង យើងនឹងឲ្យធីតារបស់យើងដល់បុរសនេះ ដើម្បីប្រយោជន៍នឹងបានថែរក្សាគ្នា" ដូច្នេះហើយទើបពោលថា "សមណៈ ខ្ញុំមានធីតាម្នាក់ ខ្ញុំនៅមិនទាន់ឃើញបុរសសមគួរដល់នាង អស់កាលមានប្រមាណប៉ុណ្ណោះ លោកជាអ្នកសមគួរដល់នាង និងនាងក៏ជាអ្នកសមគួរដល់លោកដោយពិត លោកគួរបាននាងទុកជាបាទបរិចារិកា និងនាងក៏គួរបានលោកជាភស្ដា យើងនឹងឲ្យនាងដល់លោក លោកចូរឈរចាំនៅក្នុងទីនេះរហូតខ្ញុំនឹងត្រឡប់មកវិញ ។ ព្រះសាស្ដាមិនបានត្រាស់អ្វីឡើយៗ ទ្រង់នៅដោយតុណ្ហីភាព ។ ព្រាហ្មណ៍ប្រញាប់ទៅកាន់ផ្ទះពោល (នឹងនាងព្រាហ្មណី) ថា "នាង! នាង!

យើងឃើញអ្នកដែលសមគួរដល់កូនស្រីរបស់យើងហើយ នាងចូរតែងខ្លួនកូនឲ្យរហ័សៗ” ។ ឲ្យធីតានោះតែងខ្លួនហើយ ក៏នាំទៅព្រមជាមួយនាងព្រាហ្មណី បានទៅកាន់សំណាក់របស់ព្រះសាស្តា ។ ទូទាំងព្រះនគរមានការភ្ញាក់ផ្អើលថា បានឮថា ព្រាហ្មណ៍នេះមិនឲ្យកូនស្រីទៅនរណាៗ ដោយអាងថា “បុរសដែលសមគួរដល់កូនស្រីរបស់យើងមិនមាន” អស់កាលមានប្រមាណប៉ុណ្ណេះ (តែ) ពោលថា ថ្ងៃនេះ យើងឃើញបុរសដែលសមគួរដល់កូនស្រីរបស់យើងហើយ បុរសនោះនឹងដូចអ្វីទៅ ពួកយើងនឹងមើលបុរសនោះ ។ មហាជនទើបចេញទៅជាមួយនឹងព្រាហ្មណ៍នោះដែរ ។ កាលព្រាហ្មណ៍នោះនាំធីតាមក ព្រះសាស្តាមិនបានប្រថាប់ក្នុងទីដែលព្រាហ្មណ៍នោះនិយាយទេ ទ្រង់សំដែងព្រះចេតិយ គឺ ស្នាមព្រះបាទទុកក្នុងទីនោះហើយ ស្តេចទ្រង់យាងប្រថាប់ក្នុងទីដទៃ ។ ពិតហើយ ចេតិយ គឺ ស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដនៅក្នុងទីដែលព្រះអង្គទ្រង់អធិដ្ឋានហើយជាន់ (ប្រថាប់) ទុកប៉ុណ្ណោះ រមែងមិនប្រាកដក្នុងទីដទៃ មួយទៀតចេតិយ គឺ ស្នាមព្រះបាទ ជាវត្ថុដែលទ្រង់អធិដ្ឋានទុកដើម្បីអនុគ្រោះដល់

បុគ្គលពួកណា បុគ្គលពួកនោះតែម្យ៉ាងរមែងឃើញចេតិយ គឺ ស្នាមព្រះបាទនោះ ក៏សត្វមានដំរីជាដើមជាន់ក្ដី មហាមេឃ (ភ្លៀងធំ) ធ្លាក់ចុះមកក្ដី ខ្យល់ព្យុះបក់មកក្ដី កាលឲ្យបុគ្គលនោះមើលមិនឃើញ នរណាៗ ក៏មិនអាចនឹងលុបចេតិយ៍ គឺ ស្នាមព្រះបាទនោះបានឡើយ ។ លំដាប់នោះ នាងព្រាហ្មណីពោលនឹងព្រាហ្មណ៍ថា "បុរសនេះនៅទីណា?" ព្រាហ្មណ៍គិតថា "យើងបាននិយាយចំពោះគេថា លោកចូរឈរនៅក្នុងទីនេះ គេទៅក្នុងទីណាហ្ន៎" ។ ក្រឡេកមើលហើយ ក៏ឃើញចេតិយ គឺ ស្នាមព្រះបាទ ទើបពោលថា "នេះជាស្នាមជើងរបស់បុរសនោះ" ។ នាងព្រាហ្មណីពិចារណាតាមលក្ខណៈមន្តហើយតាមនៃស្នាមព្រះបាទ ព្រោះនាងជាអ្នកឈ្លាសវៃក្នុងវេទទាំង ៣ ព្រមទាំងមន្តទាយលក្ខណៈ បានពោលថា "ព្រាហ្មណ៍ នេះមិនមែនជាស្នាមជើងរបស់អ្នកសេពកាមគុណ ៥ ទេ" ហើយពោលគាថានេះថា ៖

ក៏បុគ្គលជារាគៈ គប្បីមានស្នាមជើងខ្ពស់ឡើង (ផតកណ្ដាល)

បុគ្គលជាទោសៈ រមែងមានស្នាមកែងជើងលិចចុះ (ធួន់កែង)

បុគ្គលមោហៈ រមែងមានស្នាមចុងជើងលិចចុះ (ធ្ងន់ខាងចុងម្រាមជើង) បុគ្គលមានកិលេសជាគ្រឿងបិទបាំងត្រូវដកចេញហើយ មានស្នាមជើងដូច្នេះឯង ។

លំដាប់នោះ ព្រាហ្មណ៍និយាយថា "នែ៎នាង នាងជាអ្នកមានប្រក្រតីឃើញមន្តដូចជាការឃើញក្រពើក្នុងពាងទឹក និងដូចជាឃើញចោរនៅក្នុងផ្ទះ ចូរស្ងៀមចុះ" ។ នាងព្រាហ្មណីពោលថា "ព្រាហ្មណ៍ លោកប្រាថ្នានឹងនិយាយពាក្យណា ក៏ចូរនិយាយពាក្យនោះចុះ ស្នាមជើងនេះមិនមែនជាស្នាមជើងរបស់អ្នកសេពកាមគុណ ៥ ទេ" ។ ព្រាហ្មណ៍ក្រឡេកមើលទៅដោយជុំវិញ ឃើញព្រះសាស្តាហើយ ពោលថា "នេះ គឺ បុរសនោះ" ទើបបានពោលថា "សមណៈ ខ្ញុំនឹងឲ្យធីតាដល់លោកដើម្បីការថែរក្សាគ្នា ។ ព្រះសាស្តាទ្រង់មិនត្រាស់អ្វីឡើយថា "តថាគតមិនមានសេចក្តីត្រូវការដោយធីតារបស់លោកទេ" តែត្រាស់ថា "ម្នាលព្រាហ្មណ៍ តថាគតនឹងពោលហេតុមួយដល់អ្នក" ។ កាលព្រាហ្មណ៍ពោលថា "ចូរពោលចុះសមណៈ" ទើបត្រាស់ប្រាប់ការដែលព្រះអង្គត្រូវមារជាប់តាមតាំងអំពីចេញបួសរហូតដល់

ក្រោមដើមអជបាលនិគ្រោធ និងការប្រលោមរបស់ធីតាមារទាំងឡាយដែលមកហើយដើម្បីរម្ងាប់សេចក្តីសោករបស់មារនោះថា "ឥឡូវនេះ ព្រះសមណគោតមកន្លងវិស័យរបស់យើងហើយ" ប្រកបឡើងដោយអំណាចនៃភេទនាងកុមារិកាជាដើមត្រង់ដើមអជបាលនិគ្រោធ ហើយត្រាស់ព្រះគាថានេះថា ៖

តថាគតមិនមានសេចក្តីត្រេកអរក្នុងមេថុន ព្រោះឃើញ
នាងតណ្ហា នាងអរតី និងនាងរាគា ធ្វើដូចម្តេចនឹងមាន
សេចក្តីត្រេកអរ ព្រោះឃើញធីតារបស់អ្នកនេះ ដែល
ពេញទៅដោយមូត្រ និងករីសៈ តថាគតមិនប្រាថ្នានឹងប៉ះ
ពាល់ធីតារបស់អ្នកសូម្បីដោយម្រាមជើង ។

ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍ និងព្រាហ្មណីក៏តាំងនៅក្នុងអនាគាមិផល ចំណែកនាងមាគន្ទិយាដែលជាធីតា ចងអាឃាតក្នុងព្រះសាស្តាថា "ប្រសិនបើសមណៈនោះ មិនមានសេចក្តីត្រូវការយើង ក៏គួរពោលដល់ការដែលខ្លួនមិនមានសេចក្តីត្រូវការ តែសមណៈនេះ (ត្រឡប់) ធ្វើឲ្យយើងជាអ្នកពេញទៅដោយមូត្រ និងករីសៈ ណេ្ហីយចុះ យើងអាស្រ័យការដល់ព្រម

នៃជាតិ ត្រកូល ប្រទេស ភោគៈ យស និងវ័យរបស់ខ្លួន បានកស្ដាំបែប នោះហើយ នឹងជីងកម្មដែលគួរធ្វើដល់សមណគោតម” ។

សួរថា ក៏ព្រះសាស្ដាទ្រង់ជ្រាបការកើតឡើងនៃសេចក្ដីអាឃាតក្នុង ព្រះអង្គរបស់នាង ឬមិនទ្រង់ជ្រាប ។

ឆ្លើយថា ទ្រង់ជ្រាបដូចគ្នា ។

សួរថា បើព្រះអង្គទ្រង់ជ្រាប ហេតុអ្វីទើបត្រាស់ព្រះគាថា ។

ឆ្លើយថា ព្រះអង្គទ្រង់ត្រាស់ព្រះគាថានេះ ដោយសេចក្ដីអនុគ្រោះ ដល់ព្រាហ្មណ៍ និងព្រាហ្មណីទាំងពីរនាក់នោះ ។

ធម្មតា ព្រះពុទ្ធទាំងឡាយទ្រង់មិនគិតដល់ការចងនូវអាឃាត ទ្រង់ រមែងសំដែងធម៌ដោយអំណាចនៃបុគ្គលអ្នកគួរសម្រេចមគ្គផលប៉ុណ្ណោះ ។ មាតាបិតានាំនាងមាគន្ទិយានោះទៅជួបនាយចូឡមាគន្ទិយៈដែលជាប្អូនប្រុស ហើយទៅកាន់សំណាក់របស់ព្រះសាស្ដា ទាំងពីរនាក់បួសហើយ ក៏បាន សម្រេចអរហត្តផល ។ ចំណែកនាយចូឡមាគន្ទិយៈគិតថា “ធីតារបស់ យើងមិនគួរដល់មនុស្សថោកទាប គួរដល់ព្រះរាជាតែម្យ៉ាង” ទើបនាំនាង

ទៅកាន់ក្រុងកោសម្ពី តុបតែងដោយគ្រឿងប្រដាប់ទាំងពួងហើយ បានថ្វាយដល់ព្រះបាទឧទេនព្រមទាំងក្រាបទូលថា "ស្រីកែវនេះ គួរដល់ព្រះសម្មតិទេព" ។ ព្រះបាទឧទេន គ្រាន់តែបានទតឃើញនាង ក៏កើតសេចក្តីស្នេហាយ៉ាងក្រៃលែង ទើបបានប្រទានការអភិសេក ធ្វើមាតុគ្រាម ៥០០ នាក់ឲ្យជាបរិវាររបស់នាង តាំងទុកក្នុងតំណែងជាអគ្គមហេសី ។

( នេះជារឿងរបស់នាងមាគន្ទិយា )

ព្រះបាទឧទេនទ្រង់មានអគ្គមហេសី ៣ ព្រះអង្គ ដែលមានស្រីស្នំ ១.៥០០ នាក់ជាបរិវារ ដោយប្រការដូច្នេះ ។

## សេដ្ឋី ៣ នាក់ និងតាបស

ក៏ក្នុងសម័យនោះឯង ក្រុងកោសម្ពីមានសេដ្ឋី ៣ នាក់ គឺ ឃោសកសេដ្ឋី កុក្កុដសេដ្ឋី បាវារិកសេដ្ឋី ។ សេដ្ឋីទាំងនោះ ក្នុងកាលវស្សូបនាយិកាជិតចូលមកដល់ហើយ ឃើញតាបស ៥០០ នាក់ មកពីហិមវន្តប្រទេស កំពុងត្រាច់ទៅដើម្បីភិក្ខាក្នុងព្រះនគរ ក៏ជ្រះថ្លា ទើបនិមន្តឲ្យគង់ឲ្យឆាន់ហើយ ទទួលបដិញ្ញាឲ្យនៅក្នុងសំណាក់របស់ខ្លួនអស់ ៤ ខែ ឲ្យបដិញ្ញាដើម្បីត្រូវការឲ្យត្រឡប់មកទៀត ក្នុងសម័យសម្បូរទៅដោយភ្លៀង (រដូវភ្លៀង) កន្លងទៅហើយ ។ ចាប់ផ្ដើមពីនោះមក សូម្បីតាបសទាំងឡាយនៅក្នុងហិមវន្តប្រទេសអស់ ៨ ខែ និងនៅក្នុងសំណាក់របស់សេដ្ឋីទាំងនោះអស់ ៤ ខែ ។ តាបសទាំងនោះ កាលមកពីហិមវន្តប្រទេសក្នុងវេលាដទៃ ឃើញដើមជ្រៃធំមួយដើមត្រង់ជាយព្រៃ ទើបអង្គុយត្រង់គល់ដើមជ្រៃនោះ បណ្ដាតាបសទាំងនោះ តាបសជាប្រធានគិតថា "ទេវតាដែលស្ថិតនៅនឹងដើមឈើនេះ មិនមែនជាទេវតាមានសក្ដិតូចទេ ទេវរាជដែលមានសក្ដិធំតែម្យ៉ាងគប្បីមាននៅត្រង់ដើមឈើនេះ ទើបជាការល្អ ប្រសិនបើទេវរាជនេះ

គប្បីឲ្យទឹកគួរដល់ការផឹកដល់ពួកឥសី” ។ ទេវបុត្តនោះបានថ្វាយទឹកផឹកហើយ ។ តាបសគិតដល់ទឹកងូត ។ ទេវបុត្តក៏បានថ្វាយទឹកងូត ។ តពីនោះ តាបសជាប្រធានក៏គិតដល់ភោជន ។ ទេវបុត្តក៏បានថ្វាយភោជន ។ លំដាប់នោះ តាបសមានបរិវិតក្កៈនេះថា “ទេវបុត្តនេះឲ្យវត្ថុគ្រប់យ៉ាងដែលយើងគិតហើយៗ ឱហ្ន៎ យើងគប្បីឃើញទេវបុត្ត” ។ ទេវបុត្តនោះក៏សម្តែងខ្លួនចេញអំពីដើមឈើនោះ ។ ខណៈនោះ តាបសទាំងឡាយសួរទេវបុត្តនោះថា “បពិត្រទេវបុត្ត អ្នកមានសម្បត្តិច្រើន សម្បត្តិនេះអ្នកបានហើយព្រោះធ្វើកម្មអ្វី ។

ទេវបុត្ត. សូមកុំសួរឡើយ លោកម្ចាស់ ។

តាបស. ចូរប្រាប់មកចុះ ទេវបុត្ត ។

ទេវបុត្តនោះមានសេចក្តីខ្មាសអៀន ព្រោះកម្មដែលខ្លួនធ្វើទុកជាកម្មតិចតួច ទើបមិនហ៊ានប្រាប់ តែកាលតាបសទាំងនោះសួរហើយរឿយៗ ក៏ពោលថា “បើដូច្នោះ សូមលោកទាំងឡាយចូរស្តាប់” ដូច្នេះ ទើបដំណាលរឿងប្រាប់ ។

បានឮមកថា ទេវរាជនោះជាមនុស្សទុគ៌តម្នាក់ ស្វែងរកការងារធ្វើ ដើម្បីចិញ្ចឹមជីវិត បានការងារធ្វើក្នុងសំណាក់អនាថបិណ្ឌិកសេដ្ឋី ក៏អាស្រ័យការងារនោះចិញ្ចឹមជីវិត ។ ខាងក្រោយមក កាលដល់ថ្ងៃឧបោសថមួយ អនាថបិណ្ឌិកសេដ្ឋីមកអំពីវិហារហើយ សួរថា "ថ្ងៃនេះ មាននរណាៗ បានប្រាប់បុរសដែលជាអ្នកធ្វើការស៊ីឈ្នួលនោះថា ថ្ងៃនេះជាថ្ងៃឧបោសថដែរឬ? មនុស្សដែលនៅក្នុងផ្ទះនោះ ឆ្លើយប្រាប់ថា "លោកម្ចាស់ មិនទាន់មាននរណាម្នាក់បានប្រាប់ទេ" អនាថបិណ្ឌិកពោលថា "បើដូច្នោះ ពួកអ្នកចូរចម្អិនអាហារល្ងាចទុកសម្រាប់គេចុះ" ។ គ្រានោះ ជនទាំងនោះក៏ដាំបាយដោយអង្ករ ១ កំប៉ុង ទុកដើម្បីបុរសនោះ ។ បុរសនោះធ្វើការងារក្នុងព្រៃរហូតអស់មួយថ្ងៃ មកផ្ទះវិញក្នុងវេលាល្ងាច កាលគេដួសបាយឲ្យ ក៏មិនទាន់បរិភោគភ្លាមទេ ដោយគិតថា "យើងជាអ្នកឃ្លានហើយ" គិតថា "ក្នុងថ្ងៃមុនៗ ភាពកោលាហលរមែងមានក្នុងផ្ទះនេះថា សូមលោកឲ្យបាយឲ្យសម្ល ឲ្យម្ហូប ក្នុងថ្ងៃនេះ មនុស្សគ្រប់គ្នាជាអ្នកមានសំឡេងស្ងប់ស្ងៀមដេកអស់ រៀបចំអាហារទុកសម្រាប់អញតែម្នាក់ឯងប៉ុណ្ណោះ តើមានហេតុអ្វីហ្ន៎ ទើបសួរថា "អ្នកទាំងឡាយបរិភោគហើយឬ" ជនទាំងនោះឆ្លើយថា

“ម្នាលអ្នកដ៏ចម្រើន ថ្ងៃនេះគេមិនបរិភោគទេ” ។

អ្នកបម្រើ. ព្រោះហេតុអ្វី ?

ជនទាំងឡាយ. ក្នុងផ្ទះនេះ គេមិនចម្អិនអាហារពេលល្ងាចក្នុងថ្ងៃឧបោសថទាំងឡាយទេ ។ ព្រោះមនុស្សគ្រប់គ្នា គេជាអ្នករក្សាឧបោសថដោយហោចទៅសូម្បីទារកដែលនៅបៅដោះជាប្រក្រតី មហាសេដ្ឋីក៏ឲ្យទារកនោះខ្ពុរមាត់ហើយ ប្រើបម្រើឲ្យដាក់វត្ថុមានរសផ្អែម ៤[១] មុខ ទៅក្នុងមាត់ធ្វើឲ្យជាអ្នករក្សាឧបោសថ កាលប្រទីបដែលបុគ្គលដុតហើយដោយប្រេងមានក្លិនក្រអូប កុមារតូចធំទាំងឡាយទៅកាន់ទីដេកហើយ រមែងស្វាធ្យាយអាការ ៣២ ប្រការ ប៉ុន្តែថា ពួកយើងមិនបានធ្វើសតិទុកដើម្បីនឹងប្រាប់ដល់អ្នកថាថ្ងៃនេះ ជាថ្ងៃឧបោសថ ព្រោះហេតុនោះ ទើបពួកយើងដាំបាយទុកដើម្បីអ្នកតែម្នាក់ឯង អ្នកចូរទទួលអាហារនោះចុះ ។

បុរសអ្នកបម្រើ. ប្រសិនបើខ្ញុំរក្សាឧបោសថក្នុងកាលឥឡូវនេះ រមែងសមគួរដែរ សូម្បីខ្ញុំក៏រក្សាឧបោសថដែរ ។

ជនទាំងឡាយ. លោកសេដ្ឋីរមែងដឹងនៅកិច្ចនេះ ។

---

១ ទឹកដោះថ្លា ទឹកដោះខាប់ ទឹកឃ្មុំ ទឹកអំពៅ ។

បុរសអ្នកបម្រើ. បើដូច្នោះ សូមពួកលោកសួរលោកសេដ្ឋីនោះឲ្យខ្ញុំផង ។

ជនទាំងនោះទៅសួរសេដ្ឋី លោកសេដ្ឋីក៏ពោលយ៉ាងនេះថា “បុរសនោះមិនបរិភោគក្នុងកាលឥឡូវនេះ ខ្ទុះមាត់ហើយ អធិដ្ឋានអង្គឧបោសថទាំងឡាយនឹងបានឧបោសថកម្មពាក់កណ្ដាល” ។ ចំណែកបុរសអ្នកបម្រើស្ដាប់ពាក្យនោះហើយ បានធ្វើហើយដោយប្រការដូច្នោះ ។ កាលគេស្រេកឃ្លានព្រោះការងាររហូតអស់វេលាមួយថ្ងៃ ខ្យល់ក៏កម្រើកឡើងក្នុងសរីរៈ គេយកខ្សែចងពោះ ចាប់ត្រង់ចុងខ្សែ បម្រះនទៀលទៅមក ។ សេដ្ឋីដឹងរឿងនោះ ក៏ឲ្យមនុស្សកាន់គប់ភ្លើងទៅ ហើយអ្នកបម្រើឲ្យយកវត្ថុមានរសផ្អែម ៤ មុខ មកកាន់សំណាក់របស់បុរសនោះ សួរថា “មានរឿងអ្វី បា!”

បុរសអ្នកបម្រើ. លោកម្ចាស់ ខ្យល់កម្រើកឡើងដល់ខ្ញុំ ។

សេដ្ឋី. បើដូច្នោះ អ្នកចូរក្រោកឡើង ផឹកនូវភេសជ្ជៈនេះចុះ ។

បុរសអ្នកបម្រើ. សួរថា លោកម្ចាស់ ជនទាំងឡាយគេទទួលទានហើយឬ ។

សេដ្ឋី. សេចក្ដីមិនសប្បាយ របស់ពួកយើងមិនមាន អ្នកចូរផឹកចុះ

បុរសនោះពោលថា “បពិត្រលោកម្ចាស់ ខ្ញុំកាលរក្សាឧបោសថ មិនបានដើម្បីនឹងរក្សាឧបោសថកម្មទាំងអស់ សូម្បីឧបោសថកម្មពាក់កណ្ដាលរបស់ខ្ញុំ កុំបានជារបស់ខូះខាតឡើយ” ដូច្នេះហើយ ក៏មិនព្រមផឹកនូវភេសជ្ជៈនោះ ។ បុរសនោះ សូម្បីសេដ្ឋីពោលថា “ម្នាលអ្នកដ៏ចម្រើន អ្នកកុំធ្វើយ៉ាងនេះឡើយ” ក៏នៅតែមិនព្រមផឹក កាលអរុណរះឡើងក៏ធ្វើកាលកិរិយាទៅ ដូចផ្កាឈើដែលស្វិតដូច្នោះ កើតជាទេវតានៅនាដើមជ្រៃនេះឯង ។ ព្រោះហេតុនោះ ទេវតានោះ លុះពោលសេចក្ដីនេះហើយ ក៏ពោលដូច្នេះថា “សេដ្ឋីនោះជាអ្នករាប់អានព្រះពុទ្ធថាជារបស់យើង រាប់អានព្រះធម៌ថាជារបស់យើង រាប់អានព្រះសង្ឃថាជារបស់យើង សម្បត្តិនោះខ្ញុំ បានហើយដោយផល ដែលហូរចេញអំពីឧបោសថកម្មពាក់កណ្ដាល ដែលខ្ញុំអាស្រ័យសេដ្ឋីនោះធ្វើហើយ ។

តាបស ៥០០ នោះ គ្រាន់តែឮពាក្យថា “ព្រះពុទ្ធ” ក៏ក្រោកឡើងផ្គងអញ្ជលីចំពោះទេវតា ពោលថា “លោកនិយាយថា ព្រះពុទ្ធឬ” ដូច្នេះហើយ ក៏ញ៉ាំងទេវតានោះឲ្យប្ដេជ្ញា ៣ ដងថា “ខ្ញុំនិយាយថា ព្រះពុទ្ធមែន” ហើយបន្លឺឡើងនូវឧទានថា “សូម្បីសំឡេងគឹកកងនេះឯង ក៏រកបានលំបាក

ក្នុងលោក" ហើយពោលថា "បពិត្រទេវតា ពួកយើងជាអ្នកដែលលោកបាន ឲ្យស្តាប់សំឡេង ដែលមិនធ្លាប់បានឮមកហើយក្នុងសែនកប្បជាអនេក" ។ គ្រានោះ ពួកតាបសដែលជាអន្តេវាសិកបានពោលពាក្យនេះនឹងអាចារ្យថា "បើដូច្នោះ ពួកយើងចូរនាំគ្នាទៅកាន់សំណាក់របស់ព្រះសាស្តាចុះ" អាចារ្យ ពោលថា "ម្នាលអ្នកទាំងឡាយ សេដ្ឋី ៣ រូប ជាអ្នកមានឧបការៈច្រើនដល់ យើង ថ្ងៃស្អែកនេះ ពួកយើងទទួលភិក្ខាក្នុងលំនៅរបស់សេដ្ឋីទាំងនោះ ប្រាប់ សេដ្ឋីទាំងនោះហើយ សឹមទៅ ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយសូម បង្អង់សិនចុះ" តាបសទាំងនោះក៏បង្អង់ចាំតាមពាក្យរបស់អាចារ្យ ។ ថ្ងៃ ស្អែកឡើង សេដ្ឋីទាំង ៣ រូបនោះ ត្រៀមយាគូ និងភត្ត ហើយក្រាល អាសនៈទុក ដឹងថា "ថ្ងៃនេះ លោកម្ចាស់ដ៏ចម្រើនទាំងឡាយរបស់យើង មក" ធ្វើការក្រោកទទួលតាបសទាំងនោះ នាំទៅកាន់លំនៅ និមន្តឲ្យគង់ បានប្រគេនភិក្ខា ។ តាបសទាំងនោះធ្វើភត្តកិច្ចរួចស្រេចហើយ ពោលថា "បពិត្រមហាសេដ្ឋីទាំងឡាយ ពួកយើងនឹងទៅ" ។

សេដ្ឋី. លោកម្ចាស់ដ៏ចម្រើនទាំងឡាយ លោកម្ចាស់ទាំងឡាយបាន បដិញ្ញានឹងខ្ញុំម្ចាស់ទាំងឡាយថា នឹងនៅទីនេះរហូត ៤ ខែ ក្នុងរដូវភ្លៀងនេះ

មិនមែនឬ? ឥឡូវនេះ លោកម្ចាស់ទាំងឡាយនឹងទៅទីណា?

តាបស. ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ ព្រោះហេតុនោះ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះសាស្តា ។

សេដ្ឋី. ក៏ការទៅសំណាក់ព្រះសាស្តាអង្គនោះ គួរចំពោះតែលោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ ?

តាបស. ម្នាលអ្នកមានអាយុ សូម្បីជនពួកដទៃក៏គួរ មិនហាមឃាត់ទេ ។

សេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយរង់ចាំសិន ពួកខ្ញុំម្ចាស់រៀបចំហើយ នឹងទៅដែរ ។

តាបសទាំងនោះពោលថា "កាលអ្នកទាំងឡាយធ្វើការត្រៀមរៀបចំដំណើរយឺតយូរមែងមានដល់ពួកយើង ពួកយើងនឹងទៅមុន អ្នកទាំងឡាយគប្បីទៅតាមក្រោយចុះ" ដូច្នេះ ហើយក៏ទៅមុនចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ។

គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់តាបស

ទាំងនោះ ។ ក្នុងទីបំផុតនៃទេសនា តាបសទាំង ៥០០ នោះបានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ហើយទូលសូមបព្វជ្ជា បានជាអ្នកទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ហាក់ដូចជាព្រះថេរៈមានវស្សា ១០០ ក្នុងលំដាប់នៃព្រះតម្រាស់ដែលព្រះអង្គត្រាស់ថា "អ្នកទាំងឡាយចូរជាភិក្ខុចុះ" ។

សេដ្ឋីទាំង ៣ រូបនោះ ចាត់ចែងរទេះម្នាក់ៗ ៥០០ ផ្ទុកដោយគ្រឿងឧបករណ៍ដល់ទាន មានសំពត់ គ្រឿងស្លៀកដណ្តប់ ទឹកដោះថ្លា ទឹកឃ្មុំ និងទឹកអំពៅជាដើម ទៅដល់ក្រុងសាវត្ថីហើយ ចូលទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា ស្តាប់នូវធម្មកថា ក្នុងទីបំផុតនៃធម្មកថា ក៏បានតាំងនៅក្នុងសោតាបត្តិផល ថ្វាយទានក្នុងសំណាក់ព្រះសាស្តាអស់កន្លះខែហើយ ទូលអារាធនាព្រះសាស្តា ដើម្បីប្រយោជន៍ដល់កិរិយាស្តេចយាងទៅកាន់ក្រុងកោសម្ពី ព្រះសម្មាសម្ពុទ្ធកាលនឹងទ្រង់ប្រទាននូវការប្តេជ្ញា ក៏បានត្រាស់ថា "ម្នាលគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរតែក្នុងផ្ទះស្ងាត់" ទើបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនុ៎ះ ពួកខ្ញុំព្រះអង្គជ្រាបហើយ សូមព្រះមានព្រះភាគស្តេចយាងទៅតាមដំណឹង ដែលពួកខ្ញុំព្រះអង្គ

បញ្ជូនមកចុះ” ដូច្នេះ ហើយទៅកាន់ក្រុងកោសម្ពី បង្គាប់ឲ្យជាងសាងមហាវិហារ ៣ គឺ ឃោសកសេដ្ឋីឲ្យសាង ឃោសិតារាម កុក្កុដសេដ្ឋីឲ្យសាងកុក្កុដារាម បាវារិកសេដ្ឋីឲ្យសាង បាវារិការាម ហើយបញ្ជូនទៅដើម្បីការស្តេចយាងមកនៃព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវដំណឹងរបស់សេដ្ឋីទាំងនោះ ក៏បានយាងទៅកាន់ទីនោះ ។ សេដ្ឋីទាំងនោះក្រោកទទួលព្រមទាំងអាគន្តនាទិមន្តព្រះសាស្តាឲ្យស្តេចចូលទៅខាងក្នុងវិហារ ហើយថ្វាយ ៣ ដងថា “ខ្ញុំព្រះអង្គសូមថ្វាយវិហារនេះចំពោះភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ដែលមានព្រះពុទ្ធជាប្រធាន” ដូច្នេះ ហើយក៏ប្រតិបត្តិតាមវេនរៀងៗ ខ្លួន ។ ព្រះសាស្តារមែងគង់នៅក្នុងវិហារមួយៗ មួយថ្ងៃ ទ្រង់គង់នៅក្នុងវិហាររបស់សេដ្ឋីណា ក៏ទ្រង់យាងទៅដើម្បីបិណ្ឌបាតត្រង់ទ្វារផ្ទះសេដ្ឋីនោះឯង ។

ក៏សេដ្ឋីទាំង ៣ នាក់នោះ មាននាយមាលាការឈ្មោះសុមនៈ ជាអ្នកឧបដ្ឋាក ។ នាយសុមនមាលាការនោះ ពោលនឹងសេដ្ឋីទាំងនោះយ៉ាងនេះថា “ខ្ញុំជាអ្នកធ្វើការបម្រើលោកទាំងឡាយរហូតអស់កាលយូរ ជាអ្នកប្រាថ្នានឹងញុំាងព្រះសាស្តាយាងសោយ សូមលោកទាំងឡាយ ចូរយាងព្រះ

សាស្តាដល់ខ្ញុំមួយថ្ងៃ" ។

សេដ្ឋីទាំង ៣ នាក់នោះពោលថា "ម្នាលនាយ បើដូច្នោះ អ្នកចូរនិមន្តព្រះសាស្តាយាងសោយក្នុងថ្ងៃស្អែកនេះចុះ" ។ នាយសុមនមាលាការនោះទទួលពាក្យថា "ល្អហើយ នាយ" ដូច្នេះ ទើបនិមន្តព្រះសាស្តា ត្រៀមគ្រឿងសក្ការៈ ។ ក្នុងសម័យនោះ ព្រះរាជាព្រះរាជទាន ៨ កហាបណៈឲ្យជាតម្លៃផ្កាដល់នាងសាមាវតីរាល់ៗ ថ្ងៃ ។ ទាសីរបស់នាងសាមាវតីនោះឈ្មោះនាងខុជ្ជុត្តរា ទៅកាន់សម្នាក់សុមនមាលាការ ទទួលយកផ្កាទាំងឡាយជានិច្ច ។ ក្រោយមក ក្នុងថ្ងៃមួយ នាយមាលាការពោលនឹងនាងខុជ្ជុត្តរាដែលជាអ្នកមកក្នុងថ្ងៃនោះថា "ម្នាលនាងខុជ្ជុត្តរា ខ្ញុំនិមន្តព្រះសាស្តាទុកហើយ ថ្ងៃនេះខ្ញុំនឹងបូជាព្រះសាស្តាដោយផ្កាដ៏ប្រសើរ នាងចូរផងចាំស្តាប់ព្រះធម៌សិនហើយ សឹមទទួលយកផ្កាទៅចុះ" ។ នាងខុជ្ជុត្តរាទទួលថា "បាន" ។ នាយសុមនៈ អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន បានទទួលបាត្រដើម្បីប្រយោជន៍ដល់ការធ្វើអនុមោទនា ។ ព្រះអង្គទ្រង់ប្រារព្ធធម្មទេសនា ដើម្បីជាការអនុមោទនា ។ ចំណែកនាងខុជ្ជុត្តរា ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃមុនៗ នាងទិញផ្កាតែ ៤

កហាបណៈ ឯ ៤ កហាបណៈទុកសម្រាប់ខ្លួន ។ ក្នុងថ្ងៃនោះ នាងទិញផ្កាទាំង ៨ កហាបណៈ ។

គ្រានោះ នាងសាមាវតីពោលនឹងនាងខុជ្ជុត្តរានោះថា "ម្នាលនាងដ៏ចម្រើន ព្រះរាជាព្រះរាជទានតម្លៃផ្កាដល់យើងជាទ្វេគុណឬ ?"

នាងខុជ្ជុត្តរា. បពិត្រព្រះនាងម្ចាស់ មិនមែនទេ ។

សាមាវតី. បើដូច្នេះ ព្រោះហេតុអ្វី បានជាផ្កាច្រើនម្ល៉េះ

ខុជ្ជុត្តរា. ក្នុងថ្ងៃមុនៗ ខ្ញុំកាន់យក ៤ កហាបណៈទុកសំរាប់ខ្លួន ទិញផ្កាតែ ៤ កហាបណៈប៉ុណ្ណោះ ។

សាមាវតី. ះហេតុអ្វី ក្នុងថ្ងៃនេះទើបនាងមិនកាន់យក ?

ខុជ្ជុត្តរា. ព្រោះខ្ញុំស្តាប់ធម្មកថារបស់ព្រះសម្មាសម្ពុទ្ធហើយ សម្រេចធម៌ ។

គ្រានោះ នាងសាមាវតីមិនបានគម្រាមនាងខុជ្ជុត្តរានោះថា "នែ៎នាងទាសីកំហូច នាងចូរឲ្យកហាបណៈដែលនាងកាន់យកហើយអស់កាលមានប្រមាណប៉ុណ្ណោះដល់អញវិញ" ត្រឡប់ជាពោលថា "ម្នាលនាងដ៏ចម្រើន នាងចូរញ៉ាំងយើងទាំងឡាយឲ្យផឹកនូវទឹកអម្រឹត ដែលនាងបានផឹកហើយ

ផង” កាលនាងខុជ្ជុត្តរាពោលថា “បើដូច្នោះ សូមព្រះនាងម្ចាស់ញ៉ាំងនាងខ្ញុំឲ្យងូតទឹក” ក៏ឲ្យនាងងូតទឹក ដោយទឹកក្រអូប ១៦ ក្អម ហើយត្រាស់បង្គាប់ឲ្យប្រទានសំពត់សាដកសាច់មដ្ឋពីរផ្ទាំង ។ នាងខុជ្ជុត្តរានោះ ស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ប្រើគេឲ្យក្រាលអាសនៈ ឲ្យនាំផ្ចិតមួយមក អង្គុយលើអាសនៈចាប់ផ្ចិតដ៏វិចិត្រ ហៅមាតុគ្រាម ៥០០ នាក់មក ហើយបានសម្តែងធម៌ដល់ស្ត្រីទាំងនោះ ដូចដែលព្រះសាស្តាទ្រង់សម្តែងហើយនោះឯង ៗ ស្ត្រីទាំងអស់នោះ ស្តាប់ធម្មកថារបស់នាងខុជ្ជុត្តរាហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ៗ ស្ត្រីទាំងនោះថ្វាយបង្គំនាងខុជ្ជុត្តរា ហើយពោលថា “ម្នាលនាងដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះទៅ នាងកុំធ្វើការងារដ៏សៅហ្មងឡើយ នាងចូរតាំងនៅក្នុងឋានៈជាមាតា និងជាអាចារ្យរបស់ពួកយើងទាំងឡាយ ហើយទៅកាន់សំណាក់ព្រះសាស្តា ស្តាប់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ មកសម្តែងប្រាប់ពួកយើងទាំងឡាយ” ។ នាងខុជ្ជុត្តរាក៏ធ្វើតាមពាក្យនោះ ក្រោយមក នាងក៏បានជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ៗ តមកព្រះសាស្តាទ្រង់តាំងនាងខុជ្ជុត្តរាទុកក្នុងឯតទគ្គៈថា “ម្នាលភិក្ខុទាំងឡាយនាងខុជ្ជុត្តរានេះ ជាបុគ្គលប្រសើរលើសឧបាសិកាក្នុងសាសនាតថាគតដែល

ជាធម្មកថិក (ពហុស្សុត) ។ ស្ត្រីទាំង ៥០០ នាក់នោះ ពោលទៅកាន់នាង ខុជ្ជុត្តរានោះ យ៉ាងនេះថា "ម្នាលនាងដ៏ចម្រើន ពួកយើងទាំងឡាយប្រាថ្នា នឹងគាល់ព្រះសាស្តា សូមនាងចូរសម្តែងព្រះសាស្តាដល់យើងទាំងឡាយ ពួក យើងនឹងបូជាព្រះសាស្តាដោយសក្ការៈទាំងឡាយ មានគ្រឿងក្រអូប និងផ្កា កម្រងជាដើម" ។

នាងខុជ្ជុត្តរា. បពិត្រព្រះនាងម្ចាស់ដ៏ចម្រើនទាំងឡាយ ដែលឈ្មោះ ថា រាជត្រកូលជារបស់ធ្ងន់ នាងខ្ញុំមិនអាចដើម្បីនឹងនាំព្រះនាងទាំងឡាយ ទៅខាងក្រៅបានទេ ។

ស្ត្រីទាំងឡាយ. ម្នាលនាងដ៏ចម្រើន នាងកុំញុំាងយើងទាំងឡាយ ឲ្យវិនាសឡើយ ។ សូមនាងចូរសម្តែងព្រះសាស្តាដល់យើងទាំងឡាយចុះ ។

នាងខុជ្ជុត្តរា. បើដូច្នោះ ការមើលជាការដែលព្រះនាងអាចមើលបាន តាមប្រហោង មានប្រមាណប៉ុណ្ណា ចូរចោះប្រហោងមានប្រមាណប៉ុណ្ណោះ ត្រង់ជញ្ជាំងបន្ទប់ ដែលជាលំនៅរបស់ពួកព្រះនាងទាំងឡាយ ចូរឲ្យគេនាំ គ្រឿងក្រអូប និងកម្រងផ្កាជាដើមមក ហើយឈរនៅក្នុងទីនោះៗ ចូរក្រឡេក មើល ចូរញុំាងព្រះហស្តទាំងពីរថ្វាយបង្គំ និងចូរបូជាព្រះសាស្តាដែលស្តេច

យាងទៅកាន់ផ្ទះសេដ្ឋីទាំង ៣ នាក់នោះចុះ ។

ស្ត្រីទាំងនោះបានធ្វើយ៉ាងនោះ ក្រឡេកមើលព្រះសាស្តា ដែលយាងទៅ និងយាងមក ថ្វាយបង្គំ និងបូជាហើយ ។

តមកថ្ងៃមួយ ព្រះនាងមាគន្ទិយា ចេញអំពីប្រាសាទរបស់ខ្លួនធ្វើដំណើរទៅកាន់លំនៅរបស់ស្ត្រីទាំងនោះ ឃើញប្រហោងជញ្ជាំងបន្ទប់ទាំងឡាយ ក៏សួរថា "ប្រហោងអ្វីនេះ" កាលស្ត្រីទាំងនោះមិនដឹងថា នាងមាគន្ទិយានេះចងគំនុំនឹងព្រះសាស្តា ក៏ឆ្លើយប្រាប់ថា "ព្រះសាស្តាយាងមកកាន់នគរនេះ ពួកយើងទាំងឡាយឈរនៅក្បែរប្រហោងនេះ ហើយថ្វាយបង្គំ និងបូជាព្រះសាស្តា" លុះបានស្តាប់ដូច្នេះហើយ ក៏គិតថា "ព្រះសមណគោតមមកកាន់នគរនេះហើយ ឥឡូវនេះ យើងនឹងដឹងនូវអំពើដែលគួរធ្វើចំពោះសមណគោតមនេះ ចំណែកស្ត្រីទាំងនេះ ក៏ជាឧបដ្ឋាយិការបស់ព្រះសមណគោតមនោះ យើងនឹងដឹងនូវអំពើដែល គប្បីធ្វើសូម្បីដល់ស្ត្រីទាំងនេះ" ទើបទៅក្រាបទូលព្រះរាជាថា "បពិត្រមហារាជ ស្ត្រីទាំង ៥០០ នាក់ រួមទាំងនាងសាមាវតីផង មានសេចក្តីប្រាថ្នាខាងក្រៅ ស្ត្រីទាំងនោះនឹងប្រហារព្រះជន្មរបស់ព្រះអង្គ ក្នុងពីរបីថ្ងៃទៀតជាពិតប្រាកដ" ព្រះរាជាមិនទ្រង់ជឿ

ទ្រង់មានព្រះតម្រាស់ថា "ស្ត្រីទាំងនោះមិនធ្វើនូវអំពើបែបនេះទេ" ។ សូម្បីនាងមាគន្ទិយាក្រាបទូលទៀត ក៏នៅតែមិនព្រមជឿ ។ លំដាប់នោះ នាងមាគន្ទិយា ក្រាបទូលព្រះរាជាអង្គនោះ ដោយពាក្យដែលខ្លួនធ្លាប់ក្រាបទូលអស់វារៈ ៣ ដង ព្រះរាជាមិនទ្រង់ជឿ ក៏ក្រាបទូលថា "ប្រសិនបើព្រះអង្គទ្រង់មិនជឿ (ពាក្យ) ខ្ញុំម្ចាស់សោត សូមព្រះអង្គស្តេចយាងទៅកាន់លំនៅរបស់ស្ត្រីទាំងនោះ ហើយទ្រង់ពិនិត្យមើលចុះ" ។ ព្រះរាជាស្តេចយាងទៅទតឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ក៏ត្រាស់សួរថា "ប្រហោងអ្វីនេះ" កាលស្ត្រីទាំងនោះក្រាបទូលសេចក្តីនោះហើយ ទ្រង់មិនបានពិរោធនឹងស្ត្រីទាំងនោះ ទាំងមិនបានត្រាស់នូវអ្វីៗ ឡើយ តែទ្រង់ត្រាស់បង្គាប់ឲ្យបិទវន្ធទាំងឡាយ ហើយឲ្យធ្វើបង្អួចមានប្រហោងតូចៗ ក្នុងបន្ទប់ទាំងពួង ។ បានឮថា បង្អួចមានប្រហោងតូចៗ ទាំងឡាយ កើតមានហើយក្នុងកាលនោះ ។

ព្រះនាងមាគន្ទិយា មិនអាចនឹងធ្វើអ្វីៗ ស្ត្រីទាំងនោះបាន ក៏គិតថា "យើងនឹងធ្វើនូវអំពើដែលគប្បីធ្វើចំពោះសមណៈឲ្យខានតែបាន" ទើបឲ្យកហាបណៈដល់អ្នកនគរ ហើយពោលថា "ពួកអ្នកព្រមទាំងពួកបុរសដែលជាខ្ញុំប្រុស និងកម្មករទាំងឡាយចូរជេរផ្តាសាព្រះសមណគោតម ដែលជា

អ្នកចូលទៅកាន់ព្រះនគរ ឲ្យចៀសចេញទៅ” ពួកមិច្ឆាទិដ្ឋិដែលជាអ្នកមិនជ្រះថ្លាក្នុងរតនត្រ័យ ក៏ជាប់តាមព្រះសាស្តាដែលយាងចូលទៅកាន់ព្រះនគរជេរផ្តាសាដោយអក្កោសវត្ថុ ១០ យ៉ាងថា លោកជាចោរ លោកជាបុគ្គលពាល លោកជាមនុស្សឆ្កួត លោកជាអូដ្ឋ លោកជាគោ លោកជាលា លោកជាសត្វនរក លោកជាសត្វតិរច្ឆាន សុគតិរបស់លោកមិនមានទេ លោកសង្ឃឹមបានតែទុគ្គតិតែម្យ៉ាងប៉ុណ្ណោះ ។ ព្រះអានន្ទបានឮពាក្យនោះហើយបានក្រាបទូលពាក្យនេះ ចំពោះព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន អ្នកនគរទាំងនេះរមែងជេរ រមែងផ្តាសាពួកយើងទាំងឡាយ ពួកយើងនឹងទៅកាន់ទីដទៃអំពីទីនេះ” ។

ព្រះសាស្តាត្រាស់សួរថា “ម្នាលអានន្ទ យើងនឹង ទៅកាន់ទីណា” ។

ព្រះអានន្ទក្រាបទូលថា “ទៅក្រុងដទៃ ព្រះអង្គ” ។

ព្រះសាស្តា. ម្នាលអានន្ទ កាលពួកមនុស្សក្នុងក្រុងនោះជេរទៀត យើងនឹងទៅទីណាទៀត អានន្ទ ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់ក្រុងដទៃទៀត ។

ព្រះសាស្តា. កាលពួកមនុស្សក្នុងក្រុងនោះជេរ យើងនឹងទៅកាន់ទី

ណាទៀតទៅ ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់ក្រុងដទៃអំពីក្រុងនោះទៀត ។

ព្រះសាស្តា. ម្នាលអានន្ទ ធ្វើដូច្នេះមិនសមគួរឡើយ អធិករណ៍កើតឡើងក្នុងទីណា កាលអធិករណ៍នោះស្ងប់រម្ងាប់ហើយក្នុងទីនោះ ទើបគួរទៅទីដទៃ ម្នាលអានន្ទ ក៏ពួកមនុស្សទាំងនោះ ពួកណាទៅតែងជេរ ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងអស់នោះ មានពួកទាសៈនិងកម្មករ រមែងជេរ ។

ព្រះសាស្តាត្រាស់ថា "ម្នាលអានន្ទ តថាគតដូចជាដំរីចូលកាន់សង្គ្រាម ក៏ការអត់ទ្រាំចំពោះកូនសរដែលមកអំពីទិសទាំង ៤ រមែងជាភារៈរបស់ដំរីដែលចូលកាន់សង្គ្រាម យ៉ាងណាមិញ ដែលឈ្មោះថា ការអត់ទ្រាំចំពោះពាក្យដែលបុគ្គលទ្រុស្តសីលជាច្រើនពោលហើយ ក៏ជាភារៈរបស់តថាគតដូច្នោះដែរ" ដូច្នេះ កាលទ្រង់ប្រារព្ធចំពោះព្រះអង្គ ទើបសម្តែងនូវគាថា ៣ គាថានេះ ក្នុងនាគវគ្គថា ៖

តថាគតអត់ទ្រាំក្នុងពាក្យនិន្ទា ដូចដំរីអត់ទ្រាំចំពោះកូនសរ

ដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះជនដ៏ច្រើន

ជាអ្នកទ្រុស្តសីល រាជបុរសទាំងឡាយ តែងនាំវាហនៈដែល

ទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាស្តេចរមែងឡើងកាន់

វាហនៈដែលទូន្មានហើយ ក្នុងពួកមនុស្សទាំងឡាយ បុគ្គល

ណាអត់ទ្រាំក្នុងពាក្យនិន្ទាបាន បុគ្គលនោះឈ្មោះថា ជាអ្នក

មានខ្លួនទូន្មានហើយ ជាបុគ្គលប្រសើរបំផុត ពួកសេះអស្ស-

តរដែលហ្វឹកហាត់ហើយ ជាសត្វដ៏ប្រសើរ សេះអាជានេយ្យ

សេះសិន្ធពដែលហ្វឹកហាត់ ជាសត្វដ៏ប្រសើរ ស្តេចដំរីមាន

ជាតិកុញ្ជរដែលហ្វឹកហាត់ហើយ ក៏ជាសត្វដ៏ប្រសើរ (តែ)

បុគ្គលដែលមានខ្លួនទូន្មានហើយ ប្រសើរជាងសត្វទាំងអស់

នោះ ។

ធម្មកថាបានជាប្រយោជន៍ដល់មហាជនអ្នកដល់ព្រមហើយ ។ ព្រះសាស្តាលុះទ្រង់សម្តែងធម្មកថាយ៉ាងនេះហើយ ទ្រង់ត្រាស់ថា "ម្នាលអានន្ទ អ្នកកុំគិតឡើយ ពួកជនទាំងនោះនឹងជេរបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៨ នឹងស្ងប់ហើយ ព្រោះថា អធិករណ៍ដែលកើតឡើងចំពោះព្រះពុទ្ធ

ទាំងឡាយ មិនហួសពី ៧ ថ្ងៃទេ" ។

ព្រះនាងមាគន្ទិយា ជួលមនុស្សឲ្យជេរព្រះសាស្តាហើយ (ប៉ុន្តែ) មិនអាចធ្វើឲ្យព្រះសាស្តាយាងចេញបាន ទើបគិតថា "យើងនឹងធ្វើដូចម្តេចហ្ន៎" ដូច្នេះ ហើយគិតថា "ស្ត្រីទាំងនោះ ជាឧបដ្ឋាយិកាបស់ព្រះសមណគោតមនោះ យើងនឹងធ្វើសេចក្តីវិនាសឲ្យដល់ស្ត្រីទាំងនោះ" ថ្ងៃមួយកាលធ្វើការបម្រើព្រះរាជាក្នុងទីជាទីសោយទឹកចណ្ឌ ក៏បញ្ជូនដំណឹងទៅឪពុកមាថា ខ្ញុំត្រូវការមាន់ទាំងឡាយ សូមលោកមាចូរនាំយកមាន់ងាប់ ៨ មាន់រស់ ៨ មក ។ លុះមកដល់ហើយ ចូរឈរនៅក្នុងទីបំផុតនៃជណ្តើរ ប្រាប់ដំណឹងដែលខ្លួនមក សូម្បីកាលត្រាស់បង្គាប់ថា "ចូរមកចុះ" ក៏កុំចូលទៅចូរប្រគល់មាន់រស់ ៨ ក្បាលទៅមុន បញ្ជូនមាន់ងាប់ ទៅជាខាងក្រោយ" ហើយបានប្រទានសំណូកឲ្យអ្នកបម្រើនោះ ដោយបង្គាប់ថា "ឯងគប្បីធ្វើតាមពាក្យរបស់យើង" ។ នាយមាគន្ទិយៈមកហើយ ឲ្យថ្វាយដំណឹងដល់ព្រះរាជាឲ្យទ្រង់ជ្រាប កាលព្រះរាជាត្រាស់ថា "ចូរចូលមក" ក៏ពោលថា "ខ្ញុំនឹងមិនចូលទៅកាន់ទីដែលជាទីសោយទឹកចណ្ឌរបស់ព្រះរាជាទេ" ចំណែកព្រះនាងមាគន្ទិយាបញ្ជូនបម្រើទៅដោយពាក្យថា "ម្នាលបា អ្នកចូរទៅកាន់

សម្លាក់ឪពុកមារបស់យើង” ។ បម្រើនោះទៅហើយ នាំយកមាន់រស់ ៨ ក្បាលដែលនាយចុងភៅមាគន្ទិយៈនោះឲ្យ ហើយមកក្រាបទូលថា “បពិត្រព្រះសម្មតិទេព បុរោហិតបញ្ជូនបណ្ណាការមកហើយ” ។ ព្រះរាជាត្រាស់ថា “ប្រពៃហើយ សម្ភកកូរកើតឡើងដល់ពួកយើងហើយ នរណាហ្ន៎ គប្បីចម្អិន” ព្រះនាងមាគន្ទិយាក្រាបទូលថា “បពិត្រមហារាជ ស្ត្រី ៥០០ នាក់ មានព្រះនាងសាមាវតីជាប្រធាន ជាអ្នកមិនមានការងារធ្វើ សូមព្រះអង្គបញ្ជូនទៅឲ្យស្ត្រីទាំងនោះចុះ ស្ត្រីទាំងនោះចម្អិនហើយនឹងនាំមក (ថ្វាយ)” ។ ព្រះរាជាទ្រង់បញ្ជូនទៅ ដោយព្រះតម្រាស់ថា “ឯងចូរទៅ ឲ្យ (មាន់) ដល់ស្ត្រីទាំងនោះ ចូរកុំប្រគល់ឲ្យអ្នកដទៃ ចូរសម្លាប់ហើយចំអិនដោយខ្លួនឯង” ។ រាជអាមាត្យទទួលព្រះរាជតម្រាស់ថា “ករុណា ព្រះអង្គ” ហើយទៅប្រាប់យ៉ាងនោះ ត្រូវស្ត្រីទាំងនោះប្រកែកថា “ពួកខ្ញុំមិនធ្វើបាណាតិបាតទេ” ទើបមកក្រាបទូលសេចក្តីនោះដល់ព្រះរាជា ។ ព្រះនាងមាគន្ទិយា ក្រាបទូលថា “បពិត្រមហារាជ ព្រះអង្គឃើញទេ? ឥឡូវនេះព្រះអង្គនឹងទ្រង់ជ្រាបការធ្វើឬមិនធ្វើបាណាតិបាតនៃស្ត្រីទាំងនោះ សូមព្រះអង្គត្រាស់បង្គាប់ថា ពួកនាងចូរចម្អិន ហើយនាំទៅថ្វាយដល់ព្រះសមណគោតម ដូច្នេះចុះ ព្រះអង្គ” ។

ព្រះរាជាត្រាស់យ៉ាងនោះ ហើយបញ្ជូនទៅ ។ អាមាត្យក្រៅពីនោះ កាន់មាន់ដែលនៅរស់នោះធ្វើហាក់ដូចជាដើរទៅ ទៅហើយបានឲ្យមាន់ទាំងនោះដល់បុរោហិត ទទួលយកមាន់ងាប់ទៅកាន់សំណាក់ស្ត្រីទាំងនោះ ពោលថា "ព្រះរាជបញ្ជា ឲ្យពួកនាងឲ្យចម្អិនមាន់ទាំងនេះ ហើយបញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា" ។ ស្ត្រីទាំងនោះពោលទទួលថា "នាំមកចុះ នាយ ឈ្មោះថាការចម្អិនមាន់ងាប់នេះ ជាកិច្ចរបស់ពួកយើង" ដូច្នេះហើយ ក៏ទទួលទុក ។ អាមាត្យនោះមកកាន់សំណាក់របស់ព្រះរាជា ដែលទ្រង់ត្រាស់សួរថា "ម្នាលបា ដូចម្តេចដែរ" ក៏ក្រាបទូលថា កាលខ្ញុំព្រះអង្គគ្រាន់តែពោលថា "ពួកនាងចូរចម្អិន រួចហើយបញ្ជូនទៅថ្វាយព្រះសមណគោតមប៉ុណ្ណោះ ស្ត្រីទាំងនោះក៏ប្រញាប់ប្រញាល់មក ទទួលយកទៅ" ។ ព្រះនាងមាគន្ទិយាក្រាបទូលថា "បពិត្រមហារាជ សូមព្រះអង្គចូរទតមើលចុះ ស្ត្រីទាំងនោះមិនធ្វើឲ្យបុគ្គលដូចជាព្រះអង្គទេ កាលខ្ញុំព្រះអង្គទូលថា "ស្ត្រីទាំងនោះមានសេចក្តីប្រាថ្នាខាងក្រៅ" ព្រះអង្គមិនទ្រង់ជឿ" ។ ព្រះរាជាសូម្បីទ្រង់ព្រះសណ្តាប់នូវពាក្យនោះ ក៏ទ្រង់ខំអត់សង្កត់ចិត្តនៅស្ងៀមដូចដើម ។ ព្រះនាងមាគន្ទិយាគិតថា "យើងនឹងធ្វើយ៉ាងណាហ្ន៎" ។

ក៏ក្នុងកាលនោះ ព្រះរាជាទ្រង់តែងតែស្នាក់នៅក្នុងប្រាសាទរបស់ព្រះអគ្គមហេសីទាំង ៣ នោះ គឺ ប្រាសាទរបស់ព្រះនាងសាមាវតី ប្រាសាទរបស់ព្រះនាងវាសុលទត្តា និងប្រាសាទរបស់ព្រះនាងមាគន្ទិយា អស់ ៧ ថ្ងៃ ក្នុងប្រាសាទនីមួយៗ ។ គ្រានោះ នាងមាគន្ទិយាដឹងថា "ថ្ងៃស្អែកនេះព្រះរាជានឹងស្ដេចយាងទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី" ក៏បញ្ជូនដំណឹងទៅប្រាប់ឱពុកមាថា "សូមពុកជ្រាប ខ្ញុំត្រូវការពស់មួយក្បាល សូមពុកចូរដកចង្កូមពស់នោះ ហើយបញ្ជូនមក" នាយចូឡមាគន្ទិយៈធ្វើយ៉ាងនោះ ហើយបញ្ជូនទៅ ។ ព្រះរាជាទ្រង់កាន់យកពិណហត្ថិកន្ត គឺ ពិណសម្រាប់ញ៉ាំងដំរីឲ្យត្រេកអរ ស្ដេចទៅកាន់ទីដែលស្ដេចពេញព្រះទ័យ ។ ពិណនោះមានប្រហោងមួយ ។ ព្រះនាងមាគន្ទិយា ញ៉ាំងពស់ឲ្យចូលទៅក្នុងប្រហោងនោះ ហើយបិទប្រហោងដោយដុំនៃកម្រងផ្កា ពស់បាននៅខាងក្នុងពិណនោះឯងអស់ពីរបីថ្ងៃ ក្នុងថ្ងៃដែលព្រះរាជាស្ដេចយាងទៅ ព្រះនាងមាគន្ទិយាទូលសួរថា "បពិត្រព្រះសម្មតិទេព ថ្ងៃនេះ ព្រះអង្គស្ដេចនឹងទៅកាន់ប្រាសាទនៃអគ្គមហេសីអង្គណា" កាលព្រះរាជាត្រាស់ប្រាប់ថា "របស់នាងសាមាវតី" ក៏ក្រាបទូលថា "បពិត្រមហារាជ ថ្ងៃនេះ ខ្ញុំព្រះអង្គយល់

សុបិនមិនល្អ បពិត្រព្រះសម្មតិទេព ព្រះអង្គមិនគួរស្តេចទៅកាន់ទីនោះទេ” ព្រះរាជាត្រាស់ថា “យើងនឹងទៅឲ្យខានតែបាន” ព្រះនាងមាគន្ទិយាហាមអស់វារៈ ៣ ដង ហើយទូលថា “បើដូច្នោះ សូម្បីខ្ញុំព្រះអង្គក៏នឹងទៅជាមួយព្រះអង្គដែរ” សូម្បីព្រះរាជាឲ្យត្រឡប់ទៅវិញ ក៏មិនត្រឡប់ ក្រាបទូលថា “បពិត្រមហារាជ ខ្ញុំព្រះអង្គមិនជ្រាបថា នឹងមានហេតុអ្វីកើតឡើងដល់ព្រះអង្គទេ” ដូច្នេះ ហើយក៏បានទៅជាមួយ ។ ព្រះរាជាទ្រទ្រង់សំពត់ ប្រដាប់ផ្កាឈើ គ្រឿងប្រអូប និងអាភរណៈទាំងឡាយ ដែលពួកស្ត្រីរួមជាមួយនឹងព្រះនាងសាមាវតីថ្វាយ សោយភោជនដ៏ប្រណិត ដាក់ពិណទុកលើក្បាលដំណេក ហើយផ្ទុំលើទីបន្ទំ ។ នាងមាគន្ទិយាធ្វើហាក់ដូចជាដើរទៅ ដើរមក បាននាំដុំកម្រងផ្កាចេញអំពីប្រហោងពិណ ។ ពស់អត់អាហារ ២-៣ ថ្ងៃ ក៏លូនចេញមកតាមប្រហោងពិណនោះ បើកពពារ (បញ្ចេញសំឡេង) ដេកលើទីព្រះបន្ទំ ។ ព្រះនាងមាគន្ទិយាឃើញពស់នោះ ក៏ស្រែកឡើងថា “បពិត្រព្រះសម្មតិទេព ពស់” កាលនឹងជេរព្រះរាជា និងស្ត្រីទាំងនោះ ក៏ពោលថា “ព្រះរាជាល្ងង់អង្គនេះមិនមានវាសនា មិនជឿពាក្យរបស់យើង សូម្បីស្ត្រីទាំងនេះក៏ជាមនុស្សមិនមានសិរី ក្បាលរឹង ប្រៀនប្រដៅបានដោយ

ក្រ ពួកវាមិនបានអ្វីអំពីសំណាក់របស់ព្រះរាជាឬ? ពួកនាងឯង កាលព្រះរាជាអង្គនេះសោយទិវង្គតហើយ នឹងជាអ្នកសប្បាយឬ កាលព្រះរាជានៅមានព្រះជន្ម ពួកនាងឯងរស់នៅដោយលំបាកឬ? ថ្ងៃនេះ យើងឃើញការយល់សុបិនដ៏អាក្រក់របស់យើងហើយ ព្រះអង្គអើយ ព្រះអង្គទ្រង់មិនស្តាប់ពាក្យរបស់ខ្ញុំព្រះអង្គដែលជាអ្នកអង្វរថា "មិនគួរស្តេចទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតីទេ" ។ ព្រះរាជាទតឃើញពស់ ក៏ទ្រង់តក់ស្លុតព្រះទ័យខ្លាចមរណៈ ប្រៀបដូចជាគ្រាប់ក្លើងឆេះដោយសេចក្តីពិរោធថា "ស្ត្រីទាំងនេះធ្វើកម្មបែបនេះ ឱអញអើយ! អ្វីក៏អាក្រក់ម៉្លេះ ព្រោះមិនជឿពាក្យរបស់នាងមាគន្ទិយា ដែលជាអ្នកប្រាប់ថា ស្ត្រីទាំងនេះជាមនុស្សអាក្រក់ កាលមុនវាចោះប្រហោងទុកក្នុងបន្ទប់ទាំងឡាយរបស់ខ្លួន ហើយអង្គុយមើល ។ កាលយើងបញ្ជូនមាន់ទៅឲ្យ ក៏បញ្ជូនត្រឡប់មកវិញទៀត ថ្ងៃនេះលែងពស់ទុកលើទីដេក" ។ ចំណែកព្រះនាងសាមាវតី ក៏បានឲ្យឱវាទដល់ស្ត្រីទាំង ៥០០ នោះថា "ម្នាលនាងទាំងឡាយ ទីពឹងដទៃរបស់ពួកយើងមិនមានទេ នាងទាំងឡាយ ចូរញ៉ាំងមេត្តាចិត្តឲ្យប្រព្រឹត្តទៅស្មើក្នុងព្រះរាជា ដែលជាកំពូលនៃនរជន ក្នុងព្រះទេវី និងក្នុងខ្លួនឯង នាងទាំងឡាយកុំញ៉ាំងសេចក្តី

ក្រោធឲ្យកើតឡើងដល់នរណាៗ ឡើយ" ។ ព្រះរាជាទ្រង់កាន់យកធ្នូដែលមានសណ្ឋានដូចក្លុកដំរី (ឬស្នែងសត្វ) ដ៏គួរដល់កម្លាំងនៃបុរស ១.០០០ នាក់ ទ្រង់ទាញខ្សែធ្នូដែលភ្ជាប់នូវគ្រាប់សរលាបដោយថ្នាំពិស ធ្វើព្រះនាងសាមាវតីទុកក្នុងខាងមុខ ឲ្យស្ត្រីទាំងនោះឈរតម្រៀបគ្នាតាមលំដាប់ ហើយក៏ទ្រង់ដម្លោះនូវកូនសរទៅចំទ្រូងនៃនាងសាមាវតី ។ កូនសរនោះក៏បែរវិលត្រឡប់ជារបស់មានមុខត្ឋោះកាន់ផ្លូវដែលខ្លួនទៅហើយ ហាក់ដូចជាចូលទៅកាន់ព្រះហឫទ័យរបស់ព្រះរាជា បានឈប់នៅហើយដោយមេត្តានុភាពរបស់ព្រះនាងសាមាវតីនោះ ។ ព្រះរាជាទ្រង់ព្រះចិន្តាដូច្នេះថា "កូនសរដែលយើងបាញ់ទៅហើយ រមែងទម្លុះសូម្បីសិលា សូម្បីឋានៈដែលនឹងប៉ះខ្ទប់ក្នុងឱកាសក៏មិនមាន អើ! ក៏កូនសរនេះហេតុដូចម្តេចបានជាមានមុខត្ឋោះមកកាន់ហឫទ័យរបស់យើងវិញ? ពិតណាស់ សូម្បីកូនសរនេះ មិនមានចិត្តមិនមែនជាសត្វ មិនមែនជារបស់មានជីវិត ប៉ុន្តែដឹងគុណនាងសាមាវតី ឯខ្លួនយើងជាមនុស្ស ហេតុអ្វីបានជាមិនមានការដឹងគុណអ្វីបន្តិចសោះ ។ ព្រះរាជាទ្រង់បោះធ្នូនោះចោល ទ្រង់ផ្គងអញ្ជលីគង់ប្រហោងក្នុងទីជិតបាទមូលនៃព្រះនាងសាមាវតី ហើយត្រាស់គាថានេះថា ៖

យើងជាមនុស្សវង្វេង ជាមនុស្សល្ងង់ខ្លៅ ទិសទាំងពួងរមែង
ងងឹតដល់យើង សាមាវតីអើយ នាងចូរការពារយើង និងនាង
ចូរជាទីពឹងនៃយើង ។

ព្រះនាងសាមាវតីស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏មិនបាន ក្រាបទូលថា "បពិត្រមហារាជ ប្រពៃហើយ សូមព្រះអង្គចូរដល់ទូលបង្គំជាទីពឹងចុះ" (ប៉ុន្តែ) ក្រាបទូលថា "បពិត្រមហារាជ ខ្ញុំព្រះអង្គដល់បុគ្គលណាជាទីពឹង សូមព្រះអង្គគប្បីដល់បុគ្គលនោះជាទីពឹងចុះ" ។

ព្រះនាងសាមាវតី ដែលជាសាវិការបស់ព្រះសម្មាសម្ពុទ្ធ លុះពោលពាក្យដូច្នេះហើយ ក៏ពោលថា ៖

ព្រះអង្គទ្រង់កុំគប្បីដល់ខ្ញុំជាទីពឹងឡើយ ខ្ញុំព្រះអង្គដល់
បុគ្គលណាជាទីពឹង បពិត្រមហារាជ បុគ្គលនោះ គឺ
ព្រះពុទ្ធ ព្រះពុទ្ធនោះជាបុគ្គលដ៏កំពូល សូមព្រះអង្គ
ទ្រង់ដល់ព្រះពុទ្ធអង្គនោះ ជាទីពឹងផង ទ្រង់ជាទីពឹង
របស់ខ្ញុំព្រះអង្គផង ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ព្រះនាងសាមាវតីហើយ ក៏

ទ្រង់ត្រាស់ថា "ឥឡូវនេះ យើងខ្វាចណាស់" ហើយត្រាស់ព្រះគាថានេះថា ៖

យើងនេះវង្វេងវង្វាន់អស់ហើយ ទិសទាំងពួងរមែងមិន

ប្រាកដដល់យើង នាងសាមាវតីអើយ នាងចូរគាំពារ

យើង មួយវិញទៀតនាងចូរជាទីពឹងរបស់យើង ។

គ្រានោះ ព្រះនាងសាមាវតី ក៏ហាមឃាត់ព្រះរាជាដោយន័យដូចមុននោះឯងទៀត កាលព្រះរាជាត្រាស់ថា "បើដូច្នោះ យើងសូមដល់នាង និងព្រះសាស្តាជាទីពឹង ហើយយើងនឹងឲ្យពរដល់នាង" ដូច្នេះ ទើបក្រាបទូលថា "បពិត្រមហារាជ ពរចូរជាវត្ថុដែលខ្ញុំម្ចាស់បានទទួលចុះ" ។ ព្រះរាជាស្តេចចូលទៅគាល់ព្រះសាស្តា ទ្រង់ដល់ព្រះសាស្តាជាសរណៈហើយ ទ្រង់ថ្វាយទានដល់ភិក្ខុសង្ឃអស់ ៧ ថ្ងៃហើយ ទ្រង់ហៅនាងសាមាវតីមកត្រាស់ថា "ម្នាលនាងសមាវតី នាងចូរក្រោកឡើងទទួលពរចុះ" ព្រះនាងសាមាវតីក្រាបទូលថា "បពិត្រមហារាជ ខ្ញុំម្ចាស់មិនមានសេចក្តីត្រូវការដោយវត្ថុទាំងឡាយ មានប្រាក់ជាដើមទេ ប៉ុន្តែសូមព្រះអង្គព្រះរាជទានពរនេះដល់ខ្ញុំម្ចាស់ (គឺ) ព្រះសាស្តាព្រមទាំងភិក្ខុ ៥០០ រូប នឹងស្តេចមកកាន់ទីនេះជាប់មិនដាច់បានដោយប្រការណា សូមព្រះអង្គទ្រង់ធ្វើដោយប្រការនោះចុះ ខ្ញុំម្ចាស់

នឹងស្តាប់ធម៌” ។ ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា “បពិត្រ ព្រះអង្គដ៏ចម្រើន សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃ ៥០០ រូប ចូរស្តេចមក កាន់ទីនេះជានិច្ចចុះ ព្រោះពួកស្ត្រីដែលរួមទាំងព្រះនាងសាមាវតី ពោលថា “ខ្ញុំម្ចាស់នឹងស្តាប់ធម៌” ។

ព្រះសាស្តា. មហាបពិត្រ ធម្មតាការត្រាច់ទៅក្នុងទីតែមួយជានិច្ច រមែងមិនសមគួរដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះមហាជនក៏ប្រាថ្នាចំពោះ ព្រះពុទ្ធ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះអង្គទ្រង់ចាត់ ភិក្ខុ ១ រូបចុះ ។

ព្រះសាស្តាក៏ទ្រង់បានចាត់ព្រះអានន្ទ ។ ចាប់តាំងពីពេលនោះមក ព្រះអានន្ទត្ថេរនោះ ក៏នាំភិក្ខុ ៥០០ រូបទៅកាន់រាជត្រកូលជានិច្ច ព្រះទេវី ទាំងនោះ ញុំាងព្រះថេរៈព្រមទាំងបរិវារឲ្យឆាន់ និងស្តាប់ធម៌ជានិច្ច ។

ថ្ងៃមួយ ស្ត្រីទាំងនោះស្តាប់ធម្មកថារបស់ព្រះថេរៈហើយ ជ្រះថ្លាបាន បូជាធម៌ដោយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំង ។ ឧត្តរាសង្គៈមួយផ្ទាំងៗ មានតម្លៃ ៥០០ កហាបណៈ ។ ព្រះរាជាទ្រង់មិនឃើញសំពត់របស់ស្ត្រី

ទាំងនោះសូម្បីតែមួយផ្ទាំង ទើបត្រាស់សួរថា "សំពត់ឧត្តរាសង្គៈនៅឯណា"

ពួកស្ត្រី. ពួកខ្ញុំម្ចាស់ប្រគេនលោកម្ចាស់អានន្ទហើយ ។

ព្រះរាជា. លោកម្ចាស់អានន្ទនោះ ទទួលយកទាំងអស់ឬ ។

ពួកស្ត្រី. បពិត្រមហារាជ ទទួលទាំងអស់ ។

ព្រះរាជាស្ដេចចូលទៅរកព្រះថេរៈ ហើយត្រាស់សួរដល់ស្ត្រីទាំងនោះប្រគេនសំពត់ឧត្តរាសង្គៈ ទ្រង់ព្រះសណ្ដាប់នូវការដែលស្ត្រីទាំងនោះប្រគេន និងការដែលព្រះថេរៈទទួលហើយ ទើបត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់មានច្រើនក្រៃពេកមិនមែនឬ លោកម្ចាស់នឹងធ្វើអ្វីដោយសំពត់ច្រើនបែបនេះ? ។

ព្រះថេរៈ. ថ្វាយព្រះពរមហារាជ អាត្មាភាពទទួលសំពត់ល្មមដល់អាត្មាភាពហើយ ហើយប្រគេនសំពត់ដ៏សេសដល់ភិក្ខុទាំងឡាយដែលមានចីវរចាស់គ្រាំគ្រា ។

ព្រះរាជា. ភិក្ខុទាំងឡាយ នឹងធ្វើចីវរចាស់របស់ខ្លួនឲ្យទៅជាអ្វី ។

ព្រះថេរៈ. លោកនឹងឲ្យដល់ភិក្ខុអ្នកមានចីវរចាស់ជាងទាំងឡាយ ។

ព្រះរាជា. ភិក្ខុទាំងនោះនឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជារបស់អ្វី ។

ព្រះថេរៈ. លោកនឹងធ្វើឲ្យទៅជាសំពត់សម្រាប់ក្រាលដេក ។

ព្រះរាជា. ភិក្ខុទាំងនោះនឹងធ្វើសំពត់សម្រាប់ក្រាលដេកចាស់នោះឲ្យទៅជារបស់អ្វី ។

ព្រះថេរៈ. លោកនឹងធ្វើឲ្យជាសំពត់ក្រាលផ្ទៃ ។

ព្រះរាជា. ភិក្ខុទាំងនោះនឹងយកសំពត់ក្រាលផ្ទៃចាស់នោះទៅធ្វើអ្វី ។

ព្រះថេរៈ. ថ្វាយព្រះពរមហាបពិត្រ លោកនឹងធ្វើឲ្យជាសំពត់ជូតជើង ។

ព្រះរាជា. លោកនឹងយកសំពត់ជូតជើងចាស់នោះទៅធ្វើអ្វី ។

ព្រះថេរៈ. លោកនឹងចញ្ច្រាំឲ្យល្អិត ហើយច្របាច់លាយជាមួយនឹងដីស្អិត បូកជញ្ជាំង ។

ព្រះរាជា. បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់ទាំងឡាយដែលប្រគេនដល់ពួកលោកម្ចាស់រមែងមិនវិនាសទៅ ព្រោះធ្វើនូវកម្មមានប្រមាណប៉ុណ្ណេះឬ ។

ព្រះថេរៈ. យ៉ាងនោះឯង មហាបពិត្រ ។

ព្រះរាជាទ្រង់ជ្រះថ្លាហើយ ទ្រង់ត្រាស់ឲ្យគេនាំសំពត់ ៥០០ ផ្ទាំងដទៃទៀតមក ហើយឲ្យតម្កល់ទុកទៀបបាទមូលរបស់ព្រះថេរៈ ។ បានឮថា

ព្រះថេរៈបានសំពត់មានតម្លៃ ៥០០ ដែលព្រះរាជាទ្រង់តម្កល់ទុកទៀបបាទ-មូល ប្រគេនដោយចំណែក ៥០០ អស់វារៈ ៥០០ ដង បានសំពត់មានតម្លៃ ១.០០០ ដែលព្រះរាជាតម្កល់ទុកទៀបបាទមូលប្រគេនដោយចំណែក ១០០០ អស់វារៈ ១.០០០ ដង ទើបបានសំពត់មានតម្លៃមួយសែន ដែលព្រះរាជាតម្កល់ទុកទៀបបាទមូលប្រគេនដោយចំណែកមួយសែន អស់វារៈមួយសែនដង ។ ក៏ឈ្មោះថាការរាប់សំពត់ដែលព្រះថេរៈបានហើយ ដោយន័យជាដើមថា ១-២-៣-៤-៥-១០ ដូច្នេះ រមែងមិនមាន ។ បានឮថា កាលព្រះតថាគតបរិនិព្វានហើយ ព្រះថេរៈត្រាច់ទៅកាន់ជម្ពូទ្វីបទាំងមូល បានប្រគេនបាត្រ និងចីវរទាំងឡាយដែលជារបស់ខ្លួននោះឯង ដល់ភិក្ខុទាំងឡាយក្នុងវិហារទាំងពួង ។

## ព្រះនាងសាមាវតីត្រូវភ្លើងឆេះ

ព្រះនាងមាគន្ទិយាគិតថា "យើងធ្វើនូវអំពើណា អំពើនោះមិនបានជាយ៉ាងនោះ ត្រឡប់ជាយ៉ាងដទៃទៅវិញ យើងនឹងធ្វើដូចម្តេចហ្ន៎?" ដូច្នេះហើយគិតថា "ឧបាយនេះប្រើប្រាស់បាន" កាលព្រះរាជាស្តេចទៅកាន់ព្រះរាជឧទ្យាន ក៏បញ្ជូនដំណឹងទៅឲ្យឪពុកមាថា "សូមពុកចូរទៅកាន់ប្រាសាទ

របស់នាងសាមាវតី ប្រើឲ្យគេបើកឃ្លាំងសំពត់ និងឃ្លាំងប្រេង ហើយជ្រលក់សំពត់ក្នុងភាជនៈសម្រាប់ដាក់ប្រេង រុំទីងសសរ ធ្វើស្ត្រីទាំងអស់នោះទុកក្នុងទីជាមួយគ្នា បិទទ្វារចាក់សោរខាងក្រៅ យកគប់ភ្លើងមានដងដុតដំណាក់ហើយចូរគេចចេញទៅ" ។ នាយមាគន្ទិយៈនោះឡើងកាន់ប្រាសាទ ប្រើឲ្យគេបើកឃ្លាំងទាំងឡាយ យកសំពត់ទៅជ្រលក់ក្នុងប្រេងឲ្យទទឹក ហើយផ្តើមរុំសសរ ។ គ្រានោះ ស្ត្រីទាំង ៥០០ នាក់ ដែលមាននាងសាមាវតីជាប្រធានបានសួរនាយមាគន្ទិយៈថា "ម្នាលនាយ លោកធ្វើអ្វីហ្នឹង" ហើយក៏ចូលទៅជិត ។ នាយមាគន្ទិយៈពោលយ៉ាងនេះថា "ម្នាលនាងទាំងឡាយព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យរុំសសរទាំងនេះ ដោយសំពត់ដែលជ្រលក់ប្រេងដើម្បីប្រយោជន៍ដល់ការធ្វើឲ្យរឹងមាំ ធម្មតាក្នុងព្រះរាជវាំង កម្មដែលបុគ្គលធ្វើល្អ និងអាក្រក់ ជារបស់ដែលដឹងបានដោយកម្រ ដូច្នេះនាងទាំងឡាយកុំនៅក្នុងទីជិតខ្ញុំឡើយ" ដូច្នេះ ហើយឲ្យស្ត្រី ៥០០ ដែលមាននាងសាមាវតីជាប្រធាននោះ ចូលទៅក្នុងបន្ទប់បិទទ្វារចាក់សោរអំពីខាងក្រៅ ហើយក៏ឈ្មួលភ្លើងដុត ចាប់តាំងអំពីខាងដើមរៀងមក ។ ព្រះនាងសាមាវតីបានឲ្យឱវាទដល់ស្ត្រីទាំងនោះថា "ការកំណត់អត្តភាព ដែលត្រូវភ្លើងឆេះយ៉ាង

នេះរបស់ពួកយើងដែលត្រាច់រង្គាត់ក្នុងសង្សារវដ្ដ ដែលមានទីបំផុតខាងដើមបុគ្គលតាមដឹងមិនបាន សូម្បីពុទ្ធញ្ញាណក៏មិនមែនធ្វើបានដោយងាយ នាងទាំងឡាយចូរជាអ្នកកុំប្រមាទចុះ" ។ ស្ត្រីទាំងនោះកាលដំណាក់របស់ខ្លួនត្រូវភ្លើងឆេះ មនសិការនូវវេទនាបរិគ្គហកម្មដ្ឋាន (គឺ កម្មដ្ឋានកំណត់យកវេទនាជាអារម្មណ៍) ពួកខ្លះបានសម្រេចផលទី ២ ពួកខ្លះបានសម្រេចផលទី ៣ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា "គ្រានោះពួកភិក្ខុជាច្រើន ត្រឡប់ពីបិណ្ឌបាត ក្នុងខាងក្រោយភត្ត ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមាន-ព្រះភាគ ហើយអង្គុយក្នុងទីសមគួរមួយ បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ កាលព្រះបាទឧទេនស្ដេចទ្រង់ទៅកាន់ឧទ្យាន មានភ្លើងឆេះខាងក្នុងព្រះរាជវាំង ពួកស្ត្រី ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ធ្វើមរណកាលហើយ បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់ឧបាសិកាទាំងនោះ តើដូចម្ដេច លោកខាងមុខតើដូចម្ដេច ។ ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងឧបាសិកាទាំងនោះ ឧបា-សិកាជាសោតាបន្នាក៏មាន ជាសកទាគាមីក៏មាន ជាអនាគាមីក៏មាន ម្នាល

ភិក្ខុទាំងឡាយ ឧបាសិកាទាំងអស់នោះ ធ្វើកាលកិរិយាទៅដោយមិនឥតផល ទេ" ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនោះហើយ ទើប ទ្រង់បន្លឺឧទាននេះក្នុងវេលានោះថា ៖

សត្វលោកមានមោហៈជាចំណង ប្រាកដដូចជាវត្ថុដែលគួរ
ឲ្យរីករាយ បុគ្គលពាលមានឧបធិក្កិលេសជាគ្រឿងចង ត្រូវ
ងងឹតចោមរោមហើយ ទើបប្រាកដដូចជាទៀងទាត់ សេចក្តី
កង្វល់រមែងមិនមានដល់បណ្ឌិត ។

លុះត្រាស់យ៉ាងនោះហើយ ទ្រង់សម្តែងធម៌ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងឡាយ ដែលត្រាច់រង្គាត់ក្នុងវដ្តៈ ជាអ្នកមិនប្រមាទអស់កាល ជានិច្ច ធ្វើបុញ្ញកម្មក៏មាន ជាអ្នកមានសេចក្តីប្រមាទធ្វើបាបកម្មក៏មាន ព្រោះ ហេតុនោះ សត្វលោកដែលត្រាច់ទៅក្នុងវដ្តៈទើបសោយសុខខ្លះ ទុក្ខខ្លះ" ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ដំណឹងថា "ដំណាក់របស់ព្រះនាងសាមាវតី ត្រូវភ្លើងឆេះ" សូម្បីកាលស្តេចមកដោយប្រញាប់ ក៏មិនទាន់ដំណាក់ដែល ត្រូវភ្លើងឆេះ លុះស្តេចមកដល់ហើយ ត្រាស់បង្គាប់ឲ្យលត់ភ្លើង ទ្រង់កើត ទោមនស្សយ៉ាងខ្លាំង ដែលមានពួកអាមាត្យចោមរោម ទ្រង់គង់រឭកដល់

ព្រះគុណរបស់ព្រះនាងសាមាវតី ទ្រង់ព្រះចិន្តាថា អំពើនេះជាអំពើរបស់នរណាហ្ន៎?” ដូច្នេះ ហើយទ្រង់ជ្រាបថា “អំពើនេះប្រាកដជាអំពើដែលនាងមាគន្ទិយាបញ្ជាឲ្យគេធ្វើហើយ ទ្រង់ព្រះចិន្តាថា នាងមាគន្ទិយានោះដែលយើងគម្រាមហើយសួរ នឹងមិនប្រាប់តាមត្រង់ទេ យើងនឹងរកឧបាយ ហើយសួរដោយសន្សឹមៗ” ទើបត្រាស់នឹងអាមាត្យទាំងឡាយថា “នែអ្នកដ៏ចម្រើនទាំងឡាយ ក្នុងកាលមុនអំពីកាលនេះ យើងក្រោកឡើងហើយ ក៏ជាអ្នករង្កៀសសង្ស័យដោយជុំវិញ នាងសាមាវតីរមែងស្វែងរកតែទោសរបស់យើងជានិច្ច ឥឡូវនេះ នាងស្លាប់ហើយ យើងបានត្រជាក់ចិត្តណាស់ យើងបានរស់នៅដោយសេចក្តីសុខហើយ” ពួកអាមាត្យក្រាបទូលសួរថា “បពិត្រព្រះសម្មតិទេព កម្មនេះអ្នកណាជាអ្នកធ្វើហ្ន៎ ព្រះរាជាត្រាស់ឆ្លើយថា នឹងជាកម្មដែលអ្នកណាមួយធ្វើហើយដោយសេចក្តីស្នេហាក្នុងយើង” ។ ព្រះនាងមាគន្ទិយាឈរនៅក្នុងទីជិតព្រះតម្រាស់នោះភ្លាម ក៏ក្រាបទូលថា “អ្នកដទៃនឹងធ្វើអ្វីបាន បពិត្រមហារាជ កម្មនេះខ្ញុំម្ចាស់ជាអ្នកធ្វើ ខ្ញុំម្ចាស់បានបង្គាប់ឱពុកមារបស់ខ្ញុំម្ចាស់ឲ្យធ្វើ” ។ ព្រះរាជាត្រាស់ថា “អ្នកដែលជាទីស្រឡាញ់របស់យើងដទៃក្រៅអំពីនាង រមែងមិនមាន យើងពេញចិត្តណាស់

ម្នាលនាងទេវី យើងនឹងឲ្យពរដល់នាង នាងចូរបញ្ជូនមនុស្សឲ្យទៅហៅពួកញាតិរបស់នាងមក” នាងមាគន្ទិយាបានផ្ញើដំណឹងទៅប្រាប់ពួកញាតិថា “ព្រះរាជាទ្រង់ពេញព្រះទ័យនឹងព្រះរាជទានពរដល់យើង សូមជនទាំងឡាយដែលជាញាតិរបស់យើងចូរមកយ៉ាងឆាប់” ព្រះរាជាបញ្ជាឲ្យធ្វើនូវសក្ការៈធំដល់ញាតិទាំងឡាយរបស់ព្រះនាងមាគន្ទិយាដែលមកហើយ សូម្បីពួកជនដែលមិនមែនជាញាតិរបស់ព្រះនាងមាគន្ទិយាឃើញសក្ការៈនោះហើយ ក៏ឲ្យនូវសំណូកហើយពោលថា “ពួកយើងជាញាតិរបស់ព្រះនាងមាគន្ទិយា” ហើយក៏បាននាំគ្នាមកកាន់រាជវាំង ។ ព្រះរាជាបញ្ជាឲ្យរាជបុរសចាប់ជនទាំងអស់នោះ ហើយឲ្យជីករណ្តៅទាំងឡាយ មានជម្រៅប្រមាណត្រឹមផ្ចិត នាព្រះលានហ្លួង ឲ្យជនទាំងនោះអង្គុយក្នុងរណ្តៅទាំងនោះហើយយកដីកប់ បញ្ជាឲ្យរោយចំបើងពីខាងលើ ហើយឈួលភ្លើងដុត ក្នុងវេលាដែលស្បែកត្រូវភ្លើងឆេះ ទ្រង់បង្គាប់ឲ្យរាជបុរសភ្ជួរដោយនង្គ័លដែកទាំងឡាយ បង្គាប់ឲ្យរាជបុសធ្វើឲ្យជាកំណាត់តូច-ធំ (ឬ) ជាចំរៀកតូច-ធំ ។ ព្រះរាជាបញ្ជាឲ្យពន្លះសាច់អំពីសរីរៈរបស់នាងមាគន្ទិយា ត្រង់កន្លែងដែលមានសាច់ជាដុំៗដោយកាំបិតដ៏មុត ហើយឲ្យលើកឡើងកាន់ចង្ក្រាន ចម្អិនដោយប្រេង ឲ្យ

ចៀនដូចដានំ ហើយបញ្ជាឲ្យនាងមាគន្ទិយាទំពាស៊ីសាច់នោះ ។

តមកថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អាវុសោទាំងឡាយ ការស្លាប់ដូច្នេះ របស់ឧបាសិកាអ្នកដល់ព្រមដោយសភាពបែបនេះ មិនសមគួរសោះឡើយ" ព្រះសាស្តាស្តេចយាងមកត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី" កាលពួកភិក្ខុទាំងនោះក្រាបទូលថា "ដោយរឿងឈ្មោះនេះ" ដូច្នេះ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការស្លាប់របស់ស្ត្រីទាំងឡាយ មាននាងសាមាវតីជាប្រធាននោះ មិនសមគួរក្នុងអត្តភាពនេះពិតមែនហើយ ប៉ុន្តែថា ការស្លាប់ដែលស្ត្រីទាំងនោះបានហើយ សមគួរដល់កម្មដែលស្ត្រីទាំងនោះបានធ្វើទុកក្នុងជាតិមុន" កាលភិក្ខុទាំងនោះទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន កម្មអ្វីដែលស្ត្រីទាំងនោះធ្វើទុកក្នុងកាលមុន សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ" ដូច្នេះ ទើបទ្រង់នាំអតីតនិទានមក (សម្តែងថា) ៖

## បុព្វកម្មរបស់នាងសាមាវតី និងបរិវារ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី ព្រះបច្ចេកពុទ្ធ ៨ អង្គ តែងតែឆាន់នៅក្នុងព្រះរាជវាំងជានិច្ច ។

ស្ត្រី ៥០០ នាក់ តែងតែបម្រើព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្ដាព្រះបច្ចេក-ពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គ ទៅកាន់ហិមវន្តប្រទេស មួយអង្គទៀតគង់ចូលឈាននៅក្នុងស្បាតនៃព្រៃមួយកន្លែងក្បែរឆ្នេរស្ទឹង ។ ថ្ងៃមួយកាលព្រះបច្ចេកពុទ្ធទៅហើយ ព្រះរាជាទ្រង់នាំស្ត្រីទាំងនោះទៅដើម្បីលេងទឹកក្នុងស្ទឹង ស្ត្រីទាំងនោះលេងទឹកក្នុងស្ទឹងនោះរហូតអស់មួយថ្ងៃ ឡើងមកត្រូវរងារបៀតបៀនបំណងនឹងអាំងភ្លើង ពោលថា "ម្នាលនាងទាំងឡាយគប្បីរកមើលទីបង្កាត់ភ្លើងរបស់ពួកយើង ដើរទៅដើរមក ឃើញគុម្ពស្មៅនោះ ក៏ឈរបោមរោមបង្កាត់ភ្លើងហើយដោយសម្គាល់ថា "គំនរស្មៅ" កាលស្មៅទាំងឡាយឆេះហើយទ្រោមចុះ ស្ត្រីទាំងនោះឃើញព្រះបច្ចេកពុទ្ធ ក៏ពោលថា "យើងវិនាសហើយ! ព្រះបច្ចេកពុទ្ធរបស់ព្រះរាជាត្រូវភ្លើងឆេះព្រះរាជាទ្រង់ជ្រាបនឹងធ្វើពួកយើងឲ្យវិនាស យើងនឹងធ្វើលោកឲ្យឆេះសុះតែម្ដងទៅ" គ្រប់គ្នានាំឧសមកអំពីទីនេះទីនោះ ធ្វើឲ្យជាគំនរខាងលើព្រះបច្ចេកពុទ្ធនោះ គំនរឧសធំបានមានហើយលើព្រះបច្ចេកពុទ្ធ ។ គ្រានោះស្ត្រីទាំងនោះដុតឧសនោះ ហើយចៀសចេញទៅ ដោយសម្គាល់ថា "ឥឡូវនេះ ភ្លើងឆេះអស់ហើយ" គ្រាមុនស្ត្រីទាំងនោះមិនមានចេតនា (តែ) គ្រា

នេះក៏ត្រូវចំណងកម្ម (ចេតនា) ហើយ ។ ក៏ជនទាំងឡាយសូម្បីនាំឧសមួយពាន់រទេះមកដុត ក៏មិនអាចនឹងធ្វើព្រះបច្ចេកពុទ្ធដែលកំពុងនៅក្នុងសមាបត្តិសូម្បីឲ្យមានអាការ គឺ ចំហាយក្តៅបន្តិចបន្តួចបានឡើយ ។ ក្នុងថ្ងៃទី ៧ ក៏បានក្រោកឡើងទៅតាមសប្បាយ ។ ស្ត្រីទាំងនោះឆេះក្នុងនរកអស់ច្រើនពាន់ឆ្នាំ ព្រោះកម្មដែលខ្លួនបានធ្វើទុកហើយនោះ បានឆេះក្នុងផ្ទះដែលត្រូវភ្លើងឆេះដោយទំនងនេះឯង អស់មួយរយអត្តភាព ដោយវិបាកដ៏សេសនៃកម្មនោះឯង ។ នេះជាបុព្វកម្មរបស់ស្ត្រីទាំងនោះ ។

## បុព្វកម្មរបស់នាងខុជ្ជុត្តរា

កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ ភិក្ខុទាំងឡាយក៏ក្រាបទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ក៏នាងខុជ្ជុត្តរាដោយសារកម្មអ្វីទៅ ទើបបានជាស្រីគម? ព្រោះកម្មអ្វីទើបជាអ្នកមានបញ្ញាច្រើន? ព្រោះកម្មអ្វីទើបបានសម្រេចសោតាបត្តិផល? ព្រោះកម្មអ្វីទើបបានជាអ្នកបម្រើគេ?" ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះរាជាអង្គនោះឯងគ្រងរាជ សម្បត្តិក្នុងក្រុងពារាណសី ព្រះបច្ចេកពុទ្ធអង្គនោះជាមនុស្សគមបន្តិច ។ គ្រានោះ ស្ត្រីដែលជាឧបដ្ឋាយិកាម្នាក់ដណ្តប់សំពត់

កម្ពល កាន់ផ្តិលមាសធ្វើជាមនុស្សគម សម្តែងអាការត្រោប់តាមព្រះបច្ចេក-ពុទ្ធនោះ ដោយនិយាយថា "ព្រះបច្ចេកពុទ្ធរបស់ពួកយើង រមែងត្រោច់ទៅយ៉ាងនេះៗ" ។ ព្រោះផលដែលហូរចេញអំពីកម្មនោះ ទើបនាងបានជាស្រីគម ។ មយ៉ាងទៀត ក្នុងថ្ងៃដំបូង ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងនោះឲ្យគង់ក្នុងរាជដំណាក់ ហើយត្រាស់បង្គាប់ឲ្យរាជបុរសទទួលបាត្រ ញ៉ាំងបាត្រទាំងឡាយឲ្យពេញដោយបាយាស ហើយឲ្យប្រគេនព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ កាន់បាត្រដែលពេញដោយបាយាសដ៏ក្តៅ ត្រូវផ្លាស់ដៃទៅមកៗ រឿយៗ ។ ស្ត្រីនោះ ឃើញព្រះបច្ចេកពុទ្ធធ្វើយ៉ាងនោះក៏ប្រគេនកងដៃធ្វើអំពីភ្លុក ៨ ដែលជារបស់ខ្លួន ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ដាក់បាត្រលើកងទាំងនេះ ហើយកាន់យកចុះ" ព្រះបច្ចេកពុទ្ធទាំងនោះក៏ធ្វើយ៉ាងនោះ ហើយសម្លឹងមើលស្ត្រីនោះ ។ នាងជ្រាបសេចក្តីប្រាថ្នារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបពោលថា "បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់មិនត្រូវការកងទាំងនេះទេ ខ្ញុំម្ចាស់បរិច្ចាគកងទាំងនេះហើយដល់លោកម្ចាស់ទាំងឡាយនោះឯង សូមលោកម្ចាស់ទទួលយកទៅ" ។ ព្រះបច្ចេកពុទ្ធទាំងនោះទទួលហើយ បានទៅកាន់ញកភ្នំឈ្មោះនន្ទមូលកៈ ។

សូម្បីសព្វថ្ងៃនេះ កងទាំងនោះក៏តាំងនៅដោយល្អនោះឯង ។ ព្រោះផល ដែលហូរចេញអំពីកម្មនោះ ក្នុងកាលឥឡូវនេះ ទើបនាងបានជាអ្នកទ្រទ្រង់ ព្រះត្រៃបិដក មានបញ្ញាច្រើន ។ ព្រោះផលដែលហូរចេញអំពីការឧបដ្ឋាក ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបនាងបានសម្រេចសោតាបត្តិផល ។ នេះជា បុព្វកម្មក្នុងកាលជាចន្លោះនៃព្រះពុទ្ធរបស់នាង ។

ចំណែកក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ធីតារបស់សេដ្ឋីក្នុងក្រុង ពារាណសីម្នាក់កាន់យកកញ្ចក់ អង្គុយតាក់តែងខ្លួនក្នុងវេលានៃព្រះអាទិត្យ មានស្រមោលចម្រើន (វេលារសៀល) ។ គ្រានោះ នាងភិក្ខុនីខីណាស្រព មួយរូប ដែលជាទីស្និទ្ធស្នាលនឹងនាងបានទៅសួរសុខទុក្ខនាង ។ ពិតណាស់ នាងភិក្ខុនីសូម្បីជាព្រះខីណាស្រពហើយក៏ដោយ ក៏នៅតែប្រាថ្នាដើម្បីនឹង ឃើញត្រកូលឧបដ្ឋាករបស់ខ្លួនក្នុងវេលារសៀល ។ ក៏ក្នុងខណៈនោះ ស្ត្រី បម្រើឯណានីមួយ ក៏មិនមាននៅក្នុងសំណាក់របស់សេដ្ឋីធីតានោះឡើយ ។ ទើបនាងពោលថា “បពិត្រព្រះនាងម្ចាស់ ខ្ញុំសូមថ្វាយបង្គំ សូមព្រះនាងមេត្តា យកកញ្ច្រែងនៃគ្រឿងប្រដាប់នោះហុចឲ្យខ្ញុំបន្តិច” ។ ព្រះថេរីគិតថា “ប្រសិន បើយើងនឹងមិនយកកញ្ច្រែងគ្រឿងប្រដាប់នេះហុចឲ្យនាងសោត នាងនឹងចង

អាឃាតជាមួយយើង ក៏នឹងកើតក្នុងនរក” ប៉ុន្តែថា បើយើងនឹង (យក) ឲ្យនាងនឹងបានជាស្រីបម្រើគេ ប៉ុន្តែថា ត្រឹមតែជាអ្នកបម្រើគេប្រសើរជាងឆេះក្នុងនរក” ។ ព្រះថេរីអាស្រ័យសេចក្តីករុណា ទើបបានយកកញ្ច្រែងដាក់គ្រឿងប្រដាប់នោះហុចឲ្យនាង ។ ព្រោះផលដែលហូរចេញអំពីកម្មនោះ ទើបនាងបានជាអ្នកបម្រើគេ ។

## ព្រះសាស្តាស្តេចសម្តែងធម៌នៅធម្មសភា

លុះស្អែកឡើង ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា “ស្ត្រី ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ត្រូវភ្លើងឆេះហើយក្នុងជំណាក់ ឯពួកញាតិរបស់នាងមាគន្ទិយាត្រូវភ្លើងចំបើងឆេះពីខាងលើ ហើយបំបែកឲ្យបែកដោយនង្គ័លដែក ព្រះនាងមាគន្ទិយា ត្រូវរាជបុរសចៀនដោយប្រេងដ៏ក្តៅ ក្នុងបណ្តាជនទាំងនោះ នរណាហ្ន៎ ឈ្មោះថា រស់នៅ? នរណាហ្ន៎ ឈ្មោះថាស្លាប់ហើយ?” ។ ព្រះសាស្តាស្តេចយាងមកហើយ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះអ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី ? កាលពួកភិក្ខុទាំងនោះក្រាបទូលថា “ដោយរឿងឈ្មោះនេះ” ដូច្នេះហើយ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលណាប្រមាទហើយ បុគ្គលនោះសូម្បី

រស់នៅ ១០០ ឆ្នាំ ក៏ឈ្មោះថា ស្លាប់ហើយដោយពិត បុគ្គលណាមិនប្រមាទ បុគ្គលនោះសូម្បីស្លាប់ហើយ ក៏ឈ្មោះថា នៅរស់ ព្រោះដូច្នោះ ព្រះនាងមាគន្ទិយាទោះបីរស់នៅក្តី ស្លាប់ហើយក្តី ក៏ឈ្មោះថា ស្លាប់ហើយដោយពិត ស្រ្តី ៥០០ នាក់ មានព្រះនាងសាមាវតីជាប្រធាន សូម្បីស្លាប់ហើយ ក៏ឈ្មោះថា នៅរស់ដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមិនប្រមាទ ឈ្មោះថា រមែងមិនស្លាប់" ដូច្នេះ ទើបបានសម្តែងព្រះគាថាទាំងនេះថា ៖

អប្បមាទោ អមតំ បទំ　　បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ　　យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា　　អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ　　អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា　　និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ　　យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តី
ប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិន

ប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែល
ប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួក
បណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា (ទើបឋិត
នៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ
បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរនៃអរិ-
យបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យា-
យាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជា
អ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វានជាទីក្សេមក្សាន្ត
ចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អប្បមាទោ (សេចក្តីមិនប្រមាទ) រមែង សម្តែងនូវអត្ថដ៏ធំ គឺ កាន់យកអត្ថទូលំទូលាយនោះឯង ។ ពិតណាស់ ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកទាំងអស់ ដែលអាចារ្យទាំងឡាយនាំមកពោល រមែងប្រជុំចុះក្នុងសេចក្តីមិនប្រមាទនោះឯង ព្រោះហេតុនោះ ទើបព្រះមាន-ព្រះភាគព្រះអង្គទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ស្នាមជើងណានីមួយ

នៃសត្វដែលត្រាច់លើផែនដី ស្នាមជើងទាំងអស់នោះ តែងដល់នូវការប្រជុំចុះក្នុងស្នាមជើងនៃសត្វដំរី ស្នាមជើងនៃសត្វដំរីប្រាកដជាប្រសើរជាងស្នាមជើងនៃពួកសត្វទាំងនោះ ព្រោះថា ស្នាមជើងនៃដំរីជាស្នាមជើងធំ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសល-ធម៌ទាំងអស់នោះ មានអប្បមាទធម៌ជាមូល មានអប្បមាទធម៌ជាទីប្រជុំចុះអប្ប-មាទធម៌ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។ ក៏សេចក្តីមិនប្រមាទនោះ ដោយអត្ថ គឺ ការមិននៅប្រាសចាកសតិ ព្រោះពាក្យថា "សេចក្តីមិនប្រមាទ" នោះ ជាឈ្មោះនៃសតិដែលតាំងនៅមាំជានិច្ច ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អមតំ បទំ (ផ្លូវជាគ្រឿងដល់អមតៈ)** ព្រះនិព្វានហៅថា **អមតៈ** ព្រោះព្រះនិព្វាននោះ ដែលឈ្មោះថា មិនចាស់ មិនស្លាប់ព្រោះជាធម្មជាតិមិនកើត ព្រោះហេតុនោះ ទើបហៅព្រះនិព្វានថា **អមតៈ** , សត្វទាំងឡាយរមែងដល់ដោយសេចក្តីមិនប្រមាទនេះ ព្រោះហេតុនោះ សេចក្តីមិនប្រមាទនេះ ទើបឈ្មោះថា ជាគ្រឿងដល់ អធិប្បាយទុកថា រមែងឲ្យសម្រេចអមតៈ (ដោយសេចក្តីមិនប្រមាទ) ។ គ្រឿងដល់នូវអមតៈ ឈ្មោះថា គ្រឿងដល់អមតៈ មានអធិប្បាយថា "ជាឧបាយឲ្យសម្រេចនូវអមតៈ" ។

ភាវៈ គឺ សេចក្តីវង្វេង (ប្រហែសធ្វេស) ឈ្មោះថា **បមាទោ** សេចក្តីប្រមាទ ។ ពាក្យថា **សេចក្តីប្រមាទនោះ** ជាឈ្មោះនៃការបាត់បង់សតិ ពោលគឺ ការវង្វេងភ្លេចសតិ ។ បទថា **មច្ចុនោ (នៃមច្ចុ)** បានដល់ នៃសេចក្តីស្លាប់ ។ បទថា **បទំ (ជាផ្លូវ)** គឺ ជាឧបាយ បានដល់ ជាផ្លូវ ។ ពិតណាស់ បុគ្គលប្រមាទហើយ រមែងមិនប្រព្រឹត្តកន្លងនូវជាតិបាន សូម្បីកើតហើយ ក៏រមែងចាស់ រមែងស្លាប់ ហេតុនោះ សេចក្តីប្រមាទ ទើបឈ្មោះថា ជាផ្លូវនៃមច្ចុ គឺ រមែងនាំចូលទៅរកសេចក្តីស្លាប់ ។

បាទព្រះគាថាថា **អប្បមត្តា ន មីយន្តិ (អ្នកមិនប្រមាទហើយ ឈ្មោះថា រមែងមិនស្លាប់)** ក៏បុគ្គលអ្នកប្រកបដោយសតិ ឈ្មោះថា ជាអ្នកមិនប្រមាទ នរណាៗ មិនគប្បីកំណត់ថា "បុគ្គលមិនប្រមាទរមែងមិនស្លាប់ គឺជាអ្នកមិនចាស់ និងមិនស្លាប់" ព្រោះថា សត្វណាៗ ឈ្មោះថា មិនចាស់និងមិនស្លាប់ រមែងមិនមាន ប៉ុន្តែវដ្តៈរបស់បុគ្គលដែលប្រមាទកំណត់មិនបាន វដ្តៈរបស់បុគ្គលអ្នកមិនប្រមាទកំណត់បាន ហេតុនោះ បុគ្គលប្រមាទសូម្បីរស់នៅ ក៏ឈ្មោះថា ស្លាប់ហើយដោយពិតប្រាកដ ព្រោះអ្នកមិនផុតអំពីទុក្ខ មានជាតិទុក្ខជាដើម ចំណែកបុគ្គលមិនប្រមាទ ចម្រើនអប្បមាទ-

លក្ខណៈហើយ ធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលយ៉ាងឆាប់រហ័ស រមែងមិនកើតក្នុងអត្តភាពទី ២ និងទី ៣ ហេតុនោះ បុគ្គលអ្នកមិនប្រមាទទាំងនោះ រស់នៅក្តី ស្លាប់ហើយក្តី ក៏ឈ្មោះថា មិនស្លាប់ដោយពិត ។

បាទព្រះគាថាថា **យេ បមត្តា យថា មតា (បុគ្គលណាប្រមាទហើយ បុគ្គលនោះរមែងដូចជាបុគ្គលស្លាប់ហើយ)** សេចក្តីថា ចំណែកសត្វពួកណាប្រមាទហើយ សត្វពួកនោះ រមែងដូចជាសត្វដែលស្លាប់ហើយ ដោយការដាច់ជីវិតិន្ទ្រិយ៍ មានវិញ្ញាណទៅប្រាសហើយ ដូចជាអង្កត់ឧសដូច្នោះដែរ ព្រោះការដែលខ្លួនស្លាប់ហើយ ដោយសេចក្តីស្លាប់ គឺ សេចក្តីប្រមាទ ។ ពិតណាស់ សូម្បីចិត្តមួយដួងថា "យើងនឹងធ្វើទាន យើងនឹងរក្សាសីល យើងនឹងធ្វើឧបោសថកម្ម" រមែងមិនកើតឡើងសូម្បីដល់គេទាំងឡាយដែលជាគ្រហស្ថ ។ ចិត្តមួយដួងថា "យើងនឹងបំពេញវត្តទាំងឡាយ មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម យើងនឹងសមាទានធុតង្គ យើងនឹងចម្រើនភាវនា" រមែងមិនកើតដល់បុគ្គលទាំងនោះសូម្បីជាបព្វជិត ដូចជាចិត្តមួយដួងមិនកើតឡើងដល់សត្វដែលស្លាប់ហើយ សត្វអ្នកប្រមាទហើយនោះ នឹងជាអ្នកមានអ្វីដែលជាគ្រឿងធ្វើឲ្យផ្សេងគ្នាអំពីសត្វដែលស្លាប់ហើយ ព្រោះ

ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **បុគ្គលណាប្រមាទហើយ បុគ្គលនោះរមែងដូចជាអ្នកស្លាប់ហើយ ។**

បាទព្រះគាថាថា **ឯតំ វិសេសតោ ញត្វា (ដឹងសេចក្ដីនោះដោយប្លែកគ្នា)** សេចក្ដីថា ដឹងនូវហេតុដែលប្លែកគ្នានោះថា “ការរលាស់ចេញចាកវដ្ដៈរបស់បុគ្គលប្រមាទរមែងមិនមាន របស់បុគ្គលអ្នកមិនប្រមាទរមែងមាន” ។

មានបុច្ឆាថា “ក៏នរណា រមែងដឹងនូវហេតុដ៏ប្លែកគ្នានោះ” ។

មានវិសជ្ជនាថា **“អប្បមាទម្ហិ បណ្ឌិតា (បណ្ឌិតដែលតាំងនៅក្នុងសេចក្ដីមិនប្រមាទ) រមែងដឹង”** ។ អធិប្បាយថា បណ្ឌិត គឺ អ្នកមានមេធាបានដល់ អ្នកមានបញ្ញាទាំងឡាយណា ដែលតាំងនៅក្នុងសេចក្ដីមិនប្រមាទរបស់ខ្លួនហើយ ចម្រើនសេចក្ដីមិនប្រមាទ បណ្ឌិតទាំងនោះរមែងដឹងហេតុដែលប្លែកគ្នានោះ ។ បទថា **អប្បមាទេ បមោទន្តិ (រីករាយហើយក្នុងសេចក្ដីមិនប្រមាទ)** សេចក្ដីថា បណ្ឌិតទាំងនោះ លុះដឹងយ៉ាងនេះហើយរមែងរីករាយ គឺ ជាអ្នកមានទឹកមុខរីករាយ បានដល់ ត្រេកអរក្នុងសេចក្ដីមិនប្រមាទរបស់ខ្លួននោះ ។ បទថា **អរិយានំ គោចរេ រតា (ត្រេកអរក្នុង**

ធម៌ជាទីគោចររបស់ព្រះអរិយៈទាំងឡាយ) សេចក្តីថា បណ្ឌិតទាំងនោះរីក-រាយក្នុងសេចក្តីមិនប្រមាទនោះ ចម្រើនសេចក្តីមិនប្រមាទនោះហើយ រមែងជាអ្នកត្រេកអរ គឺ ត្រេកអរក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ ចែកចេញជាសតិប្បដ្ឋាន ៤ ជាដើម និងលោកុត្តរធម៌ ៩ ប្រការ ហៅថា ធម៌ជាទីគោចរនៃព្រះអរិយៈទាំងឡាយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះពុទ្ធទាំងឡាយ ។

បទថា **តេ ឈាយិនោ (បណ្ឌិតអ្នកមិនប្រមាទទាំងនោះ មានការសម្លឹង)** សេចក្តីថា បណ្ឌិតដែលជាអ្នកមិនប្រមាទទាំងនោះ ជាអ្នកមានការសម្លឹងពិនិត្យដោយឈានទាំងពីរយ៉ាង គឺ ដោយអារម្មណូបនិជ្ឈាន ពោលគឺ សមាបត្តិ ៨ និងដោយលក្ខណូបនិជ្ឈាន ពោលគឺ វិបស្សនា មគ្គ និងផល ។ បទថា **សាតតិកា (មានសេចក្តីព្យាយាមជាប់ត)** បានដល់ ជាអ្នកមានសេចក្តីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្តជាប់តគ្នា ចាប់តាំងពីកាលដែលចេញបួស រហូតដល់ការសម្រេចព្រះអរហត្ត ។ បទថា **និច្ចំ ទឡ្ហបរក្កមា (ឧស្សាហ៍ជានិច្ច)** សេចក្តីថា អ្នកប្រកបដោយសេចក្តីព្យាយាមបែបនេះថា “ផលឯណា ដែលបុគ្គលគប្បីសម្រេចបានដោយកម្លាំង

របស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែង របស់បុរស នៅមិនទាន់បានសម្រេចផលនោះ ហើយបញ្ឈប់សេចក្តីព្យាយាម ទីងមិនមាន (ដូច្នេះ) ឈ្មោះថា សេចក្តីប្រឹងប្រែងមាំ ដែលខ្លួនមិនបន្ធូរបន្ថយ ក្នុងចន្លោះ ។ ក្នុងបទថា **ផុសន្តិ (រមែងពាល់ត្រូវ)** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ ការពាល់ត្រូវមាន ២ យ៉ាងគឺ **ញាណផុសនា** (ការពាល់ត្រូវញាណ) **វិបាកផុសនា** (ការពាល់ត្រូវដោយវិបាក) ។ ក្នុងការពាល់ត្រូវ ២ យ៉ាងនោះ មគ្គ ៤ ឈ្មោះថា ការពាល់ត្រូវដោយញាណ ។ ផល ៤ ឈ្មោះថា ការពាល់ត្រូវដោយវិបាក ។ ក្នុងការពាល់ត្រូវ ២ យ៉ាងនោះ ការពាល់ត្រូវដោយវិបាក ព្រះមានព្រះភាគទ្រង់បំណងយកក្នុងបទថា **ផុសន្តិ (រមែងពាល់ត្រូវ)** នេះ ។ បណ្ឌិតជាអ្នកប្រាជ្ញ កាលធ្វើនិព្វានឲ្យជាក់ច្បាស់ដោយអរិយផល ឈ្មោះថា រមែងធ្វើនិព្វានឲ្យជាក់ច្បាស់ ព្រោះការពាល់ត្រូវដោយវិបាក ។ បទថា **យោគក្ខេមំ អនុត្តរំ (ជាដែនក្សេមចាកយោគៈដ៏កំពូល)** បានដល់ (នូវនិព្វាន) ដែលជាដែនក្សេម គឺមិនមានភ័យ ចាកយោគៈ ៤ ដែលញ៉ាំងមហាជនឲ្យលិចចុះក្នុងវដ្ដៈ ដែលឈ្មោះថា កំពូល ព្រោះជាគុណជាតិប្រសើរជាងលោកិយធម៌ និងលោកុ-

ត្តរធម៌ទាំងពួង ។

ក្នុងទីបំផុតនៃធម្មទេសនា ជនជាច្រើនបានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ។ ព្រះធម៌ទេសនាបានជាកថា មានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់រឿងព្រះនាងសាមាវតី

# ២. រឿងកុម្ភឃោសកៈ

ព្រះសាស្តា កាលទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ កុម្ភឃោសកៈ ត្រាស់ព្រះធម្មទេសនាដូច្នេះថា **ឧដ្ឋានវតោ (យសរមែងចម្រើនក្រៃលែង) ដល់អ្នកមានសេចក្តីព្យាយាម** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងក្រុងរាជគ្រឹះ អហិវាតករោគ (រោគកើតអំពីខ្យល់មានពិសដូចជាពិសពស់) បានកើតឡើងក្នុងផ្ទះរបស់រាជគហសេដ្ឋី ។ កាលអហិវាតរោគនោះកើតឡើងហើយ សត្វតិរច្ឆានទាំងឡាយតាំងពីរុយក្បាលខៀវរហូតដល់គោ រមែងស្លាប់មុន បន្ទាប់អំពីនោះមកទាសៈ និងកម្មករ ក្រោយគេបង្អស់ គឺ ម្ចាស់ផ្ទះ ព្រោះហេតុនោះ រោគនោះក៏កើតដល់សេដ្ឋី និងភរិយាក្រោយគេបង្អស់ ពីរនាក់ស្វាមីភរិយានោះ កាលត្រូវរោគពាល់ត្រូវហើយ សម្លឹងមើលបុត្តដែលឈរនៅជិត មាននេត្រាទាំងពីរពេញទៅដោយទឹកភ្នែក ពោលទៅកាន់បុត្តថា "នែ៎កូនសម្លាញ់ បានឮថាកាលរោគប្រភេទនេះកើតឡើង ជនទាំងឡាយ ទម្លាយជញ្ជាំងរត់គេចចេញទៅ ទើបបានជីវិត" កូនមិនចាំបាច់ហួងហែង ឬក៏អាឡោះអាល័យចំពោះយើងទាំងពីរទេ គប្បីរត់ចេញទៅឲ្យប្រញាប់ កាលមានជីវិតរស់នៅ គប្បី

ត្រឡប់មកវិញ ហើយគាស់យកទ្រព្យ ៤០ កោដិ ដែលយើងទាំងពីរកប់ទុកក្នុងទីឯណោះចិញ្ចឹមជីវិតចុះ” ។

សេដ្ឋីបុត្រស្តាប់ពាក្យរបស់មាតា និងបិតានោះហើយ យំសំពះមាតាបិតា ខ្លាចចំពោះមរណភ័យ ទើបទម្លាយជញ្ជាំងផ្ទះរត់ចេញទៅកាន់ស្បាតនៃភ្នំ នៅក្នុងទីនោះអស់ ១២ ឆ្នាំ ទើបត្រឡប់មកកាន់លំនៅរបស់មាតាបិតាវិញ ។ គ្រានោះ នរណាៗ ក៏មិនស្គាល់សេដ្ឋីបុត្តនោះ ព្រោះសេដ្ឋីបុត្តនោះទៅក្នុងកាលដែលខ្លួននៅក្មេង ត្រឡប់មកក្នុងកាលមានសក់ ពុកមាត់ ពុកចង្កាដុះឡើងទ្រុបទ្រុល ។ សេដ្ឋីបុត្រនោះ ទៅកាន់ទីកប់កំណប់ទ្រព្យដោយអំណាចនៃគ្រឿងសម្គាល់ដែលមាតាបិតាឲ្យហើយ ដឹងថា ទ្រព្យនៅមិនទាន់វិនាស ក៏គិតថា “នរណាៗ ក៏មិនស្គាល់យើង” ។ ប្រសិនបើយើងនឹងគាស់កំណប់ទ្រព្យឡើងប្រើប្រាស់សោត ជនទាំងឡាយគប្បីគិតថា “បុរសទុគ៌តម្នាក់នេះ គាស់កំណប់ទ្រព្យឡើងហើយ គប្បីចាប់យើង ហើយបៀតបៀន បើដូច្នោះ យើងគប្បីធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិតចុះ” គ្រានោះសេដ្ឋីបុត្រនោះស្លៀកសំពត់ចាស់មួយផ្ទាំង ដើរសួរថា “មាននរណាត្រូវការអ្នកបម្រើឬទេ” (ទៅ) ដល់ភូមិដែលជាលំនៅនៃពួកកម្មករ ។ ខណៈនោះ

ពួកអ្នកមានឃើញសេដ្ឋីបុត្រនោះហើយ ពោលថា "ប្រសិនបើឯងនឹងធ្វើការ-ងាររបស់ពួកយើងបានត្រឹមតែមួយសោត ពួកយើងនឹងឲ្យថ្លៃឈ្នួលសម្រាប់ទិញភត្ត" ។

សេដ្ឋីបុត្រនោះសួរថា "តើពួកលោកនឹងឲ្យខ្ញុំធ្វើការងារអ្វី" ពួកអ្នកជួលប្រាប់ថា "ការងារ គឺ ការដាស់ ប្រសិនបើឯងអាចធ្វើបានសោត ឯងចូរក្រោកឡើងពីព្រលឹម ដើរដាស់ពួកកម្មករថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរក្រោកឡើង ចូរត្រៀមរទេះទាំងឡាយ ចូរទឹមគោទាំងឡាយ វេលានេះជាវេលាទៅរកស្មៅសំរាប់សត្វពាហនៈទាំងឡាយ មានដំរី និងសេះជាដើម ដើម្បីត្រូវការស៊ីស្មៅ ម្នាលនាងទាំងឡាយ សូម្បីនាងទាំងឡាយចូរក្រោកឡើង ចូរចម្អិនបបរ និងភត្ត" គេទទួលថា "បាន" ។ លំដាប់នោះពួកអ្នកជួលបានឲ្យផ្ទះមួយខ្នងដល់សេដ្ឋីបុត្រនោះ ដើម្បីប្រយោជន៍ដល់ការនៅក្នុងទីជិត ។ សេដ្ឋីបុត្របានធ្វើការងារនោះរាល់ៗ ថ្ងៃ ។

ថ្ងៃមួយ ព្រះបាទពិម្ពិសារ ទ្រង់បានព្រះសណ្ដាប់សំឡេងរបស់គេហើយ ។ ក៏ស្ដេចជាអ្នកទ្រង់ចេះស្ដាប់សំឡេងរបស់សត្វទាំងឡាយ ព្រោះហេតុនោះ ទើបត្រាស់ថា "នោះជាសំឡេងរបស់បុគ្គលមានទ្រព្យច្រើន" ។

គ្រានោះ ស្រីស្នំរបស់ព្រះរាជាម្នាក់ ដែលឈរគាល់ព្រះរាជានៅក្នុងទីជិត គិតថា "ធម្មតាព្រះរាជាមិនត្រាស់នូវពាក្យផ្ដេសផ្ដាស់ យើងគួរដឹងនូវហេតុនេះឲ្យជាក់ច្បាស់" ។ ទើបបញ្ជូនបុរសម្នាក់ទៅ (ស៊ើប) ដោយពាក្យថា "នែ៎អ្នក អ្នកចូរទៅស៊ើបឲ្យដឹងច្បាស់នូវរឿងរបស់បុរសនោះ (ហើយត្រឡប់មកប្រាប់យើង)" ។ បុរសនោះទៅយ៉ាងប្រញាប់ ជួបកុម្ភឃោសកៈនោះហើយក៏ត្រឡប់មកប្រាប់ថា "នុ៎ះជាបុរសទុគ៌តម្នាក់ ដែលធ្វើការស៊ីឈ្នួលជនទាំងឡាយដើម្បីចិញ្ចឹមជីវិត" ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យរបស់បុរសនោះហើយ ក៏ទ្រង់តុណ្ហីភាព (ស្ងៀម) ក្នុងថ្ងៃទី ២ ក្ដី ទី ៣ ក្ដី លុះទ្រង់ព្រះសណ្ដាប់សំឡេងរបស់កុម្ភឃោសកៈនោះហើយ ក៏ទ្រង់ត្រាស់យ៉ាងនោះទៀត ។ ស្រីស្នំនោះ ក៏គិតយ៉ាងនោះទៀត បញ្ជូន (បុរស) ទៅច្រើនដង កាលបុរសនោះប្រាប់ថា "ជាមនុស្សទុគ៌ត" ក៏គិតថា "ព្រះរាជាសូម្បីទ្រង់ព្រះសណ្ដាប់នូវពាក្យថា "បុរសនោះជាមនុស្សទុគ៌ត" ក៏ទ្រង់មិនជឿ ហើយទ្រង់ត្រាស់ពាក្យដដែលៗ ទៀតថា "នុ៎ះជាសំឡេងរបស់អ្នកមានទ្រព្យច្រើន" ក្នុងសេចក្ដីនេះប្រាកដជាមានហេតុ យើងគួរតែស្គាល់បុរសនោះឲ្យបានដឹងតាមសេចក្ដីពិត" ។ ស្រីស្នំនោះ ក៏ក្រាបទូលព្រះរាជាថា "បពិត្រ

ព្រះសម្មតិទេព នាងខ្ញុំម្ចាស់ កាលបានទ្រព្យមួយពាន់នឹងនាំធីតាទៅ (ធ្វើនូវឧបាយ) ឲ្យទ្រព្យនោះចូលមកកាន់រាជត្រកូលឲ្យទាល់តែបាន" ។ ព្រះរាជាត្រាស់បង្គាប់ឲ្យព្រះរាជទានទ្រព្យមួយពាន់ដល់នាងស្នំ ។ នាងទទួលព្រះរាជ-ទ្រព្យនោះហើយ ឲ្យធីតាស្លៀកសំពត់ចាស់មួយផ្ទាំង ធ្វើដំណើរចេញចាកព្រះរាជវាំងជាមួយនឹងធីតានោះ ធ្វើអាការដូចជាអ្នកដើរផ្លូវ ទៅកាន់ភូមិដែលជាទីនៅរបស់ពួកអ្នកមាន បានចូលទៅកាន់ផ្ទះមួយ ហើយនិយាយថា "ម្នាលនាងដ៏ចម្រើន ខ្ញុំទាំងពីរនាក់ធ្វើដំណើរមកអំពីទីឆ្ងាយ (ហត់នឿយខ្លាំងណាស់) សូមសម្រាកនៅក្នុងផ្ទះនេះ ២-៣ ថ្ងៃ បានដែរឬទេ" ។ ស្ត្រីដែលជាម្ចាស់ផ្ទះពោលថា "ម្នាលនាងដ៏ចម្រើន មនុស្សដែលនៅផ្ទះនេះមានច្រើននាក់ណាស់ នាងមិនអាចសម្រាកក្នុងផ្ទះនេះបានទេ ផ្ទះរបស់នាយកុម្ភ-ឃោសកៈនោះទំនេរ នាងអញ្ជើញទៅ (សុំសម្រាក) ក្នុងផ្ទះនោះចុះ" ។ នាងស្នំទៅកាន់ផ្ទះរបស់កុម្ភឃោសកៈនោះហើយ ពោលថា "នែ៎អ្នកដ៏ចម្រើន យើងខ្ញុំទាំងពីរនាក់ជាអ្នកធ្វើដំណើរផ្លូវឆ្ងាយ នឹង (សុំសម្រាក) នៅក្នុងផ្ទះនេះមួយថ្ងៃ ឬក៏ពីរថ្ងៃ" សូម្បីត្រូវកុម្ភឃោសកៈហាមឃាត់ហើយច្រើនដងក៏ដោយ ក៏នៅតែនិយាយអង្វរថា "នែ៎អ្នកដ៏ចម្រើន ខ្ញុំទាំងពីរនាក់នឹងសូម

សម្រាកនៅក្នុងផ្ទះនេះមួយថ្ងៃ ព្រឹកឡើងនឹងទៅហើយ” តែមិនប្រាថ្នានឹងចេញទៅទេ ។ នាងសម្រាកនៅក្នុងផ្ទះរបស់កុម្ភឃោសកៈនោះឯង លុះព្រឹកឡើង ក្នុងវេលាដែលកុម្ភឃោសកៈនោះចេញទៅព្រៃ ក៏និយាយថា “នែ៎អ្នកដ៏ចម្រើន សូមអ្នកចូរប្រគល់តម្លៃអាហារសម្រាប់អ្នកទុក ហើយសឹមទៅចុះ ខ្ញុំនឹង (ចាត់ចែង) ដាំស្លទុកដើម្បីអ្នក” ។ កាលកុម្ភឃោសកៈពោលថា “កុំអីនាង ខ្ញុំនឹងដាំស្លស៊ីខ្លួនឯងក៏បាន” ក៏និយាយអង្វររឿយៗ រហូតទាល់តែបានសម្រេច ធ្វើទ្រព្យដែលកុម្ភឃោសកៈឲ្យនោះ ឲ្យជាទ្រព្យដែលខ្លួនបានទទួលទុកហើយប៉ុណ្ណោះ ប្រើគេឲ្យនាំភោជន និងវត្ថុផ្សេងៗ មានអង្ករដ៏បរិសុទ្ធជាដើមមកអំពីផ្សារ ដាំបាយឲ្យឆ្ងាញ់ និងធ្វើម្ហូបអាហារពីរបីមុខដែលមានរសជាតិឆ្ងាញ់ ដូចការដាំស្លក្នុងរាជត្រកូល ឲ្យដល់កុម្ភឃោសកៈដែលមកអំពីព្រៃ ។ លុះដឹងថា កុម្ភឃោសកៈបរិភោគហើយជាអ្នកមានចិត្តរីករាយ ក៏និយាយថា “នែ៎អ្នកដ៏ចម្រើន ខ្ញុំទាំងពីរនាក់ជាអ្នកហត់នឿយ សូមសម្រាកនៅផ្ទះនេះពីរបីថ្ងៃទៀតចុះ” កុម្ភឃោសកៈក៏ទទួលថា “បាន” ។ គ្រានោះ នាងក៏ចំអិនអាហារយ៉ាងឆ្ងាញ់ពិសា ទាំងក្នុងវេលាល្ងាច ទាំងក្នុងវេលាព្រឹក ឲ្យដល់កុម្ភឃោសកៈ ។ លុះដឹងថា គេមានចិត្តរីករាយហើយ

ក៏អង្វរ (ទៀត) ថា “នែ៎អ្នកដ៏ចម្រើន យើងទាំងពីរនាក់សុំនៅក្នុងផ្ទះនេះពីរបីថ្ងៃទៀត” ដូច្នេះ ហើយក៏នៅក្នុងផ្ទះនោះទៅ កាលនៅក្នុងផ្ទះនោះ ក៏យកសស្ត្រាដ៏មុតកាត់ត្រែខាងក្រោមនៃមេត្រែរបស់គេក្នុងទីនោះៗ ។ កាលគេមកវិញ គ្រាន់តែអង្គុយចុះប៉ុណ្ណោះ ត្រែក៏ធ្លាក់ចុះទៅខាងក្រោម ។ គេបានពោលថា “ហេតុអ្វី ទើបត្រែនេះបាក់យ៉ាងនេះ” ។

នាងស្នំ. នាយ ខ្ញុំមិនអាចហាមពួកក្មេងៗ បាន ដែលមកប្រជុំគ្នាលេងលើត្រែនេះ ។

កុម្ភឃោសកៈ. ម្នាលនាង ព្រោះអាស្រ័យអ្នកទាំងពីរ ទុក្ខនេះកើតឡើងដល់ខ្ញុំ ក្នុងកាលមុន ខ្ញុំទៅទីណាៗ ក៏បិទទ្វារហើយទើបទៅ ។

នាងស្នំ. ឲ្យខ្ញុំធ្វើដូចម្ដេច បើខ្ញុំមិនអាចហាមឃាត់បាន ។

នាងស្នំនោះកាត់ (ជើងត្រែ) ដូចលើកមុនទៀត អស់ពីរបីថ្ងៃ សូម្បីត្រូវកុម្ភឃោសកៈនោះលើកទោស ហើយតិះដៀលក៏ដោយ ក៏នៅតែពោល (ដោះខ្លួន) ដដែលទៀត ហើយកាត់ខ្សែដ៏សេសទាំងឡាយទៀត បន្សល់ទុកតែខ្សែពីរសរសៃប៉ុណ្ណោះ ។ ថ្ងៃនោះ កាលកុម្ភឃោសកៈគ្រាន់អង្គុយចុះប៉ុណ្ណោះ (ត្រែ) ទាំងអស់ក៏ធ្លាក់ចុះលើផែនដី ។ សិរសា (របស់កុម្ភឃោ-

សកៈ) បាន (ធ្លាក់ចុះ) ទៅជាមួយនឹងជន្ទន់ទាំងឡាយ កុម្ភឃោសកៈនោះក្រោកឡើងហើយ ក៏បាននិយាយថា "ខ្ញុំនឹងធ្វើដូចម្តេច? ឥឡូវនេះ ខ្ញុំនឹងទៅទីណា? ខ្ញុំជាអ្នកត្រូវពួកនាងធ្វើមិនឲ្យជាម្ចាស់នៃគ្រែដេកហើយ" ។ នាងស្នំលួងលោមថា "នែ៎អ្នកដ៏ចម្រើន នឹងធ្វើដូចម្តេចទៅ បើខ្ញុំមិនអាចហាមឃាត់ពួកក្មេងៗ ដែលវាមកលេងលើគ្រែយ៉ាងនេះបាន ណ្ហើយចុះ អ្នកកុំគិតឡើយ អ្នកនឹងទៅណាបានឥឡូវនេះ" ដូច្នេះហើយ ហៅធីតាប្រាប់ថា "នែ៎កូន កូនឯងចូរធ្វើឱកាសសម្រាប់ ជាទីដេកដល់បងប្រុសរបស់កូនឯងផងចុះ" ។ ធីតានោះដេកក្នុងចំណែកម្ខាងហើយ ពោលថា "បពិត្រអ្នកជាម្ចាស់ សូមមកដេកទីនេះចុះ" សូម្បីនាងស្នំក៏ពោលនឹងកុម្ភឃោសកៈនោះថា "នែ៎អ្នកដ៏ចម្រើន សូមអ្នកទៅដេកជាមួយនឹងប្អូនស្រីចុះ" ។ កុម្ភឃោសកៈដេកលើគ្រែមួយជាមួយនឹងធីតារបស់នាងស្នំនោះ បានធ្វើនូវសន្ថវៈក្នុងថ្ងៃនោះឯង ។ នាងកុមារិកានោះទួញយំ ។ ក្នុងពេលនោះ មាតារបស់នាងក៏សួរនាងថា "នែ៎កូនស្រី ហេតុដូចម្តេច បានជាកូនឯងយំ" ។ ធីតាពោលថា "កម្មឈ្មោះនេះកើតឡើងហើយ ម៉ែ" ។ មាតានិយាយថា "ណ្ហើយចុះកូន យើងអាចធ្វើអ្វីបាន កាលកូនបានបុរសនេះជាស្វាមីក្តី កុម្ភឃោសកៈ

នេះបានស្ត្រីអ្នកបម្រើម្នាក់ក្តី ក៏សមគួរហើយ និងព្រមទទួលកុម្ភឃោសកៈ នោះជាកូនប្រសារបស់ខ្លួន ។ គេទាំងពីរនាក់ក៏នៅរួមរស់ជាមួយគ្នា ។

ដោយកាលកន្លងទៅ ២-៣ ថ្ងៃ នាងស្នំនោះក៏បញ្ជូនដំណឹងទៅ (ក្រាបទូល) ព្រះរាជាថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រាស់បង្គាប់ឲ្យធ្វើការឃោសនាថា "មហាជន ចូរចាត់ចែងលេងមហោស្រពក្នុងតំបន់នៃពួកអភិជន ក៏បុគ្គលណាមិនចាត់ចែងមហោស្រពក្នុងផ្ទះ ត្រូវពិន័យប្រមាណប៉ុណ្ណេះដល់បុគ្គលនោះ ។ ព្រះរាជាក៏ត្រាស់បង្គាប់ឲ្យធ្វើយ៉ាងនោះ ។ គ្រានោះ ម្តាយក្មេកនិយាយនឹងកុម្ភឃោសកៈថា "នែ៎អ្នកដ៏ចម្រើន យើងចាំបាច់ត្រូវចាត់ចែងមហោស្រពក្នុងទីដែលពួកកម្មកររស់នៅ តាមព្រះរាជបញ្ជា យើងនឹងធ្វើដូចម្តេច" ។

កុម្ភឃោសកៈ. ម៉ែ ខ្ញុំនេះសូម្បីតែធ្វើការបម្រើគេ ក៏ស្ទើរតែមិនអាចរស់បានផង នឹងចាត់ចែងធ្វើមហោស្រពបានដូចម្តេចទៅ ។

ម្តាយក្មេក. ម្នាលកូន ធម្មតាបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះទាំងឡាយ ត្រូវតែទទួលយកបំណុលនេះ ព្រះរាជាទ្រង់ចេញព្រះរាជបញ្ជាហើយ មិនធ្វើតាមមិនបាន យើងអាចរួចផុតចាកបំណុលបាន ដោយឧបាយណាមួយ

ណ្ណីយចុះ កូនឯងចូរទៅនាំយកកហាបណៈ ១-២ កហាបណៈអំពីទីណាៗ ក៏បាន ។ គេទាស់ចិត្តបណ្ដើរ ទៅនាំយកកហាបណៈ ១ កហាបណៈ មក អំពីទីកប់កំណប់ទ្រព្យ ៤០ កោដិនោះ ហុចឲ្យនាងស្នំ នាងស្នំក៏បញ្ជូនមួយ កហាបណៈនោះ ទៅថ្វាយព្រះរាជា ហើយ (ចាត់ចែង) ធ្វើមហោស្រពដោយ កហាបណៈរបស់ខ្លួន ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនដំណឹងទៅ ថ្វាយព្រះរាជាដូចលើកមុនទៀត ។ ព្រះរាជាក៏ទ្រង់បញ្ជារាជបុរសឲ្យដើរ ឃោសនាទៀតថា "មហាជនចូរចាត់ចែងធ្វើមហោស្រព កាលបុគ្គលណា មិនធ្វើ មានពិន័យប្រមាណប៉ុណ្ណេះ" កុម្ភឃោសកៈនោះ ត្រូវម្ដាយក្មេកពោល បន្ទិតបន្ទំដូចលើកមុននោះឯង ទើបទៅយកកហាបណៈមក ១ កហាបណៈ ទៀត នាងស្នំនោះក៏បញ្ជូនកហាបណៈទាំងនោះទៅ (ថ្វាយ) ព្រះរាជាទៀត ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនដំណឹងទៅ (ថ្វាយ) ព្រះរាជាទៀត ថា "ឥឡូវនេះ សូមព្រះអង្គទ្រង់បញ្ជូនរាជបុរសមក បង្គាប់ឲ្យហៅកុម្ភឃោ-សកៈនេះទៅ (គាល់)" ។ ព្រះរាជាក៏ទ្រង់បញ្ជូនរាជបុរសទៅ ។ ពួករាជ បុរសទៅកាន់លំនៅឋានដែលពួកកម្មករនោះនៅ ហើយសួរកថា "អ្នកណា ឈ្មោះកុម្ភឃោសកៈ" បានជួបកុម្ភឃោសកៈហើយប្រាប់ថា "អ្នកដ៏ចម្រើន

ព្រះរាជាមានរាជបញ្ជាឲ្យអ្នកចូលគាល់" ។ កុម្ភឃោសកៈក៏ភ័យតក់ស្លុត ពោលពាក្យដោះខ្លួនជាដើមថា "ព្រះរាជាទ្រង់មិនស្គាល់ខ្ញុំទេ" ហើយមិនប្រាថ្នានឹងចូលទៅគាល់ ។ ពេលនោះ ពួករាជបុរសក៏ចាប់គេត្រង់អវយវៈទាំងឡាយមានដៃជាដើម ទាញមកដោយកម្លាំងរបស់ខ្លួន ។ ស្ត្រីដែលជាម្តាយក្មេករបស់កុម្ភឃោសកៈនោះ ឃើញបុរសទាំងនោះហើយ ក៏ធ្វើដូចជាគំរាមថា "នែ៎បុគ្គលប្រជៀក្រ ពួកអ្នកមិនគួរមកចាប់កូនប្រសាររបស់អញត្រង់អវយវៈទាំងឡាយ មានដៃជាដើមទេ" ហើយក៏លួងលោមថា "នែ៎កូន កូនឯងកុំខ្លាចឡើយ មាតាចូលគាល់ព្រះរាជាហើយ នឹងក្រាបទូលឲ្យព្រះរាជាកាត់ដៃរបស់ពួកអ្នកដែលចាប់កូនមានដៃជាដើម" ហើយក៏នាំបុត្រីទៅមុនដល់ព្រះរាជដំណាក់ហើយផ្លាស់ភេទ ប្រដាប់តុបតែងនូវគ្រឿងអលង្ការទាំងពួង បានឈរគាល់ព្រះរាជានៅក្នុងទីដ៏សមគួរមួយ ។ ឯកុម្ភឃោសកៈត្រូវពួករាជបុរសចាប់មក (ថ្វាយ) ព្រះរាជាដែរ ។ គ្រានោះ ព្រះរាជាទ្រង់ត្រាស់ទៅកាន់កុម្ភឃោសកៈដែលមកថ្វាយបង្គំ ហើយឈរគាល់នោះថា "អ្នកនេះឬ? ឈ្មោះកុម្ភឃោសកៈ" ។

កុម្ភឃោសកៈ. ព្រះករុណាថ្លៃវិសេស ។

ព្រះរាជា. ព្រោះហេតុអ្វី ទើបអ្នកបិទបាំងទ្រព្យជាច្រើនទុក? ។

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ទូលបង្គំនឹងមានមកអំពីទីណា? ទូលព្រះបង្គំជាអ្នកធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិត ។

ព្រះរាជា. អ្នកកុំធ្វើយ៉ាងនោះឡើយ អ្នកកុហកយើងធ្វើអ្វី? ។

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនបានកុហកព្រះអង្គទេ ទ្រព្យរបស់ទូលព្រះបង្គំមិនមានពិតមែន ។

គ្រានោះ ព្រះរាជាទ្រង់បង្ហាញកហាបណៈទាំងនោះដល់កុម្ភឃោសកៈ ហើយត្រាស់សួរថា "កហាបណៈទាំងនេះ ជារបស់នរណា?" ។ គេចាំ (កហាបណៈ) បាន ក៏គិតថា "ឱអញ វិនាសហើយ ហេតុអ្វីកហាបណៈទាំងនេះ ទើបធ្លាក់មកដល់ព្រះហស្តរបស់ព្រះរាជាទៅវិញ"? ក្រឡេកមើលខាងនោះខាងនេះ ក៏ឃើញស្ត្រីទាំងពីរនោះ ប្រដាប់តាក់តែងឈរគាល់ព្រះរាជានៅក្បែរទ្វារបន្ទប់ ទើបគិតថា "កម្មនេះធ្ងន់ណាស់ ប្រហែលជាព្រះរាជាចាត់ស្ត្រីទាំងនេះ (ទៅបោកបញ្ឆោតយើងទេដឹង)" ។ ខណៈនោះ ព្រះរាជាត្រាស់ទៅកាន់កុម្ភឃោសកៈថា "ម្នាលអ្នកដ៏ចម្រើន អ្នកឯងនិយាយទៅចុះ ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ" ។

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ព្រោះទីពឹងរបស់ទូលបង្គំមិន
មាន ។

ព្រះរាជា. មនុស្សដូចជាយើង មិនគួរជាទីពឹងរបស់អ្នកទេឬ ?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ប្រសិនបើព្រះអង្គទ្រង់ជាទីពឹង
របស់ខ្ញុំព្រះអង្គ ក៏ជាព្រះករុណាដ៏ក្រៃលែងណាស់ ។

ព្រះរាជា. អ្នកដ៏ចម្រើន "បាន" ទ្រព្យរបស់អ្នកមានចំនួនប៉ុន្មាន?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ខ្ញុំព្រះអង្គមាន ៤០
កោដិ ។

ព្រះរាជា. បានអ្វីយកទៅជញ្ជូន ទើបគួរ? ។

កុម្ភឃោសកៈ. រទេះទាំងឡាយ ព្រះអង្គ ។

ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យចាត់ចែងរទេះទាំងឡាយ ច្រើនរយរទេះ
ហើយបញ្ជូនឲ្យទៅនាំទ្រព្យនោះមក ត្រាស់ឲ្យធ្វើជាគំនរទុកនៅត្រង់ព្រះលាន
ហ្លួង ហើយត្រាស់ឲ្យអ្នកក្រុងរាជគ្រឹះមកប្រជុំគ្នា ទ្រង់ត្រាស់សួរថា "ក្នុង
ព្រះនគរនេះ មាននរណាមានទ្រព្យប្រមាណប៉ុណ្ណោះដែរឬទេ" ? កាលអ្នក
ក្រុងក្រាបទូលថា "ព្រះករុណាថ្លៃវិសេស មិនមានទេ ទ្រង់ត្រាស់សួរទៀត

ថា បើដូច្នោះ យើងគួរធ្វើយ៉ាងណាដល់កុម្ភឃោសកៈ កាលពួកមហាជននោះក្រាបទូលថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់តែងតាំងកុម្ភ-ឃោសកៈនោះទុកក្នុងតំណែងសេដ្ឋីទៅ សមគួរហើយ" ទើបទ្រង់តែងតាំងកុម្ភឃោសកៈនោះ ទុកក្នុងតំណែងសេដ្ឋីដោយសក្ការៈដ៏ធំ ព្រះរាជទានបុត្រីរបស់ស្រីស្នំនោះដល់កុម្ភឃោសកៈ ហើយស្តេចទៅកាន់សំណាក់ព្រះសាស្តាព្រមទាំងកុម្ភឃោសកសេដ្ឋីនោះ ថ្វាយបង្គំ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទតមើលបុរសនេះចុះ ដែលឈ្មោះថា អ្នកមានបញ្ញាជាគ្រឿងទ្រទ្រង់បែបនេះ មិនមានបុរសសូម្បីមានទ្រព្យសម្បត្តិដល់ ៤០ កោដិ ក៏មិនធ្វើអាការឆ្មើងឆ្មៃ ឬលើកតម្កើងខ្លួន មើលងាយអ្នកដទៃ (ធ្វើ) ដូចជាមនុស្សកំព្រា ស្លៀកសំពត់ចាស់ៗ ធ្វើការបម្រើគេចិញ្ចឹមជីវិត ខ្ញុំព្រះអង្គដឹងបានដោយឧបាយនេះ លុះដឹងហើយ ទើបឲ្យហៅមកសាកសួរដេញដោលឲ្យសារភាពថា ខ្លួនជាអ្នកមានទ្រព្យហើយ ឲ្យដញ្ជូនទ្រព្យនោះមក និងបានតែងតាំងទុកក្នុងតំណែងជាសេដ្ឋី (មិនមែនតែប៉ុណ្ណោះ) ខ្ញុំព្រះអង្គថែមទាំងបានព្រះរាជទានធីតាឲ្យដល់គេទៀតផង បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមានបញ្ញាជាគ្រឿងទ្រទ្រង់បែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ ។

ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ទ្រង់ត្រាស់ថា "ថ្វាយព្រះពរមហាបពិត្រ ជីវិតរបស់បុគ្គលអ្នករស់នៅយ៉ាងនោះ ឈ្មោះថា រស់នៅប្រកបដោយធម៌ ក៏កម្មមានចោរកម្មជាដើម រមែងបៀតបៀន (អ្នកធ្វើ) ទាំងក្នុងលោកនេះផង ទាំងក្នុងលោកខាងមុខផង ឈ្មោះថា សេចក្ដីសុខដែលមានកម្មនោះជាហេតុ ក៏មិនមែន ក៏បុរសធ្វើការបម្រើគេក្ដី ធ្វើស្រែក្ដី ចិញ្ចឹមជីវិតក្នុងកាលវិនាសនូវទ្រព្យនោះឯង ឈ្មោះថា ជីវិតប្រកបដោយធម៌ ព្រោះថា ភាពជាធំ (យស) រមែងចម្រើនឡើងតែម្យ៉ាងដល់បុគ្គលអ្នកដល់ព្រមដោយសេចក្ដីព្យាយាម បរិបូណ៌ដោយសតិ មានការងារដ៏បរិសុទ្ធដោយទ្វារទាំងឡាយ មានកាយទ្វារ និងវចីទ្វារជាដើម មានប្រក្រតីពិចារណាដោយបញ្ញាហើយទើបធ្វើ អ្នកដែលសង្រួមនូវទ្វារទាំងឡាយ មានកាយទ្វារជាដើម ចិញ្ចឹមជីវិតដោយធម៌ តាំងនៅក្នុងសេចក្ដីមិនប្រមាទបែបនេះឯង" ។ ដូច្នេះទើបត្រាស់ព្រះគាថានេះថា ៖

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ
សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ

យសតែងចម្រើនកុះករ ដល់បុគ្គលអ្នកមានសេចក្ដីប្រឹងប្រែង

មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឧដ្ឋានវតោ** (អ្នកមានសេចក្តីព្យាយាម) គឺ អ្នកមានសេចក្តីព្យាយាមជាហេតុដាស់តឿន ។ បទថា **សតីមតោ** (មានសតិ) គឺ សម្បូណ៌ដោយសតិ ។ បទថា **សុចិកម្មស្ស** (មានការងារស្អាត) គឺ ប្រកបដោយការងារទាំងឡាយ មានការងារតាមផ្លូវកាយជាដើម ប្រាសចាកទោស គឺ មិនមានការខុសឆ្គាំឆ្គង ។ បទថា **និសម្មការិនោ** (មានប្រក្រតីពិចារណាហើយទើបធ្វើ) បានដល់ ពិចារណា គឺ ពិចារណាយ៉ាងនេះថា "ប្រសិនបើផលយ៉ាងនេះមាន យើងនឹងធ្វើយ៉ាងនេះ" ឬថា "កាលការងារនេះដែលយើងធ្វើហើយយ៉ាងនេះ ផលបែបនេះនឹងមាន" ដូច្នេះ ទើបធ្វើនូវការងារទាំងពួង ដូចគ្រូពេទ្យត្រួតពិនិត្យដើមហេតុ (របស់រោគ) ហើយទើបព្យាបាលរោគ ដូច្នោះ ។ បទថា **សញ្ញតស្ស** (សង្រួមហើយ) បានដល់ សង្រួមហើយក្នុងទ្វារទាំងឡាយ មានកាយជាដើម ។ បទថា **ធម្ម-**

*ជីវិនោ (ចិញ្ចឹមជីវិតប្រកបដោយធម៌) គឺ បើជាគ្រហស្ថ វៀរចាកនូវអំពើ កោងទាំងឡាយ មានអំពើកោងដោយក្អែកជញ្ជីងជាដើម ចិញ្ចឹមជីវិតដោយ ការងារដ៏ប្រពៃទាំងឡាយ មានធ្វើស្រែ និងចិញ្ចឹមគោជាដើម បើជាបព្វជិត វៀរចាកអនេសនាកម្មទាំងឡាយ មានវេជ្ជកម្ម និងទូតកម្មជាដើម ចិញ្ចឹម ជីវិតដោយភិក្ខាចារដ៏ប្រពៃតាមធម៌ ។ បទថា* ***អប្បមត្តស្ស (មិនប្រមាទ)*** *គឺ មិនប្រាសចាកសតិ ។ បទថា* ***យសោភិវឌ្ឍតិ (យសរមែងចម្រើន)*** *សេចក្តីថា យសពោលគឺ ភាពជាធំ ការមានភោគសម្បត្តិ និងការរាប់អាន និងពោលគឺ ការមានកេរ្តិ៍ឈ្មោះ និងការសរសើររមែងចម្រើន ។*

*ក្នុងកាលចប់ព្រះគាថា កុម្ភឃោសកៈតាំងនៅក្នុងសោតាបត្តិផល ។ ជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ទេសនាបានសម្រេចជាប្រយោជន៍ហើយដល់មហាជនដូច្នេះឯង ។*

ចប់ រឿងកុម្ភឃោសកៈ

# ៣. រឿងព្រះចូឡបន្ថកត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ ចូឡបន្ថកៈ ត្រាស់ព្រះធម្មទេសនានេះថា **ឧដ្ឋានេនប្បមាទេន** (... ដោយសេចក្តីប្រឹងប្រែង ដោយសេចក្តីមិនប្រមាទ) ដូច្នេះ ជាដើម ។*

*ដូចបានស្តាប់មក ធីតានៃត្រកូលរបស់ធនសេដ្ឋីក្នុងក្រុងរាជគ្រឹះ ក្នុងវេលាខ្លួនចម្រើនវ័យឡើង មាតាបិតារក្សាទុកយ៉ាងមាំមួនលើប្រាសាទជាន់ទី ៧ (ប៉ុន្តែនាង) ជាស្ត្រីឡេះឡោះក្នុងបុរស ព្រោះភាពជាអ្នកស្រវឹងដោយសេចក្តីស្រវឹងក្នុងភាពជាស្រីក្រមុំ ទើបធ្វើសន្ថវៈនឹងទាសៈរបស់ខ្លួន ព្រោះខ្លាចថា (អ្នកដទៃនឹងគប្បីដឹងអំពើនេះរបស់ខ្លួន) ទើបនិយាយនឹងបុរសនោះយ៉ាងនេះថា "យើងទាំងពីរមិនអាចនៅក្នុងទីនេះបានទេ ប្រសិនបើមាតាបិតារបស់ខ្ញុំដឹងនូវរឿងនេះ គាត់នឹងកាប់ចិញ្ច្រាំយើងឲ្យជាកំណាត់តូចកំណាត់ធំ យើងនឹងទៅកាន់ទីកន្លែងផ្សេង ហើយរស់នៅ" ទាំងពីរនាក់នោះ កាន់យកទ្រព្យដែលជាសារៈ ដែលគប្បីនាំយកទៅបានដោយដៃ ចេញទៅតាមទ្វារខាងជើង ហើយបបួលគ្នាថា "យើងទាំងពីរនឹងត្រូវទៅនៅក្នុងទីណាមួយដែលជនដទៃមិនស្គាល់" ដូច្នេះ ទាំងពីរនាក់ក៏បានធ្វើដំណើរចេញទៅ ។*

កាលគេទាំងពីរនាក់នៅក្នុងទីកន្លែងមួយ នាងតាំងគភ៌ហើយ ព្រោះអាស្រ័យការនៅរួមគ្នា កគ៌ចាស់ហើយ ក៏ប្រឹក្សានឹងស្វាមីនោះថា "គភ៌របស់ខ្ញុំចាស់ហើយ ធម្មតាការប្រសូតិបុត្រក្នុងទីដែលប្រាសចាកញាតិ និងផៅ-ពង្សទាំងឡាយ រមែងជាហេតុនាំមកនូវសេចក្តីទុក្ខឲ្យដល់យើងទាំងពីរ យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូលចុះ" បុរសជាស្វាមីនោះពោលបណ្តោះបណ្តែថា "ថ្ងៃនេះកុំអាលទៅអី ចាំថ្ងៃស្អែកសិនសឹមទៅ" ញុំាងថ្ងៃទាំងឡាយឲ្យកន្លងហួសទៅ ព្រោះការខ្លាចថា "ប្រសិនបើយើងទៅទីនោះ ជីវិតរបស់យើងនឹងមិនមាន" ស្ត្រីដែលជាប្រពន្ធគិតថា "ស្វាមីអញនេះ ជាមនុស្សល្ងង់ខ្លៅមិនហ៊ានទៅព្រោះខ្លួនជាអ្នកមានទោសធំ ធម្មតា មាតាបិតារមែងមានការអនុគ្រោះតែម្យ៉ាងប៉ុណ្ណោះ បុរសដែលជាស្វាមីរបស់អញនេះទៅ ឬមិនទៅក៏ដោយ យើងនឹងទៅ" ។ លុះស្វាមីរបស់ខ្លួនចេញអំពីផ្ទះហើយ នាងក៏ទុកដាក់នូវគ្រឿងបរិក្ខារក្នុងផ្ទះ ប្រាប់អ្នកជិតខាងថា ខ្ញុំទៅកាន់ផ្ទះនៃត្រកូលរបស់ខ្ញុំហើយ ហើយក៏ធ្វើដំណើរចេញទៅ ។ ចំណែកបុរសដែលជាស្វាមី "ត្រឡប់" មកផ្ទះ មិនឃើញភរិយា ក៏សួរអ្នកជិតខាងបានដឹងថា ទៅកាន់ផ្ទះនៃត្រកូល ក៏ប្រញាប់តាមទៅទាន់ក្នុងចន្លោះផ្លូវ ។ សូម្បីភរិយារបស់បុរស

នោះ ក៏បានប្រសូតបុត្រក្នុងចន្លោះផ្លូវនោះឯង ។ បុរសដែលជាស្វាមីសួរភរិយាថា "ម្នាលនាងដ៏ចម្រើន នេះគឺជាអ្វី?" ។

ភរិយា. បង កូនប្រុសមួយ ប្រសូតហើយ ។

ស្វាមី. ឥឡូវនេះ យើងធ្វើដូចម្ដេច? ។

ទាំងពីរនាក់ប្ដីប្រពន្ធគិតឃើញដូចគ្នាថា "យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ដល់កម្មណា កម្មនោះសម្រេចហើយក្នុងចន្លោះផ្លូវ យើងនឹងទៅកាន់ទីនោះធ្វើអ្វីទៀត? ត្រឡប់ទៅវិញចុះ" ដូច្នេះហើយក៏នាំគ្នាត្រឡប់វិញ ។ ទាំងពីរនាក់ប្ដីប្រពន្ធបានដាក់ឈ្មោះទារកនោះឯងថា "**បន្ថក:**" ព្រោះកើតក្នុងផ្លូវ ។ ក្នុងសម័យថ្ងៃក្រោយមក មិនយូរប៉ុន្មានសេដ្ឋីធីតាក៏តាំងគភ៌ទៀត ។ ព្រឹត្តិការណ៍ទាំងពួង គប្បីឲ្យពិស្ដារតាមន័យដូចលើកមុនចុះ ។ ព្រោះក្មេងដែលកើតខាងក្រោយនោះ ក៏កើតក្នុងផ្លូវដែរទើបមាតាបិតាដាក់ឈ្មោះបុត្រដែលកើតមុនថា "**មហាបន្ថក:**" ដាក់ឈ្មោះបុត្រដែលកើតខាងក្រោយថា "**ចុល្លបន្ថក:**" ។ សូម្បីស្វាមីភរិយាទាំងពីរនាក់នោះ ក៏នាំក្មេងទាំងពីរទៅកាន់លំនៅរបស់ខ្លួនវិញ ។

កាលស្វាមីភរិយាទាំងពីរនាក់នៅក្នុងទីនោះ ទារកឈ្មោះមហាបន្ថក:

បានឮក្មេងៗ ដទៃហៅ (អ្នកនេះអ្នកនោះ) ថា "អ៊ំ ពូ" និងថា "តា យាយ" ទើបសួរមាតាថា "ម៉ែ ក្មេងដទៃៗ ហៅ (អ្នកនោះ) ថា តា ហៅ (អ្នកនេះ) ថា យាយ ពួកញាតិរបស់យើងមិនមានខ្លះទេឬ?" ។

មាតា. អើកូនសម្លាញ់ ជនទាំងឡាយដែលជាញាតិរបស់យើងក្នុងទីនេះមិនមាន ប៉ុន្តែតារបស់ពួកកូនឈ្មោះធនសេដ្ឋី មាននៅក្នុងក្រុងរាជគ្រឹះ ជនទាំងឡាយដែលជាញាតិរបស់យើងជាច្រើន មាននៅក្នុងក្រុងនោះ ។

មហាបន្ថក:. ម៉ែ ព្រោះហេតុអ្វី ទើបយើងមិនទៅទីនោះ ?

សេដ្ឋីធីតាមិនប្រាប់នូវហេតុដែលខ្លួនមក ដល់បុត្រ កាលបុត្រទាំងពីរសួររឿយៗ ទើបប្រាប់ដល់ស្វាមីថា "កូនយើងទាំងពីរនាក់នេះរុកកួនខ្ញុំខ្លាំងណាស់ មាតាបិតាឃើញពួកយើងហើយ នឹងទំពាស៊ីសាច់ឬ ណ្ហើយចុះ ឥឡូវនេះ យើងទាំងពីរនឹងសម្តែងនូវត្រកូលនៃជីតា ជីដូនដល់ពួកកូនយើងទាំងពីរចុះ" ។

ស្វាមី. ខ្ញុំមិនអាចនឹងចូលទៅបង្ហាញមុខបានទេ តែណ្ហើយចុះ ខ្ញុំនឹងនាំពួកក្មេងទាំងនោះទៅបាន ។

ភរិយា. ល្អហើយ ក្មេងទាំងពីរនេះ គួរតែឃើញនូវត្រកូលនៃជីតា

ដោយឧបាយយ៉ាងណាមួយដោយពិត ។

ទាំងពីរនាក់ស្វាមីភរិយានាំក្មេងៗ ទៅដល់ក្រុងរាជគ្រឹះដោយលំដាប់ សម្រាកនៅក្នុងសាលាមួយខាងទៀបទ្វារក្រុង ។ មាតារបស់ក្មេង នាំក្មេងទាំងពីរនាក់ទៅហើយ ញុំាងបុគ្គលឲ្យប្រាប់នូវការៈនៃខ្លួនជាអ្នកនាំយកនូវក្មេងទាំងពីរមកដល់មាតាបិតា ។ មាតាបិតាទាំងពីរនាក់ បានឮដំណឹងនោះហើយពោលថា "បណ្ដាជនទាំងឡាយ អ្នកត្រាច់រង្គាត់នៅក្នុងសង្សារ ដែលឈ្មោះថា មិនធ្លាប់ជាបុត្រ មិនធ្លាប់ជាធីតានឹងគ្នានោះរមែងមិនមាន បុគ្គលទាំងពីរនាក់នោះមានកំហុសចំពោះយើងធំណាស់ ពួកគេមិនអាចនឹងតាំងនៅក្នុងគន្លងចក្ខុរបស់យើងបានទេ អ្នកទាំងពីរ ចូរយកទ្រព្យប្រមាណប៉ុណ្ណេះទៅកាន់ទីដែលជាសុខហើយរស់នៅចុះ ប៉ុន្តែចូរបញ្ជូនក្មេងទាំងពីរមកឲ្យយើង" ។ ទាំងពីរនាក់ស្វាមីភរិយានោះ ទទួលយកទ្រព្យដែលមាតាបិតាបញ្ជូនមក ហើយប្រគល់ក្មេងទាំងពីរឲ្យអ្នកបម្រើដែលមកនោះឯង បញ្ជូនទៅហើយ ក្មេងទាំងពីរនាក់ចម្រើន (វ័យ) នៅក្នុងត្រកូលតាយាយ ។

ក្នុងក្មេងទាំងពីរនាក់នោះ ចូឡបន្ថកៈនៅក្មេង ចំណែកមហាបន្ថកៈរមែងទៅស្ដាប់ធម្មកថារបស់ព្រះទសពលជាមួយនឹងជីតា កាលមហាបន្ថកៈ

ទៅកាន់សំណាក់របស់ព្រះសាស្ដារឿយៗ ចិត្តក៏បង្អោនទៅដើម្បីបព្វជ្ជា ។ គេនិយាយជាមួយនឹងជីតាថា "ប្រសិនបើតាអនុញ្ញាតឲ្យខ្ញុំ ខ្ញុំនឹងបួស" ។ លោកសេដ្ឋីពោលថា "នែ៎ចៅ ចៅនិយាយអ្វី ការបួសរបស់ចៅជាការល្អដល់តាជាងការបួសរបស់បុគ្គលទូទៅក្នុងលោក ប្រសិនបើចៅអាច ក៏បួសចុះ" ដូច្នេះ ហើយនាំមហាបន្ថកៈទៅកាន់សំណាក់ព្រះសាស្ដា កាលព្រះអង្គត្រាស់សួរថា "ម្នាលគហបតី អ្នកបានក្មេងមកឬ?" ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ក្មេងនេះជាចៅរបស់ខ្ញុំព្រះអង្គ បំណងនឹងបួសក្នុងសំណាក់ព្រះអង្គ" ។ ព្រះសាស្ដាត្រាស់បង្គាប់ភិក្ខុអ្នកសមាទានបិណ្ឌបាតជាវត្ត ជាប្រក្រតីមួយរូបថា "ម្នាលភិក្ខុ អ្នកចូរឲ្យក្មេងនេះបួសចុះ" ។ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់មហាបន្ថកៈហើយ ឲ្យបព្វជ្ជា ។ លោករៀនព្រះពុទ្ធវចនៈបានច្រើន មានអាយុគ្រប់ ក៏បានឧបសម្បទា ធ្វើកម្មក្នុងយោនិសោមនសិការ (ចម្រើនកម្មដ្ឋាន) ហើយក៏បានសម្រេចព្រះអរហត្ត ។

លោកញ៉ាំងកាលឲ្យកន្លងទៅដោយសេចក្ដីសុខក្នុងឈាន និងសេចក្ដីសុខដែលកើតអំពីផល គិតថា "យើងអាចញ៉ាំងសេចក្ដីសុខនេះឲ្យកើតឡើងដល់ចុល្លបន្ថកៈបានឬទេហ្ន៎?" ក្រោយមកបានទៅកាន់សំណាក់នៃសេដ្ឋីដែល

ជាជីតា ហើយពោលយ៉ាងនេះថា "បពិត្រមហាសេដ្ឋី ប្រសិនបើលោកអនុញ្ញាត អាត្មាភាពគប្បីឲ្យចុល្លបន្ថកៈចេញបួស" ។ សេដ្ឋីបានពោលថា "លោកម្ចាស់ និមន្តឲ្យគេបួសចុះ" ។ បានឮថា សេដ្ឋីជ្រះថ្លាណាស់ក្នុងព្រះសាសនា ប៉ុន្តែកាលត្រូវសួរថា "ក្មេងទាំងនេះជាបុត្រនៃធីតាមួយណារបស់លោក" នឹងប្រាប់ថា "នៃធីតាដែលរត់បាត់ទៅនោះ" ក៏ខ្មាសគេ ព្រោះដូច្នោះ លោកទើបអនុញ្ញាតការបួសដល់ចៅទាំងពីរនោះដោយងាយ ។ ព្រះថេរៈញ៉ាំងចូឡបន្ថកៈឲ្យបួសហើយ ឲ្យតាំងនៅក្នុងសីលទាំងឡាយ ។ សូម្បីចូឡបន្ថកៈនោះ លុះបួសហើយកាលណា ក៏បានជាមនុស្សល្ងង់ខ្លៅ ។ ព្រះថេរៈកាលបង្ហាត់ចូឡបន្ថកៈ លោកពោលគាថានេះថា ៖

ផ្កាឈូកក្រហម មានក្លិនក្រអូប រីកពីព្រឹក គប្បីមានក្លិន
មិនទាន់ប្រាសទៅ យ៉ាងណា អ្នកចូរឃើញព្រះអង្គីរស
ដែលភ្លឺរុងរោចន៍ហើយ ដូចជាព្រះអាទិត្យបញ្ចេញរស្មី
ឮដីផ្ទៃអាកាស ដូច្នោះ ។

តែមួយគាថាប៉ុណ្ណោះ ដោយកាលកន្លងទៅ ៤ ខែ លោកក៏មិនអាចរៀនឲ្យចាំបាន ។

## បុព្វកម្មរបស់ចូឡបន្ថកៈ

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា បានឮថា ចូឡបន្ថកៈបួសក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ជាអ្នកមានបញ្ញាបានធ្វើនូវការសើចចំអកលេង ក្នុងកាលដែលភិក្ខុល្ងង់មួយរូប កំពុងរៀនទូវឧទ្ទេស (ព្រះបាលី) ភិក្ខុរូបនោះខ្មាស-អៀនព្រោះការសើចចំអកនោះ ឈប់រៀនឧទ្ទេស មិនធ្វើការស្វាធ្យាយ ។ ព្រោះកម្មនោះ ចូឡបន្ថកៈនេះ ពេលបួសហើយ ក៏ជាមនុស្សល្ងង់ បទធម៌ដែលរៀនរួចហើយ កាលលោករៀនបទតៗ ទៅ ក៏ភ្លេចអស់ ។ កាលលោកព្យាយាមដើម្បីរៀនគាថានេះឯង ៤ ខែ ក៏បានកន្លងទៅ ។ ពេលនោះ ព្រះមហាបន្ថកៈបានពោលនឹងលោកថា "ចូឡបន្ថកៈ អ្នកជាបុគ្គលអភ័ព្វក្នុងសាសនានេះ ៤ ខែកន្លងទៅហើយ សូម្បីតែមួយគាថាក៏អ្នករៀនមិនចាំ អ្នកនឹងញុំាងកិច្ចនៃបព្វជិតឲ្យដល់នូវទីបំផុតបានយ៉ាងណា? ចូរចេញអំពីវត្តនេះចុះ" ដូច្នេះ ហើយក៏បណ្តេញឲ្យចេញពីវិហារ ។ ព្រះចូឡបន្ថកៈមិនប្រាថ្នាភាពជាគ្រហស្ថ ព្រោះស្រឡាញ់ក្នុងព្រះពុទ្ធសាសនា ។

ក៏ក្នុងកាលនោះ ព្រះមហាបន្ថកៈជាភត្តុទ្ទេសក៍ ។ ពេទ្យឈ្មោះជីវ-

កកោមារភច្ចកាន់យកកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាច្រើនទៅកាន់អម្ពវ័ន បូជាព្រះសាស្ដា ស្ដាប់ព្រះធម៌ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះទសពលហើយ ចូលទៅរកព្រះមហាបន្ថកៈ សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុក្នុងសំណាក់នៃព្រះសាស្ដាមានចំនួនប៉ុន្មាន?" ។

ព្រះមហាបន្ថកៈ. ភិក្ខុមានប្រមាណ ៥០០ រូប ។

ពេទ្យជីវក. លោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែកនេះ សូមលោកម្ចាស់នាំភិក្ខុ ៥០០ រូប មានព្រះពុទ្ធជាប្រធាន (ទៅ) ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំ ។

ព្រះមហាបន្ថកៈ. ម្នាលឧបាសក ភិក្ខុ (ល្ងង់មួយរូប) ឈ្មោះចូឡបន្ថកៈ ជាអ្នកមានធម៌មិនចម្រើន អាត្មានឹងវៀរចូឡបន្ថកៈនោះចេញ ហើយទទួលនិមន្តដើម្បីភិក្ខុទាំងឡាយដ៏សេស ។

ព្រះចូឡបន្ថកៈឮពាក្យនោះហើយ គិតថា "ព្រះថេរៈ កាលទទួលនិមន្តដើម្បីភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណេះ ក៏ធ្វើអញឲ្យជាអ្នកខាងក្រៅ ទើបទទួល ចិត្តរបស់បងប្រុសយើងនឹងបែងបែក (អស់ទំនាក់ទំនង) ក្នុងយើងដោយគ្មានសង្ស័យឥឡូវនេះ យើងនឹងត្រូវការអ្វីដោយសាសនានេះ យើងនឹងជាគ្រហស្ថធ្វើបុណ្យផ្សេងៗ មានទានជាដើម នឹងរស់នៅ" ស្អែកឡើង

ភិក្ខុឈ្មោះចូឡបន្ថកៈដើរទៅដើម្បីសឹកតាំងពីព្រលឹម ។ ព្រះសាស្ដាទ្រង់ត្រួតមើលលោក (គឺពួកសត្វ) ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញហេតុនេះហើយទើបស្ដេចយាងទៅមុនគេ ទ្រង់បានប្រតិស្ឋានទីចង្ក្រមទៀបខ្លោងទ្វារ ក្បែរផ្លូវដែលជាទីទៅនៃព្រះចូឡបន្ថកៈ ។ ព្រះចូឡបន្ថកៈពេលដើរទៅ បានឃើញព្រះសាស្ដា ក៏ចូលទៅថ្វាយបង្គំ ។ គ្រានោះ ព្រះសាស្ដាត្រាស់នឹងលោកថា "ម្នាលចូឡបន្ថកៈ អ្នកទៅណាក្នុងវេលានេះ?" ចូឡបន្ថកៈទូលថា "បពិត្រព្រះអង្គដ៏ចម្រើន បងប្រុសរបស់ខ្ញុំព្រះអង្គបណ្ដេញខ្ញុំព្រះអង្គ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទៅដើម្បីនឹងសឹក" ។ ព្រះសាស្ដាទ្រង់ត្រាស់ថា "ម្នាលចូឡបន្ថកៈ អ្នកបព្វជ្ជាក្នុងសម្នាក់របស់តថាគត សូម្បីត្រូវបងប្រុសបណ្ដេញ ហេតុអ្វីមិនមកកាន់សម្នាក់តថាគត មកចុះ អ្នកនឹងត្រូវការអ្វីដោយភាពជាគ្រហស្ថ អ្នកចូរនៅក្នុងសំណាក់តថាគត" ដូច្នេះ ហើយទ្រង់យកព្រះហស្ដដែលមានផ្ទៃដ៏វិចិត្រប្រកបដោយចក្រអង្អែលសីសៈរបស់ចូឡបន្ថកៈ ហើយនាំទៅឲ្យគង់ខាងមុខព្រះគន្ធកុដិ ប្រទានកំណាត់សំពត់ដ៏ស្អាតដែលព្រះអង្គទ្រង់បណ្ដាលឡើងដោយឫទ្ធិ ដោយព្រះពុទ្ធតម្រាស់ថា "ម្នាលចូឡបន្ថកៈ អ្នកចូរបែរមុខទៅទិសខាងកើត ឈ្លីសំពត់នេះ ដោយបរិកម្ម (ធ្វើទុកក្នុងចិត្ត)

ថា រជោហរណំ រជោហរណំ (សំពត់ជូតធូលីៗ) នៅទីនេះឯង" កាល គេក្រាបទូលវេលាហើយ មានភិក្ខុសង្ឃហែហម ស្តេចយាងទៅកាន់ផ្ទះរបស់ ពេទ្យជីវក ទ្រង់គង់លើអាសនៈដែលគេតាក់តែងហើយ ។ ចំណែកព្រះចូឡ-បន្ថកៈអង្គុយសម្លឹងមើលព្រះអាទិត្យផង ឈ្លីសំពត់នោះ ហើយបរិកម្មថា "រជោហរណំ រជោហរណំ" ។ កាលលោកឈ្លីនូវកំណាត់សំពត់នោះ កំណាត់សំពត់បានប្រាកដឡើងជារបស់សៅហ្មង ។ គ្រានោះ លោកក៏បានគិតថា "កំណាត់សំពត់នេះស្អាតពិតៗ ប៉ុន្តែអាស្រ័យនូវអត្តភាពនេះ ក៏លះបង់ភាពប្រក្រតី ក្លាយជារបស់សៅហ្មងយ៉ាងនេះ សង្ខារទាំងឡាយមិនទៀងមែនហ្ន៎ (គ្រានោះ) ផ្តើមអំពីការអស់ទៅសូន្យទៅនៃសង្ខារធម៌ហើយ ក៏ចម្រើនវិបស្សនា ។ ព្រះសាស្តាទ្រង់ជ្រាបថា "ចិត្តរបស់ព្រះចូឡបន្ថកៈឡើងកាន់វិបស្សនាហើយ" ទើបទ្រង់ត្រាស់ថា "ម្នាលចូឡបន្ថកៈ អ្នកកុំសម្គាល់ចំពោះកំណាត់សំពត់នោះថា "សៅហ្មងហើយ ជាប់ធូលីហើយ" ក៏ធូលីទាំងឡាយមានធូលី គឺ រាគៈជាដើមមាននៅក្នុងខ្លួនអ្នក អ្នកចូរនាំ (គឺកម្ចាត់) កិលេសនុ៎ះចេញ" ដូច្នេះ ហើយទ្រង់ផ្សាយនូវព្រះរស្មី ហាក់ដូចជាមានព្រះរូបទ្រង់ប្រាកដចំពោះមុខ ទ្រង់បានត្រាស់នូវព្រះគាថានេះថា ៖

រាគៈឈ្មោះថាធូលី តែល្អងមិនមែនជាធូលីទេ ពាក្យថា "ធូលី" នោះជាឈ្មោះនៃរាគៈ ភិក្ខុទាំងនោះលះបង់ធូលីនោះបានហើយ នៅក្នុងសាសនារបស់ព្រះពុទ្ធដែលទ្រង់មានធូលីទៅប្រាសហើយ ។ ទោសៈឈ្មោះថា ធូលី តែល្អងមិនមែនជាធូលីទេ ពាក្យថា "ធូលី" នោះជាឈ្មោះនៃទោសៈ ភិក្ខុទាំងនោះលះបង់ធូលីនោះបានហើយ នៅក្នុងសាសនាព្រះពុទ្ធដែលទ្រង់មានធូលីទៅប្រាសហើយ ។ មោហៈឈ្មោះថាធូលី ឯល្អងមិនមែនជាធូលីទេ ពាក្យថា "ធូលី" នោះជាឈ្មោះនៃមោហៈ ភិក្ខុទាំងនោះលះបង់ធូលីនោះហើយ រមែងនៅក្នុងសាសនាព្រះពុទ្ធ ដែលទ្រង់មានធូលីទៅប្រាសហើយ ។

ក្នុងកាលចប់ព្រះគាថា ព្រះចូឡបន្ថកៈក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ៗ បិដកទាំង ៣ មកប្រាកដដល់លោកព្រមដោយបដិសម្ភិទានោះឯង ។ បានឮថា ក្នុងកាលមុន លោកជាស្តេចផែនដី ទ្រង់ធ្វើប្រទក្សិណព្រះនគរ កាលព្រះសេទោ (ញើស) ហូរចេញ អំពីព្រះនលាដ

(ថ្វាស់) ទ្រង់យកសំពត់ស្អាតជូតនូវទីបំផុតនៃព្រះនលាដ ។ សំពត់ក៏បាន ក្លាយជារបស់សៅហ្មង ។ ព្រះរាជាក៏បាននូវអនិច្ចសញ្ញាថា "សំពត់ស្អាត បែបនេះអាស្រ័យសរីរៈនេះ លះបង់នូវភាពប្រក្រតី ក្លាយជារបស់សៅហ្មង សង្ខារទាំងឡាយមិនទៀងហ្ន៎" ។ ព្រោះហេតុនោះ សំពត់សម្រាប់ជូតធូលី នោះឯង ទើបជាបច្ច័យដល់លោក ។

ចំណែកពេទ្យជីវក បានបង្អោនទឹកទក្ខិណោទក ចូលទៅថ្វាយព្រះ ទសពល ។ ព្រះសាស្តាទ្រង់បិតបាត្រដោយព្រះហស្ត ហើយទ្រង់ត្រាស់ថា "ម្នាលជីវក ភិក្ខុក្នុងវិហារ នៅមានមិនមែនឬ?" ព្រះមហាបន្ថកៈក្រាបទូល ថា "ក្នុងវិហារ ភិក្ខុមានឬព្រះអង្គ?" ។ ព្រះសាស្តាត្រាស់ថា "មានជីវក" ។ ពេទ្យជីវកបញ្ជូនបុរសទៅដោយប្រាប់ថា "ម្នាលនាយ បើដូច្នោះ អ្នកចូរទៅ ចូរដឹងថា ភិក្ខុក្នុងវិហារមានឬមិនមាន" ។ ក្នុងខណៈនោះ ព្រះចូឡបន្ថកៈ គិតថា "បងប្រុសរបស់យើង និយាយថា ភិក្ខុក្នុងវិហារមិនមាន យើងនឹង ប្រកាសនូវភិក្ខុក្នុងវិហារដល់លោក (បងប្រុស)" ដូច្នេះ ទើបនិម្មិតអម្ពវ័ន ទាំងមូលឲ្យពេញដោយភិក្ខុទាំងឡាយ ភិក្ខុខ្លះកំពុងដេរចីវរ ភិក្ខុខ្លះកំពុង ជ្រលក់ចីវរ ភិក្ខុខ្លះកំពុងស្វាធ្យាយ ព្រះចូឡបន្ថកៈនិម្មិតភិក្ខុ ១.០០០ រូប

ឲ្យមានរូបផ្សេងៗ គ្នាដោយប្រការយ៉ាងនេះ ។

បុរសនោះឃើញភិក្ខុច្រើនរូបនៅក្នុងវិហារ ក៏ត្រឡប់មកប្រាប់ពេទ្យជីវកថា "លោកម្ចាស់ អម្ពវ័នទាំងមូលពេញដោយភិក្ខុទាំងឡាយ" ។ (ព្រះធម្មសង្គាហកាចារ្យពោលថា) ៖

*ចំណែកព្រះថេរៈ ឈ្មោះចូឡបន្ថកៈ និម្មិតខ្លួន ១.០០០*
*(ជាភិក្ខុ ១.០០០ រូប) ក្នុងអម្ពវ័ននោះឯង ហើយអង្គុយ*
*ក្នុងអម្ពវ័ន ដែលគួរមនោរម្យ ដរាបដល់វេលាគេមកប្រាប់*
*នូវភត្តកាល ។*

គ្រានោះ ព្រះសាស្ដាត្រាស់នឹងបុរសនោះថា "អ្នកចូរទៅកាន់វិហារប្រាប់ថា "ព្រះសាស្ដាត្រាស់ហៅភិក្ខុឈ្មោះចូឡបន្ថកៈ" ។ កាលបុរសនោះទៅប្រាប់តាមព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធហើយ ទាំង ១.០០០ រូបក៏ឆ្លើយឡើងថា "អាត្មា ឈ្មោះចូឡបន្ថកៈ អាត្មា ឈ្មោះចូឡបន្ថកៈ" ។ បុរសនោះត្រឡប់ទៅក្រាបទូលព្រះសាស្ដាទៀតថា "បពិត្រព្រះអង្គដ៏ចម្រើនបានឮថា ភិក្ខុទាំងអស់នោះសុទ្ធតែឈ្មោះថាចូឡបន្ថកៈ" ។ ព្រះសាស្ដាទ្រង់ត្រាស់ថា "បើដូច្នោះ អ្នកចូរទៅ ភិក្ខុអង្គណាឆ្លើយមុនថា អាត្មាឈ្មោះ

ចូឡបន្ថក: ចូរចាប់ដៃភិក្ខុរូបនោះ ភិក្ខុដ៏សេសនឹងអន្តរធានហើយ” ។ គេបានធ្វើព្រះតម្រាស់នោះឯង ។ ភិក្ខុប្រមាណ ១.០០០ រូប ក៏វិនាសបាត់ទៅក្នុងខណៈនោះឯង ។ ព្រះថេរៈបាននិមន្តទៅជាមួយបុរសនោះ ។ ក្នុងវេលាស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់ហៅពេទ្យជីវកមក ហើយត្រាស់ថា “ម្នាលជីវក អ្នកចូរទទួលបាត្ររបស់ចូឡបន្ថក:ចុះ ចូឡបន្ថក:នេះនឹងធ្វើអនុមោ-ទនាដល់អ្នក” ។ ពេទ្យជីវកបានធ្វើហើយដោយប្រការដូច្នោះ ។ ព្រះថេរៈបន្លឺសីហនាទ ដូចជាសីហ:ដែលក្រោកពីដេក បានធ្វើអនុមោទនា ញុំាងព្រះត្រៃបិដកឲ្យប្រព្រឹត្តទៅហើយ ។ ព្រះសាស្តាស្តេចក្រោកចាកអាសនៈមានភិក្ខុហែហមស្តេចទៅកាន់វិហារ កាលភិក្ខុទាំងឡាយសម្តែងវត្តហើយស្តេចក្រោកចាកអាសនៈ ទ្រង់ប្រថាប់ឈរនៅនឹងមុខនៃព្រះគន្ធកុដិប្រទានសុគតោវាទ ត្រាស់ប្រាប់កម្មដ្ឋានដល់ភិក្ខុសង្ឃ ទ្រង់ឲ្យភិក្ខុសង្ឃទៅហើយស្តេចចូលកាន់ព្រះគន្ធកុដិដែលអប់ដោយក្លិនក្រអូប ទ្រង់ផ្ទំដោយសីហសេ-យ្យា ដោយបែរព្រះបិដ្ឋិ (ខ្នង) មកខាងស្តាំ ។

ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាខាងនេះខ្លះ ខាងនោះខ្លះដូចជាបុគ្គលបាំងវាំងននទ ដោយសំពត់កម្ពលពណ៌ក្រហម ប្រារព្ធដល់គុណ

របស់ព្រះសាស្តាថា "លោកដ៏មានអាយុ ព្រះមហាបន្ថកៈមិនជ្រាបអធ្យា-ស្រ័យរបស់ព្រះចូឡបន្ថកៈ ទើបមិនអាចនឹងឲ្យរៀនទូវបទគាថាតែមួយដោយកាល ៤ ខែបាន បណ្តេញចេញពីវិហារដោយយល់ថា "ភិក្ខុរូបនេះល្ងង់ខ្លៅ" ប៉ុន្តែព្រះសម្មាសម្ពុទ្ធបានប្រទានព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទាក្នុងរវាងនៃភត្តកាលតែមួយប៉ុណ្ណោះ ព្រោះព្រះអង្គជាធម្មរាជាដ៏កំពូល ព្រះត្រៃ-បិដកក៏មកព្រមជាមួយនឹងបដិសម្ភិទានោះឯង គួរអស្ចារ្យ ឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធទាំងឡាយមានច្រើន" ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបរឿងរ៉ាវនេះក្នុងធម្មសភាហើយ ទ្រង់ព្រះតម្រិះថា "ថ្ងៃនេះ តថាគតគួរទៅ" ស្តេចក្រោកចាកពុទ្ធសេយ្យា ទ្រង់ស្លៀកសំពត់ ២ ជាន់ ដែលជ្រលក់ល្អហើយ ទ្រង់ចងវត្ថពន្ធចង្កេះដូចជាផ្លេកបន្ទោរ ទ្រង់ដណ្តប់មហាបង្សុកូល-ចីវរព្រះសុគតដូចសំពត់កម្ពលមានពណ៌ក្រហម ស្តេចចេញចាកព្រះគន្ធកុដិដែលមានក្លិនក្រអូប យាងទៅកាន់ធម្មសភា ដោយព្រះដំណើរដ៏ស្អាតល្អនៃព្រះអកប្បកិរិយា ដូចស្តេចគុជសាចុះប្រេង និងសត្វសីហៈ (និង) ដោយព្រះពុទ្ធលីលាមិនមានទីបំផុត ស្តេចយាងឡើងកាន់បវរពុទ្ធាសនៈ ដែលតាក់តែងល្អហើយក្នុងកណ្តាលនៃរោងមូលដែលបុគ្គលប្រដាប់ហើយ ទ្រង់ប្រថាប់

គង់លើអាសនៈ ទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សី ៦ ប្រការ ប្រៀបដូចជាទេវតាញុំាងផ្ទៃមហាសមុទ្រឲ្យកម្រើក និងដូចជាព្រះអាទិត្យ កំពុងបញ្ចេញរស្មីដ៏ស្រទន់លើកំពូលភ្នំយុគន្ធរ ដូច្នោះ ។ កាលព្រះសម្មាសម្ពុទ្ធស្តេចមកដល់ភ្លាម ភិក្ខុសង្ឃក៏ផ្អាកនូវការសន្ទនា គង់ស្ងៀម ។ ព្រះសាស្តាទ្រង់ពិចារណាមើលបរិស័ទដោយព្រះទ័យដ៏ទន់ ទ្រង់រំពឹងថា "បរិស័ទនេះល្អណាស់ ការឃ្នងដោយដៃក្តី ការឃ្នងដោយជើងក្តី សំឡេងក្អកក្តី សំឡេងកណ្តាស់ក្តី សូម្បីរបស់ភិក្ខុ ១ រូប រមែងមិនមាន ភិក្ខុទាំងអស់នេះមានសេចក្តីគោរពក្នុងព្រះពុទ្ធ ដែលតេជៈនៃព្រះពុទ្ធគម្រាមហើយ ។ កាលតថាគតគង់ (ស្ងៀម) មិនពោលសូម្បីអស់កំណត់នៃអាយុ ក៏គ្មានភិក្ខុរូបណាទឹងលើករឿងឡើងមកនិយាយឡើយ ដែលឈ្មោះថា ធម្មទំនៀមនៃការលើករឿងឡើង តថាគតគប្បីដឹង តថាគតខ្លួនឯងនឹងពោលឡើងមុន" ដូច្នេះ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះសូរសៀងដ៏ពីរោះ ដូចជាសំឡេងនៃព្រហ្ម ត្រាស់សួរថា (ម្នាលិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយដល់រឿងអ្វី? រឿងអ្វីដែលពួកអ្នកបញ្ឈប់ទុកក្នុងចន្លោះ? កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយរឿងឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចូឡ-

បន្ថកៈនេះ មិនមែនល្ងង់តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ល្ងង់ដូចគ្នា ម្យ៉ាងទៀតតថាគតមិនមែនជាទីពឹងអាស្រ័យនៃចូឡបន្ថកៈតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បានជាទីពឹងអាស្រ័យរបស់ចូឡបន្ថកៈដែរ ។ ក្នុងកាលមុនតថាគតបានធ្វើចូឡបន្ថកៈនេះ ឲ្យជាម្ចាស់នៃលោកិយទ្រព្យ ឥឡូវនេះ តថាគតបានធ្វើឲ្យជាម្ចាស់នៃលោកុត្តរ-ទ្រព្យ” ភិក្ខុទាំងឡាយប្រាថ្នានឹងស្តាប់នូវសេចក្តីនោះឲ្យពិស្តារ ទើបបានទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមក (សម្តែង) ។

ក្នុងអតីតកាល មាណពអ្នកក្រុងពារាណសីម្នាក់ ទៅកាន់ក្រុងតក្ក-សិលា ជាធម្មន្តេវាសិករបស់អាចារ្យទិសាបាមោក្ខ ដើម្បីប្រាថ្នារៀនសិល្បៈ បានជាអ្នកមានឧបការៈច្រើនដល់អាចារ្យ ក្នុងចំណោមមាណព ៥០០ នាក់ ធ្វើកិច្ចគ្រប់យ៉ាង មានការប្រេបាច់ជើងជាដើម ក៏ប៉ុន្តែមិនអាចរៀនចេះនូវសិល្បៈណាមួយឡើយ ព្រោះខ្លួនជាមនុស្សល្ងង់ សូម្បីអាចារ្យខំព្យាយាមបង្ហាត់បង្រៀនដោយគិតថា “សិស្សម្នាក់នេះ មានឧបការៈដល់យើងច្រើន នឹងឲ្យសិក្សាឲ្យចេះ” ក៏មិនអាចឲ្យសិក្សាចេះចាំអ្វីបាន ។ មាណពនោះនៅអស់កាលជាយូរ សូម្បីគាថាតែមួយក៏មិនអាចនឹងរៀន (ឲ្យចាំ) បាន នឹក

រៀនខ្វាស សូមលាអាចារ្យថា "បពិត្រលោកអាចារ្យ ខ្ញុំសូមលាទៅផ្ទះវិញ" អាចារ្យគិតថា "សិស្សម្នាក់នេះមានឧបការៈដល់យើងច្រើន យើងក៏ប្រាថ្នាភាពជាបណ្ឌិតដល់គេដែរ ប៉ុន្តែមិនអាចនឹងធ្វើភាពជាបណ្ឌិតនោះឲ្យគេបាន ចាំបាច់យើងនឹងត្រូវធ្វើឧបការៈតបស្នងដល់សិស្សម្នាក់នេះ នឹងចងនូវមន្ត្រឲ្យគេ ១ បទ អាចារ្យបាននាំមាណពនោះទៅកាន់ព្រៃ ចងមន្ត្រនេះថា "**ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ**" ។ (អ្នកឯងព្យាយាមទៅ ព្យាយាមទៅ ព្រោះហេតុអ្វី? ទើបអ្នកឯងព្យាយាម សូម្បីយើងក៏ដឹងនូវហេតុនោះដែរ) ដូច្នេះ ហើយឲ្យគេរៀនទៅមកៗ ច្រើនរយដង ហើយសួរថា "អ្នកចាំហើយឬ?" កាលគេឆ្លើយថា "លោកអាចារ្យ ខ្ញុំចាំហើយ" ប្រាប់ថា "ធម្មតាសិល្បៈទាំងឡាយដែលមនុស្សល្ងង់ព្យាយាមធ្វើឲ្យស្ទាត់ហើយ រមែងមិនភ្លេច" ឲ្យស្បៀងសម្រាប់ធ្វើដំណើរហើយ ប្រាប់ថា "អ្នកទៅចុះ ហើយអាស្រ័យមន្ត្រនេះចិញ្ចឹមជីវិតចុះ តែដើម្បីប្រយោជន៍ដល់ការមិនភ្លេចនៃមន្ត្រនោះ អ្នកគប្បីធ្វើនូវការសាធ្យាយមន្ត្រនោះរឿយៗ ចុះ" ដូច្នេះ ហើយក៏ឲ្យគេទៅ ។ ក្នុងវេលាគេធ្វើដំណើរទៅដល់ក្រុងពារាណសី មាតាបានធ្វើសក្ការៈ និងសេចក្ដីស្និទ្ធស្នាល ដោយសេចក្ដីរីករាយថា "បុត្រ

របស់យើងសិក្សាសិល្បៈត្រឡប់មកវិញហើយ” ។

ក្នុងកាលនោះ ព្រះរាជាក្រុងពារាណសី ទ្រង់ពិចារណាថា “ទោសអ្វីមួយព្រោះកម្មទាំងឡាយ មានកាយកម្មជាដើមរបស់យើង មានឬហ្ន៎?” មិនទ្រង់ឃើញនូវកម្មអ្វីៗ ដែលមិនជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គ ក៏ទ្រង់ព្រះចិន្តាថា “ធម្មតាទោសរបស់ខ្លួន រមែងមិនប្រាកដដល់ខ្លួនទេ រមែងប្រាកដដល់អ្នកដទៃ យើងនឹងដឹងការប្រព្រឹត្តទៅរបស់ពួកអ្នកនគរទាំងឡាយ” ដូច្នេះ ទើបស្តេចក្លែងភេទចេញទៅក្នុងវេលាល្ងាច ទ្រង់ត្រិះរិះថា “ធម្មតាការសន្ទនាប្រាស្រ័យទាក់ទងគ្នារបស់ពួក មនុស្សអ្នកអង្គុយបរិភោគអាហារក្នុងពេលល្ងាច រមែងមានប្រការផ្សេងៗគ្នា ប្រសិនបើយើងគ្រប់គ្រងរាជដោយអធម៌ ជនទាំងឡាយគង់នឹងនិយាយគ្នាថា ពួកយើងត្រូវស្តេចផែនដីដែលមិនតាំងនៅក្នុងធម៌ ជាមនុស្សអាក្រក់ បៀតបៀនដោយអាជ្ញា និងពលីជាដើម ប្រសិនបើយើងគ្រប់គ្រងរាជដោយធម៌ ជនទាំងឡាយក៏នឹងពោលពាក្យជាដើមថា សូមព្រះរាជារបស់យើងទាំងឡាយ ចូរមានព្រះជន្មាយុយឺនយូរចុះ ហើយក៏គង់សរសើរគុណរបស់យើង” ដូច្នេះ ទើបស្តេចយាងទៅតាមលំដាប់ផ្ទះនោះៗ ។ ក្នុងខណៈនោះ ពួកចោរដែលរកស៊ីដោយការជីក

ឧមង្គ (រូង) កំពុងជីកឧមង្គក្នុងចន្លោះផ្ទះពីរខ្នង ដើម្បីត្រូវការចូលទៅក្នុងផ្ទះទាំង ២ ដោយឧមង្គតែមួយ ។ ព្រះរាជាទ្រង់ទតឃើញចោរនោះហើយទ្រង់ឈរពួនទៅក្នុងស្រមោលនៃផ្ទះ ។ ក្នុងវេលាដែលពួកចោរជីកឧមង្គចូលទៅផ្ទះបានហើយ កំពុងរកមើលនូវកណ្ឌៈទាំងឡាយ មាណពនោះភ្ញាក់ឡើង ក៏ស្វាធ្យាយនូវមន្តនោះថា **"ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ"** ។ ចោរទាំងនោះបានឮពាក្យនោះហើយ ក៏ភ័យតក់ស្លុត បោះចោលសូម្បីនូវសំពត់ដែលខ្លួនស្លៀក ហើយរត់ទៅតាមប្រកតែមួយ ដោយប្រាប់គ្នាថា "បានឮថា មាណពនេះស្គាល់ពួកយើងហើយ វានឹងញុំាងពួកយើងឲ្យវិនាសក្នុងកាលឥឡូវនេះ" ។ ព្រះរាជាទ្រង់ទតឃើញចោរទាំងនោះកំពុងរត់ទៅ នឹងទ្រង់ព្រះសណ្ដាប់នូវសំឡេងរបស់មាណពដែលស្វាធ្យាយមន្ត ទ្រង់បានដឹង (ការប្រព្រឹត្តទៅ) នៃពួកអ្នកនគរបានហើយ ទើបស្ដេចយាងទៅកាន់ព្រះរាជនិវេសន៍ លុះដល់វេលាភ្លឺច្បាស់ហើយ ទ្រង់ក៏ត្រាស់ហៅរាជបុរសម្នាក់ (មកគាល់) ត្រាស់ថា "ម្នាលនាយ អ្នកឯងចូរទៅ ពួកចោរជីកឧមង្គក្នុងផ្ទះឯណោះ ក្នុងថ្នល់ឯណោះ ក្នុងផ្ទះមួយខ្នងនោះមានមាណពដែលរៀននូវសិល្បៈមកអំពីនគរតក្កសិលា (ម្នាក់) អ្នកចូរនាំ

មាណពនោះមក" ។ រាជបុរសទៅប្រាប់ថា "ព្រះរាជាត្រាស់ឲ្យហៅអ្នក" ហើយនាំមាណពនោះមក ។ គ្រានោះ ព្រះរាជាត្រាស់ទៅកាន់មាណពនោះថា "ម្នាលអ្នកដ៏ចម្រើន អ្នកជាមាណពដែលរៀនសិល្បៈមកអំពីនគរតក្កសិលាឬ?" ។

មាណព. ព្រះករុណាថ្លៃវិសេស ។

ព្រះរាជា. ចូរឲ្យសិល្បៈដល់យើងផងចុះ ។

មាណព. បពិត្រព្រះសម្មតិទេព ប្រពៃហើយ សូមព្រះអង្គប្រថាប់លើអាសនៈដែលស្មើហើយរៀនចុះ ។

គ្រានោះ ព្រះរាជាទ្រង់ក៏ធ្វើយ៉ាងនោះ ទ្រង់រៀនមន្តនោះអំពីមាណពនោះហើយ បានព្រះរាជទានទ្រព្យ ១.០០០ ដោយព្រះតម្រាស់ថា "នេះជាចំណែកបូជាដល់អាចារ្យ" ។

ក្នុងកាលនោះ សេនាបតីនិយាយនឹងនាយខ្មាន់ព្រះកេសរបស់ព្រះរាជាថា "អ្នកឯងនឹងកោរនូវព្រះមស្សុ (ពុកចង្កា) របស់ព្រះរាជាក្នុងកាលណា?" នាយខ្មាន់ព្រះកេសពោលថា "ថ្ងៃស្អែក ឬក៏ថ្ងៃខានស្អែកនេះឯង" ។

សេនាបតីនោះឲ្យទ្រព្យ ១.០០០ ដល់គេហើយពោលថា "ខ្ញុំមានកិច្ច

(មួយ)” កាលគេសួរថា “លោកម្ចាស់ កិច្ចអ្វីទៅ?” ប្រាប់ថា “ឯងត្រូវធ្វើអាការដូចជាដាក់ព្រះមស្សុរបស់ព្រះរាជា សំលៀងកាំបិតកោរឲ្យមុតហើយកាត់នូវបំពង់ករបស់ព្រះរាជា នឹង (បាន) ជាសេនាបតី ខ្ញុំនឹងជាព្រះរាជា ។ នាយខ្នាន់ព្រះកេសទទួលយល់ព្រមថា “បាន” ក្នុងថ្ងៃដាក់នូវព្រះមស្សុថ្វាយព្រះរាជា យកទឹកក្រអូបស្រលាបព្រះមស្សុឲ្យទទឹក សំលៀងកាំបិតកោរចាប់ត្រង់ទីបំផុតនៃព្រះនលាដ (ថ្ងាស់) គិតថា “កាំបិតកោរនេះមានមុខរឹលបន្តិច យើងគួរកាត់បំពង់ក ដោយការកាត់តែម្តងប៉ុណ្ណោះ” ដូច្នេះហើយទើបឈរនៅក្នុងចំណែកម្ខាង សំលៀងកាំបិតកោរទៀត ។ ក្នុងពេលនោះព្រះរាជាទ្រង់រឭកដល់មន្តរបស់ព្រះអង្គបាន កាលនឹងទ្រង់ធ្វើការស្វាធ្យាយទ្រង់ត្រាស់ថា **“ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ”** ។ ញើសក៏បានហូរចេញអំពីថ្ងាសនៃនាយខ្នាន់ព្រះកេស ។ នាយខ្នាន់ព្រះកេសយល់ថា “ព្រះរាជាទ្រង់ជ្រាបនូវហេតុនេះ” ក៏ភិតភ័យ បោះកាំបិតកោរចោលទៅលើផែនដី ហើយក្រាបចុះក្នុងទីជិតព្រះបាទ ។ ធម្មតាព្រះរាជាទាំងឡាយទ្រង់រមែងជាអ្នកឆ្លាត ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់ទៅកាន់នាយខ្នាន់ព្រះកេសយ៉ាងនេះថា “ម្នាលខ្នាន់ព្រះកេសអាក្រក់ អ្នកឯង

សម្គាល់ថា “ព្រះរាជាទ្រង់មិនជ្រាបឬ?” ។

ខ្មាន់ព្រះកេស. បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាព្រះរាជ-ទានទោសដល់ខ្ញុំព្រះអង្គផងចុះ ។

ព្រះរាជា. ណ្ហើយចុះ អ្នកឯងកុំភ័យឡើយ ចូរប្រាប់យើងមកចុះ ។

ខ្មាន់ព្រះកេស. បពិត្រព្រះសម្មតិទេព សេនាបតីបានឲ្យទ្រព្យ ១.០០០ ដល់ខ្ញុំព្រះអង្គ ហើយប្រាប់ថា “អ្នកចូរធ្វើដូចជាដាក់នូវព្រះមស្សុថ្វាយព្រះរាជា ហើយកាត់នូវបំពង់កព្រះរាជា កាលព្រះរាជាសោយទិវង្គតហើយ ខ្ញុំនឹងជាព្រះរាជា តែងតាំងអ្នកឯងឲ្យជាសេនាបតី ។

ព្រះរាជាទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ ទ្រង់ត្រិះរិះថា “យើងបានជីវិតព្រោះអាស្រ័យអាចារ្យ” ទើបទ្រង់ត្រាស់ឲ្យហៅសេនាបតីមក (គាល់) ត្រាស់ថា “ម្នាលសេនាបតីដ៏ចម្រើន ឈ្មោះថា អ្វីដែលអ្នកមិនបានហើយអំពីសំណាក់របស់យើង ។ ឥឡូវនេះ យើងមិនអាចនឹងឃើញអ្នកបានទេ អ្នកចូរចេញអំពីដែនរបស់យើង” ត្រាស់ឲ្យបណ្តេញសេនាបតីចេញពីដែន ហើយ ក៏ត្រាស់ឲ្យអញ្ជើញមាណពដែលជាអាចារ្យមកគាល់ ត្រាស់ថា “លោកអាចារ្យដ៏ចម្រើន យើងមានជីវិតរស់នៅព្រោះអាស្រ័យលោក” ដូច្នេះហើយ

ទ្រង់ធ្វើសក្ការៈដ៏ធំ បានព្រះរាជទានតំណែងសេនាបតីដល់អាចារ្យនោះ ។ មាណពក្នុងកាលនោះបានមកជាចូឡបន្ថកៈ ព្រះសាស្ដាជាអាចារ្យទិសាបាមោក្ខ ។

ព្រះសាស្ដា លុះទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់បានត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុនចូឡបន្ថកៈ ក៏ជាបុគ្គលល្ងង់យ៉ាងនេះដូចគ្នាដែរ ។ សូម្បីក្នុងកាលនោះ តថាគតក៏បានជាទីពឹងដល់ចូឡបន្ថកៈ ញុំាងចូឡបន្ថកៈឲ្យតាំងនៅក្នុងលោកិយទ្រព្យហើយ ។ ក្នុងថ្ងៃស្អែកឡើង កាលកថា (ការសន្ទនាគ្នា) តាំងឡើងថា "គួរអស្ចារ្យណាស់ហ្ន៎ ព្រះសាស្ដាទ្រង់ជាទីពឹងរបស់ព្រះចូឡបន្ថកៈ" ហើយទ្រង់បានជំណាលនូវរឿងអតីតៈក្នុងចូឡសេដ្ឋីជាតក ហើយត្រាស់គាថាថា ៖

> បុគ្គលអ្នកមានបញ្ញាទម្ពះទម្លាយ អ្នកមានបញ្ញាជា
> គ្រឿងពិចារណា រមែងញុំាងខ្លួនឲ្យតាំងឡើងព្រម
> ដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិចតួច
> ដូចបុគ្គលបង្កាត់ភ្លើងគំនរតូច ឲ្យឆេះជាគំនរធំបាន
> ដូច្នោះ ។

ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនបានជាទីពឹង របស់ចូឡបន្ថកៈតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ។ សូម្បីក្នុងកាលមុន ក៏បានជាទីពឹងហើយដែរ ។ ប៉ុន្តែថា ក្នុងកាលមុន តថាគតបានធ្វើចូឡបន្ថកៈនេះ ឲ្យជាម្ចាស់នៃលោកិយទ្រព្យ ឥឡូវនេះ ធ្វើឲ្យជាម្ចាស់នៃលោកុត្តរ-ទ្រព្យ" ដូច្នេះ ទ្រង់ប្រជុំជាតកថា "ចូឡកន្តេវាសិក ក្នុងកាលនោះ បានមកជាចូឡបន្ថកៈ (ក្នុងកាលឥឡូវនេះ) ចំណែកចូឡកសេដ្ឋី ដែលជាបណ្ឌិត ដែលជាអ្នកឈ្លាសវៃយល់ដឹងនៅក្នុងនក្ខត្តឫក្ស (ក្នុងគ្រានោះ) គឺ តថាគត នេះឯង" ។

ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា "ម្នាលអាវុសោ ទាំងឡាយ ព្រះចូឡបន្ថកៈនេះ សូម្បីមិនអាចនឹងរៀនគាថា ៤ បាទ ដោយ ៤ ខែបាន ក៏មិនលះបង់សេចក្តីព្យាយាម និងតាំងនៅក្នុងព្រះអរហត្តហើយ ឥឡូវនេះ ក៏បានជាម្ចាស់នៃទ្រព្យ គឺ លោកុត្តរធម៌ទៀត" ។

ព្រះសាស្តាស្តេចមកត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុ

ទាំងឡាយ ភិក្ខុក្នុងសាសនារបស់តថាគត ប្រារព្ធនូវសេចក្តីព្យាយាមហើយ រមែងជាម្ចាស់នៃលោកុត្តរធម៌ដោយយ៉ាងពិតប្រាកដ ដូច្នេះ ទើបត្រាស់គាថានេះថា ៖

ឧដ្ឋានេនប្បមាទេន     សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី     យំ ឱឃោ នាភិកីរតិ ។

អ្នកប្រាជ្ញ គប្បីសាងកោះ គឺ អរហត្តផល ជាកោះដែលជំនន់ គឺ កិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មាននូវឥន្ទ្រិយផង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ទីបំ កយិរាថ (គប្បីធ្វើនូវកោះ) សេចក្តីថា អ្នកមានបញ្ញា ប្រកបព្រមហើយដោយបញ្ញាដ៏រុងរឿងក្នុងធម៌ គប្បីធ្វើ គឺ គប្បីធ្វើ បានដល់ អាចធ្វើនូវកោះ គឺ អរហត្តផល ដែលជាទីពឹងរបស់ខ្លួនក្នុងសាគរ គឺ សង្សារវដ្តដ៏ជ្រៅក្រៃលែង ព្រោះជាទីពឹងដែលបុគ្គលគប្បី

បានដោយកម្រក្រៃលែងនេះ ដោយធម៌ដែលជាហេតុ ៤ ប្រការនេះ គឺ ដោយសេចក្ដីប្រឹងប្រែង ពោលគឺ សេចក្ដីព្យាយាម ១ ដោយសេចក្ដីមិនប្រមាទ ពោលគឺ ការមិនទៅប្រាសចាកសតិ ១ ដោយសេចក្ដីសង្រួម ពោលគឺ បារិសុទ្ធិសីលបួន ១ ដោយការទូន្មាននូវឥន្ទ្រិយ ១ ។

សួរថា គប្បីធ្វើនូវកោះដូចម្ដេច?

ឆ្លើយថា *"យំ ឱឃោ នាភិកីរតិ"* (គប្បីធ្វើកោះ ដែលជំនន់ជន់លិចមិនបាន) អធិប្បាយថា គប្បីធ្វើនូវកោះដែលជំនន់ គឺ កិលេសទាំង ៤ យ៉ាង មិនអាចនឹងជន់ពន្លិច គឺ កម្ចាត់បាន ពិតណាស់ ព្រះអរហត្ត ដែលឱឃៈមិនអាចនឹងជន់ពន្លិចបានឡើយ ។

ក្នុងកាលចប់ព្រះគាថា ជនជាច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដោយប្រការដូច្នេះឯង ។

ចប់ រឿងព្រះចូឡបន្ថកៈ

# ៤. រឿងនក្ខត្តឫក្សរបស់ជនពាល

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនក្ខត្តឫក្សរបស់ជនពាល ត្រាស់ព្រះធម្មទេសនានេះថា "**បមាទមនុយុញ្ជន្តិ**" ដូច្នេះជាដើម ។*

*សេចក្ដីពិស្ដារថា បានស្ដាប់មក ក្នុងសម័យមួយ គេវាយគងប្រកាសនក្ខត្តឫក្សរបស់ជនពាលក្នុងនគរសាវត្ថី ។ ក្នុងនក្ខត្តឫក្សនោះ ពួកជនពាលដែលអប្បឥតបញ្ញា យកផេះ និងអាចម៍គោលាបរាងកាយ ដើរពោលវាចារបស់ជនអសប្បុរសរហូតអស់ ៧ ថ្ងៃ ឃើញនរណាៗ ជាញាតិក៏ដោយ ជាសម្លាញ់ក៏ដោយ ជាបព្វជិតក៏ដោយ ឈ្មោះថា មាននូវសេចក្ដីអៀនខ្មាសមិនមាន ឈរពោលវាចារបស់អសប្បុរសទៀបទ្វារផ្ទះអ្នកស្រុក ។ មនុស្សទាំងឡាយ មិនអាចស្ដាប់អសប្បុរិសវាទរបស់ពួកជនពាលនោះបាន ទើបបញ្ជូនទ្រព្យទៅឲ្យកន្លះបាទខ្លះ ១ បាទខ្លះ ១ កហាបណៈខ្លះ តាមកម្លាំងរបស់ខ្លួន ពួកជនពាលកាន់យកទ្រព្យដែលបានហើយ ត្រង់ទ្វារនៃផ្ទះរបស់មនុស្សទាំងនោះហើយ ទើបចៀសចេញទៅ ។ ក៏ក្នុងកាលនោះ ក្នុងក្រុងសាវត្ថី មានព្រះអរិយសាវកប្រមាណ ៥ កោដិ ។ ព្រះអរិយសាវកទាំងនោះបញ្ជូនដំណឹងទៅថ្វាយព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមាន-*

ព្រះភាគព្រមទាំងភិក្ខុសង្ឃ ស្តេចកុំចូលទៅកាន់ព្រះនគរ សូមប្រថាប់នៅតែក្នុងព្រះវិហារអស់ ៧ ថ្ងៃ” ក៏ក្នុងកាល ៧ ថ្ងៃនោះ លោកទាំងនោះបានចាត់ចែងយាគូ និងភត្តជាដើម បញ្ជូនទៅកាន់វិហារដើម្បីភិក្ខុសង្ឃ សូម្បីខ្លួនឯងក៏មិនចេញអំពីផ្ទះដែរ ។ ក៏ក្នុងកាលពាលនក្ខត្តឫក្សចប់ហើយ ក្នុងថ្ងៃទី ៨ អរិយសាវកទាំងនោះ និមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន យាងស្តេចចូលទៅកាន់ព្រះនគរថ្វាយមហាទាន អង្គុយក្នុងទីដ៏សមគួរមួយ ហើយក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ៧ ថ្ងៃរបស់ពួកខ្ញុំព្រះអង្គកន្លងទៅបានដោយលំបាកណាស់ កាលពួកខ្ញុំព្រះអង្គ បានឮនូវវាចាមិនមែនរបស់សប្បុរសនៃពួកជនពាល ត្រចៀកទាំង ២ ហាក់ដូចជាដល់នូវអាការបែកធ្លាយ នរណាៗ ក៏មិនមានសេចក្តីអៀនខ្មាសនឹងនរណាៗ ព្រោះហេតុនោះពួកខ្ញុំព្រះអង្គ ទើបមិនយាងព្រះអង្គស្តេចចូលកាន់ព្រះនគរ សូម្បីពួកខ្ញុំព្រះអង្គ ក៏មិនអាចចេញអំពីផ្ទះបានដែរ ។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់អរិយសាវកទាំងនោះហើយ ត្រាស់ថា “កិរិយារបស់ពួកបុគ្គលដែលអប្បឥតបញ្ញា រមែងដូច្នេះឯង ចំណែកបុគ្គលអ្នកមានបញ្ញាទាំងឡាយរក្សានូវសេចក្តីមិនប្រមាទទុក ដូចជាទ្រព្យដ៏មានខ្លឹមសារ រមែងសម្រេចនូវ

សម្បត្តិ គឺ អមតមហានិព្វាន" ដូច្នេះ ទើបទ្រង់បានត្រាស់ព្រះគាថាទាំងនេះថា ៖

បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

ពួកជនពាលអបឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្ដីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទដូចទ្រព្យដ៏ប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្ដីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្ដីរីករាយ ត្រេកអរក្នុងកាមឡើយ ត្បិតបុគ្គលមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបាននូវសេចក្ដីសុខដ៏ទូលាយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ពាលា (ពួកជនពាល) បានដល់ អ្នកប្រកបដោយភាពជាជនពាល គឺ អ្នកដែលមិនស្គាល់ប្រយោជន៍ក្នុងលោកនេះ

និងលោកខាងមុខ ។

បទថា **ទុម្មេធិនោ (អ្នកមានបញ្ញាថោកទាប)** គឺ ឥតបញ្ញា ។ ពួកជនពាលនោះ កាលមិនឃើញទោសក្នុងសេចក្ដីប្រមាទ រមែងប្រកបរឿយៗនូវសេចក្ដីប្រមាទ គឺ រមែងញុំាងកាលឲ្យកន្លងទៅដោយសេចក្ដីប្រមាទ ។

បទថា **មេធាវី (អ្នកមានបញ្ញា)** ជាដើម សេចក្ដីថា ចំណែកបណ្ឌិតដែលប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទ ដូចទ្រព្យ គឺ រតនៈ ៧ ប្រការដ៏ប្រសើរ គឺ ដ៏ខ្ពង់ខ្ពស់ ដែលជាប់តមកអំពីវង្សត្រកូល អធិប្បាយថា ដូចជនទាំងឡាយ កាលឃើញអានិសង្សក្នុងទ្រព្យថា "យើងទាំងឡាយអាស្រ័យទ្រព្យដ៏ខ្ពង់ខ្ពស់ ទើបដល់នូវសម្បត្តិ គឺ កាមគុណ ទើបធ្វើផ្លូវជាទីទៅកាន់បរលោកឲ្យបរិសុទ្ធបាន" រមែងរក្សាទ្រព្យនោះទុក យ៉ាងណាមិញ សូម្បីបណ្ឌិតក៏ដូច្នោះ កាលឃើញអានិសង្សនៃសេចក្ដីមិនប្រមាទថា "បុគ្គលអ្នកមិនប្រមាទហើយ រមែងបានចំពោះនូវឈានទាំងឡាយ មានបឋមឈានជាដើម រមែងសម្រេចលោកុត្តរធម៌ មានមគ្គ និងផលជាដើម រមែងញុំាងវិជ្ជា ៣ (និង) អភិញ្ញា ៦[១] ឲ្យដល់ព្រមបាន" រមែងរក្សា

---

១ ឥទ្ធិវិធី សម្ដែងឫទ្ធិបាន, ទិព្វសោត ត្រចៀកទិព្វ, ចេតោបរិយញ្ញាណ កំណត់ដឹងចិត្តអ្នកដទៃ, បុព្វេនិវាសានុស្សតិ រឭកជាតិបាន, ទិព្វចក្ខុ ភ្នែកទិព្វ, អាសវក្ខយញ្ញាណ ញាណធ្វើអាសវៈឲ្យអស់ទៅ, រួមជាអភិញ្ញា ៦ ។ ៣ ខាងចុង ហៅថា វិជ្ជា ៣ ក៏បាន ។

សេចក្តីមិនប្រមាទទុក ដូចជារក្សាទ្រព្យដ៏ប្រសើរ ។ បទថា **មា បមាទំ (កុំតាមប្រកប) សេចក្តីប្រមាទ** សេចក្តីថា ព្រោះហេតុនោះ អ្នកទាំងឡាយចូរកុំតាមប្រកបរឿយៗ នូវសេចក្តីប្រមាទ គឺ កុំញុំាំងកាលវេលាឲ្យកន្លងទៅដោយសេចក្តីប្រមាទ ។ បទថា **មា កាមរតិសន្ថវំ (កុំតាមប្រកបសេចក្តីស្និទ្ធស្នាលដោយសេចក្តីត្រេកអរក្នុងកាម)** សេចក្តីថា ចូរកុំប្រកប គឺ កុំគិតបានដល់ កុំបានចំពោះសូម្បីនូវសេចក្តីស្និទ្ធស្នាលដោយអំណាចនៃតណ្ហាពោលគឺ សេចក្តីត្រេកអរក្នុងវត្ថុកាម និងកិលេសកាម ។ បទថា **អប្បមត្តោ ហិ (ព្រោះថាបុគ្គលមិនប្រមាទហើយ)** ជាដើម សេចក្តីថា ព្រោះថាបុគ្គលអ្នកមិនប្រមាទហើយ ដោយភាពជាអ្នកមានសតិតាំងមាំ ខំសង្កេតពិនិត្យ រមែងសម្រេចនិព្វានសុខដ៏ទូលំទូលាយ គឺ ដ៏ឧឡារ ។

ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងនក្ខត្តឫក្សរបស់ជនពាល

# ៥. រឿងព្រះមហាកស្សបត្ថេរ

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាកស្សបៈ ត្រាស់ព្រះធម្មទេសនានេះថា **បមាទំ អប្បមាទេន** “... **សេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ**” ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈគង់នៅក្នុងបិប្ផលិគុហា ត្រាច់ទៅបិណ្ឌបាត ខាងក្រោយកត្តគង់ចម្រើនអាលោកកសិណ ពិចារណាមើលសត្វទាំងឡាយដែលប្រមាទ និងមិនប្រមាទ ដែលកំពុងស្លាប់ និងដែលកំពុងកើតក្នុងទីទាំងឡាយ មានទឹក ផែនដី និងភ្នំជាដើម ដោយទិព្វចក្ខុ ។ ព្រះសាស្តាទ្រង់ប្រថាប់នៅក្នុងវត្តជេតពននោះឯង ទ្រង់ពិចារណាមើលដោយទិព្វចក្ខុថា “ថ្ងៃនេះ កស្សបៈបុត្តរបស់តថាគត នៅដោយវិហារធម៌អ្វីហ្ន៎” ទ្រង់ជ្រាបថា “កំពុងពិចារណាមើលនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ” ទើបត្រាស់ថា “ដែលឈ្មោះថា ការចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយប្រសិនបើពុទ្ធញ្ញាណមិនកំណត់ហើយ នរណាៗ ក៏មិនអាចនឹងធ្វើការកំណត់ដឹងសត្វទាំងឡាយដែលបដិសន្ធិក្នុងផ្ទៃនៃមាតា ដែលមាតាបិតាមិនទាន់បានដឹង ក៏ចុតិហើយបាន ការដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងនោះ មិនមែន

វិស័យរបស់អ្នកទេ ម្នាលកស្សបៈ វិស័យរបស់អ្នកមានប្រមាណតិច ឯការដឹង ការឃើញ សត្វទាំងឡាយដែលកំពុងចុតិ និងបដិសន្ធិដោយប្រការទាំងពួងនោះ ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ" ដូច្នេះ ហើយទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចជាទ្រង់ប្រថាប់នៅក្នុងទីចំពោះមុខ ហើយត្រាស់ព្រះគាថានេះថា ៖

បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនី បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

កាលណា បណ្ឌិតបន្ទោបង់នូវសេចក្ដីប្រមាទ ដោយ
សេចក្ដីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់
ប្រាសាទ គឺ បញ្ញា ជាបុគ្គលមិនសោក រមែងឃើញនូវ
សត្វដែលមានសោក ធីរជន តែងឃើញពួកជនពាល
ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើល
ពួកជនដែលនៅលើផែនដី ដូច្នេះឯង ។

# អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **នុទតិ** (បន្ទោបង់) ជាដើម សេចក្តីថា កាលណាបណ្ឌិតចម្រើនកពូននូវអប្បមាទលក្ខណៈ មិនឲ្យឱកាសដល់សេចក្តីប្រមាទ ឈ្មោះថា បន្ទោបង់ គឺ រមែងបណ្តេញបង់នូវសេចក្តីប្រមាទនោះ ដោយកម្លាំងនៃសេចក្តីមិនប្រមាទ ដូចទឹកថ្មីដែលហូរចូលកាន់ស្រះបោក្ខរណី ញុំាងទឹកចាស់ឲ្យខ្ចាត់ចេញហើយ មិនឲ្យឱកាសដល់ទឹកចាស់នោះ រមែងប្រានចេញ គឺ រមែងញុំាងទឹកចាស់នោះឲ្យហូរចេញទៅ ដោយទីបំផុតនៃខ្លួន ដូច្នេះ ។ កាលនោះ បណ្ឌិតនោះ មានសេចក្តីប្រមាទដែលបន្ទោបង់ហើយ បំពេញបដិបទាដ៏សមគួរដល់សេចក្តីមិនប្រមាទនោះ ឡើងកាន់បញ្ញាដូចជាប្រាសាទ ពោលគឺ ទិព្វចក្ខុដ៏បរិសុទ្ធ ព្រោះអត្ថថា ជាធម្មជាតិដ៏ខ្ពង់ខ្ពស់ក្រៃលែង ដោយបដិបទានោះ ដូចបុគ្គលឡើងកាន់ប្រាសាទតាមកាំជណ្តើរ ដូច្នោះ ដែលឈ្មោះថា អ្នកមិនមានសេចក្តីសោកសៅ ព្រោះភាពជាអ្នកលះបង់នូវកូនសរ គឺ សេចក្តីសោកចេញបានហើយ រមែងពិចារណាឃើញ គឺ រមែងក្រឡេកឃើញនូវប្រជា គឺ ពពួកសត្វដែលមាននូវសេចក្តីសោក ព្រោះជាអ្នកលះបង់នូវកូនសរ គឺ សេចក្តីសោកមិនទាន់បាន ដែលកំពុង

ចុតិ និងបដិសន្ធិដោយទិព្វចក្ខុ ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចបុគ្គលដែលឈរនៅលើកំពូលភ្នំ រមែងក្រឡេកឃើញបុគ្គលដែលឈរនៅលើផែនដីបាន ដូច្នោះ (បព្វតដ្ឋោវ ភុម្មដ្ឋេ) អធិប្បាយថា បុគ្គលដែលឈរនៅលើកំពូលភ្នំ រមែងមើលឃើញបុគ្គលដែលឈរនៅលើផែនដីបាន ឬបុគ្គលដែលឈរនៅខាងលើប្រាសាទជាន់លើ រមែងមើលឃើញបុគ្គល ដែលឈរនៅក្នុងបរិវេណនៃប្រាសាទបាន ដោយមិនលំបាកយ៉ាងណា អ្នកប្រាជ្ញ គឺ បណ្ឌិត បានដល់ ព្រះមហាខីណាស្រពរូបនោះ ក៏រមែងពិចារណាឃើញបុគ្គលពាលទាំងឡាយ ដែលមានពូជ គឺ វដ្ដៈមិនទាន់បានកាត់ផ្ដាច់ កំពុងចុតិ និងបដិសន្ធិ ដោយមិនលំបាកដូច្នោះ ។

កាលចប់គាថា ជនជាច្រើន បានធ្វើឲ្យជាក់ច្បាស់ហើយនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងមហាកស្សបត្ថេរ

# ៦. រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប

ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុជាសម្លាញ់នឹងគ្នាពីររូប ត្រាស់ព្រះធម្មទេសនានេះថា **អប្បមត្តោ បមត្តេសុ (កាលជនទាំងឡាយប្រមាទហើយ មិនប្រមាទ)** ដូច្នេះជាដើម ។

បានឮមកថា ភិក្ខុពីររូបនោះ រៀនកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តាហើយចូលទៅកាន់វិហារដែលតាំងនៅក្នុងព្រៃ ។ ក្នុងបណ្តាភិក្ខុពីររូបនោះភិក្ខុមួយរូបនាំយកឧសមកអំពីថ្ងៃ បង្កាត់ភ្លើង ហើយអង្គុយអាំងភ្លើងចរចាជាមួយនឹងភិក្ខុកំលោះ និងសាមណេរទាំងឡាយរហូតអស់បឋមយាម ។ ភិក្ខុដែលជាអ្នកធ្វើនូវសមណធម៌ដោយសេចក្តីមិនប្រមាទ រមែងទូន្មាននូវភិក្ខុនេះថា “ម្នាលអាវុសោ អ្នកកុំធ្វើយ៉ាងនេះឡើយ ព្រោះអបាយភូមិ ៤ ដូចជាផ្ទះដែលជាទីដេកនៃបុគ្គលដែលប្រមាទហើយ ធម្មតាព្រះពុទ្ធទាំងឡាយ បុគ្គលអួត មិនអាចឲ្យទ្រង់ពេញព្រះទ័យបានឡើយ” ។ លោកមិនស្តាប់ពាក្យជាស់តឿនរបស់ភិក្ខុនោះ ។ ភិក្ខុក្រៅពីនេះគិតថា “ភិក្ខុនេះមិនជឿពាក្យទូន្មានរបស់យើង ទើបមិនប្រាថ្នា (ជាស់តឿន) ភិក្ខុដែលមិនប្រមាទនោះ ខំព្យាយាមបំពេញនូវសមណធម៌ ។ ឯព្រះថេរៈដែលខ្ជិល អាំងភ្លើង

ក្នុងបឋមយាម ក្នុងវេលាដែលភិក្ខុក្រៅពីនេះដើរចង្រ្កមហើយ ចូលទៅកាន់បន្ទប់ ទើបចូលទៅនិយាយថា "អាវុសោមហាកំជិល លោកចូលមកកាន់ព្រៃដើម្បីប្រយោជន៍ដល់ការដេកឬ បុគ្គលកាលរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធហើយក្រោកឡើងធ្វើសមណធម៌អស់យប់ និងថ្ងៃមិនគួរឬ?" ដូច្នេះហើយក៏ចូលទៅកាន់លំនៅរបស់ខ្លួន ហើយសឹងលក់ទៅ ចំណែកភិក្ខុក្រៅពីនេះសម្រាកក្នុងមជ្ឈិមហើយ ក្រោកឡើងធ្វើសមណធម៌ក្នុងបច្ឆិមយាម ។ ព្រះថេរៈនោះមិនប្រមាទយ៉ាងនោះ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។ ភិក្ខុដែលខ្ជិល ញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្តីប្រមាទតែម្យ៉ាង ។ ភិក្ខុទាំងពីររូបនោះ ពេលចេញវស្សាក៏បានទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈនឹងភិក្ខុទាំងពីររូបនោះហើយត្រាស់សួរដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបំពេញនូវសមណធម៌ដោយសេចក្តីមិនប្រមាទឬ? កិច្ចនៃបព្វជិតរបស់អ្នកទាំងឡាយដល់ទីបំផុតហើយឬ?" ភិក្ខុដែលជាអ្នកប្រមាទក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីមិនប្រមាទរបស់ភិក្ខុនោះ នឹងមានអំពីទីណា? ចាប់តាំង

ពីកាលដែលខ្លួនទៅ លោកក៏ដេក ញុំាងវេលាឲ្យកន្លងទៅហើយ” ។ ព្រះសាស្តាត្រាស់សួរថា “ម្នាលភិក្ខុ ចុះអ្នកវិញ?” ភិក្ខុដែលខ្ជិលក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនាំយកឧសមកអំពីថ្ងៃ ចាត់ចែងអំបែងភ្លើង ហើយអង្គុយអាំងរហូតអស់បឋមយាម មិនប្រព្រឹត្តនូវការលក់ មិនញុំាងកាលឲ្យកន្លងហួសទៅដោយការដេកឡើយ” ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងភិក្ខុដែលមានសេចក្តីប្រមាទនោះថា “ម្នាលភិក្ខុ អ្នកប្រមាទហើយបណ្តែតបណ្តោយពេលវេលាឲ្យកន្លងទៅ (ទទេៗ) ប៉ុន្តែនិយាយថា ខ្លួនមិនប្រមាទ នឹងធ្វើនូវភិក្ខុដែលមិនប្រមាទហើយ ឲ្យជាអ្នកប្រមាទ ។ ភិក្ខុនោះដូចជាសេះដែលទុព្វល មិនមានសន្ទុះដើរក្នុងសំណាក់នៃបុត្ររបស់តថាគត ឯបុត្ររបស់តថាគតនេះ ដូចជាសេះដែលមានសន្ទុះដើរដ៏លឿនក្នុងសម្នាក់នៃអ្នក” ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

អប្បមត្តោ   បមត្តេសុ   សុត្តេសុ   ពហុជាគរោ
អពលស្សំវ សីឃស្សោ   ហិត្វា យាតិ សុមេធសោ ។

បណ្ឌិតមានប្រាជ្ញាមោះមុត  កាលពួកបុគ្គលកំពុងប្រមាទ
លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោក

*ភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែប*

*នោះ ដូចសេះលឿន ដែលទៅចោលនូវសេះមានកម្លាំង*

*ទន់ទាប ដូច្នោះឯង ។*

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អប្បមត្តោ** (មិនប្រមាទ) សេចក្ដីថា ឈ្មោះថា អ្នកដល់ព្រមហើយដោយសេចក្ដីមិនប្រមាទ ព្រោះជាអ្នកច្រើនទៅដោយសតិ បានដល់ ព្រះខីណាស្រព ។ បទថា **បមត្តេសុ** (ប្រមាទហើយ) កាលសត្វទាំងឡាយតាំងនៅហើយក្នុងការបណ្ដែតបណ្ដោយសតិ ។ បទថា **សុត្តេសុ** (ដេកលក់ហើយ) គឺ (កាលសត្វទាំងឡាយ) ឈ្មោះថាប្រព្រឹត្តក្នុងឥរិយាបថមួយ ព្រោះមិនមានធម៌ជាគ្រឿងភ្ញាក់ គឺសតិ ។ បទថា **ពហុជាគរោ** (ភ្ញាក់ហើយ) បានដល់ អ្នកតាំងនៅក្នុងធម៌ជាគ្រឿងភ្ញាក់ គឺ ជាអ្នកបរិបូណ៌ដោយសតិ ។ បទថា **អពលស្សំវ** (សេះមិនមានកម្លាំង) សេចក្ដីថា ដូចជាសេះសិន្ធពអាជានេយ្យ ដែលមានសន្ទុះជើងដ៏រហ័ស រត់ចោលនូវសេះដែលមានកម្លាំងខ្សោយ មិនមានសន្ទុះជើង ព្រោះជាសេះខ្ចកជើង ដូច្នោះ ។ បទថា **សុមេធសោ** (អ្នកមានបញ្ញា) ជាដើម សេចក្ដីថា

បុគ្គលអ្នកមានបញ្ញាមុះមុត រមែងបោះបង់ចោលនូវបុគ្គលបែបនោះហើយទៅ ដោយអាគម គឺ បរិយត្តិផង ដោយអធិគម គឺ ការសម្រេចមគ្គផលផង អធិប្បាយថា កាលបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ព្យាយាមរៀនព្រះសូត្រមួយព្រះសូត្រនោះឯង បុគ្គលដែលមានបញ្ញាមុះមុត រមែងរៀនបានមួយវគ្គ រមែងលះចោលដោយអាគម គឺ បរិយត្តិយ៉ាងនេះឯង ។ មួយ៉ាងទៀត កាលបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ កំពុងព្យាយាមធ្វើនូវទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ និងរៀនកម្មដ្ឋានហើយស្វាធ្យាយនោះឯង បុគ្គលអ្នកមានបញ្ញាល្អ ចូលទៅកាន់ទីសម្រាកពេលថ្ងៃ ឬទីសម្រាកពេលយប់ ដែលអ្នកដទៃធ្វើទុកហើយក្នុងកាលមុន ពិចារណានូវកម្មដ្ឋាន រមែងញ៉ាំងសព្វ-កិលេសឲ្យអស់ទៅ ធ្វើលោកុត្តរធម៌ ៩ ប្រការ ឲ្យនៅក្នុងកណ្ដាប់ដៃបាន បុគ្គលដែលមានបញ្ញាមុះមុត រមែងបោះបង់ចោលនូវបុគ្គលដែលមានបញ្ញាទន់ខ្សោយដោយអធិគម គឺ ការសម្រេចមគ្គផលយ៉ាងនេះ ។ មួយ៉ាងទៀត បុគ្គលអ្នកមានបញ្ញាល្អ គឺ បោះបង់ចោលនូវបុគ្គលដែលមានបញ្ញាទន់ខ្សោយនោះទុកក្នុងវដ្ដៈ ហើយដក (ខ្លួន) ចេញចាកវដ្ដៈទៅដោយពិត ។

ក្នុងកាលចប់ព្រះគាថា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ

មានសោតាបត្តិផលជាដើម ដោយប្រការយ៉ាងនេះឯង ។

ចប់ រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប

# ៧. រឿងសក្កទេវរាជ

ព្រះសាស្ដា កាលទ្រង់ប្រថាប់នៅក្នុងក្រុងវេសាលី ប្រថាប់ក្នុងកូដាគារសាលា ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទេន មឃវា** (ស្ដេចមឃវ:... ព្រោះសេចក្ដីមិនប្រមាទ) ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ស្ដេចលិច្ឆវីព្រះនាមមហាលិ ដែលគ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងវេសាលី ។ ព្រះអង្គទ្រង់ស្ដាប់នូវទេសនានៃសក្កបញ្ហសូត្ររបស់ព្រះតថាគតហើយ ទ្រង់ព្រះតម្រិះថា "ព្រះសម្ពុទ្ធ រមែងត្រាស់នូវសម្បត្តិរបស់សក្កទេវរាជទុកជាច្រើន ព្រះអង្គទ្រង់ឃើញហើយ ទើបត្រាស់ ឬទ្រង់មិនឃើញ ទើបត្រាស់? ទ្រង់ស្គាល់សក្កទេវរាជ ឬក៏មិនស្គាល់ហ្ន៎ ? យើងនឹងទូលសួរព្រះអង្គ" ។ គ្រានោះ ស្ដេចលិច្ឆវីព្រះនាមមហាលិ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះស្ដេចលិច្ឆវីគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន ស្ដេចសក្ក ដែលជាធំជាងទេវតាទាំងឡាយ ព្រះមានព្រះភាគ (ព្រះអង្គ) ទ្រង់ឃើញមែនឬ?" ព្រះមានព្រះភាគត្រាស់ថា "មហាលិ ស្ដេចសក្កៈជាធំ

ជាងទេវតាទាំងឡាយ តថាគតឃើញដែរ" ។ មហាលិទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ស្តេចសក្កៈនោះក្លែងក្លាយ ឬក៏ពិត ព្រោះថា ស្តេចសក្កៈជាធំជាងទេវតាទាំងឡាយ បុគ្គលឃើញបានដោយលំបាក" ។ ព្រះមាន-ព្រះភាគត្រាស់ថា "មហាលិ តថាគតស្គាល់ច្បាស់នូវសក្កទេវរាជផង ទាំងធម៌ធ្វើសត្វឲ្យបានជាសក្កទេវរាជផង ក៏សក្កទេវរាជ បានដល់នូវភាវៈនៃខ្លួនជាសក្កៈ ព្រោះតែសមាទានធម៌ណា តថាគតក៏ដឹងច្បាស់នូវធម៌នោះផង" ។

មហាលិ សក្កៈជាធំជាងទេវតាទាំងឡាយ កាលកើតជាមនុស្ស ជាមាណពឈ្មោះ មឃៈ ព្រោះដូច្នោះ គេទើបហៅថា **មឃវា** ។

មហាលិ សក្កៈជាធំជាងទេវតាទាំងឡាយ កាលកើតជាមនុស្ស បានឲ្យទានមុនគេ ព្រោះដូច្នោះ គេទើបហៅថា **បុរិន្ទទៈ** ។

មហាលិ សក្កៈជាធំជាងទេវតាទាំងឡាយ កាលកើតជាមនុស្ស បានឲ្យទានដោយគោរព ព្រោះដូច្នោះ គេទើបហៅថា **សក្កៈ** ។

មហាលិ សក្កៈជាធំជាងទេវតាទាំងឡាយ កាលកើតជាមនុស្ស បានឲ្យទីស្នាក់អាស្រ័យ ព្រោះដូច្នោះ គេទើបហៅថា **វាសវៈ** ។

មហាលិ សក្កៈជាធំជាងទេវតាទាំងឡាយ ទ្រង់ត្រិះរិះសេចក្តីទាំងពាន់

បានសួមរ្បីតែមួយរំពេច ព្រោះដូច្នោះ គេទើបហៅថា **សហស្សក្ខៈ**[១] ។

មហាលិ អសុរកញ្ញាឈ្មោះសុជាតា ជាបជាបតីរបស់សក្កៈជាធំជាង ទេវតាទាំងឡាយ ព្រោះដូច្នោះ គេទើបហៅថា **សុជម្បតី** ។

មហាលិ សក្កៈជាធំជាងទេវតាទាំងឡាយ សោយរាជសម្បត្តិជាឥស្សរិយាធិបតីលើពួកទេវតាជាន់តាវត្តិង្ស ព្រោះដូច្នោះ គេទើបហៅថា **ទេវានមិន្ទៈ** ។

មហាលិ សក្កៈដល់ភាពជាសក្កៈ ព្រោះបានសមាទានវត្តបទ ៧ ណា វត្តបទ ៧ នោះ បានជាសក្កៈជាធំជាងទេវតាទាំងឡាយ កាលនៅជាមនុស្ស បានសមាទានឲ្យបរិបូណ៌ហើយនូវវត្តបទ ៧ ប្រការដូចម្ដេច គឺ យើងត្រូវចិញ្ចឹមមាតាអស់មួយជីវិត ១ ជាអ្នកមានប្រក្រតីប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូលអស់មួយជីវិត ១ ត្រូវមានវាចាផ្អែមល្ហែមអស់មួយជីវិត ១ មិនមានវាចាញុះញង់អស់មួយជីវិត ១ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ ជាអ្នកមានការបរិច្ចាគ មានបាតដៃលាងស្អាត[២] ត្រេកអរក្នុងការលះបង់ ជាអ្នកគួរដល់ការសូម ត្រេកអរក្នុងការចែកទាន ហើយនៅ

---

១-សហស្សក្ខ : អ្នកឃើញអត្ថទាំងពាន់ , ២-ន័យថា ត្រៀមវត្ថុឲ្យទាន ។

គ្រប់គ្រងផ្ទះអស់មួយជីវិត ១ ជាអ្នកមានវាចាសច្ចៈអស់មួយជីវិត ១ ជាអ្នកមិនក្រោធអស់មួយជីវិត ប្រសិនបើសេចក្ដីក្រោធកើតឡើងដល់អាត្មាអញ អាត្មាអញត្រូវបន្ទោបង់នូវសេចក្ដីក្រោធនោះភ្លាម ១ ។ មហាលិ សក្កៈជាធំជាងទេវតា ព្រោះបានសមាទានវត្តបទ ៧ ណា វត្តបទ ៧ នោះ មានដល់សក្កៈជាធំជាងទេវតាទាំងឡាយ កាលកើតជាមនុស្សក្នុងកាលមុន បានសមាទានឲ្យបរិបូណ៌ហើយ ដូច្នេះ ។

(ព្រះមានព្រះភាគ លុះត្រាស់នូវព្រះសូត្រនេះហើយ បានត្រាស់ព្រះពុទ្ធវចនៈខាងក្រោយថា) ៖

ពួកទេវតានៅឋានតាវត្តិង្ស ហៅបុគ្គលអ្នកចិញ្ចឹមមាតាបិតា
មានប្រក្រតីប្រព្រឹត្តគោរពកោតក្រែងបុគ្គលជាធំក្នុងត្រកូល
មានវាចាពីរោះផ្អែមល្ហែម លះបង់វាចាស៊កសៀត ប្រកប
ក្នុងការកម្ចាត់សេចក្ដីកំណាញ់ មានសច្ចវាចា គ្របសង្កត់
សេចក្ដីក្រោធនោះឯងថា ជាសប្បុរស ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "មហាលិ កម្មនេះសក្កទេវរាជបានធ្វើទុកហើយក្នុងកាលដែលខ្លួននៅជាមាណពឈ្មោះ មឃមាណព" ដូច្នេះ

ដែលមហាលិលិច្ឆវី ប្រាថ្នានឹងស្តាប់វត្តបដិបត្តិរបស់សក្កទេវរាជនោះដោយពិស្តារ ទើបទូលសួរទៀតថា “មឃមាណព បដិបត្តិដូចម្តេច?” ទើបត្រាស់ថា “មហាលិ បើដូច្នោះ ទ្រង់ចូរស្តាប់ចុះ” ដូច្នេះ ទើបទ្រង់នាំអតីតនិទានមក (ត្រាស់ថា) ៖

ក្នុងអតីតកាល មាណពឈ្មោះមឃៈ នៅក្នុងអចលគ្រាម ក្នុងដែនមគធៈ ទៅកាន់កន្លែងធ្វើការងារក្នុងស្រុក ឈូសនូវអាចម៍ដីដោយចុងជើងក្នុងទីដែលខ្លួនឈរ បានធ្វើឲ្យជារមណីយដ្ឋានហើយអាស្រ័យនៅ បុរសដទៃក៏យកដៃច្រានគេនាំចេញអំពីទីនោះឯង ហើយបានអាស្រ័យនៅក្នុងទីនោះវិញ ។ មឃមាណពមិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឲ្យជារមណីយដ្ឋានហើយក៏ស្នាក់នៅ ។ បុរសទាំងឡាយដែលចេញអំពីផ្ទះ ក៏យកដៃច្រានមឃមាណពចេញអំពីទីដែលគេជម្រះហើយ ដោយប្រការដូច្នេះ ។ មឃមាណពគិតថា “ជនទាំងអស់នោះ ជាអ្នកបានទទួលសេចក្តីសុខហើយ កម្មនេះ ជាបុញ្ញកម្មដែលឲ្យសេចក្តីសុខដល់យើង” ។ លុះថ្ងៃស្អែកឡើង បានកាន់យកចបទៅធ្វើទីជាមណ្ឌលប្រមាណប៉ុនលាន ឲ្យជារមណីយដ្ឋាន ។ ជនទាំងពួងបានទៅសម្រាកនៅក្នុងទីនោះឯង ។ លុះដល់រដូវរងា គេបាន

បំពក់ភ្លើងឲ្យដល់ជនទាំងនោះ ក្នុងរដូវក្ដៅ បានឲ្យទឹក ។ តមក គេគិតថា "ដែលឈ្មោះថា រមណីយដ្ឋាន រមែងជាទីស្រឡាញ់នៃជនទាំងពួង ដែលឈ្មោះថា មិនជាទីស្រឡាញ់នៃជនណាមួយមិនមាន ចាប់តាំងអំពីនេះទៅ យើងគួរដើរធ្វើផ្លូវឲ្យរាបស្មើ" ដូច្នេះ ហើយក៏ចេញអំពីផ្ទះពីព្រលឹមធ្វើផ្លូវឲ្យរាបស្មើ កាត់ឫសឈើ មែកឈើ ដែលគួរកាត់ចេញ ។ ខាងក្រោយមក បុរសម្នាក់ទៀតឃើញគេហើយ ពោលថា "ម្នាលសម្លាញ់ លោកធ្វើអ្វី?"

មឃ:. សម្លាញ់ ខ្ញុំធ្វើផ្លូវសម្រាប់ទៅកាន់ឋានសួគ៌ ។

បុរស. បើដូច្នោះ សូម្បីខ្ញុំក៏នឹងជាសម្លាញ់របស់លោកដែរ ។

មឃ:. សម្លាញ់ អ្នកចូរជាសម្លាញ់របស់ខ្ញុំចុះ ធម្មតាឋានសួគ៌រមែងជាទីស្រឡាញ់ ជាទីពេញចិត្តនៃជនជាច្រើន ។

ចាប់ពីពេលនោះមក ក៏បានបុរសនោះជាសម្លាញ់នឹងគ្នា ២ នាក់ ។ សូម្បីបុរសដទៃទៀត ឃើញជនទាំង ២ នាក់នោះហើយ សួរហើយដូចគ្នាដែរ លុះដឹងហើយក៏ជាសម្លាញ់នៃជនទាំង ២ នាក់នោះ សូម្បីជនដទៃៗទៀត ក៏បានធ្វើហើយដោយប្រការយ៉ាងនោះ រួមទាំងអស់បាន ៣៣ នាក់ ដោយប្រការដូច្នេះ ។ ជនទាំងអស់នោះ មានដៃកាន់វត្ថុ មានចបជាដើម

ធ្វើផ្លូវឲ្យរាបស្មើក្នុងទីប្រមាណ ១ យោជន៍ ២ យោជន៍ ។ មេស្រុកឃើញបុរសទាំងនោះហើយគិតថា "មនុស្សទាំងនេះ ប្រកបកិច្ចការងារក្នុងឋានៈដែលមិនគួរប្រកប ប្រសិនបើជនទាំងនេះ គប្បីនាំនូវវត្ថុទាំងឡាយមានត្រីនិងសាច់ជាដើមមកអំពីព្រៃ ឬធ្វើសុរាហើយផឹក ឬធ្វើកម្មយ៉ាងដទៃ យើងនឹងគប្បីបានចំណែកអ្វីៗ ខ្លះមិនខាន" ។ គ្រានោះ ចៅហ្វាយស្រុកក៏បានបញ្ជាឲ្យគេហៅជនទាំងនោះមក សួរថា "ពួកអ្នកដើរធ្វើអ្វី?" ជនទាំងនោះពោលថា "ធ្វើផ្លូវសួគ៌ លោក" ។ ចៅហ្វាយស្រុកពោលថា ធម្មតាបុគ្គលដែលនៅគ្រប់គ្រងផ្ទះទាំងឡាយ នឹងធ្វើយ៉ាងនោះមិនគួរ គួរនាំវត្ថុទាំងឡាយមានត្រី និងសាច់ជាដើមមកអំពីព្រៃ គួរធ្វើសុរាហើយផឹក និងគួរធ្វើការងារទាំងឡាយ មានប្រការផ្សេង ៗ ។ ជនទាំងនោះជំទាស់នឹងពាក្យរបស់ចៅហ្វាយស្រុកនោះ ។ សូម្បីត្រូវចៅហ្វាយស្រុកពោលរឿយៗ ក៏នៅតែជំទាស់រឿយៗ ដែរ ។ ចៅហ្វាយស្រុកក៏ក្រោធខឹង ហើយគិតថា "យើងនឹងឲ្យពួកវាវិនាស" ទើបទៅកាន់សំណាក់របស់ព្រះរាជា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញចោរត្រាច់ទៅដោយការចងគ្នាជាពួក" កាលព្រះរាជាត្រាស់ថា "អ្នកចូរទៅ ចូរចាប់ពួកវាហើយនាំមក" បានធ្វើតាមព្រះ

រាជបញ្ជា ហើយសម្ដែងជនទាំងនោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់មិនទាន់បានពិចារណា ទ្រង់ក៏ត្រាស់បង្គាប់ថា "ពួកអ្នកចូរញ៉ាំងដំរីឲ្យជាន់ពួកវា" ។ មយមាណពបានឲ្យឱវាទដល់ជនដ៏សេសទាំងឡាយថា "ម្នាលសម្លាញ់ទាំងឡាយ វៀរមេត្តាចេញហើយ ទីពឹងយ៉ាងដទៃរបស់ពួកយើងមិនមាន អ្នកទាំងឡាយចូរកុំធ្វើនូវសេចក្ដីក្រោធក្នុងបុគ្គលណាៗ ឡើយ ចូរជាអ្នកមានចិត្តស្មើដោយមេត្តាក្នុងព្រះរាជាផង ក្នុងចៅហ្វាយស្រុកផង ក្នុងដំរីដែលនឹងជាន់យើងផង និងក្នុងខ្លួនឯងផង" ជនទាំងនោះក៏បានធ្វើហើយដោយប្រការយ៉ាងនោះ ។ គ្រានោះ ដំរីក៏មិនហ៊ានចូលទៅជិត ព្រោះអានុភាពនៃមេត្តារបស់ជនទាំងនោះ ។ ព្រះរាជាទ្រង់ស្ដាប់នូវសេចក្ដីនោះហើយ ត្រាស់ថា "ដំរីឃើញមនុស្សច្រើន ទើបមិនហ៊ានចូលទៅជាន់ អ្នកទាំងឡាយចូរទៅចូរយកកន្ទេលផែងគ្របពួកវាហើយ ញ៉ាំងដំរីឲ្យជាន់ចុះ" ។ ដំរីដែលរាជ-បុរសទាំងឡាយយកកន្ទេលផែងគ្របជនទាំងនោះ ហើយបញ្ជូនទៅដើម្បីឲ្យជាន់ ក៏ត្រឡប់ជាថយចេញកាន់តែឆ្ងាយ ។ ព្រះរាជាទ្រង់ស្ដាប់នូវព្រឹត្តិ-ការណ៍នោះហើយ ទ្រង់ព្រះចិន្ដាថា "ក្នុងរឿងនេះប្រាកដជាមានហេតុកេទអ្វីដោយពិត" ហើយត្រាស់បង្គាប់ឲ្យរាជបុរសហៅជនទាំងនោះមកគាល់ ត្រាស់

សួរថា “ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយអាស្រ័យយើង មិនបានទូវអ្វីឬ” ។

ពួកមយៈ. ព្រះសម្មតិទេព សេចក្តីនេះ ដូចម្តេច?

ព្រះរាជា. បានឮថា ពួកអ្នកជាចោរត្រាច់ទៅក្នុងព្រៃ ដោយការចងគ្នាជាពួក ។

ពួកមយៈ. បពិត្រព្រះសម្មតិទេព នរណាទូលព្រះអង្គយ៉ាងនោះ ។

ព្រះរាជា. ចៅហ្វាយស្រុកបានប្រាប់យើង ។

ពួកមយៈ. ព្រះសម្មតិទេព ទូលព្រះបង្គំទាំងឡាយមិនមែនជាចោរទេ ទូលបង្គំទាំងឡាយជម្រះផ្លូវទៅសួគ៌របស់ខ្លួនៗ ទើបធ្វើនូវកម្មនេះ និងកម្មនេះ ចៅហ្វាយស្រុកណែនាំពួកទូលបង្គំឲ្យធ្វើនូវអំពើអកុសល ប្រាថ្នានឹងឲ្យទូលបង្គំទាំងឡាយដែលមិនធ្វើតាមពាក្យរបស់ខ្លួនវិនាស ក្រោធខឹងហើយ ទើបក្រាបទូលព្រះអង្គយ៉ាងនោះ ។ គ្រានោះ ព្រះរាជាទ្រង់ស្តាប់នូវវាចារបស់ជនទាំងនោះ ក៏ទ្រង់ដល់ហើយនូវសោមនស្ស ត្រាស់ថា “ម្នាលអ្នកទាំងឡាយ សត្វតិរច្ឆាននេះអាចដឹងនូវគុណរបស់អ្នកទាំងឡាយ ប៉ុន្តែយើងជាមនុស្សឲ្យត្រឡាំង ក៏មិនអាចដឹងគុណរបស់អ្នកទាំងឡាយ សូមអ្នក

ទាំងឡាយអត់ទោសឲ្យយើងផងចុះ” លុះត្រាស់យ៉ាងនោះហើយ ទ្រង់បាន ព្រះរាជទានចៅហ្វាយស្រុកព្រមទាំងបុត្រ និងភរិយាឲ្យជាទាសៈ ដំរីនោះ ឲ្យជាពាហនៈសម្រាប់ជិះ ហើយព្រះរាជទានស្រុកនោះឲ្យជាគ្រឿងប្រើប្រាស់ តាមសប្បាយដល់ជនទាំងនោះ ។ ពួកគេនិយាយគ្នាថា “ពួកយើងឃើញ អានិសង្សនៃបុណ្យក្នុងបច្ចុប្បន្ននេះឯង” ម្នាក់ៗ មានចិត្តជ្រះថ្លាដ៏ក្រៃលែង ផ្លាស់វេនគ្នាឡើងកាន់ដំរីនោះ ធ្វើដំណើរទៅបណ្ដើរ ប្រឹក្សាគ្នាបណ្ដើរថា “ឥឡូវនេះ ពួកយើងគួរធ្វើបុណ្យឲ្យវិសេសក្រៃលែងឡើង”ម្នាក់ៗ សាកសួរ គ្នាថា “ពួកយើងនឹងធ្វើយ៉ាងណា” ក៏សម្រេចគ្នាថា “នឹងសាងសាលាជាទី សម្រាកនៃមហាជន ឲ្យជារបស់មាំមួនក្នុងផ្លូវធំបែកជា ៤” ។ មឃមាណព និងសម្លាញ់របស់ខ្លួន ក៏បានស្វែងរកជាងឈើមកហើយ ផ្ដើមសាងសាលា ប៉ុន្តែថា ព្រោះខ្លួនមិនពេញចិត្តក្នុងមាតុគ្រាម ទើបមិនបានឲ្យចំណែកបុណ្យ ក្នុងសាលានោះដល់មាតុគ្រាមទាំងឡាយ ។

ក៏ក្នុងផ្ទះមឃមាណព មានស្ត្រី ៤ នាក់ គឺ នាងសុនន្ទា សុចិត្រា សុធម្មា សុជាតា ។ បណ្ដាស្ត្រីទាំង ៤ នាក់នោះ នាងសុធម្មាគិតឧបាយនឹង ជាងឈើ ហើយពោលថា “អ្នកបង សូមបងធ្វើខ្ញុំឲ្យជាធំក្នុងសាលានេះ

ចុះ” ដូច្នេះ ហើយបានឲ្យនូវសំណូក (ដល់ជាងឈើ) ជាងឈើនោះទទួលយល់ព្រមថា “បាន” ហើយហាលឈើសម្រាប់ធ្វើហោជាងឲ្យស្ងួតមុនគ្រឿងដទៃ ហើយឈូស ធ្លាក់ធ្វើហោជាងឲ្យសម្រេច ធ្លាក់អក្សរទាំងឡាយថា “សាលានេះឈ្មោះសុធម្មា” ដូច្នេះហើយ យកសំពត់រុំទុក ។ លុះជាងឈើសាងសាលាស្រេចហើយ ក្នុងថ្ងៃលើកហោជាង ក៏ពោលទៅកាន់ជនទាំង ៣៣ នាក់នោះថា “ស្លាប់ហើយនាយ ខ្ញុំនឹកមិនឃើញនូវកិច្ចដែលគួរធ្វើមួយ” ។

ពួកមឃៈ. អ្នកដ៏ចម្រើន អ្នកនឹកមិនឃើញដល់កិច្ចអ្វី ។

ជាង. បពិត្រនាយ ហោជាង ។

ពួកមឃៈ. អ្នកដ៏ចម្រើន ហេតុនោះចូរលើកទុកសិនចុះ ពួកយើងនឹងនាំហោជាងនោះមកដោយខ្លួនឯង ។

ជាង. ខ្ញុំមិនអាចធ្វើដោយឈើ ដែលបុគ្គលទើបតែកាត់ហើយក្នុងកាលឥឡូវនេះបានទេ ការបាននូវហោជាងដែលបុគ្គលកាត់ហើយ ឈូសហើយ ធ្លាក់ហើយ តម្កល់ទុកក្នុងកាលមុននោះឯង ទើបសមគួរ ។

ពួកមឃៈ. ឥឡូវនេះ ពួកយើងគួរធ្វើដូចម្តេច ។

ជាង. ប្រសិនបើក្នុងផ្ទះរបស់អ្នកណាៗ មានហោជាងសម្រាប់លក់

ដែលគេធ្វើស្រេចហើយតម្កល់ទុកសោត គួរស្វែងរកហោជាងនោះមក ។

ពួកមយមាណពទាំង ៣៣ នាក់ ស្វែងរកនូវហោជាង ក៏ឃើញមាននៅក្នុងផ្ទះរបស់នាងសុធម្មា ហើយឲ្យទ្រព្យ ១.០០០ ដើម្បីឲ្យនាងសុធម្មាប្រគល់នូវហោជាងដល់ខ្លួន ក៏មិនបាននូវហោជាងនោះ ដោយទ្រព្យដែលជាតម្លៃ កាលនាងសុធម្មានិយាយថា "ប្រសិនបើ ពួកលោកធ្វើខ្ញុំឲ្យជាស្ត្រីមានចំណែកបុណ្យក្នុងសាលានោះសោត ខ្ញុំនឹងឲ្យ" ។ ឆ្លើយថា "ពួកខ្ញុំមិនឲ្យនូវចំណែកបុណ្យដល់ពួកមាតុគ្រាមទេ" ។ គ្រានោះ ជាងឈើក៏បានពោលទៅកាន់ជនទាំងនោះថា "បពិត្រនាយ លោកនិយាយអ្វី? វៀរព្រហ្មលោកចេញ ទីដទៃៗ ដែលឈ្មោះថា ជាទីវៀរមាតុគ្រាមចេញរមែងមិនមាន ពួកលោកចូរទទួលយកហោជាងនោះចុះ កាលបើដូច្នោះ ការងាររបស់ពួកយើងក៏នឹងដល់នូវការសម្រេច" ។ ពួកជនទាំង ៣៣ នាក់នោះ ក៏យល់ព្រមថា "ប្រពៃហើយ" ហើយទទួលយកហោជាងនោះទៅ ញ៉ាំងសាលាឲ្យសម្រេច ហើយបែងជា ៣ ចំណែក គឺ មួយចំណែកសម្រាប់ជាទីនៅនៃពួកឥស្សរ-ជន មួយចំណែកសម្រាប់ជនទុគ៌តទាំងឡាយ មួយចំណែកទៀត សម្រាប់មនុស្សឈឺទាំងឡាយ ។ ជនទាំង ៣៣ នាក់ ឲ្យគេក្រាលបន្ទះក្តារ ៣៣ បន្ទះ

ហើយឲ្យសញ្ញាដល់ជំរឺថា "កាលភ្ញៀវមកអង្គុយលើបន្ទះក្តារ ដែលបុគ្គលណាក្រាលទុក អ្នកចូរនាំភ្ញៀវនោះទៅកាន់ផ្ទះនៃបុគ្គលជាម្ចាស់បន្ទះក្តារនោះចុះ ការប្របាច់ជើង ការប្របាច់ខ្នង របស់ដែលគួរទំពា និងរបស់ដែលគប្បីបរិភោគ ទីដេកទាំងឡាយគ្រប់យ៉ាង នឹងជាភារៈនៃបុគ្គលដែលជាម្ចាស់នៃបន្ទះក្តារនោះ" ។ ជំរឺទទួលអ្នកដែលមកហើយៗ នាំទៅកាន់ផ្ទះបុគ្គលជាម្ចាស់នៃបន្ទះក្តារនោះឯង ។ ក្នុងថ្ងៃនោះ ម្ចាស់បន្ទះក្តារនោះរមែងធ្វើកិច្ចដែលគួរធ្វើដល់អ្នកដែលជំរឺនាំទៅនោះ ។ មឃមាណពបានដាំដើមរលួសផ្អុងមួយដើម ក្នុងទីមិនឆ្ងាយអំពីសាលា ហើយក្រាលផ្ទាំងថ្មក្បែរគល់រលួសផ្អុងនោះ ។ ពួកជនដែលចូលទៅកាន់សាលាហើយ ក្រឡេកមើលហោជាងអានអក្សរទាំងឡាយហើយ រមែងនិយាយគ្នាថា "សាលាឈ្មោះសុធម្មា" ឈ្មោះរបស់ជនទាំង ៣៣ នាក់មិនប្រាកដ ។ នាងសុនន្ទាគិតថា ជនទាំងនេះ កាលធ្វើសាលា ធ្វើពួកយើងមិនឲ្យជាអ្នកមានចំណែកនៃបុណ្យផង ឯនាងសុធម្មា ក៏ធ្វើហោជាងចូលរួមចំណែកទាល់តែបាន ព្រោះនាងជាស្ត្រីឈ្លាសវៃ យើងក៏គួរនឹងធ្វើនូវកុសលកម្មអ្វីមួយ យើងនឹងធ្វើនូវអ្វីហ្ន៎? ។ គ្រានោះឯង នាងក៏មានការគិតដូច្នេះថា "ពួកជនដែលមកកាន់សាលាគួរនឹង

បានទឹកផឹក និងទឹកងូត យើងនឹងឲ្យគេជីកស្រះបោក្ខរណី” នាងសុនន្ទាក៏បាន ញុំាងបុគ្គលឲ្យជីកស្រះបោក្ខរណីមួយ ។ នាងសុចិត្រាគិតថា “នាងសុធម្មា បានឲ្យហោជាង នាងសុនន្ទាបានសាងស្រះបោក្ខរណី យើងក៏គួរសាងនូវ កុសលអ្វីមួយដែរ យើងនឹងធ្វើអ្វីហ្ន៎” ។ គ្រានោះ នាងមានការគិតដូច្នេះថា “ក្នុងកាលដែលពួកជនមកកាន់សាលា ផឹកទឹក ងូតទឹកហើយទៅ គួរប្រដាប់ នូវកម្រងផ្កា ទើបទៅរមែងសមគួរ យើងនឹងសាងសួនផ្កា” នាងបានឲ្យគេ សាងសួនផ្កាមួយដ៏ជាទីមនោរម្យ ។ មិនធ្លាប់មានអ្នកដែលនឹងនិយាយថា “ដោយច្រើនក្នុងសួននោះ ដើមឈើដែលមិនចេញផ្កាចេញផ្លែឯណោះ” ដូច្នេះ ឡើយ ។ ចំណែកនាងសុជាតា គិតថា “យើងជាជីតានៃឪពុកធំរបស់មឃះ ផង ទាំងជាបាទបរិចារិកា (ភរិយា) ផង កម្មដែលមឃមាណពនោះធ្វើ ហើយ ក៏ជារបស់យើងដែរ កម្មដែលយើងធ្វើហើយ ក៏ជារបស់មឃមាណព នោះដែរ” ដូច្នេះ មិនបានធ្វើនូវកុសលអ្វីៗ ទាំងអស់ ខំប្រឹងតែស្អិតស្អាង រាងកាយរបស់ខ្លួនប៉ុណ្ណោះ ញុំាងកាលឲ្យកន្លងហួសទៅ ។

## មឃមាណពបំពេញវត្តបទ ៧ ប្រការ

ចំណែកមឃមាណព បំពេញវត្តបទ ៧ ប្រការនេះ គឺ បម្រើមាតា

បិតា ១ ប្រព្រឹត្តឱនលំទោនគោរពបុគ្គលជាធំក្នុងត្រកូល ១ ពោលពាក្យសច្ចៈ ១ មិនពោលនូវវាចាទ្រគោះ ១ មិនពោលពាក្យញុះញង់ ១ កម្ចាត់បង់នូវសេចក្តីកំណាញ់ ១ មិនក្រោធ ១ ដល់នូវភាពជាអ្នកគួរសរសើរយ៉ាងនេះថា ៖

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតា
បិតា គោរពកោតក្រែងបុគ្គលជាធំក្នុងត្រកូល មានវាចា
ពីរោះផ្អែមល្ហែម លះបង់វាចាស៊កសៀត ប្រកបតែក្នុង
ការកម្ចាត់នូវសេចក្តីកំណាញ់ មានវាចាពិត គ្របសង្កត់
សេចក្តីក្រោធបាន ថា ជាសប្បុរស ។

ក្នុងវេលាអស់ជីវិត ក៏បានកើតជាសក្កទេវរាជក្នុងភពតាវត្តិង្ស ។ សម្លាញ់របស់មឃមាណពនោះ ក៏ទៅកើតក្នុងទីនោះដែរ ។ ជាងឈើបានកើតជាវិស្សុកម្មទេវបុត្រ ។

ក្នុងកាលនោះ ពួកអសុរនៅក្នុងភពតាវត្តិង្ស អសុរទាំងនោះ គិតថា "ទេវបុត្រថ្មីៗ កើតហើយ ទើបចាត់ចែងនូវទឹកទិព្វ ។ សក្កទេវរាជបានឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គ ក្នុងបំណងមិនឲ្យនរណាៗ ផឹក ។ ពួកអសុរ

ផឹកនូវទឹកទិព្វ ស្រវឹងទាំងអស់គ្នា ។ សក្កទេវរាជទ្រង់គិតថា "យើងត្រូវអ្វី ដោយភាពជារាជាទូទៅដល់ពួកអសុរទាំងនេះ" ទ្រង់ឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គហើយ បញ្ជាឲ្យជួយគ្នាចាប់អសុរទាំងនោះត្រង់ជើងទាំង ២ បោះទៅក្នុងមហាសមុទ្រ ។ អសុរទាំងនោះមានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងមហាសមុទ្រ ខណៈនោះ អសុរវិមានបានកើតនាផ្ទៃខាងក្រោមនៃភ្នំសិនេរុ ដោយអានុភាពបុណ្យរបស់ពួកអសុរ ។ ដើមឈើឈ្មោះ ចិត្តបាលិ (ដើមប្រទៀង) ក៏កើតហើយដែរ ។ កាលពួកអសុរបរាជ័យក្នុងសង្គ្រាមរវាងទេវតា និងអសុរ ឈ្មោះថា ទេវនគរក្នុងជាន់តាវត្តិង្សប្រមាណមួយម៉ឺនយោជន៍ កើតឡើងហើយ ។ ម្យ៉ាងទៀត ក្នុងចន្លោះទ្វារទិសខាងកើត និងទិសខាងលិចនៃព្រះនគរនោះ ក៏មានផ្ទៃដីប្រមាណមួយម៉ឺនយោជន៍ដូចគ្នា ចន្លោះទ្វារទិសខាងត្បូង និងទិសខាងជើង ក៏មានផ្ទៃដីប្រមាណប៉ុណ្ណោះដែរ ។ ម្យ៉ាងទៀត ព្រះនគរនោះ ប្រកបដោយទ្វារ ១.០០០ ប្រដាប់ដោយឧទ្យាន និងស្រះបោក្ខរណី ។ ប្រាសាទឈ្មោះ **វេជយន្ត** កំពស់ ៧០០ យោជន៍ សម្រេចហើយដោយកែវ ៧ ប្រការ ប្រដាប់ដោយទង់ទាំងឡាយកំពស់ ៣០០ យោជន៍ ផុសឡើងដោយផលនៃបុណ្យកសាងសាលា ត្រង់

កណ្ដាលព្រះនគរនោះ ។ ជង់ទង់ធ្វើអំពីមាសមានទង់ជាកែវមណី ជង់ទង់ធ្វើអំពីកែវមណីមានទង់ជាមាស ជង់ទង់ធ្វើអំពីកែវប្រវាឡមានទង់ជាកែវមុក្តា ជង់ទង់ធ្វើអំពីកែវមុក្តាមានទង់ជាកែវប្រវាឡ ជង់ទង់ជាកែវ ៧ ប្រការ ក៏មានទង់ជាកែវ ៧ ប្រការ ។ ជង់ទង់ដែលតាំងនៅត្រង់កណ្ដាល មានកំពស់ ៣០០ យោជន៍ ។ ប្រាសាទកំពស់ ១.០០០ យោជន៍ ប្រកបសុទ្ធដោយកែវ ៧ ប្រការ កើតហើយដោយផលបុណ្យនៃការកសាងសាលា ដោយប្រការដូច្នេះ ។ ដើមបារិច្ឆត្តកៈ មានបរិមណ្ឌល (ផ្សាយទៅ) ៣០០ យោជន៍ដោយជុំវិញ កើតឡើងហើយដោយផលនៃការដាំដើមល្ហុសផ្អុង ។ បណ្ឌុកម្ពលសិលា មានពណ៌ដូចផ្កាជ័យព្រឹក្ស[១] ពណ៌នៃទឹកល័ក្ក និងពណ៌ក្រហមទន់[២] មានបណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កំរាស់ ១៥ យោជន៍ បណ្ឌុកម្ពលសិលាសនៈនេះ ក្នុងវេលាដែលសក្កទេវរាជប្រថាប់គង់ហើយ កាយពាក់កណ្ដាលក៏លិចចុះទៅ ក្នុងកាលដែលសក្កទេវរាជក្រោកឡើង រមែងប៉ោងឡើងពេញបរិបូណ៌ដូចដើមវិញ កើតឡើងហើយទៀបគល់នៃដើមបារិច្ឆត្តកៈ ដោយផលនៃការក្រាលផ្ទាំងសិលា ។ ចំណែកដំរី កើតជាទេវបុត្រ

១ ជយសុមនៈ ឈ្មោះដើមឈើមានផ្កាក្រហម ដូចជាដើមផ្កាសេរីមាន់ជាដើម , ២ សេត្រគ្គនិសេប្បា បាដលោ នាម ពណ៌ក្រហមលាយខៀវ , ក្រហមស៊ីជំពូ ។

ឈ្មោះឯរាវ័ណ ។ ពិតណាស់ សត្វតិរច្ឆានទាំងឡាយរមែងមិនមានក្នុងទេវ-លោក ព្រោះហេតុនោះ ក្នុងកាលដែលសក្កទេវរាជស្ដេចចេញទៅ ដើម្បីក្រសាលនៅក្នុងរាជឧទ្យាន ទេវបុត្រនោះក៏និម្មិតខ្លួនជាដំរី ឈ្មោះឯរាវ័ណកំពស់ ១៥០ យោជន៍ ។ ដំរីទេវបុត្រនោះ និម្មិតពោង ៣៣ ដើម្បីប្រយោជន៍ដល់ជនទាំង ៣៣ នាក់ ក្នុងបណ្ដាពោងទាំងនោះ ពោងនីមួយៗដោយចំណែកមូល ៣ គាវុត ដោយចំណែកខាងបណ្ដោយកន្លះយោជន៍ ។ ទេវបុត្រនោះនិម្មិតពោង ឈ្មោះសុទស្សនៈ ប្រមាណ ៣០ យោជន៍ នៅត្រង់កណ្ដាលពោងទាំងអស់ ដើម្បីប្រយោជន៍ដល់សក្កទេវរាជ ។ ខាងលើពោងនោះ មានមណ្ឌបកែវប្រមាណ ១២ យោជន៍ ។ ទង់កែវ ៧ ប្រការកំពស់ ១ យោជន៍ តាំងឡើងក្នុងចន្លោះៗ ក្នុងមណ្ឌបកែវនោះ ។ ចន្ទោមកណ្ដឹងដែលខ្យល់យ៉ាងស្រទន់បក់ត្រូវហើយ មានសំឡេងដ៏ពីរោះដូចជាសំឡេងទិព្វសង្គីតៈ លាយដោយសំឡេងនៃតន្ត្រីមានអង្គ ៥ រមែងលាន់ឡើងត្រង់ចន្ទោមនៃកណ្ដឹងដែលព្យួរនោះ ។ បល្ល័ង្កកែវមណីប្រមាណ ១ យោជន៍ជាព្រះទីនាំង ដែលគាក់តែងល្អហើយដើម្បីសក្កទេវរាជត្រង់កណ្ដាលមណ្ឌបសក្កទេវរាជរមែងប្រថាប់លើបល្ល័ង្កនោះ ។ ទេវបុត្រ ៣៣ អង្គ អង្គុយលើ

រតនបល្ល័ង្កក្នុងពោងរៀងៗ ខ្លួន ។ បណ្ដាពោងទាំង ៣៣ នោះ ក្នុងពោង នីមួយៗ ជំរឺទេវបុត្រនោះ និម្មិតក្អុកប្រាំពីរៗ ក្នុងបណ្ដាក្អុកទាំងនោះ ក្អុក នីមួយៗ ប្រវែងប្រមាណ ៥០ យោជន៍ ក្នុងក្អុកនីមួយៗ មានស្រះបោក្ខរណី ប្រាំពីរៗ ក្នុងបណ្ដាស្រះបោក្ខរណីទាំងនោះ ស្រះបោក្ខរណីនីមួយៗ មាន គុម្ពឈូកប្រាំពីរៗ ក្នុងបណ្ដាគុម្ពឈូកទាំង ៧ នោះ ក្នុងមួយគុម្ពៗ មាន ផ្កាប្រាំពីរៗ ក្នុងផ្កានីមួយៗ មានត្របកប្រាំពីរៗ ក្នុងត្របកនីមួយៗ មាន ទេពធីតាឈររាំ ៧ អង្គ របាំ និងមហោស្រពទាំងឡាយ រមែងមានលើក្អុក ជំរឺទាំងឡាយក្នុងទីប្រមាណ ៥០ យោជន៍ ដោយជុំវិញយ៉ាងនេះឯង ។ សក្កទេវរាជសោយយសដ៏ធំ ស្ដេចត្រាច់ទៅដោយប្រការដូច្នេះ ។

សុប្បីនាងសុធម្មា ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងភពតា-វត្តិង្សនោះដែរ ។ ទេវសភាឈ្មោះសុធម្មា មានប្រមាណ ៥០០ យោជន៍ បានកើតឡើងហើយដល់នាង ។ បានឮថា ឈ្មោះថា ទីដទៃដែលគួរជាទី រីករាយជាងទេវសភានោះ រមែងមិនមាន ។ ក្នុងថ្ងៃអដ្ឋមី (តិថីទី ៨) នៃ ខែ រមែងមានការស្ដាប់នូវព្រះធម៌ក្នុងទេវសភានោះឯង ។ រហូតដល់សព្វ ថ្ងៃនេះ ជនទាំងឡាយឃើញនូវទីណាមួយដែលគួរជាទីត្រេកអរ រមែងពោល

ប្រាប់គ្នាថា "ដូចជាទេវសកាឈ្មោះសុធម្មា" ។ សូម្បីនាងសុនន្ទា ធ្វើកាល-កិរិយាហើយ ក៏បានទៅកើតក្នុងភពតាវត្តិង្សនោះដែរ ។ ស្រះបោក្ខរណី ឈ្មោះសុនន្ទា មានទំហំប្រមាណ ៥០០ យោជន៍ កើតឡើងហើយដល់នាង សុនន្ទានោះ ។ សូម្បីនាងសុចិត្រា ធ្វើកាលកិរិយាហើយ ក៏ទៅកើតក្នុងភព តាវត្តិង្សនោះដែរ ។ ឧទ្យានឈ្មោះចិត្តលតាវ័ន មានប្រមាណ ៥០០ យោជន៍ ដែលពួកទេវតានាំទេវបុត្រអ្នកមានបុព្វនិមិត្តកើតឡើងហើយ ឲ្យឈ្ងក់វង្វេង ត្រាច់ទៅ កើតឡើងហើយដល់នាងសុចិត្រានោះ ។

ឯនាងសុជាតា ធ្វើកាលកិរិយាហើយ កើតជាកុកញី នៅនាច្រោះភ្នំ មួយ ។ សក្កទេវរាជទ្រង់រមិលមើលនូវនាងបរិចារិការបស់ព្រះអង្គ ទ្រង់ ជ្រាបថា "នាងសុធម្មាកើតហើយក្នុងទីនេះដែរ នាងសុនន្ទា និងនាងសុចិត្រា ក៏យ៉ាងនោះដែរ" ។ ទ្រង់ត្រិះរិះតទៅទៀតថា "នាងសុជាតាកើតទីណាហ្ន៎" ឃើញនាងកើតនៅនាច្រោះភ្នំនោះ ហើយទ្រង់ត្រិះរិះថា "នាងសុជាតានេះ ល្ងង់ខ្លៅ មិនធ្វើបុណ្យអ្វីៗ ឥឡូវនេះ កើតហើយក្នុងកំណើតសត្វតិរច្ឆាន សូម្បីឥឡូវនេះ គួរយើងនឹងញុំាងនាងសុជាតានោះឲ្យធ្វើនូវបុណ្យ ហើយ នាំមកអំពីច្រោះភ្នំនោះ" ដូច្នេះ ទ្រង់ក៏និម្មិតអត្តភាព ស្តេចទៅកាន់សម្នាក់

របស់នាងដោយភេទដែលអ្នកដទៃមិនស្គាល់ ត្រាស់សួរថា "នាងដើរធ្វើអ្វីនៅនាព្រោះក្នុំនេះ" ។

នាងកុក. បពិត្រនាយ លោកជានរណា ?

សក្កទេវរាជ. យើង គឺ មឃមាណព ស្វាមីរបស់នាង ។

នាងកុក. បពិត្រនាយ លោកកើតនៅទីណា ?

សក្កទេវរាជ. យើងកើតនៅក្នុងតាវត្តិង្សទេវលោក តើនាងដឹងថាស្ត្រីដែលជាសម្លាញ់របស់នាងកើតទីណាហើយឬ ?

នាងកុក. បពិត្រនាយ ខ្ញុំមិនដឹងទេ ។

សក្កទេវរាជ. ស្ត្រីទាំងនោះ ក៏កើតក្នុងសំណាក់របស់យើងដែរ នាងប្រាថ្នាទៅសួរសុខទុក្ខស្ត្រីដែលជាសម្លាញ់របស់នាងដែរទេ ?

នាងកុក. ខ្ញុំនឹងទៅកាន់ទីនោះបានដោយប្រការដូចម្ដេច ?

សក្កទេវរាជត្រាស់ថា "យើងនឹងនាំនាងទៅកាន់ទីនោះ" ដូច្នេះ ហើយនាំនាងកុកទៅកាន់ទេវលោក ឲ្យនៅត្រង់មាត់ស្រះបោក្ខរណី ឈ្មោះសុនន្ទាត្រាស់ប្រាប់ព្រះមហេសីទាំង ៣ ក្រៅពីនេះថា "ពួកនាងប្រាថ្នានឹងឃើញនាងសុជាតាដែលជាសម្លាញ់របស់ពួកនាងដែរទេ?"

មហេសី. បពិត្រព្រះឧប្បត្តិទេព នាងសុជាតានៅទីណា ?

សក្កទេវរាជ. នាងឈរនៅមាត់ស្រះបោក្ខរណីឈ្មោះសុនន្ទា ។

ព្រះមហេសីទាំង ៣ នោះ ស្តេចទៅកាន់ទីនោះ ធ្វើការចំអកថា "ឱ! រូបរបស់នាងម្ចាស់ ឱ! ផលនៃការស្អិតស្អាងខ្លួន ឥឡូវនេះ អ្នកទាំងឡាយ ចូរមើលនូវចំពុះ ចូរមើលនូវស្មងទាំងឡាយ ចូរមើលនូវជើងទាំងឡាយ អត្តភាពរបស់ព្រះនាងម្ចាស់ល្អណាស់ហ្ន៎" ដូច្នេះ ហើយក៏ចៀសចេញទៅ ។ សក្កទេវរាជ ស្តេចទៅកាន់សំណាក់របស់នាងទៀត ត្រាស់សួរថា "នាងបានជួបស្ត្រីដែលជាសម្លាញ់របស់នាងហើយឬ?" កាលនាងទូលថា "ព្រះមហេសីទាំង ៣ នោះ ខ្ញុំបានជួបហើយ (គេនាំគ្នា) ពោលចំអកឲ្យខ្ញុំ ហើយក៏ចៀសចេញទៅ សូមព្រះអង្គមេត្តានាំខ្ញុំទៅកាន់ជ្រោះភ្នំនោះវិញចុះ" ដូច្នេះហើយ ក៏ទ្រង់នាំនាងកុកនោះទៅកាន់ជ្រោះភ្នំដូចដើមវិញ លែងទុកក្នុងទីនោះ បានត្រាស់សួរថា "នាងឃើញសម្បត្តិរបស់ស្ត្រីទាំង ៣ នោះហើយឬ" ។

នាងកុក. បពិត្រព្រះឧប្បត្តិទេព ខ្ញុំបានឃើញហើយ ។

សក្កទេវរាជ. សូម្បីនាង ក៏គួរធ្វើនូវឧបាយដែលជាហេតុនាំឲ្យកើតក្នុងទីនោះដែរ ។

នាងកុក. បពិត្រព្រះឧបុត្តិទេព នឹងធ្វើដូចម្ដេច ?

សក្កទេវរាជ. នាងនឹងរក្សានូវឱវាទរបស់យើងបានទេ ?

នាងកុក. បពិត្រព្រះឧបុត្តិទេព ខ្ញុំរក្សាបាន ។

គ្រានោះ សក្កទេវរាជក៏ប្រទានសីល ៥ ឲ្យដល់នាងកុក ទើបត្រាស់ថា "នាងចូរជាអ្នកមិនប្រមាទ រក្សាចុះ" ដូច្នេះហើយ ក៏ស្ដេចចៀសចេញទៅ ។ ចាប់តាំងអំពីនោះមក នាងកុកក៏ដើរស្វែងរកនូវត្រីដែលស្លាប់ឯងប៉ុណ្ណោះ ។ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ សក្កទេវរាជស្ដេចទៅដើម្បីប្រាថ្នានឹងល្បងមើលនូវនាងកុកនោះ ទើបទ្រង់និម្មិតខ្លួនដូចជាត្រីស្លាប់ ដេកផ្ងារពោះនៅលើឆ្នេរខ្សាច់ ។ នាងកុកនោះឃើញត្រីនោះហើយ បានចឹកយកដោយសេចក្ដីសម្គាល់ថា "ត្រីស្លាប់ហើយ" ក្នុងកាលនឹងលេប ត្រីនោះក៏ញ៉ាំងកន្ទុយឲ្យកម្រើក ។ កុកញីនោះដឹងថា "ត្រីនៅរស់" ទើបលែងទៅក្នុងទឹក ។ សក្កទេវរាជទ្រង់ញ៉ាំងកាលបន្តិចឲ្យកន្លងទៅ ហើយទ្រង់ក៏ធ្វើដូចជាដេកផ្ងារពោះនៅអំពីខាងមុខនាងកុកទៀត នាងកុកក៏ចឹកយកទៀត ដោយសម្គាល់ថា "ត្រីស្លាប់" ក្នុងកាលនឹងលេប ឃើញចុងកន្ទុយនៅកម្រើក ក៏លែងទៅវិញ ដោយសម្គាល់ថា "ត្រីនៅរស់" សក្កទេវរាជទ្រង់ល្បងមើលអស់វារៈ ៣ ដង

យ៉ាងនេះ ហើយត្រាស់ថា "នាងរក្សាសីលបានល្អ" ញ៉ាំងនាងកុកឲ្យដឹងច្បាស់នូវព្រះអង្គហើយ ត្រាស់ថា "យើងមកដើម្បីប្រាប្ថានីងល្បងមើលនាង នាងរក្សាសីលបានល្អ កាលនាងរក្សាបានយ៉ាងនេះ មិនយូរប៉ុន្មានក៏នឹងបានទៅកើតក្នុងសំណាក់របស់យើងដោយពិត នាងចូរជាអ្នកមិនប្រមាទចុះ" ដូច្នេះ ហើយស្តេចក៏ចៀសចេញទៅ ។ ចាប់តាំងអំពីនោះមក នាងបានត្រីដែលស្លាប់ឯងខ្លះ មិនបានខ្លះ ។ កាលមិនបាន ដោយកាលកន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏ស្គាំងស្គម ធ្វើកាលកិរិយាហើយ ទៅកើតជាធីតានៃនាយស្មូនឆ្នាំងក្នុងក្រុងពារាណសី ដោយផលនៃសីលនោះ ។

តមក ក្នុងកាលដែលនាងមានអាយុប្រហែល ១៥-១៦ ឆ្នាំ សក្កទេវរាជទ្រង់ពិចារណាមើលថា "នាងកើតនៅទីណាហ្ន៎" បានឃើញហើយ ទ្រង់ត្រិះរិះថា "ឥឡូវនេះ គួរយើងទៅកាន់ទីនោះ" ដូច្នេះ ហើយក៏ទ្រង់យកកែវ ៧ ប្រការ ដែលមានពណ៌ប្រាកដដូចជាពណ៌នៃផ្លែល្ពៅ ញ៉ាំងយានតូចឲ្យពេញដោយរតនៈ ៧ ប្រការនោះ បរទៅកាន់ក្រុងពារាណសី ស្តេចទៅតាមថ្នល់ស្រែកប្រកាសថា "ម្នាលអ្នកទាំងឡាយ (មក) យកផ្លែល្ពៅចុះ" ប៉ុន្តែទ្រង់ត្រាស់ទៅកាន់អ្នកយកសណ្តែកខៀវ និងសណ្តែករាជមាសជាដើមថា

"ខ្ញុំមិនគិតតម្លៃទេ" កាលជនទាំងនោះទូលសួរថា "លោកនឹងឲ្យដោយប្រការដូចម្ដេច" ត្រាស់ថា "ខ្ញុំនឹងឲ្យដល់ស្ត្រីអ្នករក្សាសីល" ។

អ្នកក្រុង. បពិត្រនាយ ដែលឈ្មោះថា សីល តើដូចម្ដេច? ពណ៌ខ្មៅ ឬពណ៌ខៀវ ។

សក្កទេវរាជ. ពួកអ្នកទាំងឡាយមិនស្គាល់សីលថា "ជាអ្វីផង" នឹងរក្សាសីលនោះដូចម្ដេចបាន? ប៉ុន្តែយើងនឹងឲ្យដល់ស្ត្រីអ្នករក្សាសីល ។

អ្នកក្រុង. បពិត្រនាយ ធីតារបស់នាយសុធម្មានោះ ដើរនិយាយថា "ខ្ញុំរក្សាសីល" ចូរឲ្យដល់ស្ត្រីនោះចុះ ។

សូម្បីធីតារបស់នាយសុធម្មានោះ ក៏ពោលនឹងសក្កទេវរាជថា "បើដូច្នោះ ចូរឲ្យមកខ្ញុំចុះ នាយ" ។

សក្កទេវរាជ. នាងជានរណា?

ធីតានាយសុធម្មា. ខ្ញុំ គឺ ជាស្ត្រីដែលមិនលះបង់នូវសីល ៥ ។

សក្កទេវរាជ. ផ្លែល្មៅទាំងនោះ ខ្ញុំក៏នាំមកដើម្បីនាងប៉ុណ្ណោះ ។

សក្កទេវរាជទ្រង់បរយានតូចទៅកាន់ផ្ទះរបស់នាង ហើយប្រទានទ្រព្យដែលទេវតាគប្បីឲ្យដោយលក្ខណៈស្រដៀងផ្លែល្មៅ ធ្វើមិនឲ្យជនដទៃលួច

យកទៅបាន ញ៉ាំងធីតានៃនាយស្នូនផ្ទាំងឲ្យដឹងនូវព្រះអង្គហើយ ត្រាស់ថា "នេះជាទ្រព្យសម្រាប់ចិញ្ចឹមជីវិតរបស់នាង ។ នាងចូររក្សាសីល ៥ កុំឲ្យដាច់" ហើយស្ដេចក៏ចៀសចេញទៅ ។

## នាងសុជាតាជាធីតារបស់អសុរ

ចំណែកធីតារបស់នាយស្នូនផ្ទាំងនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងភពអសុរ ដែលជាអ្នកមានពៀរចំពោះសក្កទេវរាជ ជាធីតារបស់ស្ដេចអសុរក្នុងភពអសុរ និងព្រោះកាលនាងរក្សាសីលយ៉ាងល្អក្នុងពីរអត្តភាព ទើបនាងបានជាស្ត្រីមានរូបស្រស់ស្អាត មានពណ៌សម្បុរដូចមាស ប្រកបដោយរូបសិរីមិនសាធារណៈ (ទូទៅ) ។ ស្ដេចអសុរដែលមាននាមថា វេបចិត្តិ និយាយនឹងអ្នកដែលមកហើយៗ ថា "ពួកអ្នកមិនសមគួរដល់ធីតារបស់យើងទេ" ហើយក៏មិនឲ្យធីតានោះដល់អ្នកណាមួយឡើយ គិតថា "ធីតារបស់យើង នឹងជ្រើសរើស បុរសដែលសមគួរដល់ខ្លួនដោយខ្លួនឯង" ដូច្នេះ ទើបឲ្យពួកអសុរប្រជុំគ្នា ហើយបានឲ្យកួងផ្កាដល់ធីតានោះ ដោយពោលថា "នាង ចូរជ្រើសរើសយកបុរសដែលសមគួរដល់នាងធ្វើជាស្វាមីចុះ" ។ ក្នុងខណៈនោះ សក្កទេវរាជទ្រង់ពិចារណារកមើលទីដែលនាងកើត

ទ្រង់ជ្រាបនូវព្រឹត្តិការណ៍នោះហើយ ទ្រង់ត្រិះរិះថា ឥឡូវនេះ សមគួរដល់យើងនឹងទៅនាំយកនាងមកហើយ ទើបទ្រង់និម្មិតភេទជាអសុរចាស់ ទៅឈរនៅខាងចុងទីបំផុតបរិស័ទ ។ សូម្បីនាងអសុរកញ្ញានោះ កាលរមិលមើលខាងនោះ និងខាងនេះ លុះឃើញសក្កទេវរាជនោះ ក៏ជាស្ត្រីមានហឫទ័យ គឺ សេចក្តីស្រឡាញ់ ដូចជាជំនន់ទឹកដ៏ធំកើតឡើងហើយ ដោយអំណាចបុព្វេសន្និវាសគ្របសង្កត់ ក៏ដាក់ចិត្តថា "នោះស្វាមីរបស់យើង" ទើបបោះកម្រងផ្កាទៅលើអសុរចាស់ (សក្កទេវរាជ) នោះ ។ ពួកអសុរក៏ចំអកថា "ព្រះរាជារបស់ពួកយើង មិនបានអ្នកដែលសមគួរដល់ធីតារហូតអស់កាលប្រមាណប៉ុណ្ណេះ ឥឡូវនេះបានហើយ អ្នកដែលចាស់ជាងអសុររូបនេះទើបសមគួរដល់ធីតារបស់ព្រះអង្គ" ដូច្នេះ ហើយក៏នាំគ្នាចៀសចេញទៅ ។ ឯសក្កទេវរាជទ្រង់ចាប់ដៃអសុរកញ្ញានោះហើយ ទ្រង់ប្រកាសថា "យើង គឺជាសក្កទេវរាជ" ហើយទ្រង់ហោះទៅក្នុងអាកាស ។ ពួកអសុរដឹងថា "ពួកយើងត្រូវសក្កៈកញ្ឆាស់បញ្ឆោតហើយ" ទើបនាំគ្នាដេញតាមសក្កទេវរាជនោះទៅ ។ ទេវសារថី ឈ្មោះមាតលី នាំវេជយន្តរថមកឈប់ចាំនៅរវាងផ្លូវ ។ សក្កទេវរាជទ្រង់លើកអសុរកញ្ញាឡើងកាន់វេជយន្តរថនោះហើយ មានមុខ

ភ្លោះទៅកាន់ទេវនគរ ស្តេចទៅហើយ ។ ក្នុងវេលាដែលសក្កទេវរាជស្តេចយានដល់សិម្ពលិវ័ន (ព្រៃរការ) កូនគ្រុឌបានឮសូរសំឡេងរថហើយ ក៏ភ័យខ្លាចស្រែកយំ ។ សក្កទេវរាជទ្រង់ស្តាប់នូវសំឡេងយំរបស់កូនគ្រុឌហើយត្រាស់សួរមាតលីថា "នុ៎ះជាសំឡេងយំរបស់សត្វអ្វី?" ។

មាតលី. បពិត្រមហារាជ សំឡេងយំរបស់កូនគ្រុឌ ។

សក្កទេវរាជ. ព្រោះហេតុអ្វី ទើបវាយំ ?

មាតលី. ព្រោះបានឮសំឡេងរថ ហើយខ្លាចស្លាប់ ។

សក្កទេវរាជទ្រង់ត្រាស់ថា "ព្រោះអាស្រ័យយើងតែម្នាក់ បក្សីមានប្រមាណប៉ុណ្ណេះ ត្រូវកម្លាំងនៃរថឲ្យវិនាសហើយ សូមសត្វទាំងនេះកុំវិនាសឡើយ អ្នកចូរត្រឡប់រថវិញចុះ" ។ មាតលីទេវបុត្រនោះ ឲ្យសញ្ញាដល់សេះសិន្ធពដោយរំពាត់ ឲ្យត្រឡប់ ។ ពួកអសុរឃើញកិរិយានោះហើយគិតថា "សក្កៈកញ្ជាស់ចៀសចេញទៅតាំងអំពីអសុរបុរី ឥឡូវនេះត្រឡប់រថមកវិញ នឹងបានជំនួយដោយពិត" ទើបត្រឡប់ចូលទៅកាន់អសុរបុរីតាមផ្លូវដែលមកហើយនោះឯង មិនងើបក្បាលឡើងទៀត ។ ចំណែកសក្កទេវរាជទ្រង់នាំអសុរកញ្ញា ឈ្មោះសុជាតា ទៅកាន់ទេវនគរហើយ ទ្រង់ស្ថាបនា

ទុកក្នុងតំណែងជាធំជាងនាងទេពអប្សរ ២ កោដិកន្លះ ។ អសុរកញ្ញាទូលសូមពរសក្កទេវរាជថា "បពិត្រមហារាជ មាតាបិតា ឬបងប្រុសបងស្រីរបស់ខ្ញុំព្រះអង្គក្នុងទេវលោកនេះ មិនមាន ព្រះអង្គស្តេចទីងទៅកាន់ទីណាៗ គប្បី (ទ្រង់ព្រះករុណា) នាំខ្ញុំព្រះអង្គទៅកាន់ទីនោះៗ ផង" ។ សក្កទេវរាជបានព្រះរាជទានបេ្តជ្ញាដល់អសុរកញ្ញាថា "បាន" ។

ក៏ចាប់តាំងអំពីកាលនោះមក កាលផ្កាចិត្តបាដលិរីក ពួកអសុរប្រាថ្នាដើម្បីនឹងច្បាំងជាមួយសក្កទេវរាជ ឡើងមកដើម្បីនឹងតយុទ្ធ ដោយសម្គាល់ថា "ជាវេលាដែលផ្កាបារិច្ឆត្តកៈទិព្វរបស់ពួកយើងរីក" ។ សក្កទេវរាជបានប្រទាននូវការរក្សាដល់ពួកនាគដែលនៅខាងក្នុងសមុទ្រ បន្ទាប់ពីនោះ ពួកគ្រុឌ បន្ទាប់ពីនោះ ពួកកុម្ភណ្ឌ បន្ទាប់ពីនោះ ពួកយក្ស បន្ទាប់ពីនោះ ពួកទេវតាចាតុម្មហារាជិកា ចំណែកជាន់លើជាងគេបង្អស់បានប្រតិស្ឋានរូបចម្លាក់ព្រះឥន្ទ ដែលមានវជិរាវុធ (អាវុធពេជ្រ) ក្នុងព្រះហស្ត ត្រង់ទ្វារនៃទេវនគរទាំងឡាយ ។ ពួកអសុរ សូម្បីឈ្នះពួកនាគជាដើមមកហើយ ឃើញរូបចម្លាក់ព្រះឥន្ទអំពីចម្ងាយ ក៏រមែងរត់ទៅ ដោយគិតថា "សក្កទេវរាជស្តេចចេញមកហើយ" ។

ព្រះសាស្តាត្រាស់ថា "មឃាលិ មឃមាណពបដិបត្តិ អប្បមាទបដិបទាយ៉ាងនេះ លុះមឃមាណពនោះជាអ្នកមិនប្រមាទហើយយ៉ាងនេះ ទើបដល់ភាពជាធំបែបនេះ ទ្រង់សោយរាជ្យក្នុងទេវលោកទាំង ២ ដែលឈ្មោះថា សេចក្តីមិនប្រមាទនោះ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម សរសើរហើយ ព្រោះថា ការសម្រេចគុណវិសេសដែលជាលោកិយ និងលោកុត្តរៈសូម្បីទាំងអស់ រមែងមានបាន ព្រោះអាស្រ័យសេចក្តីមិនប្រមាទ" ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ
អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាង
ទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញ
ទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ត្មិះតិះដៀល
នូវសេចក្តីប្រមាទ សព្វៗ កាល ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អប្បមាទេន (ព្រោះសេចក្តីមិនប្រមាទ) គឺ ព្រោះតែសេចក្តីមិនប្រមាទដែលធ្វើទុក តាំងអំពីការសម្អាតភូមិប្រទេសក្នុងអចលគ្រាម ។ បទថា មឃវា (ស្តេចមឃវៈ) ជាដើម សេចក្តីថា

មយមាណពដែលប្រាកដឈ្មោះថា "**មឃវៈ**" ក្នុងពេលនេះ ឈ្មោះថា ដល់កាពជាអ្នកប្រសើរបំផុតជាងទេវតាទាំងឡាយ ព្រោះជារាជានៃទេវតាទាំង ២ ជាន់ ។ បទថា **បសំសន្តិ (សរសើរ)** សេចក្ដីថា បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម រមែងសរសើរសេចក្ដីមិនប្រមាទតែម្យ៉ាង ។ ព្រោះហេតុអ្វី ? ព្រោះសេចក្ដីមិនប្រមាទ ជាហេតុនាំឲ្យសម្រេចនូវគុណវិសេសដែលជាលោកិយៈ និងលោកុត្តរៈទាំងអស់ ។ បទថា **បមាទោ គរហិតោ សទា (សេចក្ដីប្រមាទដែលបណ្ឌិតតិះដៀលគ្រប់កាល)** សេចក្ដីថា ចំណែកសេចក្ដីប្រមាទ ព្រះអរិយៈទាំងឡាយរមែងតិះដៀល គឺ និន្ទាហើយជានិច្ច ។ ព្រោះហេតុអ្វី? ព្រោះសេចក្ដីប្រមាទ ជាឫសគល់នៃគុណវិបត្តិគ្រប់យ៉ាង ។ ពិតណាស់ ភាពជាអ្នកជួបគ្រោះអាក្រក់ក្នុងមនុស្សក្ដី ការចូលដល់អបាយភូមិក្ដី សុទ្ធតែមានសេចក្ដីប្រមាទជាមូលទាំងអស់ ។

ក្នុងកាលចប់ព្រះគាថា ស្ដេចលិច្ឆវីនាមថា មហាលិ ទ្រង់តាំងនៅក្នុងសោតាបត្តិផល ។ សូម្បីបរិស័ទដែលប្រជុំគ្នាជាច្រើននោះ ក៏បានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ៕

ចប់ រឿងសក្កទេវរាជ

# ៨. រឿងភិក្ខុមួយរូប

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* ***អប្បមាទរតោ ភិក្ខុ (ភិក្ខុត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ)*** *ដូច្នេះជាដើម ។*

*បានស្តាប់មកថា ភិក្ខុរូបនោះរៀនកម្មដ្ឋានដរាបដល់ព្រះអរហត្ត ក្នុងសំណាក់ព្រះសាស្តាហើយ ចូលទៅកាន់ព្រៃខំប្រឹងប្រែង ព្យាយាម ក៏មិនអាចសម្រេចព្រះអរហត្តផលបាន ។ ភិក្ខុនោះគិតថា "យើងនឹងទៅទូលសូមព្រះសាស្តាឲ្យទ្រង់ត្រាស់ប្រាប់កម្មដ្ឋានឲ្យវិសេស (ឡើងទៅ)" ដូច្នេះ ហើយចេញអំពីព្រៃនោះ កំពុងដើរមកកាន់សំណាក់ព្រះសាស្តា ឃើញភ្លើងព្រៃដ៏ធំតាំងឡើងហើយក្នុងចន្លោះផ្លូវ ប្រញាប់ឡើងកាន់កំពូលភ្នំត្រងោលមួយ អង្គុយសម្លឹងមើលនូវភ្លើងដែលកំពុងឆេះព្រៃ កាន់យកជាអារម្មណ៍ថា "ភ្លើងនេះ ឆេះនូវកំកាច់ឈើទាំងតូចទាំងធំ យ៉ាងណាមិញ សូម្បីភ្លើង គឺ អរិយមគ្គញ្ញាណ ក៏រមែងដុតនូវសំយោជនៈទាំងឡាយ ច្រើន និងតិច ដូច្នោះ" ។ ព្រះសាស្តាប្រថាប់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុនោះហើយ ត្រាស់ថា "ម្នាលភិក្ខុ យ៉ាងហ្នឹងឯង សំយោជនៈទាំងល្អិតទាំង*

គ្រោតគ្រាត ទាំងតូចទាំងធំ ដែលកើតនៅខាងក្នុងសន្ដានរបស់សត្វទាំងនេះ ដូចរំកាច់ឈើធំខ្វះ តូចខ្វះ ដូច្នោះ ភិក្ខុគួរដុតសំយោជនៈដោយភ្លើង គឺញាណ ហើយធ្វើឲ្យជាធម្មជាតិមិនគួរដល់ការកើតឡើងបានទៀត” ដូច្នេះ ទើបទ្រង់បញ្ចេញនូវព្រះរស្មី ហាក់ដូចជាប្រថាប់នៅក្នុងទីចំពោះមុខនៃភិក្ខុនោះ ត្រាស់ព្រះគាថានេះថា ៖

អប្បមាទរតោ ភិក្ខុ    បមាទេ ភយទស្សិ វា
សំយោជនំ អណុំ ថូលំ  ឌហំ  អគ្គីវ គច្ឆតិ ។
ភិក្ខុអ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យក្នុង
សេចក្ដីប្រមាទ តែងដុតបោលសំយោជនៈទាំងតូចទាំងធំ
ដូចភ្លើងឆេះ (រាលនូវកំទេចទាំងតូចទាំងធំ) ដូច្នោះឯង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អប្បមាទរតោ (ត្រេកអរហើយក្នុងសេចក្ដីមិនប្រមាទ) សេចក្ដីថា ត្រេកអរ គឺ អភិរម្យហើយក្នុងសេចក្ដីមិនប្រមាទ បានដល់ ញុំាងកាលឲ្យកន្លងទៅដោយសេចក្ដីមិនប្រមាទ ។ បទថា បមាទេ ភយទស្សិ វា (ឬមានប្រក្រតីឃើញភ័យក្នុងសេចក្ដីប្រមាទ) សេចក្ដីថា អ្នក

ឃើញភ័យក្នុងសេចក្ដីប្រមាទ មានការចូលទៅកើតក្នុងនរកជាដើម ប្រការមួយទៀត ឈ្មោះថា អ្នកឃើញសេចក្ដីប្រមាទ ថាជាភ័យ ព្រោះសេចក្ដីប្រមាទនោះ ជាឫសគល់នៃវិបត្តិទាំងនោះ ។ បទថា **សញ្ញោជនំ (សំយោជន)** សេចក្ដីថា សំយោជនៈ ១០ យ៉ាង[១] ជាគ្រឿងប្រកប ជាគ្រឿងចង (សត្វ) ទុកក្នុងវដ្ដទុក្ខ ដែលញ៉ាំងសត្វឲ្យលិចចុះក្នុងវដ្ដៈបាន ។ បទថា **អណុំ ថូលំ (ល្អិត និងគ្រោតគ្រាត)** គឺ ច្រើន និងតិច ។ បទថា **ឌហំ អគ្គីវ គច្ឆតិ (ដូចភ្លើងឆេះរំកាច់តូចធំដូច្នោះ)** សេចក្ដីថា ភិក្ខុនោះត្រេកអរហើយក្នុងសេចក្ដីមិនប្រមាទ រមែងដុតនូវសំយោជនៈនោះ ដោយភ្លើង គឺញាណ ដែលខ្លួនសម្រេចហើយដោយសេចក្ដីមិនប្រមាទ គឺ ធ្វើឲ្យជាធម្មជាតិមិនគួរដល់ការកើតឡើងតទៅទៀតបាន ដូចភ្លើងដុតរំកាច់តូចធំ ដូច្នោះ ។

ក្នុងកាលចប់ព្រះគាថា ភិក្ខុនោះអង្គុយនៅក្នុងទីនោះឯង ក៏បានដុតបោលនូវសំយោជនៈទាំងអស់ ហើយបានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ មកតាមផ្លូវអាកាស (ហោះមក) សរសើរនូវព្រះសរីរៈ

---

១ សំយោជនៈ ១០ គឺ សក្កាយទិដ្ឋិ , វិចិកិច្ឆា , សីលព្វតបរាមាសៈ , កាមរាគៈ , បដិឃៈ , រូបរាគៈ , អរូបរាគៈ , មានះ , ឧទ្ធច្ចៈ និងអវិជ្ជា ។

*របស់ព្រះតថាគតដែលមានវណ្ណៈដូចមាស ថ្វាយបង្គំហើយ ក៏ចៀសចេញទៅ ។*

ចប់ រឿងភិក្ខុមួយរូប

# ៩. រឿងព្រះនិគមវាសីតិស្សត្ថេរ

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនិគម-វាសីតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទរតោ (ត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ)** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កុលបុត្តម្នាក់ កើតមកហើយចម្រើនវ័យក្នុងស្រុកមួយ ដែលនៅមិនឆ្ងាយពីក្រុងសាវត្ថី បព្វជ្ជាហើយបានឧបសម្បទាក្នុងព្រះសាសនារបស់ព្រះសាស្តា ប្រាកដនាមថា "ព្រះនិគមតិស្សត្ថេរ ជាអ្នកមានសេចក្តីប្រាថ្នាតិច សន្តោស ត្រេកអរតែក្នុងវត្ថុដែលខ្លួនមាន ស្ងប់ស្ងាត់ ប្រារព្ធនូវសេចក្តីព្យាយាម" ។ ព្រះថេរៈរមែងត្រាច់ទៅដើម្បីបិណ្ឌបាតតែក្នុងស្រុករបស់ញាតិជានិច្ច ។ កាលជនទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋីជាដើម ធ្វើនូវមហាទានក្តី កាលព្រះបាទបសេនទិកោសលទ្រង់បំពេញនូវអសទិសទានក្តី ក៏មិនព្រមមកកាន់ក្រុងសាវត្ថី ។ ពួកភិក្ខុក៏សន្ទនាគ្នាថា "ព្រះនិគមតិស្សត្ថេរនេះ ក្រោកឡើងហើយ ក្រោកឡើងព្រមហើយ ក៏ច្រឡូកច្រឡំ ជាប់ជំពាក់ដោយពួកញាតិ កាលជនទាំងឡាយមានអនាថបិណ្ឌិកសេដ្ឋីជាដើម ធ្វើមហាទានក្តី កាលព្រះបាទបសេនទិកោសលបំពេញអសទិស-ទានក្តី ក៏លោកមិនមក ដូច្នេះ ក៏ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។

ព្រះសាស្តា ត្រាស់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា “ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតមែនឬ?” កាលព្រះថេរៈក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមានទូវការប្រឡូកប្រឡំ ឬជាប់ជំពាក់ទៅដោយពួកញាតិទេ ខ្ញុំព្រះអង្គអាស្រ័យពួកមនុស្សដែលជាញាតិទាំងនោះរមែងបានទូវអាហារល្មមនឹងលេបចូលបាន ខ្ញុំព្រះអង្គគិតថា “កាលយើងបានអាហារដែលសៅហ្មងក្តី ប្រណីតក្តី ដែលល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានហើយ ប្រយោជន៍អ្វីដោយការស្វែងរកទូវអាហារដទៃទៀត? ដូច្នេះហើយ ទើបមិនមកកាន់ក្រុងសាវត្ថី បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា ការប្រឡូកប្រឡំដោយពួកញាតិ ឬការជាប់ជំពាក់នឹងពួកញាតិរមែងមិនមានដល់ខ្ញុំព្រះអង្គឡើយ” ។ សូម្បីតាមប្រក្រតី (ព្រះអង្គ) ក៏ទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះថេរៈ ទើបទ្រង់បានប្រទានសាធុការថា “ម្នាលភិក្ខុ ប្រពៃហើយៗ” ដូច្នេះ ទើបត្រាស់ថា “ម្នាលភិក្ខុ ក៏ការដែលអ្នកបានអាចារ្យប្រាកដដូចជាតថាគតហើយ បានជាអ្នកប្រាថ្នាតិចដោយហេតុឯណា ហេតុនោះ មិនទាន់ជាអស្ចារ្យនៅឡើយទេ ព្រោះថា ដែលឈ្មោះថា ភាពជាអ្នកប្រាថ្នាតិចនេះ ជាបែបផែនរបស់តថាគត ជាទំនៀមរបស់តថាគត” ដូច្នេះ កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកសម្តែងថា ៖

ក្នុងអតីតកាល សត្វសេកច្រើនពាន់ក្បាល នៅក្នុងព្រៃនៃដើមល្វាមួយដើម ទៀបឆ្នេរស្ទឹងគង្គាក្នុងហិមវន្តប្រទេស ។ បណ្តាសត្វសេកទាំងនោះ សត្វសេកមួយជាស្តេចនៃសេកទាំងនោះ នាកាលផ្លែទាំងឡាយនៃដើមឈើដែលខ្លួននៅអាស្រ័យនោះអស់ហើយ ក៏ចឹកស៊ីពន្លក ស្លឹក ឬសំបកដែលនៅសល់ ផឹកទឹកក្នុងស្ទឹងគង្គា ជាសត្វមានសេចក្តីប្រាថ្នាតិច ជាសត្វដែលត្រេកអរចំពោះតែវត្ថុដែលខ្លួនមាន រមែងមិនត្រាច់ទៅកាន់ទីដទៃឡើយ ដោយអំណាចគុណ គឺ សេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោសរបស់ស្តេចសេកនោះ ពិភពរបស់សក្កទេវរាជក៏បានកម្រើកញាប់ញ័រ ។ សក្កទេវរាជទ្រង់រំពឹងមើល ទ្រង់ឃើញហេតុនោះហើយ ទ្រង់ (បណ្តាល) ឲ្យដើមឈើនោះស្ងួតដោយអានុភាពរបស់ខ្លួន ដើម្បីល្បងមើលនូវស្តេចសេកនោះ ។ ដើមឈើនោះបាក់ធ្លាក់ចុះហើយ សល់នៅតែដង្គត់ប៉ុណ្ណោះ មានប្រហោងតូចនិងប្រហោងធំ ។ កាលខ្យល់បក់មកប៉ះត្រូវ បានបញ្ចេញសំឡេងដូចត្រូវគេគោះហើយ ។ លំអិតទាំងឡាយ ហុយចេញតាមប្រហោងឈើទាំងនោះ ។ ស្តេចសេកចឹកស៊ីលំអិតទាំងនោះ ហើយផឹកទឹកក្នុងស្ទឹងគង្គា មិនទៅកាន់ទីដទៃ មិនអើពើចំពោះខ្យល់ និងកំដៅថ្ងៃ ទំនៅលើទីបំផុតនៃដង្គត់ឈើល្វានោះ សក្កទេវរាជទ្រង់ជ្រាបចំពោះស្តេចសេកនោះ ជាសត្វមានសេចក្តី

ប្រាប្ថនាតិច ទ្រង់ព្រះតម្រិះថា "យើងនឹងឲ្យស្តេចសេកនោះ ពោលនូវគុណនៃមិត្តធម៌ ហើយឲ្យពរដល់ស្តេចសេកនោះ ធ្វើ (បណ្តាល) ដើមល្វាឲ្យមានផ្លែមិនឈប់" ដូច្នេះ ទើប (និម្មិត) ខ្លួនព្រះអង្គជាស្តេចហង្សមួយ នាំនាងអសុរកញ្ញាដែលមាននាមថា សុជាតា អំពីខាងមុខ ស្តេចទៅកាន់ព្រៃនៃឈើល្វានោះ ទំនៅហ្នឹងមែកនៃដើមឈើមួយដើមមិនឆ្ងាយអំពីទីនោះ កាលនឹងត្រាស់សន្ទនាជាមួយស្តេចសេកនោះ ត្រាស់គាថានេះថា ៖

សន្តិ រុក្ខា ហរិតបត្តា ទុមានេកផលា ពហូ
កស្មា នុ សុក្ខេ កោលាបេ សុវស្ស និរតោ មនោ ។

ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ
មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះ
មានចិត្តរីករាយជានិច្ច តែនឹងដង្គត់ឈើពុកស្ងួត ។

សុវជាតកទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារ តាមន័យដែលពោលមកហើយក្នុងនវកនិបាតនោះចុះ ។ ប៉ុន្តែការកើតឡើងនៃរឿងប៉ុណ្ណោះ ក្នុងនវកនិបាត និងក្នុងទីនេះផ្សេងគ្នា ពាក្យដ៏សេសដូចគ្នាទាំងអស់ ។

ព្រះសាស្តា លុះទ្រង់បាននាំព្រះធម្មទេសនានេះហើយ ទ្រង់ត្រាស់ថា "សក្កទេវរាជក្នុងកាលណោះ បានមកជាអានន្ទ ស្តេចសេកក្នុងកាលណោះ

គឺ តថាគតនេះឯង” ដូច្នេះ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងហើយ ដែលឈ្មោះថា ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច នេះជាបែបផែនជាទំនៀមរបស់តថាគត ការដែលនិគមវាសីតិស្សបុត្ររបស់តថាគត បានអាចារ្យដូចជាតថាគត ហើយជាអ្នកមាននូវសេចក្តីប្រាថ្នាតិច មិនគួរអស្ចារ្យណាស់ណាទេ ធម្មតាភិក្ខុគប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ឲ្យដូចជានិគម-វាសីតិស្សភិក្ខុ ព្រោះថា ភិក្ខុបែបនោះ ជាអ្នកមិនគួរសាបសូន្យចាកមគ្គ និងផល រមែងឋិតនៅក្នុងទីជិតនៃព្រះនិព្វានដោយពិត” ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ
ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ
ក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាក
គុណធម៌ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អភព្វោ បរិហានាយ (មិនសាបសូន្យ) សេចក្តីថា ភិក្ខុបែបនោះ ជាអ្នកមិនគួរដើម្បីនឹងសាបសូន្យចាកធម៌ គឺ សមថៈ

និងវិបស្សនា ឬចាកមគ្គ និងផល គឺ រមែងមិនវិនាសចាកគុណធម៌ដែលខ្លួនបានដល់ហើយ នឹងមិនមែនមិនបាននូវគុណធម៌ដែលខ្លួនមិនទាន់បានទេ ។ បទថា **និព្វានស្សេវ សន្តិកេ** (ក្នុងទីជិតព្រះនិព្វាន) សេចក្តីថា ឋិតនៅក្នុងទីជិតនៃកិលេសបរិនិព្វាន (ការរលត់កិលេស) ផង អនុបាទិសេសនិព្វាន (ការរំលត់បញ្ចក្ខន្ធ) ផង ។

ក្នុងកាលចប់ព្រះគាថា ព្រះនិគមវាសីតិស្សត្ថេរ សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ជនដទៃជាច្រើនក៏បានសម្រេចជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ព្រះធម៌ទេសនាមានផលច្រើនដល់មហាជន ដូច្នេះឯង ។

ចប់ រឿងព្រះនិគមវាសីតិស្សត្ថេរ

## ចប់អប្បមាទវគ្គវណ្ណនា វគ្គទី ២

ក្នុងវគ្គនេះរួមមាន ០៩ រឿង

១. រឿងព្រះនាងសាមាវតី
២. រឿងកុម្ភឃោសកៈ
៣. រឿងព្រះចូឡបន្ថកៈ
៤. រឿងពាលនក្ខត្តឫក្ស
៥. រឿងព្រះមហាកស្សបៈ
៦. រឿងភិក្ខុជាសំឡាញ់ ២ រូប
៧. រឿងសក្កទេវរាជ
៨. រឿងភិក្ខុមួយរូប
៩. រឿងព្រះតិស្សត្ថេរៈមានប្រក្រតីនៅក្នុងនិគម

# ចិត្តវគ្គ ទី ៣

## ១. រឿងព្រះមេឃិយត្ថេរ

*(ពោលដោយការហ្វឹកហ្វាត់ចិត្ត)*

[១៣] *ព្រះសាស្តា កាលប្រថាប់នៅលើភ្នំឈ្មោះចាលិកា ទ្រង់ប្រារព្ធព្រះមេឃិយៈត្រាស់ព្រះធម្មទេសនានេះថា* **ផន្ទនំ ចបលំ ចិត្តំ** *(ចិត្តដែលញាប់ញ័រឃ្លេងឃ្លោង) ជាដើម ។*

*មេឃិយៈទាំងអស់ បណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារដើម្បីឲ្យរឿងនៃព្រះមេឃិយត្ថេរៈនោះជាក់ច្បាស់ ។ ក៏ព្រះសាស្តាទ្រង់ហៅព្រះមេឃិយៈដែលលោកមិនអាចប្រកបសេចក្តីព្យាយាមក្នុងអម្ពវ័ននោះបាន ព្រោះលោកត្រូវវិតក្កៈ ៣ គ្របសង្កត់ ត្រឡប់មកហើយ ទើបត្រាស់ថា មេឃិយៈ អ្នកលះបង់ចោលតថាគតឲ្យនៅម្នាក់ឯង ហើយស្រែកយំថា មេឃិយៈ យើងនៅតែឯងៗ អ្នកចូររង់ចាំ រហូតដល់ភិក្ខុដទៃទឹងប្រាកដ ដូច្នេះ (ឈ្មោះថា) ធ្វើកម្មដ៏ធ្ងន់ក្រៃលែង ។ ដែលឈ្មោះថា ភិក្ខុជាអ្នកធ្លាក់នៅក្នុងអំណាចរបស់ចិត្ត*

យ៉ាងនេះ មិនគួរ ឈ្មោះថា ចិត្តជាធម្មជាតិ (ស្ទុះទៅ) រហ័ស ការញុំាងចិត្ត នោះឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងគួរ ដូច្នេះ ទើបទ្រង់បានភាសិត ព្រះគាថា ២ គាថានេះថា ៖

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុករោវ តេជនំ ។
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សា បានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់ បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែល បុគ្គលលើកឡើងចាកអាល័យ គឺ កាមគុណ ៥ បោះទៅ ក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីនៅ គឺ ទឹក បោះទៅលើគោក ដូច្នោះឯង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ផន្ទនំ (ញាប់ញ័រ)** គឺ ញាប់ញ័រនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។ បទថា **ចបលំ (ឃ្លេងឃ្លោង)** បានដល់ មិនតាំងនៅក្នុងអារម្មណ៍តែមួយបាន ដូចទារកក្នុងផ្ទះ នៅមិនស្ងៀមដោយឥរិយាបថណាមួយដូច្នោះ ទើបឈ្មោះថា ឃ្លេងឃ្លោង ។ បទថា **ចិត្តំ (ចិត្ត)** បានដល់ វិញ្ញាណ ។ ក៏វិញ្ញាណនោះ ព្រះមានព្រះភាគត្រាស់ហៅថាចិត្ត ព្រោះជាធម្មជាតិវិចិត្រ ដោយភូមិ វត្ថុអារម្មណ៍ និងវិថីចិត្ត មានកិរិយាចិត្តជាដើម ។ បទថា **ទុរក្ខំ (រក្សាបានលំបាក)** បានដល់ ឈ្មោះថាដែលបុគ្គលរក្សាបានដោយលំបាក ព្រោះតាំងទុកបានលំបាកក្នុងអារម្មណ៍ដែលជាទីសប្បាយណាមួយនោះឯង ។ បទថា **ទុន្និវារយំ (ហាមឃាត់បានដោយលំបាក)** បានដល់ ឈ្មោះថា ដែលបុគ្គលហាមបានលំបាក ព្រោះជាធម្មជាតិរក្សាបានដោយលំបាក ដើម្បីនឹងហាម (រារាំង) ចិត្តដែលទៅកាន់វិសភាគារម្មណ៍ ។ បទថា **ឧសុការោវ តេជនំ (ដូចអ្នកពត់ព្រួញ ពត់ព្រួញឲ្យត្រង់ ដូច្នោះ)** សេចក្តីថា នាយជាងព្រួញនាំយកកំណាត់ឈើមួយ

កំណាត់មកអំពីព្រៃហើយ បកសំបកចេញ លាបដោយទឹកបាយ និងប្រេង រោលត្រង់ក្បៀងចង្រ្កូងភ្លើង កាត់ត្រង់ចម្ពាមឈើ ធ្វើឲ្យបាត់កោង គឺ ឲ្យត្រង់ ឲ្យជារបស់គួរដល់ការបាញ់រោមទ្រាយបាន ។ ក៏គ្រាធ្វើហើយ ទើបសំដែង សិល្បៈចំពោះព្រះរាជា និងរាជមហាមាត្យ រមែងបានសក្ការៈ និងសេចក្ដី រាប់អានដ៏ច្រើន យ៉ាងណា បុរសអ្នកមានបញ្ញា គឺ បណ្ឌិត បានដល់ អ្នក ដឹងច្បាស់ ក៏ដូច្នោះដូចគ្នា (គឺ) ធ្វើចិត្តនេះ ដែលមានសភាពញាប់ញ័រជា ដើម ឲ្យអស់សំបក គឺ ឲ្យប្រាសចាកកិលេសដែលគ្រោតគ្រាត ដោយអំណាច ធុតង្គ និងការនៅព្រៃ ហើយលាបដោយជ័រ គឺ សទ្ធា រោលដោយសេចក្ដី ព្យាយាមដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្ត កាត់ត្រង់ចម្ពាម គឺ សមថៈ និងវិបស្សនា ធ្វើឲ្យត្រង់ បានដល់ ឲ្យអស់អំណាច លុះធ្វើហើយ ពិចារណា សង្ខារទាំងឡាយ ទម្លាយគំនរអវិជ្ជាធំបានហើយ ធ្វើគុណវិសេសនេះ គឺ វិជ្ជា ៣[១] អភិញ្ញា ៦[២] លោកុត្តរធម៌ ៩[៣] ឲ្យនៅក្នុងទីក្នុងកណ្ដាប់ដៃរបស់

---

១-វិជ្ជា ៣ = បុព្វេនិវាសានុស្សតិវិជ្ជា ១ , ចុតូបបាតវិជ្ជា ១ , អាសវក្ខយវិជ្ជា ១ ។ ២-អភិញ្ញា ៦ = ឥទ្ធិវិធី ១ , ទិព្វសោត ១ , ចេតោបរិយញ្ញាណ ១ , បុព្វេនិវាសានុស្សតិញ្ញាណ ១ , ទិព្វចក្ខុ ១ , អាសវក្ខយញ្ញាណ ១ ។ ៣-លោកុត្តរធម៌ ៩ = មគ្គ ៤ ផល ៤ និព្វាន ១ ។

ខ្លួន រមែងបានជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ។

បទថា **វារិជោវ** (ដូចត្រី) បានដល់ ដូចមច្ឆា ។ បទថា **ថលេ ខិត្តោ** (ត្រូវ...បោះទៅលើគោក) បានដល់ ត្រូវបោះទៅលើគោកដោយដៃ ឬជើង ឬដោយគ្រឿងចាប់ មានសំណាញ់ជាដើមយ៉ាងណាមួយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឱកមោកតឧព្ភតោ** (ដែលត្រូវលើកឡើងអំពីទីនៅ គឺ ទឹក) (ដូចតទៅនេះ) ទឹក ឈ្មោះថា **ឱកៈ** ក្នុងបទនេះថា **ឱកបុណ្ណេហិ ចីវរេហិ** (ភិក្ខុអ្នកក្រុងបាឋា មានចីវរទទឹកដោយទឹក) ។ អាល័យ ឈ្មោះថា **ឱកៈ** ក្នុងបទនេះថា **ឱកំ បហាយ អនិកេតសារី** (មុនីលះបង់អាល័យហើយមិនជាប់នៅ) ។ សូម្បីបទទាំងពីរ ក៏រមែងបានក្នុងបាទព្រះគាថានេះ ។ ក្នុងបទថា **ឱកមោកតោ** នេះ មានសេចក្តីយ៉ាងនេះថា ចាកទីនៅ គឺ ទឹក គឺ ចាកទីអាល័យ គឺ ទឹក ។ បទថា **ឧព្ភតោ** (លើកឡើង) បានដល់ ត្រូវលើកឡើងហើយ ។ បទថា **បរិផន្ទតិទំ ចិត្តំ** (ចិត្តនេះរមែងញាប់ញ័រ) សេចក្តីថា ចិត្តនេះ គឺ ដែលត្រេកអរហើយក្នុងអាល័យ គឺ កាមគុណ ៥ ដែលព្រះយោគាវចរលើកឡើងហើយអំពីអាល័យ គឺ កាមគុណ ៥ នោះ

បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដុតដោយសេចក្ដីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្ត ដើម្បីលះវដ្ដៈ ពោលគឺ អន្ទាក់មារ រមែងញាប់ញ័រ គឺ មិនអាចតាំងនៅក្នុងវិបស្សនាកម្មដ្ឋាននោះបាន ដូចជាត្រីដែលត្រូវលើកឡើងចាកទីអាល័យ បោះទៅលើគោក កាលមិនបានទឹក រមែងញាប់ញ័រដូច្នោះ ។ ចំណែកបុគ្គលអ្នកមានបញ្ញា មិនដាក់ធុរៈ រមែងធ្វើចិត្តនោះឲ្យត្រង់ គឺ ឲ្យគួរដល់ការងារ ដោយន័យដូចពោលហើយនោះឯង ។

ន័យម្យ៉ាងទៀត ចិត្តនេះ ដែលលះបង់អន្ទាក់មារ គឺ កិលេសវដ្ដៈមិនបាន ហើយតាំងនៅ រមែងញាប់ញ័រដូចត្រីនោះដូច្នោះ ព្រោះដូច្នោះ ព្រះយោគាវចរគប្បីលះបង់អន្ទាក់មារចេញ គឺ គួរលះបង់អន្ទាក់មារ ពោលគឺកិលេសវដ្ដៈដែលជាហេតុញាប់ញ័រនៃចិត្តនោះ ដូច្នេះឯង ។

ក្នុងកាលចប់គាថា ព្រះមេឃិយត្ថេរៈបានតាំងនៅក្នុងព្រះសោតាបត្តិ-ផល ។ ជនសូម្បីពួកដទៃដ៏ច្រើន ក៏បានជាអរិយបុគ្គល មានសោតាបត្តិផលជាដើមនោះឯង ។

ចប់ រឿងមេឃិយត្ថេរៈទី ១

# ២. រឿងភិក្ខុមួយរូប

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ទុន្និគ្គហស្ស លហុនោ** (ដែលសង្កត់សង្កិនបាន លំបាក ជាធម្មជាតិលឿនរហ័ស) ជាដើម ។

បានឮថា មានស្រុកមួយដែលមានមនុស្សរស់នៅកកកុញ ឈ្មោះ មាតិកគ្រាម ក្បែរជើងភ្នំ ក្នុងដែនរបស់ព្រះបាទកោសល ។ ថ្ងៃមួយ មាន ភិក្ខុប្រមាណ ៦០ រូប ទូលអារាធនាព្រះមានព្រះភាគឲ្យទ្រង់ត្រាស់ប្រាប់ព្រះកម្ម-ដ្ឋានដរាបដល់ព្រះអរហត្ត ហើយបានទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាត ។ លំដាប់នោះ មេស្រុកឈ្មោះមាតិកៈណា មាតារបស់មេស្រុកនោះ ឃើញ ភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងផ្ទះ អង្គៀសដោយបាយ យាគូ និងភត្ត ដែលមានរសឆ្ងាញ់ផ្សេងៗ ហើយសួរថា "លោកម្ចាស់ទាំងឡាយ បំណង នឹងទៅកាន់ទីណា?" ភិក្ខុទាំងនោះប្រាប់ថា "ពួកអាត្មា មានបំណងនឹងទៅ កាន់ទីដែលសប្បាយ មហាឧបាសិកា" ។ នាងជ្រាបថា លោកម្ចាស់ទាំងឡាយ ប្រហែលជាស្វែងរកទីនៅសម្រាប់ចាំវស្សា ទើបក្រាបចុះជិតព្រះបាទ ហើយ

ពោលថា "បើលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះអស់ ៣ ខែ សោត នាងខ្ញុំនឹងដល់សរណៈ ៣ សីល ៥ (និង) ធ្វើឧបោសថកម្ម" ។ ភិក្ខុទាំងឡាយប្រឹក្សាគ្នាថា "យើងទាំងឡាយ កាលអាស្រ័យឧបាសិកានេះ នឹងមិនមានសេចក្ដីលំបាកដោយភិក្ខា នឹងអាចធ្វើការរលាស់ចេញចាកភពបាន" ដូច្នេះ ទើបទទួលពាក្យនិមន្ត ។ នាងបានជម្រះវិហារត្រង់ទីនៅប្រគេនដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ កាលនៅក្នុងទីនោះ ថ្ងៃមួយបានប្រជុំគ្នា ហើយដាស់តឿនគ្នានឹងគ្នាថា អ្នកមានអាយុ ពួកយើងមិនគួរប្រព្រឹត្តក្នុងសេចក្ដីប្រមាទឡើយ ព្រោះថា មហានរក ៨ រណ្ដៅ មានទ្វារបើករង់ចាំពួកយើង ដូចជាផ្ទះរបស់ខ្លួន ។ ក៏ពួកយើងបានរៀនព្រះកម្មដ្ឋានក្នុងសំណាក់របស់ព្រះពុទ្ធដែលទ្រង់នៅព្រះជន្ម ហើយទើបមក ។ ក៏ធម្មតាព្រះពុទ្ធទាំងឡាយ ដែលនរណាៗ ជាអ្នកអួតអាង សូម្បីត្រាច់ទៅតាមស្នាមព្រះបាទ ក៏មិនអាចឲ្យទ្រង់ប្រោសប្រាណបាន (តែ) បុគ្គលអ្នកមានអធ្យាស្រ័យជាប្រក្រតីប៉ុណ្ណោះ ទើបឲ្យទ្រង់ប្រោសប្រាណបាន លោកទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ពួកយើងមិនគួរឈរ មិនគួរអង្គុយនៅក្នុងកន្លែងមួយ ២ រូប តែថា ក្នុងកាល

ជាទីទំនុកបម្រុងព្រះថេរៈក្នុងវេលាល្ងាចនោះឯង និងក្នុងកាលភិក្ខាចារវេលាព្រឹកប៉ុណ្ណោះ ពួកយើងនឹងរួមគ្នា (តែ) ក្នុងកាលដ៏សេសមិនគួរនៅរួមគ្នា ២ រូបឡើយ ។ ម្យ៉ាងទៀត កាលភិក្ខុអ្នកមិនសប្បាយ មកវាយរគាំងត្រង់កណ្ដាលវិហារហើយ ពួកយើងទើបមកតាមសញ្ញានៃរគាំង ធ្វើថ្នាំឲ្យដល់ភិក្ខុនោះ ។

កាលភិក្ខុទាំងនោះធ្វើកតិកាគ្នាយ៉ាងនេះ ថ្ងៃមួយ ឧបាសិកានោះឲ្យបុគ្គលកាន់ភេសជ្ជៈទាំងឡាយ មានទឹកដោះថ្លា និងទឹកអំពៅជាដើម ដែលជនទាំងឡាយ មានទាសៈ និងកម្មករជាដើមហែហមហើយ ទៅកាន់វិហារនោះក្នុងវេលាល្ងាច មិនឃើញភិក្ខុទាំងឡាយក្នុងវិហារ ទើបសួរពួកបុរសថា "លោកម្ចាស់ទាំងឡាយទៅក្នុងទីណា?" កាលពួកគេប្រាប់ថា "ម៉ែម្ចាស់ លោកម្ចាស់ទាំងឡាយនឹងជាអ្នកគង់ក្នុងទីស្នាក់នៅ ពេលយប់ និងពេលថ្ងៃរៀងៗ ខ្លួន (ប៉ុណ្ណោះ)" ។ ទើបពោលថា "ខ្ញុំធ្វើយ៉ាងណា ទើបបានជួបលោកម្ចាស់ទាំងនោះ?" លំដាប់នោះ មនុស្សទាំងឡាយដឹងកតិកាវត្តរបស់ភិក្ខុសង្ឃ ទើបប្រាប់ចំពោះឧបាសិកានោះថា "ម៉ែម្ចាស់ លោកម្ចាស់នឹងប្រជុំ

គ្នាក្នុងកាលដែលវាយរគាំង” ។ នាងទើបឲ្យវាយរគាំង ។ ភិក្ខុទាំងឡាយបានឮសំឡេងរគាំងហើយ ចេញចាកទីនៅរៀងៗ ខ្លួន ដោយសំគាល់ថា មានភិក្ខុរូបខ្លះនឹងមិនសប្បាយ ទើបមកប្រជុំគ្នាក្នុងកណ្តាលវិហារ ។ ភិក្ខុឈ្មោះថា និមន្តមកក្នុងផ្លូវតែមួយជាមួយគ្នាសូម្បី ២ រូប រមែងមិនមាន ។ ឧបាសិកាឃើញភិក្ខុមួយរូបៗ ប៉ុណ្ណោះ និមន្តមកពីទីកន្លែងមួយៗ ទើបគិតថា “ប្រហែលជាលោកម្ចាស់បុត្ររបស់យើងនឹងមានការឈ្លោះគ្នាទេដឹង ដូច្នេះ ទើបសំពះភិក្ខុសង្ឃហើយសួរថា “លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយមានការឈ្លោះគ្នាឬ?”

ភិក្ខុទាំងឡាយ. ពួកអាត្មាមិនមានការឈ្លោះគ្នាទេ មហាឧបាសិកា ។

ឧបាសិកា. លោកម្ចាស់ដ៏ចម្រើន បើលោកម្ចាស់មិនមានការឈ្លោះគ្នាទេ ហេតុអ្វីលោកម្ចាស់ទាំងឡាយ ទើបមិនមកដោយការរួមគ្នា ដូចកាលមកកាន់ផ្ទះរបស់នាងខ្ញុំ (ត្រឡប់ជា) មកតែមួយអង្គៗ អំពីទីកន្លែងមួយៗ? ។

ភិក្ខុ. មហាឧបាសិកា ពួកអាត្មាអង្គុយធ្វើសមណធម៌ក្នុងទីកន្លែងរៀងៗ ខ្លួន ។

ឧបាសិកា. លោកម្ចាស់ទាំងឡាយ ឈ្មោះថា សមណធម៌ គឺអ្វី ។

ភិក្ខុ. មហាឧបាសិកា ពួកខ្ញុំធ្វើការស្វាធ្យាយអាការ ៣២ ប្រការ[១] ផ្តើមតាំងពីការអស់ទៅ និងសូន្យទៅក្នុងអត្តភាពនេះ ។

ឧបាសិកា. លោកម្ចាស់ ការស្វាធ្យាយអាការ ៣២ និងផ្តើមតាំងពីការអស់ទៅ សូន្យទៅក្នុងអត្តភាពនេះ រមែងសមគួរដល់ពួកលោកម្ចាស់ប៉ុណ្ណោះ ឬរមែងសមគួរដល់ពួកនាងខ្ញុំផងដែរ? ។

ភិក្ខុ. មហាឧបាសិកា ធម៌នេះ ព្រះមានព្រះភាគទ្រង់មិនបានហាមដល់នរណាៗ ឡើយ ។

ឧបាសិកា. បើដូច្នោះ សូមលោកម្ចាស់អនុគ្រោះឲ្យអាការ ៣២ និងសូមប្រាប់អំពីការពិចារណានូវការអស់ទៅ និងសូន្យទៅក្នុងអត្តភាពនេះដល់នាងខ្ញុំផង ។

ពួកភិក្ខុពោលថា "មហាឧបាសិកា បើដូច្នោះ នាងចូររៀនចុះ" ហើយ

---

១-អាការ ៣២ = សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ទឹកប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ និងខួរក្នុងក្បាល ។

ក៏ឲ្យរៀនទាំងអស់ ។ តាំងអំពីនោះមក ឧបាសិកានោះក៏បានធ្វើការស្វា-ធ្យាយអាការ ៣២ ពិចារណាការអស់ទៅ និងសូន្យទៅក្នុងខ្លួន ក៏បានលុះមគ្គ ៣ ផល ៣ មុនភិក្ខុទាំងនោះឯង ។ បដិសម្ភិទា ៤ និងលោកិយ-អភិញ្ញា បានមកដល់ឧបាសិកានោះដោយមគ្គនោះឯង នាងចេញចាកសុខដែលកើតអំពីមគ្គ និងផលហើយ មើលដោយទិព្វចក្ខុ ពិចារណាថា លោកម្ចាស់ជាបុត្ររបស់យើងសម្រេចធម៌នេះ ក្នុងកាលណាហ្ន៎ ហើយពិចារណាថា "លោកម្ចាស់ទាំងនេះ នៅមានរាគៈ ទោសៈ មោហៈ លោកម្ចាស់ទាំងនេះ មិនមានគុណធម៌សូម្បីត្រឹមតែឈាន និងវិបស្សនាឡើយ ឧបនិស្ស័យនៃព្រះអរហត្តរបស់លោកម្ចាស់ដែលជាបុត្ររបស់យើង មាន ឬមិនមានឃើញថា "មាន" ដូច្នេះ ទើបពិចារណាសេនាសនៈជាទីសប្បាយ នឹងមានឬមិនមានហ្ន៎ សូម្បីឃើញសេនាសនៈដែលជាទីសប្បាយហើយ ទើបពិចា-រណាថា លោកម្ចាស់ទាំងឡាយរបស់យើងមិនទាន់បានបុគ្គលជាទីសប្បាយឬហ្ន៎ សូម្បីឃើញបុគ្គលជាទីសប្បាយហើយ ទើបពិចារណាថា លោកម្ចាស់ទាំងឡាយមិនទាន់បានអាហារជាទីសប្បាយឬហ្ន៎ ក៏បានឃើញថា អាហារ

ដែលជាទីសប្បាយនៅមិនទាន់មានដល់លោក ។ តអំពីនោះ ក៏ចាត់ចែង បាយយាគូមានច្រើនយ៉ាង របស់ទំពារជាអនេកប្បការ និងភោជនមានរសផ្សេងៗ ដ៏ច្រើន និមន្តភិក្ខុទាំងឡាយឲ្យគង់ ហើយថ្វាយទឹកទក្ខិណោទក[១] ដោយពាក្យថា "បពិត្រលោកដ៏ចម្រើន លោកម្ចាស់ពេញចិត្តក្នុងវត្ថុណាៗ សូមទទួលវត្ថុនោះៗ ចុះ" ។ ភិក្ខុទាំងនោះទទួលយកវត្ថុទាំងឡាយ មានបាយយាគូជាដើម ហើយឆាន់តាមសេចក្ដីពេញចិត្ត ។ កាលភិក្ខុទាំងនោះបានអាហារជាទីសប្បាយ ចិត្តក៏ជាធម្មជាតិមានអារម្មណ៍តែមួយ ។ ពួកលោកមានចិត្តតាំងស៊ប់ក្នុងវិបស្សនា តមកកាលមិនយូរ ក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ហើយគិតថា "ឱហ្ន៎! មហាឧបាសិកា ជាទីពឹងរបស់ពួកយើង បើពួកយើងមិនបានអាហារដែលជាទីសប្បាយទេ ការបាក់ធ្លុះមគ្គ និងផលនឹងមិនមានដល់ពួកយើងដោយពិត" ។ ឥឡូវនេះ ពួកយើងនៅចាំវស្សា បវារណាហើយ និងទៅកាន់សំណាក់របស់ព្រះសាស្ដា ។ ពួកលោកលាឧបាសិកាថា "ពួកអាត្មាប្រាថ្នានឹងគាល់ព្រះសាស្ដា" ។ មហា

---

១ ប្រែថា: ទឹកដើម្បីជាទក្ខិណា ។

ឧបាសិកាពោលថា “សាធុ លោកម្ចាស់ទាំងឡាយ” ហើយតាមជូនដំណើរ ភិក្ខុទាំងនោះ ពោលពាក្យដែលជាទីស្រឡាញ់ដ៏ច្រើនថា “សូមលោកម្ចាស់ ទាំងឡាយគប្បី (មក) សួរសុខទុក្ខនាងខ្ញុំផង” ដូច្នេះជាដើម ទើបត្រឡប់ វិញ ។ ចំណែកភិក្ខុទាំងនោះដល់ក្រុងសាវត្ថីហើយ ថ្វាយបង្គំព្រះសាស្ដា រួចគង់ក្នុងទីដ៏សមគួរមួយ ភិក្ខុដែលព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំង ឡាយ (សរីរយន្តមានចក្រ ៤ មានទ្វារ ៩) ពួកអ្នកអត់ធន់បានដែរឬ ពួក អ្នកល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានទេឬ មួយទៀត ពួកអ្នកមិនលំបាក ដោយការបិណ្ឌបាតទេឬ ទើបក្រាបទូលថា “ល្មមអត់ធន់បាន ព្រះអង្គ ល្មម ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ព្រះអង្គ” មយ៉ាងទៀត ខ្ញុំព្រះអង្គទាំងឡាយ មិនបានលំបាកដោយការបិណ្ឌបាតឡើយ ព្រោះថា ឧបាសិកាម្នាក់ ឈ្មោះ មាតិកមាតា ជ្រាបវារៈចិត្តរបស់ពួកខ្ញុំព្រះអង្គ កាលពួកខ្ញុំព្រះអង្គគិតយ៉ាង ណា មហាឧបាសិកានឹងចាត់ចែងអាហារឈ្មោះនេះ ដើម្បីពួកខ្ញុំព្រះអង្គ ។ (នាង) ក៏បានចាត់ចែងអាហារថ្វាយតាមដែលពួកខ្ញុំព្រះអង្គគិតហើយ ។ ដូច្នេះ ហើយក៏ពោលសរសើរគុណរបស់មហាឧបាសិកានោះ ។

ភិក្ខុមួយរូប ស្តាប់ពាក្យសរសើរគុណរបស់មហាឧបាសិកានោះហើយ ជាអ្នកប្រាថ្នានឹងទៅកាន់ទីនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ទូលលាព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់ស្រុកនោះ" ហើយចេញអំពីវត្តជេតពន ដល់ស្រុកនោះតាមលំដាប់ ក្នុងថ្ងៃដែលខ្លួនចូរទៅកាន់វិហារ គិតថា "បានឮដំណឹងថា ឧបាសិកានេះ រមែងដឹងហេតុដែលបុគ្គលដទៃគិតហើយៗ ក៏យើងហត់នឿយហើយតាមផ្លូវ មិនអាចនឹងសម្អាតវិហារបាន យ៉ាងណា ឧបាសិកានេះ នឹងបញ្ជូនមនុស្សអ្នកសម្អាតវិហារមកដើម្បីយើង" ។ ឧបាសិកាអង្គុយក្នុងផ្ទះនោះឯង បានពិចារណាដឹងសេចក្តីនោះហើយ ទើបបញ្ជូនមនុស្សឲ្យទៅ ដោយពាក្យថា "អ្នកចូរទៅសម្អាតវិហារហើយ ទើបមក" ។ ចំណែកភិក្ខុនោះប្រាថ្នាធាន់ទឹក ទើបគិតថា ធ្វើដូចម្តេច ឧបាសិកានេះនឹងគប្បីធ្វើទឹកផឹក លាយដោយស្ករបញ្ជូនមកឲ្យយើង ។ ឧបាសិកា ក៏បានបញ្ជូនទឹកនោះទៅប្រគេន ។ លោកគិតទៀតថា "សូមឧបាសិកា ចូរបញ្ជូនបាយយាគូមានរសឆ្ងាញ់ និងសម្លមកដើម្បីយើងក្នុងថ្ងៃស្អែកនេះ អំពីព្រលឹមចុះ" ។ ឧបាសិកាក៏បានធ្វើយ៉ាងនោះ ។

ភិក្ខុនោះឆាន់បាយយាគូហើយ គិតថា "ធ្វើម្ដេចហ្ន៎ ឧបាសិកាគប្បីបញ្ជូននូវរបស់ទំពារបែបនេះមកដើម្បីយើង" ។ ឧបាសិកាក៏បានបញ្ជូនរបស់ទំពារសូម្បីនោះទៅហើយ លោកគិតថា "ឧបាសិកានេះបញ្ជូនវត្ថុដែលយើងគិតហើយគ្រប់ៗ វត្ថុមក យើងប្រាថ្នានឹងជួបឧបាសិកានោះ ធ្វើដូចម្ដេច នាងគប្បីឲ្យអ្នកកាន់ភេសជ្ជៈ មានរសដ៏សេសផ្សេងៗ ដើម្បីយើង មកដោយខ្លួនឯងហ្ន៎" ។ ឧបាសិកាគិតថា "ភិក្ខុអ្នកជាបុត្ររបស់យើងប្រាថ្នានឹងឃើញយើងសង្ឃឹមការទៅរបស់យើង" ដូច្នេះ ទើបឲ្យមនុស្សកាន់ភេសជ្ជៈទៅកាន់វិហារហើយបានថ្វាយដល់ភិក្ខុនោះ ។ ភិក្ខុនោះធ្វើភត្តកិច្ចស្រេចហើយ សួរថា "មហាឧបាសិការ នាងឬ ឈ្មោះថា មាតិកមាតា" ។

ឧបាសិកា. ត្រូវហើយ លោកម្ចាស់ ។

ភិក្ខុ. ឧបាសិកា នាងដឹងចិត្តរបស់អ្នកដទៃឬ ។

ឧបាសិកា. សួរខ្ញុំធ្វើអ្វី លោកម្ចាស់ ។

ភិក្ខុ. នាងបានដឹងគ្រប់ៗ វត្ថុដែលអាត្មាគិតហើយ ព្រោះដូច្នោះអាត្មាទើបសួរនាង ។

ឧបាសិកា. លោកកូន ភិក្ខុដែលដឹងចិត្តរបស់អ្នកដទៃក៏មានច្រើន ។

ភិក្ខុ. អាត្មាមិនបានសួរដល់អ្នកដទៃទេ សួរចំពោះឧបាសិកា ។

សូម្បីយ៉ាងនោះ ឧបាសិកាក៏មិនបានឆ្លើយ (ត្រង់ៗ) ថា នាងខ្ញុំដឹងចិត្តរបស់អ្នកដទៃ (ត្រឡប់ជា) ពោលថា "លោកកូនអើយ ធម្មតាអ្នកដឹងចិត្តរបស់អ្នកដទៃ រមែងធ្វើយ៉ាងនោះបាន" ។ ភិក្ខុនោះគិតថា "កម្មនេះធ្ងន់ណាស់ ធម្មតាបុថុជ្ជនរមែងគិតដល់អារម្មណ៍ដែលស្អាតខ្លះ មិនស្អាតខ្លះ បើយើងគិតវត្ថុដែលមិនសមគួរហើយនោះសោត ឧបាសិកានេះគប្បីញុំាងយើងឲ្យដល់នៅប្រការដែលប្លែក ដូចចាប់ចោរត្រង់កណ្តាលនៃផ្នូងសក់ ដូច្នោះ យើងគួរចៀសចេញអំពីទីនេះ ហើយពោលថា "ឧបាសិកា អាត្មាលានឹងទៅហើយ" ។

ឧបាសិកា. លោកម្ចាស់ និមន្តទៅណា ។

ភិក្ខុ. អាត្មានឹងទៅកាន់សំណាក់របស់ព្រះសាស្តា ឧបាសិកា ។

ឧបាសិកា. សូមលោកម្ចាស់ ចូរនៅក្នុងទីនេះសិនចុះ ។

ភិក្ខុនោះពោលថា "អាត្មាមិននៅទេ នឹងត្រូវទៅហើយ" ហើយបាន

ដើរចេញ (អំពីទីនោះ) ទៅកាន់សំណាក់របស់ព្រះសាស្តា ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរលោកថា "ភិក្ខុ អ្នកនៅក្នុងទីនោះមិនបានឬ" ។

ភិក្ខុ. ដូច្នោះហើយ ព្រះអង្គ ខ្ញុំព្រះអង្គមិនអាចនៅក្នុងទីនោះបាន ។

ព្រះសាស្តា. ព្រោះហេតុអ្វី ភិក្ខុ ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះថា) ឧបាសិកានោះរមែងដឹងរឿងដែលអ្នកដទៃគិតហើយគ្រប់ប្រការ ខ្ញុំព្រះអង្គគិតថា "ក៏ធម្មតា បុថុជ្ជនរមែងគិតអារម្មណ៍ដែលល្អខ្លះ មិនល្អខ្លះ បើយើងគិតវត្ថុខ្លះដែលមិនសមគួរហើយសោត ឧបាសិកានោះ ក៏នឹងញាំងយើងដល់នៅប្រការដែលប្លែកដូចចាប់ចោរត្រង់កណ្តាលនៃផ្នួងសក់ ដូច្នោះ ដូច្នេះហើយទើបបានមក ។

ព្រះសាស្តា. ម្នាលភិក្ខុ អ្នកគួរនៅក្នុងទីនោះឯង ។

ភិក្ខុ. ខ្ញុំព្រះអង្គមិនអាចទេ ខ្ញុំព្រះអង្គនៅក្នុងទីនោះមិនបានទេ ។

ព្រះសាស្តា. ម្នាលភិក្ខុ បើដូច្នោះ អ្នកអាចរក្សាវត្ថុតែមួយប៉ុណ្ណោះបានទេ ។

ភិក្ខុ. រក្សាអ្វីទៅ ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា "អ្នកចូររក្សាចិត្តរបស់អ្នកនោះឯង ធម្មតាចិត្តនេះ បុគ្គលរក្សាបានដោយលំបាក អ្នកចូរហាមចិត្តរបស់អ្នកទុកឲ្យបាន កុំគិតដល់អារម្មណ៍អ្វីៗ យ៉ាងដទៃ ធម្មតាចិត្តដែលបុគ្គលហាមឃាត់បានដោយលំបាក" ដូច្នេះ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ការទូន្មានចិត្តដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

## អធិប្បាយគាថា

បណ្ឌិតគប្បីជ្រាបវិគ្រោះក្នុងព្រះគាថានេះ (ដូចតទៅនេះ) ធម្មតាចិត្តនេះ ដែលបុគ្គលរមែងសង្កត់សង្កិនបានដោយលំបាក ព្រោះដូច្នោះ ទើប

ឈ្មោះថា សង្កត់សង្កិនបានលំបាក ។ ចិត្តនេះ រមែងកើត និងរលត់រហ័ស ព្រោះដូច្នោះ ទើបឈ្មោះថា រហ័ស ។ ចិត្តនោះ ដែលសង្កត់សង្កិនបានលំបាក (ទុន្និគ្គហស្ស) ជាធម្មជាតិរហ័ស (លហុនោ) ។ បទថា យត្ថកាមនិបាតិនោ (មានប្រក្រតីធ្លាក់ទៅក្នុងអារម្មណ៍តាមសេចក្ដីប្រាថ្នា) សេចក្ដីថា ធ្លាក់ទៅក្នុងអារម្មណ៍ណាមួយនោះឯង ។ ពិតហើយ ចិត្តនេះរមែងមិនដឹងឋានៈដែលសមគួរ ឬឋានៈដែលមិនសមគួរ រមែងមិនពិចារណាមើលជាតិ មិនពិចារណាមើលត្រកូល មិនពិចារណាមើលវ័យ រមែងធ្លាក់ទៅក្នុងអារម្មណ៍ដែលខ្លួនប្រាថ្នាតែម្យ៉ាង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា "ធ្លាក់ទៅក្នុងអារម្មណ៍តាមសេចក្ដីប្រាថ្នា" ។ ការហ្វឹកហាត់ចិត្តបែបនោះ ជាការល្អ គឺ ចិត្តដែលបុគ្គលហ្វឹកហាត់ដោយអរិយមគ្គ ៤ បានដល់ ចិត្ត ដែលបុគ្គលធ្វើហើយដោយប្រការដែលចិត្តអស់អំណាចបានជាការល្អ ។ ព្រោះហេតុអ្វី? ព្រោះថា ចិត្តនេះ ដែលបុគ្គលហ្វឹកហាត់ហើយរមែងជាហេតុនាំមកនូវសេចក្ដីសុខ គឺថា ចិត្តដែលបុគ្គលហ្វឹកហាត់ហើយបានដល់ ធ្វើឲ្យអស់អំណាច រមែងនាំមកនូវសេចក្ដីសុខដែលកើតឡើងអំពី

អរិយផល និងសុខ គឺ ព្រះនិព្វានដែលជាបរមត្ថ ។

ក្នុងកាលចប់ទេសនា បរិស័ទដែលមកប្រជុំគ្នាដ៏ច្រើន ក៏បានសម្រេចជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ព្រះធម៌ទេសនាសម្រេចប្រយោជន៍ដល់មហាជនហើយ ដូច្នេះ ។

## ភិក្ខុនោះត្រឡប់ទៅកាន់មាតិកគ្រាមវិញ

ព្រះសាស្តា លុះប្រទានឱវាទនេះដល់ភិក្ខុនោះហើយ ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា "ទៅចុះភិក្ខុ អ្នកកុំគិតអ្វីយ៉ាងដទៃ ចូរនៅក្នុងទីនោះចុះ" ។ ភិក្ខុនោះបានព្រះឱវាទអំពីសំណាក់របស់ព្រះសាស្តាហើយ ទើបទៅ (នៅ) ក្នុងទីនោះ មិនបានគិតអ្វីៗ ដែលចិត្តនាំឲ្យគិតក្នុងខាងក្រៅឡើយ ។ ចំណែកមហាឧបាសិកា កាលពិចារណាដោយទិព្វចក្ខុ ក៏បានឃើញព្រះថេរៈហើយកំណត់ (ដឹង) ដោយញាណរបស់ខ្លួនថា "ឥឡូវនេះ ភិក្ខុជាបុត្ររបស់យើងបានអាចារ្យឲ្យឱវាទហើយ ទើបត្រឡប់មកវិញ ក៏បានចាត់ចែងអាហារដែលជាទីសប្បាយប្រគេនដល់ព្រះថេរៈនោះ ព្រះថេរៈបានភោជនដែលជាទីសប្បាយហើយ ក្នុងរវាង ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្ត

នៅដោយសេចក្ដីសុខដែលកើតពីមគ្គ និងផល គិតថា "គួរអស្ចារ្យហ្ន៎ មហាឧបាសិកា បានជាទីពឹងរបស់យើងហើយ យើងអាស្រ័យមហាឧបាសិកានេះ ទើបដល់នូវការរលាស់ចេញចាកភពបាន ហើយពិចារណាថា មហាឧបាសិកានេះ បានជាទីពឹងរបស់យើងតែក្នុងអត្តភាពនេះ ឬក៏កាលយើងត្រាច់រង្គាត់ក្នុងសង្សារវដ្ដ មហាឧបាសិកានេះធ្លាប់ជាទីពឹងក្នុងអត្តភាពដទៃៗ ដែរ" ។ ទើបតាមរឭកទៅរហូត ៩៩ អត្តភាព ។ សូម្បីមហាឧបាសិកានោះ ក៏បានជាបាទបរិចារិកា (ភរិយា) របស់ព្រះថេរៈក្នុងអត្តភាពទី ៩៩ ជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងបុរសដទៃ ទើបឲ្យសម្លាប់ព្រះថេរៈនោះ ។ ព្រះថេរៈលុះឃើញទោសរបស់មហាឧបាសិកានោះត្រឹមតែប៉ុណ្ណោះហើយ ទើបគិតថា "គួរឲ្យសង្វេគ មហាឧបាសិកានេះបានធ្វើកម្មធ្ងន់មកហើយ" ។ ចំណែកឧបាសិកាអង្គុយក្នុងផ្ទះនោះឯង ពិចារណាថា "កិច្ចនៃបព្វជិតរបស់ភិក្ខុដែលជាបុត្រយើង ដល់ទីបំផុតហើយឬនៅហ្ន៎" ជ្រាបថា ព្រះថេរៈនោះសម្រេចព្រះអរហត្តហើយ ទើបពិចារណាតទៅទៀត ក៏ជ្រាបថា "ភិក្ខុអ្នកជាបុត្ររបស់យើងសម្រេចព្រះអរហត្តហើយ គិតថា គួរជ្រះថ្លាណាស់ ឧបាសិកានេះបានជាទី

ពីងរបស់យើងដ៏សំខាន់ ដូច្នេះ ហើយពិចារណា (តទៅទៀត) ថា សូម្បី ក្នុងអតីតកាល ឧបាសិកានេះបានធ្លាប់ជាទីពឹងរបស់យើង ឬមិនធ្លាប់ទេ ។ តាមរឭកទៅរហូត ៩៩ អត្តភាព តែយើងបានឃុបឃិតជាមួយបុរសដទៃ សម្លាប់ព្រះថេរៈនោះក្នុងអត្តភាពទី ៩៩ ព្រះថេរៈនេះបានឃើញទោសមាន ប្រមាណប៉ុណ្ណេះរបស់យើងហើយ គិតថា គួរឲ្យសង្វេគ ឧបាសិកាបានធ្វើ កម្មធ្ងន់ហើយ ។ នាងពិចារណា (តទៅទៀត) ថា "យើងកាលត្រាច់រង្គាត់ ទៅក្នុងសង្សារវដ្ដ យើងធ្លាប់បានធ្វើឧបការៈដល់ភិក្ខុដែលជាបុត្រនេះ ឬ មិនធ្លាប់ហ្ន៎" បានរឭកដល់អត្តភាពទី ១០០ ក៏ជ្រាបថា ក្នុងអត្តភាពទី ១០០ យើងជាបាទបរិចារិកានៃព្រះថេរៈនោះ បានឲ្យជីវិតជាទានក្នុងទីដែលត្រូវ សម្លាប់មួយកន្លែង គួរអស្ចារ្យណាស់ហ្ន៎ យើងធ្វើឧបការៈច្រើនដល់ភិក្ខុ ដែលជាបុត្ររបស់យើង អង្គុយនៅក្នុងផ្ទះនោះឯង ពោលថា "សូមលោក ម្ចាស់ ពិចារណាមើលឲ្យក្រៃលែងឡើងចុះ" ។ ព្រះថេរៈនោះ បានស្ដាប់ សំឡេង (របស់ឧបាសិកានោះ) ដោយសោតធាតុដែលជាទិព្វហើយ រឭក ដល់អត្តភាពទី ១០០ ក៏ឃើញថា ឧបាសិកានោះ បានឲ្យជីវិតដល់ខ្លួនក្នុង

*អត្តភាពទី ១០០ ទើបគិតថា "គួរអស្ចារ្យ ឧបាសិកានេះធ្លាប់ធ្វើឧបការៈដល់យើង ដូច្នេះ ហើយមានចិត្តរីករាយពោលបញ្ហាក្នុងមគ្គ ៤ ផល ៤ ក្នុងទីនោះឯងដល់ឧបាសិកា លោកបានបរិនិព្វានហើយ ដោយនិព្វានធាតុដែលជាអនុបាទិសេស ។*

ចប់ រឿងភិក្ខុមួយរូប

# ៣. រឿងឧក្កណ្ឋិតភិក្ខុ

ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុដែលអផ្សុក (ចង់សឹក) មួយរូប ត្រាស់ព្រះធម្មទេសនានេះថា **សុទុទ្ទសំ** (...ដែលឃើញបានសែនលំបាក) ជាដើម ។

ដូចបានស្តាប់មក កាលព្រះសាស្តាប្រថាប់នៅក្នុងក្រុងសាវត្ថី បុត្រសេដ្ឋីបានចូលទៅរកព្រះថេរៈជាជីតុន[១] របស់ខ្លួន ពោលថា "លោកដ៏ចម្រើន ខ្ញុំប្រាថ្នានឹងរួចចាកទុក្ខ សូមលោកម្ចាស់ប្រោសប្រាប់អាការដែលឲ្យរួចចាកទុក្ខដល់ខ្ញុំ ត្រឹមតែមួយ" ។ ព្រះថេរៈពោលថា "ល្អហើយ អ្នកមានអាយុ បើលោកប្រាថ្នានឹងរួចចាកទុក្ខសោត លោកចូរថ្វាយសលាកកត្ត[២] ថ្វាយបក្ខិកកត្ត[៣] ថ្វាយវស្សាវាសិកកត្ត[៤] ថ្វាយបច្ច័យទាំងឡាយមានចីវរជាដើម បែងចែកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យជា ៣ ចំណែក ប្រកបការងារដោយទ្រព្យ ១ ចំណែក ចិញ្ចឹមបុត្រ និងភរិយា ១ ចំណែក ថ្វាយទ្រព្យទុកក្នុងព្រះពុទ្ធ-

---

១.កុលុបកៈ អ្នកចូលទៅកាន់ត្រកូល . ២ កត្តដែលទាយកថ្វាយតាមស្លាក . ៣ កត្តដែលទាយកថ្វាយក្នុងថ្ងៃបក្ស ៤. កត្តដែលទាយកថ្វាយដល់ភិក្ខុអ្នកចាំវស្សា ។

សាសនា ១ ចំណែក” ។ គេទទួលថា “សាធុ លោកម្ចាស់” ហើយធ្វើកិច្ចគ្រប់យ៉ាងតាមលំដាប់នៃកិច្ចដែលព្រះថេរៈប្រាប់ ហើយសួរព្រះថេរៈទៀតថា “ខ្ញុំនឹងធ្វើបុណ្យអ្វីដទៃឲ្យក្រៃលែងជាងនេះទៀត លោកម្ចាស់” ព្រះថេរៈឆ្លើយថា “អ្នកមានអាយុ លោកចូរទទួលត្រៃសរណៈ (និង) សីល ៥” ។ គេទទួលត្រៃសរណៈ និងសីល ៥ សូម្បីទាំងនោះហើយ ទើបសួរដល់បុញ្ញកម្មដែលក្រៃលែងជាងនោះទៀត ។ ព្រះថេរៈក៏ណែនាំថា “បើដូច្នោះ លោកចូរទទួលសីល ១០” ។ គេពោលថា “សាធុ លោកម្ចាស់” ។ ហើយក៏ទទួលសីល ១០ ។ ព្រោះហេតុដែលគេធ្វើបុញ្ញកម្មយ៉ាងនោះដោយលំដាប់ គេទើបមាននាមថា អនុបុព្វសេដ្ឋីបុត្រ ។ គេសួរទៀតថា “បុញ្ញកម្មដែលខ្ញុំធ្វើសូម្បីក្រៃលែងជាងនេះ នៅមានឬលោកម្ចាស់?” កាលព្រះថេរៈពោលថា “បើដូច្នោះ លោកចូរបួស” ទើបចេញបួសហើយ ។ ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មមួយរូបបានជាអាចារ្យរបស់លោក ភិក្ខុអ្នកទ្រទ្រង់វិន័យមួយរូបបានជាព្រះឧបជ្ឈាយ៍ ។ កាលកុលបុត្រនោះបួសហើយ អាចារ្យពោលបញ្ហាក្នុងព្រះអភិធម្មក្នុងវេលាដែលលោកមកកាន់សំណាក់របស់ខ្លួនថា “ឈ្មោះថា

ក្នុងព្រះពុទ្ធសាសនា ភិក្ខុធ្វើកិច្ចនេះទើបគួរ ធ្វើកិច្ចនេះមិនគួរ" ។ ចំណែកព្រះឧបជ្ឈាយ៍ក៏បានពោលបញ្ហាក្នុងព្រះវិន័យ ក្នុងវេលាដែលលោកមកកាន់សំណាក់របស់ខ្លួនថា "ឈ្មោះថា ក្នុងព្រះពុទ្ធសាសនា ភិក្ខុធ្វើវត្តនេះគួរ ធ្វើវត្តនេះមិនគួរ វត្តនេះសម វត្តនេះមិនសម" ។ លោកគិតថា "ឱហ្ន៎ កម្មនេះធ្ងន់ យើងប្រាថ្នានឹងរួចផុតចាកទុក្ខទើបបួស តែក្នុងព្រះពុទ្ធសាសនានេះ អ្វីដែលក្នុងកណ្ដាប់ដៃរបស់យើងមិនប្រាកដ យើងនៅក្នុងផ្ទះក៏អាចរួចចាកទុក្ខក្នុងវដ្តៈបាន យើងគួរជាគ្រហស្ថ (ល្អជាង)" ។ តាំងពីនោះមកលោកក៏អផ្សុក (ចង់សឹក) អស់សេចក្ដីត្រេកអរ (ក្នុងព្រហ្មចារ្យ) មិនធ្វើការស្វាធ្យាយក្នុងអាការ ៣២ ។ មិនរៀនឧទ្ទេស ស្គម ស្លេកស្លាំង មានខ្លួនពេញទៅដោយសរសៃ ត្រូវសេចក្ដីខ្ជិលក្រអូសគ្រប់សង្កត់ ពាសពេញហើយដោយពកគរមាស់ ។ លំដាប់នោះ ពួកភិក្ខុកំលោះ និងសាមណេរសួរលោកថា "អ្នកមានអាយុ ហេតុអ្វីលោកឈរនៅក្នុងទីដែលឈរហើយ អង្គុយក្នុងទីដែលអង្គុយហើយ ត្រូវរោគស្គមស្លាំងគ្របសង្កត់ ស្គម ស្លេកស្លាំងមានខ្លួនពេញទៅដោយសរសៃ ត្រូវសេចក្ដីខ្ជិលក្រអូសគ្របសង្កត់ ពាសពេញ

ហើយដោយភេគរមាស់ លោកធ្វើកម្មអ្វីហ្ន៎?" ។

ភិក្ខុ. អ្នកមានអាយុ ខ្ញុំជាអ្នកនឿយណាយ ។

ភិក្ខុកម្លោះ និងសាមណេរ. ព្រោះហេតុអ្វី ?

ភិក្ខុនោះប្រាប់ព្រឹត្តិការណ៍នោះហើយ ។ ភិក្ខុកម្លោះ និងសាមណេរទាំងនោះ ក៏ប្រាប់ដល់ព្រះអាចារ្យ និងព្រះឧបជ្ឈាយ៍របស់លោកហើយ ។ ព្រះអាចារ្យ និងព្រះឧបជ្ឈាយ៍បាននាំភិក្ខុនោះទៅកាន់សម្នាក់របស់ព្រះសាស្តា ព្រះសាស្តាត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកដោយកិច្ចអ្វី" ។

អាចារ្យ និងព្រះឧបជ្ឈាយ៍. បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុរូបនេះនឿយណាយក្នុងព្រះសាសនារបស់ព្រះអង្គ ។

ព្រះសាស្តា. បានឮថា យ៉ាងនោះឬ ភិក្ខុ?

ភិក្ខុ. យ៉ាងនោះមែន ព្រះអង្គ ។

ព្រះសាស្តា. ព្រោះហេតុអ្វី?

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះ) ខ្ញុំព្រះអង្គប្រាថ្នានឹងរួចចាកទុក្ខទើបបានបួស ព្រះអាចារ្យរបស់ខ្ញុំព្រះអង្គ ពោលព្រះអភិធម្មកថា ព្រះ

ឧបជ្ឈាយ៍ ពោលវិន័យកថា ។ ខ្ញុំព្រះអង្គបានធ្វើការសម្រេចចិត្តថា ក្នុងព្រះពុទ្ធសាសនានេះ អ្វីដែលស្ថិតក្នុងកណ្ដាប់ដៃមិនប្រាកដឡើយ យើងជាគ្រហស្ថក៏អាចរួចចាកទុក្ខបាន យើងនឹងជាគ្រហស្ថ ព្រះអង្គ ។

ព្រះសាស្ដា. ម្នាលភិក្ខុ បើអ្នកអាចរក្សាបានត្រឹមវត្ថុតែមួយប៉ុណ្ណោះ កិច្ច គឺ ការរក្សាវត្ថុទាំងឡាយដ៏សេស រមែងមិនមានឡើយ ។

ភិក្ខុ. អ្វីទៅ ព្រះអង្គ?

ព្រះសាស្ដា. អ្នកនឹងអាចរក្សាចិត្តរបស់អ្នក បានទេ?

ភិក្ខុ. អាចរក្សាបាន ព្រះអង្គ ។

ព្រះសាស្ដាប្រទានព្រះឱវាទនេះថា "បើដូច្នោះ អ្នកចូររក្សាចិត្តរបស់ខ្លួនចុះ អ្នកនឹងអាចផុតចាកទុក្ខបាន" ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញបានដោយកម្រក្រៃពេក
ដែលល្អិតក្រៃពេក មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុង

*អារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ*

*រមែងនាំមកនូវសេចក្តីសុខ ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **សុទុទ្ទសំ** (ដែលឃើញដោយកម្រក្រៃពេក) បានដល់ លំបាកនឹងឃើញបានដោយល្អ ។ បទថា **សុនិបុណំ** (ដែលល្អិតក្រៃពេក) បានដល់ ល្អិតជាទីបំផុត គឺ ល្អិតក្រៃលែង ។ បទថា **យត្ថកាមនិបាតិនំ** (មានប្រក្រតីធ្លាក់ចុះទៅក្នុងសេចក្តីប្រាថ្នា) សេចក្តីថា ប្រាថ្នាមិនពិចារណាមើលឋានៈទាំងឡាយមានជាតិជាដើម ធ្លាក់ទៅក្នុងអារម្មណ៍ណាមួយ ក្នុងឋានៈដែលគប្បីបាន ឬមិនគប្បីបាន សមគួរ ឬមិនសមគួរ ។ បទថា **ចិត្តំ រក្ខេថ មេធាវី** (អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក) សេចក្តីថា ជនអន្ធពាល មានបញ្ញាថោកទាប ឈ្មោះថា អាចរក្សាចិត្តរបស់ខ្លួនទុកបាន រមែងមិនមាន គេជាអ្នកប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងដល់សេចក្តីវិនាស ។ ចំណែកអ្នកមានបញ្ញា គឺ ជាបណ្ឌិតរមែងអាចរក្សាចិត្តទុកបាន ព្រោះថា ចិត្តនេះ ដែលគ្រប់គ្រងបាន ជាហេតុ*

នាំសុខមកឲ្យ គឺ រមែងនាំមកនូវសេចក្តីសុខ ដែលកើតអំពីមគ្គផល និង ព្រះនិព្វាន ។

ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុនោះ ក៏បានសម្រេចសោតាបត្តិផល ជនសូម្បីពួកដទៃដ៏ច្រើន ក៏បានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ។ ព្រះធម៌ទេសនា មានសម្រេចប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ឯង ។

ចប់ រឿងព្រះឧក្កណ្ឋិតភិក្ខុ

# ៤. រឿងព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះ សង្ឃរក្ខិតៈ ត្រាស់ព្រះធម្មទេសនានេះថា* ***ទូរង្គមំ ឯកចរំ*** *(...ដែលទៅក្នុងទីឆ្ងាយ ត្រាច់ទៅតែឯង) ជាដើម ។*

*ដូចបានស្តាប់មក កុលបុត្រមួយរូបក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយចេញបួស បានឧបសម្បទា មាននាមថា សង្ឃរក្ខិតត្ថេរ ក្នុងរវាង ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចព្រះអរហត្តផល ។ ប្អូនប្រុសរបស់លោកបានបុត្រហើយ ក៏បានតាំងឈ្មោះរបស់ព្រះថេរៈ (ដល់បុត្រនោះ) ។ គេមាននាមថា ភាគិនេយ្យសង្ឃរក្ខិត ចម្រើនវ័យហើយ ក៏បានបព្វជ្ជាឧបសម្បទាក្នុងសំណាក់របស់ព្រះថេរៈ គេទៅចាំវស្សាក្នុងវត្តជិតស្រុក បានសំពត់វស្សាវាសិកសាដក (សំពត់ដែលប្រគេនដល់ភិក្ខុអ្នកនៅចាំវស្សាហើយ) ២ ផ្ទាំង គឺ ប្រវែង ៧ ហស្ថមួយផ្ទាំង ប្រវែង ៨ ហស្ថមួយផ្ទាំង កំណត់ថា សំពត់ផ្ទាំងប្រវែង ៨ ហស្ថ នឹងជារបស់ព្រះឧបជ្ឈាយ៍យើង ។ គិតថា សំពត់ផ្ទាំងប្រវែង ៧ ហស្ថ នឹងជារបស់យើង ។ ចេញវស្សាហើយ*

ប្រាថ្នានឹងសួរសុខទុក្ខព្រះឧបជ្ឈាយ៍ និមន្តមកបិណ្ឌបាតក្នុងចន្លោះផ្លូវ គ្រាមក (ដល់) ហើយ កាលព្រះថេរៈមិនទាន់ត្រឡប់មកកាន់វិហារនោះឯង គេចូលទៅកាន់វិហារ ហើយសម្អាតទីសម្រាប់ស្នាក់នៅពេលថ្ងៃរបស់ព្រះថេរៈ ចាត់ចែងទឹកលាងជើង ក្រាលអាសនៈ ហើយអង្គុយចាំមើលផ្លូវព្រះថេរៈមក ។ លុះជ្រាបដំណឹងព្រះថេរៈមកដល់ហើយ ក៏ធ្វើការទទួលរាក់ទាក់ ទទួលបាត្រចីវរ អារាធនាព្រះថេរៈឲ្យគង់ដោយពាក្យថា "សូមលោកម្ចាស់គង់ចុះ" ។ កាន់ផ្លិតស្លឹកត្នោតបក់ ហើយថ្វាយទឹកឆាន់ លាងជើងទាំងពីរ នាំសំពត់សាដកនោះមកទុកក្នុងទីជិតជើង ពោលថា "លោកម្ចាស់ សូមលោកម្ចាស់ប្រើប្រាស់សំពត់សាដកផ្ទាំងនេះ" ដូច្នេះ ហើយបានឈរបក់លោក ។ លំដាប់នោះ ព្រះថេរៈពោលចំពោះលោកថា "សង្ឃរក្ខិតៈ ចីវររបស់ខ្ញុំបរិបូរណ៍ហើយ លោកចូរប្រើប្រាស់ចុះ ។

ព្រះសង្ឃរក្ខិត. លោកម្ចាស់ សំពត់សាដកនេះ ខ្ញុំកំណត់ទុកដើម្បីលោកម្ចាស់តែម្យ៉ាង តាំងពីវេលាដែលខ្ញុំបានហើយ សូមលោកម្ចាស់ប្រើប្រាស់ចុះ ។

ព្រះថេរៈ. ណ្ហើយចុះ សង្ឃរក្ខិតៈ ចីវររបស់ខ្ញុំសម្បូរហើយ លោកទុកប្រើប្រាស់ចុះ ។

ព្រះសង្ឃរក្ខិតៈ. លោកម្ចាស់ សូមលោកម្ចាស់កុំធ្វើយ៉ាងនោះឡើយ (ព្រោះ) កាលលោកម្ចាស់ប្រើប្រាស់សំពត់នេះ ផលច្រើននឹងមានដល់ខ្ញុំ ។

លំដាប់នោះ កាលព្រះសង្ឃរក្ខិតសូម្បីពោល (អង្វរ) ហើយ ព្រះថេរៈក៏មិនប្រាថ្នាសំពត់ផ្ទាំងនោះ ។ លោកឈរបក់ ទាំងស្ទុងគំនិតយ៉ាងនេះថា ក្នុងវេលាជាគ្រហស្ថ យើងជាចៅរបស់ព្រះថេរៈ ក្នុងវេលាបួសហើយ យើងក៏ជាសទ្ធិវិហារិក (របស់លោក) សូម្បីយ៉ាងនេះ ព្រះឧបជ្ឈាយ៍ក៏មិនប្រាថ្នាធ្វើការប្រើប្រាស់រួមជាមួយនឹងយើង បើព្រះឧបជ្ឈាយ៍មិនប្រើប្រាស់រួមជាមួយយើង យើងនឹងត្រូវការអ្វីដោយភាពជាសមណៈ យើងនឹងជាគ្រហស្ថ (ល្អជាង) ។ ខណៈនោះ លោកមានការគិតឃើញថា ការគ្រប់គ្រងផ្ទះបានដោយលំបាក យើងជាគ្រហស្ថនឹងធ្វើអ្វីក្នុងការចិញ្ចឹមជីវិត តពីនោះគិតថា យើងនឹងលក់សំពត់សាដកផ្ទាំងវែង ៨ ហត្ថ ហើយទិញមេពពែមួយក្បាល ធ្វើឲ្យជាដើមទុន កាលរួមដើមទុនបានច្រើន និងនាំស្រីម្នាក់មក

ធ្វើជាកិរិយា នាងនឹងប្រសូត្របុត្រម្នាក់ ក្នុងកាលនោះ យើងនឹងតាំងឈ្មោះរបស់អ៊ុំប្រុសដល់បុត្រនោះ ហើយឲ្យអង្គុយក្នុងយានតូច នាំបុត្រ និងនាងជាកិរិយារបស់យើងមកថ្វាយបង្គំលោកអ៊ុំ ពេលដើរមក នឹងនិយាយចំពោះកិរិយារបស់យើងក្នុងចន្លោះផ្លូវថា នាងចូរហុចបុត្រមកឲ្យយើង យើងនឹងនាំចូលទៅ នាងនឹងនិយាយថា អ្នកនឹងត្រូវការអ្វីដោយបុត្រ អ្នកចូរមកចូរបោលនូវយានតូចនេះទៅ ហើយក៏ពបុត្រទៅដោយតាំងចិត្តថា យើងនឹងនាំគេទៅ កាលមិនអាចនាំទៅបាន យើងនឹងដាក់ត្រង់ជានកង់រទេះ កាលនោះ កង់រទេះនឹងកិនសរីរៈរបស់គេ ពេលនោះ យើងនឹងនិយាយចំពោះនាងថា នាងមិនឲ្យបុត្ររបស់ខ្ញុំដល់ខ្ញុំ នាងក៏មិនអាចនាំបុត្រនោះទៅបានដែរ បុត្រនោះរមែងជាអ្នកដែលនាងឲ្យវិនាសហើយ និងយកដងជន្លួញវាយខ្នងកិរិយា ។ លោកក្មួយនោះគិតយ៉ាងនោះ ក្នុងខណៈឈរបក់ផ្លិតនោះឯង ក៏យកដងផ្លិតស្ទីកគោ្គាតវាយសីសៈរបស់ព្រះថេរៈហើយ ។ ព្រះថេរៈពិចារណាថា "ព្រោះហេតុអ្វី យើងទើបត្រូវសង្ឃរក្ខិតវាយសីសៈ" ដឹងរឿងដែលក្មួយប្រុសនោះគិតហើយទាំងអស់ ទើបនិយាយថា "សង្ឃរក្ខិតៈ អ្នកវាយមិន

ត្រូវស្ត្រីនោះទេ ក្នុងរឿងនេះយើងមានទោសអ្វី?” លោកគិតថា “ស្លាប់ហើយ យើងវិនាសហើយ ន័យថា ព្រះឧបជ្ឈាយ៍ដឹងរឿងដែលយើងគិតហើយ យើងនឹងត្រូវការអ្វីដោយភាពជាសមណៈ” ដូច្នេះ ទើបបោះផ្ចិតស្លឹកត្នោតចោលផ្ដើមនឹងគេចចេញទៅ ។ លំដាប់នោះ ភិក្ខុកំលោះ និងសាមណេរទាំងឡាយក៏តាមចាប់ភិក្ខុនោះ នាំមកកាន់សំណាក់របស់ព្រះសាស្ដា ។ ព្រះសាស្ដាទតឃើញភិក្ខុទាំងនោះហើយ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកធ្វើអ្វី ពួកអ្នកបានភិក្ខុមួយរូបនេះ?” ពួកភិក្ខុទូលថា “ករុណាព្រះអង្គ ពួកខ្ញុំព្រះអង្គនាំភិក្ខុកំលោះរូបនេះដែលអផ្សុក (ចង់សឹក) ហើយលបរត់ នាំមកកាន់សំណាក់របស់ព្រះអង្គ” ។ ព្រះសាស្ដាត្រាស់ថា “បានឮថា យ៉ាងនោះឬភិក្ខុ?” ព្រះសង្ឃរក្ខិតៈទូលថា “ករុណា ព្រះអង្គ” ។

ព្រះសាស្ដា. ម្នាលភិក្ខុ អ្នកធ្វើកម្មធ្ងន់យ៉ាងនេះដើម្បីអ្វី អ្នកជាបុត្ររបស់ព្រះពុទ្ធដែលព្រះអង្គជាអ្នកប្រារព្ធសេចក្ដីព្យាយាម បួសក្នុងសាសនារបស់ព្រះពុទ្ធដូចតថាគតមិនមែនឬ មិនអាចឲ្យគេហៅខ្លួនថា ព្រះសោតាបន្នព្រះសកទាគាមី ព្រះអនាគាមី ឬព្រះអរហន្ត បានធ្វើកម្មធ្ងន់យ៉ាងនេះដើម្បីអ្វី ។

ព្រះសង្ឃរក្ខិត:. ខ្ញុំព្រះអង្គអផ្សុក (ចង់សឹក) ព្រះអង្គ ។

ព្រះសាស្តា. ព្រោះហេតុអ្វី អ្នកទើបអផ្សុក (ចង់សឹក) ។

ព្រះសង្ឃរក្ខិត: ក្រាបទូលរឿងទាំងអស់នោះដល់ព្រះសាស្តា ចាប់តាំងពីថ្ងៃបានសំពត់វស្សាវាសិកសាដក រហូតដល់យកដងផ្ចិតស្លឹកត្នោតវាយសីស:ព្រះថេរ: ហើយក្រាបទូលថា "ព្រោះហេតុនេះ ខ្ញុំព្រះអង្គទើប(គិត) លបរត់ចេញទៅ" ។ លំដាប់នោះ ព្រះសាស្តាត្រាស់ចំពោះលោកថា "មកចុះភិក្ខុ អ្នកកុំគិតឡើយ ធម្មតាចិត្តនេះមាននាទីទទួលអារម្មណ៍ សូម្បីមាននៅក្នុងទីឆ្ងាយ ភិក្ខុគប្បីព្យាយាម ដើម្បីប្រយោជន៍ដល់ការរួចផុតអំពីគ្រឿងចង គឺ រាគ: ទោស: មោហ:" ដូច្នេះ ហើយត្រាស់ព្រះគាថានេះថា ៖

ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។

អ្នកទាំងឡាយ នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅ
តែឯង មិនមានសរីរ: មានគូហា គឺ មហាភូតរូប ៤ ជាទី

*អាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។*

# អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា **ទូរង្គមំ (ដែលទៅក្នុងទីឆ្ងាយ)** ជាដើម (គប្បីវិនិច្ឆ័យដូចតទៅនេះ) ក៏ឈ្មោះថា ការទៅ និងការមករបស់ចិត្ត ដោយចំណែកនៃទិសបូព៌ជាដើម សូម្បីមួយរយៈស្ពាដេកលក់ រមែងមិនមាន ចិត្តនោះរមែងទទួលអារម្មណ៍សូម្បីមាននៅក្នុងទីឆ្ងាយ ព្រោះហេតុនោះ ទើបឈ្មោះថា **ដែលទៅក្នុងទីឆ្ងាយ** ។ មួយវិញទៀត ចិត្ត ៧-៨ ដួង ឈ្មោះថាអាចកើតឡើងជាប់គ្នាដោយការរួមគ្នាក្នុងខណៈតែមួយ រមែងមិនមាន ក្នុងកាលកើតឡើង ចិត្តរមែងកើតឡើងមួយដួងៗ កាលចិត្តដួងនោះរលត់ ចិត្តដួងថ្មីក៏កើតឡើងមួយដួងទៀត ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកចរំ (ត្រាច់ទៅតែមួយដួង)** ។ សរីរសណ្ឋានក្ដី ប្រភេទនៃពណ៌ មានពណ៌ខៀវជាដើមក្ដីរបស់ចិត្ត រមែងមិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា **អសរីរំ (មិនមានសរីរៈ)** ។ គុហា គឺ មហាភូតរូប ៤ ឈ្មោះថា គុហា ក៏ចិត្តនេះអាស្រ័យហទយរូបប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **គុហាសយំ***

*(មានគូហាជាទីអាស្រ័យ)* ។ បទថា **យេ ចិត្តំ** *(ជនពួកណា "ទឹងសង្រួម ចិត្ត)* សេចក្តីថា ជនពួកណាមួយ គឺ ជាបុរស ឬស្ត្រី ជាគ្រហស្ថ ឬបព្វជិត ញុំាងកិលេសដែលមិនមាន ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើង លះកិលេសដែលកើតឡើងហើយព្រោះការហ្វឹកហាត់សតិ ឈ្មោះថា សង្រួម ចិត្ត គឺ ធ្វើចិត្តឲ្យស្ងប់ បានដល់ មិនឲ្យរាយមាយ ។ បទថា **មោក្ខន្តិ មារពន្ធនា** *(រមែងរួចពីចំណងនៃមារ)* សេចក្តីថា ជនពួកនោះទាំងអស់ ឈ្មោះថា នឹងផុតចាកវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលរាប់ថា ជាគ្រឿងចងរបស់ មារ ព្រោះមិនមានគ្រឿងចង គឺ កិលេស ។

ក្នុងកាលចប់ព្រះទេសនា ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរៈបានសម្រេច សោតាបត្តិផលហើយ ។ ជនសូម្បីដទៃដ៏ច្រើន ក៏បានជាអរិយបុគ្គលមាន ព្រះសោតាបន្នជាដើម ។ ព្រះទេសនាបានសម្រេចនូវប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។

ចប់ រឿងព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ

# ៥. រឿងចិត្តហត្ថត្ថេរ

*ព្រះសាស្ដា កាលទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះចិត្តហត្ថ ត្រាស់ព្រះធម្មទេសនានេះថា* ***អនវដ្ឋិតចិត្តស្ស*** *(...ដល់អ្នក* ***មានចិត្តមិនខ្ជាប់ខ្ជួន****) ជាដើម ។*

*បានឮមកថា កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ ស្វែងរកគោដែលបាត់ ទើបចូលព្រៃ ឃើញគោក្នុងវេលាថ្ងៃ ក៏ដេញឲ្យចូលហ្វូង ហើយគិតថា "យើងនឹងបានវត្ថុត្រឹមតែអាហារ ក្នុងសំណាក់របស់ភិក្ខុទាំងឡាយដោយពិត" ត្រូវសេចក្ដីស្រេកឃ្លានបៀតបៀនហើយ ទើបចូលទៅកាន់វិហារ ដល់សំណាក់របស់ភិក្ខុទាំងឡាយ ថ្វាយបង្គំហើយ បានឈរនៅក្នុងទីមួយកន្លែង ។ ក៏ក្នុងសម័យនោះឯង ភត្ត (អាហារ) ដែលសល់អំពីភិក្ខុទាំងឡាយធាន់នៅមានក្នុងថាស ។ ភិក្ខុទាំងនោះឃើញគេស្រេកឃ្លាន ទើបពោលថា "សូមអ្នកកាន់យកភត្តនេះបរិភោគចុះ" ។ ក៏ក្នុងសម័យពុទ្ធកាល សម្ល និងម្ហូបដ៏ច្រើនរមែងកើតឡើង គេទទួលភត្តល្មមនឹងរក្សាអត្តភាពអំពីថាសនោះ បរិភោគ ផឹកទឹក លាងដៃហើយ ក៏ថ្វាយបង្គំភិក្ខុទាំងឡាយ សួរថា "លោក*

ម្ចាស់ ថ្ងៃនេះលោកម្ចាស់ទាំងឡាយបានទៅកាន់ទីនិមន្ត ហើយមកឬ?" ភិក្ខុទាំងឡាយឆ្លើយថា "ឧបាសក ថ្ងៃនេះមិនមានកិច្ចនិមន្ត ភិក្ខុទាំងឡាយ រមែងបាន (កត្តាហារ) រឿយៗ ដោយទំនងយ៉ាងនេះឯង" ។ គេគិតថា ពួកយើងខ្វល់ខ្វាយក្រោកឡើងហើយ សូម្បីធ្វើការងាររឿយៗ អស់យប់ និងថ្ងៃ ក៏នៅមិនបានកត្តមានរសឆ្ងាញ់យ៉ាងនេះ បានឮថា ភិក្ខុទាំងនោះ រមែងឆាន់រឿយៗ យើងនឹងជាគ្រហស្ថធ្វើអ្វី យើងនឹងជាភិក្ខុ" ដូច្នេះ ទើបចូលទៅរកភិក្ខុទាំងឡាយសូមបព្វជ្ជា ។ លំដាប់នោះ ពួកភិក្ខុនិយាយចំពោះគេថា "ជាការល្អហើយឧបាសក" ក៏ឲ្យគេបព្វជ្ជា ។ គេបានឧបសម្បទាហើយ ធ្វើវត្ត-បដិបត្តិដែលជាឧបការៈដល់ភិក្ខុទាំងពួង ។ លោកក៏បានមានរាងកាយធាត់ដោយកន្ទងទៅ ២-៣ ថ្ងៃ ព្រោះលាភ និងសក្ការៈ ដែលកើតដល់ព្រះពុទ្ធទាំងឡាយ ។ តអំពីនោះ លោកគិតថា "យើងនឹងត្រូវអ្វី ដោយការត្រាច់ទៅដើម្បីបិណ្ឌបាតចិញ្ចឹមជីវិត យើងនឹងជាគ្រហស្ថ" ។ លោកសឹកហើយ ក៏ត្រឡប់ទៅផ្ទះ ។ កាលកុលបុត្រ (សឹកថ្មី) នោះ ធ្វើការងារនៅក្នុងផ្ទះ រាងកាយក៏ស្គមស្គាំងដោយ ២-៣ ថ្ងៃ ប៉ុណ្ណោះ ។ តពីនោះ គេក៏គិតថា

“យើងនឹងទ្រាំនៅជាមួយទុក្ខនេះធ្វើអ្វី យើងនឹងជាសមណៈ” ដូច្នេះហើយ ក៏ត្រឡប់បួសជាថ្មី ។ លោកនៅមិនបានប៉ុន្មានថ្ងៃផង ក៏អផ្សុក ហើយសឹកទៀត ។ តែលោកបានឧបការៈដល់ភិក្ខុក្នុងវេលាបួស ។ ប្រមាណ ២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏កើតសេចក្តីរង្កៀស ហើយគិតថា “យើងនៅជាគ្រហស្ថធ្វើអ្វី យើងនឹងបួស” ទើបថ្វាយបង្គំភិក្ខុទាំងឡាយសូមបព្វជ្ជា ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏ឲ្យគេបព្វជ្ជាទៀត ដោយអំណាចនៃឧបការៈ គេបួសហើយសឹកយ៉ាងនេះ អស់ ៦ ដង ។

ភិក្ខុទាំងឡាយគិតថា “ភិក្ខុនេះ ប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត” ទើបដាក់នាមដល់លោកថា **ចិត្តហត្ថត្ថេរៈ** ។ កាលនាយចិត្តហត្ថនោះត្រាច់ទៅមកៗ យ៉ាងនេះ ភរិយាក៏មានគភ៌ ។ ក្នុងវារៈទី ៧ គេលីគ្រឿងភ្ជួរអំពីព្រៃ (ត្រឡប់) ទៅផ្ទះ ដាក់គ្រឿងភ្ជួរទុកហើយ ចូលបន្ទប់ដោយបំណងថា “នឹងយកសំពត់កាសាវៈរបស់ខ្លួន” ។ ក្នុងខណៈនោះ ភរិយារបស់គេកំពុងដេកលក់ ។ សំពត់ដែលនាងដណ្តប់ក៏របូត ទឹកមាត់ហូរចេញអំពីមាត់ ស្រមុកខ្វលៗ មាត់ចំហ ខាំធ្មេញក្រឹតៗ ។ នាងប្រាកដដល់គេ ដូចរាងកាយ

ដែលហើមប៉ោង ។ គេគិតថា “រាងកាយនេះមិនទៀង ជាទុក្ខ យើងបួស អស់កាលប្រមាណប៉ុណ្ណេះហើយ អាស្រ័យរាងកាយនេះ ទើបមិនអាចតាំង ក្នុងភាពជាភិក្ខុបាន” ដូច្នេះ ក៏ចាប់យកសំពត់កាសាវៈរុំខ្លួន ដើរចេញអំពី ផ្ទះ ។ ខណៈនោះ សូម្បីយាយរបស់គេឈរនៅត្រង់ផ្ទះជិតគ្នា ឃើញគេ កំពុងដើរទៅដោយអាការយ៉ាងនោះ សង្ស័យថា “គេនេះត្រឡប់ទៅវិញហើយ គេទើបមកអំបាញ់មិញនេះឯង ក៏រុំសំពត់កាសាវៈត្រង់ពោះ ចេញដើរទៅ បែរមុខឆ្ពោះទៅកាន់វិហារ គេកើតអ្វីហ្ន៎” ទើបចូលក្នុងផ្ទះ ឃើញកូនស្រី ដេកលក់ ដឹងថា “គេឃើញកូនស្រីរបស់យើងនេះ មានការធុញទ្រាន់ ទើប ចេញទៅ” ទើបវាយកូនស្រី ពោលថា “ស្រីថោកទាប ចូរក្រោកឡើង ប្ដី របស់ឯងឃើញឯងដេក ក៏មានការធុញទ្រាន់ គេទៅហើយ តាំងអំពីព្រឹក នាងនឹងមិនមានគេ” ។ កូនស្រីពោលថា “ទៅក៏ទៅចុះម៉ែ គេទៅបានតែ ២-៣ ថ្ងៃប៉ុណ្ណោះ គេក៏នឹងត្រឡប់មកវិញហើយ” ។ សូម្បីនាយចិត្តហស្ថ នោះ ដើរបណ្ដើរត្អូញត្អែរបណ្ដើរថា “រាងកាយនេះមិនទៀង ជាទុក្ខ” ។ ក៏បានសម្រេចសោតាបត្តិផល ។ គេទៅថ្វាយបង្គំភិក្ខុទាំងឡាយ ហើយក៏

សូមបព្វជ្ជា ។ ភិក្ខុទាំងឡាយពោលថា “ពួកយើងមិនអាចឲ្យលោកបព្វជ្ជាបានទេ ភាពជាសមណៈរបស់លោកនឹងមានអំពីណា សីសៈរបស់លោកដូចជាថ្មសំលៀងកាំបិត ដូច្នោះ” ។ គេពោលថា “លោកម្ចាស់ សូមលោកម្ចាស់ប្រោសអនុគ្រោះឲ្យខ្ញុំបួសតែមួយដងនេះទៀតផងចុះ” ។ ភិក្ខុទាំងនោះទើបឲ្យគេបួស ដោយអំណាចនៃឧបការៈ ។ មិនយូរប៉ុន្មានក្នុង ២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។ ភិក្ខុសម្បីទាំងនោះពោលចំពោះលោកថា “ចិត្តហត្ថ លោកគួរដឹងវេលាដែលលោកនឹងទៅដោយពិត ហេតុអ្វី ក្នុងពេលនេះលោកទើបមិនសឹក” លោកពោលថា “ខ្ញុំទៅហើយក្នុងវេលាដែលមានសេចក្តីជាប់ជំពាក់ លោកម្ចាស់ សេចក្តីជាប់ជំពាក់នោះ ខ្ញុំកាត់បានហើយ តអំពីនេះ ខ្ញុំមិនទៅទៀតឡើយ” ។ ពួកភិក្ខុនាំគ្នាទៅកាន់សំណាក់របស់ព្រះសាស្តា ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ ត្រូវពួកខ្ញុំព្រះអង្គពោលយ៉ាងនេះ ពោលឈ្មោះយ៉ាងនេះ លោកក៏ព្យាករណ៍ព្រះអរហត្ត លោកនិយាយពាក្យមិនពិត” ។ ព្រះសាស្តាត្រាស់ថា “យ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតបានធ្វើការទៅ

និងការមក ក្នុងវេលាមិនដឹងព្រះសទ្ធម្ម ក្នុងវេលាដែលខ្លួននៅមានចិត្តមិនខ្ជាប់ខ្ជួន ឥឡូវនេះ បុត្ររបស់តថាគតលះបង់បុណ្យ និងបាបបានហើយ” ទើបទ្រង់ត្រាស់ពីរព្រះគាថានេះថា ៖

អនវដ្ឋិតចិត្តស្ស　　សទ្ធម្មំ អវិជានតោ
បរិប្លវប្បសាទស្ស　　បញ្ញា ន បរិបូរតិ ។
អនវស្សុតចិត្តស្ស　　អនន្វាហតចេតសោ
បុញ្ញបាបប្បហីនស្ស　　នត្ថិ ជាគរតោ ភយំ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យ រមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យ និងបាបលះបោលហើយ ភ្ញាក់រឭកជានិច្ច ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា អនវដ្ឋិតចិត្តស្ស (អ្នកមានចិត្តមិនខ្ជាប់

ខ្ជិល) ព្រះសាស្តាទ្រង់សំដែងសេចក្តីថា ឈ្មោះថា ចិត្តនេះ របស់នរណាៗ មិនតាំងមាំ ឬខ្ជាប់ខ្ជួន ក៏បុគ្គលណាមិនតាំងនៅក្នុងការៈណាៗ ដូចជាផ្លែល្ពៅ ខ្ចី ដែលតាំងទុកលើខ្នងសេះ ដូចបង្គោលដែលដោតទុកក្នុងគំនរអង្កាម ដូចជាផ្កាខ្ទុមពាក់លើក្បាលទំពែក គ្រាខ្លះក៏ជាសេវកាមាត្យ គ្រាខ្លះក៏ជាអាជីវក គ្រាខ្លះក៏ជានិគ្រន្ថ គ្រាខ្លះក៏ជាតាបស បុគ្គលបែបនេះ ឈ្មោះថា មានចិត្តមិនខ្ជាប់ខ្ជួន បញ្ញាដែលជាកាមាវចរៈក្តី បញ្ញាដែលជារូបាវចរៈជាដើមក្តី រមែងមិនបរិបូណ៌ដល់បុគ្គលនោះដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងព្រះសទ្ធម្ម មានពោធិបក្ខិយធម៌ ៣៧ ប្រការ ឈ្មោះថា មានសេចក្តីជ្រះថ្លាដែលអណ្តែតឡើង ព្រោះជាអ្នកមានសទ្ធាតិច ឬព្រោះជាអ្នកមានសទ្ធាឃ្លេងឃ្លោង កាលបញ្ញាសូម្បីជាកាមាវចរៈមិនបរិបូណ៌ បញ្ញាដែលរូបាវចរៈ អរូបាវចរៈ និងលោកុត្តរៈ នឹងបរិបូណ៌អំពីណាបាន ។ បទថា **អនវស្សុតចិត្តស្ស (បុគ្គលមានចិត្តមិនទទឹកដោយរាគៈ)** បានដល់ អ្នកមានចិត្តមិនទទឹកដោយរាគៈ ។ ក្នុងបទថា **អនន្វាហតចេតសោ (មានចិត្តត្រូវទោសៈខ្ទាំងខ្ទប់)** ព្រះមាន-ព្រះភាគត្រាស់ដល់ចិត្តត្រូវទោសៈខ្ទាំងខ្ទប់ហើយ ទុកក្នុងអនាគតស្ថាន ថា

“មានចិត្តត្រូវទោសៈខ្ចាំងខ្ចប់ហើយ ក៏កើតឡើងដូចជាសសរខឿន” តែក្នុង បទថា **មានចិត្តមិនត្រូវទោសៈខ្ចាំងខ្ចប់** នេះ បណ្ឌិតគប្បីជ្រាបសេចក្តីថា អ្នកមានចិត្តដែលទោសៈមិនខ្ចាំងខ្ចប់ ។ បទថា **បុញ្ញបាបប្បហីនស្ស (លះបុណ្យ និងបាបបាន)** បានដល់ បុគ្គលលះបុណ្យ និងបាបបាន ដោយមគ្គទី ៤ គឺ ជាអ្នកអស់អាសវៈហើយ ។ បទថា **នត្ថិ ជាគរតោ ភយំ (ភ័យរមែងមិន មានដល់អ្នក... ភ្ញាក់រឭក)** សេចក្តីថា ការមិនមានភ័យ ដែលព្រះមានព្រះភាគ ត្រាស់ទុកចំពោះបុគ្គលអស់អាសវៈ ភ្ញាក់ហើយនោះឯង ក៏លោកដែលអស់ អាសវៈទាំងនោះ ឈ្មោះថា ភ្ញាក់ហើយ ព្រោះប្រកបដោយធម៌ជាហេតុឲ្យ ភ្ញាក់ទាំងឡាយ មានសទ្ធាជាដើម ព្រោះដូច្នោះ លោកភ្ញាក់ហើយ (ភ្ញាក់ ពីដេក) ក្តី នៅមិនទាន់ភ្ញាក់ (ពីដេក) ក្តី ភ័យ គឺ កិលេស ឈ្មោះថា រមែងមិនមាន ព្រោះកិលេសទាំងឡាយមិនមានការវិលត្រឡប់ ពិតហើយ កិលេសទាំងឡាយ ឈ្មោះថា រមែងមិនជាប់តាមលោក ព្រោះកិលេសទាំង ឡាយដែលលោកលះបានហើយដោយមគ្គនោះៗ មិនមានការវិលត្រឡប់មក រកលោកទៀត ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា “ព្រះអរិយ-

បុគ្គលលះកិលេសពួកណាបានហើយដោយសោតាបត្តិមគ្គ លោករមែងមិន មករក គឺ មិនត្រឡប់មកកាន់កិលេសទាំងនោះទៀត ព្រះអរិយបុគ្គលលះ កិលេសពួកណាបានហើយដោយសកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ លោករមែងមិនមករក គឺ មិនត្រឡប់មកកាន់កិលេសទាំងនោះទៀត" ។

ព្រះទេសនាមានប្រយោជន៍ មានផលដល់មហាជនហើយ ។

តមកថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាថា "អ្នកមានអាយុទាំងឡាយ ឈ្មោះថា កិលេសទាំងនេះគ្រោតគ្រាត កុលបុត្រអ្នកដល់ព្រមដោយឧប- និស្ស័យនៃព្រះអរហត្តបែបនេះ នៅត្រូវកិលេសធ្វើឲ្យវង្វេងបាន (សឹក) ជា គ្រហស្ថ ៧ ដង បួស ៧ ដង" ព្រះសាស្តាទ្រង់ស្តាប់ពាក្យដែលប្រព្រឹត្ត ទៅរបស់ភិក្ខុទាំងនោះ ទើបស្តេចទៅកាន់ធម្មសភាដោយការទៅដែលសម គួរដល់ខណៈនោះ ប្រថាប់លើពុទ្ធាសនៈ ហើយត្រាស់សួរថា "ម្នាលភិក្ខុ ទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្ន៎?" កាលពួកភិក្ខុក្រាប ទូលថា "ដោយរឿងឈ្មោះនេះ" ទើបត្រាស់ថា "យ៉ាងនោះឯង ម្នាលភិក្ខុ ទាំងឡាយ ឈ្មោះថា កិលេសទាំងឡាយ រមែងជាសភាពគ្រោតគ្រាត បើ

កិលេសទាំងនេះមានរូបរាងដែលនរណាៗ គប្បីអាចនឹងរក្សាទុកក្នុងទីទាំងពួងសោត ចក្រវាឡក៏ពេញ ព្រហ្មលោកក៏ពេញ ឱកាស (ទីចន្លោះ) របស់កិលេសទាំងនោះមិនគប្បីមានកន្លែងដាក់ឡើយ កិលេសទាំងនេះ រមែងធ្វើបុរសអាជានេយ្យដែលដល់ព្រមដោយបញ្ញាសម្បីដូចតថាគត ឲ្យវង្វេងបាននឹងពោលថ្វីក្នុងពពួកជនដ៏សេស ពិតហើយ តថាគតក៏ធ្លាប់អាស្រ័យស្តៅនិងស្លួយត្រឹមតែកន្ទះនាឡិ និងចបកំរិលមួយ បួសហើយសឹក ៦ ដង" ។ ភិក្ខុទាំងនោះក្រាបទូលសួរថា "ក្នុងកាលណា ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "នឹងស្តាប់ឬ ភិក្ខុទាំងឡាយ" ភិក្ខុទាំងនោះ ក្រាបទូលថា "ព្រះករុណា ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "បើដូច្នោះ ពួកអ្នកចូរស្តាប់" ដូច្នេះ ហើយទ្រង់នាំអតីតនិទានមក (ត្រាស់ថា) ៖

ក្នុងអតីតកាល កាលស្តេចព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពា-រាណសី បុរសម្នាក់ឈ្មោះកុទ្ទាលបណ្ឌិត បួសជាអ្នកបួសខាងក្រៅ នៅក្នុងព្រៃហិមពាន្ត ៨ ខែ កាលភូមិភាគមានទឹកជន់ ក្នុងសម័យដែលភ្លៀងធ្លាក់ ក៏គិតថា "ក្នុងផ្ទះរបស់យើងនៅមានស្តៅ និងស្លួយត្រឹមតែកន្ទះនាឡិ និងចប

កំរិលមួយ ពូជ គឺ ស្ពៅ និងស្ពួយ សូមកុំវិនាសឡើយ” ហើយសឹកទៅ យកចបជម្រះផែនដីត្រង់ទីមួយកន្លែង សាបព្រោះពូជនោះ ធ្វើរបងទុក ក្នុងវេលាដែលមានផ្លែទុំក៏ប្រូត រក្សាពូជទុកប្រមាណកន្ទះនាឡិ បរិភោគពូជដ៏សេស ។ លោកគិតថា “ឥឡូវនេះ ប្រយោជន៍អ្វីដោយការគ្រប់គ្រងផ្ទះ យើងនឹងបួស ៨ ខែទៀត ទើបចេញបួស ។ លោកអាស្រ័យស្ពៅ និងស្ពួយកន្ទះនាឡិ និងចបកំរិលមួយ ជាគ្រហស្ថ ៧ ដង បួស ៧ ដង ដោយទំនងនេះឯង តែក្នុងគ្រាទី ៧ គិតថា “យើងអាស្រ័យចបកំរិលនេះ ជាគ្រហស្ថហើយបួស ៧ ដង យើងនឹងបោះវាចោលចុះ” ។ លោកទៅកាន់ស្ទឹងគង្គា គិតថា “យើងកាលឃើញត្រង់ទីធ្លាក់ គង់នឹងមុជចុះ យើងនឹងបោះវាចោលក្នុងទីដែលយើងមិនឃើញវាធ្លាក់” ។ ទើបយកសំពត់ចាស់ខ្ចប់ពូជប្រមាណកន្ទះនាឡិ ហើយចងសំពត់ចាស់ត្រង់ដងចប ចាប់ចបត្រង់ចុងដងឈរត្រង់ស្ទឹងគង្គា បិទភ្នែកគ្រវីលើសីសៈ ៣ ដង ចោលទៅក្នុងស្ទឹងនោះទៅ បានបន្លឺសំឡេង ៣ ដងថា “យើងឈ្នះហើយ យើងឈ្នះហើយ” ។ ក្នុងខណៈនោះ ព្រះបាទក្រុងពារាណសីទ្រង់ បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់ហើយ

ស្តេចមក ទ្រង់ឲ្យតាំងជុំរំស្នាក់នៅត្រង់ស្ពឹងគង្គា ស្តេចចុះកាន់ស្ពឹងប្រាថ្នានឹងស្រង់ទឹក ទ្រង់បានឮសំឡេងនោះ ។ ក៏ជម្មតា សំឡេងដែលថា "យើងឈ្នះហើយ យើងឈ្នះហើយ" រមែងមិនមានជាទីពេញព្រះទ័យរបស់ព្រះរាជាទាំងឡាយ ។ ព្រះអង្គស្តេចទើបទៅកាន់សម្នាក់របស់កុទ្ទាលបណ្ឌិតនោះត្រាស់សួរថា "យើងធ្វើការញាំញីអមិត្រហើយ ដោយគិតថា យើងឈ្នះ ចំណែកអ្នកឯងស្រែកថា យើងឈ្នះហើយ យើងឈ្នះហើយ ព្រោះរឿងអ្វី" កុទ្ទាលបណ្ឌិតទើបក្រាបទូលថា "ព្រះអង្គទ្រង់ឈ្នះពួកចោរខាងក្រៅ ការឈ្នះដែលព្រះអង្គឈ្នះហើយ រមែងត្រឡប់ចាញ់វិញបាន ចំណែកចោរ គឺសេចក្តីលោភមានក្នុងខាងក្នុង ខ្ញុំព្រះអង្គឈ្នះហើយ ចោរ គឺ សេចក្តីលោកនោះ មិនត្រឡប់ឈ្នះខ្ញុំព្រះអង្គទៀតឡើយ ឈ្នះចោរ គឺ សេចក្តីលោភនោះតែមួយជាការប្រពៃ" ដូច្នេះ ទើបពោលគាថានេះថា ៖

ការឈ្នះណាត្រឡប់ចាញ់បាន ការឈ្នះនោះមិនមែន
ជាការឈ្នះដ៏ល្អ (ចំណែក) ការឈ្នះណាមិនត្រឡប់
ចាញ់វិញ ការឈ្នះនោះឯងជាការឈ្នះដែលប្រពៃ ។

ក្នុងខណៈនោះឯង លោកក្រឡេកមើលស្ទឹងគង្គា ញ៉ាំងកសិណមានទឹកជាអារម្មណ៍ឲ្យកើតឡើង សម្រេចនូវគុណវិសេស ហើយបានអណ្តែតក្នុងអាកាស ។ ព្រះរាជាទ្រង់ស្តាប់ធម្មកថារបស់ព្រះមហាបុរស ក៏បានថ្វាយបង្គំ ហើយទ្រង់សូមបួស ទ្រង់បួសព្រមជាមួយពួកពល ។ បរិស័ទមានប្រមាណមួយយោជន៍ ។ សូម្បីក្សត្រិយ៍សាមន្តរាជដទៃ[១] ទ្រង់ជ្រាបថា ស្តេចក្រុងពារាណសីនោះបួសហើយ ស្តេចមកបំណងថា "យើងនឹងកាន់យករាជសម្បត្តិរបស់ព្រះរាជាក្រុងពារាណសីនោះ" ទ្រង់ឃើញព្រះនគរដ៏ស្តុកស្តម្ភនោះ (ត្រឡប់ជា) ទទេស្អាត ទើបទ្រង់ត្រិះរិះថា "ព្រះរាជាទ្រង់លះបង់ព្រះនគរបែបនេះហើយបួស គឺ ទ្រង់មិនបួសក្នុងឋានៈដែលថោកទាបឡើយ (ជាការពិត) សូម្បីយើងគួរតែបួស" ដូច្នេះ ទើបស្តេចទៅក្នុងទីនោះ ចូលទៅរកព្រះមហាបុរស ទ្រង់សូមបួស ទ្រង់បួសព្រមជាមួយបរិវារហើយ ។ ព្រះរាជា ៧ ព្រះអង្គ ទ្រង់បួសដោយទំនងនេះដូចគ្នានោះឯង ។ ក្នុងកាលនោះ ក៏បានមានអាស្រមបានផ្សាយទៅរហូត ៧ យោជន៍ ។ ព្រះរាជា ៧

---

១.សាមន្តរាជា គឺ ព្រះរាជាដែលនៅជាប់ដែនគ្នា ព្រះរាជាដោយជុំវិញ ព្រះរាជាជិតខាង ។

ព្រះអង្គ ក៏ទ្រង់លះបង់ភោគៈទាំងឡាយ នាំជនមានប្រមាណប៉ុណ្ណេះចេញបួសហើយ ។ ព្រះមហាបុរសបានប្រព្រឹត្តព្រហ្មចារ្យ ជាអ្នកដល់ព្រហ្មលោកហើយ ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កុទ្ទាលបណ្ឌិតក្នុងកាលនោះ បានមកជាតថាគតក្នុងកាលឥឡូវនេះ ដែលឈ្មោះថា កិលេសនោះ គឺ មានសភាពគ្រោតគ្រាតយ៉ាងនេះ ។

ចប់ រឿងព្រះចិត្តហត្ថត្ថេរ

# ៦. រឿងភិក្ខុអ្នកប្រារព្ធវិបស្សនា

*ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធពួកភិក្ខុអ្នកប្រារព្ធវិបស្សនា ត្រាស់ព្រះធម៌ទេសនានេះថា **កុម្ភូបមំ** (...ប្រៀបដូចជាឆ្នាំង) ជាដើម ។*

*បានឮថា ភិក្ខុ ៥០០ រូបក្នុងក្រុងសាវត្ថី រៀនកម្មដ្ឋានរហូតដល់ព្រះអរហត្តក្នុងសំណាក់របស់ព្រះសាស្តា ហើយគិតថា "យើងនឹងបំពេញសមណធម៌" ធ្វើដំណើរអស់ផ្លូវប្រមាណ ១០០ យោជន៍ បានទៅដល់ស្រុកធំមួយ ។ លំដាប់នោះ ពួកមនុស្សឃើញភិក្ខុទាំងនោះ ទើបនិមន្តឲ្យគង់លើអាសនៈដែលបានចាត់ចែងទុក អង្គៀសដោយកត្តាហារទាំងឡាយ មានបាយយាគូជាដើមដ៏ប្រណីត ហើយសួរថា "ពួកលោកម្ចាស់នឹងទៅទីណា" ។ កាលភិក្ខុទាំងនោះពោលថា "ពួកអាត្មានឹងទៅកាន់ទីដែលសប្បាយ" ទើបអង្វរថា "សូមនិមន្តពួកលោកម្ចាស់នៅក្នុងទីនេះ ៣ ខែចុះ សូម្បីពួកខ្ញុំក៏នឹងតាំងនៅក្នុងសរណៈរក្សាសីល ៥ ក្នុងសំណាក់របស់ពួកលោកម្ចាស់" ជ្រាបការទទួលនិមន្តរបស់ភិក្ខុទាំងនោះហើយ ទើបសួរថា "ក្នុងទីមិនឆ្ងាយ (អំពីនេះ) មានព្រៃសណ្ឋ:*

ជំ និមន្តពួកលោកម្ចាស់ស្នាក់នៅក្នុងព្រៃសណ្ឌនោះចុះ" ដូច្នេះ ទើបជូនទៅ ។ ភិក្ខុទាំងនោះ ចូលទៅកាន់ព្រៃសណ្ឌនោះឯង ។ ពួកទេវតាអាស្រ័យនៅក្នុងព្រៃនោះ គិតថា "លោកម្ចាស់ទាំងឡាយជាអ្នកមានសីល ចូលដល់ព្រៃនេះដោយលំដាប់ហើយ ក៏កាលពួកលោកម្ចាស់ទាំងឡាយស្នាក់នៅក្នុងទីនេះ ពួកយើងនាំបុត្រ និងបងប្អូននៅលើដើមឈើមិនសមគួរឡើយ ទើបចុះមកអង្គុយលើផែនដី" គិតថា "លោកម្ចាស់ទាំងឡាយ នៅក្នុងទីនេះមួយយប់ ព្រឹកឡើងនឹងទៅហើយ" ។ ចំណែកពួកភិក្ខុត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ក្នុងថ្ងៃស្អែកឡើង ហើយក៏ត្រឡប់មកកាន់ព្រៃនោះឯង ។ ពួកទេវតាគិតថា "នរណាៗនឹងនិមន្តភិក្ខុសង្ឃឆាន់ព្រឹកនេះ ព្រោះដូច្នោះ បានជាលោកទើបត្រឡប់មកវិញ ថ្ងៃនេះលោកមិនទៅ ព្រឹកស្អែកនឹងទៅជាប្រាកដ" ដូច្នេះ ទើបនាំគ្នាមកនៅលើផែនដីនោះឯង ប្រមាណជាកន្លះខែដោយឧបាយយ៉ាងនេះឯង ។ តពីនោះមក ពួកទេវតាគិតថា "លោកម្ចាស់ទាំងឡាយ នឹងនៅក្នុងទីនេះឯងអស់ ៣ ខែ ក៏កាលលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះឯង ពួកយើងសូម្បីឡើងអង្គុយលើដើមឈើក៏មិនគួរ សូម្បីការនាំយកពួកបុត្រ និងបងប្អូនអង្គុយ ឈរលើ

ផែនដីអស់ ៣ ខែ ក៏ជាទុក្ខរបស់យើង ពួកយើងនឹងធ្វើអ្វីៗ ឲ្យភិក្ខុទាំងនេះចៀសចេញទៅទើបគួរ" ។ ទេវតាទាំងនោះ ផ្ដើមសំដែងរាងខ្មោចក្បាលដាច់ និងឲ្យឮសំឡេងអមនុស្ស ក្នុងទីស្នាក់ពេលយប់ ក្នុងទីស្នាក់ពេលថ្ងៃ និងក្នុងទីបំផុតនៃទីចង្ក្រមនោះៗ ។ រោគទាំងឡាយ មានរោគស្ដមជាដើម ក៏កើតដល់ពួកភិក្ខុហើយ ។ ភិក្ខុទាំងនោះសួរគ្នាថា "អ្នកមានអាយុ រោគអ្វីបៀតបៀនលោក រោគអ្វីបៀតបៀនលោក" ពោលថា អ្នកមានអាយុ ថ្ងៃនេះ ខ្ញុំបានឃើញខ្មោចដាច់ក្បាលក្នុងទីបំផុតនៃទីចង្ក្រម ខ្ញុំបានឃើញខ្មោចត្រង់ទីនៅក្នុងពេលយប់ ខ្ញុំបានឮសំឡេងអមនុស្សក្នុងទីនៅពេលថ្ងៃ ទីនេះជាទីដែលគួរវៀរ ការមិនសប្បាយ ក៏មានដល់ពួកយើងក្នុងទីនេះ ពួកយើងនឹងទៅកាន់សម្នាក់ព្រះសាស្ដា ។ ភិក្ខុទាំងនោះចេញ (អំពីព្រៃ) ទៅកាន់សំណាក់របស់ព្រះសាស្ដាដោយលំដាប់ ថ្វាយបង្គំហើយ អង្គុយនៅក្នុងដ៏សមគួរ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់សួរចំពោះភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនអាចនៅក្នុងទីនោះបានឬ" ។

ពួកភិក្ខុ. ព្រះករុណា ព្រះអង្គ អារម្មណ៍ដែលគួរខ្លាចបែបនេះ ប្រាកដ

ដល់ពួកខ្ញុំព្រះអង្គទាំងឡាយដែលនៅក្នុងទីនោះ ព្រោះហេតុនោះ ទើបមានការមិនសប្បាយបែបនេះ ខ្ញុំព្រះអង្គទាំងឡាយគិតថា "ទីនេះជាទីគួរវៀរចេញ" ទើបលះបង់ទីនោះមកកាន់សំណាក់របស់ព្រះអង្គ ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទៅក្នុងទីនោះឯង សមគួរ ។

ពួកភិក្ខុ. មិនអាចទេ ព្រះអង្គ ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនយក (កាន់យក) អាវុធទៅ ឥឡូវនេះ ពួកអ្នកចូរកាន់ (យក) អាវុធទៅចុះ ។

ពួកភិក្ខុ. កាន់យកអាវុធប្រភេទណាទៅ ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា "តថាគតនឹងឲ្យអាវុធដល់ពួកអ្នក ពួកអ្នកចូរកាន់យកអាវុធដែលតថាគតឲ្យ ទៅចុះ" ដូច្នេះ ទើបត្រាស់មេត្តសូត្រទាំងអស់ថា ៖

អ្នកដឹងសន្តបទ (បទដែលស្ងប់) គប្បីធ្វើសិក្ខា ៣ ណា អ្នកឆ្លាតក្នុងប្រយោជន៍ គប្បីធ្វើសិក្ខា ៣ នោះ អ្នកឆ្លាតក្នុងប្រយោជន៍ គប្បីជាអ្នកអង់អាច ជាអ្នកត្រង់ ជាអ្នកស្មោះត្រង់ ជាអ្នកប្រដៅ

ងាយ ជាអ្នកទន់ភ្លន់ ជាអ្នកមិនប្រកាន់ខ្លួន ៗ

ជាអាទិ៍ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីស្វាធ្យាយមេត្តសូត្រនេះ ផ្តើមតាំងពីព្រៃសណ្ឌៈខាងក្រៅវិហារ ចូលទៅខាងក្នុងវិហារ" ទ្រង់ក៏បញ្ជូនទៅហើយ ៗ ភិក្ខុទាំងនោះថ្វាយបង្គំលាព្រះសាស្តា ទៅដល់ព្រៃសណ្ឌៈនោះដោយលំដាប់ នាំគ្នាស្វាធ្យាយជាពួកតាំងពីខាងក្រៅវិហារ ចូលទៅកាន់ព្រៃសណ្ឌៈនោះ ៗ

ពួកទេវតាក្នុងព្រៃសណ្ឌៈទាំងអស់ ក៏ត្រឡប់ជាបានមេត្តាចិត្ត ធ្វើការក្រោកទទួលភិក្ខុទាំងនោះ សួរដោយអើពើដល់ការទទួលបាត្រ និងចីវរ សួរដោយអើពើដល់ការគក់ប្រេបាច់កាយ ធ្វើការរក្សាឲ្យរៀបរយនៅក្នុងទីនោះ ៗ ដល់ពួកភិក្ខុ ៗ ដែលឈ្មោះថា សំឡេងរបស់អមនុស្សក៏មិនមានក្នុងទីណាៗទៀតឡើយ ៗ ចិត្តរបស់ភិក្ខុទាំងនោះក៏មានអារម្មណ៍តែមួយ ៗ ពួកលោកអង្គុយនៅក្នុងទីស្នាក់ពេលយប់ និងទីស្នាក់ពេលថ្ងៃ ញុំាងចិត្តឲ្យធ្លាក់ចុះក្នុងវិបស្សនា ពិចារណាការអស់ទៅ និងសូន្យទៅក្នុងខ្លួន គិតថា "ដែលឈ្មោះថា អត្តភាពនេះ ក៏ដូចជាភាជនៈដី ព្រោះអត្ថថា បែកធ្លាយ មិនមាំមួន" បាន

ចម្រើនវិបស្សនាហើយ ។ ព្រះសម្មាសម្ពុទ្ធប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបថា ភិក្ខុទាំងនោះផ្ដើមវិបស្សនាហើយ ទើបទ្រង់ហៅភិក្ខុទាំងនោះត្រាស់ថា "ដូច្នោះឯង ភិក្ខុទាំងឡាយ ដែលឈ្មោះថាអត្តភាពនេះ រមែងដូចជាភាជនៈដីដោយពិត ព្រោះអត្ថថា បែកធ្លាយ មិនមាំមួន" ដូច្នេះ ទើបទ្រង់បញ្ចេញព្រះរស្មីទៅ សូម្បីប្រថាប់នៅក្នុងទី ១០០ យោជន៍ ក៏ហាក់ដូចជាព្រះអង្គគង់ប្រថាប់នៅក្នុងទីចំពោះមុខភិក្ខុទាំងនោះ ទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សីមានព្រះរូប (ព្រះវរកាយ) ប្រាកដហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ឋបេត្វា
យោធេថ មារំ បញ្ញាវុធេន
ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

បុគ្គលដឹងច្បាស់នៅកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជា

អ្នកជំអក់នៅ (ក្នុងធម៌នោះ) ឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កុម្ភូបមំ (ដែលប្រៀបដូចឆ្នាំង)** សេចក្តីថា ដឹងនូវកាយនេះ គឺ ដែលរាប់ថា ប្រជុំនៃអាការមានសក់ជាដើម ឈ្មោះថា ប្រៀបដូចជាឆ្នាំង គឺ ដូចជាកាជនៈដី ព្រោះអត្ថថា មិនមានកម្លាំង និងសាប-សូន្យកម្លាំង ព្រោះអត្ថថា ប្រព្រឹត្តទៅមួយជួរខណៈ ដោយភាពជាកាយមិនយឺនយូរ ។ បទថា **នគរូបមំ ចិត្តមិទំ ឋបេត្វា (បិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ)** ជាដើម សេចក្តីថា ធម្មតានគរ មានគូជ្រៅៗ ហោមព័ទ្ធដោយកំពែង ប្រកបដោយទ្វារ និងប៉ម រមែងឈ្មោះថា រឹងមាំខាងក្រៅ ដល់ព្រមដោយផ្លូវបែកជា ៤ មានរានផ្សារក្នុងចន្លោះ ឈ្មោះថា ចាត់ចែងបានល្អក្នុងខាងក្នុង ពួកចោរខាងក្រៅមកកាន់ព្រះនគរនោះ ដោយគិតថា "យើងនឹងប្លន់" ក៏មិនអាចចូលទៅបាន រមែងដូចជាទង្គិចប៉ះភ្នំ ហើយខ្ចាតត្រឡប់វិញ យ៉ាងណា កុលបុត្រដែលជាបណ្ឌិតក៏ដូច្នោះដូចគ្នា ញុំាងវិបស្សនាចិត្តរបស់ខ្លួនឲ្យមាំមួន គឺ ឲ្យដូចជានគរ ហាមកិលេសដោយមគ្គៗ នោះ គប្បីសម្លាប់ដោយ

អាវុធ គឺ បញ្ញា ដែលសម្រេចហើយដោយវិបស្សនា និងអរិយមគ្គ ឈ្មោះថា គប្បីច្បាំង គឺ គប្បីប្រហារកិលេសមារនោះ ដូចអ្នកច្បាំងឈរនៅខាងក្នុងព្រះនគរ ច្បាំងនឹងពួកចោរដោយអាវុធមានប្រការផ្សេងៗ មានអាវុធមុខម្ខាងជាដើម ដូច្នោះ ។ បទថា **ជិតញ្ច រក្ខេ (គប្បីរក្សាជ័យជំនះដែលឈ្នះហើយ)** សេចក្តីថា កុលបុត្រកាលសេពអាវាសជាទីសប្បាយ វដ្តជាទីសប្បាយ គោ-ជនជាទីសប្បាយ បុគ្គលជាទីសប្បាយ និងការស្តាប់ធម៌ជាហេតុនៃសេចក្តីសប្បាយជាដើម ចូលសមាបត្តិក្នុងចន្លោះៗ ចេញចាកសមាបត្តិនោះ ពិចារណាសង្ខារទាំងឡាយដោយចិត្តបរិសុទ្ធ ឈ្មោះថា គប្បីរក្សាធម៌ដែលឈ្នះហើយ គឺ វិបស្សនាដែលទន់ខ្ចី ដែលខ្លួនឲ្យកើតឡើងហើយ ។ បទថា **អនិវេសនោ សិយា (គប្បីជាអ្នកមិនជំអក់នៅ)** បានដល់ គប្បីជាអ្នកមិនមានអាល័យ ។ អធិប្បាយថា អ្នកចម្បាំង ធ្វើកន្លែងការពារដែលជាទីរក្សាពលក្នុងភូមិប្រទេសជិតកន្លែងសង្គ្រាម ច្បាំងជាមួយពួកអមិត្រ (សត្រូវ) កាលបើស្រេក ឬឃ្លានហើយ កាលគ្រឿងក្រោះ ឬអាវុធអស់ហើយ ក៏ចូលទៅកាន់ទីការពារ សម្រាកបរិភោគ ផឹកទឹក ពាក់ក្រោះ ចាប់អាវុធហើយចេញច្បាំងទៀត ញាំញីសេនា

របស់សត្រូវ ឈ្នះបរបក្សដែលមិនទាន់បានឈ្នះ រក្សាជ័យជំនះដែលបានឈ្នះហើយ ប្រសិនបើអ្នកច្បាំងនោះ កាលសម្រាកនៅក្នុងជម្រកការពារយ៉ាងនោះ ត្រេកអរក្នុងទីជម្រកការពារនោះ គប្បីធ្វើរាជសម្បត្តិឲ្យប្រព្រឹត្តទៅក្នុងកណ្ដាប់ដៃរបស់សត្រូវ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា ព្យាយាមចូលសមាបត្តិ ចេញចាកសមាបត្តិនោះ ពិចារណាសង្ខារទាំងឡាយដោយចិត្តបរិសុទ្ធ រមែងអាចរក្សាវិបស្សនាទន់ខ្ចីដែលបានចំពោះហើយ រមែងឈ្នះកិលេសមារដោយការបានចំពោះនូវមគ្គដ៏ក្រៃលែង ប្រសិនបើ ភិក្ខុនោះ រមែងពេញចិត្តតែក្នុងសមាបត្តិ មិនព្យាយាមពិចារណាសង្ខារទាំងឡាយដោយចិត្តដែលបរិសុទ្ធទេ រមែងមិនអាចសម្រេចមគ្គ និងផលបាន ព្រោះដូច្នោះ ភិក្ខុ កាលរក្សាធម៌ដែលគួររក្សា គប្បីជាអ្នកមិនជំអក់នៅ គឺ គប្បីធ្វើសមាបត្តិឲ្យដូចជាទីស្នាក់នៅហើយមិនជំអក់នៅ បានដល់ មិនគប្បីអាល័យក្នុងសមាបត្តិនោះ ។ ព្រះសាស្ដាទ្រង់ត្រាស់ថា "អ្នកទាំងឡាយចូរធ្វើយ៉ាងនោះ" ដូច្នេះ ហើយទ្រង់សំដែងធម៌ដល់ភិក្ខុទាំងឡាយនោះ ដោយប្រការដូច្នេះ ។

ក្នុងកាលចប់ព្រះទេសនា ភិក្ខុ ៥០០ រូប អង្គុយក្នុងទីនោះឯង ក៏បាន

*សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ សរសើរ រីករាយ និង ថ្វាយបង្គំព្រះសរីរៈដែលមានវណ្ណៈដូចជាមាសរបស់ព្រះតថាគត បាននិមន្តមក ហើយនោះឯង ។*

ចប់ រឿងភិក្ខុអ្នកប្រារព្ធវិបស្សនា

# ៧. រឿងព្រះបូតិកត្តតិស្សត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធព្រះថេរៈមួយរូបនាមថា បូតិកត្តតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***អចិរំ វតយំ កាយោ (ឱហ្ន៎ មិនយូរប៉ុន្មានទេតើកាយនេះ)*** *ជាដើម ។*

*បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ ស្តាប់ធម្មកថាក្នុងសំណាក់របស់ព្រះសាស្តា ថ្វាយជីវិតក្នុងព្រះសាសនា និងបានឧបសម្បទាហើយ បានឈ្មោះថា តិស្សត្ថេរៈ ។ កាលកន្លងយូរទៅ រោគបានកើតឡើងក្នុងរាងកាយរបស់លោក ។ ពងទាំងឡាយប្រមាណប៉ុនគ្រាប់ស្ពៃផុសឡើង ។ វា (ធំឡើង) ដោយលំដាប់ ប្រមាណប៉ុនគ្រាប់សណ្តែកបាយ ប្រមាណប៉ុនគ្រាប់សណ្តែកខ្មៅ ប្រមាណប៉ុនគ្រាប់ល្ពៅ ប្រមាណប៉ុនផ្លែកន្ទួតព្រៃ ប្រមាណប៉ុនផ្លែព្នៅ ហើយក៏បែក ។ រាងកាយទាំងអស់ដូចជាប្រហោងតូចៗ ។ នាមរបស់លោកក៏បានកើតឡើងថា ព្រះបូតិកត្តតិស្សត្ថេរ (ព្រះតិស្សត្ថេរអ្នកមានកាយស្អុយ) ។ តមក ក្នុងកាលដទៃ ឆ្អឹងរបស់លោកក៏បែក ។ លោកជាអ្នកដែលនរណាៗបដិបត្តិមិនបាន ។ សំពត់ស្បៀក និងសំពត់ដណ្តប់ប្រឡាក់ដោយខ្ទុះ និងឈាម*

មានសភាពដូចជាក្រឡាសំណាញ់ ។ ពួកភិក្ខុជាសទ្ធិវិហារិកជាដើម មិនអាចនឹងបដិបត្តិបាន (ទើបនាំគ្នា) លះបង់លោក ។ លោកជាអ្នកមិនមានទីពឹងដេក (ដើបលែងរួច) ។

ក៏ធម្មតាថា ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងមិនលះបង់ការប្រមើលមើលលោកអស់កាល ២ វារៈ (គឺ) ក្នុងកាលជិតភ្លឺ កាលទ្រង់ប្រមើលមើលលោកទ្រង់ប្រមើលមើលផ្ដើមអំពីកណ្ដាប់មាត់ចក្រវាឡ ធ្វើព្រះញាណឲ្យសំដៅត្រង់មកព្រះគន្ធកុដិ , កាលទ្រង់ប្រមើលមើលវេលាល្ងាច ទ្រង់ប្រមើលមើលផ្ដើមពីព្រះគន្ធកុដិ ធ្វើព្រះញាណឲ្យសំដៅត្រង់ (ចេញទៅ) ខាងក្រៅ ។ សម័យនោះ ព្រះបូតិគត្តតិស្សត្ថេរៈប្រាកដហើយខាងក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះមានព្រះភាគ ។ ព្រះសាស្ដា ទ្រង់ឃើញឧបនិស្ស័យនៃព្រះអរហត្តរបស់តិស្សភិក្ខុ ទ្រង់ព្រះតម្រិះថា "ភិក្ខុនេះត្រូវពួកសទ្ធិវិហារិកជាដើម បោះបង់ចោលហើយ ឥឡូវនេះ លោកវៀរតថាគតចេញហើយ ក៏មិនមានទីពឹងដទៃ" ដូច្នេះទើបស្ដេចយាងចេញចាកព្រះគន្ធកុដិ ដូចស្ដេចត្រាច់ចារិកក្នុងវិហារ ស្ដេចយាងទៅកាន់រោងភ្លើង ទ្រង់លាងឆ្នាំង ដាក់ទឹក លើកឡើងកាន់ចង្ក្រាន កាលទ្រង់

រង់ចាំឲ្យទឹកក្តៅ បានប្រថាប់ឈរនៅក្នុងរោងភ្លើងនោះឯង ទ្រង់ជ្រាបទឹកក្តៅហើយ ស្តេចទៅចាប់ចុងគ្រែព្រះតិស្សភិក្ខុដេក ។ ក្នុងកាលនោះ ពួកភិក្ខុបានក្រាបទូលថា "សូមព្រះអង្គស្តេចយាងចេញទៅ ព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងលើក" ហើយ (ជួយគ្នា) លើកគ្រែ នាំទៅកាន់រោងភ្លើង ។ ព្រះសាស្តាទ្រង់ឲ្យនាំទឹកមក ទ្រង់ចាក់ទឹកក្តៅ (ដាក់) ហើយទ្រង់ត្រាស់ប្រាប់ភិក្ខុទាំងនោះឲ្យ (ផ្លាស់) យកសំពត់ដណ្តប់របស់លោកចេញ ឲ្យបោកនឹងទឹកក្តៅ ហើយឲ្យហាលថ្ងៃ ។ លំដាប់នោះព្រះសាស្តា ប្រថាប់ឈរនៅក្នុងទីជិតលោក ទ្រង់ស្រោចរាងកាយនោះឲ្យសើមដោយទឹកក្តៅអុនៗ ទ្រង់ដុសរាងកាយរបស់លោកឲ្យលោកងូតទឹកហើយ ។ ក្នុងទីបំផុតនៃការងូតទឹករបស់លោក សំពត់ដណ្តប់ក៏ស្ងួតហើយ ។ ពេលនោះ ព្រះសាស្តាទ្រង់ឲ្យលោកដណ្តប់សំពត់នោះ ទ្រង់ឲ្យបោកសំពត់កាសាវៈដែលលោកស្លៀកដោយទឹក ហើយឲ្យហាលថ្ងៃ ។ ពេលនោះ កាលទឹកត្រង់កាយរបស់លោកស្ងួត សំពត់ដណ្តប់នោះក៏ស្ងួត ។ លោកស្លៀកសំពត់កាសាវៈមួយផ្ទាំង ដណ្តប់សំពត់កាសាវៈមួយផ្ទាំង ជាអ្នកមានរាងកាយស្ងប់ ចិត្តមានអារម្មណ៍តែមួយ ដេកលើគ្រែហើយ ។ ព្រះសាស្តា

ប្រថាប់នៅទីខាងលើសីសៈរបស់លោក ត្រាស់ថា “ម្នាលភិក្ខុ កាយរបស់អ្នកនេះ កាលវិញ្ញាណទៅប្រាសហើយ រកឧបការៈមិនបាន នឹងដេក (ស្តូកស្តឹង) លើផែនដី ដូចជាអង្កត់ឧស” ដូច្នេះ ហើយត្រាស់ព្រះគាថានេះថា ៖

*អចិរំ វតយំ កាយោ     បឋវឹ អធិសេស្សតិ*

*ឆុទ្ធោ អបេតវិញ្ញាណោ     និរត្ថំវ កលិង្គរំ ។*

*ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស*

*គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើផែនដី*

*ដូចជាអង្កត់ឧស រកប្រយោជន៍គ្មាន ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **អចិរំ វត** (មិនយូរប៉ុន្មានហ្ន៎) ជាដើម សេចក្តីថា ភិក្ខុ កាលមិនយូរប៉ុន្មានឡើយ កាយនេះនឹងដេកស្តូកស្តឹងលើផែនដី គឺ នឹងដេកលើផែនដី ដែលសត្វដេកហើយ ដោយការដេកជាប្រក្រតីនេះ ។*

*បទថា **ឆុទ្ធោ** (ត្រូវបុគ្គលបោះបង់ចោល) ព្រះសាស្តាទ្រង់សម្តែងក្នុងអត្ថថា “កាយនេះ ត្រូវបោះបង់ហើយ គឺ នឹងដេកមានសភាពទទេ ព្រោះមានវិញ្ញាណ*

*ទៅប្រាស" ។ ដូចជាអ្វី? **និរត្ថំវ កលិង្គរំ** (ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន) អធិប្បាយថា ដូចអង្កត់ឧសដែលគ្មានឧបការៈ មិនមានប្រយោជន៍ ។ ពិតហើយ ពួកមនុស្សដែលមានសេចក្តីត្រូវការដោយទព្វសម្ភារៈ ចូលទៅកាន់ព្រៃហើយ កាត់ឈើត្រង់ដោយសណ្ឋាននៃឈើត្រង់ ឈើកោងដោយសណ្ឋាននៃឈើកោង កាន់យក (ជា) ទព្វសម្ភារៈ តែកាត់ឈើមានប្រហោង ឈើពុក ឈើមិនមានខ្លឹម ឈើដែលកំពឹកកំពកដ៏សេស ចោលក្នុងព្រៃនោះឯង មនុស្សពួកដទៃអ្នកមានសេចក្តីត្រូវការដោយទព្វសម្ភារៈមកហើយ ឈ្មោះថាប្រាថ្នាកាន់យកកំណាត់ឈើដែលចោលនោះ រមែងមិនមាន មនុស្សពួកនោះពិនិត្យមើលឈើនោះហើយ រមែងកាន់យកឈើដែលមានឧបការៈដល់ខ្លួនតែប៉ុណ្ណោះ ឈើពីក្រៅនេះ រមែងជាឈើសង្កត់លើផែនដីតែម្យ៉ាង ក៏ឈើនោះគប្បីជាឈើដែលនរណាៗ អាចនឹងធ្វើជាជើងគ្រែ ឬឈើប្រឹត់ ឬថា តាំងជាបន្ទះក្តារ ដោយឧបាយនោះៗ បាន , ចំណែកថា បណ្តាចំណែក ៣២ ក្នុងអត្តភាពនេះ សូម្បីចំណែកណាមួយ ឈ្មោះថា ចូលដល់ជារបស់ដែលនឹងគប្បីកាន់យកបាន ដោយអំណាចនៃឧបករណ៍វត្ថុ មានជើងគ្រែជាដើម ឬដោយ*

មុខជាឧបការៈយ៉ាងដទៃ រមែងមិនមាន កាយនេះ កាលមានវិញ្ញាណទៅប្រាស ហើយ មិនយូរប៉ុន្មាន ក៏នឹងត្រូវដេកលើផែនដី ដូចអង្កត់ឧសរកប្រយោជន៍ គ្មាន ។

ក្នុងវេលាចប់ទេសនា ព្រះបូតិគត្តតិស្សត្ថេរៈ ក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាហើយ ។ សូម្បីជនដទៃដ៏ច្រើន ក៏បានសម្រេចជាព្រះ អរិយបុគ្គល មានសោតាបន្នជាដើម ។ ចំណែកព្រះថេរៈសម្រេចព្រះអរហត្ត ហើយ ក៏បរិនិព្វាន ។ ព្រះសាស្តាប្រោសឲ្យធ្វើសរីរកិច្ចរបស់លោក ទ្រង់រក្សា (អដ្ឋិ) ធាតុ ហើយប្រោសឲ្យធ្វើចេតិយទុក ។

ពួកភិក្ខុ ក្រាបទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គ ព្រះបូតិគត្ត-តិស្សត្ថេរៈ កើតក្នុងទីណា?" ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ លោកបរិនិព្វានហើយ ។

ពួកភិក្ខុ. បពិត្រព្រះអង្គ កាយរបស់ភិក្ខុដល់ព្រមដោយឧបនិស្ស័យ នៃព្រះអរហត្តបែបនេះ ជាកាយស្អុយ ព្រោះហេតុអ្វី ក៏ឆ្អឹងទាំងឡាយបែក ហើយ ព្រោះហេតុអ្វី អ្វីជាហេតុនៃឧបនិស្ស័យព្រះអរហត្តរបស់លោក ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ផលទាំងអស់នេះ កើតហើយដល់តិស្សត្ថេរៈនោះ ក៏ព្រោះកម្មដែលខ្លួនធ្វើទុកហើយ ។

ពួកភិក្ខុ. ក៏កម្មអ្វី ដែលលោកធ្វើទុក ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកអ្នកចូរស្តាប់" ដូច្នេះ ទើបទ្រង់នាំអតីតនិទាន (ត្រាស់ដូចតទៅនេះ) ៖

តិស្សភិក្ខុនេះជាព្រានបក្សី ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមថា **កស្សបៈ** សម្លាប់សត្វដ៏ច្រើនទំនុកបម្រុងឥស្សរជន លក់សត្វដ៏សេសអំពីសត្វដែលឲ្យដល់ឥស្សរជនទាំងនោះ គិតថា "សត្វដ៏សេសនឹងលក់ កាលយើងសម្លាប់ហើយរក្សាទុក នឹងស្អុយចោល ទើបកាច់ឆ្អឹងស្មងជើង និងឆ្អឹងស្លាបរបស់សត្វទាំងនោះ ធ្វើឲ្យវាហើរទៅណាមិនបាន ហើយគរទុក" ។ គេលក់សត្វទាំងនោះក្នុងវេលាព្រឹកឡើង ក្នុងវេលាដែលបានសត្វដ៏ច្រើនក៏ឲ្យអាំងទុកដើម្បីប្រយោជន៍ដល់ខ្លួន ។ ថ្ងៃមួយ កាលភោជនមានរសរបស់គេឆ្អិនហើយ ព្រះខីណាស្រពមួយអង្គត្រាច់ទៅដើម្បីបិណ្ឌបាត បានឈរនៅត្រង់ទ្វារផ្ទះរបស់គេ ។ គេឃើញព្រះថេរៈហើយ ញុំាងចិត្តឲ្យជ្រះថ្លា គិតថា "សត្វ

មានជីវិតទាំងឡាយដ៏ច្រើន ដែលយើងសម្លាប់ហើយ ក៏លោកម្ចាស់ឈរនៅត្រង់ទ្វារផ្ទះរបស់យើង និងភោជនដែលមានរស ក៏មាននៅខាងក្នុងផ្ទះរបស់យើង យើងនឹងថ្វាយបិណ្ឌបាតដល់លោក ដូច្នេះ ទើបទទួលបាត្ររបស់ព្រះខីណាស្រពនោះ ដាក់ភោជនដែលមានរសនោះឲ្យពេញក្នុងបាត្រ ហើយថ្វាយបិណ្ឌបាតដែលមានរស ហើយថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ពោលថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំគប្បីដល់ទីបំផុតនៃធម៌ដែលលោកម្ចាស់ឃើញចុះ" ។ ព្រះថេរៈបានធ្វើអនុមោទនាថា "ចូរយ៉ាងនោះចុះ" ។

ម្នាលភិក្ខុទាំងឡាយ ផល (ទាំងអស់) នោះ សម្រេចហើយដល់តិស្សភិក្ខុ ដោយអំណាចនៃកម្មដែលតិស្សភិក្ខុធ្វើហើយក្នុងកាលនោះឯង កាយរបស់តិស្សភិក្ខុក៏ស្អុយ និងឆ្អឹងទាំងឡាយក៏បែក ដោយផលនៃការកាច់ឆ្អឹងសត្វទាំងឡាយ តិស្សភិក្ខុសម្រេចព្រះអរហត្ត ក៏ដោយផលនៃការថ្វាយបិណ្ឌបាតដែលមានរសដល់ព្រះខីណាស្រពនោះឯង ។

ចប់ រឿងបូតិកត្តតិស្សត្ថេរៈ

# ៨. រឿងនន្ទគោបាលកៈ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងកោសលជនបទ ទ្រង់ប្រារព្ធគោបាលឈ្មោះ នន្ទៈ ត្រាស់ព្រះធម្មទេសនានេះថា **ទិសោ ទិសំ (... ចោរឃើញចោរផងគ្នា)** ជាដើម ។*

*ដូចបានស្តាប់មក នាយគោបាលឈ្មោះនន្ទៈ ក្នុងក្រុងសាវត្ថី ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានសម្បត្តិច្រើន រក្សាហ្វូងគោរបស់គហបតីឈ្មោះអនាថបិណ្ឌិកៈ ។ ន័យថា នាយនន្ទគោបាលនោះ គេចចេញពីការបៀតបៀនរបស់ព្រះរាជាដោយភេទបព្វជិត រក្សាកំណប់ទ្រព្យរបស់ខ្លួន ។ គេកាន់យកបញ្ចគោរសអស់កាលសមគួរ ដល់កាល (តាមកំណត់វេលា) នាំទៅកាន់សម្នាក់របស់លោកអនាថបិណ្ឌិកសេដ្ឋី គាល់ព្រះសាស្តា ហើយស្តាប់ធម៌ ទូលសូមព្រះសាស្តាដើម្បីយាងស្តេចមកកាន់ទីលំនៅរបស់ខ្លួន ។ ព្រះសាស្តាទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់គេ ស្តេចមិនទាន់យាង (លុះ) ទ្រង់ជ្រាបថា គេមានញាណចាស់ក្លាហើយ ថ្ងៃមួយ មានភិក្ខុសង្ឃពួកធំហែហមហើយ ស្តេចចារិកទៅ ទ្រង់ចុះចាកផ្លូវ ប្រថាប់គង់ត្រង់ដើមឈើមួយ ដែលនៅជិតទីនៅរបស់*

គេ ។ នាយនន្ទៈទៅកាន់សំណាក់របស់ព្រះសាស្ដា ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈយាងព្រះសាស្ដា ហើយបានថ្វាយបញ្ចគោរសទានដ៏ប្រណីតដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ព្រះសាស្ដាទ្រង់អនុមោទនាស្រេចហើយ ត្រាស់អនុបុព្វីកថា មានទានកថាជាដើម ។ ក្នុងវេលាចប់កថានាយគោបាលឈ្មោះនន្ទៈ តាំងនៅក្នុងសោតាបត្តិផល ទទួលបាត្រព្រះសាស្ដាតាមជូនព្រះសាស្ដាទៅយ៉ាងឆ្ងាយ កាលព្រះសាស្ដាត្រាស់ឲ្យត្រឡប់ដោយព្រះតម្រាស់ថា "ម្នាលឧបាសក ចូរឈប់ចុះ" ។ គេក៏ថ្វាយបង្គំព្រះសាស្ដាត្រឡប់វិញ ។ លំដាប់នោះ មានព្រានម្នាក់បានចាក់គេឲ្យស្លាប់ទៅ ។ ពួកភិក្ខុដែលមកតាមក្រោយឃើញហើយ ទើបទៅក្រាបទូលព្រះសាស្ដាថា "បពិត្រព្រះអង្គនាយគោបាលឈ្មោះនន្ទៈ ថ្វាយមហាទានហើយក៏ជូនព្រះអង្គ កាលគេត្រឡប់ទៅវិញ ត្រូវព្រានម្នាក់សម្លាប់គេហើយ ព្រោះព្រះអង្គស្ដេចយាងមកក្នុងទីនេះប្រសិនបើព្រះអង្គមិនបានស្ដេចយាងមកទេ សេចក្ដីស្លាប់នឹងមិនមានដល់គេឡើយ" ។ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគតមកក្ដីមិនបានមកក្ដី ឈ្មោះថា ឧបាយជាគ្រឿងរួចចាកសេចក្ដីស្លាប់របស់នាយនន្ទៈ

នោះ សូម្បីគេទៅកាន់ទិសធំទាំង ៤ ទិសតូចទាំង ៤ រមែងមិនមាន ព្រោះថា ចិត្តប៉ុណ្ណោះបានតម្កល់ទុកខុសហើយ ដែលប្រព្រឹត្តទៅក្នុងខាងក្នុងរបស់សត្វទាំងនោះ រមែងធ្វើសេចក្ដីវិនាស ដែលពួកចោរ (ឬ) ពួកបុគ្គលចងពៀរនឹងធ្វើ (ឲ្យ) មិនមាន" ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

*ទិសោ ទិសំ យន្តំ កយិរា  វេរី វា បន វេរិនំ*
*មិច្ឆាបណិហិតំ ចិត្តំ  បាបិយោ នំ តតោ ករេ ។*

ចោរក្រឡេកឃើញចោរផងគ្នា ឬបុគ្គលមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើសេចក្ដីវិនាសណាមួយដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាងសេចក្ដីវិនាសនោះទៅទៀត ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ទិសោ ទិសំ (ចោរក្រឡេកឃើញចោរផងគ្នា) បានដល់ ចោរឃើញចោរ ។ ស័ព្ទថា ទិស្វា (ឃើញ) ជាព្រះបាលីដ៏សេស (បណ្ឌិតគប្បីបញ្ចូល) ។ បទថា យន្តំ កយិរា (គប្បីធ្វើ (ដល់គ្នា)

នោះ) បានដល់ គប្បីធ្វើសេចក្ដីវិនាសនោះដល់ចោរ ឬបុគ្គលចង់ពៀរនោះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូចគ្នា ។ មានពាក្យអធិប្បាយថា "ចោរដែលប្រទុស្សរាយចំពោះមិត្រម្នាក់ កាលប្រព្រឹត្តខុសក្នុងបុត្រ ភរិយា ស្រែ ចម្ការ គោ និងក្របីជាដើមរបស់ចោរម្នាក់ទៀត ខ្លួនខុសចំពោះចោរណា ក៏ឃើញចោរនោះសូម្បីខុសក្នុងខ្លួនយ៉ាងនោះឯង ឈ្មោះថា គប្បីធ្វើសេចក្ដីវិនាសណាដល់ចោរ ឬបុគ្គលអ្នកចងពៀរនោះ គឺ គប្បីបៀតបៀនបុត្រ និងភរិយារបស់ចោរ ឬបុគ្គលចងពៀរនោះ គប្បីធ្វើវត្ថុផ្សេងៗ មានស្រែជាដើមរបស់ចោរ ឬរបស់បុគ្គលអ្នកចងពៀរនោះឲ្យវិនាស ឬគប្បីផ្ដាច់ជីវិតចោរ ឬបុគ្គលអ្នកចងពៀរនោះ ព្រោះខ្លួនជាអ្នកកាចសាហាវ គឺ ព្រោះខ្លួនជាអ្នកធ្វើខុស ចិត្តឈ្មោះថា តាំងទុកខុស ព្រោះជាចិត្តតាំងទុកខុសក្នុងអកុសលកម្មបថ ១០ គប្បីធ្វើឲ្យគេអាក្រក់ក្រៃលែងជាងសេចក្ដីវិនាសនោះ គឺ ធ្វើបុរសនោះឲ្យជាបុគ្គលលាមកជាងហេតុនោះ ពិតហើយ ចោរក្ដី បុគ្គលចងពៀរក្ដី មានប្រការដូចពោលហើយ គប្បីញ៉ាំងទុក្ខឲ្យកើតឡើង ឬគប្បីធ្វើការអស់ទៅនៃជីវិតដល់ចោរ ឬដល់អ្នកចងពៀរ (បាន) ក្នុងអត្តភាពនេះប៉ុណ្ណោះ ចំណែកចិត្ត

ដែលតាំងទុកខុសក្នុងអកុសលកម្មបថទាំងឡាយ រមែងញ៉ាំងបុគ្គលនោះឲ្យដល់សេចក្តីវិនាសក្នុងទិដ្ឋធម៌ខ្លះ រមែងធ្លាក់ទៅក្នុងអបាយ ៤ មិនឲ្យងើបសីសៈឡើងបាន ក្នុងពាន់អត្តភាពខ្លះ” ។

ក្នុងកាលចប់ព្រះទេសនា ជនដ៏ច្រើនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ព្រះធម៌ទេសនារមែងមានប្រយោជន៍ដល់មហាជនយ៉ាងនេះ ។ ក៏កម្មដែលឧបាសកបានធ្វើទុកក្នុងរវាងភព ពួកភិក្ខុមិនបានទូលសួរ ព្រោះដូច្នោះ (កម្មនោះ) ព្រះសាស្តាទើបមិនបានត្រាស់ប្រាប់ ។

ចប់ រឿងនន្ទគោបាលកៈ

# ៩. រឿងព្រះសោរេយ្យត្ថេរ

*ព្រះសាស្តា ទ្រង់សំដែងព្រះធម្មទេសនានេះថា* **ន តំ មាតា បិតា កយិរា (មាតាបិតា... មិនគប្បីធ្វើហេតុនោះ “ឲ្យបាន”)** *ជាដើម ដែលតាំងឡើងក្នុងសោរេយ្យនគរ ឲ្យជាចុងក្រោយក្នុងក្រុងសាវត្ថី ។*

*កាលព្រះសម្មាសម្ពុទ្ធប្រថាប់នៅក្នុងក្រុងសាវត្ថី កូលប្រុសរបស់សោរេយ្យសេដ្ឋី ក្នុងសោរេយ្យនគរ អង្គុយលើយានតូចយ៉ាងសប្បាយជាមួយសំឡាញ់ម្នាក់ ចេញអំពីព្រះនគរ ដើម្បីត្រូវការនឹងងូតទឹកព្រមជាមួយបរិវារជាច្រើន ។ ខណៈនោះ ព្រះមហាកច្ចាយនត្ថេរ មានបំណងនឹងចូលទៅកាន់សោរេយ្យនគរដើម្បីបិណ្ឌបាត ស្លៀកដណ្តប់សង្ឃាដិខាងក្រៅព្រះនគរ ។ ក៏កាយរបស់ព្រះថេរៈមានពណ៌ដូចមាស ។ កូនប្រុសរបស់សោរេយ្យសេដ្ឋី ឃើញលោកហើយ ទើបគិតថា “ស្អាតណាស់ហ្ន៎ ព្រះថេរៈរូបនេះគួរជាភរិយារបស់យើង ឬសម្បុរនៃកាយរបស់ភរិយាយើង គប្បីដូចជាសម្បុរនៃកាយរបស់ព្រះថេរៈនោះ” ។ ក្នុងខណៈត្រឹមតែគិតហើយប៉ុណ្ណោះ ភេទប្រុសរបស់បុត្រសេដ្ឋីនោះក៏វិនាសទៅ ភេទស្រីបានប្រាកដឡើង ។ គេមានសេចក្តីអៀនខ្មាស*

ទើបចុះពីយានតូចនោះគេចចេញទៅ ។ អ្នកជិតខាងចាំកូនប្រុសរបស់សេដ្ឋីនោះមិនបាន ទើបពោលថា "អ្វីនោះ" ។ សូម្បីនាងក៏ដើរទៅតាមផ្លូវឆ្ពោះទៅកាន់ក្រុងតក្កសិលា ។ ចំណែកសំឡាញ់របស់នាង សូម្បីដើររកដោយជុំវិញក៏មិនបានជួប ។ ជនទាំងឡាយងូតទឹកស្រេចហើយ បានត្រឡប់ទៅកាន់ផ្ទះកាលជនទាំងឡាយនិយាយគ្នាថា "បុត្រសេដ្ឋីទៅណា" ជនដែលទៅជាមួយទើបឆ្លើយថា "ពួកខ្ញុំគិតថា គេងូតទឹកហើយៗ ត្រឡប់វិញ" ។ ខណៈនោះមាតា និងបិតារបស់គេ រកមើលនៅក្នុងទីនោះៗ កាលមិនឃើញ ទើបយំរៀបរាប់ បានថ្វាយភត្តដើម្បីអ្នកស្លាប់ដោយសេចក្ដីសម្គាល់ថា "កូនប្រុសរបស់ខ្លួនស្លាប់ហើយ" ។ នាងឃើញអ្នករទេះមួយក្រុមទៅកាន់ក្រុងតក្កសិលាទើបដើរជាប់តាមយាន ទៅអំពីខាងក្រោយ ។ ខណៈនោះ ពួកមនុស្សឃើញនាងហើយ ពោលថា "នាងដើរតាមពីក្រោយនៃយានរបស់ពួកយើងធ្វើអ្វី ពួកយើងមិនស្គាល់នាងថា នាងជាកូនស្រីរបស់អ្នកណាទេ" នាងពោលថា "នាយពួកលោកចូរជិះយានរបស់ពួកលោកចុះ ខ្ញុំនឹងដើរទៅ" កាលដើរយូរៗ ទៅ (គេអស់កម្លាំង) បានដកចិញ្ចៀនដែលពាក់ត្រង់ម្រាមដៃឲ្យហើយ ឲ្យធ្វើឱកាស

(ធ្វើចន្ទោះ) ក្នុងយានមួយកន្លែង (ដើម្បីខ្លួន) ។ ពួកមនុស្សគិតថា កូនប្រុសសេដ្ឋីរបស់ពួកយើងក្នុងក្រុងតក្កសិលានៅមិនទាន់មានភរិយា យើងទាំងឡាយនឹងប្រាប់ដល់លោក បណ្ណាការធំនឹងមានដល់ពួកយើង ។ ពួកគេក៏ចូលទៅហើយ និយាយថា "នាយ កែវ គឺ ស្រី ពួកខ្ញុំបាននាំមកហើយដើម្បីលោក ។ កូនប្រុសរបស់សេដ្ឋីនោះបានស្តាប់ហើយ ឲ្យហៅនាងមក ឃើញនាងសមនឹងវ័យរបស់ខ្លួន មានរាងស្អាតបាតគួរពេញចិត្ត ក៏មានសេចក្តីស្រឡាញ់កើតឡើង ទើបបានធ្វើនាងទុក (ឲ្យជាភរិយា) ក្នុងផ្ទះរបស់ខ្លួន ។

## ប្រុសអាចត្រឡប់ជាស្រី និងស្រីអាចត្រឡប់ជាប្រុសបាន

ពិតហើយ ពួកមនុស្សប្រុស ឈ្មោះថា មិនធ្លាប់ត្រឡប់ភេទជាស្រី ឬពួកមនុស្សស្រីមិនធ្លាប់ត្រឡប់ភេទជាប្រុស រមែងមិនមាន ។ ព្រោះថា ពួកមនុស្សប្រុសប្រព្រឹត្តកន្លងក្នុងភរិយាទាំងឡាយរបស់អ្នកដទៃ ធ្វើកាលៈហើយឆេះក្នុងនរកអស់ជាច្រើនសែនឆ្នាំ កាលត្រឡប់មកកាន់ជាតិមនុស្ស រមែងដល់ការៈជាស្រីអស់ ១០០ អត្តភាព ។ សូម្បីព្រះអានន្ទ ដែលជាអរិយសាវ័កមានបារមីបំពេញហើយមួយសែនកប្ប ត្រាច់រង្គាត់ក្នុងសង្សារ ក្នុងអត្តភាព

មួយ បានកើតក្នុងត្រកូលជាងមាស ធ្វើកម្ម គឺ ការប្រព្រឹត្តកន្លងកិរិយារបស់អ្នកដទៃ ក៏ឆេះក្នុងនរកហើយ ដោយផលកម្មដែលនៅសល់ បានត្រឡប់មកកើតជាស្រីបម្រើបុរសអស់ ១៤ អត្តភាព មិនមានកូន (ជាស្រីអា) អស់ ៧ អត្តភាព ។ ចំណែកស្រីទាំងឡាយធ្វើបុណ្យមានទានជាដើម មិនពេញចិត្តក្នុងភាពជាស្រី តាំងចិត្តថា "បុណ្យរបស់ខ្ញុំទាំងឡាយនេះ សូមប្រព្រឹត្តទៅដើម្បីត្រឡប់បានអត្តភាពជាប្រុស" ធ្វើកាលៈហើយ រមែងត្រឡប់បានអត្តភាពជាប្រុស ។ ពួកស្រីដែលមានស្វាមីដូចជាទេវតា រមែងត្រឡប់បានអត្តភាពជាប្រុស សូម្បីដោយអំណាចនៃការបដិបត្តិល្អក្នុងស្វាមីដូចគ្នា ។ ចំណែកកូនប្រុសរបស់សេដ្ឋីនេះ ញុាំងចិត្តមិនល្អឲ្យកើតឡើងក្នុងព្រះថេរៈ ទើបត្រឡប់បានភាវៈជាស្រីក្នុងអត្តភាពនេះមួយរំពេច ។

នាងបានតាំងគភ៌ហើយ ព្រោះអាស្រ័យការនៅរួមជាមួយកូនប្រុសសេដ្ឋីក្នុងក្រុងតក្កសិលា ។ ដោយកាលកន្លងទៅ ១០ ខែ នាងបាន (ប្រសូតបុត្រ) ក្នុងវេលាដែលបុត្ររបស់នាងចេះដើរ ក៏បានបុត្រសូម្បីដទៃទៀត ដោយអាការយ៉ាងនេះ បុត្ររបស់នាងទើបមានរហូត ៤ នាក់ គឺ បុត្រដែលនៅក្នុងផ្ទៃខ្លួន

២ នាក់ បុត្រកើតព្រោះអាស្រ័យលោក (កាលនៅជាប្រុស) ក្នុងសោរេយ្យនគរ ២ នាក់ ។

ក្នុងកាលនោះ កូនប្រុសសេដ្ឋីដែលជាសំឡាញ់របស់នាង (ចេញ) ពីសោរេយ្យនគរទៅកាន់ក្រុងតក្កសិលាដោយរទេះ ៥០០ គ្រឿង អង្គុយលើយានដ៏សប្បាយចូលទៅកាន់ព្រះនគរ ។ ខណៈនោះ នាងបើកបង្អួចប្រាសាទជាន់ខាងលើ ឈរមើលត្រង់វាំងផ្លូវ ឃើញសំឡាញ់នោះ ចាំគេបានច្បាស់ ទើបបញ្ជូនអ្នកបម្រើឲ្យទៅអញ្ជើញគេមក ហើយឲ្យអង្គុយលើកម្រាលដ៏មានតម្លៃច្រើន បានធ្វើសក្ការៈ និងសេចក្ដីស្មោះស្មើយ៉ាងធំ ។ ខណៈនោះ សំឡាញ់នោះពោលនឹងនាងថា "នាងដ៏ចម្រើន ក្នុងកាលមុន ខ្ញុំមិនធ្លាប់ស្គាល់នាងទេ ហេតុអ្វី នាងទើបធ្វើសក្ការៈធំដល់ខ្ញុំ នាងស្គាល់ខ្ញុំឬ"

នាង. ចាំនាយ ខ្ញុំស្គាល់ លោកជាអ្នកក្រុងសោរេយ្យនគរមែនឬ ។

សំឡាញ់. ត្រូវហើយ នាងដ៏ចម្រើន ។

នាងបានសួរដល់សេចក្ដីសុខទុក្ខរបស់មាតាបិតា របស់ភរិយា ទាំងរបស់កូនប្រុសទាំងពីរ ។ សំឡាញ់នោះបានឆ្លើយថា "នាងដ៏ចម្រើន ជនទាំង

នោះសុខសប្បាយទេ” ហើយសួរថា “នាងដ៏ចម្រើន នាងស្គាល់ជនទាំងនោះឬ ។

នាង. ចាំនាយ ខ្ញុំស្គាល់ កូនប្រុសរបស់លោកទាំងនោះ មានម្នាក់ គេទៅណាហ្ន៎ ។

សំឡាញ់. នាងដ៏ចម្រើន នាងកុំនិយាយដល់គេឡើយ ខ្ញុំជាមួយគេថ្ងៃមួយបានអង្គុយក្នុងយានដ៏សប្បាយ ចេញទៅដើម្បីងូតទឹក ស្រាប់តែមិនដឹងគេទៅណា ដើររកមើលជុំវិញនោះ (ក៏) មិនឃើញគេ ទើបបានប្រាប់ដល់មាតា និងបិតា (របស់គេ) សូម្បីមាតា និងបិតារបស់គេ បានយំខ្សឹកខ្សួលធ្វើកិច្ចដែលសមគួរអ្នកដែលស្លាប់ទៅហើយ ។

នាង. ខ្ញុំ គឺគេនោះឯង នាយ ។

សំឡាញ់. នាងដ៏ចម្រើន នាងនិយាយអ្វី សំឡាញ់របស់ខ្ញុំ ស្អាតដូចជាកូនទេវតា (ទាំង) គេជាប្រុស (ផង) ។

នាង. មែនណានាយ ខ្ញុំ គឺ គេ ។

ខណៈនោះ សំឡាញ់ទើបសួរនាងថា រឿងនេះព្រោះហេតុអ្វី ។

នាង. ថ្ងៃនោះ លោកឃើញព្រះមហាកច្ចាយនៈទេ ?

សំឡាញ់. ឃើញ ។

នាង. ខ្ញុំឃើញព្រះមហាកច្ចាយនៈជាម្ចាស់ហើយ បានគិតថា ស្អាតណាស់ហ្ន៎ ព្រះថេរៈអង្គនេះគួរជាភរិយារបស់យើង ឬថា ពណ៌សម្បុរនៃកាយរបស់ភរិយារបស់យើង គប្បីដូចជាពណ៌សម្បុរនៃកាយរបស់ព្រះថេរៈនោះ ក្នុងខណៈដែលខ្ញុំគិតហើយនោះឯង ភេទប្រុសបានវិនាសទៅ ភេទស្រីក៏បានប្រាកដឡើង ដូច្នោះ ខ្ញុំមិនអាចប្រាប់ដល់នរណាបាន ទើបគេចចេញអំពីទីនោះដោយសេចក្ដីអៀនខ្មាស មកនៅក្នុងទីនេះឯង នាយ ។

សំឡាញ់. តាមពិត លោកធ្វើកម្មធ្ងន់ហើយ ហេតុអ្វីលោកទើបមិនប្រាប់ដល់ខ្ញុំ សំឡាញ់ ក៏លោកឲ្យព្រះថេរៈអត់ទោសហើយឬ ។

នាង. នៅមិនទាន់ឲ្យលោកអត់នៅឡើយទេ នាយ ក៏លោកដឹងឬថាព្រះថេរៈនៅក្នុងទីណា ។

សំឡាញ់. ព្រះថេរៈអាស្រ័យនៅក្នុងនគរនេះឯង ។

នាង. ប្រសិនបើលោកនិមន្តបិណ្ឌបាត គប្បីមកក្នុងទីនេះសោត ខ្ញុំនឹង

សូមឲ្យលោកម្ចាស់របស់យើងអត់ទោសឲ្យដល់ខ្ញុំ ។

សំឡាញ់. បើដូច្នោះ សូមលោកចូរប្រញាប់ធ្វើសក្ការៈទុក ខ្ញុំនឹងសូមលោកម្ចាស់របស់យើងឲ្យអត់ទោសឲ្យ ។

បុត្រសេដ្ឋីទៅកាន់ទីនៅរបស់ព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយនៅក្នុងទីដ៏សមគួរមួយ ហើយនិមន្តថា “លោកម្ចាស់ ព្រឹកនេះសូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំ” ។

ព្រះថេរៈ. បុត្រសេដ្ឋី លោកជាភ្ញៀវមិនមែនឬ ។

បុត្រសេដ្ឋី. លោកម្ចាស់ សូមលោកកុំសួរការដែលខ្ញុំជាភ្ញៀវឡើយ ព្រឹកនេះ សូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំចុះ ។

ព្រះថេរៈទទួលនិមន្តហើយ ។ សក្ការៈដ៏ច្រើន គេបានត្រៀមទុក សូម្បីក្នុងផ្ទះដើម្បីព្រះថេរៈ ។ ព្រឹកឡើង ព្រះថេរៈបានទៅកាន់ទ្វារផ្ទះរបស់នាង ។ ខណៈនោះ បុត្រសេដ្ឋីនិមន្តលោកឲ្យគង់ហើយ អង្គៀសដោយអាហារដ៏ប្រណីត នាំស្រីនោះមកហើយ ឲ្យក្រាបចុះត្រង់ទៀបព្រះបាទរបស់ព្រះថេរៈ ពោលថា “លោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ស្ត្រីជាសំឡាញ់របស់ខ្ញុំផងចុះ ។

ព្រះថេរៈ. មានរឿងអ្វី ។

បុត្រសេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលមុន ម្នាក់នេះជាមិត្តជាទីស្រឡាញ់របស់ខ្ញុំ ឃើញលោកម្ចាស់ហើយ បានគិតយ៉ាងនោះ កាលនោះ ភេទប្រុសរបស់គេក៏បានវិនាសទៅ ភេទស្រីក៏បានប្រាកដឡើង សូមលោកម្ចាស់មេត្តាអត់ទោសផងចុះ ។

ព្រះថេរៈ. បើដូច្នោះ អ្នកចូរក្រោកឡើង អាត្មាអត់ទោសឲ្យគេ ។

ក្នុងទីបំផុតនៃការពោលរបស់ព្រះថេរៈថា "អាត្មាអត់ទោសឲ្យ" ប៉ុណ្ណោះ ភេទស្រីបានវិនាសទៅ ភេទប្រុសបានប្រាកដហើយ ។

កាលភេទប្រុសបានប្រាកដឡើងហើយ បុត្រសេដ្ឋីក្នុងក្រុងតក្កសិលា បានពោលចំពោះគេថា "សំឡាញ់អ្នករួមទុក្ខ ក្មេងប្រុស ២ នាក់នេះ ជាកូនរបស់យើងសូម្បីទាំងពីរពិត ព្រោះជាអ្នកនៅក្នុងផ្ទៃរបស់លោក (និង) ព្រោះជាអ្នកអាស្រ័យខ្ញុំកើត យើងទាំងពីរនាក់នឹងនៅក្នុងនគរនេះឯង លោកកុំខ្វល់ខ្វាយឡើយ" ។ សោរេយ្យសេដ្ឋីនិយាយថា "អ្នករួមទុក្ខ ខ្ញុំដល់នូវអាការដ៏ប្លែក គឺ ដំបូងជាប្រុស ហើយដល់ភាពជាស្រី និងត្រឡប់ជាប្រុសវិញទៀត

ដោយអត្តភាពតែមួយ (ប៉ុណ្ណោះ) កាលមុន បុត្រ ២ នាក់អាស្រ័យខ្ញុំកើតឡើង ឥឡូវនេះ បុត្រ ២ នាក់ ប្រសូត្រអំពីផ្ទៃរបស់ខ្ញុំ លោកកុំធ្វើសេចក្តីសំគាល់ថា ខ្ញុំនោះដល់អាការដែលប្លែកដោយអត្តភាពតែមួយ នឹងនៅក្នុងផ្ទះតទៅទៀតបាន ខ្ញុំនឹងបួសក្នុងសំណាក់របស់លោកម្ចាស់របស់យើង ក្មេង ២ នាក់នេះ ចូរជាភារៈរបស់លោក កុំបោះបង់ចោល (ប្រមាទ) ក្នុងក្មេង ២ នាក់នេះ” ដូច្នេះ ហើយថើបបុត្រទាំង ២ អង្អែល (ខ្នង) ហើយប្រគល់ឲ្យដល់បិតា ចេញទៅបួសក្នុងសំណាក់របស់ព្រះថេរៈ ។ ចំណែកព្រះថេរៈ ឲ្យលោកបព្វជាឧបសម្បទាស្រេចហើយ នាំចារិកទៅ បានទៅដល់ក្រុងសាវត្ថីដោយលំដាប់ ។ លោកក៏បានទាមថា **សោរេយ្យថេរៈ** ។

អ្នកស្រុកជនបទដឹងរឿងនោះ បានប្រមូលគ្នាទៅសួរថា “បានឮថា រឿងនេះជាការពិតឬ លោកម្ចាស់” ។

ព្រះសោរេយ្យៈ. ពិតហើយ អ្នកមានអាយុ ។

អ្នកស្រុក. លោកម្ចាស់ដ៏ចម្រើន ឈ្មោះថា ហេតុសូម្បីដូច្នេះមាន (ពិតឬ) ។ គេនិយាយគ្នាថា “បុត្រ ២ នាក់កើតក្នុងផ្ទៃរបស់លោក បុត្រ ២

នាក់អាស្រ័យលោកកើតឡើង” បណ្ដាបុត្រទាំង ២ ពួកនោះ លោកស្រឡាញ់ក្នុងពួកណា ។

ព្រះសោរេយ្យៈ. ក្នុងពួកបុត្រដែលនៅក្នុងផ្ទៃ អ្នកមានអាយុ ។

ជនអ្នកមកហើយ ក៏សួរយ៉ាងនោះឯងដូចគ្នា ។ ព្រះថេរៈប្រាប់ហើយប្រាប់ទៀតថា “មានសេចក្ដីស្រឡាញ់អ្នកនៅក្នុងផ្ទៃច្រើនជាង” ។ កាលមានការរំខាន ទើបអង្គុយតែម្នាក់ឯង ឈរតែម្នាក់ឯង ។ លោកចូលដល់ភាពជាអ្នកនៅតែម្នាក់ឯងយ៉ាងនេះ ហើយពិចារណាការអស់ទៅ សូន្យទៅក្នុងអត្តភាព ក៏បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។ តមក ពួកជនអ្នកមកហើយៗ សួរលោកថា “លោកម្ចាស់ដ៏ចម្រើន បានឮថា ហេតុយ៉ាងនេះៗ បានមានហើយឬ” ។

ព្រះសោរេយ្យៈ. ពិតហើយ អ្នកមានអាយុ ។

ពួកជន. លោកមានសេចក្ដីស្រឡាញ់ក្នុងបុត្រពួកណា ។

ព្រះសោរេយ្យៈ. ឈ្មោះថា សេចក្ដីស្រឡាញ់ក្នុងបុត្រណារបស់អាត្មារមែងមិនមាន ។

ភិក្ខុទាំងឡាយក្រាបទូលព្រះសាស្តាថា "ភិក្ខុរូបនេះ និយាយមិនពិត ក្នុងថ្ងៃមុនៗ និយាយថា មានសេចក្តីស្រឡាញ់ក្នុងបុត្រដែលនៅក្នុងផ្ទៃច្រើនជាង ឥឡូវនេះនិយាយថា សេចក្តីស្រឡាញ់ក្នុងបុត្រណាៗ របស់យើង រមែងមិនមាន រមែងព្យាករណ៍អរហត្តផល ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតព្យាករណ៍អរហត្តផលក៏មិនមែន (ព្រោះថា) តាំងពីវេលាដែលបុត្ររបស់តថាគតឃើញមគ្គទស្សនៈ[១] ដោយចិត្តដែលតាំងទុកប្រពៃហើយ សេចក្តីស្នេហាក្នុងបុត្រណាៗ មិនកើតឡើងឡើយ ចិត្តតែប៉ុណ្ណោះ ដែលប្រព្រឹត្តទៅក្នុងខាងក្នុងរបស់សត្វទាំងនេះ រមែងឲ្យនូវសម្បត្តិដែលមាតាបិតាមិនអាចធ្វើឲ្យបាន" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ន តំ មាតា បិតា កយិរា     អញ្ញេ វាបិច ញាតកា
សម្មាបណិហិតំ ចិត្តំ     សេយ្យសោ នំ តតោ ករេ ។

មាតាបិតាមិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិ
មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុក

---

១-ក្នុងកាលឃើញមគ្គ ។

ត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ន តំ (មិនគប្បីធ្វើហេតុនោះបាន) សេចក្ដីថា មាតាបិតា (និង) ញាតិដទៃ មិនគប្បីធ្វើហេតុនោះបានឡើយ ។ បទថា សម្មាបណិហិតំ (ដែលបុគ្គលតាំងទុកត្រូវហើយ) គឺ ឈ្មោះថា តាំងទុកត្រូវហើយ ព្រោះសភាពជាធម្មជាតិតាំងទុកប្រពៃក្នុងកុសលកម្មបថ ១០ ។ បទថា សេយ្យសោ នំ តតោ ករេ (រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន) សេចក្ដីថា គប្បីធ្វើ គឺ រមែងធ្វើគេឲ្យប្រសើរជាង គឺ ប្រសើរជាងបានដល់ ឲ្យក្រៃលែងជាងហេតុនោះ ។ ពិតហើយ មាតាបិតា កាលនឹងឲ្យទ្រព្យដល់បុត្រទាំងឡាយ រមែងអាចឲ្យទ្រព្យសម្រាប់ចិញ្ចឹមជីវិតនៅជាសុខដោយមិនបាច់ធ្វើការងារឡើយ បានក្នុងអត្តភាពតែមួយប៉ុណ្ណោះ សូម្បីមាតា-បិតារបស់នាងវិសាខា អ្នកមានទ្រព្យដ៏ច្រើន មានភោគៈដ៏ច្រើន បានឲ្យទ្រព្យសម្រាប់ចិញ្ចឹមជីវិតដោយសប្បាយដល់នាង តែក្នុងអត្តភាពមួយប៉ុណ្ណោះ ក៏ធម្មតាមាតាបិតានឹងអាចឲ្យសិរី គឺ ភាពជាស្ដេចចក្រពត្តិក្នុងទ្វីបទាំងបួនដល់

បុត្រទាំងឡាយបាន នឹងចាំបាច់ពោលថ្វី (ដល់មាតាបិតាអ្នកដែលអាចឲ្យ) ទិព្វសម្បត្តិ ឬសម្បត្តិមានបឋមឈានជាដើម (និងមានអំពីណា) ក្នុងការឲ្យលោកុត្តរសម្បត្តិ ក៏មិនចាំបាច់ពោលដល់ឡើយ ។ តែថា ចិត្តនេះ ដែលតាំងទុកត្រូវហើយ រមែងអាចឲ្យសម្បត្តិសូម្បីទាំងអស់បាន ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **គប្បីធ្វើបុគ្គលឲ្យប្រសើរជាងនោះ** ។

ក្នុងកាលចប់ទេសនា ជនដ៏ច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

ចប់ រឿងព្រះសោរេយ្យត្ថេរ:

## ចប់ចិត្តវគ្គវណ្ណនា វគ្គទី ៣

ក្នុងវគ្គនេះរួមមាន ០៩ រឿង


១. រឿងព្រះមេឃិយត្ថេរ
២. រឿងភិក្ខុមួយរូប
៣. រឿងឧក្កណ្ឋិតភិក្ខុ
៤. រឿងព្រះភាគិនេយ្យសង្ឃរក្ខិតៈ
៥. រឿងព្រះចិត្តហត្ថត្ថេរ:
៦. រឿងភិក្ខុអ្នកច្រារព្វវិបស្សនា
៧. រឿងព្រះបូតិគត្តតិស្សត្ថេរ:
៨. រឿងនន្ទគោបាលកៈ
៩. រឿងព្រះសោរេយ្យត្ថេរ:


ចប់អដ្ឋកថាខុទ្ទកនិកាយ បឋមភាគ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត .............................. $ 2.000 USA

-ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ
$ 200 USA

-ឧបាសិកា តាំង ស៊ីថា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-កុមារី តាំង សុមាវតី .............................. $ 100 USA

-ឧបាសិកា វ៉ូច លាង ព្រមទាំងបុត្ត .............................. $ 100 AUS


ព្រះរាជាណាចក្រកម្ពុជា